SUTTAPITAKE
KHUDDAKANIKĀYE

KHMER
Volume II

15TH INTERNATIONAL TIPITAKA
CHANTING CEREMONY
BODHGAYA, INDIA

Dhammagiri Pāli Ganthamālā

Khuddakanikāye

Khmer

Sections: Cūḷaniddesapāḷi

Suttapitake Khuddakanikāya
The Pali Text of Chaṭṭha Saṅgāyanā in Khmer Script
Suttapitake Khuddakanikāya

Printed for free distribution by
The Corporate Body of the Buddha Educational Foundation
11F, No. 55, Sec. 1, Hang Chow South Road, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
This book is strictly for free distribution, it is not to be sold.

សម្រាប់ចែកជាធម្មទាន

Printed in Taiwan

DEDICATION

Homage to the Buddha, Dharma, and Sangha!

Here under the sacred Bodhi Tree, where Bhagavan Buddha Shakyamuni brought the blessings of Enlightenment into our world, the Mahasangha from eleven countries has assembled once again to recite the Tipitaka. The teachings we commemorate here were spoken to the Sangha at various places in India. They were affirmed by five hundred Arhats who assembled at the Satipattana cave in Rajgir a year after the Blessed One passed into Parinirvana. Led by Mahakassapa, Ananda, and Upali, the noble Arhats, empowered with full recall of all they had heard, recited the teachings and confirmed them as the true words of the Tathagata.

Since this first great council, the Sangha has kept alive the memory of the Buddha's presence and faithfully transmitted the Four Noble Truths and the Eightfold Path in all directions. From their dedication, four major traditions took form and gave rise to eighteen schools. While they emphasized different aspects of the teachings, all relied on the Three Jewels

as the only refuge from the ever-present miseries of Sarvam Dukkam.

Transcending discrimination based on caste and culture, the teachings won the support of the Chakravartin King Ashoka, who recognized the importance of the Dharma and sponsored its transmission throughout his vast empire and beyond, to Sri Lanka and Myanmar, to Kashmir, to lands beyond the Indus, and to Kashgar and Khotan. Through acts of faith and through edicts and inscriptions, Ashoka encouraged people of all regions to awaken faith in the Buddha, cultivate virtue, and practice the Eightfold Path.

For centuries, even as empires flourished and passed away, the Dharma continued to unfold its blessings in land after land. In China, Tibet, and Mongolia; in Korea and Japan, and in all parts of Southeast Asia, the grace and balance inspired by virtuous action manifested in the shapes of temples and stupas, in images of the Enlightened Ones, and in depictions of the Buddha's great actions in this and previous lives. Through the devotion and dedication of countless great beings that transmitted the Dharma across the earth, this Aryadesha is renowned as the spiritual heart of our world. To this day, the pulse of enlightenment still beats within this sacred ground.

We are fortunate that of all the early Dharma traditions, the living lineages of two schools remain: Sarvastivadin, within the Vinaya of the Mahayana traditions, and Theravadin, vital today in the Sanghas of Bangladesh, Cambodia, Indonesia, India, Laos PDR, Myanmar, Nepal, Sri Lanka, Thailand and Vietnam. It has long been my dream that these streams of Sangha would return to Bodh Gaya after an absence of seven hundred years, to bear witness to the Buddha's message of harmony and peace.

Since 2006, the Light of Buddhadharma Foundation International has acted as the primary sponsor of this gathering of the Theravadin Sanghas. Now, in our 15th anniversary, we congratulate all the great Venerable masters and their lay devotees for their exemplary commitment to spreading the Dharma teachings to many parts of the world. We would also like to congratulate the International Mahasangha for organising this ceremony along with the International Tipitaka Chanting Council. We are also grateful to the Bodhgaya Temple Management Committee and the Government of Bihar for their gracious assistance in facilitating this auspicious gathering. These ceremonies are a great symbol of World Peace and help to free us from the bondage of karma and klesha. We have 25 more years to complete the entire 84000 teachings in Pali under the Sacred Bodhi Tree.

We are also grateful to the Corporate Body of the Buddha Education Foundation in Taiwan for printing this volume as a free gift to all lay devotees. Such noble actions are indeed a great cause for all of us to rejoice especially in recognizing their generosity to share the teachings for the benefit of all.

In this chaotic, materialistic world, ruled by self-interest and greed, people everywhere can benefit from prayers that wish all beings freedom from suffering and freedom from thoughts and actions that lead to suffering for self and others. Joined together in this most sacred place, the voices of many cultures can resound as one, reciting Lord Buddha's words that support health and tranquility, easing the force of desire and aggression and promoting harmony and balance in these stressful times of rapid change. Everywhere, people who become disheartened or disillusioned can look for inspiration to the Bodhi Tree and the Mahabodhi Temple, our shining stars that illuminate the way to peace and harmony. It is our great good fortune that we, as humble laypersons, have been granted the honor of supporting these historic assemblies. They manifest the blessings of the Dharma and fill us with hope that the merit generated here will encourage the awakening of more enlightened beings for the benefit of the earth, the

environment, and people everywhere. In these turbulent times, they remind us that there is no need to continue wandering, lost in this samsaric realm. Help is close at hand; the teachings that can awaken us are still here, and we who understand their value must not let them pass away. It is our duty to support the Sangha and keep these teachings alive through our practice and devotion. We pray that we may continue to support these ceremonies as they carry significant blessings for the world.

I am grateful to the leaders of the Sangha for allowing me this opportunity to commemorate the Lord Buddha and honor the beauty of his heritage. I thank my daughter Kunzang Wangmo Dixey and her team, who has coordinated these assemblies over the last fourteen years. May the offering of this year's printed volume of the Khuddakanikāya be received with the great wish that these precious teachings continue to be recited by the Mahasangha for the benefit of all beings. May the sound of the Buddavaccana be loud and heard throughout all realms!

Sarvam Mangalam

Tarthang-pa Kunga Gellek Yeshe Dorje

Tarthang Rinpoche

Founder of the Bodh Gaya Monlam Chenmo,

World Peace Ceremony

Founder, Light of Buddhadharma Foundation International

June 2019

www.lbdfi.org

Note on Pronunciation of Pāli

Pāli was a spoken language of northern India in the time of Gotama the Buddha. It was written in the Brāhmi script in India in the time of Emperor Asoka and has been preserved in the scripts of the various countries where the language has been maintained. In Roman script, the following set of diacritical marks is used to indicate the proper pronunciation.

The alphabet consists of forty-one characters: eight vowels, thirty-two consonants and one nasal sound (niggahita).

Vowels: a, ā, i, ī, u, ū, e, o

Consonants:

Velar: k, kh, g, gh, ṅ

Palatal: c, ch, j, jh, ñ

Retroflex: ṭ, ṭh, ḍ, ḍh, ṇ

Dental: t, th, d, dh, n

Labial: p, ph, b, bh, m

Miscellaneous: y, r, l, v, s, h, ḷ

Nasal sound (niggahita): ṃ

The vowels a, i, u are short; ā, ī, ū are long; e and o are pronounced short before double consonants: mettā, khetta, koṭṭha, sotthi; and long before single consonants: deva, senā, loka, odana.

a is pronounced like ‘a’ in ‘about’;
ā like ‘a’ in ‘father’;
i is pronounced like ‘i’ in ‘mint’;
ī like ‘ee’ in ‘see’;
u is pronounced like ‘u’ in ‘put’;
ū like ‘oo’ in ‘cool’

Consonants are pronounced mostly as in English. The consonant c is pronounced as ‘ch’ in ‘church’. All the aspirated consonants are pronounced with an audible expulsion of breath following the normal unaspirated sound. Therefore th is not as in ‘three’ but more like the sound in ‘Thailand’, and ph is not as in ‘photo’ but rather is pronounced ‘p’ accompanied by an expulsion of breath.

The retroflex consonants, ṭ, ṭh, ḍ, ḍh, ṇ are pronounced with the tip of the tongue turned back; whereas in the dental consonants, t, th, d, dh, n it touches the upper front teeth.

The palatal nasal, ñ, is the same as the Spanish ‘ñ’, as in ‘señor’. The velar nasal, ṅ, is pronounced like ‘ng’ in ‘singer’ but occurs only with the other consonants in its group: ṅk, ṅkh, ṅg, ṅgh. The pronunciation of ṃ is similar to ṅ but occurs most commonly as a terminal nasalization: ‘evaṃ me sutaṃ’. The Pāli v is a soft ‘v’ or ‘w’ and ḷ produced with the tongue retroflexed, is almost a combined ‘rl’ sound.

Double consonants are very frequent in Pāli and must be strictly pronounced as long consonants, thus nn is like the English ‘nn’ in ‘unnecessary’.

ព្រះ
ត្រៃបិដកបាលី
និង
សេចក្តីប្រៀបភាសាខ្មែរ
សុត្តន្តបិដក
ខុទ្ទកនិកាយ ចុទ្ធសិទ្ធេស
បឋមភាគ
៦៧

ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឆរាជាធិបតី ហ្ស ក្ងី
សម្តេចព្រះមហាសង្ឆរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា

ព. ស. ២៥៥៣

SUTTANTAPIṬAKA

KHUDDAKANIKĀYA

CŪḶANIDDESA

PAṬHAMABHĀGA

67

សម្តេចព្រះអតិសីរីសុគន្ធាមហាសង្ឆរាជាធិបតី ប៊ូ ត្រី
សម្តេចព្រះមហាសង្ឆរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈ ក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឆបូជា ។

សូមសេចក្ដីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្ដីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបឋុមធ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

ប៊ូ-ត្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

Printed for free distribution by
The Corporate Body of the Buddha Educational Foundation
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
This book is strictly for free distribution, it is not to be sold.
សម្រាប់ចែកជាធម្មទាន

សេចក្ដីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរ: **សម្ល** *ក្នុងពាក្យនេះ ព្យញ្ជនៈ* **ល** *គឺជាជើងរបស់ព្យញ្ជនៈ* **ម** *ដូច្នេះពាក្យនេះគឺ* **សម្ល** *។*

-ពាក្យបាលី: **ត**ស្ស **ត**ស្ស *គឺ* **ត**ស្ស *។*

*២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឆរាជជោតញ្ញាណ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។*

៣) ចំពោះ **សន្ធឹកច្រាប់ពាក្យ**ខុ**ស-ត្រូ** វ *ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។*

សុត្តន្តបិដក

ខុទ្ទកនិកាយ ចូឡនិទ្ទេស

បឋមភាគ

៦៧

៣. ស. ២៥០៤

សុត្តន្តបិដកេ

ខុទ្ទកនិកាយស្ស ចូឡនិទ្ទេសោ

បឋមោ ភាគោ

ឧមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

បារាយនវគ្គោ

វត្ថុគាថា

[១] តោសលានំ បុរា រម្ម អតមា ឧក្ខិណាបមំ
អាកិញ្ចញ្ញំ បត្ថយានោ ព្រាហ្មណោ មន្ត្តចារកូ ។

[២] សោ អស្សកស្ស វិសយេ មុឡ្ហកស្ស[1] សមាសនេ
វសី តោជារីកូលេ ឧញ្ជេន ច ផលេន ច ។

[៣] តស្ស្ជ ឧបនិស្ជាយ តាមោ ច វិបុលោ អហុ
តតោ ជាតេន អាយេន មហាយញ្ញំ អកប្ជយិ ។

[៤] មហាយញ្ញំ យជិត្ជាន បុន ចារិសិ អស្ជមំ
តស្មឹ បដិបវិដ្ឋម្ហិ អញ្ញោ អាគញ្ជិ ព្រាហ្មណោ ។

---

១ ម. មឡ្ហកស្ស ។

សុត្តន្តបិដក

ខុទ្ទកនិកាយ ចូឡនិទ្ទេស

បឋមភាគ

សូមនមស្ការ ចំពោះព្រះអរហន្ត សម្មាសម្ពុទ្ធព្រះអង្គនោះ ។

បារាយនវគ្គ

វត្ថុគាថា

[១] *ពាវរីព្រាហ្មណ៍ អ្នកដល់ត្រើយនៃមន្ត ប្រាជ្ញាសេចក្តីមិនមានកង្វល់ ចេញចាកបុរីជាទីរីករាយ នៃពួកអ្នកដែនកោសល ទៅកាន់ទក្ខិណាបថជនបទ ។*

[២] *គាត់អាស្រ័យនៅ ទៀបច្រាំងស្ទឹងគោធាវរី ក្នុងទីព្រំដែនអស្សក: និងមុឡក: (ចិញ្ចឹមជីវិត) ដោយការស្វែងរកមើមនិងផលាផល ។*

[៣] *ស្រុកអាស្រ័យជិតស្ទឹងគោធាវរីនោះ ជាស្រុកសម្បូរ ព្រាហ្មណ៍ក៏បានបរិច្ចាគមហាយ័ញ្ញ ដោយសួយ ដែលកើតអំពីស្រុកនោះ ។*

[៤] *លុះពាវរីព្រាហ្មណ៍ បរិច្ចាគមហាយ័ញ្ញរួចហើយ ក៏ចូលមកកាន់អាស្រមវិញ កាលគាត់ត្រឡប់ចូលមកហើយ ព្រាហ្មណ៍ដទៃ បានមកដល់ដែរ ។*

[៥] ឧគ្ឃដ្ដបាទោ តសិតោ បង្កទន្តោ រជស្សិរោ
សោ ច នំ ឧបសង្កម្ម សតានិ បញ្ច យាចតិ ។

[៦] តមេនំ ពាវរី ទិស្វា អាសនេន និមន្តយិ
សុខញ្ច កុសលំ បុច្ឆិ ឥទំ វចនមព្រវិ ។

[៧] យំ ខោ មមំ ទេយ្យធម្មំ សព្វំ វិសជ្ជិតំ មយា
អនុជានាហិ មេ ព្រហ្មេ នត្ថិ បញ្ច សតានិ មេ ។

[៨] សចេ មេ យាចមានស្ស ភវំ នានុប្បទស្សតិ
សត្តមេ ទិវសេ តុយ្ហំ មុទ្ធា ផលតុ សត្តធា ។

[៩] អភិសង្ខរិត្វា កុហកោ ភេរវំ សោ អកិត្តយិ
តស្ស តំ វចនំ សុត្វា ពាវរី ទុក្ខិតោ អហុ ។

[១០] ឧស្សុស្សតិ អនាហារោ សោកសល្លសមប្បិតោ
អថោបិ ឯវំ ចិត្តស្ស ឈានេ ន[១] រមតី មនោ ។

---

១ ឱ. ម. ឈានេ ។

[៥] ព្រាហ្មណ៍នោះ មានជើងធ្ងន់ ស្ងួតសស្ងើត មានធ្មេញព័ណ៌ក្រហម ក្បាលប្រឡាក់ធូលី ចូលមករកពាវរីព្រាហ្មណ៍នោះ ហើយ សូមទ្រព្យ ចំនួន ៥០០ ។

[៦] ពាវរីព្រាហ្មណ៍ លុះឃើញព្រាហ្មណ៍យាចកនោះហើយ ក៏អញ្ជើញ ដោយអាសនៈ ហើយសាកសួរសេចក្តីសប្បាយស្រួល ទើបពោលនូវពាក្យនេះថា

[៧] ទេយ្យធម៌ណា ដែលខ្ញុំគប្បីឲ្យ ទេយ្យធម៌ទាំងអស់នោះ ខ្ញុំបរិច្ចាគអស់រលីងហើយ ម្នាលព្រាហ្មណ៍ អ្នកចូរអនុញ្ញាត ដល់ខ្ញុំផងចុះ ខ្ញុំមិនមានទ្រព្យ ៥០០ ទេ ។

[៨] (ព្រាហ្មណ៍យាចកពោលថា) អ្នកដ៏ចម្រើន កាលបើខ្ញុំសូម ប្រសិនបើ អ្នកដ៏ចម្រើន មិនឲ្យ សូមឲ្យក្បាលអ្នក បែកជា ៧ ភាគ ក្នុងថ្ងៃជាគម្រប់ ៧ ។

[៩] ព្រាហ្មណ៍ អ្នកកុហកនោះ បានកៃងក្ងាយ ពោលពាក្យគួរខ្ជាបពាវរីព្រាហ្មណ៍ បានឮពាក្យនៃព្រាហ្មណ៍នោះហើយ ក៏កើតទុក្ខ ។

[១០] គាត់អត់អាហារ ដោតដោយសរ គឺសោកក្រៀមក្រំ មួយទៀត កាលព្រាហ្មណ៍មានចិត្តយ៉ាងនេះហើយ ចិត្តក៏មិនរីករាយ ក្នុងការលះបង់[១] ។

---

១ បានដល់ចិត្តដែលមិនរីករាយ ក្នុងការចម្រើនឈាន ។ អដ្ឋកថា ។

វត្ថុគាថា

[១១] ឧត្រស្តំ ទុក្ខិតំ ទិស្វា ទេវតា អត្ថកាមិនី
ពាវរឹ ឧបសង្កម្ម ឥទំ វចនមព្រវិ ។

[១២] ន សោ មុទ្ធំ បជានាតិ កុហកោ សោ ធនត្ថិកោ
មុទ្ធនិ មុទ្ធាធិបាតេ វា ញាណំ តស្ស ន វិជ្ជតិ ។

[១៣] បហោតិ(១) ចរហិ ជានាតិ តម្មេ អក្ខាហិ បុច្ឆិតា
មុទ្ធំ មុទ្ធាធិបាតញ្ច តំ សុណោម វចោ តវ ។

[១៤] អហម្បេតំ ន ជានាមិ ញាណម្មេត្ថ ន វិជ្ជតិ
មុទ្ធំ មុទ្ធាធិបាតោ ច(២) ជិនានំ ហេតទស្សនំ(៣) ។

[១៥] អថ កោ ចរហិ ជានាតិ អស្មឹ បថវិមណ្ឌលេ
មុទ្ធំ មុទ្ធាធិបាតញ្ច តម្មេ អក្ខាហិ ទេវតេ ។

[១៦] បុរា កបិលវត្ថុម្ហា និក្ខន្តោ លោកនាយកោ
អបច្ចោ ឱក្កាករាជស្ស សក្យបុត្តោ បភង្ករោ ។

---

១ ឱ. ភោតិ ។ ម. ភោតិ ។ ២ ម. មុទ្ធាធិបាតេ ។ ៣ ម. ជិនានញ្ហេត្ថ ទស្សនំ ។

វត្ថុគាថា

[១១] *ទេវតា អ្នកប្រាជ្ញាប្រយោជន៍ បានឃើញពាវរីព្រាហ្មណ៍ កំពុងមានសេចក្ដីតក់ស្ទុត កើតទុក្ខ ទើបចូលទៅរក ពាវរីព្រាហ្មណ៍ ហើយពោលពាក្យនេះថា*

[១២] *(ព្រាហ្មណ៍នោះ) មិនដឹងប្រាកដនូវអំបែងក្បាល ព្រាហ្មណ៍នោះ ជាអ្នកកុហក ប្រាជ្ញាទ្រព្យ ញាណសម្រាប់ដឹងនូវក្បាល ឬធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ របស់គាត់នោះ មិនមានទេ ។*

[១៣] *(ពាវរីព្រាហ្មណ៍សួរថា) នរណា អាចដឹងនូវក្បាល ដឹងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ខ្ញុំសួរហើយ អ្នកចូរប្រាប់ដំណើរនោះដល់ខ្ញុំ ខ្ញុំនឹងស្ដាប់ពាក្យរបស់អ្នកនោះ ។*

[១៤] *(ទេវតាតបថា) ខ្ញុំក៏មិនដឹងដំណើរនោះដែរ ការដឹងក្នុងដំណើរនុ៎ះ របស់ខ្ញុំមិនមានទេ លុះតែព្រះជិន: ទើបទ្រង់ជ្រាបនូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ។*

[១៥] *(ពាវរីព្រាហ្មណ៍សួរថា) លើប្រឹថពីមណ្ឌលនេះ តើនរណា ទើបដឹងនូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ម្នាលទេវតា អ្នកចូរប្រាប់បុគ្គលអ្នកដឹងនោះ ដល់ខ្ញុំ ។*

[១៦] *(ទេវតាតបថា) ព្រះលោកនាយក ជាពួជពង្សរបស់ព្រះបាទឱក្កាក: ជាសក្យបុត្រ ជាអ្នកធ្វើនូវពន្ធឿ ព្រះអង្គស្ដេចចេញចាកកបិលវត្ថុបុរី (ទ្រង់ព្រះផ្នួស) ។*

[១៧] សោ ហិ ព្រាហ្មណ សម្ពុទ្ធោ សព្វធម្មាន ចារកូ
សព្វាភិញ្ញាពលប្ផត្តោ សព្វធម្មេសុ ចក្ខុមា
សព្វធម្មក្ខយំ បត្តោ វិមុត្តោ ឧបធិក្ខយេ ។
[១៨] ពុទ្ធោ សោ ភគវា លោកេ ធម្មំ ទេសេតិ ចក្ខុមា
តំ ត្វំ ឥជ្ឌាន បុច្ឆស្ស សោ តេ តំ ព្យាការិស្សតិ ។
[១៩] សម្ពុទ្ធោតិ វចោ សុត្វា ឧទគ្គោ ពាវរី អហុ
សោកស្ស ឥជ្ឌតោ អាសិ ឧបាតិញ្ច វិបុលំ លភិ ។
[២០] សោ ពាវរី អត្តមនោ ឧទគ្គោ
តំ ទេវតំ បុច្ឆតិ ឯកជ្ជាតោ
ឥតមម្ហិ តាមេ ឯតមម្ហិ វ បន
ឥតមម្ហិ វ ជនបទេ លោកជ្ជាថោ
យត្ត ឥជ្ឌ ឥមស្ស្ស្ស[1]
សម្ពុទ្ធំ ឯបមុត្តមំ ។
[២១] សាវត្ថិយំ ឥោសលមជ្ជ្ហ ជ្ជ ជ្ជ
ឧបហ្ជ្ជ ឧបញ្ញ ១ ១ ១ ១
ស ១ ១ ១ ១ ១ ១ ១ ១
ស ១ ១ ១ ១ ១ ១ ១ ១
ស ១ ១ ១ ១ ១ ១ ១ ១

---

1 ម. ១ ១ ១ ១ ។

[១៧] ម្នាលព្រាហ្មណ៍ ព្រះលោកនាយកនោះ ជាអ្នកត្រាស់ដឹង ដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ដល់ហើយនូវអភិញ្ញានិងពល:សព្វគ្រប់ ប្រកបដោយសមន្តចក្ខុ ក្នុងធម៌ទាំងពួង ទ្រង់ដល់នូវធម៌ទាំងពួងជាទីអស់កិលេស ទ្រង់ផុតវិសេសហើយ និមិត្តធម៌ជាទីក្សីយនៃឧបធិ ។

[១៨] ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាព្រះពុទ្ធ ក្នុងលោក មានបញ្ញា-ចក្ខុ តែងសម្តែងធម៌ អ្នកចូរទៅក្រាបទូលសួរព្រះសម្ពុទ្ធអង្គនោះចុះ ទ្រង់នឹងព្យាករនូវធម៌នោះ ដល់អ្នក ។

[១៩] ពាវរីព្រាហ្មណ៍ ឮពាក្យថា សម្ពុទ្ធ ដូច្នេះហើយ ក៏មានចិត្តអណ្តែតឡើង មានសោកស្រាល ទាំងបានបីតិដ៏ខ្លាំងក្លា ។

[២០] ពាវរីព្រាហ្មណ៍នោះ មានចិត្តត្រេកអរ មានចិត្តអណ្តែតឡើង មានចិត្តរីករាយ សួរទេវតានោះថា ព្រះលោកនាថ ទ្រង់គង់នៅ ក្នុងស្រុកណា និគមណា ឬក្នុងជនបទណា យើងនឹងទៅនមស្ការព្រះសម្ពុទ្ធដ៏ឧត្តមជាងសត្វជើងពីរនោះក្នុងទីណា ។

[២១] (ទេវតាតបថា) ព្រះជិន: ទ្រង់សម្រេចសម្រាន្តព្រះតរិយាបថ ក្នុងកោសលមន្ទីរ ជិតក្រុងសាវត្ថី ទ្រង់មានបញ្ញាច្រើន មានបញ្ញា ដូចផែនដីដ៏ប្រសើរ ព្រះអង្គជាសក្យបុត្រ ទ្រង់មិនមានធុរ: មិនមានអាសវ: ជាឧត្តមបុរស ប្រសើរជាងជន ជ្រាបច្បាស់នូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ។

វត្ថុគាថា

[២២] តតោ អាមន្តយី សិស្សេ ព្រាហ្មណោ មន្តធារកេ
ឯថ មាណវា អក្ខិស្សំ សុណោថ វចនំ មម ។

[២៣] យស្សេសោ ទុល្លភោ លោកេ ចាតុភាវោ អភិណ្ហសោ
ស្វាជ្ជ លោកម្ហិ ឧប្បន្នោ សម្ពុទ្ធោ ឥតិ វិស្សុតោ
ខិប្បំ គន្ត្វាន សាវត្ថឹ បស្សវ្ហោ ទិបទុត្តមំ ។

[២៤] កថំ ចរហិ ជានេមុ ទិស្វា ពុទ្ធោតិ ព្រាហ្មណ
អជានតំ នោ បព្រូហិ យថា ជានេមុ តំ មយំ ។

[២៥] អាគតានិ ហិ មន្តេសុ មហាបុរិសលក្ខណា
ទ្វត្តឹសា ច ព្យាខ្យាតា(១) សមត្តា អនុបុព្វសោ ។

[២៦] យស្សេតេ ហោន្តិ គត្តេសុ មហាបុរិសលក្ខណា
ទុវេ វ(២) តស្ស គតិយោ តតិយា ហិ ន វិជ្ជតិ ។

---

១ ឱ. ម. ព្យាក្ខាតា ។ ២ ឱ. ម. ទ្វេយេវ ។

វត្ថុគាថា

[២២] លំដាប់នោះ ពាវរីព្រាហ្មណ៍ ហៅពួកព្រាហ្មណ៍ជាសិស្ស អ្នកដល់នូវត្រើយនៃមន្ត ថា ម្នាលមាណពទាំងឡាយ អ្នកទាំងឡាយ ចូរមក យើងនឹងប្រាប់ អ្នកទាំងឡាយ ចូរស្តាប់ពាក្យរបស់យើង ។

[២៣]ការកើតប្រាកដរឿយៗ ក្នុងលោក នៃព្រះសម្ពុទ្ធអង្គណា ដែលរកកម្របាន ថ្ងៃនេះ ព្រះសម្ពុទ្ធជាម្ចាស់អង្គនោះ ទ្រង់កើតហើយ ក្នុងលោក គេដឹងឮល្បីល្បាញប្រាកដថា ព្រះអង្គត្រាស់ដឹងឯង អ្នកទាំងឡាយ ចូរប្រញាប់ទៅកាន់ក្រុងសាវត្ថី គាល់ព្រះអង្គ ទ្រង់ឧត្តមជាងសត្វជើងពីរនោះ ។

[២៤] (ព្រាហ្មណ៍ជាសិស្សច្បងសួរថា) បពិត្រព្រាហ្មណ៍ ធ្វើម្តេចយើងទាំងឡាយ ឃើញហើយ ទើបស្គាល់ថាជាព្រះពុទ្ធ សូមលោកប្រាប់ឧបាយ ជាហេតុឲ្យយើងស្គាល់ នូវព្រះសម្ពុទ្ធនោះ ដល់យើងទាំងឡាយ ដែលមិនធ្លាប់ស្គាល់ ។

[២៥] (ពាវរីព្រាហ្មណ៍តបថា) មហាបុរិសលក្ខណៈទាំងឡាយ ៣២ ប្រការ មានមកក្នុងមន្តទាំងឡាយ (ដែលពួកព្រាហ្មណាចារ្យ) ព្យាករគ្រប់គ្រាន់ហើយ តាមលំដាប់ ។

[២៦] មហាបុរិសលក្ខណៈទាំងនុ៎ះ រមែងមានក្នុងកាយរបស់មហាបុរសណា មហាបុរសនោះ មានគតិទៀងតែ ២ មិនមានគតិទៅជាគម្រប់បីទេ ។

[២៧] សចេ អគារំ អាវសតិ វិជេយ្យ បឋវឹ ឥមំ
អទណ្ឌេន អសត្ថេន ធម្មេនមនុសាសតិ ។
[២៨] សចេ ច សោ បព្វជតិ អគារា អនគារិយំ ។
វិវដច្ឆទោ សម្ពុទ្ធោ អរហា ភវតិ អនុត្តរោ ។
[២៩] ជាតឹ គោត្តញ្ច លក្ខណំ មន្តេ សិស្សេ បុនាបរេ
មុទ្ធំ មុទ្ធាធិបាតញ្ច មនសាយេវ បុច្ឆថ ។
[៣០] អនាវរណទស្សាវី យទិ ពុទ្ធោ ភវិស្សតិ
មនសា បុច្ឆិតេ បញ្ហេ វាចាយ វិសជ្ជេស្សតិ ។
[៣១] ពាវរិស្ស វចោ សុត្វា សិស្សា សោឡស ព្រាហ្មណា
អជិតោ តិស្សមេត្តេយ្យោ បុណ្ណកោ អថ មេត្តគូ
ធោតកោ ឧបសីវោ ច នន្ទោ ច អថ ហេមកោ
តោទេយ្យកប្បា ឧភយោ ជតុកណ្ណី ច បណ្ឌិតោ
ភទ្រាវុធោ ឧទយោ ច បោសាលោ ចាបិ ព្រាហ្មណោ
មោឃរាជា ច មេធាវី បិង្គិយោ ច មហាឥសិ ។

[២៧] *បើមហាបុរសនោះ នៅគ្រប់គ្រងផ្ទះ គប្បីឈ្នះប្រឹថពីមណ្ឌលនេះ ដោយមិនមានប្រើអាជ្ញា សស្ត្រាវុធ ទាំងគ្រប់គ្រងតាមច្បាប់ ។*

[២៨] *ប្រសិនបើ មហាបុរសនោះ (ចេញ) ចាកផ្ទះហើយ បួសក្នុងកេទនៃបុគ្គលមិនមានផ្ទះ នឹងបានជាព្រះពុទ្ធ មានដំបូលគឺកិលេសបើកហើយ ជាអរហន្ត ឥតមានបុគ្គលដទៃប្រសើរដូច ។*

[២៩] *អ្នកទាំងឡាយ ចូរសួរនូវជាតិ គោត្ត លក្ខណៈ មន្ត និងសិស្សទាំងឡាយដទៃទៀតផង នូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះផង ដោយចិត្តតែម្យ៉ាង ។*

[៣០] *ប្រសិនបើ ព្រះអង្គជាព្រះពុទ្ធ មានកិរិយាឃើញ ឥតមានអ្វីទើសទាល់ កាលបើអ្នកទាំងឡាយ សួរប្រស្នា ដោយចិត្តហើយ ទ្រង់នឹងវិសជ្ជនា ដោយវាចា ។*

[៣១] *លុះស្តាប់ពាក្យពារីព្រាហ្មណ៍ហើយ ព្រាហ្មណ៍ជាសិស្ស ១៦ នាក់គឺ អជិតៈ ១ តិស្សមេត្តេយ្យៈ ១ បុណ្ណកៈ ១ មេត្តគូ ១ ធោតកៈ ១ ឧបសីវៈ ១ នន្ទៈ ១ ហេមកៈ ១ តោទេយ្យៈ ១ កប្បៈ ១ ជតុកណ្ណីបណ្ឌិត ១ ភទ្រាវុធ ១ ឧទយៈ ១ ពោសាលព្រាហ្មណ៍ ១ មោឃរាជមេធាវី ១ បិង្គិយមហាឫសី ១ ។*

៧

វត្ថុគាថា

[៣២] បច្ចេកគណិនោ សព្វេ សព្វលោកស្ស វិស្សុតា
ឈាយី ឈានរតា ធីរា បុព្វវាសនវាសិតា ។

[៣៣] ពាវរី អភិវាទេត្វា កត្វា ច នំ បទក្ខិណំ
ជដាជិនធរា សព្វេ បក្កាមុំ ឧត្តរាមុខា ។

[៣៤] មុឡ្ហកស្ស បតិដ្ឋានំ បុរិមំ[១] មាហិស្សតឹ តទា
ឧជ្ជេនិញ្ចាបិ គោនទ្ធំ វេទិសំ វនសវ្ហយំ
កោសម្ពិញ្ចាបិ សាកេតំ សាវត្ថិញ្ច បុរុត្តមំ
សេតព្យំ កបិលវត្ថុំ កុសិនារញ្ច មន្ទិរំ
បាវញ្ច ភោគនគរំ វេសាលឹ មាគធំ បុរំ
បាសាណកំ ចេតិយញ្ច រមណីយំ មនោរមំ ។

[៣៥] តសិតោ វុទកំ សីតំ មហាលាភំវ វាណិជោ
ឆាយំ ឃម្មាភិតត្តោវ តុរិតា បព្វតមារុហុំ

[៣៦] ភគវា ច តម្ហិ សមយេ ភិក្ខុសង្ឃបុរក្ខតោ
ភិក្ខូនំ ធម្មំ ទេសេតិ សីហោវ នទតី វនេ ។

---

១ បុរន្តិ បាឋោ ទិស្សតិ អដ្ឋកថាយំ ។

វត្ថុគាថា

[៣២] អ្នកទាំងអស់គ្នា ជាគណាចារ្យមួយៗ ល្បីទូទៅពេញលោកថា ជាអ្នកមានឈាន ត្រេកអរក្នុងឈាន ជាអ្នកប្រាជ្ញ សឹងមានវាសនា អប់រំមកហើយ ក្នុងបុព្វជាតិ ។

[៣៣] (ព្រាហ្មណ៍ទាំងនោះ) ក៏ក្រាបអភិវាទ ធ្វើប្រទក្សិណ នូវពារ៉ី-ព្រាហ្មណ៍នោះ ទាំងអស់គ្នា ជាអ្នកមានជដា ទ្រទ្រង់អជិនចម្ម-ករណ: មានមុខឆ្ពោះទៅកាន់ឧត្តរទិស ដើរចេញទៅ ។

[៣៤]ក្នុងកាលនោះ តាបសទាំងនោះ ទៅកាន់ក្រុងឈ្មោះ មហិស្សតី ជាទីប្រតិស្ឋាននៃដែនមុឡក: ១ ក្រុងឧជ្ជេនី ១ ក្រុងគោនទ្ធ: ១ ព្រៃវេទិស: ១ ក្រុងកោសម្ពី ១ ក្រុងសាកេត ១ ក្រុងសាវត្ថីដ៏ឧត្តម ១ ក្រុងសេតព្យ: ១ ក្រុងកបិលវត្ថុ ១ ក្រុងកុសិនារា ១ ក្រុងបាវា ១ ភោគនគរ ១ ក្រុងវេសាលី ១ ក្រុងក្នុងដែនមគធ: ១ និងបាសាណ-កចេតិយស្ថាន ជាទីត្រេកអរ រីករាយចិត្ត ១ ។

[៣៥] (ពួកព្រាហ្មណ៍ទាំងនោះ) នាំគ្នាឡើងកាន់ភ្នំ ប្រញាប់ប្រញាល់ ដូចជាបុគ្គលស្រេក បានទឹកត្រជាក់ ដូចជាពាណិជ បានលាភធំ ឬ ដូចជាបុគ្គលដែលត្រូវក្តៅ បានម្ទប់ ។

[៣៦] សម័យនោះ ព្រះមានព្រះភាគ មានភិក្ខុសង្ឆ្យចោមរោម កំពុងសម្តែងធម៌ដល់ពួកភិក្ខុ ដូចសីហ:កំពុងបន្ទឹ ក្នុងព្រៃ ។

[៣៧] អជិតោ អទ្ទស សម្ពុទ្ធំ វីតរំសឹវ ភាណុមំ
ចន្ទំ យថា បណ្ណរសេ បារិបូរឹ ឧបាគតំ ។

[៣៨] អថស្ស គត្តេ ទិស្វាន បរិបូរញ្ច ព្យញ្ជនំ
ឯកមន្តំ ឋិតោ ហដ្ឋោ មនោបញ្ហេ អបុច្ឆថ

[៣៩] អាទិស្ស ជម្មនំ ព្រូហិ គោត្តំ ព្រូហិ សលក្ខណំ
មន្តេសុ បារមឹ ព្រូហិ កតិ វាចេតិ ព្រាហ្មណោ ។

[៤០] វីសំ វស្សសតំ អាយុ សោ ច គោត្តេន ពាវរី
តិណស្ស លក្ខណាគត្តេ តិណ្ណំ វេទាន បារគូ

[៤១] លក្ខណេ ឥតិហាសេ ច សនិឃណ្ឌុ សកេដុភេ
បញ្ចសតានិ វាចេតិ សធម្មេ បារមឹ គតោ ។

[៤២] លក្ខណានំ បវិចយំ ពាវរិស្ស នរុត្តម
តណ្ហាច្ឆិទ[១] បកាសេហិ មា នោ កង្ខាយិតំ អហុ ។

---

១ ម. តណ្ហាច្ឆិទំ ។

[៣៧] អជិតមាណព បានឃើញព្រះសម្ពុទ្ធ ហាក់ដូចព្រះអាទិត្យកំពុងផ្សាយចេញនូវរស្មី ពុំនោះសោត ដូចព្រះចន្ទពេញវង់ រះឡើងក្នុងថ្ងៃពេញបូណ៌មី ។

[៣៨] លុះអជិតមាណព ឃើញព្រះកាយ របស់ព្រះសម្ពុទ្ធ ដ៏បរិបូណ៌ដោយព្យញ្ជនៈ ក៏មានចិត្តរីករាយ ឋិតនៅក្នុងទីសមគួរ ហើយសួរបញ្ហា ដោយចិត្តនឹកថា

[៣៩] សូមព្រះអង្គ ទ្រង់សម្តែងអាង នូវចំណាស់ សម្តែងនូវគោត្ត ព្រមទាំងលក្ខណៈ សម្តែងនូវសេចក្តីសម្រេច ក្នុងមន្តទាំងឡាយ តើព្រាហ្មណ៌ (ជាអាចារ្យរបស់ខ្ញុំព្រះអង្គ) បង្រៀនសិស្សប៉ុន្មាន ។

[៤០] (ព្រះមានព្រះភាគត្រាស់ថា) ព្រាហ្មណ៌ ជាអាចារ្យរបស់អ្នកនោះ ឈ្មោះពាវរី ដោយគោត្ត មានអាយុ ១២០ វស្សា កាយរបស់គាត់មានលក្ខណៈ ៣ យ៉ាង អ្នកដល់នូវត្រើយនៃវេទទាំងបី ។

[៤១] គាត់បង្រៀនលក្ខណៈ និងឥតិហាសសាស្ត្រ ព្រមទាំងនិឃណ្ឌុ-សាស្ត្រ និងកេដុភសាស្ត្រ ដល់សិស្ស ៥០០ នាក់ ដល់នូវការសម្រេច ក្នុងធម៌របស់ខ្លួន ។

[៤២] (អជិតមាណពទូលសួរថា) បពិត្រព្រះអង្គឧត្តមជាងជន ជាអ្នកផ្តាច់បង់នូវតណ្ហា សូមព្រះអង្គ ជ្រើសរើសលក្ខណៈទាំងឡាយ របស់ពាវរីព្រាហ្មណ៌ហើយប្រកាស កុំឲ្យយើងខ្ញុំសង្ស័យឡើយ ។

វត្ថុគាថា

[៤៣] មុទ្ធំ ជិវ្ហាយ ឆាទេតិ ឧណ្ណាសេ្ច ភមុកន្តរេ
តោសោ ហិតំ វត្ថុកុយ្ហំ ឯវំ ជានាហិ មាណវ ។

[៤៤] បុច្ឆំ ហិ ភញ្ជិ អសុណាន្តោ សុត្វា បញ្ហេ វិយាកតេ
វិចិន្តេតិ ជនោ សព្ពោ ទេវជានោ ភតញ្ជលិ

[៤៥] ភោ ឧ ទេវោ ព្រហ្មា វ ឥន្ទោ វាបិ សុជម្ផតិ
មនសា បុច្ឆិតេ បញ្ហេ ភគវេ បជិភាសតិ ។

[៤៦] មុទ្ធំ មុទ្ធាធិចាតញ្ច ពាវរី បរិបុច្ឆតិ
តំ ព្យាករោហិ ភគវា ភគ្ចំ ជិនយ ជោ ឥសេ ។

[៤៧] អវិជ្ជា មុទ្ធាតិ ជានាហិ វិជ្ជា មុទ្ធាធិចាតិនី
សទ្ធាសតិសមាធីហិ ឆន្ទវីរិយេន សំយុតា ។

[៤៨] ឥតោ ជេនេ មហាតា សន្ត្ថិ ត្ថាន មាណវោ
ឯកំសំ អជ្ជិនំ ភគ្ចា ចាទេសុ សិរសា បតិ

វត្ថុគាថា

[៤៣](ព្រះមានព្រះភាគត្រាស់ថា) ពាវរីព្រាហ្មណ៍បិទបាំងមុខ ដោយជិវ្ហាបាន មានឧណ្ណាលោម ត្រង់ចន្លោះចិញ្ចើម មានវត្ថុគុយ្ហៈនៅក្នុងស្រោម ម្នាលមាណព អ្នកចូរដឹងយ៉ាងនេះចុះ ។

[៤៤] ពួកជនទាំងពួង មិនឮនូវការសួរនីមួយសោះ លុះឮបញ្ហាដែលព្រះមានព្រះភាគព្យាករហើយ ក៏កើតសេចក្ដីរីករាយ ប្រណម្យអញ្ជលី គិតផ្សេងៗថា

[៤៥] នរណាហ្ន៎ ជាទេវតា ឬជាព្រហ្ម ឬជាព្រះឥន្ទ្រឈ្មោះសុជម្បតិ កាលបើគេសួរប្រស្នាដោយចិត្ត ម្ដេចក៏ទ្រង់ឆ្លើយតបប្រស្នានោះបាន ។

[៤៦] (អជិតមាណព ទូលសួរដោយចិត្តតទៅទៀតថា) បពិត្រព្រះមានព្រះភាគ ពាវរីព្រាហ្មណ៍សួរនូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ សូមព្រះអង្គព្យាករប្រស្នានោះ បពិត្រព្រះអង្គជាឥសី សូមព្រះអង្គកម្ចាត់បង់នូវកង្ខារបស់យើងទាំងឡាយ ។

[៤៧](ព្រះមានព្រះភាគត្រាស់ថា) អ្នកចូរដឹងថា អវិជ្ជា ជាក្បាល វិជ្ជាដែលប្រកបដោយ សទ្ធា សតិ សមាធិ ឆន្ទៈ វីរិយៈ ជាធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ។

[៤៨] លំដាប់នោះ (អជិតមាណព) មានបីតិ មានកម្លាំងក្លាខ្លាំងកើតហើយ ទើបធ្វើអជិនចម្មាភរណៈ ឆៀងស្មាម្ខាង ក្រាបទៀបព្រះបាទដោយសិរសា ទូលថា

[៤៩] ពាវរី ព្រាហ្មណោ ភោតោ សហ សិស្សេហិ មារិស
ឧទគ្គចិត្តោ សុមនោ ចាទេ វន្ទតិ ចក្ខុម ។

[៥០] សុខិតោ ពាវរី ហោតុ សហ សិស្សេហិ ព្រាហ្មណោ
ត្វញ្ចាបិ សុខិតោ ហោហិ ចិរំ ជីវាហិ មាណវ ។

[៥១] ពាវរិស្ស ច តុយ្ហំ វា សព្វេសំ សព្វសំសយំ
កតាវកាសា បុច្ឆវ្ហោ យង្កិញ្ចិ មនសិច្ឆថ ។

[៥២] សម្ពុទ្ធេន កតោកាសោ និសីទិត្វាន បញ្ជលិ
អជិតោ បឋមំ បញ្ហំ តត្ថ បុច្ឆិ តថាគតំ ។

វត្ថុគាថា និដ្ឋិតា ។

[៤៩] *បពិត្រព្រះអង្គទ្រង់និរទុក្ខមានចក្ខុ ពាវរីព្រាហ្មណ៍ ព្រមទាំងពួកសិស្ស មានចិត្តរីករាយសោមនស្ស ថ្វាយបង្គំព្រះបាទ នៃព្រះអង្គដ៏ចម្រើន ។*

[៥០] *(ព្រះមានព្រះភាគ ត្រាស់តបថា) ពាវរីព្រាហ្មណ៍ ព្រមទាំងពួកសិស្ស ចូរបានសុខ ម្នាលមាណព ទាំងអ្នកក៏ចូរបានសុខ ចូរមានជន្មាយុយឺនយូរ ។*

[៥១] *អ្នកទាំងឡាយ តថាគតបើកឱកាសឲ្យហើយ ប្រាជ្ញាក្នុងចិត្ត (ដើម្បីសួរ) នូវប្រស្នាណាមួយ ចូរសួរមកចុះ ដើម្បីកម្ចាត់បង់សេចក្តីសង្ស័យគ្រប់ប្រការ របស់ពាវរីព្រាហ្មណ៍ផង របស់អ្នកផង ទាំងអស់គ្នា ។*

[៥២] *អជិតមាណព ដែលព្រះសម្ពុទ្ធទ្រង់បើកឱកាសឲ្យហើយ ក៏អង្គុយប្រណម្យអញ្ជលី សួរប្រស្នាជាបឋម ចំពោះព្រះតថាគត ក្នុងបាសាណកចេតិយនោះ ។*

ចប់ រតនគាថា ។

អជិតមាណវកប្បញ្ហានិទ្ទេសោ

[៤៣] កេនស្សុ និវុតោ លោកោ (ឥច្ចាយស្មា អជិតោ)
កេនស្សុ ឧប្ផ្លាសតិ
កិស្មាភិលេបនំ ព្រូហិ[1]
កីសុ ឥស្ស មហាភ្ភយំ ។

[៤៤] កេនស្សុ[2] និវុតោ លោកោតិ និរយ-លោកោ តិរច្ឆានលោកោ បិត្តិវិសយលោកោ មនុស្សលោកោ ទេវលោកោ ខន្ធលោកោ ធាតុ-លោកោ អាយតនលោកោ អយំ លោកោ បរោ លោកោ ព្រហ្មលោកោ សទេវលោកោ អយំ វុច្ចតិ លោកោ ។ អយំ លោកោ កេន អាវុតោ និវុតោ ឱផុដោ បិហិតោ បដិច្ឆន្នោ បដិកុជ្ជិតោតិ កេនស្សុ និវុតោ លោកោ ។

[៤៥] ឥច្ចាយស្មា អជិតោតិ ឥច្ចាតិ បទសន្ធិ បទសំ-សគ្គោ បទចារិបូរិ អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វកមេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវចនំ ការ-ការវចនំ សការវសប្ផតិសញ្ជាជិវចនមេតំ អាយស្មាតិ ។

---

១ ឱ. ម. ព្រូសិ ។ ២ ឱ. ម. ឥមេ បាឋា កេនស្សុ និវុតោត្យាទិកា នត្ថិ ។

អជិតមាណវកปุจฉานิទ្ទេស

[៥៣] (អជិតមាណព មានអាយុ សួរដូច្នេះថា)

លោក ត្រូវអ្វី បិទបាំង

លោក មិនក្ងឹស្ងាត់ ព្រោះហេតុអ្វី

សូមព្រះអង្គត្រាស់ប្រាប់នូវធម៌អ្វី ថាជាគ្រឿងលាប

លោកនោះ អ្វីជាភ័យធំ របស់លោកនោះ ។

[៥៤] ពាក្យថា លោក ត្រូវអ្វីបិទបាំង សេចក្តីថា និរយលោក តិរច្ឆានលោក បិត្តិវិសយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក លោកនេះ លោកខាងមុខ ព្រហ្មលោក ព្រមទាំងទេវលោក នេះហៅថា លោក ។ លោកនេះ ត្រូវអ្វីបិទបាំង បិទទាំងខាងក្រោម បិទទាំងខាងលើ បិទកន្ត្រិត គ្រប ហេតុនោះ (លោក សួរថា) លោក ត្រូវអ្វីបិទបាំង ។

[៥៥] ពាក្យថា ដូច្នេះ នៃពាក្យថា អជិត: មានអាយុ សួរ ដូច្នេះ គឺជាពាក្យតបទ ជាពាក្យភ្ជាប់បទ ជាពាក្យបំពេញបទ ជាទីប្រជុំនៃអក្ខរ: ជាសេចក្តីពីរោះដោយព្យញ្ជន: ពាក្យថា ដូច្នេះ នុ៎ះ ជាលំដាប់នៃបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុ នុ៎ះ ជាពាក្យពោលដោយគោរព កោតក្រែង ។

អជិតោតិ តស្ស ព្រាហ្មណស្ស នាមំ សង្ខា សមញ្ញា បញ្ញត្តិ វោហារោ នាមំ នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោតិ ឥច្ចាយស្មា អជិតោ ។

[៤៦] កេនស្សុ នប្បកាសតីតិ កេន លោកោ នប្បកាសតិ ន ភាសតិ ន តបតិ ន វិរោចតិ ន សញ្ញាយតិ ន បញ្ញាយតីតិ កេនស្សុ នប្បកាសតិ ។

[៤៧] កិស្សាភិលេបនំ ព្រូសីតិ កឹ អស្ស លោកស្ស អភិលេបនំ លគ្គនំ ពន្ធនំ ឧបក្កិលេសោ កេន លោកោ លិត្តោ បលិត្តោ កិលិដ្ឋោ សង្កិលិដ្ឋោ មក្ខិតោ សំសដ្ឋោ លគ្គោ លគ្គិតោ បលិពុទ្ធោ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ កិស្សាភិលេបនំ ព្រូហិ ។

[៤៨] កឹសុ តស្ស មហព្ភយន្តិ កឹ តស្ស លោកស្ស មហព្ភយំ បីឡនំ ឃដ្ដនំ ឧបទ្ទវោ ឧបសគ្គោតិ កឹសុ តស្ស មហព្ភយំ ។ តេនាហ សោ ព្រាហ្មណោ

ពាក្យថា អជិត: គឺជានាម ជាសង្ខ្យា ជាឈ្មោះ ជាបញ្ញត្តិ ជាវោហារ ជានាម ជានាមកម្ម ជានាមធেយ្យ ជាភាសា ជាព្យញ្ជន: ជាពាក្យហៅ របស់ព្រាហ្មណ៍នោះ ហេតុនោះ មានពាក្យថា អជិតមាណពមាន អាយុ សួរ ដូច្នេះ ។

[៥៦] *ពាក្យថា លោកមិនក្ងឹស្វាងព្រោះហេតុអ្វី គឺលោកមិនក្ងឹស្វាង មិនមានរស្មី មិនមានពន្ធឺ មិនរុងរឿង មិនយល់ច្បាស់ មិនប្រាកដ ព្រោះហេតុអ្វី ហេតុនោះ លោកសួរថា លោកមិនក្ងឹស្វាងព្រោះហេតុអ្វី ។*

[៥៧] *ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់ នូវធម៌អ្វីជាគ្រឿងលាប លោកនោះ គឺអ្វីជាគ្រឿងលាប ជាគ្រឿងចំពាក់ ជាគ្រឿងចង ជាឧបក្ខិ-លេស របស់លោកនោះ លោក ត្រូវអ្វីលាប ស្រឡាប ធ្វើឲ្យសៅហ្មង ឲ្យសៅហ្មងព្រម ឲ្យប្រឡាក់ ឲ្យច្រឡំព្រម ឲ្យជាប់ ឲ្យចំពាក់ ឲ្យជាប់ ស្អិត សូមព្រះអង្គត្រាស់ប្រាប់ សម្តែងបញ្ញត្ត តាំងទុក បើក ចែក រំលែក ធ្វើឲ្យងាយ ប្រកាស ហេតុនោះ សូមព្រះអង្គត្រាស់ប្រាប់នូវអ្វី ជា គ្រឿងលាបលោកនោះ ។*

[៥៨] *ពាក្យថា អ្វីជាកំ្យធំ របស់លោកនោះ គឺអ្វីជាកំ្យធំ ជា គ្រឿងបៀតបៀន ជាគ្រឿងគាប ជាឧបទ្រព ជាឧបស័គ្ត របស់លោក នោះ ហេតុនោះ លោកសួរថា អ្វីជាកំ្យធំ របស់លោកនោះ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលហើយថា*

កេនស្ស និវុតោ លោកោ (ឥច្ចាយស្មា អជិតោ)

កេនស្ស ជប្ប្ការសតិ

ការ្ការ្ការ្ការ្ការ

ការ្ការ្ការ្ការ

[៤៩] អវិជ្ជាយ និវុតោ លោកោ (អជិតាតិ ភគវា)

ការ្ការ្ការ្ការ

ជប្ប្ការ្ការ

ជ្ជ្ជ

ជ្ជ

[៦០] អវិជ្ជាយ និវុតោ លោកោតិ អវិជ្ជាតិ ទុក្ខេ អញ្ញាណំ ទុក្ខសមុទយេ អញ្ញាណំ ទុក្ខនិរោធេ អញ្ញ-ណំ ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ បុព្វន្តេ អញ្ញាណំ អបរន្តេ អញ្ញាណំ បុព្វន្តាបរន្តេ អញ្ញាណំ ឥទប្ប្ចយតាបដិចសមុប្ប្ន្នេសុ ធម្មេសុ អញ្ញាណំ

លោក ត្រូវអ្វី បិទបាំង

លោក មិនភ្ជឿស្វាង ព្រោះហេតុអ្វី

សូមព្រះអង្គត្រាស់ប្រាប់នូវធម៌អ្វី ជាគ្រឿងលាប

លោកនោះ អ្វីជាភ័យធំ របស់លោកនោះ ។

[៥៩] *(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអជិត:)*

លោកត្រូវអវិជ្ជាបិទបាំង លោក មិនភ្ជឿស្វាង

ព្រោះសេចក្តីប្រាថ្នាផ្សេងៗ (និងសេចក្តីប្រ-

ហែស) តថាគតពោលនូវសេចក្តីប្រាថ្នា ថាជា

គ្រឿងលាប ទុក្ខជាភ័យធំ របស់លោកនោះ ។

[៦០] *អធិប្បាយពាក្យថា លោក ត្រូវអវិជ្ជាបិទបាំង ត្រង់ពាក្យថាអវិជ្ជា បានន័យថា សេចក្តីមិនដឹងក្នុងទុក្ខ សេចក្តីមិនដឹងក្នុងតណ្ហា ជាហេតុឲ្យកើតទុក្ខ សេចក្តីមិនដឹងក្នុងកិរិយារលត់ទុក្ខ សេចក្តីមិនដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ សេចក្តីមិនដឹងក្នុងទីបំផុតខាងដើម សេចក្តីមិនដឹងក្នុងទីបំផុតខាងចុង សេចក្តីមិនដឹងក្នុងទីបំផុតខាងដើម និងទីបំផុតខាងចុង សេចក្តីមិនដឹងក្នុងធម៌ដែលកើតឡើងហើយ អាស្រ័យធម៌នេះជាបច្ច័យ*

យំ ឯវ្រូបំ អញ្ញាណំ អនស្សនំ អនភិសមយោ អនវុពោធោ អសម្ពោធោ អប្ប‌ដិ‌វេ‌ធោ អ‌ស‌ង្ខ‌ហ-ណា អ‌ប‌រិ‌យោ‌ត‌ហ‌ណា អ‌ស‌ម‌ប‌ក្ខ‌ណា អ‌ប្ប‌ច្ចូ‌ប‌ក្ខ‌ណា អ‌ប្ប‌ច្ចូ‌ក្ខ‌ក‌ម្មំ ទុ‌ម្មេ‌ជ្ឌ ពា‌ឡ‌ំ អ‌ស‌ម្ប‌ជ‌ញ្ញ‌ំ ប‌ម‌ោ‌ហ‌ោ ស‌ម្ប‌ម‌ោ‌ហ‌ោ អ‌វិ‌ជ្ជា‌យ‌ោ អ‌វិ‌ជ្ជា‌យ‌ោ‌គ‌ោ អ‌វិ‌ជ្ជា‌ឧ‌ស-យ‌ោ អ‌វិ‌ជ្ជា‌ប‌រិ‌យុ‌ដ្ឋា‌ន‌ំ អ‌វិ‌ជ្ជា‌ជ‌ាល‌ំ ម‌ោ‌ហ‌ោ អ‌ក‌ុ‌ស-ល‌ម‌ូ‌ល‌ំ អ‌យ‌ំ រ‌ុ‌ច្ចូ‌ត‌ិ អ‌វិ‌ជ្ជា ។ ‌ល‌ោ‌ក‌ោ‌ត‌ិ ន‌ិ‌រ‌យ‌ល‌ោ-ក‌ោ ត‌ិ‌រ‌ច្ឆា‌ន‌ល‌ោ‌ក‌ោ ប‌ិ‌ត្ត‌ិ‌វ‌ិ‌ស‌យ‌ល‌ោ‌ក‌ោ ម‌នុ‌ស្ស-ល‌ោ‌ក‌ោ ‌ទ‌េ‌វ‌ល‌ោ‌ក‌ោ ‌ខ‌ន្ធ‌ល‌ោ‌ក‌ោ ‌ធ‌ាតុ‌ល‌ោ‌ក‌ោ អ‌ាយ‌ត‌ន‌ល‌ោ‌ក‌ោ អ‌យ‌ំ ‌ល‌ោ‌ក‌ោ ‌ប‌ពេ ‌ល‌ោ‌ក‌ោ ‌ព្រ‌ហ្ម‌ល‌ោ‌ក‌ោ ‌ស‌ទ‌េ‌វ‌ល‌ោ‌ក‌ោ អ‌យ‌ំ រ‌ុ‌ច្ចូ‌ត‌ិ ‌ល‌ោ‌ក‌ោ ។ ‌ឥ‌ម‌ាយ អ‌វិ‌ជ្ជា‌យ អ‌ាវ‌ុ‌ត‌ោ ន‌ិ‌វ‌ុ‌ត‌ោ ‌ឌ‌ិ‌ដ្ឋ‌ោ ‌ប‌ិ‌ហ‌ិ‌ត‌ោ ‌ប‌ដ‌ិ‌ច្ច‌ន្ធ‌ោ ‌ប‌ដ‌ិ‌ក‌ុ‌ជ្ជ‌ិ‌ត‌ោ‌ត‌ិ អ‌វិ‌ជ្ជា‌យ ន‌ិ‌វ‌ុ‌ត‌ោ ‌ល‌ោ‌ក‌ោ ។

[៦១] អ‌ជ‌ិ‌ត‌ាតិ ‌ភ‌ក‌វា ‌ត‌ំ ‌ព្រ‌ាហ្ម‌ណ‌ំ ‌ជ‌ាម‌េ‌ន អ‌ាល‌ប‌ត‌ិ ។ ‌ភ‌ក‌វា‌ត‌ិ ‌ការ‌ណ‌ន‌ិ‌វ‌ច‌ន‌ម‌េ‌ត‌ំ ។ អ‌ប‌ិ‌ច ‌ភ‌ក្ត‌ារ‌ោ‌ត‌ិ ‌ភ‌ក‌វា ។ ‌ភ‌ក្ត‌ោ‌ឧ‌ស‌ោ‌ត‌ិ ‌ភ‌ក‌វា ។

កិរិយាមិនដឹង ការមិនឃើញ ការមិនត្រាស់ដឹង ការមិនត្រាស់ដឹងតាម ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនចុះចិត្ត ការមិនចុះ ចិត្តស៊ប់ ការមិនមានការរំពៃ ការមិនមានការពិចារណា ការមិន មានការយល់ច្បាស់ ការយល់បានដោយក្រ ភាពជាពាល ភាពមិន មានសម្បជញ្ញៈ សេចក្តីវង្វេងទូទៅ សេចក្តីវង្វេងព្រម ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា ការស្នាក់ដំណើរគឺអវិជ្ជា បណ្តាញ គឺអវិជ្ជា មោហៈ អកុសលមូល ណា មានសភាពយ៉ាងនេះ នេះហៅ ថា អវិជ្ជា ។ ពាក្យថា លោក គឺនិរយលោក តិរច្ឆានលោក បិត្តិ-វិសយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយ-តនលោក លោកនេះ លោកខាងមុខ ព្រហ្មលោក ព្រមទាំងទេវលោក នេះហៅថា លោក ។ លោក ត្រូវអវិជ្ជានេះ បិទបាំង បិទ បិទខាង ក្រោម បិទខាងលើ បិទភ្ជិត គ្រប ហេតុនោះ (ទ្រង់ត្រាស់ថា) លោក ត្រូវអវិជ្ជាបិទបាំង ។

[៦១] *ពាក្យថា អជិតៈ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅ នូវ ព្រាហ្មណ៍នោះចំឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគនេះ ជាពាក្យពោល ដោយគោរព ។ មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់ បង់រាគៈ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់ទោសៈ ។*

ភក្តមោហោតិ ភគវា ។ ភក្តមានោតិ ភគវា ។ ភក្តជិជ្ជីតិ ភគវា ។ ភក្តកណ្ណោកោតិ ភគវា ។ ភក្ត-ក្ខិលេសោតិ ភគវា ។ ភជិ វិភជិ បជិវិភជិ ធម្ម-រតនន្តិ ភគវា ។ ភវានំ អន្តករោតិ ភគវា ។ ភា-វិតកាយោតិ ភគវា ។ ភាវិតសីលោតិ ភាវិតចិត្តោតិ ភាវិតប្បញ្ញោតិ ភគវា ។ ភជិ ឋ ភគវា អរញ្ញវន-បត្ថានិ បន្តានិ សេនាសនានិ អប្បសទ្ទានិ អប្បនិ-ក្ឃោសានិ វិជនវាតានិ មនុស្សរាហាសេយ្យកានិ បដិ-សល្លានសារ្ប្បានីតិ ភគវា ។ ភាគី ឋ ភគវា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ភគវា ។ ភាគី ឋ ភគវា អត្ថរសស្ស ធម្មរសស្ស វិមុត្តិរសស្ស អធិសីលស្ស អធិចិត្តស្ស អធិប្បញ្ញា-យាតិ ភគវា ។ ភាគី ឋ ភគវា ចតុន្នំ ឈានានំ ចតុន្នំ អប្បមញ្ញានំ ចតុន្នំ អរូបសមាបត្តីនន្តិ ភគវា ។

ព្រះនាមថាព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់មោហៈ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់មានៈ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់ទិដ្ឋិ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់បន្ទាគឺកាម ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់កិលេស ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់ចែកបែងរំលែកនូវធម្មរតនៈ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់ធ្វើនូវទីបំផុតកព ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់មានកាយចម្រើន ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់មានសីលចម្រើន ព្រោះទ្រង់មានចិត្តចម្រើន ព្រោះទ្រង់មានបញ្ញាចម្រើន ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់គប់រកសេនាសនៈដ៏ស្ងាត់ ដែលតាំងនៅក្នុងព្រៃតូចព្រៃធំ មិនមានសូរសព្ទ មិនមានគឹកកង ជាទីប្រាសចាកខ្យល់ដែលកើតអំពីសរីរៈនៃមនុស្ស គួរជាទីកំបាំងនៃមនុស្ស គួរដល់កិរិយាសម្ងំនៅ ។ មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យទ្រង់មានភាគនៃចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារគឺថ្នាំកែរោគ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត និងអធិប្បញ្ញា ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យមានភាគនៃឈាន៤ អប្បមញ្ញា៤ និងអរូបសមាបត្តិ៤ ។

ភាគី វា ភគវា អដ្ឋន្នំ វិមោក្ខានំ អដ្ឋន្នំ អភិភាយ-
តនានំ ឌវន្នំ អនុបុព្ពវិហារសមាបត្តីនន្តិ ភគវា ។
ភាគី វា ភគវា ឌសន្នំ សញ្ញាភាវនានំ ឌសន្នំ កសិណ-
សមាបត្តីនំ អានាបានស្សតិសមាធិស្ស អសុភសមា-
បត្តិយាតិ ភគវា ។ ភាគី វា ភគវា ចតុន្នំ
សតិប្បដ្ឋានានំ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបា-
ទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ
ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្សាតិ ភគវា ។
ភាគី វា ភគវា ឌសន្នំ តថាគតពលានំ ចតុន្នំ វេសា-
រជ្ជានំ ចតុន្នំ បដិសម្ភិទានំ ឆន្នំ អភិញ្ញានំ ឆន្នំ
ពុទ្ធធម្មានន្តិ ភគវា ។ ភគវាតិ នេតំ នាមំ មាតរ
កតំ ន បិតរ កតំ ន ភាតរ កតំ ន ភគិនិយ
កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិ-
តេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន
ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ
ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភ
សច្ចិកា បញ្ញត្តិ យទិទំ ភគវាតិ អធិវចនំ ភគវា ។

ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគ នៃវិមោក្ខ ៨ អភិភាយតន: ៨ និងអនុបុព្វវិហារសមាបត្តិ ៩ ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃសញ្ញា-ភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិសមាធិ និងអសុក-សមាបត្តិ ។ ព្រះនាមថា មានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មាន ភាគនៃសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល: ៥ ពោជ្ឈង្គ ៧ និងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ ព្រះនាមថា ព្រះមាន ព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃតថាគតពល ១០ វេសារជ្ជ: ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ និងពុទ្ធធម៌ ៦ ។ ពាក្យថា ព្រះមានព្រះភាគ នេះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុស ថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនមិត្តនិងអាមាត្យថ្វាយ មិនមែន ញាតិសាលោហិតថ្វាយ មិនមែនសមណ:និងព្រាហ្មណ៍ថ្វាយ មិនមែន ទេវតាទាំងឡាយថ្វាយទេ ពាក្យថា ព្រះមានព្រះភាគនុ៎ះ កើតក្នុងទីបំផុត វិមោក្ខរបស់ព្រះពុទ្ធទាំងឡាយ ទ្រង់មានភាគ ។ បញ្ញត្តិថា ព្រះមានព្រះ-ភាគនេះ (កើតហើយ) ដោយកិរិយាធ្វើឲ្យជាក់ច្បាស់ ព្រមទាំងការបាន ចំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនោះ ទើបមាន ពាក្យថា ព្រះមានព្រះភាគត្រាស់ថា ម្នាលអជិត: ។

អជិតមាណវកបញ្ហានិទ្ទេសោ

[៦២] វេវិច្ឆា (បមាទា) នប្បកាសតីតិ វេវិច្ឆំ វុច្ចន្តិ បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ ។ យំ ឯវរូបំ មច្ឆរិយំ មច្ឆរាយនា មច្ឆរាយិតត្តំ វេវិច្ឆំ កទរិយំ កដុកញ្ចុកតា អគ្គហិតត្តំ ចិត្តស្ស ឥទំ វុច្ចតិ មច្ឆរិយំ ។ អបិច ខន្ធមច្ឆរិយំបិ មច្ឆរិយំ ធាតុមច្ឆរិយំបិ មច្ឆរិយំ អាយតនមច្ឆរិយំបិ មច្ឆរិយំ គាហោ វុច្ចតិ មច្ឆរិយំ ។ បមាទោ វត្តព្វោ កាយទុច្ចរិតេ វា វចីទុច្ចរិតេ វា មនោទុច្ចរិតេ វា បញ្ចសុ វា កាមគុណេសុ ចិត្តស្ស វោស្សគ្គោ វោស្សគ្គានុប្បទានំ វា កុសលានំ វា ធម្មានំ ភាវនាយ អសក្កច្ចកិរិយតា អសាតច្ចកិរិយតា អនដ្ឋិតតា ឱលីនវុត្តិតា និក្ខិត្តច្ឆន្ទតា និក្ខិត្តធុរតា អនាសេវនា អភាវនា អពហុលីកម្មំ អនធិដ្ឋានំ អននុយោគោ បមាទោ យោ ឯវរូបោ បមាទោ បមជ្ជនា បមជ្ជិតត្តំ អយំ វុច្ចតិ បមាទោ ។

[៦២] *ពាក្យថា លោក មិនភ្ជឿស្ទាង ព្រោះសេចក្តីប្រាថ្នាផ្សេងៗ(និងសេចក្តីប្រហែស) អធិប្បាយថា សេចក្តីកំណាញ់ ៥ គឺ កំណាញ់អាវាស កំណាញ់ត្រកូល កំណាញ់លាភ កំណាញ់វណ្ណៈ កំណាញ់ធម៌ ហៅថា សេចក្តីប្រាថ្នាផ្សេងៗ ។ សេចក្តីកំណាញ់ អាការនៃសេចក្តីកំណាញ់ ភាពនៃសេចក្តីកំណាញ់ សេចក្តីកំណាញ់ផ្សេងៗ សេចក្តីកំណាញ់រឹង ភាពនៃសេចក្តីកំណាញ់ក្តៅ ភាពនៃចិត្តហួងហែងមាំ ណា មានសភាពយ៉ាងនេះ នេះហៅថា សេចក្តីកំណាញ់ ។ មួយទៀត សេចក្តីកំណាញ់ ខន្ធ ហៅថា កំណាញ់ សេចក្តីកំណាញ់ធាតុ ហៅថា កំណាញ់ សេចក្តីកំណាញ់អាយតនៈ ហៅថា កំណាញ់ សេចក្តីកាន់ (ក្តាប់ទុក) ហៅថា កំណាញ់ ។ សេចក្តីប្រហែស ខ្ញុំគប្បីពោលដូចតទៅនេះ ការបណ្តែតបណ្តោយចិត្ត ការឲ្យកម្ចាំងដល់ការបណ្តែតបណ្តោយចិត្ត ទៅក្នុងកាយ-ទុច្ចរិតក្តី ក្នុងវចីទុច្ចរិតក្តី ក្នុងមនោទុច្ចរិតក្តី ក្នុងកាមគុណប្រាំក្តី ឬភាពនៃការធ្វើមិនគោរព ភាពនៃកិរិយាមិនធ្វើព្យាយាមរឿយៗ ភាពនៃចិត្តមិនតាំងនៅមាំ ភាពនៃចិត្តប្រព្រឹត្តរួញរា ភាពនៃសេចក្តីប្រាថ្នាដាក់ចុះ ភាពនៃធុរៈដាក់ចុះ ការមិនសេព ការមិនចម្រើន អំពើមិនសន្សំរឿយៗ ការមិនតាំងចិត្ត ការមិនប្រកបព្យាយាមរឿយៗ សេចក្តីប្រហែសក្នុងការចម្រើនទូវកុសលធម៌ទាំងឡាយ សេចក្តីប្រហែស អាការនៃសេចក្តីប្រហែស ភាពនៃសេចក្តីប្រហែសណាមានសភាពយ៉ាងនេះ នេះហៅថាសេចក្តីប្រហែស ។*

ហ្ការ (បមាណ) ជប្ជកាសតីតិ ឥមិណា មច្ចរិយេន ឥមិណា បមាទេន លោកោ ជប្ជកាសតិ ន ភាសតិ ន តបតិ ន វិរោចតិ ន សញ្ញាយតិ ន បញ្ញាយ-តីតិ ហ្ការ (បមាណ) ជប្ជកាសតិ ។

[៦៣] ជប្ជាកិលេបនំ ព្រូមីតិ ជប្ជា រុច្ចតិ តណ្ហា យោ ភវោ សាភវោ អនុនយោ អនុរោធោ ឧន្ទ្ធ ឧន្ទ្ធ្ការ ចិត្តស្ស សាភវោ ឥច្ឆា មុច្ឆា អជ្ឌោ-សានំ ឆេទោ បលិឆេទោ សង្ខោ បង្ខោ ឯជា មាយា ជនិកា សញ្ជនី សិព្ពិនី ជាលិនី សរិតា វិសត្តិកា ឆេត្តំ វិសតា អាយូហនី ទុតិយា បណិធិ ភវនេត្តិ វនំ វនថោ សន្ថវ សិនេហោ អបេក្ខា បដិពន្ធ អាសា អាសីសនា អាសីសិតត្តំ រូចាសា សន្ធាសា ឥន្ធាសា រសាសា ផោដ្ឋព្ពាសា លាភាសា ធនាសា បុត្តាសា ជីវិតាសា ជប្ជា បជប្ជា អភិជប្ជា ជប្ជនា ជប្ជិតត្តំ

ពាក្យថា លោក មិនក្ងឹស្ងាត ព្រោះសេចក្ដីប្រាថ្នាផ្សេង ៗ (និងសេចក្ដីប្រហែស) បានសេចក្ដីថា លោក មិនក្ងឹស្ងាត មិនមានរស្មី មិនមានពន្លឺ មិនរុងរឿង មិនយល់ច្បាស់ មិនប្រាកដ ព្រោះសេចក្ដីកំណាញ់នេះ ព្រោះសេចក្ដីប្រហែសនេះ ហេតុនោះ(ទ្រង់ត្រាស់ថា) លោក មិនក្ងឹស្ងាត ព្រោះសេចក្ដីប្រាថ្នាផ្សេង ៗ (និងសេចក្ដីប្រហែស) ។

[៦៣] *ពាក្យថា តថាគត ពោលនូវសេចក្ដីប្រាថ្នាថាជាគ្រឿងលាបអធិប្បាយថា តណ្ហា លោកហៅថា សេចក្ដីប្រាថ្នា បានដល់តម្រេក តម្រេកខ្លាំង សេចក្ដីត្រេកអរ សេចក្ដីត្រេកអរខ្លាំង សេចក្ដីត្រេកត្រអាល សេចក្ដីត្រេកត្រអាលខ្លាំង គឺតម្រេក ចិត្តត្រេកខ្លាំង សេចក្ដីប្រាថ្នា សេចក្ដីជ្រប់ចុះ កិរិយាលង់ចុះ ចំណង់ ចំណង់ខ្លាំង ការជាប់ភក់ញាប់ញ័រ ការលាក់ពុត ធម្មជាតញ៉ាំងសត្វឲ្យកើត គ្រឿងញ៉ាំងទុក្ខឲ្យកើត គ្រឿងចាក់ស្រេះបណ្ដាញ គ្រឿងហូរទៅ ធម្មជាតដូចពិស ខ្សែតណ្ហា គ្រឿងផ្សព្វផ្សាយ គ្រឿងញ៉ាំងអាយុឲ្យវិនាស សម្ងាញ់ ប្រណិធាន គ្រឿងនាំសត្វទៅកាន់ភព ព្រៃតូច ព្រៃធំ សន្ដវៈ ស្នេហា អាល័យ សេចក្ដីជាប់ចំពាក់ បំណង សេចក្ដីប៉ុនប៉ង ភាពនៃសេចក្ដីប៉ុនប៉ង បំណងរូប បំណងសំឡេង បំណងក្លិន បំណងរស បំណងផ្សព្វ បំណងលាភ បំណងទ្រព្យ បំណងបុត្រ បំណងជីវិត ការជាប់ចិត្ត ការជាប់ចិត្តខ្លាំង ការជាប់ចិត្តក្រៃលែង អាការជាប់ចិត្ត ភាពនៃការជាប់ចិត្ត*

អជិតមាណវកប្បញ្ហានិទ្ទេសោ

លោលុប្ជា លោលុប្ជាយនា លោលុប្ជាយិតត្តំ បុច្ច-
ញ្ជិកតា សាធុកម្យតា អជ្ឌម្ភកោ វិសមលោភោ
ជិកន្ធិ ជិកាមនា បត្ថនា បិហនា សម្ឆត្ថនា កាម-
តណ្ហា ភវតណ្ហា វិភវតណ្ហា រូបតណ្ហា អរូបតណ្ហា
ជិរោធតណ្ហា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រស-
តណ្ហា ផោដ្ឌព្ឌតណ្ហា ធម្មតណ្ហា ឱឃោ យោគោ
គន្ថោ ឧបាទានំ អាវរណំ នីវរណំ ឆទនំ ពន្ធនំ
ឧបក្ខិលេសោ អនុសយោ បរិយុដ្ឋានំ លតា វេវិច្ឆំ
ទុក្ខមូលំ ទុក្ខនិទានំ ទុក្ខប្ជករោ មារចាសោ
មារពលិសំ មារវិសយោ មារគោចរោ មារពន្ធនំ
តណ្ហានទី តណ្ហាជាលំ តណ្ហាគទ្ទុលំ តណ្ហាសមុទ្ទោ
អភិជ្ឌា លោភោ អកុសលមូលំ អយំ រុច្ចតិ ជប្ជ ។
លោភស្ស លេបនំ លត្ថនំ ពន្ធនំ ឧបក្ខិលេសោ
ឥមាយ ជប្ជាយ លោភោ លិត្ថោ បលិត្ថោ
ភិលិដ្ឋោ សង្ខ្លិលិដ្ឋោ មក្ខិតោ សំសដ្ឋោ លត្ថោ
លត្ថិតោ បលិពុទ្ធោ ។ ត្ជូហិ អាចិក្ខាមិ ទេសេមិ
បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្ថានី-
ភរោមិ បភាសេមីតិ ជប្ជាភិលេបនំ ត្ជូមិ ។

សេចក្តីលោភលន់ អាការលោភលន់ ភាពនៃសេចក្តីលោភលន់ សេចក្តីប្រាថ្នាអន្ទះអន្ទែង សេចក្តីប្រាថ្នា ក្នុងអារម្មណ៍ស្រួល តម្រេកខុសធម៌ លោភខុសទំនង អាល័យ អាការអាល័យ ការប្រាថ្នា សេចក្តីស្រឡាញ់ ការប្រាថ្នាខ្លាំង ចំណង់កាម ចំណង់ភព ចំណង់វិភព ចំណង់រូប ចំណង់អរូប ចំណង់និរោធ ចំណង់រូប ចំណង់សំឡេង ចំណង់ក្លិន ចំណង់រស ចំណង់ផ្សព្វ ចំណង់ធម្មារម្មណ៍ អន្ទង់ គ្រឿងប្រកប គ្រឿងសាំញ៉ាំ គ្រកងប្រកាន់ គ្រឿងរារាំង គ្រឿងហាម គ្រឿងប្រក់ គ្រឿងចង គ្រឿងចូលទៅឲ្យសៅហ្មង គ្រឿងដេកត្រាំ គ្រឿងស្អាក់ដំណើរ រលឹ្ម សេចក្តីប្រាថ្នាផ្សេង ១ ឫសនៃទុក្ខ ហេតុនៃទុក្ខ កំណើតទុក្ខ អន្ទាក់មារ សន្ទូចមារ វិស័យមារ គោចរមារ ចំណងមារ ស្ទឹងគឺតណ្ហា បណ្តាញគឺតណ្ហា ទន្ទីងគឺតណ្ហា សមុទ្ទគឺតណ្ហា សេចក្តីសម្ងឹងលោភ អកុសលមូល ណា នេះហៅថា សេចក្តីប្រាថ្នា ។ គ្រឿងលាប គ្រឿងជាប់ គ្រឿងចង គ្រឿងចូលទៅឲ្យសៅហ្មង របស់លោក លោកលាប លាបស្រឡាប សៅហ្មង សៅហ្មងព្រម ប្រឡាក់ ច្រឡំព្រម ជាប់ ចំពាក់ ជាប់ស្ងួតហើយ ដោយសេចក្តីប្រាថ្នានេះ ។ តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក រំលែក ធ្វើឱ្យងាយប្រកាស ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតពោល នូវសេចក្តីប្រាថ្នាថាជាគ្រឿងលាប ។

[៦៤] ទុក្ខមស្ស មហាព្ភយន្តិ ទុក្ខន្តិ ជាតិទុក្ខំ ជរាទុក្ខំ ព្យាធិទុក្ខំ មរណទុក្ខំ សោកបរិទេវទុក្ខ-ទោមនស្សុបាយាសទុក្ខំ ទេវយិកំ ទុក្ខំ តិរច្ឆាន-យោនិកំ ទុក្ខំ បិត្តិវិសយិកំ ទុក្ខំ មានុសិកំ ទុក្ខំ គព្ភោក្កន្តិមូលកំ ទុក្ខំ គព្ភេដ្ឋិតិមូលកំ ទុក្ខំ គព្ភ-វុដ្ឋានមូលកំ ទុក្ខំ ជាតស្សូបនិពន្ធកំ ទុក្ខំ ជាតស្ស បរាធេយ្យកំ ទុក្ខំ អត្តូបក្កមំ ទុក្ខំ បរូបក្កមំ ទុក្ខំ ទុក្ខទុក្ខំ សង្ខារទុក្ខំ វិបរិណាមទុក្ខំ ចក្ខុរោគោ សោតរោគោ ឃានរោគោ ជិវ្ហារោគោ កាយរោគោ សីសរោគោ កណ្ណរោគោ មុខរោគោ ទន្តរោគោ កា-សោ សាសោ បិនាសោ ឌហោ ជរោ កុច្ឆិរោគោ មុច្ឆា បក្ខន្ធិកា សុលា វិសូចិកា កុដ្ឋំ គណ្ឌោ កិលាសោ សោសោ អបមារោ ទទ្រុ កណ្ឌូ កច្ឆូ រាជា វិតច្ឆិកា លោហិតំ បិត្តំ មធុមេហោ អំសា បិឬកា ភគន្ទលា

[៦២] *អធិប្បាយពាក្យថា ទុក្ខជាភ័យធំរបស់លោកនោះ ត្រង់ពាក្យ ថា ទុក្ខ គឺទុក្ខព្រោះកំណើត ទុក្ខព្រោះសេចក្តីចាស់ ទុក្ខព្រោះជំងឺ ទុក្ខ ព្រោះសេចក្តីស្លាប់ ទុក្ខព្រោះសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តី លំបាកកាយ សេចក្តីតូចចិត្ត សេចក្តីក្រៀមក្រំ ទុក្ខក្នុងកំណើតនរក ទុក្ខក្នុងកំណើតតិរច្ឆាន ទុក្ខក្នុងកំណើតបេតវិស័យ ទុក្ខក្នុងកំណើត មនុស្ស ទុក្ខមានការចុះកាន់គភ៌ជាមូល ទុក្ខមានការឋិតនៅក្នុងគភ៌ជាមូល ទុក្ខមានកិរិយាចេញចាកគភ៌ជាមូល ទុក្ខជាបំណងរបស់[1]សត្ត្ব ដែល កើតហើយ ទុក្ខទាក់ទងដោយបុគ្គលដទៃនៃសត្ត្ব ដែលកើតហើយ ទុក្ខ កើត ព្រោះព្យាយាមរបស់ខ្លួន ទុក្ខកើត ព្រោះព្យាយាមរបស់បុគ្គលដទៃ ទុក្ខគឺទុក្ខវេទនា (ប្រព្រឹត្តទៅក្នុងកាយនិងចិត្ត) ទុក្ខព្រោះសង្ខារ ទុក្ខព្រោះ ការផ្លាស់ប្តូរ រោគភ្នែក រោគត្រចៀក រោគច្រមុះ រោគអណ្តាត រោគ កាយ រោគក្បាល រោគស្លឹកត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត ឬសដូងច្រមុះ ក្តៅក្រហាយ ស្តាំងស្ពម រោគផ្ទៃ រ៉ាលមុខ ធ្លាក់ឈាម ចុកសៀត ចុះរាក ឃ្ងង់ ពក ស្រែង រ៉ីងរ៉ៃ ឆ្ពិតជ្រូក ដំណួចពិស រមាស់ កម រោគក្នុងទីខ្ជូរដោយក្រចក កមរលាយ ប្រមាត់ក្រហម ទឹកនោមផ្អែម ឬសដូងដុះ រលកកែវ ឬសដូងបាត*

---

1 បានដល់សេចក្តីទុក្ខដោយការថែទាំ គឺ ងូតទឹក លាបប្រេង ទំពាស៊ី ហុត ផឹក ជាដើម ។ អដ្ឋកថា ។

បិត្តសមុដ្ឋានា អាពាធា សេម្ហសមុដ្ឋានា អាពាធា វាតសមុដ្ឋានា អាពាធា សន្និបាតិកា អាពាធា ឧតុបរិណាមជា អាពាធា វិសមបរិហារជា អាពាធា ឱបក្កមិកា អាពាធា កម្មវិបាកជា អាពាធា សីតំ ឧណ្ហំ ជិឃច្ឆា បិបាសា ឧច្ចារោ បស្សាវោ ឌំសមកសវាតាតបសិរឹសបសម្ផស្សទុក្ខំ មាតុមរណំ ទុក្ខំ បិតុមរណំ ទុក្ខំ ភាតុមរណំ ទុក្ខំ ភគិនីមរណំ ទុក្ខំ បុត្តមរណំ ទុក្ខំ ធីតុមរណំ ទុក្ខំ ញាតិព្យសនំ ទុក្ខំ ភោគព្យសនំ ទុក្ខំ រោគព្យសនំ ទុក្ខំ សីលព្យសនំ ទុក្ខំ ទិដ្ឋិព្យសនំ ទុក្ខំ យេសំ ធម្មានំ អាទិតោ សមុទាគមនំ បញ្ញាយតិ អត្ថង្គមតោ និរោធោ បញ្ញាយតិ កម្មសន្និស្សិតោ វិបាកោ វិបាកសន្និស្សិតំ កម្មំ នាមសន្និស្សិតំ រូបំ រូបសន្និស្សិតំ នាមំ ជាតិយា អនុគតំ ជរាយ អនុសដំ ព្យាធិនា អភិភូតំ មរណេន អព្ភាហតំ ទុក្ខេ បតិដ្ឋិតំ អតាណំ អលេណំ អសរណំ អសរណីភូតំ ឥទំ វុច្ចតិ ទុក្ខំ ។ អស្ស លោកស្ស ទុក្ខំ មហព្ភយំ បីឡនំ ឃដ្ដនំ ឧបទ្ទវោ ឧបសគ្គោតិ ទុក្ខមស្ស មហព្ភយំ ។ តេនាហ ភគវា

អាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីការប្រជុំ (ខ្យល់ប្រមាត់ស្លេស្ម) អាពាធកើតអំពីការផ្ទាស់ប្តូររដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើ អាពាធកើតអំពីព្យាយាម (មានការសម្ងាប់និងចងជាដើម) អាពាធកើតអំពីផលកម្ម ត្រជាក់ ក្តៅ សេចក្តីឃ្លាន សេចក្តីស្រេក ឧច្ចារៈ បស្សាវៈ ទុក្ខកើតអំពីសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់ ការស្លាប់មាតាជាទុក្ខ ការស្លាប់បិតាជាទុក្ខ ការស្លាប់បងប្អូនប្រុសជាទុក្ខ ការស្លាប់បងប្អូនស្រីជាទុក្ខ ការស្លាប់កូនប្រុស ជាទុក្ខ ការស្លាប់កូនស្រីជាទុក្ខ ការព្រាត់ប្រាសញាតិជាទុក្ខ ការវិនាសភោគៈជាទុក្ខ វិនាសគឺរោគជាទុក្ខ វិនាសសីលជាទុក្ខ វិនាសទិដ្ឋិជាទុក្ខ ការកើតឡើងនៃធម៌ទាំងឡាយណា រមែងប្រាកដក្នុងខាងដើម ការរលត់ទៅ (នៃធម៌ទាំងឡាយនោះ) រមែងប្រាកដដោយការវិនាស វិបាកអាស្រ័យកម្ម កម្មអាស្រ័យវិបាក រូបអាស្រ័យនាម នាមអាស្រ័យរូប ត្រូវជាតិទៅតាមហើយ ត្រូវជរាផ្តេកផ្ដិតហើយ ត្រូវព្យាធិគ្របសង្កត់ហើយ ត្រូវមរណៈកម្ចាត់ហើយ តាំងនៅស៊ីប់ក្នុងសេចក្តីទុក្ខ ឥតមានទីពឹង ឥតមានទីជ្រក ឥតមានទីរឭក ឥតមានទីសង្ឃឹម នេះហៅថា ទុក្ខ ។ ទុក្ខជាភ័យធំ ជាគ្រឿងបៀតបៀន ជាគ្រឿងគាប ជាគ្រឿងឧបទ្រព ជាឧបស័គ្គ របស់លោកនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ទុក្ខជាភ័យធំ របស់លោកនោះ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ហើយថា

អវិជ្ជាយ និវុតោ លោកោ (អជិតាតិ ភគវា)
ឧវិច្ចា (បមាទា) ឧប្ប្ឫកាសតិ
ជប្ប្ឫកិលេបនំ ព្ឫូមិ
ឧក្ខ្ឫមស្ស មហាព្ភយន្តិ ។

[៦៥] សវន្តិ សព្ឫជិ សោតា (ឥច្ចាយស្ម្ឫ អជិតោ)
សោតានំ ឥកិន្ទ្ធ្ឫារណំ
សោតានំ សំវរំ ព្ឫូហិ
ឥកេន សោតា ឧបិជ្ជ្ឫរេ ។

[៦៦] សវន្តិ សព្ឫជិ សោតាតិ សោតាតិ ឥណ្ហា-សោតោ ជ្ឫិដ្ឋិសោតោ ឥកិលេសសោតោ ឧច្ចរ្ឫិតសោ-តោ អ្ឫវិជ្ជ្ឫាសោតោ ។ សព្ឫជ្ឫីតិ សព្ឫេសុ អ្ឫាយតនេ-សុ ។ សវន្តីតិ សវន្តិ អ្ឫាសវន្តិ ឧប្ប្ឫជ្ជ្ឫន្តិ ឧប្ប្ឫត្តន្តិ ចក្ខុ-តោ ្ឫូបេ សវន្តិ អ្ឫាសវន្តិ ឧប្ប្ឫជ្ជ្ឫន្តិ ឧប្ប្ឫត្តន្តិ សោតតោ ្ឫសេ សវន្តិ ឃ្ឫានតោ ្ឫគន្ធេ សវន្តិ ជ្ឫិហ្ឫាតោ ្ឫសេ សវន្តិ ្ឫកាយតោ ្ឫផោដ្ឋ្ឫព្ឫេ សវន្តិ ្ឫមនតោ ្ឫធ្ឫ្ម្ឫ សវន្តិ អ្ឫាសវន្តិ ឧប្ប្ឫជ្ជ្ឫន្តិ ឧប្ប្ឫត្តន្តិ ចក្ខ្ឫុតោ ្ឫូបតណ្ហ្ឫា សវន្តិ អ្ឫាសវន្តិ ឧប្ប្ឫជ្ជ្ឫន្តិ ឧប្ប្ឫត្តន្តិ សោតតោ

(ព្រះមានព្រះភាគត្រាស់ថា) ម្នាលអជិត: លោក ត្រូវអវិជ្ជា
បិទបាំង លោក មិនភ្ញឹស្ងាត ព្រោះសេចក្ដីប្រាថ្នាផ្សេង ។
(និងសេចក្ដីប្រហែស) តថាគត ពោលនូវសេចក្ដីប្រាថ្នាថា
ជាគ្រឿងលាប ទុក្ខជាភ័យធំ របស់លោកនោះ ។

[៦៥] (អជិតមាណពមានអាយុ ក្រាបបង្គំទូលសួរដូច្នេះថា) ខ្សែ
ទាំងឡាយ រមែងហូរទៅ ក្នុងទីទាំងពួង អ្វីជាគ្រឿងរារាំង
នូវខ្សែទាំងឡាយ សូមព្រះអង្គ ទ្រង់សម្ដែងធម៌ជាគ្រឿងបិទ
ខ្សែទាំងឡាយ បុគ្គលបិទខ្សែទាំងឡាយ ដោយអ្វី ។

[៦៦] *អធិប្បាយពាក្យថា ខ្សែទាំងឡាយ រមែងហូរទៅក្នុងទីទាំង
ពួង ត្រង់ពាក្យថា ខ្សែទាំងឡាយ បានដល់ខ្សែគឺតណ្ហា ខ្សែគឺទិដ្ឋិ ខ្សែ
គឺកិលេស ខ្សែគឺទុច្ចរិត ខ្សែគឺអវិជ្ជា ។ ពាក្យថា ក្នុងទីទាំងពួង គឺក្នុង
អាយតន:ទាំងពួង ។ ពាក្យថា ហូរទៅ សេចក្ដីថា ហូរទៅ ហូរសំយុង
ហូរមិនដាច់ ប្រព្រឹត្តទៅ គឺហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅ
អំពីភ្នែកទៅកាន់រូប ហូរអំពីត្រចៀកទៅកាន់សំឡេង ហូរអំពីច្រមុះទៅ
កាន់ក្លិន ហូរអំពីអណ្ដាតទៅកាន់រស ហូរអំពីកាយទៅកាន់ផ្សព្វ ហូរទៅ
ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅ អំពីចិត្តទៅកាន់ធម្មារម្មណ៍ រូប-
តណ្ហា ហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅ អំពីភ្នែក*

សទ្ទតណ្ហា សវន្តិ អាសវន្តិ សន្ទន្តិ បវត្តន្តិ ឃា-
ណតោ គន្ធតណ្ហា សវន្តិ ជិវ្ហាតោ រសតណ្ហា សវន្តិ
កាយតោ ផោដ្ឋព្វតណ្ហា សវន្តិ មនតោ ធម្មតណ្ហា
សវន្តិ អាសវន្តិ សន្ទន្តិ បវត្តន្តីតិ សវន្តិ សព្វធិ
សោតា ។

[៦៧] ឥច្ចាយស្មា អជិតោតិ ឥច្ចាតិ បទសន្ធិ
បទសំសគ្គោ បទបារិបូរិ អក្ខរសមវាយោ ព្យញ្ជន-
សិលិដ្ឋតា បទានុបុព្វកមេតំ ឥច្ចាតិ ។ អាយស្មាតិ
បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ
អាយស្មាតិ ។ អជិតោតិ តស្ស ព្រាហ្មណស្ស នាមំ
សង្ខា សមញ្ញា បញ្ញត្តិ វោហារោ នាមំ នាមកម្មំ
នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោតិ ឥច្ចាយស្មា
អជិតោ ។

[៦៨] សោតានំ កិន្និវារណន្តិ សោតានំ កឹ
អាវរណំ នីវរណំ សំវរណំ រក្ខនំ គោបនន្តិ
សោតានំ កិន្និវារណំ ។

សទ្ទតណ្ហា ហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅ អំពីត្រចៀក គន្ធតណ្ហា ហូរទៅអំពីច្រមុះ រសតណ្ហា ហូរទៅអំពីអណ្តាត ផោដ្ឋព្ព-តណ្ហា ហូរទៅអំពីកាយ ធម្មតណ្ហាហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅ អំពីចិត្ត ហេតុនោះ លោកសួរថា ខ្សែទាំងឡាយ រមែង ហូរទៅ ក្នុងទីទាំងពួង ។

[៦៧] *ពាក្យថា ដូច្នេះនៃបទថា អជិត:មានអាយុ (ទូលសួរ) ដូច្នេះ គឺជាការតបទ ជាការជាប់ដោយបទ ជាការបំពេញបទ ជាការប្រជុំនៃអក្ខរ: ជាសេចក្តីពីពោះ ដោយព្យញ្ជន: ពាក្យថា ដូច្នេះ នេះ ជាលំដាប់នៃបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុនេះ ជាពាក្យពោល ដោយគោរព កោតក្រែង ។ ពាក្យថា អជិត: គឺជានាម ជាសង្ខ្យា ជាឈ្មោះ ជាបញ្ញត្តិ ជាវោហារ ជានាម ជានាមកម្ម ជានាមធេយ្យ ជាកាសា ជាព្យញ្ជន: ជាពាក្យហៅ របស់ព្រាហ្មណ៍នោះ ហេតុនោះ មានពាក្យ ថា អជិត:មានអាយុ (ទូលសួរ) ដូច្នេះ ។*

[៦៨] *ពាក្យថា អ្វីជាគ្រឿងរារាំងនូវខ្សែទាំងឡាយ គឺអ្វីជាគ្រឿង ឃាត់ខាំង ជាគ្រឿងរារាំង ជាគ្រឿងបិទ ជាគ្រឿងរក្សា ជាគ្រឿង គ្រប់គ្រង នូវខ្សែទាំងឡាយ ហេតុនោះ លោកសួរថា អ្វីជាគ្រឿង រារាំង នូវខ្សែទាំងឡាយ ។*

[៦៩] សោតានំ សំវរំ ព្រូហីតិ សោតានំ អាវរណំ នីវរណំ សំវរណំ រក្ខនំ គោបនំ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ សោតានំ សំវរំ ព្រូហិ ។

[៧០] កេន សោតា បិធិយ្យរេតិ កេន សោតា បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ នប្បវត្តន្តីតិ កេន សោតា បិធិយ្យរេ ។ តេនាហ សោ ព្រាហ្មណោ

សវន្តិ សព្វធិ សោតា (ឥច្ចាយស្មា អជិតោ)
សោតានំ កិន្និវារណំ
សោតានំ សំវរំ ព្រូហិ
កេន សោតា បិធិយ្យរេតិ ។

[៧១] យានិ សោតានិ លោកស្មឹ (អជិតាតិ ភគវា)
សតិ តេសំ និវារណំ
សោតានំ សំវរំ ព្រូមិ
បញ្ញាយេតេ បិធិយ្យរេ ។

[៦៩] *ពាក្យថា សូមព្រះអង្គ ទ្រង់សម្តែងធម៌ជាគ្រឿងបិទខ្សែទាំងឡាយ គឺសូមព្រះអង្គ ពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយ ប្រកាស នូវធម៌ជាគ្រឿងឃាត់ខាំង គ្រឿងរារាំង គ្រឿងបិទ គ្រឿងរក្សា គ្រឿងគ្រប់គ្រង ខ្សែទាំងឡាយ ហេតុនោះ លោកសួរថា សូមព្រះអង្គ ទ្រង់សម្តែងធម៌ជាគ្រឿងបិទខ្សែទាំងឡាយ ។*

[៧០] *ពាក្យថា បុគ្គលបិទខ្សែទាំងឡាយ ដោយអ្វី គឺខ្សែទាំងឡាយ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររៀយៗ មិនប្រព្រឹត្តទៅ ដោយអ្វី ហេតុនោះ លោកសួរថា បុគ្គលបិទខ្សែទាំងឡាយ ដោយអ្វី ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា*

ខ្សែទាំងឡាយ រមែងហូរទៅ ក្នុងទីទាំងពួង អ្វីជាគ្រឿងរារាំង នូវខ្សែទាំងឡាយ សូមព្រះអង្គទ្រង់សម្តែងធម៌ ជាគ្រឿងបិទខ្សែទាំងឡាយ បុគ្គលបិទខ្សែទាំងឡាយ ដោយអ្វី ។

[៧១] *(ព្រះមានព្រះភាគត្រាស់ថា ម្នាលអជិត:) ខ្សែទាំងឡាយ ណា ក្នុងលោក សតិ ជាគ្រឿងបិទខ្សែទាំងនោះ តថាគត ពោលនូវការបិទខ្សែទាំងឡាយ ខ្សែទាំងនុ៎ះ បុគ្គលបិទ បាន ដោយបញ្ញា ។*

[៧២] យានិ សោតានិ លោកស្មិន្តិ យានិ ឯ-
តានិ សោតានិ មយា កិត្តិតានិ អាចិក្ខិតានិ ទេ-
សិតានិ បញ្ញបិតានិ បដ្ឋបិតានិ វិវរិតានិ វិភជិតានិ
ឧត្តានីកតានិ បកាសិតានិ សេយ្យថីទំ តណ្ហាសោ-
តោ ទិដ្ឋិសោតោ កិលេសសោតោ ទុច្ចរិតសោតោ
អវិជ្ជាសោតោ ។ លោកស្មិន្តិ អបាយលោកេ ម-
នុស្សលោកេ ទេវលោកេ ខន្ធលោកេ ធាតុលោ-
កេ អាយតនលោកេតិ យានិ សោតានិ លោ-
កស្មឹ ។ អជិតាតិ ភគវា តំ ព្រាហ្មណំ ជានេន
អាលបតិ ។

[៧៣] សតិ តេសំ និវារណន្តិ សតីតិ យា
សតិ អនុស្សតិ បដិស្សតិ សតិ សរណតា ចារណ-
តា អបិលាបនតា អសម្មុស្សនតា សតិ សតិន្ទ្រិយំ
សតិសម្ពោជ្ឌង្គោ ឯកាយនមគ្គោ អយំ វុច្ចតិ សតិ ។
និវារណន្តិ អាវរណំ នីវរណំ សំវរណំ រក្ខនំ គោ-
បនន្តិ សតិ តេសំ និវារណំ ។

អជិតមាណវកប្បញ្ហានិទ្ទេស

[៧២] ពាក្យថា ខ្សែទាំងឡាយណា ក្នុងលោក សេចក្តីថា ខ្សែទាំងឡាយណា ដែលតថាគត ពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក ញែក ចែក ធ្វើឲ្យងាយ ប្រកាសហើយថា ខ្សែគឺតណ្ហា ខ្សែគឺទិដ្ឋិ ខ្សែគឺកិលេស ខ្សែគឺទុច្ចរិត ខ្សែគឺអវិជ្ជា ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ខ្សែទាំង-ឡាយណា ក្នុងលោក ។ ពាក្យថា អជិត: គឺ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅព្រាហ្មណ៍នោះចំឈ្មោះ ។

[៧៣] ពាក្យថា សតិជាគ្រឿងបិទទាំងនោះ ត្រង់ពាក្យថា សតិ បានដល់សេចក្តីរឭក សេចក្តីរឭករឿយ ៗ សេចក្តីរឭកចំពោះ សេចក្តីរឭក អាការនៃសេចក្តីរឭក សេចក្តីចាំ សេចក្តីជ្រួតជ្រាប សេចក្តីមិនវង្វេង សេចក្តីរឭក ឥន្ទ្រិយគឺសតិ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹងគឺសតិ ផ្លូវជាទីទៅនៃបុគ្គលតែមួយ នេះហៅថា សតិ ។ ពាក្យថា ជាគ្រឿងបិទ គឺជាគ្រឿងរាំង ជាគ្រឿងបិទ ជាគ្រឿងឃាត់ខាំង ជាគ្រឿងរក្សា ជាគ្រឿងគ្រប់គ្រង ហេតុនោះ ទ្រង់ត្រាស់ថា សតិ ជាគ្រឿងបិទខ្សែទាំងនោះ ។

[៧៤] សោតានំ សំវរំ ព្រូមីតិ សោតានំ អារ-
រណំ នីវរណំ សំវរណំ រក្ខនំ គោបនំ ព្រូមិ អា-
ចិក្ខামិ ទេសেমি បញ្ញបেমি បដ্ঠপেমি វিবরামি বিভজামি
উত্তানীকরোমি បকাসেমীতি សោតានំ សំវរំ ព្រូមិ ។

[៧៥] បញ្ញាយេតে បិថিয়্যরেতি បញ্ঞাতি យা
មួយទៀត បានដឹង យល់ ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យជាក់ច្បាស់ថា មិនទៀង បានដឹង យល់ ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យជាក់ច្បាស់ ថា ជាទុក្ខ ជារោគ ជាបូស ជាសរ ។ បេ ។ ថាមិនមែនជាគ្រឿងរលាស់ ខ្លួនចេញចាកទុក្ខ ។ ពាក្យថា រលត់ហើយ គឺរលត់ហើយព្រោះលោក ញ្ចុំងរាគៈឲ្យរលត់ រលត់ហើយ ព្រោះញ្ចុំងទោសៈឲ្យរលត់ រលត់ហើយ ព្រោះញ្ចុំងមោហៈឲ្យរលត់ រលត់ហើយ ព្រោះញ្ចុំងក្រោធ ការចងក្រោធ ទុក សេចក្តីលុបគុណ ការវាយឫកស្មើ សេចក្តីច្រណែន សេចក្តីកំណាញ់ ការបិទបាំងទោសរបស់ខ្លួន សេចក្តីអួតអាង សេចក្តីរឹងត្អឹង ការ ប្រណាំងប្រជែង មានះ សេចក្តីមើលងាយ សេចក្តីស្រវឹង សេចក្តីធ្វេស កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តី រោលរាលទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អកិសង្ខារជាអកុសល ទាំងពួងឲ្យរលត់ ។ ពាក្យថា ភិក្ខុ គឺឈ្មោះថា ភិក្ខុ ព្រោះទម្លាយបង់ធម៌ ប្រាំពីរ ។ បេ ។ មានមគ្គអប់រំ មានកពជ្ជីអស់ បុគ្គលនោះលោកហៅ ថាភិក្ខុ ហេតុនោះ (ទ្រង់ត្រាស់ថា) ដឹងហើយ រលត់ហើយ ជាភិក្ខុ ។

[១០៧] អធិប្បាយពាក្យថា សេចក្តីញាប់ញ័រ របស់ភិក្ខុនោះ មិនមាន ត្រង់ពាក្យថា របស់ភិក្ខុនោះបានដល់ការញាប់ញ័រទាំងឡាយ គឺការញាប់ ញ័រដោយតណ្ហា ញាប់ញ័រដោយទិដ្ឋិ ញាប់ញ័រដោយមានះ ញាប់ញ័រ ដោយកិលេស ញាប់ញ័រដោយកម្ម របស់ព្រះអរហន្តខីណាស្រព ។

តស្មិមេ ឥញ្ជិតា នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ តស្ស នោ សន្តិ ឥញ្ជិតា[១] ។

[១០៨] សោ ឧភន្តមភិញ្ញាយ មជ្ឈេ មន្តា ន លិម្បតីតិ អន្តោតិ ផស្សោ ឯកោ អន្តោ ផស្សសមុទយោ ទុតិយោ អន្តោ ផស្សនិរោធោ មជ្ឈេ អតីតំ ឯកោ អន្តោ អនាគតំ ទុតិយោ អន្តោ បច្ចុប្បន្នំ មជ្ឈេ សុខា វេទនា ឯកោ អន្តោ ទុក្ខា វេទនា ទុតិយោ អន្តោ អទុក្ខមសុខា វេទនា មជ្ឈេ នាមំ ឯកោ អន្តោ រូបំ ទុតិយោ អន្តោ វិញ្ញាណំ មជ្ឈេ ឆ អជ្ឈត្តិកានិ អាយតនានិ ឯកោ អន្តោ ឆ ពាហិរានិ អាយតនានិ ទុតិយោ អន្តោ វិញ្ញាណំ មជ្ឈេ សក្កាយោ ឯកោ អន្តោ សក្កាយសមុទយោ ទុតិយោ អន្តោ សក្កាយនិរោធោ មជ្ឈេ ។ មន្តា វុច្ចតិ បញ្ញា យា បញ្ញា បជានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ លេបាតិ ទ្វេ លេបា តណ្ហាលេបោ ច ទិដ្ឋិលេបោ ច ។

១ ម. ឥតោ បរំ តេនាហ ភគវា កាមេសុ ព្រហ្មចរិយវា មេត្តេយ្យាតិ ភគវា វីតតណ្ហោ សទា សតោ សង្ខាយ និព្វុតោ ភិក្ខុ តស្ស នោ សន្តិ ឥញ្ជិតាតិ ។ សោ ឧភន្តមភិញ្ញាយ មជ្ឈេ មន្តា ន លិម្បតិ តំ ព្រូមិ មហាបុរិសោតិ សោ ឥធ សិព្វនិមជ្ឈតា ។

សេចក្តីញាប់ញ័រទាំងនេះ របស់ព្រះខីណាស្រពនោះ គ្មាន មិនមាន មិនមានព្រម មិនបាន (គឺលោក) បានលះបង់ ផ្តាច់បង់ រម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្តីញាប់ញ័ររបស់ភិក្ខុនោះ មិនមាន ។

[១០៨] *អធិប្បាយពាក្យថា ភិក្ខុនោះ ដឹងច្បាស់នូវទីបំផុតទាំងពីរ និងកណ្តាលដោយការដឹង ហើយមិនជាប់ ត្រង់ពាក្យថា ទីបំផុត គឺ ផស្ស:ជាទីបំផុតមួយ ការកើតឡើងនៃផស្ស: ជាទីបំផុតទីពីរ ការរលត់នៃផស្ស: ទុកជាកណ្តាល អតីតជាទីបំផុតមួយ អនាគតជាទីបំផុតទីពីរ បច្ចុប្បន្នទុកជាកណ្តាល សុខវេទនាជាទីបំផុតមួយ ទុក្ខវេទនាជាទីបំផុតទីពីរ អទុក្ខមសុខវេទនា ទុកជាកណ្តាល នាមជាទីបំផុតមួយ រូបជាទីបំផុតទីពីរ វិញ្ញាណទុកជាកណ្តាល អាយតន: ខាងក្នុង ៦ ជាទីបំ-ផុតមួយ អាយតន: ខាងក្រៅ ៦ ជាទីបំផុតទីពីរ វិញ្ញាណទុកជាកណ្តាល សក្កាយ: ជាទីបំផុតមួយ ការកើតឡើងនៃសក្កាយ: ជាទីបំផុតទីពីរ ការរលត់នៃសក្កាយ: ទុកជាកណ្តាល ។ បញ្ញា លោកហៅថា ការដឹង គឺ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្តីឃើញត្រូវ ។ ពាក្យថា ការជាប់ បានដល់ការជាប់ជំពាក់ពីរគឺ ការជាប់ជំពាក់ ដោយតណ្ហា ១ ការជាប់ជំពាក់ ដោយទិដ្ឋិ ១ ។*

កតមោ តណ្ហាលេចោ ។ យាវតា តណ្ហាសង្ខ្យា-
តេន សីមកតំ មរិយាទិកតំ ឱធិកតំ បរិយន្តិកតំ
បរិក្ខិត្តំ មមាយិតំ ឥទំ មមំ ឯតំ មមំ ឯត្តកំ មមំ
ឯត្តាវតា មមំ មម រូបា សទ្ទា គន្ធា រសា ផោដ្ឋព្ពា
អត្ថរណា ចាបុរណា[1] ជាតរូបា អជេឡកា
កុក្កុដសូករា ហត្ថិគវាស្សវឡវា ខេត្តំ វត្តុ ហិរញ្ញ
សុវណ្ណំ គាមនិគមរាជធានិយោ រដ្ឋញ្ច ជនបទោ
ច កោសោ ច កោដ្ឋាគារញ្ច ការណីយ្យ មហាបរិ
តណ្ហាវសេន មមាយតិ យាវតា អដ្ឋសតតណ្ហាវិចរិតំ[2]
អយំ តណ្ហាលេចោ ។ កតមោ ទិដ្ឋិលេចោ ។ វីសតិ-
វត្ថុកា សក្កាយទិដ្ឋិ ទសវត្ថុកា មិច្ឆាទិដ្ឋិ ទសវត្ថុកា
អន្តគ្គាហិកា ទិដ្ឋិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិកន្តារោ
ទិដ្ឋិកន្ទរោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិស-
ញ្ញោជនំ គាហោ បដិគ្គាហោ អភិនិវេសោ បរា-
មាសោ ឋានំ ឋានមត្តោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ
វិបរិយេសគ្គាហោ វិបរីតគ្គាហោ វិបល្លាសគ្គាហោ
មិច្ឆាគាហោ អយាថាវកស្មឹ យាថាវកន្តិ គាហោ

---

១ ម. ចាវុរណា ។ ២ ម. អដ្ឋសតតណ្ហាវិចរិតំ ។

ការជាប់ចំពាក់ដោយតណ្ហា តើដូចម្តេច ។ សេចក្តីហួងហែង សេចក្តីប្រកាន់ដែលធ្វើឲ្យជាដែន ធ្វើឲ្យជាទំនប់ ធ្វើឲ្យជាចំណែក ធ្វើឲ្យជាទីបំផុត ដោយចំណែកនៃតណ្ហាជាកំណត់ថា នេះរបស់អញ នុ៎ះរបស់អញ វត្ថុមានប្រមាណប៉ុណ្ណោះ របស់អញ ធម្មជាតមានប្រមាណប៉ុណ្ណោះ របស់អញ រូប សំឡេង ក្លិន រស ផ្សព្វ កម្រាល សំពត់ដណ្តប់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះឈ្មោល-ញីស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ ឃ្វាំង ជង្រុក របស់អញ មួយវិញទៀត បុគ្គលប្រកាន់មហាប្រឹថពីទាំងមូល ដោយអំណាចនៃតណ្ហា តណ្ហាវិបរីត យ៉ាងពិស្តារ ១០៨ ជាកំណត់ នេះឈ្មោះថា ការជាប់ចំពាក់ដោយតណ្ហា ។ ការជាប់ចំពាក់ដោយទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិ មានវត្ថុ ២០ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ អន្តគ្គាហិកាទិដ្ឋិ មានវត្ថុ ១០ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃស្បាតគឺទិដ្ឋិ ផ្លូវលំបាកគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ សេចក្តីញាប់ញ័រគឺទិដ្ឋិ សញ្ញោជនៈ គឺទិដ្ឋិ ការប្រកាន់ ការប្រកាន់ចំពោះ ការផ្តេកផ្ចិត ការស្ទាបអង្អែល ផ្លូវខុស ផ្លូវអាក្រក់ ភាពនៃសេចក្តីខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ដោយការស្វែងខុស សេចក្តីប្រកាន់វិបរីត សេចក្តីប្រកាន់វិបល្លាស សេចក្តីប្រកាន់ខុស សេចក្តីប្រកាន់ថា ជារបស់ពិត ក្នុងរបស់ដែលមិនពិត

យាវតា ទ្វាសដ្ឋី ទិដ្ឋិគតានិ អយំ ទិដ្ឋិលេចោ ។ សោ ឧភន្តមកិញ្ញាយ មជ្ឈ មន្តា ន លិម្ពតីតិ សោ ឧភោ ច អន្តេ មជ្ឈញ្ច មន្តាយ អកិញ្ញាយ ជានិត្វា តុលយិត្វា តីរយិត្វា វិការយិត្វា វិភូតំ កត្វា ន លិម្ពតិ[1] ន្ទូបលិម្ពតិ អលិត្តោ[2] អន្ទូបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្ប្រមុត្តោ វិសំយុត្តោ វិមរិយា-ទិកតេន ចេតសា វិហរតីតិ សោ ឧភន្តមកិញ្ញាយ មជ្ឈ មន្តា ន លិម្ពតិ ។

[១០៩] តំ ព្រូមិ មហាបុរិសោតិ អត្តបុរិសោ សេដ្ឋបុរិសោ វិសេដ្ឋបុរិសោ ចាមោក្ខបុរិសោ ឧត្តម-បុរិសោ បវរបុរិសោតិ តំ ព្រូមិ តំ ភណាមិ តំ មញ្ញាមិ តំ ភណាមិ តំ បស្សាមិ[3] តំ ហេមាវមិ ។ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច មហាបុរិសោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ មហាបុរិសោ ហោតីតិ ។

---

១ ម. ឯត្តន្តរេ ន ច បលិម្ពតីតិ ទិស្សតិ ។ ២ ម. ឯត្តន្តរេ អសំលិត្តោ ។ ៣ ម. ទីបេមិ ។

ទិដ្ឋិ ៦២ ទាំងប៉ុន្មាន ឯណា មានសភាពយ៉ាងនេះ នេះឈ្មោះថា ការជាប់ចំពាក់ដោយទិដ្ឋិ ។ ពាក្យថា ភិក្ខុនោះដឹងច្បាស់ទីបំផុតទាំងពីរនិងកណ្តាល ដោយការដឹង ហើយមិនជាប់ បានន័យថា ភិក្ខុនោះដឹងច្បាស់ យល់ ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យប្រាកដ ទីបំផុតទាំងពីរនិងកណ្តាល ដោយការដឹងហើយ មិនចូលទៅជិតជាប់ គឺជាអ្នកមិនជាប់ចំពាក់ មិនចូលទៅជិតជាប់ ចេញ រលាស់ ចេញ ផុតស្រឡះ មិនប្រកបព្រម នៅដោយចិត្តដែលធ្វើកិលេសដូចជាទំនប់ ទៅប្រាសហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនោះដឹងច្បាស់ ទីបំផុតទាំងពីរនិងកណ្តាល ដោយការដឹងហើយ ។

[១០៩] ពាក្យថា តថាគតហៅបុគ្គលនោះថា មហាបុរស អធិប្បាយថា តថាគតហៅបុគ្គលនោះ ប្រាប់បុគ្គលនោះ សម្គាល់បុគ្គលនោះ ពោលបុគ្គលនោះ ឃើញបុគ្គលនោះ ហៅបុគ្គលនោះថា មហាបុរស បុរសដ៏លើស បុរសដ៏ប្រសើរ បុរសវិសេសបំផុត បុរសជាប្រធាន បុរសឧត្តម បុរសថ្លៃថ្នូ ។ ឧទាហរណ៍ដូចព្រះសារីបុត្តមានអាយុ ទូលសួរពាក្យនេះ នឹងព្រះមានបុណ្យ ថា សូមទ្រង់ព្រះមេត្តាប្រាស បុគ្គលដែលគេហៅថា មហាបុរស សូមទ្រង់ព្រះមេត្តាប្រាស បុគ្គលដែលជាមហាបុរស តើដោយហេតុប៉ុន្មាន ។

វិមុត្តចិត្តត្តា ១ាហំ សារីបុត្ត មហាបុរិសោតិ វេទាមិ អធិមុត្តចិត្តត្តា ០ោ មហាបុរិសោតិ វេទាមិ ១ាកថញ្ច សារីបុត្ត វិមុត្តចិត្តត្តា ហោតិ ១ធ សារីបុត្ត ១ិក្ខុ អជ្ឈត្តំ ១ាយេ ១ាយានុបស្សី វិហរតិ អ១ាតាបី សម្ប១ា០ោ ០តិមា វិ០េយ្យ ០ោ០េ ១ាកិ១្ឆា-០ោមនស្សំ ០ស្ស ១ាយេ ១ាយានុបស្សិ០ោ វិហរ០ោ ចិត្តំ វិ១ូ០តិ វិមុ១ូ០តិ ១ាមុ១ាន១ាយ ១ាសវេហិ ០េ០ាសុ ចិ០ត្ត ០ម្ម០ុ ០ម្ម១ានុបស្សី វិហរតិ ១ាតាបី ០ម្ម១ា០ោ ០តិមា វិ០េយ្យ ០ោ០េ ១ាកិ១្ឆា-០ោមនស្សំ ០ស្ស ០ម្ម០ុ ០ម្ម១ានុបស្សិ០ោ វិហរ០ោ ចិត្តំ វិ១ូ០តិ វិមុ១ូ០តិ ១ាមុ១ាន១ាយ ១ាសវេហិ ០ៅ ០ោ សារីបុត្ត ១ិក្ខុ វិមុត្តចិ០ោ វិមុត្តចិត្តត្តា ១ាហំ សារីបុត្ត មហាបុរិសោតិ ០ាមិ ១ាធិមុត្តចិត្តត្តា ០ោ មហាបុរិសោតិ ០ាមីតិ តំ ០ូ្ត មហាបុរិសោតិ ។

ម្នាលសារីបុត្ត តថាគតហៅថា មហាបុរស ព្រោះបុគ្គលនោះ មានចិត្តរួចស្រឡះហើយ មិនហៅថា មហាបុរស ព្រោះបុគ្គលនោះ មានចិត្តគ្រាន់តែជឿទេ ម្នាលសារីបុត្ត បុគ្គលមានចិត្តរួចស្រឡះហើយ ដោយប្រការដូចម្តេច ម្នាលសារីបុត្ត ភិក្ខុក្នុងសាសនានេះ ពិចារណា ឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង ជាអ្នកមានព្យាយាមដុត កម្តៅកិលេស ដឹងច្បាស់ មានស្មារតី បន្ទោបង់អភិជ្ឌានិងទោមនស្ស ក្នុងលោក ភិក្ខុនោះកាលពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ចិត្ត ក៏ប្រាសចាកតម្រេក រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់ មាំ ជាអ្នកពិចារណាឃើញរឿយៗ (នូវវេទនា) ក្នុងវេទនាទាំងឡាយ ពិចារណាឃើញរឿយៗ (នូវចិត្ត) ក្នុងចិត្ត ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាអ្នកមានព្យាយាម ដុតកម្តៅកិលេស ដឹងច្បាស់ មានស្មារតី បន្ទោបង់អភិជ្ឌានិងទោមនស្សក្នុងលោក ភិក្ខុ នោះ កាលពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ចិត្តក៏ ប្រាសចាកតម្រេក រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់ មាំ ម្នាលសារីបុត្ត ភិក្ខុមានចិត្តរួចស្រឡះហើយ យ៉ាងនេះឯង ម្នាល សារីបុត្ត តថាគតហៅថា មហាបុរស ព្រោះភិក្ខុនោះមានចិត្តផុតស្រឡះ ហើយ មិនហៅថា មហាបុរស ព្រោះភិក្ខុនោះមានចិត្តគ្រាន់តែជឿទេ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតហៅបុគ្គលនោះថា មហាបុរស ។

[១១០] សោ ឥធ សិព្វនិមច្ចតាតិ សិព្វនី វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឌា លោភោ អកុសលមូលំ ។ យស្សេសា សិព្វនី តណ្ហា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណាគ្គិនា ឌឌ្ឍា សោ សិព្វនីតណ្ហំ អច្ចតា ឧបច្ចតា អតិក្កន្តោ សមតិក្កន្តោ វីតិវត្តោតិ សោ ឥធ សិព្វនិមច្ចតា ។ តេនាហ ភគវា

> កាមេសុ[1] ព្រហ្មចរិយវា (មេត្តេយ្យាតិ ភគវា)
> វីតតណ្ហោ សទា សតោ
> សង្ខាយ និព្ពុតោ ភិក្ខុ
> តស្ស នោ សន្តិ ឥញ្ជិតា
> សោ ឧភន្តមភិញ្ញាយ
> មជ្ឌេ មន្តា ន លិម្ពតិ
> តំ ព្រូមិ មហាបុរិសោតិ
> សោ ឥធ សិព្វនិមច្ចតាតិ ។

---

1 ម. ឥធ កាមេសុត្យាទិ នត្ថិ ។

[១១០] *ពាក្យថា ភិក្ខុនោះបានកន្ទ្ធ១ តណ្ហាជាគ្រឿងចាក់ស្រេះក្នុងលោកនេះ សេចក្តីថា តណ្ហា លោកហៅថា ធម្មជាតិជាគ្រឿងចាក់ស្រេះ បានខាងសេចក្តីត្រេកអរ សេចក្តីត្រេកអរខ្លាំង ។ បេ ។ អកិណ្ណ លោ: អកុសលមូល ។ តណ្ហាជាគ្រឿងចាក់ស្រេះនេះ ដែលបុគ្គលណា លះបង់ ផ្តាច់បង់ រម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះបានកន្ទ្ធ១ ចូលទៅកន្ទ្ធ១ ឈានកន្ទ្ធ១ ឈានកន្ទ្ធ១ព្រម ប្រព្រឹត្តកន្ទ្ធ១ នូវតណ្ហាជាគ្រឿងចាក់ស្រេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនោះបានកន្ទ្ធ១តណ្ហាជាគ្រឿងចាក់ស្រេះ ក្នុងលោកនេះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា*

(ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តេយ្យ)

(ភិក្ខុណា) មានព្រហ្មចរិយ: (សង្រ្ទួម) ក្នុងកាមទាំងឡាយ ប្រាសចាកតណ្ហា មានស្មារតី សព្វកាល ដឹងហើយ រលត់ហើយ សេចក្តីញាប់ញ័ររបស់ភិក្ខុនោះ មិនមានទេ ភិក្ខុនោះដឹងច្បាស់ទីបំផុតទាំងពីរនិងកណ្តាល ដោយការដឹងហើយមិនជាប់ តថាគតហៅភិក្ខុនោះថា មហាបុរស ភិក្ខុនោះ បានកន្ទ្ធ១តណ្ហាជាគ្រឿងចាក់ស្រេះ ក្នុងលោកនេះ ។

តិស្សមេត្តេយ្យមាណវកปัญหานิទ្ទេសោ

[១១១] សហ តាថាปริโยสานา[1] តេន ព្រាហ្ម-ណេន សទ្ធឹ ឯកច្ចន្ធា ឯកปฏิโยคา ឯកาธิปฺปา-យา ឯกวาสนวาสิตา តេសំ អនេกชาณาส-หาสฺสานํ วีรํ วีตมลํ ธมฺมจกฺขุํ อุธปาธิ យញ្ជ្ញិញ្ចិ សมุธยธมฺมํ สพฺพนฺตํ นิโรธธมฺนฺติ ตสฺส ช ព្រាហ្ম-ณสฺส អนุปาทาย อาสวेหิ จิตฺตํ วิมุจฺจิ ។ សห อรหาตฺตปฺปตฺตา អธินฺธชาวกจีวรณฺฐากมณฺฐาลุเกสา ช มสฺชุ ช อนฺตรหิตา ។ กณฺฐกาสายวตฺถวสโน สชฺฌาธิปตฺตจีวรธโร អนฺตฺตปฺปธิปตฺติยา បญฺญลิโก กตวนฺตํ ธมสฺชุมาโน นิสินฺโน โหติ สตฺถา មេ กโต กตวา สาวโกหมสฺมีติ ។

តិស្សមេត្តេយ្យមាណวกปัญหานิทฺเทสโส ทุติโย ។

---

1 ម. ឯตฺตนฺตเร เย ทิสฺสติ ។

តិស្សមេត្តេយ្យមាណវកបញ្ហានិទ្ទេស

[១១១] ព្រាហ្មណ៍មាណពទាំងឡាយ មានអធ្យាស្ស័យតែមួយ មានប្រយោគតែមួយ មានសេចក្តីប៉ុនប៉ងតែមួយ មានធម៌ជាគ្រឿងអប់រំតែមួយ បានអប់រំហើយ (ក្នុងពុទ្ធសាសនាជាអតីត) ជាមួយគ្នា មួយអន្ទើ ដោយព្រាហ្មណ៍ (ឈ្មោះតិស្សមេត្តេយ្យ) នោះ ធម្មចក្ខុ (សោតាបត្តិ-មគ្គ) មានធូលីទៅប្រាសហើយ មានមន្ទិលទៅប្រាសហើយ កើតឡើងដល់ពាន់នៃសត្វដ៏ច្រើនទាំងនោះថា ធម្មជាតណាមួយ មានកិរិយា-កើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ឯ (តិស្សមេត្តេយ្យព្រាហ្មណ៍នោះ) មានចិត្តផុតស្រឡះហើយ ចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់ ដំណាលគ្នានឹងការចប់គាថា ។ (លំដាប់នោះ) ស្បែកខ្វា ជដា សំពត់សម្បកឈើ ឈើច្រត់ កុណ្ឌីទឹក និងសក់ ពុកមាត់ ពុកចង្កា ក៏បាត់ទៅ ជាមួយនឹងពេលដែលដល់នូវភាពនៃខ្លួនជាព្រះអរហន្ត ។ (តិស្សមេត្តេយ្យព្រាហ្មណ៍បានជាឯហិភិក្ខុ) ស្លៀកដណ្តប់នូវកណ្ឌៈ គឺសំពត់កាសាយៈ ទ្រទ្រង់នូវសង្ឆាដី បាត្រ និងចីវរ អង្គុយប្រណម្យអញ្ជលីនមស្សការព្រះមានព្រះភាគ ដោយប្រតិបត្តិសមគួរដល់ប្រយោជន៍ (ហើយប្រកាសថា) បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

ចប់ តិស្សមេត្តេយ្យមាណវកបញ្ហានិទ្ទេស ទី ២ ។

បុណ្ណកមាណវកបញ្ហានិទ្ទេសោ

[១១២] អនេជំ មូលទស្សាវី (ឥច្ចាយស្មា បុណ្ណកោ)

អត្ថិ បញ្ហេន អាគមំ

កិំ និស្សិតា ឥសយោ មនុជា

ខត្តិយា ព្រាហ្មណា ទេវតានំ

យញ្ញមកប្បឯ[1] បុថូធ លោកេ

បុច្ឆামិ តំ ភគវា ព្រូហិ មេ តំ ។

[១១៣] អនេជំ មូលទស្សាវីតិ ឯជា វុច្ចតិ តណ្ហា យោ ភវោ សាភវោ ។ បេ ។ អកិញ្ចា លោកេ អកុសលមូលំ ។ សា ឯជា តណ្ហា ពុទ្ធស្ស ភគវតោ បហីនា ឧচ្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្គតា អាយតិំអនុប្បាទធម្មា តស្មា ពុទ្ធោ អនេជោ ។ ឯជាយ បហីនត្តា អនេជោ ។

---

1 ម. យញ្ញមកប្ប យ៉ឯ ។

បុណ្ណកមាណវកปัญหานิទ្ទេស

[១១២] (បុណ្ណក:មានអាយុ ក្រាបទូលសួរថា) យើងខ្ញុំមកដោយ ត្រូវការសួរប្រស្នា ចំពោះព្រះអង្គ ជាបុគ្គលមិនមានការ ញាប់ញ័រ ទ្រង់ឃើញនូវមូល ចុះពួកមនុស្ស គឺឥសី ក្សត្រ និងព្រាហ្មណ៍ ច្រើននាក់ ក្នុងលោកនេះ អាស្រ័យអ្វី ទើប បានសម្រេចយញ្ញ: ដល់ទេវតាទាំងឡាយ បពិត្រព្រះ មានព្រះភាគ ខ្ញុំព្រះអង្គ ទូលសួរព្រះអង្គ សូមព្រះអង្គ ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[១១៣] ពាក្យថា ជាបុគ្គលមិនមានការញាប់ញ័រ ទ្រង់ឃើញនូវ មូល អធិប្បាយថា តណ្ហាលោកហៅថាការញាប់ញ័រ បានដល់សេចក្តី ត្រេកអរ សេចក្តីត្រេកអរខ្លាំង ។ បេ ។ អកិញ្ចា លោក: អកុសលមូល ។ ការញាប់ញ័រ គឺតណ្ហានោះ ព្រះពុទ្ធមានព្រះភាគ លះបង់ហើយ មានឫសផ្តាច់ផ្តិលហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើឲ្យដល់នូវការមិនមានបែបភាព មិនឲ្យមានការកើតឡើងតទៅជា ធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានការញាប់ញ័រ ។ ព្រះពុទ្ធឈ្មោះថា មិនញាប់ញ័រ ព្រោះព្រះអង្គលះនូវការញាប់ញ័រ ។

ភតវា លាភេបិ ន ឥញ្ជតិ អលាភេបិ ន ឥញ្ជតិ យ-
សេបិ ន ឥញ្ជតិ អយសេបិ ន ឥញ្ជតិ បសំសាយបិ
ន ឥញ្ជតិ និន្ទាយបិ ន ឥញ្ជតិ សុខេបិ ន ឥញ្ជតិ
ទុក្ខេបិ ន ឥញ្ជតិ ន ចលតិ ន វេធតិ ន ប្ប្ជវ-
ធតីតិ អនេជំ ។ មូលឧស្ជាវិន្តិ ភតវា មូលឧស្ជាវី
ហេតុឧស្ជាវី និទានឧស្ជាវី សម្ភវឧស្ជាវី សមុដ្ឋា-
នឧស្ជាវី អាហារឧស្ជាវី អារម្មណឧស្ជាវី បច្ចយ-
ឧស្ជាវី សមុទយឧស្ជាវី ។ តីណិ អកុសលមូលានិ
លោភោ អកុសលមូលំ ទោសោ អកុសលមូលំ
មោហោ អកុសលមូលំ ។ រុត្តញ្ជេតំ ភតវតា តី-
ណិមានិ ភិក្ខវេ និទានានិ កម្មានំ សមុទយាយ
លោភោ និទានំ កម្មានំ សមុទយាយ ទោសោ និទានំ
កម្មានំ សមុទយាយ មោហោ និទានំ កម្មានំ សមុ-
ទយាយ ន ភិក្ខវេ លោភជេន កម្មេន ទោសជេន
កម្មេន មោហជេន កម្មេន ទេវា បញ្ញាយន្តិ មនុស្ជ
បញ្ញាយន្តិ យា វ បនញ្ញាបិ ការិ សុកតិយោ

ទុកជាក្នុងលោក ព្រះមានព្រះភាគក៏មិនញាប់ញ័រ ទុកជាក្នុងអលោកក៏មិនញាប់ញ័រ ទុកជាក្នុងយសក៏មិនញាប់ញ័រ ទុកជាក្នុងអយសក៏មិនញាប់ញ័រ ទុកជាក្នុងសេចក្តីសរសើរក៏មិនញាប់ញ័រ ទុកជាក្នុងសេចក្តីតិះដៀលក៏មិនញាប់ញ័រ ទុកជាក្នុងសុខក៏មិនញាប់ញ័រ ទុកជាក្នុងទុក្ខក៏មិនញាប់ញ័រ មិនកម្រើក មិនរំកើប មិនរន្ធត់ ហេតុនោះ(លោកសួរថា) ជាបុគ្គលមិនមានការញាប់ញ័រ ។ ពាក្យថា ឃើញមូល គឺព្រះមានព្រះភាគ ទ្រង់ឃើញឫស-គល់ ឃើញហេតុ ឃើញនិទាន ឃើញសម្ភវ: ឃើញសមុដ្ឋាន ឃើញអាហារ ឃើញអារម្មណ៍ ឃើញបច្ច័យ ឃើញសមុទ័យ ។ អកុសលមូល ៣ គឺ លោភ: ជាអកុសលមូល ទោស: ជាអកុសលមូល មោហ: ជាអកុសលមូល ។ សមដូចព្រះមានព្រះភាគ ត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៣ នេះ ជាហេតុឲ្យកើតកម្មទាំងឡាយ គឺលោភ: ជាហេតុឲ្យកើតកម្ម ទោស:ជាហេតុឲ្យកើតកម្ម មោហ:ជាហេតុឲ្យកើតកម្ម ម្នាលភិក្ខុទាំងឡាយ មិនមែនដោយកម្មកើតអំពីលោភ: ដោយកម្មកើតអំពីទោស: ដោយកម្មកើតអំពីមោហ:ទេ ដែល(ធ្វើឲ្យ) ពួកទេវតាប្រាកដ ពួកមនុស្សប្រាកដ ឬក៏ពួកសុគតិណានីមួយសូម្បីដទៃ (ប្រាកដ)

អថខោ ភិក្ខវេ លោភជេន កម្មេន ឧោសជេន
កម្មេន មោហជេន កម្មេន និរយោ បញ្ញាយតិ
តិរច្ឆានយោនិ បញ្ញាយតិ បិត្តិវិសយោ បញ្ញាយតិ
យា វា បនញ្ញាបិ កាចិ ទុគ្គតិយោ និរយេ តិរច្ឆាន-
យោនិយំ បិត្តិវិសយេ អត្តភាវាភិនិព្ពត្តិយា ឥមានិ
តីណិ អកុសលមូលានីតិ ភគវា ជានាតិ បស្សតិ ។
ឯវម្ប៎ិ ភគវា មូលឧស្ជ្ជាវី ។ បេ ។ សមុឧយឧស្ជ្ជាវី ។
តីណិ កុសលមូលានិ អលោភោ កុសលមូលំ អឧោ-
សោ កុសលមូលំ អមោហោ កុសលមូលំ ។ ១ុត្តញ្ហេតំ
ភគវតា តីណិមានិ ។ បេ ។ ន ភិក្ខវេ អលោភជេន
កម្មេន អឧោសជេន កម្មេន អមោហជេន កម្មេន
និរយោ បញ្ញាយតិ តិរច្ឆានយោនិ បញ្ញាយតិ បិត្តិវិស-
យោ បញ្ញាយតិ យា វា បនញ្ញាបិ កាចិ ទុគ្គតិយោ
អថខោ ភិក្ខវេ អលោភជេន កម្មេន អឧោសជេន
កម្មេន អមោហជេន កម្មេន ឧេវ បញ្ញាយន្តិ
មនុស្ជ្ជ បញ្ញាយន្តិ យា វា បនញ្ញាបិ កាចិ សុគតិ-
យោ ឧេវ ច មនុស្ជ្ជ ច អត្តភាវាភិនិព្ពត្តិយា ឥមានិ
តីណិ កុសលមូលានីតិ ភគវា ជានាតិ បស្ជ្ជតិ ។

ម្នាលភិក្ខុទាំងឡាយ តាមពិត ដោយកម្មកើតអំពីលោភ: ដោយកម្មកើតអំពីទោស: ដោយកម្មកើតអំពីមោហ: នរកទើបប្រាកដ កំណើតតិរច្ឆានប្រាកដ វិស័យនៃប្រេតប្រាកដ ឬក៏ពួកទុគ្គតិឯណានីមួយសូម្បីដទៃ ដើម្បីញ៉ាំងអត្តភាពឲ្យកើតក្នុងនរក ក្នុងកំណើតតិរច្ឆាន ក្នុងវិស័យនៃប្រេត (ក៏ប្រាកដ) នេះអកុសលមូល ៣ ព្រះមានព្រះភាគទ្រង់ជ្រាប ទ្រង់ឃើញដូច្នេះ ។ ព្រះមានព្រះភាគ ព្រះអង្គឃើញឫសគល់ ។ បេ ។ ឃើញសមុទ័យ យ៉ាងនេះឯង ។ កុសលមូល មាន៣គឺ អលោភ: ជាកុសលមូល អទោស: ជាកុសលមូល អមោហ: ជាកុសលមូល ។ ដូចព្រះមានព្រះភាគ ត្រាស់ព្រះតម្រាស់នេះថា កុសលមូលទាំង ៣ នេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មិនមែនដោយកម្មកើតអំពីអលោភ: ដោយកម្មកើតអំពីអទោស: ដោយកម្មកើតអំពីអមោហ:ទេ ដែលនរកប្រាកដ កំណើតតិរច្ឆានប្រាកដ វិស័យនៃប្រេតប្រាកដ ឬក៏ពួកទុគ្គតិឯណានីមួយសូម្បីដទៃ(ប្រាកដ) ម្នាលភិក្ខុទាំងឡាយ តាមពិត ដោយកម្មកើតអំពីអលោភ: ដោយកម្មកើតអំពីអទោស: ដោយកម្មកើតអំពីអមោហ: ពួកទេវតាទើបប្រាកដ ពួកមនុស្សប្រាកដ ឬក៏ពួកសុគតិ ឯណានីមួយសូម្បីដទៃ ដើម្បីញ៉ាំងអត្តភាពឲ្យកើត ក្នុងទេវតានិងមនុស្ស (ក៏ប្រាកដ) នេះ កុសលមូល ៣ ព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញដូច្នេះ ។

ឯវម្ៀ ភគវា មូលឧស្ឆារី ។ បេ ។ សមុឧយឧស្ឆារី ។ រុត្តញ្ហេតំ ភគវតា យេកេចិ ភិក្ខវេ ធម្មា អកុសលា អកុសលភាគិយា អកុសលបក្ខិកា សព្វេ តេ អវិជ្ជាមូលកា អវិជ្ជាសមោសរណា អវិជ្ជាសមុក្ឃាតា សព្វេ តេ សមុក្ឃាតំ គច្ឆន្តីតិ ភគវា ជានាតិ បស្ឆតិ ។ ឯវម្ៀ ភគវា មូលឧស្ឆារី ។ បេ ។ សមុឧយឧស្ឆារី ។ រុត្តញ្ហេតំ ភគវតា យេកេចិ ភិក្ខវេ ធម្មា កុសលា កុសលភាគិយា កុសលបក្ខិកា សព្វេ តេ អប្ឆមា-ឧមូលកា អប្ឆមាឧសមោសរណា អប្ឆមាឧោ តេសំ ធម្មានំ អក្ខមក្ខាយតីតិ ភគវា ជានាតិ បស្ឆតិ ។ ឯវម្ៀ ភគវា មូលឧស្ឆារី ។ បេ ។ សមុឧយឧស្ឆារី ។ អថវា ភគវា ជានាតិ បស្ឆតិ អវិជ្ជា មូលំ សង្ខារានំ សង្ខារា មូលំ វិញ្ញាណស្ឆ វិញ្ញាណំ មូលំ ជាមរូបស្ឆ ជាមរូបំ មូលំ សឋ្ឆាយតនស្ឆ សឋ្ឆាយតនំ មូលំ ផស្ឆស្ឆ ផស្ឆោ មូលំ វេឧនាយ វេឧនា មូលំ តណ្ហាយ តណ្ហា មូលំ ឧចាឧានស្ឆ ឧចាឧានំ មូលំ ភវស្ឆ ភវោ មូលំ ជាតិយា ជាតិ មូលំ ជរាមរណស្ឆាតិ ភគវា ជានាតិ បស្ឆតិ ។

ព្រះមានព្រះភាគទ្រង់ឃើញឫសគល់ ។ បេ ។ ឃើញសមុទ័យយ៉ាងនេះ ឯង ។ មួយទៀត ព្រះមានព្រះភាគត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុ ទាំងឡាយ ធម៌ទាំងឡាយណានីមួយ ជាអកុសល ជាចំណែកអកុសល ប្រព្រឹត្តទៅក្នុងពួកអកុសល ធម៌ទាំងអស់នោះ មានអវិជ្ជាជាឫស ប្រជុំចុះ ក្នុងអវិជ្ជា ធម៌ទាំងអស់នោះ ដល់នូវការរបើកឡើង ព្រោះរបើកឡើងនៃ អវិជ្ជា ព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ឃើញឫសគល់ ។ បេ ។ ឃើញសមុទ័យយ៉ាងនេះឯង ។ មួយវិញទៀត ព្រះមានព្រះភាគ ត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង-ឡាយណានីមួយ ជាកុសល ជាចំណែកកុសល ប្រព្រឹត្តទៅក្នុងពួកកុសល ធម៌ទាំងអស់នោះ មានសេចក្តីមិនប្រហែសជាឫស ប្រជុំចុះក្នុងសេចក្តីមិន ប្រហែស សេចក្តីមិនប្រហែសប្រាកដជាកំពូលធម៌ទាំងនោះ ព្រះមានព្រះ ភាគទ្រង់ជ្រាប ទ្រង់ឃើញដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ឃើញឫសគល់ ។ បេ ។ ឃើញសមុទ័យ យ៉ាងនេះឯង ។ ន័យមួយទៀត ព្រះមានព្រះភាគ ទ្រង់ជ្រាបទ្រង់ឃើញថា អវិជ្ជាជាមូលនៃសង្ខារ សង្ខារជាមូលនៃវិញ្ញាណ វិញ្ញាណ ជាមូលនៃនាមរូប នាមរូប ជាមូលនៃសឡាយតនៈ សឡាយតនៈ ជាមូលនៃផស្សៈ ផស្សៈ ជាមូលនៃវេទនា វេទនា ជាមូលនៃតណ្ហា តណ្ហា ជាមូលនៃឧបាទាន ឧបាទាន ជាមូលនៃភព ភព ជាមូលនៃជាតិ ជាតិ ជាមូលនៃជរាមរណៈ ព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញដូច្នេះ ។

ឯវម្ៀ ភគវា មូលឧស្ឆារី ។ បេ ។ សមុឧយឧស្ឆារី[1] ។ រុត្តញ្ហោតំ[2] ភគវតា យេកេចិ ភិក្ខវេ ធម្មា អកុសលា អកុសលភាគិយា អកុសលបក្ខិកា សព្វេ តេ អវិជ្ជា-មូលកា អវិជ្ជាសមោសរណា អវិជ្ជាសមុក្ឃាតា សព្វេ តេ សមុក្ឃាតំ គច្ឆន្តីតិ ភគវា ជានាតិ បស្សតិ ។ ឯវម្ៀ ភគវា មូលឧស្ឆារី ហេតុឧស្ឆារី និទានឧស្ឆារី សម្ភវឧ-ស្ឆារី សមុដ្ឋានឧស្ឆារី អាហារឧស្ឆារី អារម្មណឧស្ឆារី បច្ចយឧស្ឆារី សមុឧយឧស្ឆារីតិ អនេជំ មូលឧស្ឆារឹ ។ ឥច្ចាយស្មា បុណ្ណោតិ ឥច្ចាតិ បឧសង្ខ្យ ។ អាយស្មាតិ បិយវចនំ ។ បុណ្ណោតិ តស្ស ព្រាហ្មណស្ស នាមំ ។

[១១៤] អត្ថិ បញ្ហេន អាគមន្តិ បញ្ហត្ថិកម្ហា អា-គតា បញ្ហំ បុច្ឆិតុកាមម្ហា អាគតា បញ្ហំ សោតុ-កាមា អាគតម្ហាតិ ឯវម្ៀ អត្ថិ បញ្ហេន អាគមំ ។

---

១ ម. ឥតោ បរំ អថវា ជានាតិ បស្សតិ ចក្ខុ មូលំ ចក្ខុរោគានំ សោតំ មូលំ សោត-រោគានំ ឃានំ មូលំ ឃានរោគានំ ជិវ្ហា មូលំ ជិវ្ហារោគានំ កាយោ មូលំ កាយរោគានំ មនោ មូលំ ចេតសិកានំ ទុក្ខានន្តិ ភគវា ជានាតិ បស្សតិ ។ ឯវម្ៀ ភគវា មូល-ទស្សាវី ហេតុទស្សាវី ។ ល ។ នាមន្តិ ទិស្សន្តិ ។ ២ ម. រុត្តញ្ហោតំ ភគវា ។ ល ។ គច្ឆន្តីតិ ភគវា ជានាតិ បស្សតីតិ នត្ថិ ។

ព្រះមានព្រះភាគ ទ្រង់ឃើញឫសគល់ ។ បេ ។ ឃើញសមុទ័យយ៉ាងនេះឯង ។ ហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយណានីមួយ ជាអកុសល ជាចំណែកនៃអកុសល ប្រព្រឹត្តទៅ ក្នុងពួកនៃអកុសល ធម៌ទាំងអស់នោះ មានអវិជ្ជាជាឫស ប្រជុំចុះក្នុងអវិជ្ជា ធម៌ទាំងអស់នេះ ដល់នូវការរបើកឡើង ព្រោះរបើកឡើងនៃអវិជ្ជា ព្រះមានព្រះភាគទ្រង់ជ្រាបទ្រង់ឃើញ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ឃើញឫសគល់ ឃើញហេតុ ឃើញនិទាន ឃើញសម្ភវ: ឃើញសមុដ្ឋាន ឃើញអាហារ ឃើញអារម្មណ៍ ឃើញបច្ច័យ ឃើញសមុទ័យ យ៉ាងនេះឯង ហេតុនោះ (លោកសួរថា) មិនមានការញាប់ញ័រ ទ្រង់ឃើញនូវមូល ។ ពាក្យថា ដូច្នេះ ក្នុងបទថា ព្រះបុណ្ណក:មានអាយុ (ក្រាបទូលសួរ) ដូច្នេះ គឺជាពាក្យតបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា បុណ្ណក: ជាឈ្មោះនៃព្រាហ្មណ៍នោះ ។

[១១២] ពាក្យថា យើងខ្ញុំ មក ដោយត្រូវការសួរប្រស្នា អធិប្បាយថា យើងខ្ញុំ មក មានសេចក្ដីត្រូវការដោយប្រស្នា មក មានប្រាថ្នាសួរប្រស្នា មក មានប្រាថ្នានឹងស្តាប់ប្រស្នា ហេតុនោះ (លោកសួរថា) យើងខ្ញុំ មក ដោយត្រូវការសួរប្រស្នា យ៉ាងនេះឯង ។

អថវា បញ្ហត្ថិកានំ បញ្ហំ បុច្ឆិតុកាមានំ បញ្ហំ សោតុកាមានំ អាគមំ អភិក្កមនំ ឧបសង្កមនំ បយិរុបាសនំ អត្ថីតិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។ អថវា បញ្ហាគមោ តុយ្ហំ អត្ថិ ត្វម្បិ បហុ វិសវី[១] អលមត្តោ មយា បុច្ឆិតំ កថេតុំ វិសជ្ជេតុំ សន្ទ-ស្សេតុំ ភណិតុន្តិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។

[១១៥] កឹនិស្សិតា ឥសយោ មនុជាតិ កឹនិស្សិ-តាតិ កឹ និស្សិតា អាសិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តា ។ ឥសយោតិ ឥសិនាមកា យេកេចិ ឥសិប្បព្វជ្ជំ បព្វជិតា អាជីវកា និគ្គន្ថា ជដិលា តាបសា ។ មនុជាតិ មនុស្សា វុច្ចន្តីតិ កឹនិស្សិតា ឥសយោ មនុជា ។

១ ម. ត្វំបិ ពហុ វីសតិ ។

មួយទៀត ការមក ការឈានមកចំពោះ ការចូលទៅរក ការចូលទៅ អង្គុយជិត (នៃយើងខ្ញុំ ជាអ្នកមានសេចក្ដីត្រូវការដោយប្រាជ្ញា ជាអ្នក ប្រាថ្នានឹងសួរប្រាជ្ញា ជាអ្នកប្រាថ្នានឹងស្តាប់ប្រាជ្ញា ហេតុនោះ (លោក សួរថា) យើងខ្ញុំមក ដោយត្រូវការសួរប្រាជ្ញា យ៉ាងនេះឯង ។ មួយវិញ ទៀត ការមកដោយប្រាជ្ញាមានចំពោះព្រះអង្គ ព្រះអង្គមានបញ្ញាច្រើន មានព្យាយាម អាចដើម្បីសម្ដែង ដោះស្រាយ ពន្យល់ ពោលប្រាជ្ញា ដែលខ្ញុំព្រះអង្គសួរហើយ ហេតុនោះ (លោកសួរថា) យើងខ្ញុំមក ដោយត្រូវការសួរប្រាជ្ញា យ៉ាងនេះឯង ។

[១១ថ] ពាក្យថា ចុះពួកមនុស្ស គឺឥសី អាស្រ័យអ្វី ត្រង់ ពាក្យថា អាស្រ័យអ្វី គឺអាស្រ័យ ផ្ដេកផ្ដួល ភ្ជាប់ ចូលទៅជិតដល់ ស្រេបចុះ ជឿនូវអ្វី ។ ពាក្យថា ឥសី គឺជនទាំងឡាយណានីមួយ ជាអាជីវក និគ្រន្ថ ជដិល តាបស ដែលបួសជាឥសី ជនទាំងនោះ ឈ្មោះថា ឥសី ។ ពួកមនុស្ស លោកហៅថា មនុស្ស ហេតុនោះ (លោកសួរថា) ចុះពួកមនុស្ស គឺឥសី អាស្រ័យអ្វី ។

[១១៦] ខត្តិយា ព្រាហ្មណា ទេវតានន្តិ ខត្តិយាតិ យេកេចិ ខត្តិយជាតិកា ។ ព្រាហ្មណាតិ យេកេចិ ភោវាទិកា ។ ទេវតានន្តិ អាជីវកសាវកានំ អាជីវ-កា ទេវតា និគ្គន្ថសាវកានំ និគ្គន្ថា ទេវតា ជដិ-លសាវកានំ ជដិលា ទេវតា បរិព្វាជកសាវកានំ បរិព្វាជកា ទេវតា អារុទ្ធកសាវកានំ អារុទ្ធកា ទេវតា ហត្ថិវតិកានំ ហត្ថី ទេវតា អស្សវតិកានំ អស្សា ទេវតា គោវតិកានំ គាវោ ទេវតា កុក្កុរវតិ-កានំ កុក្កុរា ទេវតា ការការតិកានំ ការការា ទេវតា វាសុទេវវតិកានំ វាសុទេវោ ទេវតា ពលទេវវតិកានំ ពលទេវោ ទេវតា បុណ្ណភទ្ទវតិកានំ បុណ្ណភទ្ទោ ទេវតា មណិភទ្ទវតិកានំ មណិភទ្ទោ ទេវតា អគ្គិវតិកានំ អគ្គិ ទេវតា ជាតវតិកានំ ជាតា ទេវតា សុវណ្ណវតិកានំ សុវណ្ណា ទេវតា យក្ខវតិកានំ យក្ខា ទេវតា អសុរវតិកានំ អសុរា ទេវតា គន្ធព្វវតិកានំ គន្ធព្វា ទេវតា

[១១៦] *អធិប្បាយពាក្យថា ក្សត្រនិងព្រាហ្មណ៍ ទើបបានសម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ ត្រង់ពាក្យថា ក្សត្រ គឺជនទាំងឡាយណានីមួយ មានជាតិជាក្សត្រ ។ ពាក្យថា ព្រាហ្មណ៍ គឺជនទាំងឡាយណានីមួយ ជាកោវាទី ។ ពាក្យថា ដល់ទេវតាទាំងឡាយ គឺពួកអាជីវក ជាទេវតារបស់ពួកសាវ័កនៃអាជីវក ពួកនិគ្រន្ថ ជាទេវតារបស់ពួកសាវ័កនៃនិគ្រន្ថ ពួកជដិល ជាទេវតារបស់ពួកសាវ័កនៃជដិល ពួកបរិព្វាជក ជាទេវតារបស់ពួកសាវ័កនៃបរិព្វាជក ពួកអារុទ្ធកៈ ជាទេវតារបស់ពួកសាវ័កនៃអារុទ្ធកៈ ពួកដំរី ជាទេវតារបស់អ្នកប្រព្រឹត្តវត្តដំរី ពួកសេះ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តសេះ ពួកគោ ជាទេវតារបស់អ្នកអ្នកប្រព្រឹត្តវត្តគោ ពួកឆ្កែ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តឆ្កែ ពួកក្អែក ជាទេវតារបស់ពួកអ្នកប្រព្រឹត្តវត្តក្អែក វាសុទេព ជាទេវតារបស់អ្នកប្រព្រឹត្តវត្តវាសុទេព ពលទេព ជាទេវតារបស់អ្នកប្រព្រឹត្តវត្តពលទេព បុណ្ណ-ភទ្ទៈ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តបុណ្ណភទ្ទៈ មណិភទ្ទៈ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តមណិភទ្ទៈ ក្ងើងជាទេវតារបស់អ្នកប្រព្រឹត្តវត្តក្ងើង ពួកនាគ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តនាគ ពួកគ្រុទ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តគ្រុទ ពួកយក្ស ជាទេវតារបស់អ្នកប្រព្រឹត្តវត្តយក្ស ពួកអសុរ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តអសុរ ពួកគន្ធព្ធ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តគន្ធព្ធ*

មហារាជវតិកានំ មហារាជា ទេវតា ចន្ទវតិកានំ ចន្ទោ ទេវតា សុរិយវតិកានំ សុរិយោ ទេវតា ឥន្ទវតិកានំ ឥន្ទោ ទេវតា ព្រហ្មវតិកានំ ព្រហ្មា ទេវតា ទេវវតិកានំ ទេវា ទេវតា ទិសាវតិកានំ ទិសា ទេវតា យេ យេសំ ឧក្ខិណោយ្យា តេ តេសំ ទេវតាតិ ខត្តិយា ព្រាហ្មណា ទេវតានំ ។

[១១៧] យញ្ញមកប្ប៊ីសុ[១] បុថូជ លោកេតិ យញ្ញោ រុច្ចតិ ទេយ្យធម្មោ ចីវរបិណ្ឌាចាតសេនាសន-កិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ ចានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ ។ យញ្ញមកប្ប៊ីសូតិ យេបិ យញ្ញ ឯសន្តិ ភវេសន្តិ បរិយេ-សន្តិ ចីវរបិណ្ឌាចាតសេនាសនកិលានប្បច្ចយភេសជ្ជ-បរិក្ខារំ អន្នំ ចានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ តេបិ យញ្ញ ភកប្បន្តិ ។

---

១ ម. យញ្ញមកប្ប យ៊ីសុ ។

មហារាជ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តមហារាជ ព្រះចន្ទ្រ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តព្រះចន្ទ្រ ព្រះអាទិត្យ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តព្រះអាទិត្យ ព្រះឥន្ទ្រ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តព្រះឥន្ទ្រ ព្រហ្ម ជាទេវតារបស់អ្នកប្រព្រឹត្តវត្តព្រហ្ម ពួកទេវតា ជាទេវតារបស់អ្នកប្រព្រឹត្តវត្តទេវតា ទិស ជាទេវតារបស់អ្នកប្រព្រឹត្តវត្តទិស ជនទាំងឡាយណា ជាទក្ខិ-ណេយ្យបុគ្គលរបស់ពួកជនណា ជនទាំងនោះ ជាទេវតារបស់ពួកជននោះ ហេតុនោះ (លោកសួរថា) ក្សត្រនិងព្រាហ្មណ៍ ទើបបានសម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ ។

[១១៧] ពាក្យថា ច្រើននាក់ ក្នុងលោកនេះ ទើបបានសម្រេចយញ្ញៈ សេចក្ដីថា ទេយ្យធម៌ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលា-នប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្ការកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្ងាត់អាស្រ័យ គ្រឿងប្រទីប លោកហៅថា យញ្ញៈ ។ ពាក្យថា ទើបបានសម្រេចយញ្ញៈ គឺពួកជនណា ស្វែងរក ស្វះស្វែងរក ដើររកនូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្ការកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្ងាត់អាស្រ័យ គ្រឿងប្រទីប ពួកជនទាំងនោះ ឈ្មោះថា សម្រេចយញ្ញៈ ។

យេបិ យញ្ញ អកិសន្ធ្ហេន្តិ ចីវរបិណ្ឌាចាតសេនាសន-
គិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្ធំ ចានំ វត្ថំ យានំ
មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ
តេបិ យញ្ញ ភាសន្តិ ។ យេបិ យញ្ញ ទេន្តិ យជន្តិ
បរិចូជន្តិ ចីវរបិណ្ឌាចាតសេនាសនគិលានប្បច្ចយ-
ភេសជ្ជបរិក្ខារំ អន្ធំ ចានំ វត្ថំ យានំ មាលា
គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ តេបិ យញ្ញ
ភាសន្តិ ។ បុថូតិ យញ្ញ ភ ឯតេ បុថូ យញ្ញយជ្ជា[1]
ភ ឯតេ បុថូ ឧក្ខិណោយ្យា ភ ឯតេ បុថូ ។ ភវ
យញ្ញ ភ ឯតេ បុថូ[2] ។ ឯតេ យញ្ញ បុថូ
ចីវរបិណ្ឌាចាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារ
អន្ធំ ចានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ
សេយ្យាវសថំ បទីបេយ្យំ ឯវ យញ្ញ ភ ឯតេ
បុថូ ។ ភវ យញ្ញយជ្ជា ភ ឯតេ បុថូ ។ ឯតេ
យញ្ញយជ្ជា បុថូ ខត្តិយា ច ព្រាហ្មណា ច វេស្សា
ច សុទ្ធា ច ភហាជ្ជា ច បញ្ជិតា ច ទេវ ច
មនុស្ស ច ឯវ យញ្ញយជ្ជា ភ ឯតេ បុថូ ។

---

១ ម. យញ្ញយាជ្ជា ។ ២ ម. បុថូ ពហុកានំ ។

សូម្បីពួកជនណា តាក់តែងនូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្ការកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ពួកជនទាំងនោះ ក៏ឈ្មោះថា សម្រេចយញ្ញៈ ។ ពួកជនណា ឲ្យ បូជាលះបង់នូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្ការកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ជនទាំងនោះ ក៏ឈ្មោះថា សម្រេចយញ្ញៈ ។ ពាក្យថា ច្រើន គឺពួកយញ្ញនុ៎ះច្រើន ឬពួកអ្នកបូជាយញ្ញៈនុ៎ះច្រើន ឬក៏ពួកជនដែលគួរដល់ទក្ខិណានុ៎ះ ច្រើន ។ ពួកយញ្ញៈនុ៎ះ ច្រើន តើដូចម្តេច ។ ពួកយញ្ញៈនុ៎ះ មានច្រើន គឺ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្ការកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ពួកយញ្ញៈនុ៎ះ មានច្រើន យ៉ាងនេះ ។ ពួកអ្នកបូជាយញ្ញៈនុ៎ះ មានច្រើន តើដូចម្តេច ។ ពួកអ្នកបូជាយញ្ញៈនុ៎ះ មានច្រើន គឺក្សត្រ ព្រាហ្មណ៍ អ្នកជំនួញ អ្នកគ្រួ គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ពួកអ្នកបូជាយញ្ញនុ៎ះ មានច្រើន យ៉ាងនេះ ។

ឧកដំ ឧក្ខិណោយ្យា វ ឯតេ បុថូ ។ ឯតេ ឧក្ខិណោយ្យា
បុថូ សមណាព្រាហ្មណា យាចកាវណិពូកសាវកា
ឯវំ ឧក្ខិណោយ្យា វ ឯតេ បុថូ ។ ឥធ លោកេ តិ
មនុស្សលោកេ តិ យញ្ញមកប្ផឿសុ បុថូធ លោកេ ។

[១១៨] បុច្ឆាមិ តំ ភគវ ព្រូហិ មេ ឥន្ធ បុច្ឆាតិ
តិស្សោ បុច្ឆា អនិជ្ជជោតនា បុច្ឆា ឧជ្ជសំសនា
បុច្ឆា វិមតិច្ឆេទនា បុច្ឆា ។

ឥតមា អនិជ្ជជោតនា បុច្ឆា ។ បកតិយា
លក្ខណំ អញ្ញាតំ ហោតិ អនិជ្ជំ អតុលិតំ អតិរិតំ
អវិភាវិតំ អវិភូតំ ឥស្ស ញ្ញាណាយ ឧស្សជ្ជាយ
តុលជ្ជាយ តិរណាយ វិភាវនត្ថាយ វិភូតត្ថាយ បញ្ហ
បុច្ឆតិ អយំ អនិជ្ជជោតនា បុច្ឆា ។

ពួកជនដែលគួរដល់ទក្ខិណានុ៎ះ មានច្រើន តើដូចម្តេច ។ ពួកជនដែលគួរដល់ទក្ខិណានុ៎ះ មានច្រើន គឺសមណព្រាហ្មណ៍ ស្មូម ជនអ្នកពណ៌នា ហើយសូម និងសាវ័ក ពួកជនដែលគួរដល់ទក្ខិណានុ៎ះ មានច្រើនយ៉ាងនេះ ។ ពាក្យថា ក្នុងលោកនេះ គឺក្នុងមនុស្សលោក ហេតុនោះ លោកសួរថា ច្រើនគ្នា ក្នុងលោកនេះ សម្រេចយញ្ញៈ ។

[១១៨] អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ ទូលសួរព្រះអង្គ សូមព្រះអង្គ ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ ពាក្យថា សួរ បានដល់ ការសួរ ៣ គឺការសួរសម្រាប់បំភ្ញីសេចក្តីដែលមិនយល់ ១ ការសួរសម្រាប់ប្រៀបផ្ទឹមសេចក្តីដែលខ្លួនយល់ហើយ ១ ការសួរសម្រាប់កាត់សេចក្តីសង្ស័យ ១ ។

ការសួរសម្រាប់បំភ្ញីសេចក្តីដែលមិនយល់ តើដូចម្តេច ។ លក្ខណៈជាធម្មជាត ដែលបុគ្គលមិនបានដឹង មិនបានឃើញ មិនបានថ្ងឹង មិនបានពិចារណា មិនបានយល់ច្បាស់ មិនបានប្រាកដដោយប្រក្រតី បុគ្គលសួរប្រាស្នាដើម្បីដឹង ឃើញ ថ្ងឹង ពិចារណា ដើម្បីប្រយោជន៍ដល់ការយល់ច្បាស់ ដើម្បីប្រយោជន៍ឲ្យប្រាកដ នូវលក្ខណៈនោះ នេះ ការសួរសម្រាប់បំភ្ញីសេចក្តីដែលមិនយល់ ។

កតមា ជិដ្ឋសំសន្ធនា បុច្ឆា ។ បកតិយា លក្ខណំ ញាតំ ហោតិ ជិដ្ឋំ តុលិតំ តីរិតំ វិការិតំ វិភូតំ អញ្ញេហិ បណ្ឌិតេហិ សទ្ធឹ សំសន្ធនត្ថាយ បញ្ហ បុច្ឆតិ អយំ ជិដ្ឋសំសន្ធនា បុច្ឆា ។

កតមា វិមតិច្ឆេទនា បុច្ឆា ។ បកតិយា សំ-សយំ បក្ខន្ទោ ហោតិ វិមតឺ បក្ខន្ទោ ទ្វេធ្ឫក-ជាតោ ឯវំ នុ ខោ ន នុ ខោ កិន្នុ ខោ កថំ នុខោតិ សោ វិមតិច្ឆេទនត្ថាយ បញ្ហ បុច្ឆតិ អយំ វិមតិច្ឆេទនា បុច្ឆា ។ ឥមា តិស្សោ បុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា មនុស្សបុច្ឆា អមនុស្ស-បុច្ឆា ជិម្ហិតបុច្ឆា ។

កតមា មនុស្សបុច្ឆា ។ មនុស្សា ពុទ្ធំ ភគវន្តំ ឧបសង្ក្រមិត្វា បញ្ហ បុច្ឆន្តិ ភិក្ខូ បុច្ឆន្តិ ភិក្ខុនិយោ បុច្ឆន្តិ ឧចាសកា បុច្ឆន្តិ ឧចាសិកាយោ បុច្ឆន្តិ រាជានោ បុច្ឆន្តិ ខត្តិយា បុច្ឆន្តិ ព្រាហ្មណា បុច្ឆន្តិ វេស្សា បុច្ឆន្តិ សុទ្ទា បុច្ឆន្តិ គហដ្ឋា បុច្ឆន្តិ បព្ជ-ជិតា បុច្ឆន្តិ អយំ មនុស្សបុច្ឆា ។

ការសួរសម្រាប់ប្រៀបផ្ទឹមសេចក្តីដែលខ្ជួនយល់ហើយ តើដូចម្តេច ។ លក្ខណៈ ជាធម្មជាត ដែលបុគ្គលបានដឹង បានឃើញ បានថ្វឹង បានពិចារណា បានយល់ច្បាស់ ប្រាកដដោយប្រក្រតី បុគ្គលសួរ ប្រស្នា ដើម្បីប្រយោជន៍ដល់ការប្រៀបផ្ទឹម ជាមួយនឹងបណ្ឌិតទាំងឡាយ ឯទៀត នេះ ការសួរសម្រាប់ប្រៀបផ្ទឹមសេចក្តីដែលខ្ជួនយល់ហើយ ។

ការសួរសម្រាប់កាត់សេចក្តីសង្ស័យ តើដូចម្តេច ។ បុគ្គលស្ទុះទៅកាន់សេចក្តីសង្ស័យដោយប្រក្រតី ស្ទុះទៅកាន់សេចក្តីងឿងឆ្ងល់ មានចិត្តបែកជាពីរថា យ៉ាងនេះទេឬ ឬមិនមែនទេ ហេតុដូចម្តេចហ្ន៎ ប្រការដូចម្តេចហ្ន៎ បុគ្គលនោះ សួរប្រស្នាដើម្បីកាត់សេចក្តីសង្ស័យ នេះ ការសួរសម្រាប់កាត់សេចក្តីសង្ស័យ ។ នេះ ការសួរ ៣ ។

ការសួរ ៣ ដទៃទៀត គឺការសួររបស់មនុស្ស ១ ការសួររបស់អមនុស្ស ១ ការសួររបស់ពុទ្ធនិម្មិត ១ ។

ការសួររបស់មនុស្ស តើដូចម្តេច ។ មនុស្សទាំងឡាយចូលទៅគាល់ព្រះពុទ្ធមានព្រះភាគសួរប្រស្នា គឺពួកភិក្ខុសួរ ពួកភិក្ខុនីសួរ ពួកឧបាសកសួរ ពួកឧបាសិកាសួរ ពួកព្រះរាជាសួរ ពួកក្សត្រសួរ ពួកព្រាហ្មណ៍សួរ ពួកអ្នកជំនួញសួរ ពួកអ្នកគ្រួសួរ ពួកគ្រហស្ថសួរ ពួកបព្វជិតសួរ នេះ ការសួររបស់មនុស្ស ។

កតមា អមនុស្សបុច្ឆា ។ អមនុស្សា ពុទ្ធំ ភគវន្តំ ឧបសង្កមិត្វា បញ្ហំ បុច្ឆន្តិ ជាតា បុច្ឆន្តិ សុបណ្ណា បុច្ឆន្តិ យក្ខា បុច្ឆន្តិ អសុរា បុច្ឆន្តិ គន្ធព្ពា បុច្ឆន្តិ មហារាជានោ បុច្ឆន្តិ ឥន្ទា បុច្ឆន្តិ ព្រហ្មានោ បុច្ឆន្តិ ទេវតាយោ បុច្ឆន្តិ អយំ អមនុ-ស្សបុច្ឆា ។

កតមា និម្មិតបុច្ឆា ។ យំ ភគវា រូបំ អភិនិម្មិ-ជាតិ មនោមយំ សព្វង្គប្បច្ចង្គំ អហីនិន្ទ្រិយំ សោ និម្មិតោ ពុទ្ធំ ភគវន្តំ ឧបសង្កមិត្វា បញ្ហំ បុច្ឆតិ ភគវា វិសជ្ជេតិ អយំ និម្មិតបុច្ឆា ។ ឥមា តិស្សោ បុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា អត្តត្ថបុច្ឆា បរត្ថបុច្ឆា ឧភយត្ថបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា ទិដ្ឋធម្មិកត្ថបុច្ឆា សម្ប-រាយិកត្ថបុច្ឆា បរមត្ថបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា អនវជ្ជត្ថបុច្ឆា និក្កិលេ-សបុច្ឆា ឱទានត្ថបុច្ឆា ។

ការសួររបស់អមនុស្ស តើដូចម្តេច ។ អមនុស្សទាំងឡាយចូលទៅគាល់ព្រះពុទ្ធមានព្រះភាគ សួរប្រស្នា គឺពួកនាគសួរ ពួកគ្រុឌសួរ ពួកយក្សសួរ ពួកអសុរសួរ ពួកគន្ធព្វសួរ ពួកមហារាជសួរ ពួកព្រះឥន្ទ្រសួរ ពួកព្រហ្មសួរ ពួកទេវតាសួរ នេះ ការសួររបស់អមនុស្ស ។

ការសួររបស់ពុទ្ធនិម្មិត តើដូចម្តេច ។ ព្រះមានព្រះភាគនិម្មិតរូបណាដ៏សម្រេចដោយព្រះទ័យ មានអវយវៈតូចធំគ្រប់សព្វ មានឥន្ទ្រិយមិនខ្វះខាត ពុទ្ធនិម្មិតនោះចូលទៅគាល់ព្រះពុទ្ធមានព្រះភាគសួរប្រស្នា ព្រះមានព្រះភាគទ្រង់ដោះស្រាយ នេះ ការសួររបស់ពុទ្ធនិម្មិត ។ នេះ ការសួរ ៣ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍របស់ខ្លួន ១ ការសួរប្រយោជន៍របស់បុគ្គលដទៃ ១ ការសួរប្រយោជន៍ទាំងពីរ ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ការសួរប្រយោជន៍ក្នុងបរលោក ១ ការសួរប្រយោជន៍ដ៏ក្រៃលែង គឺព្រះនិព្វាន ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍មិនមានទោស ១ ការសួរប្រយោជន៍មិនមានសេចក្តីសៅហ្មង ១ ការសួរប្រយោជន៍ដ៏ផូរផង់ ១ ។

អបរាបិ តិស្សោ បុច្ឆា អតីតបុច្ឆា អនាគតបុច្ឆា បច្ចុប្បន្នបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា អជ្ឈត្តបុច្ឆា ពហិទ្ធាបុច្ឆា អជ្ឈត្តពហិទ្ធាបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា កុសលបុច្ឆា អកុស-លបុច្ឆា អព្យាកតបុច្ឆា ។

អបរាបិ តិស្សោ បច្ឆា ខន្ធបុច្ឆា ធាតុបុច្ឆា អាយតនបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា សតិប្បដ្ឋានបុច្ឆា សម្ម-ប្បធានបុច្ឆា ឥទ្ធិបាទបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា ឥន្ទ្រិយបុច្ឆា ពលបុច្ឆា ពោជ្ឈង្គបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា មគ្គបុច្ឆា ផលបុច្ឆា និព្ពានបុច្ឆា ។

ការសួរ ៣ ដទៃទៀត គឺការសួរហេតុជាអតីត ១ ការសួរហេតុជាអនាគត ១ ការសួរហេតុជាបច្ចុប្បន្ន ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរធម៌ខាងក្នុង ១ ការសួរធម៌ខាងក្រៅ ១ ការសួរធម៌ទាំងខាងក្នុងទាំងខាងក្រៅ ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរធម៌ជាកុសល ១ ការសួរធម៌ជាអកុសល ១ ការសួរធម៌ជាអព្យាកត ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរខន្ធ ១ ការសួរធាតុ ១ ការសួរអាយតនៈ ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរសតិប្បដ្ឋាន ១ ការសួរសម្មប្បធាន ១ ការសួរឥទ្ធិបាទ ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរឥន្ទ្រិយ ១ ការសួរពលៈ ១ ការសួរពោជ្ឈង្គៈ ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរមគ្គ ១ ការសួរផល ១ ការសួរនិព្វាន ១ ។

បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

បុច្ឆាមិ តន្តិ បុច្ឆាមិ តំ យាចាមិ តំ អជ្ឈេសាមិ តំ បសាទេមិ តំ ភគវស្ស មេតិ បុច្ឆាមិ តំ ។ ភគវាតិ ការណជិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ។ ព្រូហិ មេ តន្តិ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បការាសេហីតិ បុច្ឆាមិ តំ ភគវ ព្រូហិ មេ តំ ។ តេនាហ សោ ព្រាហ្មណោ

អនេជំ មូលទស្ស្ទាវី (ឥច្ចាយស្មា បុណ្ណកោ)

អត្ថិ បញ្ហេន អាគមំ

ភីនិស្ស្ជិតា ឥសយោ មនុជា

ខត្តិយា ព្រាហ្មណា ទេវតានំ

យញ្ញមកប្ប៊ីសុ បុថូជ លោកេ

បុច្ឆាមិ តំ ភគវ ព្រូហិ មេ តន្តិ ។

ពាក្យថា ខ្ញុំព្រះអង្គទូលសួរព្រះអង្គ គឺខ្ញុំព្រះអង្គទូលសួរព្រះអង្គ អង្វរព្រះអង្គ អារាធនាព្រះអង្គ ញ៉ាំងព្រះអង្គឲ្យជ្រះថ្លា សូមព្រះអង្គ ប្រាប់ (សេចក្ដីនោះ) ដល់ខ្ញុំព្រះអង្គ ហេតុនោះ (លោកសួរថា) ខ្ញុំ ព្រះអង្គទូលសួរព្រះអង្គ ។ ពាក្យថា បពិត្រព្រះមានព្រះភាគ នេះ គឺ ពាក្យហៅ ដោយគោរព ។ បេ ។ ការបញ្ញត្តថា មានព្រះភាគ នេះ កើតហើយ ព្រោះការត្រាស់ដឹង ។

ពាក្យថា សូមព្រះអង្គប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គ គឺសូម ព្រះអង្គពោល ប្រាប់ សម្ដែង បញ្ញត្ត ផ្ដើម បើក ចែករលែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (លោកសួរថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះ អង្គទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

(ព្រះបុណ្ណក:មានអាយុ ក្រាបទូលសួរថា) យើងខ្ញុំមកដោយ ត្រូវការសួរប្រស្នាចំពោះព្រះអង្គ ជាបុគ្គលមិនមានការញ្ជាប់ ញ័រ ឃើញនូវមូល ចុះពួកមនុស្ស គឺឥសី ក្សត្រនិង ព្រាហ្មណ៍ ជាច្រើននាក់ ក្នុងលោកនេះ អាស្រ័យអ្វី ទើបបានសម្រេចយញ្ញ: ដល់ទេវតាទាំងឡាយ បពិត្រព្រះ មានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់ សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គ ។

[១១៩] យេកេចិមេ ឥសយោ មនុជា
(បុណ្ណកាតិ ភគវា)
ខត្តិយា ព្រាហ្មណា ទេវតានំ
យញ្ញមកប្ឃឹសុ បុថូជ លោកេ
អាសឹសមានា បុណ្ណក ឥត្ថតំ[១]
ជរំ សិតា យញ្ញមកប្ឃយឹសុ ។

[១២០] យេកេចិមេ ឥសយោ មនុជាតិ យេ-កេចិមេតិ[២] សព្ពេ សព្ពំ សព្ពថា សព្ពំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ យេកេចិមេតិ ។ ឥសយោតិ ឥសិនាមកា យេកេចិ ឥសិប្ឃព្ពជ្ជំ បព្ជិតា អាជីវកា និក្ខន្តា ជដិលា តាបសា ។ មនុ-ជាតិ មនុស្សា រុច្ចន្តីតិ យេកេចិមេ ឥសយោ មនុ-ជា ។ បុណ្ណកាតិ ភគវា តំ[៣] ព្រាហ្មណំ ជាមេន អាលបតិ ។ ភគវាតិ ការណជិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ បុណ្ណកាតិ ភគវា ។

---

១ ម. ឥត្ថិភាវំ ។ ២ ម. យេកេចីតិ ។ ៣ ម. ឥតោ បរំ តំ ព្រាហ្មណន្ត្យាតិ នត្ថិ ។

[១១៩] (ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ) ពួកមនុស្ស ណានីមួយ គឺឥសី ក្សត្រ និងព្រាហ្មណ៍ ជាច្រើននាក់ ក្នុងលោកនេះ សម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ ម្នាលបុណ្ណកៈ ពួកសត្វទាំងនោះ ប្រាជ្ញាភាពនេះ អាស្រ័យ ជវាទើបបានសម្រេចយញ្ញៈឡើង ។

[១២០] ពាក្យថា ពួកមនុស្ស ណានីមួយ គឺឥសី ត្រង់ពាក្យថា ណានីមួយ គឺ សព្វគ្រប់ សព្វទាំងអស់ ឥតសេសសល់ គ្មានសេសសល់ ពាក្យថា ណានីមួយ នេះជាពាក្យរួបរួម ។ ពាក្យថា ឥសី គឺជនទាំងឡាយ ណានីមួយ ជាអាជីវក និគ្រន្ថ ជដិល តាបស បួសជាឥសី (ជនទាំងនោះ) ឈ្មោះថា ឥសី ។ ពួកមនុស្ស លោកហៅថា មនុស្ស ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកមនុស្ស ណានីមួយ គឺឥសី ។ ពាក្យថា ម្នាលបុណ្ណកៈ គឺព្រះមានព្រះភាគ ទ្រង់ហៅព្រាហ្មណ៍នោះ ដោយចំឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នេះ ជាពាក្យហៅ ដោយគោរព ។ បេ ។ ការបញ្ញត្តថា មានព្រះភាគ នេះ (កើតហើយ) ព្រោះការត្រាស់ដឹង ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ ។

បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

[១២១] ខត្តិយា ព្រាហ្មណា ទេវតានន្តិ ខត្តិយាតិ យេកេចិ ខត្តិយជាតិកា ។ ព្រាហ្មណាតិ យេកេចិ ភោវាទិកា ។ ទេវតានន្តិ អាជីវកសាវកានំ អាជីវកា ទេវតា ។ បេ ។ ឥសាវតិកានំ ឥសា ទេវតា យេ យេសំ ឧក្ខិណោយ្យា តេ តេសំ ទេវតាតិ ខត្តិយា ព្រាហ្មណា ទេវតានំ ។

[១២២] យញ្ញមកប្ឆីសុ បុថូ ឧ លោកេតិ យញ្ញោ រុច្ចតិ ទេយ្យធម្មោ ចីវរបិណ្ឌាចាតសេនាសនគិលានប្ប-ច្ចយភេសជ្ជបរិក្ខារំ អន្នំ ចានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ ។ យញ្ញម-កប្ឆីសូតិ យេបិ យញ្ញ ឯសន្តិ ឧវេសន្តិ បរិយេសន្តិ ចីវរបិណ្ឌាចាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ ចានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ តេបិ យញ្ញ ឧកប្ឆន្តិ ។

[១២១] ពាក្យថា ក្សត្រនិងព្រាហ្មណ៍ (សម្រេចយញ្ញ:) ដល់ទេវតាទាំងឡាយ ត្រង់ពាក្យថា ក្សត្រ គឺជនទាំងឡាយ ណានីមួយ មានជាតិជាក្សត្រិយ៍ ។ ពាក្យថា ព្រាហ្មណ៍ គឺជនទាំងឡាយណានីមួយ ជាកោវាទី ។ ពាក្យថា ដល់ទេវតាទាំងឡាយ គឺពួកអាជីវក ជាទេវតា របស់ពួកសាវ័កនៃអាជីវក ។ បេ ។ ទិសទាំងឡាយ ជាទេវតា របស់អ្នកប្រព្រឹត្តវត្តទិស ពួកជនណា ជាទក្ខិណេយ្យបុគ្គល របស់ពួកជនណា ជនទាំងនោះ ជាទេវតារបស់ពួកជននោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ក្សត្រនិងព្រាហ្មណ៍ (សម្រេចយញ្ញ:) ដល់ទេវតាទាំងឡាយ ។

[១២២] ពាក្យថា ជាច្រើននាក់ ក្នុងលោកនេះ សម្រេចយញ្ញ: សេចក្តីថា ទេយ្យធម៌ គឺចីវរ បិណ្ឌបាត សេនាសន: គិលានប្បច្ចយ-ភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប លោកហៅថា យញ្ញ: ។ ពាក្យថា សម្រេចយញ្ញ: សេចក្តីថា សូម្បីជនទាំងឡាយណា ប្រាថ្នារក ស្វែងរក ស្វះស្វែងរក នូវយញ្ញ: គឺចីវរ បិណ្ឌបាត សេនាសន: គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់-អាស្រ័យ គ្រឿងប្រទីប ជនទាំងនោះ ឈ្មោះថា សម្រេចយញ្ញ: ។

បុជ្ជតិ យញ្ញា វ ឯតេ បុជ្ជ យញ្ញយជ្ជា វ ឯតេ បុជ្ជ ឧក្ខិណោយ្យា វ ឯតេ បុជ្ជ ។ ឆដ្ឋ យញ្ញា វ ឯតេ បុជ្ជ ។ បេ ។ ឯវ ឧក្ខិណោយ្យា វ ឯតេ បុជ្ជ ។ ឥធ លោកេ តិ មនុស្ស្ យលោកេ តិ យញ្ញម-ត្ថាយ បុជ្ជ ឧ លោកេ ។

[១២៣] អាសីសមានា បុណ្ណ្ណ ឥត្ថ តិ អាសី-សមានាតិ រូបប្ប ដិ លាភ អាសីសមានា សទ្ទ ប្ប ដិ-លាភ អាសីសមានា គន្ធ ប្ប ដិ លាភ អាសីសមានា រសប្ប ដិ លាភ អាសីសមានា ផោដ្ឋ ព្ប ដិ លាភ អា-សីសមានា បុត្ត ប្ប ដិ លាភ អាសីសមានា ធ ប្ប ដិ-លាភ អាសីសមានា ធ ន ប្ប ដិ លាភ អាសីសមានា យ ប្ប ដិ លាភ អាសីសមានា ឥ ស្ស រិ ប្ប ដិ លាភ អាសីសមានា ខ ត្តិ ម ហ ស ល ។ អ ត្ត ប្ប-ដិ លាភ អាសីសមានា ព្រ ហ្ម ណ ម ហ ស ល ។ អ ត្ត ប្ប ដិ លាភ អាសីសមានា គ ហ ប ត ម ហ-ស ល ។ អ ត្ត ប្ប ដិ លាភ អាសីសមានា

ពាក្យថា ជាច្រើននាក់ គឺយញ្ញៈទាំងនុ៎ះច្រើន ឬពួកអ្នកស្វែងរកយញ្ញៈនោះ ច្រើន ឬក៏ពួកជនដែលគួរដល់ទក្ខិណានុ៎ះ ច្រើន ។ ពួកយញ្ញៈទាំងនុ៎ះ ច្រើន តើដោយប្រការដូចម្តេច ។ បេ ។ ពួកជនដែលគួរដល់ទក្ខិណា ទាំងនោះច្រើន យ៉ាងនេះ ។ ពាក្យថា ក្នុងលោកនេះ គឺក្នុងមនុស្ស លោក ហេតុនោះ (ទ្រង់ត្រាស់ថា) ជាច្រើននាក់ ក្នុងលោកនេះ សម្រេចយញ្ញៈ ។

[១២៣] *អធិប្បាយពាក្យថា ម្នាលបុណ្ណកៈ (ជនទាំងនោះ) ប្រាថ្នានូវ ភាពនេះ ត្រង់ពាក្យថា ប្រាថ្នា គឺប្រាថ្នាការបានចំពោះរូប ប្រាថ្នាការបាន ចំពោះសំឡេង ប្រាថ្នាការបានចំពោះក្លិន ប្រាថ្នាការបានចំពោះរស ប្រាថ្នា ការបានចំពោះផ្សព្វ ប្រាថ្នាការបានចំពោះកូន ប្រាថ្នាការបានចំពោះប្រពន្ធ ប្រាថ្នាការបានចំពោះទ្រព្យ ប្រាថ្នាការបានចំពោះយស ប្រាថ្នាការបាន ចំពោះភាពជាឥស្សរៈ ប្រាថ្នាការបានចំពោះអត្តភាព ក្នុងត្រកូលនៃខត្តិយ-មហាសាល ប្រាថ្នាការបានចំពោះអត្តភាព ក្នុងត្រកូលនៃព្រាហ្មណមហា-សាល ប្រាថ្នាការបានចំពោះអត្តភាពក្នុងត្រកូល នៃគហបតិមហាសាល*

ចាតុម្មហារាជិកេសុ ទេវេសុ អត្តការ្យដិលាភំ អាសឹ-
សមានា តាវត្តឹសេសុ ទេវេសុ យាមេសុ ទេវេសុ តុសិ-
តេសុ ទេវេសុ និម្មានរតីសុ ទេវេសុ បរនិម្មិតវសវត្តីសុ
ទេវេសុ ព្រហ្មកាយិកេសុ ទេវេសុ អត្តការ្យដិលាភំ
អាសឹសមានា ឥច្ឆមានា សាធិយមានា បត្ថយមានា
បិហយមានា អភិជ្ឌ្យមានាតិ អាសឹសមានា ។
បុណ្ណ្ហក ឥត្ថតន្តិ ឯត្ថ អត្ថការ្យកិនិ ព្ធត្ថ អាសឹសមានា
ឯត្ថ ខត្តិយមហាសាលកុលេ អត្ថការ្យកិនិ ព្ធត្ថ
អាសឹសមានា ឯត្ថ ព្រាហ្មណមហាសាលកុលេ
អត្ថការ្យកិនិ ព្ធត្ថ អាសឹសមានា ឯត្ថ គហបតិ-
មហាសាលកុលេ អត្ថការ្យកិនិ ព្ធត្ថ អាសឹសមានា
ឯត្ថ ចាតុម្មហារាជិកេសុ ទេវេសុ អត្ថការ្យកិនិ ព្ធត្ថ
អាសឹសមានា ឯត្ថ តាវត្តឹសេសុ ទេវេសុ ឯត្ថ
យាមេសុ ទេវេសុ ឯត្ថ តុសិតេសុ ទេវេសុ ឯត្ថ
និម្មានរតីសុ ទេវេសុ ឯត្ថ បរនិម្មិតវសវត្តីសុ ទេវេសុ

ប្រាជ្ញាការបានចំពោះអត្តភាព ក្នុងពួកទេវតា ជាន់ចាតុម្មហារាជិក: ប្រាជ្ញាចង់បាន ត្រេកអរ បំណង ស្រឡាញ់ ជាប់ចិត្ត នូវការបានចំពោះអត្តភាព ក្នុងពួកទេវតាជាន់តាវត្តិង្ស ក្នុងពួកទេវតាជាន់យាម: ក្នុងពួកទេវតាជាន់តុសិត ក្នុងពួកទេវតាជាន់និម្មានរតី ក្នុងពួកទេវតាជាន់បរនិម្មិតវសវត្តី ក្នុងពួកទេវតាដែលប្រព្រឹត្តទៅក្នុងពួកនៃព្រហ្ម ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រាជ្ញា ។ ពាក្យថា ម្នាលបុណ្ណក: (ជនទាំងនោះ ប្រាជ្ញា) នូវភាពនេះ សេចក្តីថា ប្រាជ្ញាការកើតអត្តភាព ក្នុងត្រកូលទាំងនេះ គឺ ប្រាជ្ញាការកើតអត្តភាព ក្នុងត្រកូលខត្តិយមហាសាលនេះ ប្រាជ្ញាការកើតអត្តភាព ក្នុងត្រកូលព្រាហ្មណមហាសាលនេះ ប្រាជ្ញាការកើតអត្តភាព ក្នុងត្រកូលគហបតិមហាសាលនេះ ប្រាជ្ញាការកើតអត្តភាព ក្នុងពួកទេវតាជាន់ចាតុម្មហារាជិក:នេះ ប្រាជ្ញា ចង់បាន ត្រេកអរ បំណង ស្រឡាញ់ ជាប់ចិត្ត នូវការកើតអត្តភាពក្នុងពួកទេវតាជាន់តាវត្តិង្សនេះ ក្នុងពួកទេវតាជាន់យាម:នេះ ក្នុងពួកទេវតាជាន់តុសិតនេះ ក្នុងពួកទេវតាជាន់និម្មានរតីនេះ ក្នុងពួកទេវតាជាន់បរនិម្មិតវសវត្តីនេះ

ឯត្ត ព្រហ្មកាយិកេសុ ទេវេសុ អត្តភាវាភិនិព្ពត្តី អាសឹ-
សមានា ឥច្ឆមានា សាធិយមានា បត្ថយមានា បិហយ-
មានា អភិជប្បមានាតិ អាសឹសមានា បុណ្ណ្ហាក ឥត្ថំ ។

[១២៤] ជរំ សិតា យញ្ញមកប្បយឹសូតិ ជរំ សិ-
តាតិ ជរានិស្សិតា ព្យាធិនិស្សិតា មរណនិស្សិតា
សោកបរិទេវទុក្ខទោមនស្សុបាយាសនិស្សិតា យទេវ
តេ ជាតិនិស្សិតា វា តទេវ តេ ជរានិស្សិតា យ-
ទេវ តេ ជរានិស្សិតា វា តទេវ តេ ព្យាធិនិស្សិ-
តា យទេវ តេ ព្យាធិនិស្សិតា វា តទេវ តេ មរ-
ណនិស្សិតា យទេវ តេ មរណនិស្សិតា វា តទេវ
តេ សោកបរិទេវទុក្ខទោមនស្សុបាយាសនិស្សិតា យ-
ទេវ តេ សោកបរិទេវទុក្ខទោមនស្សុបាយាសនិស្សិ-
តា វា តទេវ តេ កតិនិស្សិតា យទេវ តេ កតិ-
និស្សិតា វា តទេវ តេ ឧបបត្តិនិស្សិតា យទេវ

ក្នុងពួកទេវតាដែលប្រព្រឹត្តទៅក្នុងពួកព្រហ្មនេះ ហេតុនោះ(ទ្រង់ត្រាស់ថា) ម្នាលបុណ្ណក: (ពួកជនទាំងនោះ) ប្រាជ្ញាភាពនេះ ។

[១២៦] អធិប្បាយពាក្យថា អាស្រ័យជរា ទើបបានសម្រេចយ័ញ្ញឡើង ត្រង់ពាក្យថា អាស្រ័យជរា គឺអាស្រ័យជរា អាស្រ័យព្យាធិ អាស្រ័យមរណ: អាស្រ័យសោក សេចក្តីខ្សឹកខ្សួល ទុក្ខ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ សត្វទាំងនោះ អាស្រ័យជាតិ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យជរា ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យជរា ក្នុងកាលណា សត្វទាំងនោះ អាស្រ័យព្យាធិ ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យព្យាធិ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យមរណ: ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យមរណ: ក្នុងកាលណា សត្វទាំងនោះ អាស្រ័យសោក សេចក្តីខ្សឹកខ្សួល ទុក្ខ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យសោក សេចក្តីខ្សឹកខ្សួល ទុក្ខ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យគតិ ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យគតិក្នុងកាលណា សត្វទាំងនោះ អាស្រ័យឧបបត្តិក្នុងកាលនោះ

តេ ឧបបត្តិនិស្សិតា វា តេ តេ បដិសន្ធិនិស្សិតា យេ តេ បដិសន្ធិនិស្សិតា វា តេ តេ ភវនិស្សិ-តា យេ តេ ភវនិស្សិតា វា តេ តេ សំសារ-និស្សិតា យេ តេ សំសារនិស្សិតា វា តេ តេ វដ្ដនិស្សិតា អាសិតា អលីនា ឧបគតា អជ្ឌោសិតា អធិមុត្តាតិ[១] ជវំ សិតា យញ្ញមកប្ប យីសុ ។ តេនាហ ភគវា

យេ កេចិ មេ ឥសយោ មនុជា
(បុណ្ណកាតិ ភគវា)
ខត្តិយា ព្រាហ្មណា ទេវតានំ
យញ្ញមកប្ប យីសុ បុថូ ឧ លោកេ
អាសីសមានា បុណ្ណក ឥត្ថតំ
ជវំ សិតា យញ្ញមកប្ប យីសូតិ ។

---

១ ម. ឥមេ បាហ មវ្ម្ហ ្ បោ ត្ត ្ ក ្ ខ ន អ ្ ហ ្ ហ ិ ្ ស ្ ោ ធ ិ ្ ត ា ។

សត្វទាំងនោះ អាស្រ័យឧបបត្តិក្នុងកាលណា សត្វទាំងនោះ អាស្រ័យ បដិសន្ធិក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យបដិសន្ធិ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យកពក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យ កព ក្នុងកាលណា សត្វទាំងនោះ អាស្រ័យសង្ឃារ ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យសង្ឃារ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យ រដ្ត: អាស្រ័យនៅ ជាប់នៅ ចូលទៅជិតដល់ លិចចុះ ចុះស៊ីប់ ក្នុងកាលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) អាស្រ័យជរ ទើបសម្រេច យញ្ញ:ឡើង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណក:) ពួកមនុស្ស ណានីមួយ គឺឥសី ក្សត្រ និងព្រាហ្មណ៍ ជាច្រើននាក់ ក្នុងលោកនេះ សម្រេចយញ្ញ: ដល់ទេវតាទាំងឡាយ ម្នាលបុណ្ណក: ពួកសត្វទាំងនោះ ប្រាជ្ញាភាពនេះ អាស្រ័យ ជរ ទើបសម្រេចយញ្ញ:ឡើង ។

[១២៥] យេកេចិមេ ឥសយោ មនុជា
(ឥច្ចាយស្មា បុណ្ណកោ)
ខត្តិយា ព្រាហ្មណា ទេវតានំ
យញ្ញមកប្បឹសុ បុថូឝ លោកេ
កច្ចិស្សុ តេ ភគវា យញ្ញបថេ អប្បមត្តា
អតារុំ ជាតិញ្ច ជរញ្ច មារិស
បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។

[១២៦] យេកេចិ មេ ឥសយោ មនុជាតិ យេ-
កេចិមេតិ ។ បេ ។ កច្ចិស្សុ តេ ភគវា យញ្ញប-
ថេ អប្បមត្តាតិ កច្ចិស្សូតិ សំសយបុច្ឆា វិមតិបុច្ឆា
ទ្វេធ្ហ្ការបុច្ឆា អនេកំសបុច្ឆា ឯវំ នុ ខោ ន នុ ខោ
កិន្នុ ខោ កថំ នុ ខោតិ កច្ចិស្សុ ។ តេតិ យញ្ញយ-
ជកា[1] ។ ភគវាតិ ការណជិវចនមេតំ ។ បេ ។ សច្ចិ-
កា បញ្ញត្តិ យទិទំ ភគវាតិ កច្ចិស្សុ តេ ភគវា ។

---

១ ម. យញ្ញយាជកា បុច្ឆន្តិ ។

[១២៥] (បុណ្ណកៈ មានអាយុ ទូលសួរដូច្នេះថា) ពួកមនុស្សណានីមួយ គឺឥសី ក្សត្រ និងព្រាហ្មណ៍ជាច្រើននាក់ក្នុងលោកនេះ សម្រេចយ័ញ្ញដល់ទេវតាទាំងឡាយ បពិត្រព្រះមានព្រះភាគ ពួកមនុស្សទាំងនោះ មិនធ្វេសក្នុងផ្លូវយ័ញ្ញ បពិត្រព្រះអង្គនិរទុក្ខ (មនុស្សទាំងនោះ) ធ្វងជាតិនិងជរាបានដែរឬ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[១២៦] ពាក្យថា ណានីមួយ ក្នុងបទថា ពួកមនុស្សណានីមួយ គឺឥសី ។ បេ ។ អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ពួកមនុស្សទាំងនោះ មិនធ្វេសក្នុងផ្លូវយ័ញ្ញ ធ្វងជាតិនិងជរាបានដែរឬ ត្រង់ពាក្យថា ដែរឬ គឺការសួរដោយសង្ស័យ ការសួរដោយសេចក្តីងឿងឆ្ងល់ ការសួរដោយចិត្តបែកជាពីរ ការសួរដោយចំណែកច្រើនថា យ៉ាងនេះឬ មិនមែនទេឬ ដូចម្តេចហ្ន៎ ដោយប្រការដូចម្តេចហ្ន៎ ហេតុនោះ (លោកសួរថា) ដែរឬ ។ ពាក្យថា មនុស្សទាំងនោះ បានដល់ពួកមនុស្សអ្នកបូជាយ័ញ្ញ ។ ពាក្យថា មានព្រះភាគ នុ៎ះ ជាពាក្យហៅ ដោយគោរព ។ បេ ។ ការបញ្ញត្តថា មានព្រះភាគ នេះ (កើត) ព្រោះការត្រាស់ដឹង ហេតុនោះ (លោកសួរថា) បពិត្រព្រះមានព្រះភាគ មនុស្សទាំងនោះ ដែរឬ ។

យញ្ញបថេ អប្បមត្តាតិ យញ្ញោយេវ វុច្ចតិ យញ្ញបថោ ។ យថា អរិយមគ្គោ អរិយបថោ ទេវមគ្គោ ទេវបថា ព្រហ្មមគ្គោ ព្រហ្មបថោ ឯវមេវ យញ្ញោយេវ វុច្ចតិ យញ្ញបថោ ។ អប្បមត្តាតិ យញ្ញបថេ អប្បមត្តា សក្កច្ចការិនោ សាតច្ចការិនោ អដ្ឋិតការិនោ អនោលីនវុត្តិនោ[១] អនិក្ខិត្តច្ឆន្ទា អនិក្ខិត្តធុរា តច្ចរិតា តព្ពហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា តទធិមុត្តា តទាធិបតេយ្យាតិ[២] យញ្ញបថេ អប្បមត្តា ។ យេបិ យញ្ញំ ឯសន្តិ គវេសន្តិ បរិយេសន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ សក្កច្ចការិនោ ។ បេ ។ តទាធិបតេយ្យា តេបិ យញ្ញបថេ អប្បមត្តា ។ យេបិ យញ្ញំ អភិសង្ខរោន្តិ[៣] ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ សក្កច្ចការិនោ ។ បេ ។

១ ម. អនោលីនវុត្តិកា ។ ២ ម. តទធិបតេយ្យាតិ តេបិ ។ ៣ ម. ឯត្ថន្តរេ យជន្តិ បរិច្ចជន្តីតិ ទិស្សតិ ។

ពាក្យថា មិនធ្វេសក្នុងផ្លូវយញ្ញៈ សេចក្ដីថា យញ្ញៈហ្នឹងឯង លោកហៅថា ផ្លូវយញ្ញៈ ។ មគ្គប្រសើរ ផ្លូវប្រសើរ មាគ៌ាទេវតា ផ្លូវទេវតា មាគ៌ាព្រហ្ម ផ្លូវព្រហ្មយ៉ាងណា យញ្ញៈហ្នឹងឯង លោកហៅថា ផ្លូវយញ្ញៈ យ៉ាងនោះ ឯង ។ ពាក្យថា មិនធ្វេស គឺមិនធ្វេស ធ្វើដោយគោរព ធ្វើរឿយៗ មានកិរិយាធ្វើតាំងមាំ មានកិរិយាប្រព្រឹត្តមិនរួញរា មានឆន្ទៈមិនដាក់ចុះ មានធុរៈមិនដាក់ចុះ ប្រព្រឹត្តក្នុងផ្លូវយញ្ញៈនោះ ច្រើនក្នុងផ្លូវយញ្ញៈនោះ ធ្ងន់ក្នុងផ្លូវយញ្ញៈនោះ ខ្ជិនទៅក្នុងផ្លូវយញ្ញៈនោះ ទោរទៅក្នុងផ្លូវយញ្ញៈនោះ ញោចទៅក្នុងផ្លូវយញ្ញៈនោះ ចុះសិប់ក្នុងផ្លូវយញ្ញៈនោះ មានផ្លូវយញ្ញៈនោះ ជាអធិបតី ហេតុនោះ (លោកសួរថា) មិនធ្វេសក្នុងផ្លូវយញ្ញៈ ។ សូម្បីពួកជនណា ស្វែង ស្វះស្វែង ស្វែងរកនូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្ការកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ជាអ្នកធ្វើដោយគោរព ។ បេ ។ មានផ្លូវយញ្ញៈនោះជាអធិបតី ជនទាំងនោះ ឈ្មោះថា មិនធ្វេសក្នុងផ្លូវយញ្ញៈ ។ សូម្បីពួកជនណា តាក់តែងយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្ការកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ជាអ្នកធ្វើដោយគោរព ។ បេ ។

តជាជិបតេយ្យា តេបិ យញ្ញបថេ អប្បមត្តា ។ យេបិ យញ្ញំ ទេន្តិ យជន្តិ បរិច្ចជន្តិ ចីវរបិណ្ឌបាត-សេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ សក្កច្ចការិនោ ។ បេ ។ តជាជិបតេយ្យា តេបិ យញ្ញបថេ អប្បមត្តាតិ កាច្ចិស្សុ តេ ភគវា យញ្ញបថេ អប្បមត្តា ។

[១២៧] អតារុំ ជាតិញ្ច ជរញ្ច មារិសាតិ ជាតិជរា-មរណំ អតារិំសុ ឧត្តរិំសុ បតរិំសុ សមតិក្កមិំសុ វីតិ-វត្តិំសុ ។ មារិសាតិ បិយវចនំ គរុវចនំ សគារវសប្ប-តិស្សាធិវចនមេតំ មារិសាតិ អតារុំ ជាតិញ្ច ជរញ្ច មារិស ។

មានផ្ទូវយ័ញ្ញនោះ ជាអធិបតី ជនទាំងនោះ ឈ្មោះថា មិនធ្វេសក្នុងផ្ទូវយញ្ញ: សូម្បីពួកជនណា ឲ្យ បូជា លះបង់នូវយ័ញ្ញ គឺចីវរ បិណ្ឌបាត សេនាសន: គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្ការកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្ងាត់អាស្រ័យ គ្រឿងប្រទីប ជាអ្នកធ្វើដោយគោរព ។ បេ ។ មានផ្ទូវយ័ញ្ញនោះ ជាអធិបតី ជនទាំងនោះ ឈ្មោះថា មិនធ្វេសក្នុងផ្ទូវយ័ញ្ញ ហេតុនោះ (លោកសួរថា) បពិត្រព្រះមានព្រះភាគ មនុស្សទាំងនោះ មិនធ្វេសក្នុងផ្ទូវយ័ញ្ញ (ធ្វងជាតិនិងជរាបាន) ដែរឬ ។

[១២៧] ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ មនុស្សទាំងនោះធ្វងជាតិនិងជរាបាន (ដែរឬ) គឺធ្វង ធ្វងឡើង ធ្វងទូទៅ កន្ធងព្រមប្រព្រឹត្តកន្ធង នូវជាតិ ជរា និងមរណ: បាន (ដែរឬ) ។ ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នេះគឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នេះ ជាពាក្យហៅ ដោយគោរព កោតក្រែង ហេតុនោះ (លោកសួរថា) បពិត្រព្រះអង្គនិរទុក្ខ មនុស្សទាំងនោះ ធ្វងជាតិនិងជរាបាន (ដែរឬ) ។

បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

[១២៨] បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ បុច្ឆាមិ តន្តិ បុច្ឆាមិ តំ យាចាមិ តំ អជ្ឈេសាមិ តំ បសាទេមិ តំ កថស្សុ មេតិ បុច្ឆាមិ តំ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ។ ព្រូហិ មេ តន្តិ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។ តេនាហ សោ ព្រាហ្មណោ យេកេចិមេ ឥសយោ មនុជា (ឥច្ចាយស្មា បុណ្ណកោ)

ខត្តិយា ព្រាហ្មណា ទេវតានំ
យញ្ញមកប្បឹសុ បុថូធ លោកេ
កច្ចិស្សុ តេ ភគវា យញ្ញបថេ អប្បមត្តា
អតារុំ ជាតិញ្ច ជរញ្ច មារិស
បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ ។

[១២៨] *អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គ ប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា ខ្ញុំព្រះអង្គទូលសួរព្រះអង្គ គឺ ខ្ញុំព្រះអង្គ ទូលសួរព្រះអង្គ អង្វរព្រះអង្គ អាឫធនាព្រះអង្គ ញ៉ាំងព្រះអង្គឲ្យជ្រះថ្លា សូមព្រះអង្គប្រាប់(សេចក្ដីនោះ) ដល់ខ្ញុំព្រះអង្គ ហេតុនោះ (លោកសួរថា) ខ្ញុំព្រះអង្គទូលសួរព្រះអង្គ ។ ពាក្យថា បពិត្រព្រះមានព្រះភាគ នុ៎ះជាពាក្យហៅដោយគោរព ។ បេ ។ ការបញ្ញត្តថា មានព្រះភាគនេះ(កើត)ព្រោះការត្រាស់ដឹង ។ ពាក្យថា សូមព្រះអង្គប្រាប់សេចក្ដីនោះដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គប្រាប់ បង្ហាញ សម្ដែង បញ្ញត្ត តាំងផ្ដើម បើក ចែករំលែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ(លោកសួរថា)បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា*

> *(បុណ្ណក:មានអាយុ ទូលសួរដូច្នេះថា) ពួកមនុស្សណាមួយ គឺឥសី ក្សត្រ និងព្រាហ្មណ៍ ជាច្រើននាក់ ក្នុងលោកនេះ សម្រេចយញ្ញ:ដល់ទេវតាទាំងឡាយ បពិត្រព្រះមានព្រះភាគ ពួកមនុស្សទាំងនោះ មិនធ្វេសក្នុងផ្លូវយញ្ញ: បពិត្រព្រះអង្គ និរទុក្ខ (មនុស្សទាំងនោះ) ឆ្ងងជាតិនិងជរាបានដែរឬ បពិត្រ ព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គ ប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គ ។*

[១២៩] អាសីសន្តិ[1] ថោមយន្តិ (អភិជប្ប‌ន្តិ) ជុហន្តិ
(បុណ្ណ‌ាកាតិ ភ‌ត‌ា)

ការ‌ាភិ‌ជ‌ប្ប‌ន្តិ ‌ប‌ដ‌ិ‌ច្ច ‌ល‌ាកំ
‌ត‌េ ‌យ‌ាជ‌យ‌ោ‌ត‌ា ‌ភ‌ព‌ាភ‌ព‌ត្ត‌ា
‌ជ‌ាត‌រ‌ីសុ ‌ជ‌ាតិ‌ជ‌ន្តិ ‌ត្រ‌ូ‌ម‌ិ ។

[១៣០] អ‌ាសីសន្តិ ‌ថ‌ោ‌ម‌យ‌ន្តិ អ‌ភ‌ិ‌ជ‌ប្ប‌ន្តិ ‌ជ‌ុ‌ហ‌ន្តី-
‌ត‌ិ អ‌ាសីសន្តីតិ ‌រ‌ូ‌ប‌ប្ប‌ដ‌ិ‌ល‌ាកំ អ‌ាសីសន្តិ ‌ស‌ទ្ទ‌ប្ប-
‌ដ‌ិ‌ល‌ាកំ អ‌ាសីសន្តិ ‌ក‌ន្ធ‌ប្ប‌ដ‌ិ‌ល‌ាកំ អ‌ាសីសន្តិ ‌រ‌ស‌ប្ប-
‌ដ‌ិ‌ល‌ាកំ អ‌ាសីសន្តិ ‌ផ‌ោ‌ដ‌្ឋ‌ព្ព‌ប្ប‌ដ‌ិ‌ល‌ាកំ អ‌ាសីសន្តិ
‌ប‌ុ‌ត្ត‌ប្ប‌ដ‌ិ‌ល‌ាកំ អ‌ាសីសន្តិ ‌ធ‌ន‌ប្ប‌ដ‌ិ‌ល‌ាកំ អ‌ាសីសន្តិ
‌ញ‌ត‌ប្ប‌ដ‌ិ‌ល‌ាកំ អ‌ាសីសន្តិ ‌យ‌ស‌ប្ប‌ដ‌ិ‌ល‌ាកំ អ‌ាសីសន្តិ
‌ឥ‌ស្ស‌រ‌ិ‌យ‌ប្ប‌ដ‌ិ‌ល‌ាកំ អ‌ាសីសន្តិ ‌ខ‌ត្ត‌ិ‌យ‌ម‌ហ‌ាសា‌ល-
‌ក‌ុ‌ល‌េ អ‌ត្ត‌ភ‌ាវ‌ប្ប‌ដ‌ិ‌ល‌ាកំ អ‌ាសីសន្តិ ‌ព្រ‌ាហ្ម‌ណ‌ម-
‌ហ‌ាសា‌ល‌ក‌ុ‌ល‌េ ‌គ‌ហ‌ប‌ត‌ិ‌ម‌ហ‌ាសា‌ល‌ក‌ុ‌ល‌េ ‌ចា‌ត‌ុ-
‌ម្ម‌ហ‌ារ‌ាជ‌ិ‌ក‌ោ‌ស‌ុ ‌ឧ‌ទ‌េ‌ស‌ុ ។ ‌ប‌េ ។ ‌ព្រ‌ហ្ម‌ក‌ាយ‌ិ‌ក‌ោ‌ស‌ុ
‌ឧ‌ទ‌េ‌ស‌ុ អ‌ត្ត‌ភ‌ាវ‌ប្ប‌ដ‌ិ‌ល‌ាកំ អ‌ាសីសន្តិ ‌ស‌ាធ‌ិ‌យ‌ន្តិ
‌ប‌ត្ថ‌យ‌ន្តិ ‌ប‌ិ‌ហ‌យ‌ន្តីតិ អ‌ាសីសន្តិ ។

---

1 ម. អ‌ាសិ‌ស‌ន្តិ ។

[១២៩] (ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ) ជនទាំងឡាយ ណា ប្រាថ្នា សរសើរ (ជាប់ចិត្ត) បូជា ជាប់ចិត្តក្នុងកាម ព្រោះអាស្រ័យលាភ តថាគតពោលថា ជនទាំងនោះ ប្រកប ក្នុងបូជា ត្រេកអរក្នុងភវគៈ ឆ្លងជាតិនិងជរាមិនបានទេ ។

[១៣០] *អធិប្បាយពាក្យថា ប្រាថ្នា សរសើរ (ជាប់ចិត្ត) បូជា ត្រង់ពាក្យថា ប្រាថ្នា គឺប្រាថ្នាការបាននូវរូប ប្រាថ្នាការបាននូវ សំឡេង ប្រាថ្នាការបាននូវក្លិន ប្រាថ្នាការបាននូវរស ប្រាថ្នាការ បាននូវផ្សព្វ ប្រាថ្នាការបាននូវកូន ប្រាថ្នាការបាននូវប្រពន្ធ ប្រាថ្នាការបាននូវទ្រព្យ ប្រាថ្នាការបាននូវយស ប្រាថ្នាការបាន នូវភាពជាឥស្សរៈ ប្រាថ្នាការបាននូវអត្តភាព ក្នុងត្រកូលខត្តិយ-មហាសាល ប្រាថ្នា ត្រេកអរ បំណង ស្រឡាញ់ នូវការបាន ចំពោះអត្តភាព ក្នុងត្រកូលនៃព្រាហ្មណមហាសាល ក្នុងត្រកូលនៃគហ-បតិមហាសាល ក្នុងពួកទេវតាជាន់ចាតុម្មហារាជិកៈ ។ លេ ។ ក្នុងពួកទេវតា ប្រព្រឹត្តទៅក្នុងពួកព្រហ្ម ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រាថ្នា ។*

ចោទយន្តីតិ យញ្ញំ វា ចោទេន្តិ ផលំ វា ចោទេន្តិ ទក្ខិណេយ្យំ វា ចោទេន្តិ ។ កថំ យញ្ញំ ចោទេន្តិ ។ បិយំ ទិន្នំ មនាបំ ទិន្នំ បណីតំ ទិន្នំ កប្បិយំ ទិន្នំ វិចេយ្យំ ទិន្នំ អនវជ្ជំ ទិន្នំ អភិណ្ហំ ទិន្នំ ទទំ ចិត្តំ បសាទេតន្តិ ចោទេន្តិ កិត្តេន្តិ វណ្ណេន្តិ បសំសន្តិ ឯវំ យញ្ញំ ចោទេន្តិ ។ កថំ ផលំ ចោទេន្តិ ។ ឥតោនិទានំ រូបប្បដិលាភោ ភវិស្សតិ សទ្ទប្បដិលាភោ ភវិស្សតិ គន្ធប្បដិលាភោ ភវិស្សតិ រសប្បដិលាភោ ភវិស្សតិ ផោដ្ឋព្វប្បដិលាភោ ភវិស្សតិ ខត្តិយមហាសាលកុលេ ព្រាហ្មណមហាសាលកុលេ ។ បេ ។ ព្រហ្មកាយិកេសុ ទេវេសុ អត្តភាវប្បដិលាភោ ភវិស្សតីតិ ចោទេន្តិ កិត្តេន្តិ វណ្ណេន្តិ បសំសន្តិ ឯវំ ផលំ ចោទេន្តិ ។ កថំ ទក្ខិណេយ្យំ ចោទេន្តិ ។ ទក្ខិណេយ្យា ជាតិសម្បន្នា គោត្តសម្បន្នា អជ្ឈាយកា មន្តធរា តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេតុភានំ អក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកា វេយ្យាករណា លោកាយតមហាបុរិសលក្ខណេសុ

បុណ្ណកមាណវកបញ្ហានិទ្ទេស

ពាក្យថា សរសើរ គឺសរសើរយញ្ញ:ក្តី សរសើរផលក្តី សរសើរ
ទក្ខិណេយ្យបុគ្គលក្តី ។ សរសើរយញ្ញ: តើដូចម្តេច ។ ជនទាំងឡាយ
សរសើរ សម្តែង ពណ៌នា ស្ទើចថា បុគ្គលឲ្យវត្ថុជាទីស្រឡាញ់
ឲ្យវត្ថុជាទីគាប់ចិត្ត ឲ្យវត្ថុដ៏ថ្លៃថ្នូ ឲ្យវត្ថុដ៏គួរ ឲ្យវត្ថុដែលពិចារណារួច
ហើយ ឲ្យវត្ថុមិនមានទោស ឲ្យរឿយ ៗ កាលឲ្យក៏ញ្ចុំងចិត្តឲ្យជ្រះថ្នូ
សរសើរយញ្ញ:យ៉ាងនេះ ។ សរសើរផល តើដូចម្តេច ។ ជនទាំងឡាយ
សរសើរ សម្តែង ពណ៌នា ស្ទើចថា ព្រោះការឲ្យនេះជាហេតុ
នឹងបានរូប នឹងបានសំឡេង នឹងបានក្លិន នឹងបានរស នឹងបានផ្សព្វ
នឹងបានអត្តភាពក្នុងត្រកូលនៃខត្តិយមហាសាល ក្នុងត្រកូលនៃព្រាហ្មណ-
មហាសាល ។ បេ ។ ក្នុងពួកទេវតាដែលប្រព្រឹត្តទៅក្នុងពួកព្រហ្ម សរ-
សើរផល យ៉ាងនេះ ។ សរសើរទក្ខិណេយ្យបុគ្គល តើដូចម្តេច ។ ជនទាំង
ឡាយ សរសើរ សម្តែង ពណ៌នា ស្ទើចថា ទក្ខិណេយ្យបុគ្គលទាំងឡាយ
ជាអ្នកបរិបូណ៌ដោយជាតិ បរិបូណ៌ដោយគោត្រ ជាអ្នកស្វាធ្យាយ
[១៨៣] *អធិប្បាយពាក្យថា ព្រះមានព្រះភាគ ទ្រង់លះបង់ទុក្ខ ដោយពិត ត្រង់ពាក្យថា ដោយពិត គឺជាពាក្យដាច់ខាត ជាពាក្យឥត សង្ស័យ ជាពាក្យឥតងឿងឆ្ងល់ ជាពាក្យមិនបែកជាពីរ ជាពាក្យមិនមាន ចំពាមពីរ ជាពាក្យស្រាចស្រង់ ជាពាក្យមិនខុស ពាក្យថា ដោយពិត ជាពាក្យតាំងមាំ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះ ជាពាក្យពោលដោយ គោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះ ការត្រាស់ដឹង ។ ពាក្យថា ទ្រង់លះទុក្ខ គឺលះបង់ លះចេញ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យមានបែបភាព នូវជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខ ហេតុនោះ (លោក សួរថា) ព្រះមានព្រះភាគ ទ្រង់លះទុក្ខបានដោយពិត ។*

[១៨៤] *ពាក្យថា ព្រោះធម៌នុ៎ះ ព្រះអង្គជ្រាបច្បាស់ហើយ គឺ ព្រោះធម៌នុ៎ះ ព្រះអង្គជ្រាបច្បាស់ ដឹង ច្ចឹង ពិចារណា ឈ្វេងយល់ ច្បាកដ ហេតុនោះ (លោកសួរថា) ព្រោះធម៌នុ៎ះព្រះអង្គជ្រាប ច្បាស់ហើយ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា*

ឯតាភិនន្ទាមិ វចោ មហេសិនោ
សុកិត្តិតំ គោតម ន្ធូបធីកំ
អន្ធា ហិ ភគវា បហាសិ ទុក្ខំ
តថា ហិ តេ វិជិតោ ឯស ជម្ភោតិ ។

[១៨៥] តេ ចាបិ ន្ធូន បជហេយ្យុ ទុក្ខំ
យេ ត្វំ មុនី អដ្ឋិតំ ឱវទេយ្យ
តន្តំ ឧមស្ឆាមិ សមេច្ច ធីរ
អម្ប្រេ មំ ភគវា អដ្ឋិតំ ឱវទេយ្យ ។

[១៨៦] តេ ចាបិ ន្ធូន បជហេយ្យុ ទុក្ខន្តិ តេ ចាបីតិ ខត្តិយា ច ព្រាហ្មណា ច វេស្ស ច សុទ្ធា ច គហដ្ឋា ច បព្ជិតា ច ទេវ ច មនុស្ស ច ប-ជហេយ្យុ ។ ទុក្ខន្តិ ជាតិទុក្ខំ ជរាទុក្ខំ ព្យាធិទុក្ខំ មរណទុក្ខំ សោកបរិទេវទុក្ខទោមនស្ស្ឧបាយាសទុ-ក្ខំ បជហេយ្យុ វិនោទេយ្យុ ព្យន្តីករេយ្យុ អនភាវ្ត-មេយ្យុន្តិ តេ ចាបិ ន្ធូន បជហេយ្យ ទុក្ខំ ។

ខ្ញុំព្រះអង្គ ត្រេកអរចំពោះព្រះវាចានុ៎ះ របស់ព្រះមហេសី
បពិត្រព្រះគោតម ព្រះនិព្វាន ជាគុណជាតមិនមានឧបធិ
ព្រះអង្គសម្តែងហើយដោយប្រពៃ ព្រះមានព្រះភាគ លះ
ទុក្ខបានដោយពិត ព្រោះធម៌នុ៎ះព្រះអង្គជ្រាបច្បាស់ហើយ ។

[១៨៥] បពិត្រព្រះមុនិ ព្រះអង្គទូន្មានពួកជនណា ដោយត្រឹមត្រូវ
ពួកជនទាំងនោះ ក៏លះទុក្ខបានដោយពិត ព្រោះហេតុនោះ
ខ្ញុំព្រះអង្គចូលមក នមស្តារចំពោះព្រះអង្គ ជាព្រះពុទ្ធនាគ
សូមព្រះមានព្រះភាគទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវចុះ ។

[១៨៦] ពាក្យថា ពួកជនទាំងនោះ របស់បទថា ពួកជនទាំងនោះ ក៏លះទុក្ខបានដោយពិត បានដល់ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្ស: សុទ្ទ: គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ក៏លះបង់ (ទុក្ខបាន) ។ ពាក្យថា ទុក្ខ គឺ គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខទោ-មនស្សុបាយាសទុក្ខ ហេតុនោះ (លោកពោលថា) ពួកជនទាំងនោះ ក៏លះទុក្ខបានដោយពិត ។

[១៨៧] យេ ត្វំ មុនី អជ្ឈិតំ ឱវទេយ្យាតិ យេតិ ខត្តិយេ ច ព្រាហ្មណេ ច វេស្សេ ច សុទ្ទេ ច គហដ្ឋេ ច បព្វជិតេ ច ទេវេ ច មនុស្សេ ច ។ ត្វន្តិ ភគវន្តំ ភណតិ ។ មុនីតិ មោនំ វុច្ចតិ ញាណំ ។ បេ ។ សង្គជាលមតិច្ច សោ មុនិ ។ អជ្ឈិតំ ឱវទេយ្យាតិ[១] សក្កច្ចំ ឱវទេយ្យ អភិណ្ហំ ឱវទេយ្យ បុនប្បុនំ ឱវទេយ្យ អនុសាសេយ្យាតិ យេ ត្វំ មុនី អជ្ឈិតំ ឱវទេយ្យ ។

[១៨៨] តន្តំ នមស្សាមិ សមេច្ច នាគន្តិ តន្តិ ភគវន្តំ ភណតិ ។ នមស្សាមីតិ កាយេន វា នមស្សាមិ ចិត្តេន វា នមស្សាមិ អន្វត្ថប្បដិបត្តិយា វា នមស្សាមិ ធម្មានុធម្មប្បដិបត្តិយា វា នមស្សាមិ សក្ករោមិ គរុករោមិ មានេមិ បូជេមិ ។ សមេច្ចាតិ សមេច្ច អភិសមេច្ច សមាគន្ត្វា អភិសមាគន្ត្វា សម្មុខា តំ នមស្សាមិ ។ នាគន្តិ នាគោ ។

១ ម. អជ្ឈិតំ ឱវទេយ្យាតិ អជ្ឈិតំ ឱវទេយ្យ ។

[១៨៧] ពាក្យថា ណា របស់បទថា បពិត្រព្រះមុនិ ព្រះអង្គ ទូន្មានពួកជនណា ដោយត្រឹមត្រូវ បានដល់ ពួកជនជាក្សត្រិយ៍ ព្រាហ្មណ៍ វេស្ស: សុទ្ទ: គ្រហស្ថ បព្វជិត ទេវតានិងមនុស្ស ។ ពាក្យថា ព្រះអង្គ គឺព្រាហ្មណ៍ពោលចំពោះព្រះមានព្រះភាគ ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោន: ។ បេ ។ ព្រះមុនិនោះ កន្ធងនូវបណ្តាញគឺកិលេសជាគ្រឿងជាប់ចំពាក់ ។ ពាក្យថា ទូន្មាន ដោយត្រឹមត្រូវ គឺគប្បីទូន្មាន ទូន្មានដោយគោរព ទូន្មានរឿយៗ ទូន្មាន ប្រៀនប្រដៅញយៗ ដាស់តឿន ហេតុនោះ (លោកពោលថា) បពិត្រព្រះមុនិ ព្រះអង្គទូន្មានពួកជនណា ដោយត្រឹមត្រូវ ។

[១៨៨] អធិប្បាយពាក្យថា ខ្ញុំព្រះអង្គចូលមក នមស្ការចំពោះ ព្រះអង្គជាព្រះពុទ្ធនាគ ត្រង់ពាក្យថា ចំពោះព្រះអង្គ គឺព្រាហ្មណ៍ពោល ចំពោះព្រះមានព្រះភាគ ។ ពាក្យថា នមស្ការ គឺខ្ញុំព្រះអង្គសូមថ្វាយបង្គំ ដោយកាយក្តី ថ្វាយបង្គំដោយចិត្តក្តី ថ្វាយបង្គំដោយសេចក្តីប្រតិបត្តិដ៏ សមគួរដល់អត្តក្តី ថ្វាយបង្គំដោយសេចក្តីប្រតិបត្តិដ៏សមគួរដល់ធម៌ក្តី ធ្វើ សក្ការ: គោរព រាប់អាន បូជា ។ ពាក្យថា ចូលមក គឺខ្ញុំព្រះអង្គសំដៅ មក សំដៅមកចំពោះ មកត្រង់ ឆ្ពោះមក នមស្ការព្រះអង្គចំពោះ ព្រះកត្ត្រ ពាក្យថា ព្រះពុទ្ធនាគ គឺព្រះមានព្រះភាគជាបុគ្គលដ៏ប្រសើរ ។

ភគវា អាគុំ ន ករោតីតិ ឯវំ ភគវា អាគុំ ន ករោតីតិ នាគោ ។ ន គច្ឆតីតិ នាគោ ។ ន អាគច្ឆតីតិ នាគោ ។

កថំ ភគវា អាគុំ ន ករោតីតិ នាគោ ។ អាគូ វុច្ចន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា[១] ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ។

អាគុំ ន ករោតិ កិញ្ចិ លោកេ
សព្វសំយោគេ វិសជ្ជ ពន្ធនានិ
សព្វត្ថ ន សជ្ជតី វិមុត្តោ
នាគោ តាទិ បវុច្ចតេ តថត្តាតិ ។

ឯវំ ភគវា អាគុំ ន ករោតីតិ នាគោ ។

១ ឱ. ម. នន្ទិរាគា ។

ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគ មិនធ្វើអំពើអាក្រក់ ។ ព្រះនាមថា នាគ ព្រោះទ្រង់មិនលុះ ។ ព្រះនាមថា នាគ ព្រោះទ្រង់មិនមក ។

ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគមិនធ្វើអំពើអាក្រក់ តើដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង នាំមកនូវភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានផលជាទុក្ខ គួរដល់ជាតិ ជរា មរណៈតទៅ លោកពោលថា អំពើអាក្រក់ ។

ព្រះមានព្រះភាគ មិនធ្វើអំពើអាក្រក់ណាមួយ ក្នុងលោក ទ្រង់ស្រាយចំណងគឺកិលេស ក្នុងការប្រកបទុកនូវសត្វទាំងពួង ព្រះអង្គរួចហើយ មិនជាប់ក្នុងអារម្មណ៍ទាំងពួង ព្រះអង្គជាបុគ្គលនឹងធឹង ទើបហៅថា នាគ ព្រោះព្រះអង្គជាបុគ្គលទៀង ។

ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគ មិនធ្វើអំពើអាក្រក់យ៉ាងនេះឯង ។

កថំ ភគវា ន កច្ចតីតិ ជានោ ។ ភគវា ន ឆន្ទ-
គតឹ កច្ចតិ ន ទោសាគតឹ កច្ចតិ ន មោហាគតឹ កច្ចតិ
ន ភយាគតឹ កច្ចតិ ន ភាគវសេន កច្ចតិ ន ទោសវ-
សេន កច្ចតិ ន មោហវសេន កច្ចតិ ន ទិដ្ឋិវសេន
កច្ចតិ ន មានវសេន កច្ចតិ ន ឧទ្ធច្ចវសេន កច្ចតិ ន
វិចិកិច្ឆាវសេន កច្ចតិ ន អនុសយវសេន កច្ចតិ ន
រាគ្គេហិ ឆម្ទេហិ យាយតិ និយ្យតិ រុយ្ហតិ សំហរិយតិ
ឯវំ ភគវា ន កច្ចតីតិ ជានោ ។

កថំ ភគវា ន អាគច្ចតីតិ ជានោ ។
សោតាបត្តិមគ្គេន យេ កិលេសា បហីនា តេ
កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ចតិ សកា-
ទាគាមិមគ្គេន អនាគាមិមគ្គេន យេ កិលេសា បហីនា
តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ចតិ
អរហត្តមគ្គេន យេ កិលេសា បហីនា តេ កិ-
លេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ចតិ

ព្រះនាមថា នាគ ព្រោះទ្រង់មិនលុះ តើដូចម្តេច ។ ព្រះមានព្រះ
ភាគមិនលុះឆន្ទាគតិ មិនលុះទោសាគតិ មិនលុះមោហាគតិ មិនលុះ
ភយាគតិ មិនលុះដោយអំណាចរាគ: មិនលុះដោយអំណាចទោស:
មិនលុះដោយអំណាចមោហ: មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយ
អំណាចមាន: មិនលុះដោយអំណាចឧទ្ធច្ច: មិនលុះដោយអំណាចវិចិ-
កិច្ឆា មិនលុះដោយអំណាចអនុសយ គឺព្រះអង្គមិនទៅ មិនឃ្លាត
មិនរសាត់ មិនដោយតាមធម៌ជាពួកទាំងឡាយ ព្រះនាមថា នាគ
ព្រោះព្រះមានព្រះភាគ មិនលុះ យ៉ាងនេះឯង ។

ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគ មិនមក តើដូច
ម្តេច ។ កិលេសទាំងឡាយណា ដែលព្រះអង្គលះហើយ ដោយ
សោតាបត្តិមគ្គ ព្រះអង្គមិនមក មិនបែរមក មិនត្រឡប់មក កាន់
កិលេសទាំងនោះវិញ កិលេសទាំងឡាយណា ដែលព្រះអង្គលះ
ហើយ ដោយសកទាគាមិមគ្គ អនាគាមិមគ្គ ព្រះអង្គមិនមក មិន
បែរមក មិនត្រឡប់មក កាន់កិលេសទាំងនោះវិញ កិលេសទាំង-
ឡាយណា ដែលព្រះអង្គលះហើយ ដោយអរហត្តមគ្គ ព្រះអង្គ
មិនមក មិនបែរមក មិនត្រឡប់មក កាន់កិលេសទាំងនោះវិញទេ

ឯវំ ភគវា ន អាគច្ឆតីតិ ជានោតិ តន្តំ ជមស្សាមិ សមេច្ច ជានកំ ។

[១៨៩] អប្ប្យេ មំ ភគវា អដ្ឋិតំ ឱវទេយ្យាតិ អប្ប- យ មំ ភគវា អដ្ឋិតំ ឱវទេយ្យ សក្ខិច្ចំ ឱវទេយ្យ អ-ភិណ្ហ ឱវទេយ្យ បុនប្ប្យុនំ ឱវទេយ្យ អនុសាសេយ្យាតិ អប្ប្យេ មំ ភគវា អដ្ឋិតំ ឱវទេយ្យ ។ តេនាហ សោ ព្រាហ្មណោ

តេ ចាបិ ន្ទូន បជហេយ្យ ឧក្ខ្ជ
យេ ត្ថ មុនី អដ្ឋិតំ ឱវទេយ្យ
តន្តំ ជមស្សាមិ សមេច្ច ជានកំ
អប្ប្យេ មំ ភគវា អដ្ឋិតំ ឱវទេយ្យាតិ ។

[១៩០] យំ ព្រាហ្មណ្ណ ឯកមុ អភិជ្ជ
អកិញ្ចនំ ការមកេ អសត្ត
អជ្ជ ហិ សោ ឱឃមិមំ អតារិ
តិណ្ណោ ច ចារ អទ្ធិលោ អកង្ខ ។

ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគមិនមក យ៉ាងនេះឯង ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គ ចូលមកនមស្ការ ព្រះអង្គជាព្រះពុទ្ធនាគ ។

[១៨៩] ពាក្យថា សូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវចុះ គឺសូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវ សូមទូន្មានដោយគោរព ទូន្មានរឿយៗ ទូន្មាន ប្រៀនប្រដៅញយៗ ហេតុនោះ (លោកពោលថា) សូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវចុះ ។ ហេតុនោះ ព្រាហ្មណ៍ពោលថា

> បពិត្រព្រះមុនិ ព្រះអង្គទូន្មានពួកជនណា ដោយត្រឹមត្រូវ ពួកជនទាំងនោះ ក៏លះទុក្ខបានដោយពិត ព្រោះហេតុនោះ ខ្ញុំព្រះអង្គចូលមក នមស្ការចំពោះព្រះអង្គ ជាព្រះពុទ្ធនាគ សូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវចុះ ។

[១៩០] (ព្រះមានព្រះភាគត្រាស់តបថា) បុគ្គលគប្បីដឹងច្បាស់នូវ

> ព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ អ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមគុណ ព្រាហ្មណ៍នោះ ឈ្មោះថា បានធ្វើ ឱ្យ:នេះ ដោយពិត ទាំងធ្វើដល់ត្រើយ ជាអ្នកមិនមានបង្គោល មិនមានសេចក្ដីជ្រើងធ្ងល់ ។

[១៩១] យំ ព្រាហ្មណំ វេទកុំ អភិជញ្ញាតិ ព្រាហ្ម-ណាន្តិ សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ ។ សក្កាយទិដ្ឋិ ពាហិតា ហោតិ វិចិកិច្ឆា ពាហិតា ហោតិ សីលព្ពតបរាមាសោ ពាហិតោ ហោតិ រាគោ ពាហិតោ ហោតិ ទោសោ ពាហិតោ ហោតិ មោ-ហោ ពាហិតោ ហោតិ មានោ ពាហិតោ ហោតិ ។ ពាហិតស្ស ហោន្តិ ចាបកា អកុសលា ធម្មា សង្កិ-លេសិកា ចោនោត្ត្ថវិកា សទរ ទុក្ខវិបាកា អា-យតឹ ជាតិជរាមរណីយា ។

ពាហេត្វា សព្ពចាបកានិ (សកិយាតិ ភគវា)
ភគវា រិមលោ សាធុសមាហិតោ ឋិតត្តោ[1]
សំសារមតិចុ គោវលី សោ
អនិស្ស្ជិតោ តានិ បរុច្ចតេ ព្រហ្ម ។

វេទគុន្តិ វេទោ រុច្ចតិ ចតូសុ មគ្គេសុ ញាណំ ។ បេ ។ សព្ពវេទមតិចុ វេទកូ សោតិ ។ អភិជញ្ញាតិ អភិជានេយ្យ អាជានេយ្យ វិជានេយ្យ បជិវិជានេយ្យ បជិវិជ្ឌ្ឍយ្យាតិ យំ ព្រាហ្មណំ វេទកុំ អភិជញ្ញ ។

---

1 ម. ជិតត្តោ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

[១៩១] *អធិប្បាយពាក្យថា បុគ្គលគប្បីដឹងច្បាស់ នូវព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ ត្រង់ពាក្យថា ព្រាហ្មណ៍ សេចក្តីថា ដែលឈ្មោះថា ព្រាហ្មណ៍ ព្រោះបន្សាត់បង់ធម៌ ៧ ។ គឺបន្សាត់បង់សក្កាយទិដ្ឋិ បន្សាត់បង់វិចិកិច្ឆា បន្សាត់បង់សីលព្វតបរាមាសៈ បន្សាត់បង់រាគៈ បន្សាត់បង់ទោសៈ បន្សាត់បង់មោហៈ បន្សាត់បង់មានៈ ។ លោកបានលះបង់ នូវអកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង នាំមកនូវភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានផលជាទុក្ខ ជាទីតាំងនៃជាតិ ជរ មរណៈតទៅ ។*

(ព្រះមានព្រះភាគត្រាស់ថា ម្នាលសកិយៈ) ព្រះមានព្រះភាគ បន្សាត់បង់នូវបាបទាំងពួង ជាបុគ្គលប្រាសចាកមន្ទិល មានព្រះហឫទ័យតម្កល់នៅដោយល្អ មានខ្ជួនខ្ជាប់ខ្ជួន ព្រះមានព្រះភាគនោះ ជាបុគ្គលបរិសុទ្ធ កន្ទងនូវសំសារ មិនអាស្រ័យ (តណ្ហានិងទិដ្ឋិ) ជាបុគ្គលនឹងធឹង លោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា អ្នកដល់នូវវេទ សេចក្តីថា ញាណក្នុងមគ្គ ៤ លោកហៅថាវេទ ។ បេ ។ បុគ្គលនោះដល់នូវវេទ កន្ទងនូវវេទទាំងពួង ។ ពាក្យថា គប្បីដឹងច្បាស់ គឺគប្បីដឹងចំពោះ ដឹងទូទៅ ដឹងវិសេស ដឹងច្បាស់ យល់ច្បាស់ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីដឹងច្បាស់នូវព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ ។

[១៩២] អកិញ្ចនំ កាមភវេ អសត្តន្តិ អកិញ្ចនន្តិ រាគកិញ្ចនំ ទោសកិញ្ចនំ មោហកិញ្ចនំ មានកិញ្ចនំ ទិដ្ឋិកិញ្ចនំ កិលេសកិញ្ចនំ ឧបធិវិបាកកិញ្ចនំ ។ យស្សេតេ កិញ្ចនា បហីនា សមុច្ឆិន្នា រូបសន្តា បដិប្ប្ស្ស្ធ្ធា អភព្ពុប្ប្ត្តិកា ញ្ញាណាគ្គិនា ឌឌ្ឍា សោ រុច្ចតិ អកិញ្ចនោ ។ កាមាតិ ឧទ្ធានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ រុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ រុច្ចន្តិ កិលេសកាមា ។ ភវាតិ ទ្វេ ភវា កម្មភវោ ច បដិសន្ធិភវោ ច បុនព្ភវោ ។ បេ ។ អយំ កម្មភវោ ។ បេ ។ អយំ បដិសន្ធិភវោ បុនព្ភវោ ។ អកិញ្ចនំ កាមភវេ អសត្តន្តិ អកិញ្ចនំ[1] កាមភវេ អសត្តំ អលគ្គំ អលគ្គិតំ អបលិពុទ្ធន្តិ[2] អកិញ្ចនំ កាមភវេ អសត្តំ ។

[១៩៣] អជ្ឌា ហិ សោ ឱឃមិមំ អតារីតិ អជ្ឌាតិ ឯកំសវចនំ ។ បេ ។ អវត្ថានវចនមេតំ អជ្ឌាតិ ។

---

១ ម. អកិញ្ចនំ បុគ្គលំ ។ ២ ម. ឯត្ថន្តរេ និក្ខន្តំ និស្សដំ វិប្ប្ឍុត្តំ វិសញ្ញុត្តំ វិមរិយាទិកតេន ចេតសា វិហរន្តន្តីតិ ទិស្សតិ ។

[១៩២] *អធិប្បាយពាក្យថា អ្នកមិនមានកង្វល់ មិនជាប់នៅ ក្នុងកាមភព ត្រង់ពាក្យថា អ្នកមិនមានកង្វល់ សេចក្តីថា កង្វល់គឺរាគ: កង្វល់គឺទោស: កង្វល់គឺមោហ: កង្វល់គឺមានៈ កង្វល់គឺទិដ្ឋិ កង្វល់គឺកិលេស កង្វល់គឺទុច្ចរិត ។ គ្រឿងកង្វល់ទាំងឡាយនុ៎ះ ព្រះខីណាស្រពណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ សូប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ព្រះខីណាស្រពនោះ លោកហៅថា អ្នកមិនមានកង្វល់ ។ ពាក្យថា កាម បើតាមឧទ្ទាន បានដល់ កាម ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ នេះ ហៅថា វត្ថុកាម ។ បេ ។ នេះ ហៅថា កិលេសកាម ។ ពាក្យថា ភព បានដល់ភព ២ គឺ កម្មភព ១ បុនព្ភពគឺបដិសន្ធិ ១ ។ បេ ។ នេះ កម្មភព ។ បេ ។ នេះ បុនព្ភពគឺបដិសន្ធិ ។ ពាក្យថា អ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមភព គឺអ្នកមិនមានកង្វល់ មិនជាប់នៅ មិនជ្ជក់នៅ មិនស្អិតនៅ មិនចាក់កណ្តាញ់នៅ ក្នុងកាមភព ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនមានកង្វល់ មិនជាប់នៅ ក្នុងកាមភព ។*

[១៩៣] *ពាក្យថា ព្រាហ្មណ៍នោះ ឈ្មោះថា បានធ្វើ ឱ្ឃ:នេះ ដោយពិត ត្រង់ពាក្យថា ដោយពិត គឺជាពាក្យដាច់ខាត ។ បេ ។ ពាក្យថា ដោយពិត នុ៎ះ ជាពាក្យប្រាកដ ។*

ឱឃន្តិ កាមោឃំ ភវោឃំ ឧជ្ជោឃំ អវិជ្ជោឃំ ។ អតារីតិ អតារិ ឧត្តរិ បតរិ សមតិក្កមិ វីតិវត្តីតិ អជ្ឌា ហិ សោ ឱឃមិមំ អតារិ ។

[១៩៤] តិណ្ណោ ច ចារំ អទិសោ អកង្ខោតិ តិណ្ណោតិ កាមោឃំ តិណ្ណោ ភវោឃំ តិណ្ណោ ឧជ្ជោឃំ តិណ្ណោ អវិជ្ជោឃំ តិណ្ណោ ឧត្តិណ្ណោ ឧត្តិណ្ណោ អតិក្ក-ន្តោ វីតិវត្តោ សោ រុជ្ជវាសោ ចិណ្ណចរណោ កតកុ្ខ-ត្ត-ជ-ិ- សោ កតកោ-ជ-ិ-ត-ោ ចាលិ-ត-ព្រ-ហ្ម-ចរ-ិ-យ-ោ ឧ-ត្ត-ម-ជ-ិ-ដ-ិ-ប-្ប-ត-ោ ភ-ាវ-ិ-ត-ម-ក-ោ ប-ហ-ីន-ក-ិ-ល-េ-ស-ោ ប-ដ-ិ-ទ-ា-ក-ុ-ប-្ប-ា-ស-ច-ិ-ត-ន-ិ-ភ-េ-ដ-ោ ។ ឧ-ក-ុ-ដ-ំ ត-ស-្ស ប-រ-ិ-ញ-ា-ត-ំ ស-ម-ុ-ទ-យ-ោ ប-ហ-ី-ដ-ោ ម-ក-ោ ភ-ា-វ-ិ-ត-ោ ន-ិ-ភ-េ-ដ-ោ ស-ច-ិ-ក-ត-ោ អ-ភ-ិ-ញ-ញ-េ-យ-្យ-ំ អ-ភ-ិ-ញ-ា-ត-ំ ប-រ-ិ-ញ-ញ-េ-យ-្យ-ំ ប-រ-ិ-ញ-ា-ត-ំ ប-ហ-ា-ត-ព-្ព-ំ ប-ហ-ី-ន-ំ ភ-ា-វ-េ-ត-ព-្ព-ំ ភ-ា-វ-ិ-ត-ំ ស-ច-ិ-ក-ា-ត-ព-្ព-ំ ស-ច-ិ-ក-ត-ំ ។

ពាក្យថា ឱឃៈ បានដល់ ឱឃៈគឺកាម ឱឃៈគឺភព ឱឃៈគឺទិដ្ឋិ ឱឃៈគឺអវិជ្ជា ។ ពាក្យថា បានឆ្លង គឺបានឆ្លងឡើង ឆ្លងកាត់ ឈានកន្ទង ប្រព្រឹត្តកន្ទង ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍នោះ ឈ្មោះថា បានឆ្លងឱឃៈនេះ ដោយពិត ។

[១៩៦] អធិប្បាយពាក្យថា ទាំងឆ្លងដល់ត្រើយ ជាអ្នកមិនមានបង្គោល មិនមានសេចក្តីជឿងឆ្ងល់ ត្រង់ពាក្យថា ឆ្លង គឺព្រាហ្មណ៍ណា ឆ្លងកាមោឃៈ ឆ្លងភវោឃៈ ឆ្លងទិដ្ឋោឃៈ ឆ្លងអវិជ្ជោឃៈ ឆ្លងឡើង ឆ្លងចេញ កន្ទង ប្រព្រឹត្តកន្ទង ព្រាហ្មណ៍នោះ ឈ្មោះថាជាអ្នកមានព្រហ្មចរិយ-ធម៌អប់រំហើយ មានចរណធម៌ប្រព្រឹត្តហើយ មានកាលវែងកន្ទងហើយ មានទិសគឺនិព្វានដល់ហើយ មានទីបំផុតដល់ហើយ មានព្រហ្មចរិយ-ធម៌រក្សាហើយ ដល់នូវសម្មាទិដ្ឋិដ៏ឧត្តម មានមគ្គចម្រើនហើយ មានកិលេសលះបង់ហើយ មានអកុប្បធម៌ត្រាស់ដឹងហើយ មាននិរោធធម៌ធ្វើឲ្យជាក់ច្បាស់ហើយ ។ ព្រះអរិយបុគ្គលនោះ កំណត់ដឹងទុក្ខហើយ លះបង់សមុទយៈហើយ ចម្រើនមគ្គហើយ ធ្វើឲ្យជាក់ច្បាស់នូវនិរោធហើយ ត្រាស់ដឹងនូវគុណជាត ដែលគប្បីត្រាស់ដឹង កំណត់ដឹងទុក្ខដែលគប្បីកំណត់ដឹង លះបង់នូវកិលេសជាតដែលគប្បីលះ ចម្រើននូវធម្មជាតដែលគប្បីចម្រើន ធ្វើឲ្យជាក់ច្បាស់នូវគុណជាតដែលគប្បីធ្វើឲ្យជាក់ច្បាស់ ។

សោ ឧក្ខិត្តបលិឃោ សង្ខិ្ណណ្ណាបរិក្ខោ អព្ភុច្ឆ្ដិសិកោ និ-
រគ្គឡោ អរិយោ បន្ទទ្ធជោ បន្ទភារោ វិសំយុត្តោ បញ្ចង្គ-
វិប្ប្ហីនោ ឆឡង្គ្គសមន្ទ្ធាគតោ ឯការក្ខោ ចតុរាប-
ស្សោ បន្ទុណ្ណាប្ប្ចេកសច្ចោ សមវាយសង្ខ្ជេសនោ
អនាវិលសង្ខ្ជប្ប្ភោ បស្ស្ទ្ធកាយសង្ខ្ជារោ សុវិមុត្តចិត្តោ
សុវិមុត្តប្ប្ញ្ញោ ភោវលី រុសិតវា ឧត្ដមបុរិសោ បរមបុរិ-
សោ បរមប្ប្ត្ដិប្ប្ត្ដោ ។ សោ នេវ អាចិនាតិ ន អបចិនា-
តិ អបចិនិត្ងា ឋិតោ នេវ បជហាតិ ន ឧចាឌិយតិ បជហិ-
ត្ងា ឋិតោ នេវ វិសិនេតិ ន ឧស្ស្ដិនេតិ វិសិនេត្ងា ឋិតោ
នេវ ឆ្ជូបេតិ ន សន្ទ្ជូបេតិ ឆ្ជូបេត្ងា ឋិតោ អសេក្ខេន
សីលក្ខន្ធេន សមន្ទ្ធាគតត្ដា ឋិតោ អសេក្ខេន សមា-
ឌិក្ខន្ធេន អសេក្ខេន បញ្ញាខន្ធេន អសេក្ខេន វិមុត្ដិ-
ក្ខន្ធេន អសេក្ខេន វិមុត្ដិញ្ញាណឌស្ស្ដនក្ខន្ធេន
សមន្ទ្ធាគតត្ដា ឋិតោ សង្ជ(១) បជិចាឌយិត្ងា(២) ឋិតោ

---

១ ម. សច្ជន្ដិ អដ្ដកថាយំ ទិស្ស្ដតិ ។ ២ ម. សំបដិបាទិយិត្ងា ។

ព្រះអរិយបុគ្គលនោះ មានសសរគោល (គឺអវិជ្ជា) ដកចេញហើយ មានស្នាមភ្ជោះគឺសំសារលុបចោលហើយ មានសសរគឺតណ្ហាដកចេញហើយ មានសន្ទះទ្វារគឺនីវរណៈបើកចេញហើយ មានទង់គឺមានៈដកចេញហើយ មានភារៈដាក់ចេញហើយ ជាអ្នកប្រាសចាក (រ៉ាគ:) ជាអ្នកមានអង្គ ៥ លះបង់ហើយ ជាអ្នកប្រកបដោយអង្គ ៦ មានការរក្សាតែមួយគឺសតិ មានធម៌ជាគ្រឿងពឹងផ្អែក ៤ យ៉ាង មានសច្ចធម៌ផ្សេងបន្ទោបង់ហើយ មានការស្វែងរកទាំងអស់លះបង់ហើយ មានការត្រិះរិះមិនល្អក់ មានកាយសង្ខារសូប់រម្ងាប់ មានចិត្តរួចស្រឡះដោយប្រពៃ មានប្រាជ្ញារួចស្រឡះប្រពៃ ជាបុគ្គលបរិសុទ្ធ មានព្រហ្មចរិយធម៌ប្រព្រឹត្តចប់ហើយ ជាឧត្តមបុរស ជាបរមបុរស ជាអ្នកដល់នូវគុណជាតជាគ្រឿងដល់ដ៏ក្រៃ-លែង ។ អរិយបុគ្គលនោះ មិនសន្សំ មិនប្រមូល ឈ្មោះថាខ្ជាប់ខ្ជួនព្រោះមិនប្រមូល មិនលះបង់ មិនប្រកាន់ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះលះបង់ មិនចាក់ស្រេះ មិនក្រអឺតក្រអោង ឈ្មោះថាអ្នកខ្ជាប់ខ្ជួនព្រោះលែងចាក់ស្រេះ មិនលត់ មិនបង្ក្រាត់ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះរលត់ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះប្រកបដោយសីលក្ខន្ធជាអសេក្ខ: ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះប្រកបដោយសមាធិក្ខន្ធជាអសេក្ខ: ដោយបញ្ញា-ខន្ធជាអសេក្ខ: ដោយវិមុត្តិក្ខន្ធជាអសេក្ខ: ដោយវិមុត្តិញ្ញាណទស្សន-ក្ខន្ធជាអសេក្ខ: ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះសម្រេចនូវកិច្ចទាំងពួង

ឯវំ សមតិក្កមិត្វា បិតោ កិលេសគ្គិំ បរិយាទយិត្វា បិតោ អបរិគមនតាយ បិតោ កដំ[១] សមាទាយ បិ-តោ វិមុត្តិប្បដិសេវនតាយ បិតោ មេត្តាយ ចារិសុទ្ធិយា បិតោ ករុណាយ មុទិតាយ ឧបេក្ខាយ ចារិសុទ្ធិ-យា បិតោ អច្ចន្តចារិសុទ្ធិយា បិតោ អកម្មញ្ញតាយ[២] បិតោ វិមុត្តត្តា បិតោ សន្តចិត្តតាយ បិតោ ខន្ធបរិ-យន្តេ បិតោ ធាតុបរិយន្តេ បិតោ អាយតនបរិយន្តេ បិតោ គតិបរិយន្តេ បិតោ ឧបបត្តិបរិយន្តេ បិតោ បដិ-សន្ធិបរិយន្តេ បិតោ ភវបរិយន្តេ បិតោ សំសារបរិ-យន្តេ បិតោ វដ្ដបរិយន្តេ បិតោ អន្តិមភវេ បិតោ អន្តិ-មសមុស្សយេ បិតោ អន្តិមទេហធរោ អរហា ។

តស្សាយំ បច្ឆិមកោ ភវោ ចរិមោយំ សមុស្សយោ
ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ ។

---

១ ម. កុដន្តិ អ.ទិ ។ ២ ម. អកម្មយតាយាតិ ភវិតព្វំ ។ អកម្មយតាយាតិ តណ្ហាទិដ្ឋិ មានា កម្មយាតិ វុច្ចន្តិ តេសំ អភាវោ អកម្យតា ។ កាមសុត្តនិទ្ទេសវណ្ណនាយំ ។

ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះកន្ទ(តណ្ហា) យ៉ាងនេះ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះរំលត់ភ្លើងគឺកិលេស ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះកិរិយាមិនត្រឡប់មកវិញ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះកាន់យកនូវជ័យជម្នះ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះកិរិយាសេពនូវវិមុត្តិ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះការបរិសុទ្ធដោយមេត្តា ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះការបរិសុទ្ធដោយករុណា មុទិតា ឧបេក្ខា ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះសេចក្តីបរិសុទ្ធដ៏ក្រៃលែង ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះភាពនៃលោក មិនគួរដល់ការងារ[1] ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះលោករួចស្រឡះ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះភាពនៃលោកមានចិត្តស្ងប់ ឈ្មោះថាអ្នកខ្ជាប់ខ្ជួនក្នុងទីបំផុតខន្ធ ខ្ជាប់ខ្ជួនក្នុងទីបំផុតធាតុ ខ្ជាប់ខ្ជួនក្នុងទីបំផុតអាយតនៈ ខ្ជាប់ខ្ជួនក្នុងទីបំផុតគតិ ខ្ជាប់ខ្ជួនក្នុងទីបំផុតការកើត ខ្ជាប់ខ្ជួនក្នុងទីបំផុតបដិសន្ធិ ខ្ជាប់ខ្ជួនក្នុងទីបំផុតភព ខ្ជាប់ខ្ជួនក្នុងទីបំផុតសំសារ ខ្ជាប់ខ្ជួនក្នុងទីបំផុតវដ្ដៈ ខ្ជាប់ខ្ជួនក្នុងភពទីបំផុត ខ្ជាប់ខ្ជួនក្នុងរាងកាយជាទីបំផុត ឈ្មោះថាព្រះអរហន្ត ទ្រទ្រង់នូវអត្តភាពជាទីបំផុត ។

ភពនេះនៃព្រះអរហន្តនោះ ចាត់ថាមានក្នុងទីបំផុត រាងកាយនេះ ចាត់ថាមានជាខាងក្រោយបង្អស់ ភពថ្មីគឺការអន្ទោលទៅដោយជាតិ ជរា និងមរណៈ នៃព្រះអរហន្តនោះមិនមាន ។

---

១ ពាក្យថា ការងារ ក្នុងទីនេះ បានដល់ តណ្ហា ទិដ្ឋិ មានៈ ។ អដ្ឋកថា ។

តិណ្ណោ ច ចារន្តិ ចារំ រុច្ចតិ អមតំ និព្ជានំ យោ
សោ សព្ជសង្ខារសមថោ សព្ជុបធិប្ជដិនិស្ជគ្គោ ត-
ណ្ហាក្ខយោ វិរាគោ និរោធោ និព្ជានំ ។ សោ ចារ-
កតោ ចារប្ជត្តោ អន្តកតោ អន្តប្ជត្តោ កោដិកតោ
កោដិប្ជត្តោ បរិយន្តកតោ បរិយន្តប្ជត្តោ ភោសាន-
កតោ ភោសានប្ជត្តោ តាណកតោ តាណប្ជត្តោ
លេណកតោ លេណប្ជត្តោ សរណកតោ សរណ-
ប្ជត្តោ អភយកតោ អភយប្ជត្តោ អច្ចុតកតោ អច្ចុ-
តប្ជត្តោ អមតកតោ អមតប្ជត្តោ និព្ជានកតោ និព្ជា-
នប្ជត្តោ សោ រុដ្ឋរាសោ ចិណ្ណចរណោ ។ បេ ។ ជា-
តិជរាមរណសំសារោ នត្ថិ តស្ជ បុនព្ភវោតិ តិណ្ណោ
ច ចារំ ។ អវិលោតិ រាគោ វិលោ ទោសោ វិលោ
មោហោ វិលោ កោធោ វិលោ ឧបនាហោ
វិលោ ។ បេ ។ សព្ជាកុសលាភិសង្ខារា វិលា ។

ពាក្យថា ទាំងធ្ងងដល់ត្រើយ សេចក្ដីថា អមតនិព្វាន លោកហៅថា ត្រើយ បានដល់ ការរម្ងាប់នូវសង្ខារទាំងពួង ការលាស់ចេញនូវឧបធិ ទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ទីរលត់ និព្វាន ។ ព្រះអរហន្តនោះ ទៅកាន់ត្រើយ ដល់ត្រើយ ទៅកាន់ទីបំផុត ដល់ ទីបំផុត ទៅកាន់ទីខាងចុង ដល់ខាងចុង ទៅកាន់ទីបំផុតជុំវិញ ដល់ ទីបំផុតជុំវិញ ទៅកាន់ទីចប់ ដល់ទីចប់ ទៅកាន់ទីពំនាក់ ដល់ទីពំ-នាក់ ទៅកាន់ទីជ្រកកោន ដល់ទីជ្រកកោន ទៅកាន់ទីពឹង ដល់ទី ពឹង ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីមិនច្យុត ដល់ទីមិនច្យុត ទៅកាន់អមត: ដល់អមត: ទៅកាន់ព្រះនិព្វាន ដល់ ព្រះនិព្វាន ព្រះអរហន្តនោះ មានការអប់រំនៅស្រេចហើយ មានចរណ-ធម៌ប្រព្រឹត្តហើយ ។ បេ ។ ភពថ្មីគឺការអន្ទោលទៅ ដោយជាតិជរ និងមរណៈរបស់ព្រះអរហន្តនោះមិនមាន ហេតុនោះ (ទ្រង់ត្រាស់ថា) ទាំងធ្ងងទៅដល់ត្រើយ ។ ពាក្យថា មិនមានបង្គោល សេចក្ដីថា បង្គោលគឺរាគ: បង្គោលគឺទោស: បង្គោលគឺមោហ: បង្គោលគឺកោធ: បង្គោលគឺឧបនាហ: ។ បេ ។ បង្គោលគឺការតាក់តែងអកុសលទាំងពួង ។

១៦៩

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

យស្សេតេ ខិលា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ អខិលោ ។ អកង្ខោតិ ទុក្ខេ កង្ខា ទុក្ខសមុទយេ កង្ខា ទុក្ខនិរោធេ កង្ខា ទុក្ខនិរោធគាមិនិយា បដិបទាយ កង្ខា បុព្វន្តេ កង្ខា អបរន្តេ កង្ខា បុព្វន្តាបរន្តេ កង្ខា ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ កង្ខា យា ឯវរូបា កង្ខា កង្ខាយនា កង្ខាយិតត្តំ វិមតិ វិចិកិច្ឆា ទ្វេឡ្ហកំ ទ្វេធាបថោ សំសយោ អនេកំសគ្គាហោ អាសប្បនា បរិសប្បនា អបរិយោគាហនា ឆម្ភិតត្តំ ចិត្តស្ស មនោវិលេខោ ។ យស្សេតា កង្ខា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចន្តិ អកង្ខោតិ តិណ្ណោ ច ចារំ អខិលោ អកង្ខោ ។ តេនាហ ភគវា

បង្គោលទាំងនោះ ព្រះអរហន្តណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ព្រះអរហន្តនោះ លោកហៅថា អ្នកមិនមានបង្គោល ។ ពាក្យថា មិនមានសេចក្តីជឿងធ្ងល់ សេចក្តីថា ការជឿងធ្ងល់ក្នុងទុក្ខ ការជឿងធ្ងល់ក្នុងសមុទយ ការជឿងធ្ងល់ក្នុងទុក្ខនិរោធ ការជឿងធ្ងល់ក្នុងទុក្ខនិរោធគា-មិនីបដិបទា ការជឿងធ្ងល់ក្នុងទីបំផុតខាងដើម ការជឿងធ្ងល់ក្នុងទីបំផុតខាងចុង ការជឿងធ្ងល់ ក្នុងទីបំផុតខាងដើមនិងខាងចុង ការជឿងធ្ងល់ក្នុងធម៌ទាំងឡាយ ដែលកើតឡើង ព្រោះអាស្រ័យឥទប្បច្ច័យ គឺបានដល់សេចក្តីជឿងធ្ងល់ អាការជឿងធ្ងល់ ភាពនៃសេចក្តីជឿងធ្ងល់ ការប្រាសចាកគំនិត សេចក្តីសង្ស័យ ហេតុបែកជាពីរ ផ្លូវបែកជាពីរ ការអល់ឯក ការកាន់យកច្រើនយ៉ាង ការកន្ទុះ ការអង្គឹអង្ហែ ការមិនចុះស៊ប់ ភាពនៃចិត្តស្ងន់ស្ងា ការប្រេះធានៃចិត្ត មានសភាពយ៉ាងនេះ ។ សេចក្តីជឿងធ្ងល់ទាំងនុ៎ះ ព្រះអរហន្តណា បានលះបង់ ផ្តាច់ផ្តិល ស្ងប់រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ព្រះអរហន្តនោះ លោកពោលថា អ្នកមិនមានសេចក្តីជឿងធ្ងល់ ហេតុនោះ (ទ្រង់ត្រាស់ថា) ទាំងធ្ងងដល់ត្រើយ ជាអ្នកមិនមានបង្គោល មិនមានសេចក្តីជឿងធ្ងល់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

យំ ព្រាហ្មណំ វេទគុំ អភិជញ្ញា
អកិញ្ចនំ កាមភវេ អសត្តំ
អជ្ជា ហិ សោ ឱឃមិមំ អតារិ
តិណ្ណោ ច ចារំ អទិសោ អកង្ខោតិ ។

[១៩៥] ទ្វិជ្ជា ច យោ វេទគូ ឧភោ ឥធ
ភវាភវេ សង្គមិមំ វិសជ្ជ
សោ វីតតណ្ហោ អនិឃោ និរាសោ
អត្តារិ សោ ជាតិជរន្តិ ព្រូមិ ។

[១៩៦] ទ្វិជ្ជា ច យោ វេទគូ ឧភោ ឥជាតិ
ទ្ធិជ្ជាតគោ ញាណី ទ្ធិការី មេធាវី ។ យោតិ យោ
យាទិសោ ។ បេ ។ មនុស្ស[1] ភ ។ វេទគូតិ វេទោ
ទ្ធុច្ចតិ ចតូសុ មគ្គេសុ ញាណំ ។ បេ ។ សព្វវេទមតិច្ច
វេទគូ សោតិ ។ ឧភោតិ សត្ថោ ឧភោ មាណវោ
ចោសោ បុត្តលោ ជីវោ ជាតុ ជន្តុ ឥន្ទ្ធគូ មនុជោ ។
ឥជាតិ ឥមិស្ស ទ្ធិជ្ជិយ ។ បេ ។ ឥមស្មឿ មនុស្ស-
លោកេតិ ទ្ទ្ធ ច យោ វេទគូ ឧភោ ឥធ ។

---

១ ម. យោតិ យោ យាទិសោ ។ បេ ។ មនុស្ស ភ្ជាតិ ឧត្ត ។

បុគ្គលគប្បីដឹងច្បាស់ នូវព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ អ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមភព ព្រាហ្មណ៍នោះ ឈ្មោះថា បានធ្វើឱ្យ:នេះ ដោយពិត ទាំងធ្វើដល់ត្រើយ ជាអ្នកមិនមានបង្គោល មិនមានសេចក្តីងឿងធ្ងល់ ។

[១៩៥] *នរ:ណា ជាអ្នកចេះដឹង អ្នកដល់នូវវេទ ក្នុងលោកនេះ បានស្រាយនូវការជាប់ចំពាក់នេះ ក្នុងភពតូចនិងភពធំ តថាគតពោលថា នរ:នោះ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរ:នោះ បានធ្វើនូវជាតិនិងជរា ។*

[១៩៦] *ពាក្យថា នរ:ណា ជាអ្នកចេះដឹង អ្នកដល់នូវវេទក្នុងលោកនេះ សេចក្តីថា នរ:ដែលសម្រេចវិជ្ជា មានញាណ មានការឈ្វេងយល់ មានប្រាជ្ញាធ្ងុះធ្ងាយ (ឈ្មោះថា ជាអ្នកចេះដឹង) ។ ពាក្យថា ណា គឺអ្នកណា បែបណា ។ បេ ។ ទោះជាមនុស្សក្តី ។ ពាក្យថា អ្នកដល់នូវវេទ សេចក្តីថា ញាណក្នុងមគ្គ ៤ លោកហៅថា វេទ ។ បេ ។ បុគ្គលនោះដល់នូវវេទ ព្រោះកន្ទងនូវវេទទាំងពួង ។ ពាក្យថា នរ: បានដល់ សត្វ នរ: មាណព បុរស បុគ្គល ជីវ: ជនជាតិ សត្វ ជាតុ សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា ក្នុងលោកនេះ គឺក្នុងទិដ្ឋិនេះ ។ បេ ។ ក្នុងមនុស្សលោកនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) នរ:ណា ជាអ្នកចេះដឹង អ្នកដល់នូវវេទក្នុងលោកនេះ*

[១៩៧] ភវាភវេ សង្គមិមំ វិសជ្ជាតិ ភវាភវេតិ ភវាភវេ កម្មភវេ បុនព្ភវេ កាមភវេ កម្មភវេ កាមភវេ បុនព្ភវេ រូបភវេ កម្មភវេ រូបភវេ បុនព្ភវេ អរូបភវេ កម្មភវេ អរូបភវេ បុនព្ភវេ បុនប្បុនំ ភវេ បុនប្បុនំ គតិយា បុនប្បុនំ ឧបបត្តិយា បុនប្បុនំ បដិសន្ធិយា បុនប្បុនំ អត្តភាវាភិនិព្វត្តិយា ។ សង្គន្តិ សត្ត សង្គា រាគសង្គោ ទោសសង្គោ មោហសង្គោ មានសង្គោ ទិដ្ឋិសង្គោ កិលេសសង្គោ ទុច្ចរិតសង្គោ ។ វិសជ្ជាតិ សង្គេ វោស្សជ្ជិត្វា វា វិសជ្ជ ។ អថវា សង្គេ ពន្ធេ[១] អាពន្ធេ លគ្គេ លគ្គិតេ បលិពុទ្ធេ ពន្ធនេ មោចយិត្វា[២] វា វិសជ្ជ យថា ច យានំ វា វយ្ហំ វា រថំ វា សកដំ វា សន្ទមានិកំ វា សជ្ជំ វិសជ្ជំ ករោន្តិ វិកោបេន្តិ ឯវមេវ តេ សង្គេ វោស្សជ្ជិត្វា វា វិសជ្ជ អថវា សង្គេ ពន្ធេ អាពន្ធេ លគ្គេ លគ្គិតេ បលិពុទ្ធេ ពន្ធនេ មោចយិត្វា វា វិសជ្ជាតិ ភវាភវេ សង្គមិមំ វិសជ្ជ ។

---

១ ម. ពន្ធេ វិពន្ធេ ។ ២ ម. ពោជយិត្វា ។

[១៩៧] *ពាក្យថា បានស្រាយនូវការជាប់ចំពាក់នេះ ក្នុងកពតូចនិងកពធំ ត្រង់ពាក្យថាក្នុងកពតូចនិងកពធំ គឺក្នុងកម្មកព បុនព្ភព ឈ្មោះថាកពតូចនឹងកពធំ កាមកព ឈ្មោះថាកម្មកព កាមកព ឈ្មោះថាបុនព្ភព រូបកព ឈ្មោះថាកម្មកព រូបកព ឈ្មោះថាបុនព្ភព អរូបកព ឈ្មោះថាកម្មកព អរូបកពឈ្មោះថាបុនព្ភព គឺក្នុងការកើតរឿយៗ ក្នុងការទៅរឿយៗ ក្នុងការចូលទៅរឿយ ៗ ក្នុងបដិសន្ធិរឿយ ៗ ក្នុងការកើតអត្តភាពរឿយ ៗ ។ ពាក្យថា ការជាប់ចំពាក់ បានដល់ ការជាប់ចំពាក់ ៧ គឺការជាប់ចំពាក់គឺរាគ: ការជាប់ចំពាក់គឺទោស: ការជាប់ចំពាក់គឺមោហ: ការជាប់ចំពាក់គឺមានៈ ការជាប់ចំពាក់គឺទិដ្ឋិ ការជាប់ចំពាក់គឺកិលេស ការជាប់ចំពាក់គឺទុច្ចរិត ។ ពាក្យថា ស្រាយ គឺ រលាស់ចេលឬដោះ នូវការជាប់ចំពាក់ទាំងឡាយ ។ មួយទៀត បុគ្គលដោះឬស្រាយ នូវការជាប់ចំពាក់ គឺ ចំណងដែលចង ចងទូទៅ ជ្ជក់ ទាក់ ចំពាក់ ពួកជនរុះរើ ធ្វើឲ្យខ្ទេចខ្ទី នូវយានក្តី រ៉ក្តី រថក្តី រទេះក្តី រថទ្រង់គ្រឿងក្តី យ៉ាងណាមិញ បុគ្គលរលាស់ចេលឬលះចេញ នូវការជាប់ចំពាក់ទាំងនោះ ក៏យ៉ាងនោះដែរ មួយវិញទៀត បុគ្គលដោះចេញ ឬស្រាយ នូវការជាប់ចំពាក់ គឺចំណង ដែលចង ចងទូទៅ ជ្ជក់ ទាក់ ចំពាក់ ហេតុនោះ (ទ្រង់ត្រាស់ថា) បានស្រាយនូវការជាប់ចំពាក់នេះ ក្នុងកពតូចនិងកពធំ ។*

[១៩៨] សោ រីតតណ្ហោ អនិឃោ និរាសោ អត្តារ
សោ ជាតិជរន្តិ ព្រូមីតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា
គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។
យស្សេសា តណ្ហា បហីនា សមុច្ឆិន្នា រូបសន្ធា
បដិប្ឋស្សទ្ធា អភព្វុប្ឋត្តិកា ញាណាគ្គិនា ឌឌ្ឍា សោ
រុច្ចតិ រីតតណ្ហោ ចត្តតណ្ហោ វន្តតណ្ហោ មុត្តតណ្ហោ
បហីនតណ្ហោ បដិនិស្សដ្ឋតណ្ហោ រីតរាគោ ចត្ត-
រាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្ស-
ដ្ឋរាគោ និច្ឆាតោ និព្ពុតោ សីតិភូតោ សុខប្ឋដិ-
សំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ សោ រីត-
តណ្ហោ ។ អនិឃោតិ រាគោ នីឃោ ទោសោ នីឃោ
មោហោ នីឃោ កោធោ នីឃោ ឧបនាហោ
នីឃោ ។ បេ ។ សញ្ញាកុសលាកិសង្ខារ នីឃា ។

[១៩៨] *អធិប្បាយពាក្យថា តថាគតពោលថា នរៈនោះជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះ បានធ្វើនូវជាតិនិងជរា ត្រង់ពាក្យថា តណ្ហា បានដល់ រូប-តណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហានុ៎ះ នរៈណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ឲ្យសូន្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ នរៈនោះលោកហៅថា អ្នកប្រាសចាកតណ្ហា លះចោលតណ្ហា ខ្ជាក់ចោលតណ្ហា ផុតចាកតណ្ហា បន្សាត់ចោលតណ្ហា រលាស់ចេញចាកតណ្ហា ប្រាសចាករាគៈ លះចោលរាគៈ ខ្ជាក់ចោលរាគៈ ផុតចាករាគៈ បន្សាត់ចោលរាគៈ រលាស់ចេញចាករាគៈ មិនមានសេចក្តីប្រាថ្នា រលត់ទុក្ខ មានចិត្តត្រជាក់ សោយសុខ មានចិត្តត្រជាក់ ហេតុនោះ (ទ្រង់ត្រាស់ថា) នរៈនោះប្រាសចាកតណ្ហា ។ ពាក្យថា មិនមានសេចក្តីតានតឹង សេចក្តីថា រាគៈ ជាសេចក្តីតានតឹង ទោសៈ ជាការតានតឹង មោហៈ ជាការតានតឹង កោធៈ ជាការតានតឹង ឧបនាហៈ ជាការតានតឹង ។ បេ ។ ការតាក់តែង នូវអកុសលទាំងពួង ជាការតានតឹង ។*

យស្សេតេ នីយា បហីនា សមុច្ឆិន្នា រូបសន្តា បដិប្ប-
ស្សទ្ធា អភព្ពុប្បត្តិកា ញាណក្តិនា ឌឌ្ឍា សោ រុច្ចតិ
អនីឃោ ។ និរាសោតិ អាសា រុច្ចតិ តណ្ហា យោ
រាគោ សារាគោ ។ បេ ។ អកិញ្ចនោ លោកោ អកុស-
លមូលំ ។ យស្សេសា អាសា តណ្ហា បហីនា
សមុច្ឆិន្នា រូបសន្តា បដិប្ប្ស្សទ្ធា អភព្ពុប្បត្តិកា ញាណ-
ក្តិនា ឌឌ្ឍា សោ រុច្ចតិ និរាសោ ។ ជាតីតិ យា តេសំ
តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ
សញ្ជាតិ ឱក្កន្តិ និព្ពត្តិ អភិនិព្ពត្តិ ខន្ធានំ ចាតុ-
ភូមកានំ អាយតនានំ បដិលាភោ ។ ជរាតិ យា
តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា
ជីរណតា ខណ្ឌិច្ចំ ចាលិច្ចំ វលិត្តចតា អាយុនោ
សំហានិ ឥន្ទ្រិយានំ បរិបាកោ ។ មរណន្តិ
យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិ-
កាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ
មរណំ កាលកិរិយា ខន្ធានំ ភេទោ ការេ្ប-
រស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ។

សេចក្តីតានតឹងទាំងនុ៎ះ នរៈណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ឲ្យស្ងប់ រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ នរៈនោះ លោកហៅថា អ្នកមិនមានសេចក្តីតានតឹង ។ ពាក្យថា មិនមានសេចក្តីប៉ុនប៉ង សេចក្តីថា តណ្ហា លោកហៅថា សេចក្តីប៉ុនប៉ង បានដល់ ភគៈ ភគៈមានកម្លាំង ។ បេ ។ អកិញ្ចា លោកៈ អកុសលមូល ។ តណ្ហា គឺសេចក្តីប៉ុនប៉ងនោះ នរៈណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ឲ្យស្ងប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងញាណហើយ នរៈនោះ លោកហៅថា អ្នកមិនមានសេចក្តីប៉ុនប៉ង ។ ពាក្យថា ជាតិ បានដល់ កំណើត ការកើតព្រម ការចុះកាន់គភ៌ ការផ្ទួចផ្តើម ការចម្រើនឡើង ការកើតប្រាកដនៃខន្ធ ការបានចំពោះនូវអាយតនៈ នៃពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ។ ពាក្យថា ជរា បានដល់ ការចាស់ ការគ្រាំគ្រា ការបាក់ធ្មេញ ការស្កូវសក់ ការជ្រួញជ្រីវស្បែក ការរួញថយនៃអាយុ ការចាស់ឥន្ទ្រិយ នៃពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ។ ពាក្យថា មរណៈ បានដល់ ការចុតិ ការឃ្លាត ការបែកធ្លាយ ការអន្តរធាន មច្ចុ មរណៈ កាលកិរិយា ការបែកធ្លាយខន្ធ ការដាក់ចោលនូវសាកសព ការដាច់សូន្យជីវិតិន្ទ្រិយ នៃពួកសត្វនោះ ៗ ក្នុងសត្តនិកាយនោះ ៗ ។

សោ រីតតណ្ហោ អនិយោ និរាសោ អត្ថារិ សោ ជាតិ-ជរន្តិ ព្រូមីតិ យោ សោ រីតតណ្ហោ ច អនីយោ ច និរាសោ ច សោ ជាតិជរាមរណំ អត្ថារិ បតរិ សមតិក្កមិ រីតិវត្តីតិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ រីរាមិ រិកជាមិ ឧត្ថានីករោមិ បការេសមីតិ សោ រីតតណ្ហោ អនិយោ និរាសោ អត្ថារិ សោ ជាតិជរន្តិ ព្រូមិ ។ តេនាហ ភគវា

រិត្ថា ច យោ ឯតេ ន ហោ ឥធ
ភវាភវេ សង្ខ្ហមិមំ រិសជ្ជ
សោ រីតតណ្ហោ អនិយោ និរាសោ
អត្ថារិ សោ ជាតិជរន្តិ ព្រូមីតិ ។

សហ តាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

ពាក្យថា តថាគតពោលថា នរៈនោះ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះបានធ្វើនូវជាតិ និងជរា បានសេចក្តីថា តថាគត ពោល ប្រាប់ សម្តែង បញ្ញត្ត តាំង ទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសថា នរៈណានោះ ប្រាសចាកតណ្ហាផង មិនមានសេចក្តីតានតឹងផង មិនមានសេចក្តីប៉ុនប៉ងផង នរៈនោះ បានធ្វើ ធ្វើកាត់ ឈានកន្ទ្ង ប្រព្រឹត្តកន្ទ្ង នូវជាតិជរានិងមរណៈ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតពោលថា នរៈនោះ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះ បានធ្វើនូវជាតិនិងជរា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> *នរៈណា ជាអ្នកចេះដឹង អ្នកដល់នូវវេទ ក្នុងលោកនេះ បានស្រាយ នូវការជាប់ចំពាក់នេះ ក្នុងភពតូចនិងភពធំ តថាគតពោលថា នរៈនោះ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះ បានធ្វើនូវជាតិនិងជរា ។*

(មេត្តគូបានប្រកាសខ្លួន) ដំណាលគ្នានឹងកាលជាទីចប់គាថា ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំ ព្រះអង្គជាសាវ័ក ។

ចប់ មេត្តគូមាណវកប្បញ្ហានិទ្ទេស ទី ៤ ។

ធោតកមាណវកបញ្ហានិទ្ទេសោ

[១៩៩] បុច្ឆামិ តំ ភគវា ព្រូហិ មេ តំ

(ឥច្ចាយស្មា ធោតកោ)

វាចាភិកង្ខាមិ មហេសិ តុយ្ហំ

តវ សុត្វាន និក្ខេសំ

សិក្ខេ និព្ពានមត្តនោ ។

[២០០] បុច្ឆামិ តំ ភគវា ព្រូហិ មេ តន្តិ បុច្ឆ-
មីតិ តិស្សេ បុច្ឆា អនិជ្ឌនោតនា បុច្ឆា និជ្ឌសំ-
សន្ធនា បុច្ឆា វិមតិច្ឆេទនា បុច្ឆា ។ បេ ។ ឥមា
តិស្សេ បុច្ឆា ។ បេ ។ និព្ពានបុច្ឆា ។ បុច្ឆামិ តន្តិ
បុច្ឆামិ តំ យាចាមិ តំ អជ្ឈេសាមិ តំ បសាទេមិ
តំ កថយ្ស[1] មេតិ បុច្ឆামិ តំ ។ ភគវាតិ ការណនិ-
ទ្ទេសមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ។

---

1 ម. កថយ្ស ។

ធោតកមាណវកប្បញ្ហានិទ្ទេស

[១៩៩] ធោតក:មានអាយុ (ទូលសួរដូច្នេះថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ បពិត្រព្រះមហេសី ខ្ញុំព្រះអង្គ ប្រាថ្នា (ស្តាប់) ព្រះពុទ្ធដីការបស់ព្រះអង្គ (ព្រោះថា) បុគ្គលស្តាប់ទេសនា របស់ព្រះអង្គហើយ នឹងសិក្សានូវការរំលត់ (កិលេស) របស់ខ្លួនបាន ។

[២០០] អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ សូមព្រះអង្គ សម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា សូមសួរ បានដល់បុច្ឆា ៣ គឺ អទិដ្ឋជោតនាបុច្ឆា ១ ទិដ្ឋសំសន្ទនាបុច្ឆា ១ វិមតិច្ឆេទនាបុច្ឆា ១ ។ បេ ។ នេះ បុច្ឆា ៣ ។ បេ ។ និព្វានបុច្ឆា ។ ពាក្យថា ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ គឺខ្ញុំព្រះអង្គ សូមសួរចំពោះព្រះអង្គ សូមអង្វរព្រះអង្គ សូមអារាធនាព្រះអង្គ សូមជ្រះថ្លានឹងព្រះអង្គ សូមព្រះអង្គសម្តែង ដល់ខ្ញុំព្រះអង្គ ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ ។ ពាក្យថា ព្រះមានព្រះភាគ នេះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ។

ព្រូហិ មេ តន្តិ ព្រូហិ អាចិក្ខាហិ ទេសេហិ
បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានី-
ករោហិ បកាសេហីតិ បុច្ឆាមិ តំ ភគវា ព្រូហិ
មេ តំ ។ ឥច្ចាយស្មា ឆោតកោតិ ឥច្ចាតិ បទសន្ធិ ។
អាយស្មាតិ បិយវចនំ[1] ។ ឆោតកោតិ តស្ស
ព្រាហ្មណស្ស នាមំ ។ បេ ។ អកិលាចោតិ ឥច្ចាយស្មា
ឆោតកោ ។

[២០១] ឱ្យាកិកង្ខាមិ មហេសិ តុយ្ហន្តិ តុយ្ហំ វចនំ
ឲ្យបមំ ទេសនំ អនុសន្ធិ កង្ខាមិ អភិកង្ខាមិ ឥច្ឆាមិ
សាធិយាមិ បត្ថយាមិ បិហេមិ អភិជប្ប៎ាមិ ។ មហេ-
សីតិ ភោជនត្ថេន មហេសី ។ ភគវា មហន្តំ សីលក្ខន្ធំ
ឯសិ គវេសិ បរិយេសីតិ មហេសី ។ បេ ។ ភគវា ជ-
ាសភោតិ មហេសីតិ ឱ្យាកិកង្ខាមិ មហេសិ តុយ្ហំ ។

---

១ ម. បិយវចនំ គរុវចនំ សគារវសប្ប៎ាតិស្ស្ យាធិវចនមេតំ អាយស្មាតិ ។

ពាក្យថា សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គ ពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយ ប្រកាស ហេតុនោះ (លោកពោលថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូម ទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនុ៎ះ ដល់ខ្ញុំព្រះអង្គ ។ ពាក្យថា ដូច្នេះ នៃបទថា ជោតក:មានអាយុ ពោលដូច្នេះ គឺជាបទតភ្ជាប់ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា ជោតក-មាណព ជាឈ្មោះ ។ បេ ។ ជាពាក្យហៅ របស់ព្រាហ្មណ៍នោះ ។ ហេតុនោះ (មានពាក្យថា) ជោតក:មានអាយុ ទូលសួរដូច្នេះ ។

[២០១] ពាក្យថា បពិត្រព្រះមហេសី ខ្ញុំព្រះអង្គប្រាជ្ញ (ស្តាប់) ព្រះពុទ្ធដីកា របស់ព្រះអង្គ គឺខ្ញុំព្រះអង្គ ប្រាជ្ញ ប្រាជ្ញចំពោះ ប ច ជ្រះ ថ្ម ផ្ត ស្រឡាញ់ ជាប់ចិត្ត នូវព្រះពុទ្ធដីកា គន្ធងនៃព្រះពុទ្ធដីកា ទេសនា អនុសន្ធិ របស់ព្រះអង្គ ។ សំណួរត្រង់ពាក្យថា មហេសី ចុះ ឈ្មោះថា មហេសី ដោយអត្ថដូចម្តេច ។ ឈ្មោះថា មហេសី ព្រោះ ព្រះមានព្រះភាគ ទ្រង់រក សែ្វង ស្វះសែ្វង នូវកងសីលដ៏ធំ ។ បេ ។ ឈ្មោះថា មហេសី ព្រោះព្រះអង្គ ជានរ:ប្រសើរ គង់ក្នុងទីណា ហេតុនោះ (លោកពោលថា) បពិត្រព្រះមហេសី ខ្ញុំព្រះអង្គ ប្រាជ្ញ (ស្តាប់) ព្រះពុទ្ធដីកា របស់ព្រះអង្គ ។

ធោតកមាណវកប្បញ្ហានិទ្ទេសោ

[២០២] តេ សុត្វាន និក្ខ្លេសន្តិ តុយ្ហំ វចនំ ព្យបថំ ឧេសនំ អនុសន្ធឺ សុត្វាន សុណិត្វា ឧក្ខណ្ហិត្វា ឧបជ្ឌាយិត្វា ឧបលក្ខយិត្វាតិ តេ សុត្វាន និក្ខ្លេសំ ។

[២០៣] សិក្ខេ និព្វានមត្តនោតិ សិក្ខេតិ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ បេ ។ អយំ អធិប្បញ្ញាសិក្ខា ។ និព្វានមត្តនោតិ[1] ភគ្គស្ស និព្វានាយ ឧោសស្ស និព្វានាយ មោហ-ស្ស និព្វានាយ ឧោកនស្ស និព្វានាយ ឧបនាហស្ស និព្វានាយ ។ បេ ។ សព្វាកុសលាភិសង្ខ្លារានំ សមាយ ឧបសមាយ ១ូបសមាយ និព្វានាយ បដិនិស្សគ្គាយ បដិប្ប១ស្ស១ទ្ធិយា អធិសីលម្ហិ សិក្ខេយ្យ អធិចិត្តម្ហិ សិក្ខេយ្យ អធិប្បញ្ញម្ហិ សិក្ខេយ្យ ឥមា តិស្សោ សិក្ខា អាវជ្ជេន្តោ សិក្ខេយ្យ ជានន្តោ សិក្ខេយ្យ បស្សន្តោ សិក្ខេយ្យ បច្ចវេក្ខន្តោ សិក្ខេយ្យ ចិត្តំ អធិដ្ឌហន្តោ[2] សិក្ខេយ្យ សទ្ធាយ អធិមុច្ចន្តោ សិក្ខេយ្យ ១ីរិយំ បគ្គណ្ហ-ន្តោ សិក្ខេយ្យ សតឺ ឧបដ្ឌបេន្តោ សិក្ខេយ្យ ចិត្តំ ស-មាធហន្តោ សិក្ខេយ្យ បញ្ញាយ បជានន្តោ សិក្ខេយ្យ

---

១ ម. ឯត្ថន្តរេ អត្តនោ អត្ថិ ។ ២ ម. បទហន្តោ ។

ធោតកមាណវកប្បញ្ហានិទ្ទេស

[២០២] ពាក្យថា បុគ្គលស្តាប់ទេសនា របស់ព្រះអង្គហើយ គឺ បុគ្គលស្តាប់ ឮ រៀន ទ្រទ្រង់ កំណត់ទុកហើយ នូវព្រះពុទ្ធដីកា គន្ធង់ព្រះពុទ្ធដីកា ទេសនា អនុសន្ធិ របស់ព្រះអង្គ ហេតុនោះ (លោកពោលថា) បុគ្គលស្តាប់ទេសនា របស់ព្រះអង្គហើយ ។

[២០៣] អធិប្បាយពាក្យថា សិក្សា នូវការរំលត់ (កិលេស) របស់ខ្លួនបាន ត្រង់ពាក្យថា សិក្សា បានដល់សិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ បេ ។ នេះ អធិប្បញ្ញាសិក្ខា ។ ពាក្យថា នូវការរំលត់ (កិលេស) របស់ខ្លួនបាន គឺនឹងសិក្សាអធិសីលផង នឹងសិក្សាអធិចិត្តផង នឹងសិក្សាអធិប្បញ្ញាផង ដើម្បីការរំលត់រាគៈ រំលត់ទោសៈ រំលត់មោហៈ រំលត់កោធៈ រំលត់ឧបនាហៈ ។ បេ ។ ដើម្បីសេចក្តីស្ងប់ រម្ងាប់ ចូលទៅជិតស្ងប់ រំលត់ លះបង់ លះបង់ផ្តាច់ នូវអកិសង្ខារ ជាអកុសលទាំងពួង គឺ នឹងពិចារណាសិក្សា នូវសិក្ខាទាំង ៣ នេះ នឹងដឹងសិក្សា នឹងឃើញសិក្សា នឹងពិចារណាសិក្សា នឹងតាំងចិត្តសិក្សា នឹងចុះចិត្តស៊ប់ដោយសទ្ធាសិក្សា នឹងផ្គងព្យាយាមសិក្សា នឹងប្រុងសតិសិក្សា នឹងតម្កល់ចិត្តឲ្យស្រួលសិក្សា នឹងដឹងដោយប្រាជ្ញាសិក្សា

អភិញ្ញាយ អភិជានន្តោ សិក្ខេយ្យ បរិញ្ញាយ បរិជានន្តោ សិក្ខេយ្យ បហាតព្ពំ បជហន្តោ សិក្ខេយ្យ ភាវេតព្ពំ ភាវេន្តោ សិក្ខេយ្យ សច្ឆិកាតព្ពំ សច្ឆិករោន្តោ សិក្ខេយ្យ សមាធាយ ចរេយ្យ សមាធាយ វត្តេយ្យាតិ សិក្ខេ និព្ពានមត្តនោ ។ តេនាហ សោ ព្រាហ្មណោ

បុច្ឆামិ តំ ភគវា ព្រូហិ មេ តំ

(ឥច្ចាយស្មា ឧទតគោ)

ឱចាកិកង្ខាមិ មហេសិ តុយ្ហំ

តវ សុត្វាន និក្ខ្លេសំ

សិក្ខេ និព្ពានមត្តនោតិ ។

[២០៤] តេនហាតប្ប ការោហិ

(ឧទតគាតិ ភគវា)

ឥធេវ និបកោ សតោ

ឥតោ សុត្វាន និក្ខ្លេសំ

សិក្ខេ និព្ពានមត្តនោ ។

នឹងដឹងជាក់ដោយអភិញ្ញាសិក្សា នឹងកំណត់ដឹងដោយបរិញ្ញាសិក្សា នឹងលះបង់នូវធម៌ដែលគួរលះបង់សិក្សា នឹងចម្រើននូវធម៌ដែលគួរចម្រើនសិក្សា នឹងធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា នឹងប្រព្រឹត្តសមាទាននឹងប្រតិបត្តិសមាទាន ហេតុនោះ លោកពោលថាសិក្សា នូវការរំលត់ (កិលេស) របស់ខ្លួនបាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ បពិត្រព្រះមហេសី ខ្ញុំព្រះអង្គប្រាថ្នា(ស្តាប់) ព្រះពុទ្ធដីការបស់ព្រះអង្គ (ព្រោះថា) បុគ្គលស្តាប់ទេសនារបស់ព្រះអង្គហើយ នឹងសិក្សានូវការរំលត់ (កិលេស) របស់ខ្លួនបាន ។

[២០៤] *(ព្រះមានព្រះភាគ ត្រាស់ថា) ម្នាលធោតក: បើដូច្នោះ ចូរអ្នកធ្វើសេចក្តីព្យាយាមចុះ បុគ្គលក្នុងលោកនេះ ជាអ្នកមានបញ្ញាចាស់ក្លា មានស្មារតី ស្តាប់ទេសនាអំពីទីនេះហើយ នឹងសិក្សានូវការរំលត់ (កិលេស)របស់ខ្លួនបាន ។*

ធោតកមាណវកប្បញ្ហានិទ្ទេសោ

[២០៥] តេនហាតប្បំ ភវេហីតិ អាតប្បំ ភវេ-
ហិ ឧស្សាហំ ភវេហិ ឧស្សាហ្ជ្ជ ភវេហិ ភ-
យាមំ[១] ភវេហិ ជិតឺ ភវេហិ វីរិយំ ភវេហិ
ឆន្ទំ ជនេហិ សញ្ជនេហិ ឧបដ្ឋបេហិ[២] ជិញ្ជតេហិ
អភិជិញ្ជតេហីតិ តេនហាតប្បំ ភវេហិ ។ ធោតកាតិ
ភគវាតិ ធោតកាតិ ភគវា តំ ព្រាហ្មណំ ជាមេន
អាលបតិ ។ ភគវាតិ ការវាជិវចនមេតំ ។ បេ ។
សច្ចិកា បញ្ញត្តិ យជិទំ ភគវាតិ ធោតកាតិ ភគវា ។

[២០៦] ឥធេវ ជិបភោ សតោតិ ឥជាតិ ឥមិស្សា
ជិដ្ឋិយា ឥមិស្សា ១ន្ជិយា ឥមិស្សា រុចិយា ឥមស្មឺ អា-
ជាយេ ឥមស្មឺ ជម្មេ ឥមស្មឺ វិនយេ ឥមស្មឺ ជម្មវិនយេ
ឥមស្មឺ ចារ១ជេ ឥមស្មឺ ព្រហ្មចរិយេ ឥមស្មឺ សត្ថុសា-
សនេ ឥមស្មឺ អត្ថភាវេ ឥមស្មឺ មនុស្សលោកេ ។

---

១ ម. ថាមំ ។ ២ ម. ឧបដ្ឋបេហិ សមុដ្ឋបេហិ ។

ធោតកមាណវកបញ្ហានិទ្ទេស

[២០៥] ពាក្យថា បើដូច្នោះ ចូរអ្នកធ្វើសេចក្តីព្យាយាមចុះ គឺអ្នកចូរធ្វើសេចក្តីព្យាយាម ចូរធ្វើឧស្សាហ៍ ចូរធ្វើសេចក្តីប្រឹងប្រែង ចូរធ្វើសេចក្តីសង្វាត ចូរធ្វើសេចក្តីឱហាត ចូរធ្វើសេចក្តីខ្នះខ្នែង ចូរធ្វើសេចក្តីខ្ចីឃ្នាត ចូរញ៉ាំងសេចក្តីពេញចិត្តឲ្យកើត ឲ្យកើតព្រម ឲ្យតាំងនៅស៊ប់ សួន ឲ្យដុះ ឲ្យដុះចំពោះ ហេតុនោះ (ទ្រង់ត្រាស់ថា) បើដូច្នោះ អ្នកចូរធ្វើសេចក្តីព្យាយាមចុះ ។ ពាក្យថា ធោតក: នៃបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលធោតក: គឺព្រះមានព្រះភាគ ហៅព្រាហ្មណ៍នោះ ដោយចំឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគនេះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគនេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលធោតក: ។

[២០៦] អធិប្បាយពាក្យថា បុគ្គលក្នុងលោកនេះ ជាអ្នកមានបញ្ញាចាស់ក្លា មានស្មារតី ត្រង់ពាក្យថា ក្នុងលោកនេះ គឺក្នុងទិដ្ឋិនេះ ក្នុងសេចក្តីពេញចិត្តនេះ ក្នុងសេចក្តីគាប់ចិត្តនេះ ក្នុងការកាន់យកនេះ ក្នុងធម៌នេះ ក្នុងវិនិ័យនេះ ក្នុងធម្មវិនិ័យនេះ ក្នុងពាក្យជាប្រធាននេះ ក្នុងព្រហ្មចារ្យនេះ ក្នុងសាសនាព្រះសាស្តានេះ ក្នុងអត្តភាពនេះ ក្នុងមនុស្សលោកនេះ ។

ជិបកោតិ ជិបកោ បណ្ហិតោ បញ្ញវា ពុទ្ធិមា ញា-ណី វិភាវី មេធាវី ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ សតោ ។ បេ ។ សោ រុច្ចតិ សតោតិ ឥធេវ ជិបកោ សតោ ។

[២០៧] ឥតោ សុត្វាន ជិក្ខ្លាសន្តិ ឥតោ មយ្ហំ វចនំ ព្យបថំ ឧេសនំ អនុសន្ធឺ សុត្វាន សុណិត្វា ឧគ្គហិ-ត្វា ឧបធារយិត្វា ឧបលក្ខយិត្វាតិ ឥតោ សុត្វាន ជិក្ខ្លាសំ ។

[២០៨] សិក្ខេ ជិញ្ញានមត្តោតិ សិក្ខេតិ តិ-ស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិ-ប្បញ្ញាសិក្ខា ។ បេ ។ អយំ អធិប្បញ្ញាសិក្ខា ។ ជិញ្ញានមត្តោតិ ភាគស្ស ជិញ្ញាបនាយ ឧោសស្ស ជិញ្ញាបនាយ មោហស្ស ជិញ្ញាបនាយ ឧោឆស្ស ជិញ្ញាបនាយ ឧបនាហស្ស ជិញ្ញាបនាយ ។ បេ ។

ពាក្យថា មានបញ្ញាចាស់ក្លា គឺ មានបញ្ញាធ្ងន់ ជាបណ្ឌិតមានប្រាជ្ញា មានការចេះដឹង មានញាណ ជាអ្នកប្រាជ្ញ មានប្រាជ្ញាជាគ្រឿងទម្លាយបង់នូវកិលេស ។ ពាក្យថា មានស្មារតី គឺមានស្មារតី ដោយហេតុ ៤ គឺ បុគ្គលកំពុងចម្រើនកាយានុបស្សនាសតិប្ឋានក្នុងកាយ ឈ្មោះថា អ្នកមានស្មារតី ។ បេ ។ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលក្នុងលោកនេះ ជាអ្នកមានបញ្ញាចាស់ក្លា មានស្មារតី ។

[២០៧] ពាក្យថា ស្តាប់ទេសនា អំពីទីនេះហើយ គឺស្តាប់ ត្រង ត្រាប់ រៀន ទ្រទ្រង់ កំណត់ទុក នូវពាក្យ គន្ធងពាក្យ ទេសនា អនុសន្ធិ របស់តថាគត អំពីទីនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ស្តាប់នូវទេសនា អំពីទីនេះហើយ ។

[២០៨] អធិប្បាយពាក្យថា នឹងសិក្សានូវការរំលត់ (កិលេស) របស់ខ្លួន ត្រង់ពាក្យថា នឹងសិក្សា បានដល់សិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ បេ ។ នេះ អធិប្បញ្ញាសិក្ខា ។ ពាក្យថា ការរំលត់ (កិលេស) របស់ខ្លួន គឺនឹងសិក្សាអធិសីលផង នឹងសិក្សាអធិចិត្តផង នឹងសិក្សាអធិប្បញ្ញាផង ដើម្បីការរំលត់រាគៈ ការរំលត់ទោសៈ ការរំលត់មោហៈ ការរំលត់កោធៈ ការរំលត់ឧបនាហៈ ។ បេ ។

ធោតកមាណវកប្បញ្ហានិទ្ទេសោ

សព្វាកុសលាភិសង្ខារានំ សមាយ ឧបសមាយ រូបស-
មាយ និញ្ជាបនាយ បដិនិស្សគ្គាយ បដិប្ប្ស្ស្ទ្ធិយា
អធិសីលម្ហិ សិក្ខេយ្យ អធិចិត្តម្ហិ សិក្ខេយ្យ អធិ-
ប្ប ញ្ញ ម្ហិ សិក្ខេយ្យ ឥមា តិស្សោ សិក្ខា អាវជ្ជេន្តោ
សិក្ខេយ្យ ជានន្តោ សិក្ខេយ្យ ។ បេ ។ សច្ចិកាតព្ពំ
សច្ចិករោន្តោ សិក្ខេយ្យ សមាធាយ[1] ចរេយ្យ សមា-
ធាយ រត្តេយ្យាតិ សិក្ខេ និញ្ជានមត្តនោ ។ តេនាហ ភគវា

តេនហាតប្ប ំ ករោហិ [ធោតការាតិ ភគវា]
ឥធេវ និបកោ សតោ
ឥតោ សុត្វាន និគ្ឃោសំ សិក្ខេ និញ្ជានមត្តនោតិ ។

[២០៩] បស្សាមហំ ទេវ មនុស្សលោកេ
អកិញ្ចនំ ព្រាហ្មណំ ឥរិយមានំ
តន្តំ នមស្សាមិ សមន្តចក្ខុ
បមុញ្ច មំ សក្ក កថំកថាហិ ។

---

១ ម. អាទាយ សមាទាយ ។

ដើម្បីការសូប់ រម្ងាប់ សូប់រម្ងាប់ រំលត់ លះបង់ រម្ងាប់ នូវអកិសង្ខារ ជាអកុសលទាំងពួង នឹងពិចារណាសិក្សា នូវសិក្ខាទាំង ៣ នេះ នឹងដឹងសិក្សា ។ បេ ។ នឹងធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា នឹងប្រព្រឹត្តសមាទាន នឹងប្រតិបត្តិសមាទាន ហេតុនោះ (ទ្រង់ត្រាស់ថា) នឹងសិក្សានូវការរំលត់ (កិលេស) របស់ខ្លួនបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> ម្នាលធោតក: បើដូច្នោះ ចូរអ្នកធ្វើសេចក្តីព្យាយាមចុះ បុគ្គលក្នុងលោកនេះ ជាអ្នកមានបញ្ញាចាស់ក្លា មានស្មារតីស្តាប់ទេសនាអំពីទីនេះហើយ នឹងសិក្សា នូវការរំលត់ (កិលេស) របស់ខ្លួនបាន ។

[២០៩] (ធោតក:ពោលថា) ខ្ញុំព្រះអង្គបានឃើញព្រះអង្គ ជាទេវតាក្នុងមនុស្សលោក ព្រះអង្គមិនមានកង្វល់ ជាព្រាហ្មណ៍កំពុងប្រព្រឹត្ត បពិត្រព្រះអង្គជាសមន្តចក្ខុ ខ្ញុំព្រះអង្គសូមនមស្តារព្រះអង្គ បពិត្រព្រះអង្គជាសក្ក: សូមព្រះអង្គដោះខ្ញុំព្រះអង្គ ឲ្យផុតចាកសេចក្តីសង្ស័យទាំងឡាយ ។

[២១០] បស្ឆាមហំ ទេវ មនុស្ស្ឆលោកេតិ ទេវ-
តិ តយោ ទេវ សម្មតិទេវ ច ឧបបត្តិទេវ ច
វិសុទ្ធិទេវ ច ។ កតមេ សម្មតិទេវ ។ សម្មតិទេវ
រុច្ចន្តិ រាជានោ ច រាជកុមារា ច ទេវិយោ ច ។
កតមេ ឧបបត្តិទេវ ។ ឧបបត្តិទេវ រុច្ចន្តិ ចាតុម្មហា-
រាជិកា ទេវ តាវត្តឹសា ទេវ យាមា ទេវ តុសិតា
ទេវ និម្មានរតី ទេវ បរនិម្មិតវសវត្តី ទេវ ព្រហ្មកា-
យិកា ទេវ យេ ច ទេវ ឥត្ថ្ថុបរិ ។ កតមេ វិសុទ្ធិ-
ទេវ ។ វិសុទ្ធិទេវ រុច្ចន្តិ ឥមាកតសាវកា អរហ-
ន្តោ ខីណាសវា យេ ច បច្ចេកសម្ពុទ្ធា ។ ឥមា
សម្មតិទេវានញ្ច ឧបបត្តិទេវានញ្ច វិសុទ្ធិទេវានញ្ច
ទេវេ ច អតិទេវេ ច ទេវាតិទេវេ ច សីហសី-
ហោ ជាតជាតោ ឥណ្ឌិឥណ្ឌី មុនិមុនី រាជរាជា ។

[២១០] *អធិប្បាយពាក្យថា ខ្ញុំព្រះអង្គបានឃើញព្រះអង្គ ជាទេវតាក្នុងមនុស្សលោក ត្រង់ពាក្យថា ទេវតា បានដល់ ពួកទេព ៣ គឺ សម្មតិទេព ១ ឧបបត្តិទេព ១ វិសុទ្ធិទេព ១ ។ សម្មតិទេព តើដូចម្តេច ។ ពួកព្រះរាជា ព្រះរាជកុមារ និងព្រះទេពី លោកហៅថា សម្មតិទេព ។ ឧបបត្តិទេព តើដូចម្តេច ។ ពួកទេពឋិតនៅ ក្នុងចាតុម្មហារាជិកា ពួកទេពឋិតនៅក្នុងតាវត្តិង្ស ពួកទេពឋិតនៅក្នុងយាមា ពួកទេពឋិតនៅក្នុងតុសិត ពួកទេពឋិតនៅ ក្នុងនិម្មានរតី ពួកទេពឋិតនៅក្នុងបរនិម្មិត-វសវត្តី និងពួកទេពជាពួកនៃព្រហ្ម ជាពួកទេពដែលឋិតនៅខាងលើពួកទេពទាំងនុ៎ះ លោកហៅថា ឧបបត្តិទេព ។ វិសុទ្ធិទេព តើដូចម្តេច ។ ពួកព្រះអរហន្ត ខីណាស្រព ជាសាវ័ករបស់ព្រះតថាគត និងពួកព្រះខីណាស្រព ដែលជាព្រះបច្ចេកពុទ្ធ លោកហៅថា វិសុទ្ធិ-ទេព ។ ព្រះមានព្រះភាគ ជាទេពរបស់ពួកសម្មតិទេព ឧបបត្តិទេព និងវិសុទ្ធិទេព ជាទេពដ៏ក្រៃលែងផង ជាទេពធំកន្ទ្ធងជាងពួកទេពផង ជាសីហៈធំជាងសីហៈផង ជានាគធំជាងនាគផង ជាមេគណៈធំជាងមេគណៈផង ជាមុនីធំជាងមុនីផង ជាព្រះរាជាធំជាងព្រះរាជាផង ។*

បស្សាមហំ នេវ មនុស្សលោកេតិ មនុស្សលោកេ នេវ បស្សាមិ អតិនេវ បស្សាមិ នេវាតិនេវ បស្សាមិ ឧក្ខាមិ ឱលោកេមិ ជិជ្ឈាយាមិ ឧបបរិក្ខាមីតិ បស្សាមហំ នេវ មនុស្សលោកេ ។

[២១១] អកិញ្ចនំ ព្រាហ្មណំ ឥរិយមានន្តិ អកិញ្ចនន្តិ ភគកិញ្ចនំ នោសកិញ្ចនំ មោហកិញ្ចនំ មានកិញ្ចនំ ទិដ្ឋិកិញ្ចនំ កិលេសកិញ្ចនំ ទុច្ចរិតកិញ្ចនំ តេ កិញ្ចនា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្គតា អាយតឹ-អនុប្បាទធម្មា តស្មា ពុទ្ធោ អកិញ្ចនោ ។ ព្រាហ្ម-ណន្តិ ភគវា សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ សក្កាយទិដ្ឋិ ពាហិតា ហោតិ វិចិកិច្ឆា ពាហិតា ហោតិ សីលព្ពតបរាមាសោ ពាហិតោ ហោតិ រាគោ ពាហិតោ ហោតិ នោសោ ពាហិតោ ហោតិ មោហោ ពាហិតោ ហោតិ មានោ ពាហិតោ ហោតិ ពាហិ-តស្ស ហោន្តិ ចាបកា អកុសលា ធម្មា សង្ខ្លិលេសិ-កា ចោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹជាតិ-ជរាមរណីយា ។

ពាក្យថា ខ្ញុំព្រះអង្គបានឃើញព្រះអង្គជាទេវតា ក្នុងមនុស្សលោក បានន័យថា ខ្ញុំព្រះអង្គឃើញព្រះអង្គជាទេវតា គឺខ្ញុំព្រះអង្គឃើញព្រះអង្គជាទេវតាកន្ធងទេវតា ឃើញ ប្រទះឃើញ រមិលឃើញ សម្ងឹងមើល ពិចារណាមើល នូវព្រះអង្គជាទេពធំជាងពួកទេព ហេតុនោះ លោកពោលថា ខ្ញុំព្រះអង្គបានឃើញព្រះអង្គជាទេវតា ក្នុងមនុស្សលោក ។

[២១១] អធិប្បាយពាក្យថា ព្រះអង្គមិនមានកង្វល់ ជាព្រាហ្មណ៍ កំពុងប្រព្រឹត្ត ត្រង់ពាក្យថា ព្រះអង្គមិនមានកង្វល់ បានដល់ កង្វល់គឺរាគ: កង្វល់គឺទោស: កង្វល់គឺមោហ: កង្វល់គឺមានៈ កង្វល់គឺទិដ្ឋិ កង្វល់គឺកិលេស កង្វល់គឺទុច្ចរិត កង្វល់ទាំងនុ៎ះ ព្រះពុទ្ធមានព្រះភាគ ទ្រង់លះបង់ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យនៅតែទីកើតដូចដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជារបស់មានសភាពមិនកើតតទៅទៀត ហេតុនោះ ព្រះពុទ្ធឈ្មោះថា មិនមានកង្វល់ ។ ពាក្យថា ជាព្រាហ្មណ៍ គឺព្រះមានព្រះភាគ ឈ្មោះថាព្រាហ្មណ៍ ព្រោះទ្រង់បន្សាត់ចោលធម៌ ៧ គឺ បន្សាត់សក្កាយទិដ្ឋិ បន្សាត់វិចិកិច្ឆា បន្សាត់សីលព្វតបរាមាស: បន្សាត់រាគ: បន្សាត់ទោស: បន្សាត់មោហ: បន្សាត់មានៈ ទាំងអកុសលធម៌ដ៏លាមកទាំងឡាយ ច្រឡូកច្រឡំដោយសេចក្តីសៅហ្មង នាំឲ្យកើតក្នុងភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាផល ជាទីតាំងនៃជាតិ ជរា និងមរណៈទៅខាងមុខ ព្រះអង្គបន្សាត់ចោលហើយ ។

ពាហេត្វា សព្វចាបកានិ (សកិយាតិ ភគវា)
ភគវា វិមលោ សាធុសមាហិតោ ឋិតត្តោ[1]
សំសារមតិចូ គោវលី សោ
អនិស្ស្ជិតោ តានិ បវុច្ចតេ ព្រហ្ម ។

ឥរិយមានន្តិ ចរន្តំ វិចរន្តំ ឥរិយន្តំ វត្តេន្តំ ចាលេន្តំ យបេន្តំ យាបេន្តន្តិ អកិញ្ចនំ ព្រាហ្មណំ ឥរិយមានំ ។

[២១២] តន្តំ ឧមស្ជ្ជមិ សមន្តចក្ខូតិ តន្តិ ភ-ណ្ឌន្តំ ភណ្ឌតិ ។ ឧមស្ជ្ជមីតិ ការាយេន វា ឧមស្ជ្ជមិ វាចាយ វា ឧមស្ជ្ជមិ ចិត្តេន វា ឧមស្ជ្ជមិ អ-ជ្ជត្តប្ជដិបត្តិយា វា ឧមស្ជ្ជមិ ធម្មានុធម្មប្ជដិបត្តិយា វា ឧមស្ជ្ជមិ សក្ការេមិ ករុការេមិ មានេមិ ឬជេ-មិ ។ សមន្តចក្ខូតិ សមន្តចក្ខុ វុច្ចតិ សព្វញ្ញុត-ញ្ញាណំ ។ ភគវា តេន សព្វញ្ញុតញ្ញាណេន ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុ-បបន្នោ សមន្នាគតោ ។

---

1 ម. ធិតត្តោ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសកិយៈ ព្រះមានព្រះភាគ បន្សាត់បង់នូវបាបទាំងពួង ទ្រង់មិនមានមន្ទិល មានព្រះទ័យតម្កល់ដោយប្រពៃ មានព្រះទ័យនឹងនួន ព្រះមានព្រះភាគនោះ ព្រះអង្គបរិបូណ៌ដោយគុណគ្រប់យ៉ាង កន្ទងបង់នូវសំសារ មិនអាស្រ័យ (តណ្ហានិងទិដ្ឋិ) ទ្រង់មិនញាប់ញ័រ (ដោយលោកធម៌) ទើបលោកហៅថា ព្រាហ្មណ៍ ។

ពាក្យថា កំពុងប្រព្រឹត្ត គឺកំពុងត្រាច់ទៅ ត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្ត-ទៅ រក្សា យាត្រា យាត្រាទៅ ហេតុនោះ (លោកពោលថា) ព្រះអង្គមិនមានកង្វល់ ជាព្រាហ្មណ៍ កំពុងប្រព្រឹត្ត ។

[២១២] ពាក្យថា បពិត្រព្រះអង្គជាសមន្តចក្ខុ ខ្ញុំព្រះអង្គសូមនមស្តារព្រះអង្គ ត្រង់ពាក្យថា ព្រះអង្គ គឺលោកហៅ ព្រះមានព្រះភាគ ។ ពាក្យថា សូមនមស្តារ គឺសូមនមស្តារដោយកាយក្តី សូមនមស្តារដោយវាចាក្តី សូមនមស្តារដោយចិត្តក្តី សូមនមស្តារដោយសេចក្តីប្រតិបត្តិដែលមានប្រយោជន៍ជាលំដាប់ៗ ក្តី សូមនមស្តារ ធ្វើសក្តារៈ ធ្វើគោរព រាប់អាន បូជា ដោយធម្មានុធម្មប្បដិបត្តិក្តី ។ ពាក្យថា សមន្តចក្ខុ សេចក្តីថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ ព្រះមានព្រះភាគ ដល់ ដល់ព្រម មកដល់ មកដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ប្រកបហើយដោយសព្វញ្ញុតញ្ញាណនោះ ។

ន តស្ស អចិជ្ជមិជត្ថិ កិញ្ចិ

អថោ អវិញ្ញាតមជានិតព្វំ

សព្វំ អភិញ្ញាសិ យទត្ថិ ឋេយ្យំ

តថាគតោ តេន សមន្តចក្ខូតិ ។

តន្តំ នមស្សាមិ សមន្តចក្ខុ ។

[២១៣] បមុញ្ច មំ សក្ក កាថង្កថាហីតិ សក្កាតិ

ភគវា សក្យកុលា បព្វជិតោតិបិ សក្កោ ។ អថវា

អឌ្ឍោ មហទ្ធនោ ធនវាតិបិ សក្កោ ។ តស្សិមានិ

ធនានិ សេយ្យថីទំ សទ្ធាធនំ សីលធនំ ហិរិធនំ ឱត្ត-

ប្បធនំ សុតធនំ ចាគធនំ បញ្ញាធនំ សតិប្បដ្ឋានធនំ

សម្មប្បធានធនំ ឥទ្ធិបាទធនំ ឥន្ទ្រិយធនំ ពលធនំ

ពោជ្ឈង្គធនំ មគ្គធនំ ផលធនំ និព្វានធនំ ។

វត្ថុនីមួយក្នុងលោកនេះ ដែលព្រះមានព្រះភាគមិនឃើញ ឬ មិនដឹង មិនគប្បីដឹង មិនមានទេ ព្រះតថាគត ទ្រង់ជ្រាប ច្បាស់នូវវត្ថុទាំងអស់ ដែលគួរជ្រាប ហេតុនោះ ព្រះតថា-គត ឈ្មោះថា សមន្តចក្ខុ ។

ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គ ជាសមន្តចក្ខុ ខ្ញុំព្រះអង្គ សូមនមស្ការព្រះអង្គ ។

[២១៣] *អធិប្បាយពាក្យថា បពិត្រព្រះអង្គជាសក្ក: សូមព្រះអង្គ ដោះខ្ញុំព្រះអង្គ ឲ្យផុតចាកសេចក្ដីសង្ស័យទាំងឡាយ ត្រង់ពាក្យថា បពិត្រព្រះអង្គជាសក្ក: សេចក្ដីថា ព្រះមានព្រះភាគ ចេញចាកសក្ય-ត្រកូល ហើយទ្រង់បព្វជ្ជា ហេតុនោះ ទើបទ្រង់ព្រះនាមថា សក្ក: ក៏មាន ។ មួយទៀត ព្រះមានព្រះភាគ ស្តុកស្តម្ភ មានទ្រព្យច្រើន មានទ្រព្យធន ហេតុនោះ ទើបទ្រង់ព្រះនាមថា សក្ក: ក៏មាន ។ ទ្រព្យទាំងនោះ របស់ព្រះអង្គ គឺ ទ្រព្យសទ្ធា ទ្រព្យសីល ទ្រព្យ ហិរិ ទ្រព្យឱត្តប្ប: ទ្រព្យសុត: ទ្រព្យចាគ: ទ្រព្យបញ្ញា ទ្រព្យ សតិប្បដ្ឋាន ទ្រព្យសម្មប្បធាន ទ្រព្យឥទ្ធិបាទ ទ្រព្យឥន្ទ្រិយ ទ្រព្យ ពល: ទ្រព្យពោជ្ឈង្គ: ទ្រព្យមគ្គ: ទ្រព្យផល ទ្រព្យព្រះនិព្វាន ។*

ឥមេហិ អនេកវិធេហិ ឆន្ទរាគេហិ អជ្ឈោ មមាយិ-
តោ ឆន្ទរាគោតិបិ សក្កោ ។ អថវា សក្កោ បហុ
វិសវី អលមត្តោ សូរោ វីរោ[១] វិក្កន្តោ អភិរុ
អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគត-
លោមហំសោតិបិ សក្កោ ។ កាមច្ឆន្ទំ វុច្ចតិ វិចិ-
កិច្ឆា ទុក្ខេ កង្ខា ទុក្ខសមុទយេ កង្ខា ទុក្ខ-
និរោធេ កង្ខា ទុក្ខនិរោធគាមិនិយា បដិបទាយ
កង្ខា បុព្វន្តេ កង្ខា អបរន្តេ កង្ខា បុព្វន្តាប-
រន្តេ កង្ខា ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ
កង្ខា យា ឯវរូបា កង្ខា កង្ខាយនា កង្ខាយិ-
តត្តំ វិមតិ វិចិកិច្ឆា ទ្វេឡ្ហកំ ទ្វេធាបថោ សំសយោ
អនេកំសគ្គាហោ អាសប្បនា បរិសប្បនា អបរិ-
យោគាហនា ឆម្ភិតត្តំ ចិត្តស្ស មនោវិលេខោ ។

១ ម. ធីរោ ។

ព្រះមានព្រះភាគ ស្តុកស្តម្ភ មានទ្រព្យច្រើន មានទ្រព្យធន ដោយទ្រព្យ ប្រសើរទាំងឡាយ ច្រើនប្រការនេះ ហេតុនោះ ទើបទ្រង់ព្រះនាម ថា សក្ក:ក៏មាន ។ មួយទៀត ព្រះមានព្រះភាគ ទ្រង់អង់អាច អាចហ៊ាន ក្លាហាន មោះមុត ក្ងៀវក្ងា មានព្យាយាម ធ្លាប់ ចូលកាន់សង្គ្រាម មិនខ្លាច មិនរន្ធត់ មិនតក់ស្លុត មិនរត់ចោល លះកំ‌យគួរខ្លាច ទ្រង់មិនព្រឺរោម ហេតុនោះ ទើបទ្រង់ព្រះនាមថា សក្ក: ក៏មាន ។ សេចក្តីស្គាក់ស្ទើរ លោកហៅថា សេចក្តីសង្ស័យ គឺសង្ស័យក្នុងទុក្ខ សង្ស័យក្នុងតណ្ហា ជាហេតុឲ្យកើតទុក្ខ សង្ស័យ ក្នុងសេចក្តីរំលត់ទុក្ខ សង្ស័យក្នុងបដិបទា ជាដំណើរទៅដើម្បីរំលត់ ទុក្ខ សង្ស័យក្នុងចំណែកខាងដើម សង្ស័យក្នុងចំណែកខាងចុង សង្ស័យ ទាំងចំណែកខាងដើមនិងខាងចុង សង្ស័យក្នុងធម៌ទាំងឡាយ ដែលកើត ឡើងអាស្រ័យព្រោះបច្ច័យនេះ គឺបានខាងការសង្ស័យ អាការនៃការ សង្ស័យ ភាពនៃការសង្ស័យ ការងឿងឆ្ងល់ ការស្គាក់ស្ទើរ ការ យល់ជាពីរយ៉ាង ការបែកគំនិតជាពីរផ្លូវ ការសន្ទិះសង្ស័យ ការប្រ-កាន់ច្រើនចំណែក ការរសេមរសាម ការស្ទុគស្ទាញ ការប្រកាន់ ធ្ងែង ភាពនៃចិត្តញាប់ញ័រ គំនូសនៃចិត្ត មានសភាពយ៉ាងនេះ ។

បមុញ្ចេ មំ សក្ក កថង្កថាហីតិ មុញ្ចេ មំ មោចេហិ មំ បមោចេហិ មំ ឧទ្ធរ មំ សមុទ្ធរ មំ រុដ្ឋាបេហិ មំ កថង្កថាសល្លតោតិ បមុញ្ចេ មំ សក្ក កថង្ក-ថាហិ ។ តេនាហ សោ ព្រាហ្មណោ

បស្សាមហំ ទេវ មនុស្សលោកេ
អកិញ្ចនំ ព្រាហ្មណំ ឥរិយមានំ
តន្តំ ឧមស្សាមិ សមន្តចក្ខុ
បមុញ្ចេ មំ សក្ក កថង្កថាហីតិ ។

[២១៤] ជាហំ សមិស្សាមិ បមោចនាយ
កថង្កថី ធោតក កញ្ចិ លោកេ
ឧម្ហញ្ចេ សេដ្ឋ អាជានមានោ
ឯវំ តុវំ ឱឃមិមំ តរេសិ ។

ពាក្យថា បពិត្រព្រះអង្គជាសក្ក: សូមព្រះអង្គ ដោះខ្ញុំព្រះអង្គឲ្យផុតចាកសេចក្ដីសង្ស័យទាំងឡាយ បានន័យថា សូមព្រះអង្គ ដោះខ្ញុំព្រះអង្គ សូមស្រាយខ្ញុំព្រះអង្គ សូមលែងខ្ញុំព្រះអង្គ សូមជ្រោងឡើងនូវខ្ញុំព្រះអង្គ សូមស្រង់ឡើងនូវខ្ញុំព្រះអង្គ សូមញ៉ាំងខ្ញុំព្រះអង្គឲ្យរួចផុតស្រឡះអំពីសរគឺសេចក្ដីសង្ស័យ ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាសក្ក: សូមព្រះអង្គ ដោះខ្ញុំព្រះអង្គ ឲ្យផុតចាកសេចក្ដីសង្ស័យទាំងឡាយ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

ខ្ញុំព្រះអង្គ បានឃើញព្រះអង្គ ជាទេវតាក្នុងមនុស្សលោក ព្រះអង្គមិនមានកង្ងល់ ជាព្រាហ្មណ៍ កំពុងប្រព្រឹត្ត បពិត្រព្រះអង្គជាសមន្ដចក្ខុ ខ្ញុំព្រះអង្គ សូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាសក្ក: សូមព្រះអង្គ ដោះខ្ញុំព្រះអង្គ ឲ្យផុតចាកសេចក្ដីសង្ស័យទាំងឡាយ ។

[២១២] (ព្រះមានព្រះភាគត្រាស់ថា) ម្នាលធោតក: តថាគតមិនអាចដើម្បីដោះអ្នកណាមួយ ក្នុងលោកនេះ ដែលមានសេចក្ដីសង្ស័យបានទេ ប៉ុន្ដែកាលបើអ្នកបានដឹងច្បាស់ នូវធម៌ដ៏ប្រសើរយ៉ាងនេះ នឹងធ្វើនូវ

[២១៤] នាហំ សមិស្សាមិ បមោចនាយាតិ នាហន្តំ សក្កោមិ មុញ្ចិតុំ បមុញ្ចិតុំ មោចេតុំ បមោចេតុំ ឧទ្ធរិតុំ ឧទ្ធរាបេតុំ វុដ្ឋាបេតុំ(១) កថង្កថាសល្លតោតិ ឯវម្បិ នាហំ សមិស្សាមិ បមោចនាយ ។ អថវា ន ឦហាមិ ន សហាមិ ន ឧស្សហាមិ ន វាយមាមិ ន ឧស្សាហំ ករោមិ ន ឧស្សោឡ្ហិំ ករោមិ ន ថាមំ ករោមិ ន ធិតឹ ករោមិ ន វីរិយំ ករោមិ ន ឆន្ទំ ជនេមិ ន សញ្ជនេមិ ន និព្វត្តេមិ ន អភិនិព្វត្តេមិ អស្សទ្ធេ បុគ្គលេ អច្ឆន្ទិកេ កុសីតេ ហីនវីរិយេ អប្បដិបជ្ជមានេ ធម្មទេសនាយាតិ ឯវម្បិ នាហំ សមិស្សាមិ បមោចនាយ ។ អថវា នត្ថញ្ញោ កោចិ មោចេតុំ(២) តេ យទិ មុញ្ចេយ្យុំ សកេន ថាមេន សកេន ពលេន សកេន វីរិយេន សកេន បរក្កមេន សកេន បុរិសត្ថាមេន សកេន បុរិសពលេន សកេន បុរិសវីរិយេន សកេន បុរិសបរក្កមេន អត្តនា សម្មាបដិបទំ អនុលោមប្បដិបទំ(៣) អន្វត្ថប្បដិបទំ ធម្មានុធម្មប្បដិបទំ បដិបជ្ជមានា មុញ្ចេយ្យុន្តិ

១ ម. សមុទ្ធរិតុំ ឧដ្ឋាបេតុំ សមុដ្ឋាបេតុំ ។ ២ កត្ថចិ ស្យាមបោត្ថកេ មោចេតាតិបិ បាឋោ ។ ម. មោចេតា ។ ៣ ម. ឯត្ថន្តរេ អបច្ចនីកបដិបទំ អត្ថិ ។

[២១៥] ពាក្យថា តថាគត មិនអាចដើម្បីដោះ អធិប្បាយ ថា តថាគត មិនអាចដោះអ្នក ស្រាយចេញ ស្រាយលែង ដោះ លែង ជ្រោងឡើង ស្រង់ឡើង ឲ្យក្រោកចេញ អំពីសរគឺសេចក្តី សង្ស័យបាន ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគត មិនអាច ដើម្បីដោះ យ៉ាងនេះខ្លះ ។ មួយទៀត តថាគត មិនខ្ជល់ខ្ជាយ មិន ខ្ជល់ខ្ជាយខ្លាំង មិនឧស្សាហ៍ មិនព្យាយាម មិនធ្វើឧស្សាហ៍ មិន ធ្វើសេចក្តីប្រឹងប្រែង មិនធ្វើនូវសេចក្តីខ្នះខ្នែង មិនធ្វើសេចក្តីឱហាត មិនធ្វើព្យាយាម មិនញ៉ាំងឆន្ទៈឲ្យកើត មិនឲ្យកើតព្រម មិនឲ្យដុះ មិនឲ្យដុះដាល (ដើម្បីដោះ) នូវពួកបុគ្គល មិនមានឆន្ទៈ ខ្ជិលច្រអូស ថយព្យាយាម មិនប្រតិបត្តិតាម ដោយធម្មទេសនាបានទេ ព្រោះហេតុ នោះ (ទ្រង់ត្រាស់ថា) តថាគត មិនអាចដោះ យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលដទៃណាមួយ ញ៉ាំងបុគ្គលដទៃឲ្យរួចបានមិនមានទេ ត្រូវតែបុគ្គលទាំងនោះ រួចដោយសេចក្តីព្យាយាមដ៏តឹងរុងរបស់ខ្លួន ដោយកម្លាំងរបស់ខ្លួន ដោយការព្យាយាមរបស់ខ្លួន ដោយសេចក្តីប្រឹងប្រែង របស់ខ្លួន ដោយការព្យាយាមដ៏តឹងរ៉ឹងនៃបុរសរបស់ខ្លួន ដោយកម្លាំង បុរសរបស់ខ្លួន ដោយការព្យាយាមបុរសរបស់ខ្លួន ដោយសេចក្តីប្រឹង ប្រែងបុរសរបស់ខ្លួន គឺប្រតិបត្តិនូវសម្មាបដិបទា អនុលោមប្បដិបទា អនុត្តប្បដិបទា ធម្មានុធម្មប្បដិបទា ដោយខ្លួនឯង ទើបរួចបាន

ធោតកមាណវកប្បញ្ហានិទ្ទេសោ

ឯវម្ៀ ជាហំ សមិស្ជាមិ បមោចជាយ ។ វុត្តញ្ហេតំ ភគវតា សោ វត ចុន្ទ អត្តជា បលិបបលិបន្ធោ បរំ បលិបបលិបន្ធំ ឧទ្ធរិស្ជតីតិ ឣតំ ឋានំ វិជ្ជតិ សោ វត ចុន្ទ អត្តជា អ១ន្ធោ អវិជីតោ អបរិនិព្ជុតោ បរំ ១មេស្ជតិ វិ១ស្ជតិ បរិនិព្ជាបេស្ជតីតិ ឣតំ ឋានំ វិជ្ជតីតិ ឯវម្ៀ ជាហំ សមិស្ជាមិ បមោចជាយ ។ វុត្តញ្ហេតំ ភគវតា

អត្តជាវ ១តំ ១ាបំ អត្តជា សង្ខ្លិ១ិស្ជតិ
អត្តជា អ១តំ ១ាបំ អត្តជាវ វិសុជ្ជតិ
សុទ្ធិ អសុទ្ធិ បចូ១ត្តំ ជាញ្ហ អ១ញ្ញ វិ១ោ១យេតិ[1] ។

ឯវម្ៀ ជាហំ សមិស្ជាមិ បមោចជាយ ។ វុត្តញ្ហេតំ ភគវតា ឯវមេវ ខោ ព្រាហ្មណ តិជ្ជតេវ ១ិញ្ជ១ំ តិជ្ជតិ ១ិញ្ជ១មត្ត[2] តិជ្ជាមហំ សមា១ បេតា

---

១ វិ១ោ១យេតិ១ិ ១ាហ ។ ២ ម. ១ិញ្ជ១គាមិ១ត្ត ។

ហេតុនោះ ទ្រង់ត្រាស់ថា តថាគត មិនអាចដើម្បីដោះ យ៉ាងនេះខ្ញុះ ។ សមដូចព្រះពុទ្ធតម្រាស់នេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលចុន្ទ: បុគ្គលនោះ លិចចុះក្នុងកក់ខ្លួនឯង នឹងស្រង់បុគ្គលដទៃ ដែលលិចចុះក្នុងកក់បាន ហេតុនេះមិនដែលមានទេ ម្នាលចុន្ទ: បុគ្គលនោះ មិនបានទូន្មាន មិនបានប្រៀនប្រដៅ មិនបានរំលត់កិលេសដោយខ្លួនឯង នឹងទូន្មានប្រៀនប្រដៅបុគ្គលដទៃ ឬថា ញ៉ាំងកិលេសរបស់បុគ្គលដទៃឲ្យរលត់បាន ហេតុនេះ មិនដែលមានទេ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគត មិនអាចដោះ យ៉ាងនេះខ្ញុះ ។ មួយទៀត សមដូចព្រះពុទ្ធ-តម្រាស់នេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា

> បុគ្គលធ្វើបាប ដោយខ្លួនឯង រមែងសៅហ្មងដោយខ្លួនឯង
> មិនធ្វើបាបដោយខ្លួនឯង រមែងស្អាតដោយខ្លួនឯង សេចក្តីបរិសុទ្ធ និងសេចក្តីមិនបរិសុទ្ធ មានចំពោះខ្លួន បុគ្គលដទៃ
> មិនគប្បីញ៉ាំងបុគ្គលដទៃឲ្យស្អាតបានទេ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគត មិនអាចដោះ យ៉ាងនេះខ្ញុះ ។ មួយទៀត សមដូចព្រះពុទ្ធតម្រាស់នេះ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ព្រះនិព្វាន ក៏មាននៅស្រាប់ ទាំងផ្លូវទៅកាន់ព្រះនិព្វាន ក៏មាននៅស្រាប់ តថាគតជាអ្នកបបួល ក៏មាននៅស្រាប់

អជ ច បន មម សាវកា មយា ឯវំឱវទិយមានា ឯវំអនុសាសិយមានា អប្បេកច្ចេ អច្ចន្តនិដ្ឋំ និព្វានំ អារាធេន្តិ ឯកច្ចេ នារាធេន្តិ ឯត្ថ ក្យាហំ ព្រាហ្មណ ករោមិ មគ្គក្ខាយី ព្រាហ្មណ តថាគតោ មគ្គំ ពុទ្ធោ[១] អាចិក្ខតិ អត្តនា បដិបជ្ជមានា មុញ្ចេយ្យុន្តិ ឯវម្បិ នាហំ សមិស្សាមិ បមោចនាយ ។

[២១៦] កថង្កថឹ ធោតក កញ្ចិ លោកេតិ កថង្កថឹ បុគ្គលំ សកង្ខំ សវិលំ ទ្វេឡ្ហកំ[២] សវិចិកិច្ឆំ ។ កញ្ចីតិ កញ្ចិ ខត្តិយំ វា ព្រាហ្មណំ វា វេស្សំ វា សុទ្ទំ វា គហដ្ឋំ វា បព្វជិតំ វា ទេវំ វា មនុស្សំ វា ។ លោកេតិ អបាយលោកេ ។ បេ ។ អាយតនលោកេតិ កថង្កថឹ ធោតក កញ្ចិ លោកេ ។

---

១ ម. ពុទ្ធោ ។ ២ ម. សទ្វេឡ្ហកំ ។

តែថា ពួកសាវ័ករបស់តថាគត ដែលតថាគតទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ពួកខ្លះ បានសម្រេចព្រះនិព្វានជាទីបំផុតដោយពិត ពួកខ្លះក៏មិនបានសម្រេច ម្នាលព្រាហ្មណ៍ តថាគតនឹងធ្វើដូចម្តេចក្នុងបុគ្គលពួកនេះ ម្នាលព្រាហ្មណ៍ ព្រះតថាគត ជាអ្នកប្រាប់ផ្លូវ បើគេសួរផ្លូវហើយ ទើបព្រះតថាគតប្រាប់បាន បុគ្គលកាលប្រតិបត្តិដោយខ្លួនឯងគប្បីរួចបាន ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតមិនអាចដោះ យ៉ាងនេះខ្លះ ។

[២១៦] ពាក្យថា ម្នាលជោតក: (តថាគតមិនអាចដើម្បីដោះ) អ្នកណាមួយ ក្នុងលោកនេះ ដែលមានសេចក្តីសង្ស័យបានទេ គឺបុគ្គលដែលមានសេចក្តីសង្ស័យ ប្រកបដោយសេចក្តីងឿងឆ្ងល់ មានសេចក្តីរឹងរូស មានការយល់ជាពីរផ្លូវ មានសេចក្តីស្ទាក់ស្ទើរ ។ ពាក្យថា អ្នកណាមួយ គឺក្សត្រក្តី ព្រាហ្មណ៍ក្តី វេស្ស:ក្តី សុទ្ទ:ក្តី គ្រហស្ថក្តី បព្វជិតក្តី ទេវតាក្តី មនុស្សក្តី ណាមួយ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។ ក្នុងអាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលជោតក: តថាគតមិនអាចដើម្បីដោះ អ្នកណាមួយ ក្នុងលោកនេះ ដែលមានសេចក្តីសង្ស័យបានទេ ។

ធោតកមាណវកប្បញ្ហានិទ្ទេសោ

[២១៧] ឩម្ហញ្ហ សេដ្ឋំ អាជានមានោតិ ឩម្ហំ សេដ្ឋំ វុច្ចតិ អមតំ និព្ពានំ យោ សោ សព្ពសង្ខារ-សមថោ សព្ពុបធិប្ប ដិនិស្សគ្គោ តណ្ហាក្ខយោ វិរ-គោ និរោធោ និព្ពានំ ។ សេដ្ឋន្តិ អគ្គំ សេដ្ឋំ វិសេ-ដ្ឋំ ចាមោក្ខំ ឧត្តមំ បវរំ ឩម្ហំ ។ អាជានមានោតិ អាជានមានោ វិជានមានោ បដិវិជានមានោ បដិវិជ្ឌ-មានោតិ ឩម្ហញ្ហ សេដ្ឋំ អាជានមានោ ។

[២១៨] ឯវំ តុវំ ឧិយមិមំ តរេសីតិ ឯវំ តុវំ កា-មោឃំ ភវោឃំ ឧិច្ឆោឃំ អវិជ្ជោឃំ តរេយ្យាសិ(១) សមតិក្ក្រមេយ្យាសិ វីតិវត្តេយ្យាសីតិ ឯវំ តុវំ ឧិយមិមំ តរេសិ ។ តេនាហ ភគវា

ជាហំ សមិស្ជ្ជាមិ បមោចនាយ
ភវជ្ជ្ជ្ជ ជោតក ភញ្ជ្ជ លោកេ
ឩម្ហញ្ហ សេដ្ឋំ អាជានមានោ
ឯវំ តុវំ ឧិយមិមំ តរេសីតិ ។

---

១ ឯត្ថន្តរេ ឧត្តរេយ្យាសិ តរេយ្យាសីតិ ទិស្សតិ ។

[២១៧] ពាក្យថា ប៉ុន្តែ កាលបើអ្នកបានដឹងច្បាស់នូវធម៌ដ៏ប្រសើរ សេចក្តីថា អមតនិព្វាន លោកហៅថា ធម៌ដ៏ប្រសើរ បានខាងការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកវាគៈ ការរលត់ និព្វាន ។ ពាក្យថា ប្រសើរ គឺធម៌ដ៏លើស ដ៏ប្រសើរ ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្នូ ។ ពាក្យថា ដឹងច្បាស់ គឺដឹងច្បាកដ យល់ច្បាស់ ជ្រាបច្បាស់ ចាក់ធ្ងុះចំពោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ប៉ុន្តែ កាលបើអ្នកបានដឹងច្បាស់ នូវធម៌ដ៏ប្រសើរ ។

[២១៨] ពាក្យថា យ៉ាងនេះ នឹងធ្វើនូវឱ្ឃៈនេះបាន គឺអ្នកគប្បីធ្វើ គប្បីឈានកន្ទ្ធ គប្បីប្រព្រឹត្តកន្ទ្ធ នូវកាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ អវិជ្ជោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) យ៉ាងនេះ នឹងធ្វើឱ្ឃៈនេះបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលធោតកៈ តថាគតមិនអាចដើម្បីដោះអ្នកណាមួយ ក្នុងលោកនេះ ដែលមានសេចក្តីសង្ស័យបានទេ ប៉ុន្តែ កាលបើអ្នកបានដឹងច្បាស់នូវធម៌ដ៏ប្រសើរ យ៉ាងនេះ នឹងធ្វើឱ្ឃៈនេះបាន ។

[២១៩] អនុសាស ព្រហ្មេ ករុណាយមានោ
វិវេកធម្មំ យមហំ វិជញ្ញំ
យថាហំ អាកាសោ ច អព្យាបជ្ជមានោ
ឥធេវ សន្តោ អសិតោ ចរេយ្យំ ។

[២២០] អនុសាស ព្រហ្មេ ករុណាយមានោតិ អនុសាស ព្រហ្មេតិ អនុសាស ព្រហ្មេ អនុគ្គណ្ហ ព្រហ្មេ អនុកម្ប ព្រហ្មេតិ អនុសាស ព្រហ្មេ ។ ករុណាយមានោតិ ករុណាយមានោ អនុទ្ទយមានោ អនុរក្ខមានោ អនុគ្គណ្ហមានោ អនុកម្បមានោតិ អនុសាស ព្រហ្មេ ករុណាយមានោ ។

[២២១] វិវេកធម្មំ យមហំ វិជញ្ញន្តិ វិវេកធម្មំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ ។ យមហំ វិជញ្ញន្តិ យំ អហំ ជានេយ្យំ វិជានេយ្យំ បដិវិជានេយ្យំ បដិវិជ្ឈេយ្យន្តិ[១] វិវេកធម្មំ យមហំ វិជញ្ញំ ។

១ ម. ជានេយ្យំ អាជានេយ្យំ វិជានេយ្យំ បដិវិជានេយ្យំ បដិវិជ្ឈេយ្យំ អធិគច្ឆេយ្យំ បស្សេយ្យំ សច្ឆិករេយ្យន្តិ ។

[២១៩] (ជោតក:ក្រាបទូលថា) *បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គទ្រង់ព្រះករុណា ប្រៀនប្រដៅ នូវវិវេកធម៌ ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ ដើម្បីកុំឲ្យខ្ញុំព្រះអង្គទើសទាក់ ដូចអាកាស ជាបុគ្គលសូប់ មិនអាស្រ័យនៅ(ដោយកិលេស)ប្រព្រឹត្តក្នុងទីនេះឯង ។*

[២២០] *ពាក្យថា* *បពិត្រព្រះអង្គជាព្រហ្ম សូមព្រះអង្គប្រៀនប្រដៅ* *នៃបទថា* *បពិត្រព្រះអង្គជាព្រហ្ম សូមព្រះអង្គទ្រង់ព្រះករុណា ប្រៀនប្រដៅ* *គឺ* *បពិត្រព្រហ្ম សូមព្រះអង្គប្រៀនប្រដៅ* *បពិត្រព្រហ្ম សូមព្រះអង្គអនុគ្រោះ* *បពិត្រព្រហ្ম សូមព្រះអង្គស្រោចស្រង់* *ហេតុនោះ* (លោកពោលថា) *បពិត្រព្រះអង្គជាព្រហ្ম សូមព្រះអង្គប្រៀនប្រដៅ ។* *ពាក្យថា* *ទ្រង់ព្រះករុណា* *គឺទ្រង់ព្រះករុណា* *ទ្រង់អាណិត* *ទ្រង់អាសូរ* *ទ្រង់អនុគ្រោះ* *ទ្រង់ស្រោចស្រង់* *ហេតុនោះ* (លោកពោលថា) *បពិត្រព្រះអង្គជាព្រហ្ম សូមព្រះអង្គទ្រង់ព្រះករុណា ប្រៀនប្រដៅ ។*

[២២១] *ពាក្យថា* *វិវេកធម៌* *ឲ្យខ្ញុំព្រះអង្គដឹងច្បាស់* *សេចក្ដីថា* *អមតនិព្វាន* *លោកហៅថា* *វិវេកធម៌* *បានដល់* *ការរម្ងាប់សង្ខារទាំងពួង* *ការលះបង់ឧបធិទាំងពួង* *ការអស់តណ្ហា* *ការប្រាសចាករាគ:* *ការរលត់* *និព្វាន ។* *ពាក្យថា* *ឲ្យខ្ញុំព្រះអង្គដឹងច្បាស់* *គឺឲ្យខ្ញុំព្រះអង្គចេះដឹង* *ដឹងច្បាស់* *យល់ច្បាស់* *ចាក់ធ្ងុះចំពោះ* *ហេតុនោះ* (លោកពោលថា) *នូវវិវេកធម៌* *ឲ្យខ្ញុំព្រះអង្គដឹងច្បាស់* *។*

ធោតកមាណវកប្បញ្ហានិទ្ទេសោ

[២២២] យថាហំ អាកាសោ ច អព្យាបជ្ឈមានោ-
តិ យថា អាកាសោ ឌប្ប្ជ្ជតិ ន ពជ្ឈតិ[១] ន ប-
លិពជ្ឈតិ ឯវំ អបជ្ជមានោ អពជ្ឈមានោ[២] អប-
លិបជ្ឈមានោតិ ឯវម្ឯ អាកាសោ ច[៣] អព្យាបជ្ឈ-
មានោ ។ យថា អាកាសោ ឌវជ្ជតិ លាខាយ វ
ហលិទ្ទេន វ នីលេន វ មញ្ជេដ្ឋាយ វ ឯវំ អវជ្ជមា-
នោ អឧ្ស្ស្ជមានោ អមុយ្ជ្ជមានោ អកិលិយមានោតិ
ឯវម្ឯ អាកាសោ ច អព្យាបជ្ឈមានោ ។ យថា
អាកាសោ ន ឧ្ប្ជ្ជតិ ន ព្យាបជ្ឈតិ ន បដិលី-
យតិ ន បដិហាញ្ជតិ ឯវំ អឧ្ប្ជ្ជមានោ អព្យា-
បជ្ឈមានោ អប្ជ្ជដិលីយមានោ អប្ជ្ជដិហាញ្ជមានោតិ[២]
ឯវម្ឯ អាកាសោ ច អព្យាបជ្ឈមានោ ។

[២២៣] ឥធេវ សន្ដោ អសិតោ ចវេយ្យន្ដិ ឥធេវ
សន្ដោតិ ឥធេវ សន្ដោ សមានោ ឥធេវ ឌិសីឌន្ដោ
សមានោ ឥមស្ម៏ិយេវ អាសនេ ឌិសិន្ដោ សមានោ

---

១ ម. ន ឧ្ប្ជ្ជតិ ន ពជ្ឈតិ ។ ២ ម. អឧ្ប្ជ្ជមានោ អពជ្ឈមានោ ។ ៣ ម. វ ។
៤ ម. អប្ជ្ជដិហាញ្ជមានោ ។ អប្ជ្ជដិហាតមានោតិ ។

[២២២] ពាក្យថា ដើម្បីកុំឲ្យខ្ញុំព្រះអង្គទើសទាក់ ដូចអាកាស គឺឲ្យខ្ញុំព្រះអង្គមិនទើសទាល់ មិនជាប់ចំពាក់ មិនជាប់ស្អិត ដូចអាកាស មិនទើសទាល់ មិនជាប់ចំពាក់ មិនជាប់ស្អិត ដូច្នោះឯង ហេតុនោះ (លោកពោលថា) មិនទើសទាក់ ដូចអាកាស ដោយប្រការដូច្នេះខ្ញុះ ។ ឲ្យខ្ញុំព្រះអង្គ មិនត្រេកអរ មិនប្រទូស្ត មិនរង្វេង មិនលំបាកដូចអាកាស មិនជិតដោយល័ខ ឬដោយល្បៀត ដោយវត្ថុពណ៌ខៀវ ឬដោយវត្ថុពណ៌ហង្សបាទ ដូច្នោះឯង ហេតុនោះ (លោកពោលថា) មិនទើសទាក់ ដូចអាកាស ដោយប្រការដូច្នេះខ្ញុះ ។ ឲ្យខ្ញុំព្រះអង្គ មិនក្រោធ មិនបៀតបៀន មិនរិលវល់នៅ មិនលំបាក ដូចអាកាស មិនកម្រើក មិនបៀតបៀន មិនរិលវល់នៅ មិនលំបាក ដូច្នោះឯង ហេតុនោះ (លោកពោលថា) មិនទើសទាក់ដូចអាកាស ដោយប្រការដូច្នេះខ្ញុះ ។

[២២៣] អធិប្បាយពាក្យថា ជាបុគ្គលសូប់ មិនអាស្រ័យនៅ (ដោយកិលេស) ប្រព្រឹត្ត ក្នុងទីនេះឯង ត្រង់ពាក្យថា ជាបុគ្គលសូប់ ក្នុងទីនេះឯង គឺជាអ្នកនៅក្នុងទីនេះឯង ជាអ្នកកំពុងអង្គុយក្នុងទីនេះឯង ជាអ្នកអង្គុយ លើអាសនៈនេះឯង ជាអ្នកអង្គុយក្នុងបរិស័ទនេះឯង

ឥមិស្សាយេវ បរិសាយ និសិន្នោ សមានោតិ ឯវម្បិ ឥធេវ សន្តោ ។ អថវា ឥធេវ សន្តោ ឧបសន្តោ វូបសន្តោ និព្វុតោ បដិប្បស្សទ្ធោតិ ឯវម្បិ ឥធេវ សន្តោ ។ អសិតោតិ ទ្វេ និស្សយា តណ្ហានិស្សយោ ច ទិដ្ឋិនិស្សយោ ច ។ បេ ។ អយំ តណ្ហានិស្សយោ ។ បេ ។ អយំ ទិដ្ឋិនិស្សយោ ។ តណ្ហានិស្សយំ បហាយ ទិដ្ឋិនិស្សយំ បដិនិស្សជ្ជិត្វា ចក្ខុំ អនិស្សិតោ សោតំ អនិស្សិតោ ឃានំ អនិស្សិតោ ជិវ្ហំ អនិស្សិតោ កាយំ អនិស្សិតោ មនំ អនិស្សិតោ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ កុលំ គណំ អាវាសំ លាភំ យសំ បសំសំ សុខំ ចីវរំ បិណ្ឌបាតំ សេនាសនំ គិលានប្បច្ចយភេសជ្ជបរិក្ខារំ កាមធាតុំ រូបធាតុំ អរូបធាតុំ កាមភវំ រូបភវំ អរូបភវំ សញ្ញាភវំ អសញ្ញាភវំ នេវសញ្ញានាសញ្ញាភវំ ឯកវោការភវំ ចតុវោការភវំ បញ្ចវោការភវំ អតីតំ អនាគតំ បច្ចុប្បន្នំ[១]

១ ម. កុលេ គណេ អាវាសេ ។ ល ។ អតីតេ អនាគតេ បច្ចុប្បន្នេ ។

ហេតុនោះ (លោកពោលថា) ជាបុគ្គលសូប់ក្នុងទីនេះឯង ដោយប្រការដូច្នេះខ្ញុះ ។ មួយទៀត ជាអ្នកមានចិត្តសូប់រម្ងាប់ មានចិត្តសូប់រម្ងាប់ មានចិត្តរលត់ មានចិត្តសូប់ស្ងាត់ ក្នុងទីនេះឯង ហេតុនោះ (លោកពោលថា) ជាអ្នកសូប់ក្នុងទីនេះឯង ដោយប្រការដូច្នេះខ្ញុះ ។ ពាក្យថា មិនអាស្រ័យ សេចក្ដីថា ការអាស្រ័យ ២ គឺ ការអាស្រ័យគឺតណ្ហា ១ ការអាស្រ័យគឺទិដ្ឋិ ១ ។ បេ ។ នេះ ការអាស្រ័យគឺតណ្ហា ។ បេ ។ នេះ ការអាស្រ័យគឺទិដ្ឋិ ។ បុគ្គលលះបង់ នូវការអាស្រ័យគឺតណ្ហា លះលែងនូវការអាស្រ័យគឺទិដ្ឋិ មិនអាស្រ័យភ្នែក មិនអាស្រ័យត្រចៀក មិនអាស្រ័យច្រមុះ មិនអាស្រ័យអណ្ដាត មិនអាស្រ័យកាយ មិនអាស្រ័យចិត្ត រូប សំឡេង ក្លិន រស ផោដ្ឋព្ធ: ត្រកូល ពួក អាវាស លាភ យស សេចក្ដីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសន: គិលានប្បច្ចយភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន

ជិជ្ជសុតមុតវិញ្ញាតព្វេ ធម្មេ អនិស្សិតោ[1] អនលីនោ អ-
នុបតតោ អនជ្ឈោសិតោ អនធិមុត្តោ និក្ខន្តោ និស្ស-
ដ្ឋោ វិប្ប្រមុត្តោ វិមរិយាទិកតេន[2] ចេតសា វិហរតីតិ
អសិតោ ។ ចរេយ្យន្តិ ចរេយ្យំ វិចរេយ្យំ ឥរិយេយ្យំ
វត្តេយ្យំ ចាលេយ្យំ យរេយ្យំ យាបេយ្យន្តិ ឥធេវ
សន្តោ អសិតោ ចរេយ្យំ ។ តេនាហ សោ ព្រា-
ហ្មណោ

អនុសាស ព្រហ្មេ ការុណាយមានោ
វិវេកធម្មំ យមហំ វិជញ្ញ
យថាហំ អាការោ ច អញ្ញាបជ្ជមានោ
ឥធេវ សន្តោ អសិតោ ចរេយ្យន្តិ ។

[២២៤] កិត្តយិស្សាមិ តេ សន្តិ [ធោតការ ភតវា]
ជិជ្ជ ធម្មេ អនីតិហំ
យំ វិទិត្វា សតោ ចរំ តរេ លោកេ វិសត្តិកំ ។

---

១ ម. អសិតោ អនិស្សិតោ ។ ២ ម. និស្សដោ វិប្ប្រមុត្តោ វិសំយុត្តោ វិបរិយាទិកតេន ។

មិនអាស្រ័យ មិនផ្ដេកផ្ដិត មិនចូលទៅជិត មិនងប់ចុះ មិនលង់ចុះ ងាកចេញ មិនជាប់ រលាស់ចេញ នូវធម៌ដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង ជាបុគ្គលមានចិត្តមិនសល់រាល់ ហេតុនោះ (លោកពោលថា) មិនអាស្រ័យ ។ ពាក្យថា ប្រព្រឹត្ត គឺនៅ ត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្ត ទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ (លោកពោលថា) ជាអ្នកស្ងប់ មិនអាស្រ័យនៅ (ដោយកិលេស) ប្រព្រឹត្ត ក្នុងទីនេះឯង ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គទ្រង់ព្រះករុណា ប្រៀនប្រដៅនូវវិវេកធម៌ ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ ដើម្បីកុំឲ្យខ្ញុំព្រះអង្គទើសទាក់ ដូចអាកាស ជាបុគ្គលស្ងប់ មិនអាស្រ័យនៅ (ដោយកិលេស) ប្រព្រឹត្ត ក្នុងទីនេះឯង ។

[២២២] *(ព្រះមានព្រះភាគទ្រង់ត្រាស់ថា) ម្នាលធោតក: បុគ្គលមានស្មារតី ដឹងច្បាស់នូវសន្ដិបទណា ហើយគប្បីប្រព្រឹត្តធ្ងន់នូវវិសត្ដិកាតណ្ហា ក្នុងលោកបាន តថាគត នឹងសម្ដែងប្រាប់អ្នកនូវសន្ដិបទនោះ ដែលតថាគតជាក់ច្បាស់ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ។*

[២២៥] កិត្តយិស្សាមិ តេ សន្តិន្តិ រាគស្ស សន្តឺ ទោសស្ស សន្តឺ មោហស្ស សន្តឺ កោធស្ស ឧ-បនាហស្ស មក្ខស្ស បឬាសស្ស ឥស្សាយ មច្ឆ-រិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស សព្វកិ្លលេ-សានំ សព្វទុច្ចរិតានំ សព្វទរថានំ សព្វបរិឬាហានំ សព្វសន្ដាបានំ សព្វាកុសលាភិសង្ខារានំ សន្តឺ ឧប-សន្តឺ រូបសន្តឺ និព្ពុតឺ បដិប្ឬស្សទ្ធឺ កិត្តយិស្សាមិ អា-ចិក្ខិស្សាមិ ទេសិស្សាមិ បញ្ញបេស្សាមិ បដ្ឋបេស្សា-មិ វិវរិស្សាមិ វិភជិស្សាមិ ឧត្តានីករិស្សាមិ បកា-សិស្សាមីតិ កិត្តយិស្សាមិ តេ សន្តឺ ។ ជោតកាតិ ភគវាតិ ជោតកាតិ ភគវា តំ ព្រាហ្មណំ ជាមេន អាលបតិ ។ ភគវាតិ ការណជិវចនមេតំ ។ បេ ។ សច្ចិកា បញ្ញត្តិ យជិជំ ភគវាតិ ជោតកាតិ ភ-គវា ។

[២២ថ] *ពាក្យថា តថាគតនឹងសម្តែងប្រាប់អ្នកនូវសន្តិបទនោះ គឺតថា-គត នឹងត្រាស់ ប្រាប់ សម្តែង បញ្ញត្ត តែងតាំង បើក ចែក ធ្វើឲ្យងាយ ប្រកាសនូវការស្ងប់រាគៈ ការស្ងប់ទោសៈ ការស្ងប់មោហៈ នូវការរម្ងាប់ ការស្ងប់ ការរំលត់ ការស្ងប់ស្ងាត់នៃកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋেយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ពួកកិលេសទាំងពួង ទុច្ចរិតទាំងពួង ការក្រវល់ក្រវាយទាំងពួង ការក្រហល់ក្រហាយទាំងពួង ការក្តៅក្រហាយទាំងពួង អកុសលាកិសង្ខារទាំងពួង ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតនឹងសម្តែងប្រាប់អ្នកនូវសន្តិបទនោះ ។ ពាក្យថា ម្នាលធោតកៈ នៃបទថា ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលធោតកៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះដោយចំឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នេះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលធោតកៈ ។*

ធោតកមាណវកប្បញ្ហានិទ្ទេសោ

[២២៦] ជិដ្ឋេ ធម្មេ អនីតិហន្តិ ជិដ្ឋេ ធម្មេតិ ជិដ្ឋេ ធម្មេ ញាតេ ធម្មេ តុលិតេ ធម្មេ តីរិតេ ធម្មេ វិភាវិតេ ធម្មេ វិភូតេ ធម្មេ សព្វេ[១] សង្ខារា អនិច្ចាតិ ។ បេ ។ យញ្ចិ ញ្ចិ សមុទយធម្មំ សព្វន្តំ ជិវោធធម្មន្តិ ជិដ្ឋេ ធម្មេ ញាតេ ធម្មេ តុលិតេ ធម្មេ តីរិតេ ធម្មេ វិភាវិតេ ធម្មេ វិភូតេ ធម្មេតិ ឯវម្ប៎ ជិដ្ឋេ ធម្មេ ។ អថវា ឧុក្ខេ ជិដ្ឋេ ឧុក្ខំ កថយិ-ស្សាមិ សមុទយេ ជិដ្ឋេ សមុទយំ កថយិស្សាមិ មគ្គេ ជិដ្ឋេ មគ្គំ កថយិស្សាមិ ជិវោធេ ជិដ្ឋេ ជិ-វោធំ កថយិស្សាមីតិ ឯវម្ប៎ ជិដ្ឋេ ធម្មេ ។ អថវា ជិដ្ឋេ ធម្មេ[២] សន្ធិដ្ឋិកំ អកាលិកំ ឯហិ-បស្ស៎ិកំ ឱបនយិកំ បច្ចត្តំ វេទិតព្ពំ វិញ្ញូហីតិ

---

១ ម. សព្វេ សង្ខារា ។ បេ ។ ធម្មេតិ នត្ថិ ។ ២ ម. ទិដ្ឋេ ធម្មេតិ នត្ថិ ។

ធោតកមាណវកបញ្ហានិទ្ទេស

[២២៦] *អធិប្បាយពាក្យថា ដែលតថាគតជាក់ច្បាស់ ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ត្រង់ពាក្យថា ចំពោះធម៌ដែលឃើញហើយ គឺ ចំពោះធម៌ដែលឃើញ ធម៌ដែលដឹង ធម៌ដែលថ្វឹង ធម៌ដែលពិចារណា ធម៌ដែលចម្រើន ធម៌ដែលកើតប្រាកដហើយថា សង្ខារទាំងពួងមិនទៀង ។ បេ ។ ចំពោះធម៌ដែលឃើញ ធម៌ដែលដឹង ធម៌ដែលថ្វឹង ធម៌ដែលពិចារណា ធម៌ដែលចម្រើន ធម៌ដែលប្រាកដហើយថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងពួងនោះ មានការរលត់ទៅវិញជាធម្មតា ហេតុនោះ (ទ្រង់ត្រាស់ថា) ចំពោះធម៌ដែលឃើញហើយ ដោយប្រការដូច្នេះខ្លះ ។ មួយទៀត តថាគត នឹងសម្តែងនូវសេចក្តីទុក្ខ ក្នុងទុក្ខដែលឃើញហើយ សម្តែងនូវសមុទ័យ ក្នុងសមុទ័យដែលឃើញហើយ សម្តែងនូវមគ្គ ក្នុងមគ្គដែលឃើញហើយ សម្តែងនិរោធ ក្នុងនិរោធដែលឃើញហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ចំពោះធម៌ដែលឃើញហើយ ដោយប្រការដូច្នេះខ្លះ ។ មួយទៀត (តថាគតនឹងសម្តែងធម៌) ដែលឃើញច្បាស់ដោយខ្លួនឯង ដែលឲ្យផលមិនរង់ចាំកាល ដែលគួនឹងហៅថា អ្នកចូរមកមើលចុះ ដែលគួរបង្អោនចូលមក ដែលពួកវិញ្ញូជនគប្បីដឹងចំពោះខ្លួន ចំពោះធម៌ដែលតថាគតឃើញហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ចំពោះធម៌ដែលឃើញហើយ ដោយប្រការដូច្នេះខ្លះ*

ឯវម្បិ ទិដ្ឋេ ធម្មេតិ ទិដ្ឋេ ធម្មេ ។ អនីតិហន្តិ ន ឥតិហំ ន ឥតិកិរាយ[១] ន បរម្បរាយ ន បិដកសម្បទាយ ន តក្កហេតុ ន នយហេតុ ន អាការបរិវិតក្កេន ន ទិដ្ឋិនិជ្ឈានក្ខន្តិយា សាមំ សយមភិញ្ញាតំ អត្តប្បច្ចក្ខំ ធម្មំ[២] កថយិស្សាមីតិ ទិដ្ឋេ ធម្មេ អនីតិហំ ។

[២២៧] យំ វិទិត្វា សតោ ចរន្តិ យំ វិទិតំ កត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ វិទិតំ កត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ សតោ ។ បេ ។ សោ វុច្ចតិ សតោ ។ ចរន្តិ ចរន្តោ វិចរន្តោ ឥរិយន្តោ វត្តេន្តោ បាលេន្តោ យបេន្តោ យាបេន្តោតិ យំ វិទិត្វា សតោ ចរំ ។

១ ម. ន កិរិយាយ ។ ២ ម. អត្តប្បច្ចក្ខធម្មំ តំ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) ចំពោះធម៌ដែលឃើញហើយ ។ ពាក្យថា ដែលតថាគតជាក់ច្បាស់ក្នុងខ្លួន គឺ តថាគតនឹងសម្តែងធម៌ដែលដឹងច្បាស់ចំពោះខ្លួនឯង ជាក់ច្បាស់ក្នុងខ្លួន មិនមែនដោយជឿស្តាប់បុគ្គលដទៃ មិនមែនជឿដោយអាងថាឮមកដូច្នេះ មិនមែនដោយឮត ។ គ្នា មិនមែនដោយការផ្ទៃផ្ទាំនឹងក្ជួន មិនមែនដោយហេតុនៃការត្រិះរិះ មិនមែនដោយហេតុនៃការគ្នេរគ្នាន់ មិនមែនដោយការជញ្ជឹងនូវអាការ: មិនមែនដោយហេតុដែលខ្លួនយល់ ខ្លួនពិនិត្យ ខ្លួនចូលចិត្តហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ដែលតថាគតជាក់ច្បាស់ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ។

[២២៧] ពាក្យថា បុគ្គលមានស្មារតី ដឹងច្បាស់នូវសន្តិបទណា ហើយគប្បីប្រព្រឹត្ត សេចក្តីថា បុគ្គលធ្វើឲ្យដឹង ថ្វឹង ពិចារណា ចម្រើន ធ្វើឲ្យជាក់ច្បាស់នូវធម៌ណា ថា សង្ខារទាំងពួងមិនទៀង ។ បេ ។ ធ្វើឲ្យដឹង ថ្វឹង ពិចារណា ចម្រើន ធ្វើឲ្យប្រាកដថា ធម្មជាតណាមួយមានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ ពាក្យថា មានស្មារតី គឺមានស្មារតីដោយហេតុ ៤ គឺ បុគ្គលចម្រើនកាយានុ-បស្សនាសតិប្ឋានក្នុងកាយ ឈ្មោះថាអ្នកមានស្មារតី ។ បេ ។ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ។ ពាក្យថា ប្រព្រឹត្ត គឺប្រតិបត្តិ ប្រព្រឹត្ត ផ្សេងៗ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមានស្មារតី គួរដឹងច្បាស់នូវសន្តិបទណា ហើយប្រព្រឹត្ត ។

ធោតកមាណវកប្បញ្ហានិទ្ទេសោ

[២២៨] តេ លោកេ វិសត្តិកន្តិ វិសត្តិកា វុច្ចតិ តណ្ហា យោ ភវោ សាភវោ ។ បេ ។ អភិជ្ឌា លោ-ភោ អកុសលមូលំ ។ វិសត្តិកាតិ កេនដ្ឋេន វិស-ត្តិកា ។ បេ ។ វិសជា វិត្ថតាតិ វិសត្តិកា ។ លោកេ-តិ អជ្ឌាយលោកេ ។ បេ ។ អាយតនលោកេ ។ តេ លោកេ វិសត្តិកន្តិ យា សា លោកេ វិសត្តិកា លោកេ តំ វិសត្តិកំ សតោ តរេយ្យ ឧត្តរេយ្យ ប-តរេយ្យ សមតិក្ក្រមេយ្យ វីតិវត្តេយ្យាតិ តេ លោកេ វិសត្តិកំ ។ តេនាហ ភគវា

កិត្តយិស្សាមិ តេ សន្តិ [ធោតការាតិ ភគវា]

ឧជ្ជេ ធម្មេ អនីតិហំ

យំ វិទិត្វា សតោ ចរំ តេ លោកេ វិសត្តិកន្តិ ។

ធោតកមាណវកប្បញ្ហានិទ្ទេស

[២២៨] ពាក្យថា ធ្វើវិសត្តិកាតណ្ហា ក្នុងលោក បានសេចក្ដីថា តណ្ហា លោកហៅថា វិសត្តិកា បានខាងតម្រេក តម្រេកខ្លាំង ។ បេ ។ អកិញ្ចា លោក: អកុសលមូល ។ សំណួរត្រង់ពាក្យថា វិសត្តិកា ចុះតណ្ហាឈ្មោះថា វិសត្តិកា ដោយអត្ថដូចម្ដេច ។ បេ ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិផ្សាយទូទៅ ផ្សព្វផ្សាយទៅ ។ ពាក្យថា ក្នុងលោក គឺ ក្នុងអបាយលោក ។ បេ ។ ក្នុងអាយ-តនលោក ។ ពាក្យថា ធ្វើវិសត្តិកាតណ្ហា ក្នុងលោកបាន មានន័យថា តណ្ហាណា ដែលផ្សាយទៅកាន់អារម្មណ៍ផ្សេងៗ ក្នុងលោក បុគ្គលមានស្មារតី គប្បីធ្វើ ធ្វើឡើង ធ្វើរំលង ធ្វើកាត់ ផ្ទោះរំលងនូវតណ្ហាដែលផ្សាយទៅកាន់អារម្មណ៍ផ្សេងនោះៗ ក្នុងលោកបាន ហេតុនោះ (ទ្រង់ត្រាស់ថា) ធ្វើនូវវិសត្តិកាតណ្ហា ក្នុងលោកបាន ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ម្នាលធោតក: បុគ្គលមានស្មារតី ដឹងច្បាស់នូវសន្ដិ-
បទណា ហើយគប្បីប្រព្រឹត្ដធ្វើវិសត្តិកាតណ្ហា ក្នុងលោក
បាន តថាគតនឹងសម្ដែងប្រាប់អ្នក នូវសន្ដិបទនោះ ដែល
តថាគតជាក់ច្បាស់ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ។

[២២៩] តញ្ចាហំ អភិនន្ទាមិ មហេសី សន្តិមុត្តមំ

យំ វិនិត្វា សតោ ចរំ តរេ លោកេ វិសត្តិកំ ។

[២៣០] តញ្ចាហំ អភិនន្ទាមីតិ តន្តិ តុយ្ហំ វចនំ ព្យបថំ ឧេសនំ អនុសន្ធិ ។ អភិនន្ទាមីតិ ជន្ទាមិ អភិនន្ទាមិ មោទាមិ អនុមោទាមិ សាធិយាមិ បត្ត-យាមិ បិហយាមិ អភិជ្ឌាមីតិ តញ្ចាហំ អភិនន្ទាមិ មហេសី សន្តិមុត្តមន្តិ មហេសីតិ ភតវា មហន្តំ សីលក្ខន្ធំ ឯសិ តវេសិ បរិយេសីតិ មហេសី ។ មហន្តំ សមាធិក្ខន្ធំ ។ បេ ។ ឥមាំ ឧេវ ឧេវ ឥមាំ ជរាសភោតិ មហេសី ។ សន្តិមុត្តមន្តិ សន្តិ រុច្ចតិ អមតំ និព្ពានំ យោ សោ សព្ពសង្ខារសមថោ សព្ពុបធិ ប្ប ដិនិ ស្ស ក្ខោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្ពានំ ។ ឧត្តមន្តិ អគ្គំ សេដ្ឋំ វិសេដ្ឋំ ចាមោក្ខំ ឧត្តមំ បរវន្តិ មហេសី សន្តិមុត្តមំ ។

[២២៩] (ផោតក: ក្រាបទូលថា) បពិត្រព្រះមហេសី បុគ្គលមានស្មារតី ដឹងនូវសន្តិបទណា ហើយគប្បីប្រព្រឹត្តធ្វើនូវវិសត្តិកាតណ្ហាក្នុងលោកបាន ខ្ញុំព្រះអង្គនឹងត្រេកអរចំពោះសន្តិបទដ៏ឧត្តមនោះ ។

[២៣០] *អធិប្បាយពាក្យថា ខ្ញុំព្រះអង្គនឹងត្រេកអរ ចំពោះសន្តិបទនោះ ត្រង់ពាក្យថា ចំពោះសន្តិបទនោះ គឺចំពោះព្រះពុទ្ធដីកា គន្ថដ៏ព្រះពុទ្ធដីកា ទេសនា អនុសន្ធិរបស់ព្រះអង្គ ។ ពាក្យថា នឹងត្រេកអរ គឺខ្ញុំព្រះអង្គនឹងត្រេកអរ ត្រេកអរចំពោះ រីករាយ រីករាយតាម ជ្រះថ្លា ប្រាថ្នា ស្រឡាញ់ជាប់ចិត្ត ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គនឹងត្រេកអរចំពោះសន្តិបទនោះ ។ ពាក្យថា បពិត្រព្រះមហេសី... សន្តិបទដ៏ឧត្តម ត្រង់ពាក្យថា ព្រះមហេសី សេចក្តីថា ព្រះនាមថា មហេសីព្រោះព្រះមានព្រះភាគទ្រង់រក ស្វែង ស្វះស្វែង នូវកងសីលដ៏ធំ ។ ព្រះនាមថាមហេសី (ព្រោះព្រះមានព្រះភាគស្វែងរក) នូវកងសមាធិដ៏ធំ ។ បេ ។ ព្រះពុទ្ធជាទេវតាកន្ថដ៏ជាងទេវតា គង់ ក្នុងទីណា ព្រះពុទ្ធជានរ:អង់អាច គង់ ក្នុងទីណា ។ ពាក្យថា សន្តិបទដ៏ឧត្តម សេចក្តីថា អមតនិព្វាន លោកហៅថា សន្តិបទ បានខាងការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគ: ការរលត់ និព្វាន ។ ពាក្យថា ដ៏ឧត្តម គឺ ប្រសើរ ប្រសើរផុត ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ហេតុនោះ (លោកពោលថា) បពិត្រព្រះមហេសី.....សន្តិបទដ៏ឧត្តម ។*

ធោតកមាណវកប្បញ្ហានិទ្ទេសោ

[២៣១] យំ វិនិត្វា សតោ ចរន្តិ យំ វិនិតំ កត្វា តុលយិត្វា តីរយិត្វា វិការយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ យំ វិនិតំ កត្វា តុលយិត្វា តី-រយិត្វា វិការយិត្វា វិភូតំ កត្វា ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិ-ប្បដ្ឋានំ ភាវេន្តោ សតោ ។ បេ ។ សោ រុច្ចតិ សតោ ។ ចរន្តិ ចរន្តោ វិចរន្តោ ឥរិយន្តោ វត្តេន្តោ ចាលេន្តោ យាបេន្តោ យាបេន្តោតិ យំ វិនិត្វា សតោ ចរំ ។

[២៣២] តត្រ លោកេ វិសត្តិកន្តិ វិសត្តិកា រុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ វិសត្តិកាតិ កេនត្ថេន វិសត្តិកា ។ បេ ។ វិសជា វិត្ថតាតិ វិសត្តិកា ។ លោកេតិ អជ្ឌាយលោកេ ។ បេ ។

ធោតកមាណវកប្បញ្ហានិទ្ទេស

[២៣១] *ពាក្យថា បុគ្គលមានស្មារតី ដឹងនូវសន្តិបទណា ហើយគប្បីប្រព្រឹត្ត គឺបុគ្គលធ្វើឲ្យដឹង ថ្វឹង ពិចារណា ចម្រើន ធ្វើឲ្យច្រាកដ នូវធម៌ណាថា សង្ខារទាំងពួងមិនទៀង ។ បេ ។ ធ្វើឲ្យដឹង ថ្វឹង ពិចារណា ចម្រើន ធ្វើឲ្យច្រាកដ នូវធម៌ណាថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅ វិញជាធម្មតា ។ ពាក្យថា មានស្មារតី គឺមានស្មារតី ដោយហេតុ ៤ គឺ បុគ្គលចម្រើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថា អ្នកមាន ស្មារតី ។ បេ ។ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ។ ពាក្យថា ប្រព្រឹត្ត គឺប្រព្រឹត្ត ត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ (លោកពោលថា) មានស្មារតី ដឹងនូវ សន្តិបទណា ហើយគប្បីប្រព្រឹត្ត ។*

[២៣២] *អធិប្បាយពាក្យថា ធ្វងវិសត្តិកាតណ្ហា ក្នុងលោកបាន សេចក្តីថា តណ្ហា លោកហៅថា វិសត្តិកា បានខាង តម្រេក តម្រេកខ្ជាំង ។ បេ ។ អកិញ្ចា លោក: អកុសលមូល ។ សំណួរ ត្រង់ពាក្យថា វិសត្តិកា ចុះតណ្ហាឈ្មោះថា វិសត្តិកា ដោយអត្ត ដូចម្តេច ។ បេ ។ តណ្ហាឈ្មោះវិសត្តិកា ព្រោះផ្សាយទូទៅ ផ្សព្វ ផ្សាយទៅ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។*

អាយតនលោកេ ។ តយ លោកេ វិសត្តិកន្តិ យា សា លោកេ វិសត្តិកា លោកេ តំ វិសត្តិកំ សតោ តយ្យ ឧត្តយ្យ បតយ្យ សមតិក្ក-មេយ្យ រីតិវត្តេយ្យាតិ តយ លោកេ វិសត្តិកំ ។ តេនាហ សោ ព្រាហ្មណោ

តញ្ចាហំ អភិនន្ទាមិ មហេសី សន្តិមុត្តមំ
យំ វិនិត្វា សតោ ចរំ តយ លោកេ វិសត្តិកន្តិ ។

[២៣៣] យន្តិញ្ចិ សម្ឆជានាសិ (ឧោតកាតិ ភគវា)
ឧទ្ធं អធោ តិរិយញ្ចាបិ មជ្ឈ
ឯតំ វិនិត្វា សង្គោតិ លោកេ
ភវាភវាយ មាកាសិ តណ្ហំ ។

[២៣៤] យន្តិញ្ចិ សម្ឆជានាសីតិ យន្តិញ្ចិ សម្ឆ-ជានាសិ វិជានាសិ បដិវិជានាសិ បដិវិជ្ឈសីតិ យន្តិញ្ចិ សម្ឆជានាសិ ។ ឧោតកាតិ ភគវាតិ ឧោតកាតិ ភគវា តំ ព្រាហ្មណំ ជានេន អាលបតិ ។

ក្នុងអាយតនលោក ។ ពាក្យថា ធ្វើនូវវិសត្តិកាតណ្ហា ក្នុងលោកបាន សេចក្តីថា តណ្ហាឈ្មោះ វិសត្តិកា ណា ក្នុងលោក បុគ្គលមានស្មារតី គប្បីធ្វើ ធ្វើឡើង ធ្វើរំលង ធ្វើកាត់ ផ្ទោះរំលង នូវតណ្ហាឈ្មោះ វិសត្តិកានោះ ក្នុងលោកបាន ហេតុនោះ (លោកពោលថា) ធ្វើនូវ វិសត្តិកាតណ្ហា ក្នុងលោកបាន ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

> បពិត្រព្រះមហេសី បុគ្គលមានស្មារតី ដឹងនូវសន្តិបទណា
> ហើយគប្បីប្រព្រឹត្តធ្វើ នូវវិសត្តិកាតណ្ហា ក្នុងលោកបាន ខ្ញុំ
> ព្រះអង្គនឹងត្រេកអរ ចំពោះសន្តិបទដ៏ឧត្តមនោះ ។

[២៣៣] (ព្រះមានព្រះភាគទ្រង់ត្រាស់ថា) ម្នាលជោតក: បើអ្នក
> ដឹងច្បាស់ នូវអារម្មណ៍ណាមួយ ក្នុងចំណែកខាងលើ ក្នុង
> ចំណែកខាងក្រោម និងក្នុងចំណែកទទឹងគឹកណ្តាល លុះអ្នក
> បានដឹងនូវអារម្មណ៍នុ៎ះ ថាជាគ្រឿងជាប់នៅក្នុងលោកយ៉ាង
> នេះហើយ អ្នកកុំធ្វើនូវចំណង់ ក្នុងកពតូចកពធំឡើយ ។

[២៣២] ពាក្យថា បើអ្នកដឹងច្បាស់នូវអារម្មណ៍ណាមួយ គឺបើអ្នក ដឹងច្បាស់ យល់ច្បាស់ យល់ជាក់ ជ្រាបច្បាស់ នូវអារម្មណ៍ណាមួយ ហេតុនោះ (ទ្រង់ត្រាស់ថា) បើអ្នកដឹងច្បាស់នូវអារម្មណ៍ណាមួយ ។ ពាក្ય ថា ម្នាលជោតក: នៃបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលជោតក: គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះ ដោយចំឈ្មោះ ។

ភគវាតិ ការវាជិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ធោតកាតិ ភគវា ។

[២៣៤] ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេតិ ឧទ្ធន្តិ រុច្ចតិ អនាគតំ អធោតិ អតីតំ តិរិយញ្ចាបិ មជ្ឈេតិ បច្ចុប្បន្នំ ។ អថវា ឧទ្ធន្តិ សុខា វេទនា អធោតិ ទុក្ខា វេទនា តិរិយញ្ចាបិ មជ្ឈេតិ អទុក្ខមសុខា វេទនា ។ ឧទ្ធន្តិ កុសលា ធម្មា អធោតិ អកុសលា ធម្មា តិរិយញ្ចាបិ មជ្ឈេតិ អព្យាកតា ធម្មា ។ ឧទ្ធន្តិ ទេវលោកោ អធោតិ អបាយលោកោ តិរិយញ្ចាបិ មជ្ឈេតិ មនុស្សលោកោ ។ ឧទ្ធន្តិ អរូបធាតុ អធោតិ កាមធាតុ តិរិយញ្ចាបិ មជ្ឈេតិ រូបធាតុ ។ ឧទ្ធន្តិ ឧទ្ធំ ចាឧតលា អធោតិ អធោ កេសមត្ថកា តិរិយញ្ចាបិ មជ្ឈេតិ ឯមជ្ឈេតិ ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈ ។

ពាក្យថា ព្រះមានព្រះភាគ នេះជាពាក្យពោលដោយគោរព ។ បេ ។ ការ
បញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់
ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលធោតក: ។

[២៣៥] ពាក្យថា ខាងលើ ខាងក្រោម និងទទឹងគឺកណ្តាល សេចក្តី
ថា អនាគត លោកហៅថា ខាងលើ អតីត លោកហៅថា ខាងក្រោម
បច្ចុប្បន្ន លោកហៅថា ទទឹងគឺកណ្តាល ។ មួយទៀត សុខវេទនា លោក
ហៅថា ខាងលើ ទុក្ខវេទនា លោកហៅថា ខាងក្រោម អទុក្ខមសុខវេទនា
លោកហៅថា ទទឹងគឺកណ្តាល ។ ពួកកុសលធម៌ លោកហៅថា ខាង
លើ ពួកអកុសលធម៌ លោកហៅថា ខាងក្រោម ពួកធម៌អព្យាក្រឹត
លោកហៅថា ទទឹងគឺកណ្តាល ។ ទេវលោក លោកហៅថា ខាងលើ
អបាយលោក លោកហៅថា ខាងក្រោម មនុស្សលោក លោកហៅថា
ទទឹងគឺកណ្តាល ។ អរូបធាតុ លោកហៅថា ខាងលើ កាមធាតុ លោក
ហៅថា ខាងក្រោម រូបធាតុ លោកហៅថា ទទឹងគឺកណ្តាល ។ តាំង
អំពីផ្នែបាតជើងឡើងមក ហៅថា ខាងលើ តាំងអំពីចុងសក់ចុះទៅ
ហៅថា ខាងក្រោម ត្រង់ទីពាក់កណ្តាលខ្លួន ហៅថា ទទឹងគឺកណ្តាល
ហេតុនោះ (ទ្រង់ត្រាស់ថា) ខាងលើ ខាងក្រោម ទទឹង គឺកណ្តាល ។

[២៣៦] ឯតំ វិនិត្វា សង្ហោតិ លោកោតិ សង្ហោ ឯសោ លក្ខនំ ឯតំ ពន្ធនំ ឯតំ បលិពោធោ ឯ-សោតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវ-យិត្វា វិភូតំ កត្វាតិ ឯតំ វិនិត្វា សង្ហោតិ លោកោ ។

[២៣៧] ភវាភវាយ មាកាសិ តណ្ហន្តិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្ពតណ្ហា ធម្ម-តណ្ហា ។ ភវាភវាយាតិ ភវាភវាយ កម្មភវាយ បុនព្ភ-វាយ កាមភវាយ កម្មភវាយ កាមភវាយ បុនព្ភ-វាយ រូបភវាយ កម្មភវាយ រូបភវាយ បុនព្ភវាយ អរូបភវាយ កម្មភវាយ អរូបភវាយ បុនព្ភវាយ បុនប្បុនំ ភវាយ បុនប្បុនំ គតិយា បុនប្បុនំ ឧប-បត្តិយា បុនប្បុនំ បដិសន្ធិយា បុនប្បុនំ អត្តភាវ-ភិនិព្ពត្តិយា តណ្ហំ មាកាសិ មា ជនេសិ មា សញ្ជនេសិ មា និព្ពត្តេសិ មា អភិនិព្ពត្តេសិ បជ-ហិ វិនោទេហិ ព្យន្តីករោហិ អនភាវង្គមេហីតិ ភ-វាភវាយ មាកាសិ តណ្ហំ ។ តេនាហ ភគវា

[២៣៦] *ពាក្យថា លុះអ្នកបានដឹង នូវអារម្មណ៍នុ៎ះ ថាជាគ្រឿងជាប់នៅក្នុងលោក គឺបុគ្គលដឹង យល់ ច្ប៊ីង ពិចារណា ចម្រើន ធ្វើឲ្យច្រាកដថា នុ៎ះការជាប់ នុ៎ះការចំពាក់ នុ៎ះចំណង នុ៎ះកង្ខ្ល ហេតុនោះ (ទ្រង់ត្រាស់ថា) លុះអ្នកបានដឹងនូវអារម្មណ៍នុ៎ះ ថាជាគ្រឿងជាប់នៅក្នុងលោក ។*

[២៣៧] *ពាក្យថា អ្នកកុំធ្វើនូវចំណង់ ក្នុងកពតូចកពធំឡើយ គឺចំណង់ក្នុងរូប ចំណង់ក្នុងសំឡេង ចំណង់ក្នុងក្លិន ចំណង់ក្នុងរស ចំណង់ក្នុងផ្សព្ធ ចំណង់ក្នុងធម្មារម្មណ៍ ។ ពាក្យថា ក្នុងកពតូចកពធំ គឺអ្នកកុំធ្វើ កុំបង្កើត កុំបង្កើតព្រម កុំបង្កើតច្រាកដ កុំបង្កើតឡើងចំពោះ គឺថា លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបៃបភាពតទៅនូវចំណង់ក្នុងកពតូចកពធំ គឺកម្មកព បុនព្ភព គឺថា ក្នុងកាមកព កម្មកព ក្នុងកាមកព បុនព្ភព ក្នុងរូបកព កម្មកព ក្នុងរូបកព បុនព្ភព ក្នុងអរូបកព កម្មកព ក្នុងអរូបកព បុនព្ភព គឺក្នុងកំណើតរឿយៗ ក្នុងដំណើររឿយៗ ក្នុងការកើតរឿយៗ ក្នុងបដិសន្ធិរឿយៗ ក្នុងការបាននូវអត្តភាពរឿយ ។ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកកុំធ្វើនូវចំណង់ ក្នុងកពតូចកពធំឡើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា*

ធោតកមាណវកប្បញ្ហានិទ្ទេសោ

យម្ហិ ញត្វា សម្បជានាសិ (ធោតកាតិ ភគវា)

ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេ

ឯតំ វិទិត្វា សង្គោតិ លោកេ

ភវាភវាយ មាកាសិ តណ្ហន្តិ ។

សហគាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

ធោតកមាណវកប្បញ្ហានិទ្ទេសោ បញ្ចមោ ។

ម្នាលធោតក: បើអ្នកដឹងច្បាស់នូវអារម្មណ៍ណាមួយ ក្នុងចំណែកខាងលើ ក្នុងចំណែកខាងក្រោម និងក្នុងចំណែកទទឹង គឺកណ្តាល លុះអ្នកបានដឹងនូវអារម្មណ៍នុ៎ះ ថាជាគ្រឿងជាប់នៅក្នុងលោកយ៉ាងនេះហើយ អ្នកកុំធ្វើនូវចំណង់ក្នុងភពតូចភពធំឡើយ ។

លុះចប់គាថាហើយ ។ បេ ។ (ធោតក: ក៏ប្រកាសខ្ជូនថា) បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាព្រះសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

ចប់ ធោតកមាណវកប្បញ្ហានិទ្ទេស ទី ៥ ។

ឧបសីវមាណវកបញ្ហានិទ្ទេសោ

[២៣៨] ឯកោ អហំ សក្ក មហន្តមោឃំ

(ឥច្ចាយស្មា ឧបសីវោ)

អនិស្សិតោ នោ វិសហামិ តារិតុំ

អារម្មណំ ព្រូហិ សមន្តចក្ខុ

យំ និស្សិតោ ឱឃមិមំ តរេយ្យំ ។

[២៣៩] ឯកោ អហំ សក្ក មហន្តមោឃន្តិ ឯកោតិ បុគ្គលោ វា មេ ឧតិយោ នត្ថិ ឆម្នា វា មេ ឧតិយោ នត្ថិ យំ វា បុគ្គលំ និស្សាយ ឆម្មំ វា និស្សាយ មហន្តំ តាមោឃំ ភវោឃំ ឱឆ្ឌោឃំ អវិជ្ជោឃំ តរេយ្យំ ឧត្តរេយ្យំ បតរេយ្យំ សមតិក្កមេ-យ្យំ វីតិវត្តេយ្យន្តិ ឯកោ ។ សក្ខាតិ សក្ខោ ។ ភគវា សក្យកុលា បព្ជជិតោតិបិ សក្ខោ ។ អថវា អត្ថោ មហន្ទោ ឆនវាតិបិ សក្ខោ ។ តស្សិមានិ ឆនានិ សេយ្យថីទំ សទ្ធាឆនំ សីលឆនំ ហិរិឆនំ ឱត្តប្ប-ឆនំ សុតឆនំ ចាតឆនំ បញ្ញាឆនំ សតិប្បដ្ឋានឆនំ ។ បេ ។

ឧបសីវមាណវកប្បញ្ហានិទ្ទេស

[២៣៨] (ឧបសីវៈ មានអាយុ ទូលសួរដូច្នេះថា) បពិត្រ
ព្រះអង្គជាសក្ក: ខ្ញុំព្រះអង្គម្នាក់ឯង មិនបានអាស្រ័យ(បុគ្គល
ឬធម៌) ទើបមិនអាចធ្វើអន្ទង់ដ៏ធំបាន បពិត្រព្រះអង្គជាសមន្ត-
ចក្ខុ សូមព្រះអង្គ សម្តែងនូវអារម្មណ៍ ដែលនាំឲ្យខ្ញុំព្រះអង្គ
អាស្រ័យហើយធ្វើនូវអន្ទង់នេះបាន ។

[២៣៩] អធិប្បាយពាក្យថា បពិត្រព្រះអង្គជាសក្ក: ខ្ញុំព្រះអង្គ
ម្នាក់ឯង... អន្ទង់ធំបាន ត្រង់ពាក្យថា ម្នាក់ឯង គឺ បុគ្គលជាគម្រប់ពីរ
នឹងខ្ញុំមិនមាន ឬធម៌ជាគម្រប់ពីរនឹងខ្ញុំមិនមាន ដែលជាបុគ្គល ឬជាធម៌
ដែលខ្ញុំព្រះអង្គអាស្រ័យហើយ គប្បីធ្វើ ធ្វើឡើង ធ្វើរំលង ធ្វើកាត់
ផ្ទោះរំលង នូវអន្ទង់គឺកាម អន្ទង់គឺភព អន្ទង់គឺទិដ្ឋិ អន្ទង់គឺអវិជ្ជាដ៏ធំ
បាន ហេតុនោះ (លោកពោលថា) ម្នាក់ឯង ។ ពាក្យថា បពិត្រ
ព្រះអង្គ ជាសក្ក: គឺព្រះមានព្រះភាគ ទ្រង់ព្រះនាមថា សក្ក: ។ ព្រះ
មានព្រះភាគទ្រង់ព្រះនាមសក្ក: ព្រោះទ្រង់ចេញចាកសក្យត្រកូល ហើយ
បព្វជ្ជា ក៏បាន ។ មួយទៀត ទ្រង់ព្រះនាមសក្ក: ព្រោះទ្រង់ស្តុកស្តម្ភ
មានទ្រព្យច្រើន មានទ្រព្យធន ក៏បាន ។ ទ្រព្យទាំងឡាយនេះ របស់
ព្រះមានព្រះភាគនោះ គឺ ទ្រព្យសទ្ធា ទ្រព្យសីល ទ្រព្យហិរិ ទ្រព្យ
ឱ្ត្ត ទ្រព្យសុត: ទ្រព្យចាគ: ទ្រព្យបញ្ញា ទ្រព្យសតិប្ឋាន ។ បេ ។

ជិញ្ញានធនំ ។ ឥមេហិ អនេកវិធេហិ ធនរតនេហិ អឌ្ឍោ
មហទ្ធនោ ធនវាតិបិ សក្ខោ ។ អថវា សក្ខោ បហុ
វិសវី អលមត្តោ សូរោ វីរោ វិក្កន្តោ អភីរុ អច្ឆម្ភី អនុ-
ត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំ-
សោតិបិ សក្ខោតិ ឯកោ អហំ សក្ក មហន្តមោ-
ឃំ ។ ឥច្ចាយស្មា ឧបសីវោតិ ឥច្ចាតិ[1] បទសន្ធិ ។
អាយស្មាតិ ២ិយវចនំ ។ ឧបសីវោតិ តស្ស ព្រាហ្ម-
ណស្ស នាមំ ។ បេ ។ អភិលាបោតិ ឥច្ចាយស្ម
ឧបសីវោ ។

[២៤០] អនិស្សិតោ នោ វិសហាមិ តារិតុន្តិ អនិ-
ស្សិតោតិ បុគ្គលំ វា អនិស្សិតោ ធម្មំ វា អនិស្សិតោ ។
នោ វិសហាមីតិ ន ឧស្សហামি ន សក្ខោមិ ន
បដិពលោ ។ តារិតុន្តិ មហន្តំ ការាមោឃំ ភវោឃំ ឱ-
ឆ្ឌោឃំ អវិជ្ជោឃំ តារិតុំ ឧត្តរិតុំ បតរិតុំ សមតិក្ខមិតុំ

---

១ ម. ឧបសីវោ ឥច្ចាតិ បទសន្ធិ ។ ល ។ ឧបសីវោតិ នត្ថិ ។

ទ្រព្យគឺនិព្វាន ។ ព្រះនាមថាសក្ក: ព្រោះទ្រង់ស្តុកស្តម្ភ មានទ្រព្យច្រើន មានទ្រព្យធន ដោយធនរតន៍ទាំងនេះ ច្រើនប្រការ ក៏បាន ។ ឬថា ព្រះនាមថាសក្ក: ព្រោះព្រះមានព្រះភាគ ទ្រង់អង់អាច អាចហាន ក្លាហាន មោះមុត ក្ងៀវក្ងា មានព្យាយាម ធ្លាប់ចូលកាន់សង្គ្រាម មិនខ្លាច មិនរន្ធត់ មិនតក់ស្ទុត មិនរត់ចោល លះកំ័យគួរខ្លាច មិនព្រឺរោម ក៏បាន ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាសក្ក: ខ្ញុំព្រះអង្គម្នាក់ឯង... អន្ទង់ធំ ក៏បាន ។ ពាក្យថា ដូច្នេះ នៃបទថា ឧបសីវ: មានអាយុ ទូលសួរដូច្នេះ គឺជាពាក្យតភ្ជាប់ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា ឧបសីវ: គឺជានាម របស់ព្រាហ្មណ៍នោះ ។ បេ ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ (មានពាក្យថា) ឧបសីវ: មានអាយុ ទូលសួរដូច្នេះ ។

[២៦០] ពាក្យថា ខ្ញុំព្រះអង្គមិនបានអាស្រ័យ (បុគ្គលឬធម៌) ទើបមិនអាចធ្វេ ត្រង់ពាក្យថា មិនបានអាស្រ័យ គឺមិនបានអាស្រ័យបុគ្គល ឬមិនបានអាស្រ័យធម៌ ។ ពាក្យថា មិនអាច គឺមិនអាច មិនហ៊ាន មិនប្រតិ-ពល ។ ពាក្យថា ធ្វេ គឺរំលង ធ្វេឡើង ធ្វេរំលង ធ្វេកាត់ ផ្ទោះរំលង នូវអន្ទង់គឺកាម[១] អន្ទង់គឺភព[២] អន្ទង់គឺទិដ្ឋិ[៣] អន្ទង់គឺអវិជ្ជា[៤] ដ៏ធំ

១ ដែលថាឆ្លងអន្លង់ គឺឆ្លងអន្លង់កាម ដោយអនាគាមិមគ្គ ។ ២ ឆ្លងអន្លង់ភពដោយអរហត្តមគ្គ ។ ៣ ឆ្លងអន្លង់ទិដ្ឋិ ដោយសោតាបត្តិមគ្គ ។ ៤ ឆ្លងអន្លង់អវិជ្ជា ដោយអរហត្តមគ្គ ។ អដ្ឋកថា ។

រីតិវត្តិតុន្តិ អនិស្សិតោ ឣហំ វិសហামិ តារិតុំ ។

[២៤១] អារម្មណំ ព្រូហិ សមន្តចក្ខូតិ អារម្មណំ ព្រូហីតិ អារម្មណំ អាលម្ពណំ និស្សយំ ឧបនិស្សយំ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បការាសេហីតិ អារម្មណំ ព្រូហិ ។ សមន្តចក្ខូតិ សមន្តចក្ខុ វុច្ចតិ សព្ពញ្ញុតញ្ញាណំ ។ ភគវា ឣនេន សព្ពញ្ញុតញ្ញាណេន ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ ។

ន ឣស្ស ឣនិដ្ឋមិធត្ថិ កិញ្ចិ
ឣថោ ឣវិញ្ញាតមជានិតព្ពំ
សព្ពំ ឣភិញ្ញាសិ យទត្ថិ ជានេយ្យំ
ឣថាគតោ ឣនេន សមន្តចក្ខូតិ ។

អារម្មណំ ព្រូហិ សមន្តចក្ខុ ។

ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គមិនបានអាស្រ័យ (បុគ្គល ឬធម៌) ទើបមិនអាចធ្ងន់ ។

[២៦១] ពាក្យថា បពិត្រព្រះអង្គ ជាសមន្តចក្ខុ សូមព្រះអង្គសម្តែងអារម្មណ៍ ត្រង់ពាក្យថា សូមព្រះអង្គសម្តែងអារម្មណ៍ គឺសូមព្រះអង្គពោល ប្រាប់ បង្ហាញ បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយ ប្រកាស នូវសភាពត្រេកអរ ជាទីគោង ជាទីអាស្រ័យ ជាទីពឹងផ្អែក ហេតុនោះ (លោកពោលថា) សូមព្រះអង្គសម្តែងអារម្មណ៍ ។ ពាក្យថា សមន្តចក្ខុ សេចក្តីថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ ព្រះមានព្រះភាគ ដល់ ដល់ព្រម មកដល់ មកដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ប្រកបហើយ ដោយសព្វញ្ញុតញ្ញាណនោះ ។

> អ្វីមួយក្នុងលោក ដែលព្រះតថាគតនោះមិនឃើញ មិនជ្រាប ឬមិនគប្បីជ្រាប មិនមានទេ របស់ណាដែលគួរដឹង ព្រះតថាគត ទ្រង់ជ្រាបរបស់ទាំងអស់នោះ ហេតុនោះ ព្រះតថាគត ទ្រង់ព្រះនាមថា សមន្តចក្ខុ ។

ហេតុនោះ (ទើបមានពាក្យថា) បពិត្រព្រះអង្គ ជាសមន្តចក្ខុ សូមព្រះអង្គសម្តែងអារម្មណ៍ ។

[២៤២] យំ និស្សិតោ ឱឃមិមំ តរេយ្យន្តិ យំ និស្សិតោតិ យំ វា បុគ្គលំ និស្សិតោ ធម្មំ វា និ-ស្សិតោ ។ ឱឃមិមំ តរេយ្យន្តិ មហន្តំ កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ តរេយ្យុំ ឧត្តរេយ្យុំ បតរេយ្យុំ សមតិក្កមេយ្យុំ វីតិវត្តេយ្យន្តិ យំ និស្សិតោ ឱឃមិមំ តរេយ្យុំ ។ តេនាហ សោ ព្រាហ្មណោ

ឯកោ អហំ សក្ក មហន្តមោឃំ

(ឥច្ចាយស្មា ឧបសីវោ)

អនិស្សិតោ ឧោ វិសហាមិ តារិតុំ

អារម្មណំ ព្រូហិ សមន្តចក្ខុ

យំ និស្សិតោ ឱឃមិមំ តរេយ្យន្តិ ។

[២៤៣] អាកិញ្ចញ្ញំ បេក្ខមានោ សតិមា

(ឧបសីវាតិ ភគវា)

ឧត្តីតិ និស្ឋាយ តរស្សុ ឱឃំ

កាមេ បហាយ វិរោ ភវាហិ

តណ្ហក្ខយំ រត្តមហាភិបស្ស ។

ឧបសីវមាណវកប្បញ្ហានិទ្ទេស

[២៦២] *ពាក្យថា ដែលនាំឲ្យខ្ញុំព្រះអង្គអាស្រ័យ ហើយគប្បីធ្វើអន្ទង់នេះបាន ត្រង់ពាក្យថា ដែលនាំឲ្យអាស្រ័យ គឺអាស្រ័យបុគ្គលឬអាស្រ័យធម៌ ។ ពាក្យថា គប្បីធ្វើអន្ទង់នេះបាន គឺគប្បីធ្វើ ធ្វើរំលង ធ្វើកាត់ ផ្ទោះរំលង នូវអន្ទង់គឺកាម អន្ទង់គឺភព អន្ទង់គឺទិដ្ឋិ អន្ទង់គឺអវិជ្ជា ដ៏ធំ ហេតុនោះ (លោកពោលថា) ដែលនាំឲ្យខ្ញុំព្រះអង្គអាស្រ័យ ហើយធ្វើអន្ទង់នេះបាន ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា*

បពិត្រព្រះអង្គជាសក្ក: ខ្ញុំព្រះអង្គម្នាក់ឯង មិនបានអាស្រ័យ (បុគ្គលឬធម៌) ទើបមិនអាចធ្វើនូវអន្ទង់ដ៏ធំបាន បពិត្រព្រះអង្គ ជាសមន្តចក្ខុ សូមព្រះអង្គសម្តែងអារម្មណ៍ដែលនាំឲ្យខ្ញុំព្រះអង្គអាស្រ័យ ហើយធ្វើអន្ទង់នេះ ។

[២៦៣] *(ព្រះមានព្រះភាគត្រាស់ថា) ម្នាលឧបសីវ: អ្នកចូរមានស្មារតីសម្ងឹងអាកិញ្ចញ្ញាយតនជ្ឈាន អាស្រ័យ (អាកិញ្ចញ្ញាយតនសមាបត្តិ) ដោយបរិកម្មថាមិនមានៗ ហើយធ្វើអន្ទង់ចុះ អ្នកចូរលះបង់កាមទាំងឡាយ ហើយវៀរចាកកថាទាំងឡាយចេញ ហើយសម្ងឹងនូវការអស់តណ្ហា ទាំងយប់ទាំងថ្ងៃ ។*

[២៤៤] អាកិញ្ចញ្ញំ បេក្ខមានោ សតិមាតិ សោ ព្រា-
ហ្មណោ បកតិយា អាកិញ្ចញ្ញាយតនសមាបត្តឺ លាភី-
យេវ និស្សយំ ន ជានាតិ អយំ មេ និស្សយោតិ ។
តស្ស ភតវា និស្សយញ្ច អាចិក្ខតិ ឧត្តរិញ្ច និយ្យា-
នបថំ អាចិក្ខតិ នេវសញ្ញានាសញ្ញាយតនសមាបត្តឺ
សមាបជ្ជិត្វា តតោ វុដ្ឋហិត្វា តត្ត ជាតេ ចិត្តចេតសិ-
កេ ធម្មេ អនិច្ចតោ បេក្ខមានោ ខុក្ខតោ រោគតោ
គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បលោ-
កតោ ឞ្ឌៀតិតោ ឧបទ្ទវតោ អសាតតោ ភយតោ
ឧបសគ្គតោ ចលតោ បភង្គុតោ អទ្ធុវតោ អតាណតោ
អលេណតោ អសរណតោ អសរណីភូតតោ រិត្តតោ
តុច្ឆតោ សុញ្ញតោ អនត្តតោ អាទីនវតោ វិបរិណា-
មធម្មតោ អសារកតោ អឃមូលតោ វធកតោ
សាសវតោ រជកតោ សង្ខ្ជតោ មារាមិសតោ

[២៤៤] *ពាក្យថា អ្នកចូរមានស្មារតី សម្ងឹងអាកិញ្ចញ្ញាយត-នផ្សាន អធិប្បាយថា ព្រាហ្មណ៍នោះ បានអាកិញ្ចញ្ញាយតនសមាបត្តិ តាមប្រក្រតី តែមិនដឹងការអាស្រ័យថា អាកិញ្ចញ្ញាយតនសមាបត្តិនេះ ជាទីអាស្រ័យរបស់អាត្មាទេ ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់ទីអាស្រ័យ ផង ទ្រង់ប្រាប់ផ្លូវជាទីស្រោចស្រង់តទៅទៀតផង ដល់ព្រាហ្មណ៍នោះ ថា អ្នកចូលកាន់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ហើយចេញអំពី សមាបត្តិនោះ ហើយពិចារណាធម៌គឺចិត្តនិងចេតសិកទាំងឡាយ ដែល កើតហើយក្នុងសមាបត្តិនោះ ដោយសភាពថាមិនទៀង ពិចារណាមើល រំពឹងមើល សម្ងឹងមើល រមិលមើល ដោយសភាពថាជាទុក្ខ ជារោគ ជា បូស ជាសរ ជាអន្តរាយ ជាជំងឺ ជារបស់អ្នកដទៃ ជារបស់វិនាស ជា ចង្រៃ ជាឧបទ្រព ជារបស់មិនគួរប្រាថ្នា ជាភ័យ ជាឧបស័គ្គ ជារបស់ ញាប់ញ័រ ជារបស់ពុករលួយ ជារបស់មិនបិតថេរ ជារបស់ឥតទីពឹង ផ្នែក ជារបស់ឥតទីពួន ជារបស់ឥតទីរឭក ជារបស់ឥតទីពំនឹង ជារបស់ឥតអំពើ ជារបស់ទទេ ជារបស់សូន្យ មិនមែនជារបស់ ខ្លួន ជាទោស ជាសភាវៈប្រែប្រួល ជារបស់ឥតខ្លឹម ជារបស់ ជាទីតាំងនៃទោស ជារបស់ប្រាសចាកសេចក្ដីចម្រើន ជារបស់ប្រកប ដោយអាសវៈ ជាអ្នកសម្ងាប់ ជាទីតាក់តែង ជានុយរបស់មារ*

ជាតិធម្មតោ ជរាធម្មតោ ព្យាធិធម្មតោ មរណធម្មតោ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មតោ សមុទ-យធម្មតោ អត្ថង្គមតោ អនស្សាទតោ អាទីនវតោ អនិ-ស្សរណតោ បេក្ខមានោ ឯលោកយមានោ និជ្ឌាយ-មានោ ឧបបរិក្ខមានោ ។ សតិមាតិ យា សតិ អនុស្សតិ បដិស្សតិ ។ បេ ។ សម្ម្ទាសតិ អយំ រុច្ចតិ សតិ ។ ឥមា-យ សតិយា ឧបេតោ សមុបេតោ ឧចាតតោ សមុចា-តតោ ឧបបន្នោ សមុបបន្នោ សមន្ទាតតោ សោ រុច្ច-តិ សតិមាតិ អាកិញ្ចញ្ញំ បេក្ខមានោ សតិមា ។ ឧបសីវាតិ ភគវាតិ ឧបសីវាតិ ភគវា តំ ព្រាហ្មណំ ជាមេន អាលបតិ ។ ភគវាតិ ការវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ឧបសីវាតិ ភគវា ។

[២៤៥] ជត្តីតិ និស្សាយ តរស្ស ឯយត្ថ ជត្តុ កិញ្ចីតិ អាកិញ្ចញ្ញាយតនសមាបត្តិ ។ ឆ្នាការ-ណា ជត្តុ កិញ្ចីតិ អាកិញ្ចញ្ញាយតនសមាបត្តិ ។

មានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា មានមរណៈជាធម្មតា មានសោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈជាធម្មតា ជារបស់មានធម៌ជាគ្រឿងប្រជុំកើត ជាធម្មតា ជារបស់ដល់នូវការវិនាស ជាធម្មតា ជារបស់មិនមានអានិសង្ស ជារបស់មានទោស មិនជាទីរលាស់ចេញជាធម្មតា ។ ពាក្យថា មានស្មារតី សេចក្ដីថា ស្មារតី ការរឭករឿយៗ ការរឭកចំពោះ ។ បេ ។ ការរឭកប្រពៃ ណា នេះ ហៅថា ស្មារតី ។ បុគ្គលណាដល់ ដល់ព្រម ចូលទៅដល់ ចូលទៅដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ប្រកបហើយដោយស្មារតីនេះ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកចូរមានស្មារតី សម្ដឹងអាកិ-ញ្ចញ្ញាយតនជ្ឌាន ។ ពាក្យថា ម្នាលឧបសីវៈ នៃបទថា ព្រះមានព្រះភាគ ត្រាស់ថា ម្នាលឧបសីវៈ គឺព្រះមានព្រះភាគ ហៅព្រាហ្មណ៍នោះ ដោយចំឈ្មោះ ។ ពាក្យថាព្រះមានព្រះភាគ នេះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្ដថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យច្បាស់លាស់ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ។

[២៤ថ] ពាក្យថា អាស្រ័យ (អាកិញ្ចញ្ញាយតនសមាបត្ដិ) ដោយបរិកម្មថាមិនមាន ។ ហើយធ្វើអនុវត្ដ ចុះ បានដល់ គឺអាកិញ្ចញ្ញាយតន-សមាបត្ដិ ដោយបរិកម្មថា វត្ថុតិចតួចមិនមាន ។ ចុះ អាកិញ្ចញ្ញាយ-តនសមាបត្ដិ ដោយបរិកម្មថា វត្ថុតិចតួចមិនមាន តើព្រោះហេតុអ្វី ។

វិញ្ញាណញ្ចាយតនសមាបត្តី សតោ សមាបជ្ជិត្វា តតោ វុដ្ឋហិត្វា តញ្ញេវ វិញ្ញាណំ អភាវេតិ វិភាវេតិ អន្តរ-ធាបេតិ នត្ថិ កិញ្ចីតិ បស្សតិ តំការណា នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនសមាបត្តិ ។ តំ និស្សាយ ឧបនិ-ស្សាយ អារម្មណំ អាលម្ពណំ ករិត្វា កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ តរស្សុ ឧត្តរស្សុ ប-តរស្សុ សមតិក្កមស្សុ វីតិវត្តស្សូតិ នត្ថីតិ និស្សា-យ តរស្សុ ឱឃំ ។

[២៤៦] កាមេ បហាយ វិរតោ កថាហីតិ កា-មេតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេ-សកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ កាមេ បហាយាតិ វត្ថុកាមេ បរិជានិត្វា កិលេសកាមេ បហាយ បជហិ-ត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ កាមេ ប-ហាយ ។ វិរតោ កថាហីតិ កថង្កថា វុច្ចតិ វិចិកិច្ឆា ។

បុគ្គលមានស្មារតី ចូលវិញ្ញាណញ្ចាយតនសមាបត្តិ ចេញអំពីសមាបត្តិ នោះហើយ មិនចម្រើន មិនអប់រំ ធ្វើឲ្យវិនាស នូវវិញ្ញាណនោះឯង ទើបឃើញថា វត្ថុតិចតួចមិនមាន ព្រោះហេតុនោះ អាកិញ្ចញ្ញាយតន-សមាបត្តិ ដោយបរិកម្មថា វត្ថុតិចតួចមិនមាន ។ អ្នកចូរអាស្រ័យ អាស្រ័យស៊ប់នូវអាកិញ្ចញ្ញាយតនសមាបត្តិនោះ ហើយធ្វើឲ្យជាអារម្មណ៍ ឲ្យជាទីតោង ហើយធ្វង ធ្វងឡើង ធ្វងរំលង ធ្វងកាត់ ផ្ទោះរំលង នូវអន្ទង់គឺកាម អន្ទង់គឺភព អន្ទង់គឺទិដ្ឋិ អន្ទង់គឺអវិជ្ជា ហេតុនោះ (ទ្រង់ត្រាស់ថា) អាស្រ័យ (អាកិញ្ចញ្ញាយតនសមាបត្តិ) ដោយបរិកម្មថា មិនមានៗ ហើយធ្វងអន្ទង់ចុះ ។

[២៨៦] *អធិប្បាយពាក្យថា អ្នកចូរលះបង់កាមទាំងឡាយ ហើយ រៀរចាកកថាទាំងឡាយចេញ បើតាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ នេះ លោកហៅថា វត្ថុកាម ។ បេ ។ នេះ លោកហៅថា កិលេសកាម ។ ពាក្យថា អ្នកចូរលះបង់កាមទាំងឡាយ គឺអ្នកចូរកំណត់ដឹងវត្ថុកាម ហើយលះបង់ បោះបង់ បន្ទោបង់ ធ្វើឲ្យ វិនាស ធ្វើមិនឲ្យមានបែបភាពតទៅ នូវកិលេសកាមទាំងឡាយ ហេតុ នោះ (ទ្រង់ត្រាស់ថា) អ្នកចូរលះបង់កាមទាំងឡាយ ។ ពាក្យថា រៀរ ចាកកថាទាំងឡាយ សេចក្ដីថា វិចិកិច្ឆា លោកហៅថា កថង្ក្ដថា ។*

ជុក្ខេ ភជ្ជា ។ បេ ។ ឆម្ភិតត្តំ ចិត្តស្ស មនោវិលេខោ ។ ភជន្តីតាយ អារតោ វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្ប្រមុត្តោ វិសំយុត្តោ វិមរិយាទីភូតេន ចេតសា វិហរតីតិ ឯវម្ៀ វិរតោ ភជាហិ ។ អថវា ទ្វត្តឹសាយ តិរច្ឆានកថាយ អារតោ វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្ប្រមុត្តោ វិសំយុត្តោ វិមរិយា-ទីភូតេន ចេតសា វិហរតីតិ ឯវម្ៀ វិរតោ ភជាហីតិ ភាមេ បហាយ វិរតោ ភជាហិ ។

[២៤៧] តណ្ហាក្ខយំ រត្តមហាភិបស្សាតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្ព-តណ្ហា ធម្មតណ្ហា ។ រត្តន្តិ រត្តិ ។ អហោតិ ជិវសោ ។ រត្តិញ្ច ជិវ ច តណ្ហាក្ខយំ ភាគក្ខយំ ផោសក្ខយំ មោ-ហក្ខយំ ភតិក្ខយំ ឧបបត្តិក្ខយំ បដិសន្ធិក្ខយំ ភវ-ក្ខយំ សំសារក្ខយំ វដ្ដក្ខយំ បស្ស អភិបស្ស ឧក្ខ ឱលោភយ ជិជ្ឈាយ ឧបបរិក្ខាតិ តណ្ហាក្ខយំ រត្តម-ហាភិបស្ស ។ ភេជ្ជាហ ភតវា

សេចក្ដីធ្ងៃ១ធ្ងល់ក្នុងទុក្ខ ។ បេ ។ ភាពនៃចិត្តញាប់ញ័រ ការរសេម រសាមនៃចិត្ត ។ បុគ្គលវៀរ វៀរស្រឡះ លះបង់ ចេញផុត លះលែង រួចស្រឡះ ប្រាសចេញចាកសេចក្ដីសង្ស័យ ជាអ្នកមានចិត្តមិនសល់រ៉ាល់ បុគ្គលវៀរចាកកថាទាំងឡាយ ដោយប្រការដូច្នេះ ក៏បាន ។ មួយទៀត បុគ្គលវៀរ វៀរស្រឡះ លះបង់ ចេញផុត លះលែង រួចស្រឡះ ប្រាស ចេញចាកតិរច្ឆានកថា ៣២ ជាបុគ្គលមានចិត្តមិនសល់រ៉ាល់ បុគ្គលវៀរចាក កថាទាំងឡាយ ដោយប្រការដូច្នេះ ក៏បាន ហេតុដូច្នោះ (ទ្រង់ត្រាស់ថា) អ្នកចូរលះបង់កាមទាំងឡាយ ហើយវៀរចាកកថាទាំងឡាយចេញ ។

[២៨៧] *អធិប្បាយពាក្យថា សម្ងឹងនូវការអស់តណ្ហាទាំងយប់ទាំងថ្ងៃ ត្រង់ពាក្យថា តណ្ហា គឺរូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា យប់ គឺរាត្រី ។ ពាក្យថា ថ្ងៃ គឺ វេលាដែលមានពន្លឺព្រះអាទិត្យប្រាកដ ។ អ្នកចូរមើល មើលចំពោះ ចូរឃើញ ចូរមិលមើល ចូរសម្ងឹងមើល ចូរពិចារណា នូវការអស់តណ្ហា ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ការអស់គតិ នូវការអស់ ឧបបត្តិ ការអស់បដិសន្ធិ ការអស់ភព ការអស់សង្សារ ការអស់វដ្ដៈ ទាំងយប់ទាំងថ្ងៃ ហេតុនោះ (ទ្រង់ត្រាស់ថា) សម្ងឹង នូវការអស់ តណ្ហា ទាំងយប់ទាំងថ្ងៃ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា*

អាកិញ្ចញ្ញំ បេក្ខមានោ សតិមា
(ឧបសីវាតិ ភគវា)
នត្ថីតិ និស្សាយ តរស្សុ ឱឃំ
កាមេ បហាយ វិរតោ កថាហិ
តណ្ហក្ខយំ រត្តមហាភិបស្សាតិ ។

[២៤៨] សព្វេសុ កាមេសុ យោ វីតរាគោ
(ឥច្චាយស្មា ឧបសីវោ)
អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញំ
សញ្ញាវិមោក្ខេ បរមេធិមុត្តោ[១]
តិដ្ឋេ នុ សោ តត្ថ អនានុយាយី ។

[២៤៩] សព្វេសុ កាមេសុ យោ វីតរាគោតិ សព្វេសូតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ សព្វេសូតិ ។ កាមេសូតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។

១ ឱ. វិមុត្តោ ។

(ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវ:) អ្នកចូរមានស្មារតីសម្ងឹងអាកិញ្ចញ្ញាយតនជ្ឌាន អាស្ត្រយអាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា មិនមានៗ ហើយធ្ងងអន្ទង់ចុះ អ្នកចូរលះបង់កាមទាំងឡាយ ហើយវៀរចាកកថាទាំងឡាយចេញ ហើយសម្ងឹងនូវការអស់តណ្ហា ទាំងយប់ទាំងថ្ងៃ ។

[២៨៨] (ឧបសីវ: មាណព មានអាយុ ទូលសួរដូច្នេះថា) បុគ្គលណាមិនមានតម្រេក ក្នុងកាមទាំងឡាយទាំងពួង លះបង់សមាបត្តិដទៃ អាស្ត្រយអាកិញ្ចញ្ញាយតនជ្ឌាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ បុគ្គលនោះ ជាអ្នកមិនឃ្លាតគប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឌាន បានដែរឬទេ ។

[២៨៩] អធិប្បាយពាក្យថា បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង ត្រង់ពាក្យថា ទាំងពួង គឺសព្វទាំងអស់ គ្រប់ទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ទាំងពួង នេះជាពាក្យរួបរួម ។ ពាក្យថា ក្នុងកាមទាំងឡាយ បើតាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ នេះហៅថា វត្ថុកាម ។ បេ ។ នេះហៅថា កិលេសកាម ។

ឧបសីវមាណវកប្បញ្ហានិទ្ទេសោ

សព្វេសុ កាមេសុ យោ វីតរាគោតិ សព្វេសុ កាមេសុ យោ វីតរាគោ[1] ចត្តរាគោ វន្តរាគោ មុត្តរាគោ ប-ហីនរាគោ បដិនិស្សដ្ឋរាគោ វិក្ខម្ភិតរាគោតិ សព្វេ-សុ កាមេសុ យោ វីតរាគោ ។ ឥច្ចាយស្មា ឧ-បសីវោតិ ឥច្ចាតិ បទសន្ធិ ។ អាយស្មាតិ បិយវ-ចនំ ។ ឧបសីវោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាចោតិ ឥច្ចាយស្មា ឧបសីវោ ។

[២៥០] អាកិញ្ចញ្ញំ និស្សិតោ ហិ តូមញ្ញន្តិ ហេ-ដ្ឋិមា ឆ សមាបត្តិយោ ហិ ត្វា វជ្ជេត្វា[2] បរិចូជិត្វា អតិក្កមិត្វា សមតិក្កមិត្វា វីតិវត្តិត្វា អាកិញ្ចញ្ញាយ-តនសមាបត្តឹ និស្សិតោ អល្លីនោ ឧចាតតោ សមុ-ចាតតោ អជ្ឌោសិតោ អធិមុត្តោតិ អាកិញ្ចញ្ញំ និ-ស្សិតោ ហិ តូមញ្ញ ។

[២៥១] សញ្ញាវិមោក្ខេ បរមេ ធិមុត្តោតិ សញ្ញា-វិមោក្ខា រុច្ចន្តិ សត្ត សញ្ញាសមាបត្តិយោ ។

---

១ ម. វិគតរាគោ ។ ២ ម. ចជិត្វា ។

ពាក្យថា បុគ្គលណា មិនមានតម្រេក ក្នុងកាមទាំងឡាយទាំងពួង មានន័យថា បុគ្គលណា មិនមានរាគៈ ខ្ជាក់រាគៈ ខ្ជាក់ចោលរាគៈ ផុតរាគៈ លះបង់រាគៈ លះបង់ផ្តាច់រាគៈ សង្កត់សង្កិនរាគៈ ក្នុងកាមទាំងឡាយទាំងពួង ហេតុនោះ (លោកសួរថា) បុគ្គលណា មិនមានតម្រេក ក្នុងកាមទាំងឡាយទាំងពួង ។ ពាក្យថា ដូច្នេះ នៃបទថា ឧបសីវៈមានអាយុសួរដូច្នេះ ជាពាក្យតភ្ជាប់ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា ឧបសីវៈ ជាឈ្មោះនៃព្រាហ្មណ៍នោះ ។ បេ ។ ជាពាក្យហៅព្រាហ្មណ៍ន៏ុះ ហេតុនោះ (មានពាក្យថា) ឧបសីវៈមានអាយុសួរដូច្នេះ ។

[២៥០] *ពាក្យថា លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន គឺលះបង់ រៀរបង់ ចោះបង់ កន្ទងបង់ កន្ទងរំលង ប្រព្រឹត្តកន្ទង នូវសមាបត្តិទាំង ៦ ឲ្យដ៏ខាងក្រោម ហើយអាស្រ័យ ផ្ដេកផ្ដិត ចូលមកជិត ចូលមកជិតព្រម មានចិត្តឱនចុះ មានចិត្តឱនចុះ ស៊ប់ កាន់អាកិញ្ចញ្ញាយតនសមាបត្តិ ហេតុនោះ (លោកសួរថា) លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ។*

[២៥១] *ពាក្យថា ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ សេចក្ដីថា សញ្ញាសមាបត្តិ ទាំង ៧ លោកហៅថា សញ្ញាវិមោក្ខ ។*

តាសំ សញ្ញាសមាបត្តីនំ អាកិញ្ចញ្ញាយតនសមាបត្តិ
វិមោក្ខា អត្ថ ច សេដ្ឋា ច វិសេដ្ឋា ច ចាមោក្ខា
ច ឧត្តមា ច បវរា ច ។ បរមេ អត្ថេ សេដ្ឋេ វិសេដ្ឋេ
ចាមោក្ខេ ឧត្តមេ បវរេ អធិមុត្តវិមោក្ខេន អធិមុត្តោ
តត្រាធិមុត្តោ តទធិមុត្តោ តច្ចរិតោ តព្ភហុលោ
តគ្គរុកោ តន្និន្នោ តប្ផោណោ តប្ភញ្ភារោ ត-
ជ្ជាធិបតេយ្យោតិ[1] សញ្ញាវិមោក្ខេ បរមេធិមុត្តោ ។

[២៥២] តិដ្ឋេ ជុ សោ តត្ត អជ្ជាជុយាយីតិ[2] តិដ្ឋេ
ជូតិ សំសយបុច្ឆា[3] ទ្វេជ្ឈ្ឌកបុច្ឆា អនេកំសបុច្ឆា
ឯវំ ជុ ខោ ន ជុ ខោ ឥ ជុ ខោ ឥ ជ ជុ
ខោតិ តិដ្ឋេ ជុ ។ តត្ថាតិ អាកិញ្ចញ្ញាយតនេ ។
អជ្ជាជុយាយីតិ អជ្ជាជុយាយី អវេជ្ជមានោ អវិតច្ច-
មានោ អនន្តរជ្ជាយមានោ អបរិហ្ជាយមានោ[4] ។

---

១ ម. តទធិមុត្តោ ទទធិបតេយ្យោតិ ។ ២ ម. អនានុវ្ជាយីតិ ។ ៣ ម. សំសយ-
បុច្ឆា វិមតិបុច្ឆា ។ ៤ ម. អបរិហ្ជាយមានោ ។

អាកិញ្ចញ្ញាយតនសមាបត្តិ ជាវិមោក្ខដ៏ប្រសើរផង វិសេសផង ប្រសើរ វិសេសផង ជាប្រធានផង ឧត្តមផង ថ្លៃថ្លាផង ជាងសញ្ញាសមាបត្តិទាំងនោះ ។ បុគ្គលចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ ជាកំពូល វិសេសប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ដោយអធិមុត្តវិមោក្ខ ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខនោះ មានចិត្តឱនចុះ ក្នុងសញ្ញាវិមោក្ខនោះ មានចិត្តជឿស៊ប់ក្នុងសញ្ញាវិមោក្ខនោះ ត្រាច់ទៅកាន់សញ្ញាវិមោក្ខនោះ ច្រើនដោយសញ្ញាវិមោក្ខនោះ ធ្ងន់ក្នុងសញ្ញាវិមោក្ខនោះ ឱនទៅកាន់សញ្ញា-វិមោក្ខនោះ ទោរទៅកាន់សញ្ញាវិមោក្ខនោះ ឈមទៅកាន់សញ្ញា-វិមោក្ខនោះ មានសញ្ញាវិមោក្ខនោះជាអធិបតី ហេតុនោះ (លោកសួរថា) ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខ ដ៏ប្រសើរ ។

[២៥២] *ពាក្យថា បុគ្គលនោះ ជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអា-កិញ្ចញ្ញាយតនដ្ឋានបានដែរឬទេ ត្រង់ពាក្យថា គប្បីតាំងនៅបានដែរឬទេ គឺជាពាក្យសួរដោយសង្ស័យ សួរដោយចិត្តបែកជាចំពាមពីរ សួរដោយការយល់ច្រើនយ៉ាងថា យ៉ាងនេះទេឬ។ មិនមែនទេ ដូចម្តេចហ្ន៎ ដោយប្រការដូចម្តេចហ្ន៎ ហេតុនោះ (លោកសួរថា) គប្បីតាំងនៅបានដែរឬទេ ។ ពាក្យថា ក្នុងនោះ គឺក្នុងអាកិញ្ចញ្ញាយតនៈ ។ ពាក្យថា ជាអ្នកមិនឃ្លាត គឺជាអ្នកមិនបែកចេញ មិនកម្រើក មិនប្រាស មិនវិនាស មិនសាបសូន្យ ។*

អថវា អវជ្ជមានោ អជុសុ្ឍមានោ អមុយ្ហមានោ អកិ-លិយមានោតិ តិដ្ឋេ ជុ សោ តត្ត អជានុយាយី ។ តេនាហ សោ ព្រាហ្មណោ

សព្វេសុ កាមេសុ យោ វីតរាគោ

(ឥច្ចាយស្មា ឧបសីវោ)

អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញំ

សញ្ញាវិមោក្ខេ បរមេ ឋិមុត្តោ

តិដ្ឋេ ជុ សោ តត្ត អជានុយាយីតិ ។

[២៥៣] សព្វេសុ កាមេសុ យោ វីតរាគោ

(ឧបសីវាតិ ភគវា)

អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញំ

សញ្ញាវិមោក្ខេ បរមេ ឋិមុត្តោ

តិដ្ឋេយ្យ សោ តត្ត អជានុយាយី ។

[២៥៤] សព្វេសុ កាមេសុ យោ វីតរាគោតិ សព្វេសូតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ សព្វេសូតិ ។

ឬថា ជាអ្នកមិនត្រេកអរ មិនប្រទូស្ត មិនវង្វេង មិនលំបាក ហេតុនោះ (លោកសួរថា) បុគ្គលនោះជាអ្នកមិនឃ្វាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញា-យតនជ្ឈានបានដែរឬទេ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

> បុគ្គលណាមិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ បុគ្គលនោះ ជាអ្នកមិនឃ្វាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាន បានដែរឬទេ ។

[២៥៣] (ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបសីវៈ) បុគ្គលណា មិនមានតម្រេក ក្នុងកាមទាំងឡាយទាំងពួង លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ បុគ្គលនោះជាអ្នកមិនឃ្វាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានៈនោះបាន ។

[២៥២] អធិប្បាយពាក្យថា បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង ត្រង់ពាក្យថា ទាំងពួង គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ទាំងពួង នេះ ជាពាក្យរួបរួម ។

កាមេសូតិ ឧជ្ជានតោ ទ្វេ កាមា វត្ថុកាមា ច កិ-
លេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា
។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ សព្វេសុ
កាមេសុ យោ វីតរាគោតិ សព្វេសុ កាមេសុ យោ
វីតរាគោ ចត្តរាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ
បដិនិស្សដ្ឋរាគោ វិក្ខម្ភិតរាគោតិ សព្វេសុ កាមេសុ
យោ វីតរាគោ ។ ឧបសីវតិ ភគវតិ ឧបសីវតិ
ភគវា តំ ព្រាហ្មណំ ជាមេន អាលបតិ ។ ភគវតិ
ការវាជិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ
ភគវតិ ឧបសីវតិ ភគវា ។

[២៥៥] អាកិញ្ចញ្ញំ ជិស្សិតោ ហិ ត្វមញ្ញន្តិ ហេដ្ឋិ-
មា ឆ សមាបត្តិយោ ហិត្វា រជ្ជេត្វា បរិចុជិត្វា អតិក្ក-
មិត្វា សមតិក្កមិត្វា វីតិវត្តិត្វា អាកិញ្ចញ្ញាយតនស-
មាបត្តឺ ជិស្សិតោ[1] អលូ្យនោ ឧចាតតោ សមុចាត-
តោ អជ្ឌោសិតោ អជ្ឌិមុត្តោតិ អាកិញ្ចញ្ញំ ជិស្សិ-
តោ ហិ ត្វមញ្ញ ។

---

1 ម. និស្សិតោ អាសិតោ ។

ពាក្យថា ក្នុងកាមទាំងឡាយ បើតាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ នេះ ហៅថា វត្ថុកាម ។ បេ ។ នេះហៅថា កិលេសកាម ។ ពាក្យថា បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង បានសេចក្តីថា បុគ្គលណាមិនមានរាគៈ លះរាគៈ ខ្ជាក់រាគៈ លៃងរាគៈ ចោលរាគៈ លះបង់រាគៈ សង្កត់សង្កិនរាគៈ ក្នុងកាមទាំងឡាយទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលណាមិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង ។ ពាក្យថា ម្នាលឧបសីវៈ នៃបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ គឺព្រះមានព្រះភាគទ្រង់ហៅព្រាហ្មណ៍នោះ ដោយចំឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នេះជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ។

[២៥៥] ពាក្យថា លះបង់ សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឌាន គឺលះបង់ រៀរបង់ ចោះបង់ កន្ទ្ធបង់ កន្ទ្ធរំលង ប្រព្រឹត្តកន្ទ្ធនូវសមាបត្តិទាំង ៦ ខាងក្រោម ហើយអាស្រ័យ ផ្ដេកផ្ដិត ចូលមកជិត ចូលមកជិតព្រម ឱ្យនចុះ ចុះស៊ប់កាន់អាកិញ្ចញ្ញាយតនសមាបត្តិ ហេតុនោះ (ទ្រង់ត្រាស់ថា) លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឌាន ។

ឧបសីវមាណវកប្បញ្ហានិទ្ទេសោ

[២៥៦] សញ្ញាវិមោក្ខេ បរមេ ឯមុត្តោតិ សញ្ញាវិ-
មោក្ខា រុច្ចន្តិ សត្ត សញ្ញាសមាបត្តិយោ ។ តាសំ
សញ្ញាសមាបត្តីនំ អាកិញ្ចញ្ញាយតនសមាបត្តិ វិមោ-
ក្ខា អក្តា ច សេដ្ឋា ច វិសេដ្ឋា ច ចាមោក្ខា
ច ឧត្តមា ច បវរា ច ។ បរមេ អក្តេ សេដ្ឋេ
វិសេដ្ឋេ ចាមោក្ខេ ឧត្តមេ បវរេ អធិមុត្តវិមោក្ខេន
អធិមុត្តោ តត្រាធិមុត្តោ តទធិមុត្តោ តច្ចរិតោ តព្ភ-
ហុលោ តក្ករុកោ តន្និន្នោ តប្ភោណោ តប្ឆ្ភារោ
តជាធិបតេយ្យោតិ សញ្ញាវិមោក្ខេ បរមេ ឯមុត្តោ ។

[២៥៧] តិដ្ឋេយ្យ សោ តត្ត អជានុយាយីតិ
តិដ្ឋេយ្យាតិ តិដ្ឋេយ្យ សដ្ឋីកប្បសហស្សានិ ។
តត្ថាតិ អាកិញ្ចញ្ញាយតនេ ។ អជានុយាយីតិ
អជានុយាយី អវេជមានោ អវិតច្ឆមានោ[1] អនន្តរ-
ជាយមានោ អបរិហាយមានោ ។ អថវា អវជ្ជមា-
នោ អឧុស្សមានោ អមុយ្ហមានោ អកិលិយមានោតិ

---

១ ម. អធិគច្ឆមានោ ។

ឧបសីវមាណវកប្បញ្ហានិទ្ទេស

[២៥៦] *ពាក្យថា ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ សេចក្តីថា សញ្ញាសមាបត្តិទាំង ៧ ហៅថា សញ្ញាវិមោក្ខ ។ អាកិញ្ចញ្ញាយតនសមាបត្តិ ជាវិមោក្ខដ៏ប្រសើរផង វិសេសផង ប្រសើរវិសេសផង ជាប្រធានផង ឧត្តមផង ថ្លៃថ្នូផង ជាងសញ្ញាសមាបត្តិទាំងនោះ ។ បុគ្គលចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ ជាកំពូល វិសេស ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្នូ ដោយអធិមុត្តវិមោក្ខ មានចិត្តឱនចុះក្នុងសញ្ញាវិមោក្ខនោះ ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខនោះ ត្រាច់ទៅកាន់សញ្ញាវិមោក្ខនោះ ច្រើនដោយសញ្ញាវិមោក្ខនោះ ធ្ងន់ក្នុងសញ្ញាវិមោក្ខនោះ ឱនទៅកាន់សញ្ញាវិមោក្ខនោះ ទោរទៅកាន់សញ្ញាវិមោក្ខនោះ ឈមទៅកាន់សញ្ញាវិមោក្ខនោះ មានសញ្ញាវិមោក្ខនោះជាអធិបតី ហេតុនោះ (ទ្រង់ត្រាស់ថា) ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ ។*

[២៥៧] *ពាក្យថា បុគ្គលនោះ ជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានៈ ត្រង់ពាក្យថា គប្បីតាំងនៅ គឺគប្បីតាំងនៅអស់ពាន់នៃកប្ប ៦០ ។ ពាក្យថា ក្នុងអាកិញ្ចញ្ញាយតនជ្ឈាន គឺក្នុងអាកិញ្ចញ្ញាយតនៈ ។ ពាក្យថា ជាអ្នកមិនឃ្លាត គឺជាអ្នកមិនបោះបង់ មិនកម្រើក មិនទៅប្រាស មិនវិនាស មិនសាបសូន្យ ។ ឬថា មិនត្រេកអរ មិនប្រទូស្ត មិនរង្វើង មិនលំបាក*

តិដ្ឋេយ្យ សោ តត្ថ អនានុយាយី ។ តេនាហ ភគវា

សព្វេសុ កាមេសុ យោ វីតរាគោ

(ឧបសីវាតិ ភគវា)

អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញំ

សញ្ញាវិមោក្ខេ បរមេធិមុត្តោ

តិដ្ឋេយ្យ សោ តត្ថ អនានុយាយីតិ ។

[២៤៨] តិដ្ឋេ ចេ សោ តត្ថ អនានុយាយី

បូគម្បិ វស្សានំ[១] សមន្តចក្ខុ

តត្ថេវ សោ សីតិ សិយា វិមុត្តោ

ភវេថ[២] វិញ្ញាណំ តថាវិធស្ស ។

[២៤៩] តិដ្ឋេ ចេ សោ តត្ថ អនានុយាយីតិ តិដ្ឋេ ចេ សោតិ សចេ សោ តិដ្ឋេយ្យ សដ្ឋីកប្បសហស្សានិ ។ តត្ថាតិ អាកិញ្ចញ្ញាយតនេ ។

១ ម. វស្សានិ ។ ២ ម. ចវេថ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានៈ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ) បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឧ្ចាយទាំងពួង លះបង់សមាបត្តិ ដ ទ ៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ បុគ្គលនោះជាអ្នកមិនឃ្លាត គប្បីតាំងនៅ ក្នុងអាកិញ្ចញ្ញាយតនជ្ឈានៈ ។

[២៥៨] (ឧបសីវមាណពទូលសួរថា) បពិត្រព្រះអង្គជាសមន្តចក្ខុ បើបុគ្គលនោះជាអ្នកសាបសូន្យ គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានៈ សូម្បីអស់គំនរនៃឆ្នាំទាំងឧ្ចាយ បុគ្គលនោះ គប្បីជាអ្នកត្រជាក់ រួចស្រឡះ ក្នុងអាកិញ្ចញ្ញាយតនជ្ឈានៈ ឯ ង ចុះ វ ិ ញ្ ញ ា ណ របស់បុគ្គលមានសភាពដូច្នោះ ត្រូវកើតទៀតឬ ទ េ ។

[២៥៩] ពាក្យថា បើបុគ្គលនោះ ជាអ្នកមិនសាបសូន្យ គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានៈ ត្រង់ពាក្យថា បើបុគ្គលនោះ គប្បីតាំងនៅ គឺ ប្រសិនបើបុគ្គលនោះ គប្បីតាំងនៅ អស់ពាន់នៃកប្ប ៦០ ។ ពាក្យថា ក្នុងនោះ គឺក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ។

អជានុយាយីតិ អជានុយាយី អវេជមានោ អវិកប្បមានោ អនន្តរជាយមានោ អបរិហិយមានោ អថវា អវជ្ជមានោ អខុស្សមានោ អមុយ្ហមានោ អកិលិយមានោតិ តិដ្ឋេ ចេ សោ តត្ថ អជានុយាយី ។

[២៦០] បូគម្បិ វស្សានំ សមន្តចក្ខូតិ បូគម្បិ វស្សានន្តិ បូគម្បិ វស្សានំ[១] ពហូនំ វស្សានំ ពហូនំ វស្សសតានំ ពហូនំ វស្សសហស្សានំ ពហូនំ វស្សសតសហស្សានំ ពហូនំ កប្បសតានំ ពហូនំ កប្បសហស្សានំ ពហូនំ កប្បសតសហស្សានំ ។ សមន្តចក្ខូតិ សមន្តចក្ខុ វុច្ចតិ សព្វញ្ញុតញ្ញាណំ ។ បេ ។ តថាគតោ តេន សមន្តចក្ខូតិ បូគម្បិ វស្សានំ សមន្តចក្ខុ ។

[២៦១] តត្ថេវ សោ សីតិ សិយា វិមុត្តោ ភវេថ វិញ្ញាណំ តថាវិធស្សាតិ តត្ថេវ សោ សីតិភាវមនុប្បត្តោ ធុវោ[២] សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តត្ថេវ តិដ្ឋេយ្យ អថវា

១ ម. វស្សានិ ពហូនិ វស្សានិ ពហូនិ ។ បេ ។ កប្បសតសហស្សានិ ។ ២ ម. និច្ចោ ធុវោ។

ពាក្យថា ជាអ្នកមិនសាបសូន្យ គឺជាអ្នកមិនឃ្លាត មិនកម្រើក មិនទៅប្រាស មិនវិនាស មិនសាបសូន្យ ឬថា ជាអ្នកមិនក្រេកអរ មិនប្រទូស្ត មិនរង្វេង មិនលំបាក ហេតុនោះ (លោកសួរថា) បើបុគ្គលនោះ ជាអ្នកមិនសាបសូន្យ គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឌានៈ ។

[២៦០] *ពាក្យថា បពិត្រព្រះអង្គជាសមន្តចក្ខុ ... សូម្បីអស់គំនរនៃឆ្នាំទាំងឡាយ ត្រង់ពាក្យថា សូម្បីអស់គំនរនៃឆ្នាំទាំងឡាយ គឺសូម្បីអស់ពួកនៃឆ្នាំទាំងឡាយ នៃឆ្នាំដ៏ច្រើន នៃរយឆ្នាំដ៏ច្រើន នៃពាន់ឆ្នាំដ៏ច្រើន នៃសែនឆ្នាំដ៏ច្រើន នៃរយកប្ជដ៏ច្រើន នៃពាន់កប្ជដ៏ច្រើន នៃសែនកប្ជដ៏ច្រើន ។ ពាក្យថា បពិត្រព្រះអង្គជាសមន្តចក្ខុ សេចក្តីថា សព្វញ្ញុតញ្ញាណ ហៅថា សមន្តចក្ខុ ។ បេ ។ ព្រះតថាគត ព្រះនាមថា សមន្តចក្ខុ ដោយហេតុនោះ ហេតុនោះ (លោកសួរថា) បពិត្រព្រះអង្គជាសមន្តចក្ខុ... សូម្បីអស់គំនរនៃឆ្នាំទាំងឡាយ ។*

[២៦១] *ពាក្យថា បុគ្គលនោះ គប្បីជាអ្នកត្រជាក់ រួចស្រឡះ ក្នុងអាកិញ្ចញ្ញាយតនជ្ឌានៈឯង ចុះវិញ្ញាណរបស់បុគ្គលមានសភាពដូច្នោះ ត្រូវកើតទៀតឬទេ គឺ ព្រះឧបសីវ: សួរនូវការទៀងទាត់ផង ការដាច់សូន្យផង របស់បុគ្គល ដែលកើតហើយក្នុងអាកិញ្ចញ្ញាយតន: ថា បុគ្គលនោះ ដល់នូវភាពជាអ្នកត្រជាក់ ក្នុងអាកិញ្ចញ្ញ:នោះឯង ជាបុគ្គលទៀង ឬតថេរ មិនប្រែប្រួលជាធម្មតា គប្បីនៅក្នុងអាកិញ្ចញ្ញ:*

តស្ស វិញ្ញាណំ ចវេយ្យ ឧច្ឆិជ្ជេយ្យ វិនស្សេយ្យ ន ភវេយ្យ ន បដិសន្ធិវិញ្ញាណំ និព្វត្តេយ្យ កាមធាតុយា វា រូបធាតុយា វា អរូបធាតុយា វាតិ អាកិញ្ចញ្ញាយតនេ ឧប្បន្នស្ស សស្សតញ្ច ឧច្ឆេទញ្ច បុច្ឆតិ ឧទាហុ តត្ថេវ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយេយ្យ អថវា តស្ស វិញ្ញាណំ ចវេយ្យ បុន បដិសន្ធិវិញ្ញាណំ និព្វត្តេយ្យ កាមធាតុយា វា រូបធាតុយា វា អរូបធាតុយា វាតិ អាកិញ្ចញ្ញាយតនេ ឧប្បន្នស្ស បរិនិព្វានញ្ច បដិសន្ធិញ្ច បុច្ឆតិ ។ តថាវិធស្សាតិ តថាវិធស្ស តាទិសស្ស តស្សណ្ឋិតស្ស តប្បការស្ស តប្បដិភាគស្ស អាកិញ្ចញ្ញាយតនេ ឧប្បន្នស្សាតិ តត្ថេវ សោ សីតិ សិយា វិមុត្តោ ភវេថ វិញ្ញាណំ តថាវិធស្ស ។ តេនាហ សោ ព្រាហ្មណោ

តិដ្ឋេ ចេ សោ តត្ថ អនានុយាយី
បូគម្បិ វស្សានំ សមន្តចក្ខុ
តត្ថេវ សោ សីតិ សិយា វិមុត្តោ
ភវេថ វិញ្ញាណំ តថាវិធស្សាតិ ។

នោះឯង ស្មើដោយសស្សតិវត្ត ឬថា វិញ្ញាណរបស់បុគ្គលនោះ គប្បីឃ្វាត ដាច់សូន្យ វិនាស មិនគប្បីកើត គឺបដិសន្ធិវិញ្ញាណ មិនគប្បីកើតក្នុងកាមធាតុក្តី ក្នុងរូបធាតុក្តី ក្នុងអរូបធាតុក្តី មួយទៀត លោកសួរនូវបរិនិព្វានផង បដិសន្ធិផង របស់បុគ្គលដែលកើតហើយក្នុងអាកិញ្ចញ្ញា-យតនៈថា (បុគ្គលនោះ) គប្បីបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងអាកិញ្ចញ្ញាយតនៈនោះឯង ឬថា វិញ្ញាណរបស់បុគ្គលនោះ គប្បីឃ្វាត គឺបដិសន្ធិវិញ្ញាណ គប្បីកើតទៀត ក្នុងកាមធាតុក្តី ក្នុងរូបធាតុក្តី ក្នុងអរូបធាតុក្តី ។ ពាក្យថា របស់បុគ្គល មានសភាពដូច្នោះ គឺរបស់បុគ្គល មានសភាពបែបនោះ ប្រហែលដូច្នោះ ទ្រង់ទ្រាយដូច្នោះ មានប្រការដូច្នោះ មានចំណែកប្រៀបដូច្នោះ កើតហើយក្នុងអាកិញ្ចញ្ញាយតនៈ ហេតុនោះ (លោកសួរថា) បុគ្គលនោះ គប្បីជាអ្នកត្រជាក់ រួចស្រឡះក្នុងអាកិញ្ចញ្ញាយតនជ្ឈានឯង ចុះវិញ្ញាណរបស់បុគ្គល មានសភាពដូច្នោះ គប្បីកើតទៀតឬទេ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

> *បពិត្រព្រះអង្គជាសមន្តចក្ខុ បើបុគ្គលនោះ ជាអ្នកមិនសាបសូន្យ គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានឯង សូម្បីអស់គំនរនៃឆ្នាំទាំងឡាយ បុគ្គលនោះ គប្បីជាអ្នកត្រជាក់ រួចស្រឡះក្នុងអាកិញ្ចញ្ញាយតនជ្ឈានឯង ចុះវិញ្ញាណរបស់បុគ្គលមានសភាពដូច្នោះ ត្រូវកើតទៀតឬទេ ។*

[២៦២] អច្ចិ យថា ភតវេតេន ទិត្តំ
(ឧបសីភាតិ ភគវា)
អត្តំ បលេតិ ន ឧបេតិ សង្ខ្លំ
ឯវំ មុនិ ជាមតាយ វិមុត្តោ
អត្តំ បលេតិ ន ឧបេតិ សង្ខ្លំ ។

[២៦៣] អច្ចិ យថា ភតវេតេន ទិត្តន្តិ អច្ចិ រុច្ចតិ ជាលសិខា ។ ភតាតិ បុរត្ថិមា ភតា បច្ឆិមា ភតា ឧត្តរា ភតា ទក្ខិណា ភតា សរជា ភតា អបរ-ជា ភតា សីតា ភតា ឧណ្ហា ភតា អធិមត្តា[1] ភតា វេរម្ភភតា បក្ខភតា សុបណ្ណភតា តាលបណ្ណភ-តា ទ្រីឃបនភតា ។ ភតវេតេន ទិត្តន្តិ ភតវេតេន ទិត្តំ ឧក្ខិត្តំ ឧជ្ជុ បឧជ្ជុ ទ្ធម្ភិតំ ទ្ធក្ខម្ភិតន្តិ[2] អច្ចិ យថា ភតវេតេន ទិត្តំ ។ ឧបសីភាតិ ភគវាតិ ឧបសីភាតិ ភគវា តំ ព្រាហ្មណំ ជាមេន អាលបតិ ។

---

១ ម. បរិត្តា ភតា ភាលភតា ។ ២ ម. ខិត្តា ឧក្ខិត្តា ឧជ្ជុ ឧជ្ជុ ខម្ភិតា ទ្ធខម្ភិតាតិ ។

ឧបសីវមាណវកប្បញ្ហានិទ្ទេស

ន ចលតិ ន វេធតិ ន បវេធតិ ន សម្ផវេធតិ តស្មា ពុទ្ធោ អនេជោតិ ឱកញ្ជហំ តណ្ហាច្ឆិទំ អនេជំ ។ ឥច្ចាយស្មា ភទ្រាវុធោតិ ឥច្ចាតិ បទសន្ធិ ។ បេ ។ បទានុបុព្ពកមេតំ ឥច្ចាតិ ។ អាយស្មាតិ ឧបិយវចនំ ករុវចនំ សការវសប្ផតិសញ្ជាជិវចនមេតំ អាយស្មាតិ ។ ភទ្រាវុធោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អកិលាចោតិ ឥច្ចាយស្មា ភទ្រាវុធោ ។

[៤១១] ជន្ធិញ្ជហំ ឱឃតិណ្ណោ វិមុត្តន្តិ ជន្ធិ រុច្ចតិ តណ្ហា យោ ភគោ សាភគោ ។ បេ ។ អភិជ្ឌា លោភោ អកុសលមូលំ ។ សា ជន្ធិ តណ្ហា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវ-ត្ថុកតា អនភាវង្គតា អាយតឺអនុប្ផាទធម្មា តស្មា ពុទ្ធោ ជន្ធិញ្ជហោ ។ ឱឃតិណ្ណោន្តិ ភគវា កាមោ-ឃំ តិណ្ណោ ភវោឃំ តិណ្ណោ ទិដ្ឋោឃំ តិណ្ណោ អវិជ្ជោឃំ តិណ្ណោ សព្ពំ សំសារបថំ តិណ្ណោ ឧត្ត-ណ្ណោ ជិតិណ្ណោ អតិក្កន្តោ សមតិក្កន្តោ វីតិវត្តោ សោ រុជ្ជវាសោ ចិណ្ណចរណោ ។ បេ ។

ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានការញាប់ញ័រ ហេតុនោះ (លោកពោលថា) ព្រះអង្គលះបង់លំនៅ កាត់បង់តណ្ហា មិនមានការញាប់ញ័រ ។ ពាក្យថា ដូច្នេះ របស់បទថា ភទ្រាវុធមានអាយុ ពោលដូច្នេះ ជាពាក្យតបទ ។ បេ ។ ពាក្យថា ដូច្នេះ ន ុ ំ ជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុ ន ុ ំ ជាពាក្យពោលដោយគោរព ក្រោតក្រែង ។ ពាក្យថា ភទ្រាវុធ ជាឈ្មោះ ។ បេ ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ (មានពាក្យថា) ភទ្រាវុធមានអាយុ ពោលដូច្នេះ ។

[៦១១] ពាក្យថា លះបង់សេចក្តីត្រេកអរ ធ្វង់អន្ទង់ មានព្រះទ័យរួចស្រឡះ អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីត្រេកអរ បានដល់ភគ: ភគ:មានកម្លាំង ។ បេ ។ អកិញ្ចា លោក: អកុសលមូល ។ សេចក្តីត្រេកអរ គឺតណ្ហានោះ ព្រះពុទ្ធមានព្រះភាគ លះបង់ផ្តាច់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព មិនឲ្យកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធទើបឈ្មោះថា លះបង់សេចក្តីត្រេកអរ ។ ពាក្យថា ធ្វង់អន្ទង់ គឺព្រះមានព្រះភាគ ទ្រង់ធ្វង់កាមោយ: ធ្វង់ភវោយ: ធ្វង់ទិដ្ឋោយ: ធ្វង់អវិជ្ជោយ: ធ្វង់ ធ្វង់ឡើង ធ្វង់កាត់ កន្ទង់ ឈានរំលង ផ្ទោះរំលង ទ្ទូរផ្ទូរគឺសង្ខារទាំងអស់ ព្រះអង្គមានការអប់រំនៅហើយ មានចរណ:ប្រព្រឹត្តហើយ ។ បេ ។

ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ នន្ទិ-
ញ្ជហំ ឱឃតិណ្ណំ ។ វិមុត្តន្តិ ភគវតោ រាគា ចិត្តំ
មុត្តំ វិមុត្តំ សុវិមុត្តំ ទោសា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ
មោហា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ កោធា ឧបនាហា
។ បេ ។ សព្វាកុសលាភិសង្ខារេហិ ចិត្តំ មុត្តំ
វិមុត្តំ សុវិមុត្តន្តិ នន្ទិញ្ជហំ ឱឃតិណ្ណំ វិមុត្តំ ។

[៤១២] កប្បញ្ជហំ អភិយាចេ សុមេធន្តិ កប្បាតិ ទ្វេ
កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច ។ បេ ។
អយំ តណ្ហាកប្បោ ។ បេ ។ អយំ ទិដ្ឋិកប្បោ ។
ពុទ្ធស្ស ភគវតោ តណ្ហាកប្បោ បហីនោ ទិដ្ឋិកប្បោ ។
បដិនិស្សដ្ឋោ តណ្ហាកប្បស្ស បហីនត្តា ទិដ្ឋិកប្ប-
ស្ស បដិនិស្សដ្ឋត្តា ពុទ្ធោ កប្បញ្ជហោ ។ អភិយា-
ចេតិ យាចាមិ អភិយាចាមិ អជ្ឈេសាមិ សាទិយាមិ
បត្ថយាមិ បិហេមិ អភិជប្បាមិ ។ សុមេធន្តិ មេ-
ធា វុច្ចតិ បញ្ញា យា បញ្ញា បជាននា ។ បេ ។

ភពថ្មី គឺជាតិ ជរា មរណៈ និងសង្ខារ នៃព្រះអង្គ មិនមានឡើយ ហេតុនោះ ទើបឈ្មោះថា ទ្រង់លះបង់សេចក្តីត្រេកអរ ធ្ងងអន្ទង់ ។ ពាក្យថា មានព្រះទ័យរួចស្រឡះ គឺព្រះហឫទ័យ របស់ព្រះមានព្រះ-ភាគ ផុត រួចស្រឡះ រួចស្រឡះដោយប្រពៃ ចាករាគៈ ព្រះហឫទ័យ ផុត រួចស្រឡះ រួចស្រឡះដោយប្រពៃ ចាកទោសៈ ព្រះហឫទ័យ ផុត រួចស្រឡះ រួចស្រឡះដោយប្រពៃ ចាកមោហៈ ព្រះហឫទ័យ ផុត រួចស្រឡះ រួចស្រឡះដោយប្រពៃ ចាកកោធៈ ឧបនាហៈ ។ បេ ។ អកុសលាភិសង្ខារ ទាំងអស់ ហេតុនោះ (លោកពោលថា) លះបង់ សេចក្តីត្រេកអរ ធ្ងងអន្ទង់ មានព្រះហឫទ័យរួចស្រឡះ ។

[៨១២] *ពាក្យថា ខ្ញុំព្រះអង្គសូមអារាធនាព្រះមានព្រះភាគ ទ្រង់ លះបង់គ្រឿងកំណត់ មានបញ្ញាល្អ ត្រង់ពាក្យថា គ្រឿងកំណត់ បានដល់ កប្ប: (គ្រឿងកំណត់) ២ គឺតណ្ហាកប្ប: ១ ទិដ្ឋិកប្ប: ១ ។ បេ ។ នេះ តណ្ហាកប្ប: ។ បេ ។ នេះ ទិដ្ឋិកប្ប: ។ ព្រះពុទ្ធមានព្រះភាគ លះបង់ តណ្ហាកប្ប: រលាស់ចោលទិដ្ឋិកប្ប: ព្រះពុទ្ធ ឈ្មោះថា លះបង់កប្ប: ព្រោះលះបង់តណ្ហាកប្ប: ព្រោះរលាស់ចោលទិដ្ឋិកប្ប: ។ ពាក្យថា សូមអារាធនា គឺ ខ្ញុំព្រះអង្គ សូមអង្វរ អារាធនា និមន្ត ត្រេកអរ ប្រាថ្នា ស្រឡាញ់ ប៉ុនប៉ង ។ ពាក្យថា មានបញ្ញាល្អ សេចក្តីថា ប្រាជ្ញា ហៅថា បញ្ញា បានដល់ ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។*

អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ ភគវា ឥមាយ មេធាយ បញ្ញាយ ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា ពុទ្ធោ សុមេធោតិ ភគ្គវ្ហាំ អភិយាចេ សុមេធំ ។

[៤១៣] សុត្វាន ជាតស្ស អបនមិស្សន្តិ ឥតោតិ ជាតស្សាតិ ជាតោ ។ ភគវា អាកុំ ន ភវោតីតិ ជាតោ ។ ន ឧប្ផតីតិ ជាតោ ។ ន អាឧប្ផតីតិ ជាតោ ។ បេ ។ ឯវំ ភគវា ន អាឧប្ផតីតិ ជាតោ ។ សុត្វាន ជាតស្ស អបនមិស្សន្តិ ឥតោតិ តុយ្ហំ វចនំ ព្យបថំ ឧេសនំ អនុសន្ធិ សុត្វា សុណិត្វា ឧគ្គហេត្វា ឧបធារយិត្វា ឧបលក្ខយិត្វា ឥតោ អបនមិស្សន្តិ វជិស្សន្តិ ឧិសាវិឧិសំ ឧមិស្សន្តីតិ[1] សុត្វាន ជាតស្ស អបនមិស្សន្តិ ឥតោ ។ ឥតោ ហ សោ ព្រាហ្មណো

1 ម. ឧក្ខមិស្សន្តិ ទិសំ ឧមិស្សន្តីតិ ។

សេចក្ដីមិនវង្វេង ការពិនិត្យធម៌ ឃើញត្រូវ ។ ព្រះមានព្រះភាគ ប្រកប ប្រកបព្រម ចូលទៅប្រកប ចូលទៅប្រកបព្រម ចូលដល់ ចូលដល់ព្រម មកដល់ព្រម ដោយបញ្ញាជាគ្រឿងកម្ចាត់នេះឯង ហេតុនោះ ព្រះពុទ្ធ ទើបឈ្មោះថា មានបញ្ញាដ៏ល្អ ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គ សូមអារាធនាព្រះអង្គ ទ្រង់លះបង់គ្រឿងកំណត់ មានបញ្ញាល្អ ។

[៤១៣] ពាក្យថា ពួកជនបានស្ដាប់ (ព្រះតម្រាស់) របស់ព្រះអង្គ ជាព្រះពុទ្ធនាគហើយ នឹងចៀសចេញអំពីទីនេះ ត្រង់ពាក្យថា នាគ គឺ (ព្រះពុទ្ធ) ទ្រង់ព្រះនាមថា ព្រះនាគ ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា នាគ ព្រោះមិនធ្វើអំពើអាក្រក់ ។ ទ្រង់ព្រះនាមថា នាគ ព្រោះមិនលុះ (អគតិ) ។ ទ្រង់ព្រះនាមថា នាគ ព្រោះមិនមក ។ បេ ។ ព្រះមានព្រះភាគ ព្រះនាមថា នាគ ព្រោះមិនមក យ៉ាងនេះឯង ។ ពាក្យថា ពួកជនស្ដាប់(ព្រះតម្រាស់) របស់ព្រះអង្គជាព្រះពុទ្ធនាគហើយ នឹងចៀសចេញអំពីទីនេះ គឺ ពួកជនស្ដាប់ ឮ ក្ងចកាន់ ចាំទុក កំណត់ទុក នូវព្រះតម្រាស់ គន្ធង់នៃវាចា ទេសនា អនុសន្ធិ របស់ព្រះអង្គហើយ នឹងចៀសចេញ នឹងគេចចេញ អំពីទីនេះ ទៅកាន់ទិសផ្សេង ។ ហេតុនោះ (លោកពោលថា) ពួកជនស្ដាប់ (ព្រះតម្រាស់) របស់ព្រះអង្គ ជាព្រះពុទ្ធនាគហើយ នឹងចៀសចេញអំពីទីនេះ ។ ហេតុនោះ ព្រាហ្មណ៍ នោះ ពោលថា

ឱកញ្ជហំ តណ្ហាច្ឆិទំ អនេជំ
(ឥច្චាយស្មា កប្បោ)
នន្ទិញ្ជហំ ឱឃតិណ្ណំ វិមុត្តំ
កប្បញ្ជហំ អភិយាចេ សុមេធំ
សុត្វាន នាគស្ស អបនមិស្សន្តិ ឥតោតិ ។

[៤១៤] នានាជនា ជនបទេហិ សង្គតា
តវ វីរ វាក្យំ អភិកង្ខមានា
តេសំ តុវំ សាធុ វិយាករោហិ
តថា ហិ តេ វិទិតោ ឯស ធម្មោ ។

[៤១៥] នានាជនា ជនបទេហិ សង្គតាតិ នានាជនាតិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ច ។ ជនបទេហិ សង្គតាតិ អង្គា ច មគធា ច កាសិយា ច កោសលា ច វជ្ជិយា ច មល្លា ច ចេតិយម្ហា ច សាគរម្ហា ច បញ្ចាលា ច អវន្តិយា ច យោនា ច កម្ពោជា ច ។ សង្គតាតិ សង្គតា សមាគតា សមោហិតា សន្និបតិតាតិ នានាជនា ជនបទេហិ សង្គតា ។

(ក្ទ្រាវុធមានអាយុ ពោលដូច្នេះថា) ខ្ញុំព្រះអង្គសូមអារាធនាព្រះមានព្រះភាគ ព្រះអង្គលះលំនៅ កាត់បង់តណ្ហា មិនមានការញាប់ញ័រ លះបង់សេចក្ដីត្រេកអរ ធ្វងអន្ទង់ មានព្រះហឫទ័យរួចស្រឡះ លះបង់គ្រឿងកំណត់ មានបញ្ញាល្អ ពួកជនបានស្ដាប់ (ព្រះតម្រាស់) របស់ព្រះអង្គ ជាព្រះពុទ្ធនាគ ហើយ នឹងចៀសចេញ អំពីទីនេះ ។

[៦១៧] បពិត្រព្រះអង្គជាវីរបុរស ពួកជនផ្សេងៗ ចេញអំពីជនបទទាំងឡាយ មកប្រជុំគ្នា ត្រូវការព្រះតម្រាស់របស់ព្រះអង្គ សូមព្រះអង្គសម្ដែងដោះប្រស្នា ដើម្បីជនទាំងនោះ ព្រោះថាធម៌ន៏ុះ ព្រះអង្គជ្រាបហើយ ដោយពិត ។

[៦១៧] *អធិប្បាយពាក្យថា ពួកជនផ្សេងៗ ចេញអំពីជនបទទាំងឡាយ មកប្រជុំគ្នា ត្រង់ពាក្យថា ពួកជនផ្សេងៗ បានដល់ ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្ស: សុទ្ទ: គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ។ ពាក្យថា ចេញអំពីជនបទទាំងឡាយ មកប្រជុំគ្នា គឺចេញអំពីជនបទ ឈ្មោះអង្ក:ផង មគធ:ផង កាសីផង កោសល:ផង វជ្ជីផង មល្ល:ផង ចេតិយ:ផង សាគរ:ផង បញ្ចាល:ផង អវន្ដិផង យោន:ផង កម្ពោជ:ផង ។ ពាក្យថា មកប្រជុំគ្នា គឺមកផ្ដុំ មកព្រមគ្នា មកស្រុះគ្នា មកជួបជុំគ្នា ហេតុនោះ(លោកពោលថា) ពួកជនផ្សេងៗ ចេញអំពីជនបទទាំងឡាយ មកប្រជុំគ្នា ។*

[៤១៦] តវ វីរ វាក្យំ អភិកង្ខមាជាតិ វីរាតិ វីរោ ។ភគវា វិរិយវាតិ វីរោ ។ បហូតិ វីរោ ។ វីសវីតិ វីរោ ។ អលមត្តោតិ វីរោ ។ បេ ។ វិគតលោមហំសោតិ វីរោ ។

វិរតោ ឥធ សព្វបាបកេហិ
និរយទុក្ខមតិច្ច វិរិយវាសោ
សោ វិរិយវា បធានវា
វីរោ តាទិ បវុច្ចតេ តថត្តាតិ ។

តវ វីរ ។ វាក្យំ អភិកង្ខមាជាតិ តុយ្ហំ វចនំ ព្យបថំ ទេសនំ អនុសដ្ឋឹ ។ អភិកង្ខមាជាតិ កង្ខមាជា អភិកង្ខមាជា ឥច្ឆមាជា សាទិយមាជា បត្ថមាជា បិហយមាជា អភិជប្បមាជាតិ តវ វីរ វាក្យំ អភិកង្ខមាជា ។

[៤១៧] តេសំ តុវំ សាធុ វិយាករោហីតិ តេសន្តិ តេសំ ខត្តិយានំ ព្រាហ្មណានំ វេស្សានំ សុទ្ទានំ គហដ្ឋានំ បព្វជិតានំ ទេវានំ មនុស្សានំ ។

ភទ្រាវុធមាណវកปุจฉานิទ្ទេស

[៤១៦] *ពាក្យថា* *បពិត្រព្រះអង្គជាវីរបុរស* (*ពួកជន*) *ត្រូវការព្រះតម្រាស់*
របស់ព្រះអង្គ *ត្រង់ពាក្យថា* *បពិត្រព្រះអង្គជាវីរបុរស* *គឺព្រះពុទ្ធជាវីរបុរស* ។
ព្រះមានព្រះភាគ *ព្រះនាមថា* *វីរបុរស* *ព្រោះទ្រង់មានព្យាយាម* ។ *ព្រះ*
នាមថា *វីរបុរស* *ព្រោះទ្រង់សម្បូណ៌ដោយគុណ* ។ *ព្រះនាមថា* *វីរបុរស*
ព្រោះទ្រង់ជាអ្នកបណ្តុះសេចក្តីព្យាយាម ។ *ព្រះនាមថាវីរបុរស* *ព្រោះទ្រង់*
អង់អាច ។ *បេ* ។ *ព្រះនាមថា* *វីរបុរស* *ព្រោះទ្រង់ប្រាសចាកការព្រឺពោម* ។

បុគ្គលណាវៀរហើយ *ចាកបាបទាំងពួង* *ក្នុងលោកនេះ* *ជាអ្នក*
មានព្យាយាមជាលំនៅ *កន្ទងនិរយទុក្ខ* *បុគ្គលនោះ* *ជាអ្នក*
មានព្យាយាម *មានសេចក្តីប្រឹងប្រែង* *មានសភាពដូច្នោះ*
លោកហៅថា *វីរបុរស* *ជាបុគ្គលមិនកម្រើក* ។

ហេតុនោះ (*លោកពោលថា*) *បពិត្រព្រះអង្គ* *ជាវីរបុរស...* *របស់*
ព្រះអង្គ ។ *ពាក្យថា* *ត្រូវការព្រះតម្រាស់* *គឺព្រះតម្រាស់* *គន្ធងនៃវាចា*
ទេសនា *អនុសន្ធិ* *របស់ព្រះអង្គ* ។ *ពាក្យថា* *ត្រូវការ* *គឺប៉ុនប៉ង* *ត្រូវការ*
ប្រាថ្នា *ត្រេកអរ* *ចង់បាន* *ស្រឡាញ់* *ជាប់ចិត្ត* *ហេតុនោះ* (*លោកពោល*
ថា) *បពិត្រព្រះអង្គជាវីរបុរស* *ពួកជនត្រូវការព្រះតម្រាស់របស់ព្រះអង្គ* ។

[*៤១៧*] *ពាក្យថា* *សូមព្រះអង្គសម្តែងដោះប្រស្នា* *ដើម្បីជនទាំងនោះ*
ត្រង់ពាក្យថា *ដើម្បីជនទាំងនោះ* *គឺដើម្បីជនទាំងនោះ* *បានដល់ក្សត្រិយ៍*
ព្រាហ្មណ៍ *វេស្ស:* *សុទ្ទ:* *គ្រហស្ថ* *បព្វជិត* *ទេវតា* *និងមនុស្ស* ។

តុវន្តិ ភតវន្តំ ភណាតិ ។ សាធុ វិយាករោហីតិ សាធុ អា-ចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បការេហីតិ[1] សាធុ វិយាករោហិ ។

[៤១៨] តថាហិ តេ វិនិតោ ឯស ធម្មោតិ តថាហិ តេ វិនិតោ ញាតោ តុលិតោ តីរិតោ វិការិតោ វិភូតោ ឯស ធម្មោតិ តថាហិ តេ វិនិតោ ឯស ធម្មោ ។ តេនាហ សោ ព្រាហ្មណោ

ជាជាជនា ជនបទេហិ សង្ខ្តា
តវ រីរ ភាសៃ អភិកង្ខ្ជមានា
តេសំ តុវំ សាធុ វិយាករោហិ
តថាហិ តេ វិនិតោ ឯស ធម្មោតិ ។

[៤១៩] អាជានតណ្ហំ វិនយេថ សព្ពំ (ភ្ជ្ជ្ជ្ជ្ជ្ជ្ជ្ជ្ជ ភតវា)
ឧទ្ធំ អធោ តិរិយំ ភាបិ មជ្ឈ
យំ យំ ហិ លោកស្មឺ ឧចាឧិយន្តិ
តេនេវ មារោ អន្ធេតិ ជន្តុំ ។

[៤២០] អាជានតណ្ហំ វិនយេថ សព្ពន្តិ អាជានតណ្ហា រុច្ចតិ រូបតណ្ហា ។ ឆ្ជ្ជ្ជ្ជ្ជ្ជ្ជ្ជ្ជ អាជានតណ្ហា រុច្ចតិ

---

១ ម. ឯត្ថន្តរេ តេសំ តុវំ សាធុ វិយាករោហីតិ ទិស្ស្ជ្ជ្ជ ។

ពាក្យថា ព្រះអង្គ គឺកទ្រាវុធនិយាយចំពោះព្រះមានព្រះភាគ ។ ពាក្យថា សូមព្រះអង្គសម្តែង គឺសូមព្រះអង្គប្រាប់ សម្តែង បញ្ញត្ត ផ្តើម បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (លោកពោលថា) សូមព្រះអង្គសម្តែង ។

[៤១៨] ពាក្យថា ធម៌ន៏ុ ព្រះអង្គជ្រាបហើយ ដោយពិត គឺធម៌ន៏ុ ព្រះអង្គជ្រាប ដឹង ច្ប៊ីង ពិចារណា ឈ្ងង់យល់ ប្រាកដ ដោយពិត ហេតុនោះ (លោកពោលថា) ធម៌ន៏ុ ព្រះអង្គជ្រាបហើយដោយពិត ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

> បពិត្រព្រះអង្គជាវីរបុរស ពួកជនផ្សេងៗ ចេញអំពីជនបទ ទាំងឡាយ មកប្រជុំគ្នា ត្រូវការព្រះតម្រាស់របស់ព្រះអង្គ សូមព្រះអង្គសម្តែង ដោះប្រស្នា ដើម្បីជនទាំងនោះ ព្រោះថា ធម៌ន៏ុ ព្រះអង្គជ្រាបហើយ ដោយពិត ។

[៤១៩] (ព្រះមានព្រះភាគត្រាស់ថា ម្នាលកទ្រាវុធ) បុគ្គលគប្បីកម្ចាត់អាទានតណ្ហា (តណ្ហាជាគ្រឿងប្រកាន់) ទាំងអស់ ទាំងខាងលើ ទាំងខាងក្រោម ទាំងទទឹងគឺកណ្តាល ព្រោះថា ពួកសត្វប្រកាន់ នូវខន្ធបញ្ចក: ណាៗ ក្នុងលោក មារតែងជាប់តាម នូវសត្វ ដោយអកិសង្ខារ គឺកម្មនោះឯង ។

[៤២០] ពាក្យថា បុគ្គលត្រូវកម្ចាត់អាទានតណ្ហាទាំងអស់ គឺ រូបតណ្ហា ហៅថា អាទានតណ្ហា ។ ព្រោះហេតុអ្វី រូបតណ្ហា ហៅថា អាទានតណ្ហា ។

រូបតណ្ហា ។ តាយ រូបំ អាឌិយន្តិ ឧចាឌិយន្តិ កណ្ហាន្តិ
បរាមសន្តិ អភិនិវិសន្តិ វេឌនំ សញ្ញំ សង្ខារេ វិញ្ញាណំ
ឥតឺ ឧបបត្តឺ បដិសន្ធឺ ភវំ សំសារំ វដ្ដំ អាឌិយន្តិ
ឧចាឌិយន្តិ កណ្ហាន្តិ បរាមសន្តិ អភិនិវិសន្តិ
តំការណា អាជានតណ្ហា រុច្ចតិ រូបតណ្ហា ។
អាជានតណ្ហា វិនយេថ សព្វន្តិ សព្វំ អាជានតណ្ហា
វិនយេថ វិនេយ្យ បជហេយ្យ វិនោទេយ្យ អនភាវ-
មេយ្យាតិ អាជានតណ្ហា វិនយេថ សព្វំ ។ ភទ្រាវុជា-
តិ ភតវាតិ ភទ្រាវុជាតិ ភតវា តំ ព្រាហ្មណំ
ជាមេន អាលបតិ ។ ភតវាតិ ការវាជិវចនមេតំ
។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភតវាតិ ភទ្រា-
វុជាតិ ភតវា ។

[៤២១] ឧទ្ធំ អធោ តិរិយំ វាបិ មជ្ឈេតិ ឧទ្ធន្តិ រុច្ចតិ
អនាគតំ ។ អធោតិ អតីតំ ។ តិរិយំ វាបិ មជ្ឈេតិ
បច្ចុប្ផន្នំ ។ ឧទ្ធន្តិ កុសលា ធម្មា ។ អធោតិ អកុស-
លា ធម្មា ។ តិរិយំ វាបិ មជ្ឈេតិ អព្យាកតា ធម្មា ។
ឧទ្ធន្តិ ទេវលោកោ ។ អធោតិ អបាយលោកោ ។

ពួកសត្វមែងកាន់ ប្រកាន់ ក្ងេចកាន់ ស្ទាបអង្អែល ជាប់ចំពាក់ ចំពោះ
រូប ដោយតណ្ហានោះ កាន់ ប្រកាន់ ក្ងេចកាន់ ស្ទាបអង្អែល ជាប់ចំពាក់
ចំពោះវេទនា សញ្ញា ពួកសង្ខារ វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព
សង្សារ វដ្ដៈ ហេតុនោះ រូបតណ្ហា ហៅថា អាទានតណ្ហា ។ ពាក្យថា
បុគ្គលត្រូវកម្ចាត់អាទានតណ្ហាទាំងអស់ គឺបុគ្គល ត្រូវកម្ចាត់ បណ្ដេញ
លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវអាទានតណ្ហា
ទាំងអស់ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលត្រូវកម្ចាត់អាទានតណ្ហា
ទាំងអស់ ។ ពាក្យថា ភទ្រាវុធ របស់បទថា ព្រះមានព្រះភាគត្រាស់ថា
ម្នាលភទ្រាវុធ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះ តាមឈ្មោះ ។
ពាក្យថា ព្រះមានព្រះភាគ ន៏ុះ ជាពាក្យពោលដោយគោរព ។ បេ ។
ការបញ្ជ្ជតថា មានព្រះភាគ នេះ (ក្ដីត) ព្រោះការធ្វើឲ្យជាក់ច្បាស់
ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលភទ្រាវុធ ។

[៦២១] ពាក្យថា ទាំងខាងលើ ទាំងខាងក្រោម ទាំងទទឹង
គឺកណ្ដាល សេចក្ដីថា អនាគត ហៅថា ខាងលើ ។ អតីត
ហៅថា ខាងក្រោម ។ បច្ចុប្បន្ន ហៅថា ទទឹង គឺកណ្ដាល ។
ពួកកុសលធម៌ ហៅថា ខាងលើ ។ ពួកអកុសលធម៌ ហៅថា ខាង
ក្រោម ។ ពួកអព្យាកតធម៌ ហៅថា ទទឹង គឺកណ្ដាល ។ ទេវ-
លោក ហៅថា ខាងលើ ។ អបាយលោក ហៅថា ខាងក្រោម ។

តិរិយំ ភាបិ មជ្ឈេតិ មនុស្ស្យលោកោ ។ ឧទ្ធន្តិ
សុខា វេទនា ។ អធោតិ ទុក្ខា វេទនា ។
តិរិយំ ភាបិ មជ្ឈេតិ អទុក្ខមសុខា វេទនា ។
ឧទ្ធន្តិ អរូបធាតុ ។ អធោតិ កាមធាតុ ។ តិរិយំ
ភាបិ មជ្ឈេតិ រូបធាតុ ឧទ្ធន្តិ ឧទ្ធំ ចាតតលា ។
អធោតិ អធោ ភោសមត្ថកា ។ តិរិយំ ភាបិ មជ្ឈេតិ
ឧមជ្ឈេតិ ឧទ្ធំ អធោ តិរិយំ ភាបិ មជ្ឈ ។

[៤២២] យំ យំ ហិ លោកស្មឿ ឧចាឧិយន្តីតិ
យំ យំ ហិ រូបកតំ វេទនាកតំ សញ្ញាកតំ សង្ខារ-
កតំ វិញ្ញាណកតំ អាឧិយន្តិ ឧចាឧិយន្តិ ឧណ្ហាន្តិ
ឧរាមសន្តិ អភិនិវិសន្តិ ។ លោកស្មិន្តិ អចាយលោកេ
។ ឧ ។ អាយតនលោកេតិ យំ យំ ហិ លោកស្មឿ
ឧចាឧិយន្តិ ។

[៤២៣] ឧនេវ មាវ អន្ធេតិ ជន្តុន្តិ ឧនេវ
ឧកម្ម្ភាកិសង្ខារវសេន ឧជិសន្ធិកោ ១ជ្ជមាវ ជាតុ-
មាវ អាយតនមាវ ឧតិមាវ ឧបបត្តិមាវ
ឧជិសន្ធិមាវ ភវមាវ សំសារមាវ វដ្ដមាវ
អន្ធេតិ អនុឧច្ចតិ អជ្ជាយិកោ ហោតិ ។

មនុស្សលោក ហៅថា ទទឹង គឺកណ្តាល ។ សុខវេទនា ហៅថា ខាងលើ ។ ទុក្ខវេទនា ហៅថា ខាងក្រោម ។ អទុក្ខមសុខវេទនា ហៅថា ទទឹង គឺកណ្តាល ។ អរូបធាតុ ហៅថា ខាងលើ ។ កាមធាតុ ហៅថា ខាងក្រោម ។ រូបធាតុ ហៅថា ទទឹង គឺ កណ្តាល ។ សរីរៈខាងលើ អំពីបាតជើងឡើងទៅ ហៅថា ខាងលើ ។ សរីរៈខាងក្រោម អំពីចុងសក់ចុះមក ហៅថា ខាងក្រោម ។ សរីរៈ ត្រង់ពាក់កណ្តាល ហៅថា ទទឹង គឺកណ្តាល ហេតុនោះ (ទ្រង់ត្រាស់ថា) ទាំងខាងលើ ទាំងខាងក្រោម ទាំងទទឹងគឺកណ្តាល ។

[៦២២] *ពាក្យថា ព្រោះពួកសត្វប្រកាន់នូវខន្ធបញ្ចកៈណាៗ ក្នុងលោក គឺព្រោះពួកសត្វកាន់ ក្ជកាន់ ប្រកាន់ ស្ទាបអង្អែល ជាប់ចំពាក់ចំពោះរូប វេទនា សញ្ញា សង្ខារ វិញ្ញាណណាៗ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។ ក្នុងអាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកសត្វប្រកាន់នូវខន្ធបញ្ចកៈណាៗ ក្នុងលោក ។*

[៦២៣] *ពាក្យថា មារតែងជាប់តាមនូវសត្វ ដោយអកិសង្ខារ គឺកម្មនោះឯង បានដល់ មារគឺខន្ធ មារគឺធាតុ មារគឺអាយតនៈ មារគឺគតិ មារគឺឧបបត្តិ មារគឺបដិសន្ធិ មារគឺភព មារគឺសង្សារ មារគឺវដ្តៈ ដែលប្រកបដោយបដិសន្ធិ តែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ដោយអំណាច នៃអកិសង្ខារ គឺកម្មនោះឯង ។*

ជន្តុន្តិ សត្តំ នរំ មាណវំ ពោសំ បុគ្គលំ ជីវំ ជាតុំ[១] ជន្តុំ ឥន្ទគុំ មនុជន្តិ តេនេវ មារោ អន្វេតិ ជន្តុំ ។ តេនាហ ភគវា

អាទានតណ្ហំ វិនយេថ សព្វំ (ភទ្រាវុធាតិ ភគវា)
ឧទ្ធំ អធោ តិរិយំ វាបិ មជ្ឈេ
យំ យំ ហិ លោកស្មឹ ឧបាទិយន្តិ
តេនេវ មារោ អន្វេតិ ជន្តុន្តិ ។

[៤២៤] តស្មា បជានំ ន ឧបាទិយេថ
ភិក្ខុ សតោ កិញ្ចនំ សព្វលោកេ
អាទានសត្តេ ឥតិ បេក្ខមានោ
បជំ ឥមំ មច្ចុធេយ្យេ វិសត្តំ ។

[៤២៥] តស្មា បជានំ ន ឧបាទិយេថាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា ឯតំ អាទីនវំ សម្បស្សមានោ អាទានតណ្ហាយាតិ តស្មា ។ បជានន្តិ ជានន្តោ បជានន្តោ អាជានន្តោ វិជានន្តោ បដិវិជានន្តោ បដិវិជ្ឈន្តោ សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។

១ ម. ជគុំ ។

ពាក្យថា សត្ត គឺសត្ត នរ: មាណព បុរស បុគ្គល ជីវ: សត្តមានជាតិ មានជីវ សត្តទៅដោយឥន្ទ្រិយ សត្តកើតអំពីមនុស្ស ហេតុនោះ (ទ្រង់ត្រាស់ថា) មារតែងជាប់តាមនូវសត្ត ដោយអកិសង្ខារគឺកម្មនោះឯង ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលភទ្រាវុធ) បុគ្គលត្រូវកម្ចាត់
អាទានតណ្ហាទាំងអស់ ទាំងខាងលើ ទាំងខាងក្រោម ទាំងទទឹង
គឺកណ្តាល ព្រោះថា ពួកសត្តប្រកាន់នូវខន្ធបញ្ចក:ណាៗក្នុង
លោក មារតែងជាប់តាមសត្ត ដោយអកិសង្ខារគឺកម្មនោះឯង ។

[៦២៦] ព្រោះហេតុដូច្នោះ ភិក្ខុដឹងច្បាស់ នឹករលឹកឃើញ កាលសម្ងឹងឃើញ នូវពួកសត្តដែលជាប់ ក្នុងអារម្មណ៍ជាគ្រឿងប្រ-
កាន់ នូវប្រជាជននេះ ដែលជាប់ចំពាក់ក្នុងហេតុជាទីតាំងនៃមន្ទ:
ដូច្នេះ មិនគប្បីប្រកាន់នូវខន្ធបញ្ចក:នីមួយ ក្នុងលោកទាំងពួង ។

[៦២៧] ពាក្យថា ព្រោះហេតុដូច្នោះ... ដឹងច្បាស់... មិនគប្បីប្រកាន់ គឺ ព្រោះហេតុដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ឃើញច្បាស់នូវទោសនុ៎ះ ក្នុងអាទាន-តណ្ហា ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុដូច្នោះ ។ ពាក្យថា ដឹងច្បាស់ គឺ ដឹង ដឹងច្បាស់ យល់ច្បាស់ ដឹងវិសេស យល់ធ្ងុះធ្ងាយ ត្រាស់ដឹងថា សង្ខារទាំងឡាយ ទាំងពួង មិងទៀង ។ បេ ។

យន្តីញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ជានន្តោ បជានន្តោ អាជានន្តោ វិជានន្តោ បដិវិជានន្តោ បដិ-វិជ្ឌន្តោ ។ ន ឧចាធិយេថាតិ រូបំ ជាធិយេយ្យ ន ឧចាធិយេយ្យ ន កណ្ហាយ្យ ន បរាមសេយ្យ ជាកិ-ធិវិសេយ្យ វេទនំ សញ្ញ សង្ខារេ វិញ្ញាណំ ឥតឺ ឧបមត្ត្ត បដិសន្ធ្ធ ភវ សំសារ វដ្ដ ជាធិយេយ្យ ន ឧចាធិយេយ្យ ន ឥណ្ហាយ្យ ន បរាមសេយ្យ ជាកិធិវិ-សេយ្យាតិ ឥស្ម បជានំ ន ឧចាធិយេថ ។

[៤២៦] ភិក្ខុ សតោ ឥកិញ្ចនំ សព្វលោកេតិ ភិក្ខូតិ ឥកល្យាណបុថុជ្ជនោ វា ភិក្ខុ សេក្ខោ វា ភិក្ខូតិ ភិក្ខុ ។ សតោតិ ចតូហិ ការណេហិ សតោ ឥកាយេ ឥកាយានុបស្សនាសតិប្ឋ្ឌានំ ភាវេន្តោ សតោ ។ បេ ។ សោ រុចូតិ សតោតិ ភិក្ខុ សតោ ។ ឥកិញ្ចនន្តិ ឥកិញ្ចិ រូបកតំ វេទនាកតំ សញ្ញាកតំ សង្ខារកតំ វិញ្ញាណាក-តំ ។ សព្វលោកេតិ សព្វអបាយលោកេ សព្វទេវ-លោកេ សព្វមនុស្ឍលោកេ សព្វក្ខន្ធលោកេ សព្ព-អាយតនលោកេ សព្ធ្ធាតុលោកេតិ ភិក្ខុ សតោ ឥកិញ្ចនំ សព្ធ្ធលោកេ ។

ដឹង ដឹងច្បាស់ យល់ច្បាស់ ដឹងវិសេស យល់ធ្ងុះធ្ងាយ ត្រាស់ដឹងថា ធម្មជាតណានីមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ពាក្យថា មិនគប្បីប្រកាន់ គឺមិនត្រូវកួចកាន់ មិនត្រូវកាន់យក មិនត្រូវស្ទាបអង្អែល មិនត្រូវជាប់ចំពាក់ចំពោះរូប មិនត្រូវប្រកាន់ មិនត្រូវកួចកាន់ មិនត្រូវកាន់យក មិនត្រូវស្ទាបអង្អែល មិនត្រូវចំពាក់ ចំពោះវេទនា សញ្ញា ពួកសង្ខារ វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព សង្សារ វដ្ដ: ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុដូច្នោះ ដឹងច្បាស់ មិនគប្បីប្រកាន់ ។

[៤២៦] ពាក្យថា ភិក្ខុនឹករលឹកឃើញនូវខន្ធបញ្ចក:នីមួយ ក្នុងលោកទាំងពួង ត្រង់ពាក្យថាភិក្ខុ គឺភិក្ខុជាកល្យាណបុថុជ្ជន ឬភិក្ខុជាសេក្ខ: ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុ ។ ពាក្យថា នឹករលឹកឃើញ គឺនឹករលឹកដោយហេតុ ៤ គឺកំពុងចម្រើន កាយេកាយានុបស្សនាសតិប្បដ្ឋាន ឈ្មោះថានឹករលឹកឃើញ ។ បេ ។ ភិក្ខុនោះលោកហៅថាអ្នករលឹកឃើញ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនឹករលឹកឃើញ ។ ពាក្យថា ខន្ធបញ្ចក:នីមួយ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ណានីមួយ ។ ពាក្យថា ក្នុងលោកទាំងពួង គឺក្នុងអបាយលោកទាំងមូល ក្នុងទេវលោកទាំងមូល ក្នុងមនុស្សលោកទាំងមូល ក្នុងខន្ធលោកទាំងមូល ក្នុងអាយតនលោកទាំងមូល ក្នុងធាតុលោកទាំងមូល ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនឹករលឹកឃើញខន្ធបញ្ចក:នីមួយ ក្នុងលោកទាំងពួង ។

ភទ្រាវុធមាណវកប្បញ្ហានិទ្ទេសោ

[៤២៧] អាជានសត្តេ ឥតិ បេក្ខមានោតិ អាជានសត្តា រុច្ចន្តិ យេ រូបំ អាឌិយន្តិ ឧចាឌិយន្តិ កណ្ហាន្តិ បរាមសន្តិ អភិនិវិសន្តិ រេឌនំ សញ្ញ សង្ខ្យាវេ វិញ្ញាណំ ឥតឺ ឧបបត្តឺ បដិសន្ធឺ ភវ សំសារ រដ្ឋ អាឌិយន្តិ ឧចាឌិយន្តិ កណ្ហាន្តិ បរាមសន្តិ អភិនិវិសន្តិ ។ ឥតីតិ បឌសន្ធិ ។ បេ ។ បជានុបុព្ពកមេតំ ឥតីតិ ។ បេក្ខមានោតិ ឌក្ខមានោ ជិស្សមានោ បស្សមានោ ឱលោកយមានោ ជិជ្ឌាយមានោ ឧបបរិក្ខមានោតិ អាជានសត្តេ ឥតិ បេក្ខមានោ ។

[៤២៨] បជំ ឥមំ មច្ចុឌេយ្យ វិសត្តន្តិ ប-ជន្តិ សត្តាជិវចនំ ។ មច្ចុឌេយ្យតិ មច្ចុឌេយ្យា រុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខ្យារ ច ។ បជា មច្ចុឌេយ្យ មារឌេយ្យ មរណាឌេយ្យ វិសត្តា អាសត្តា លក្ខ លក្ខិតា បលិពុទ្ធា ។

ភទ្រាវុធមាណវកប្បញ្ហានិទ្ទេស

[៦២៧] ពាក្យថា កាលសម្ធឹងឃើញនូវពួកសត្វដែលជាប់ក្នុងអារម្មណ៍ជាគ្រឿងប្រកាន់ដូច្នេះ គឺពួកសត្វណា កាន់ ក្ជកាន់ ប្រកាន់ ស្ទាប អង្អែល ជាប់ចំពាក់ ចំពោះរូប កាន់ ក្ជកាន់ ប្រកាន់ ស្ទាបអង្អែល ជាប់ចំពាក់ ចំពោះវេទនា សញ្ញា ពួកសង្ខារ វិញ្ញាណ កតិ ឧបបត្តិ បដិ-សន្ធិ ភព សង្សារ វដ្ដ: សត្វទាំងនោះ លោកហៅថា អ្នកជាប់ក្នុងអារម្មណ៍ជាគ្រឿងប្រកាន់ ។ ពាក្យថា ដូច្នេះ គឺជាពាក្យតបទ ។ បេ ។ ពាក្យថា ដូច្នេះ នុ៎ះ ជាលំដាប់បទ ។ ពាក្យថា កាលសម្ធឹងឃើញ គឺកាលឃើញ មើលឃើញ យល់ឃើញ រមិលមើល គន់មើល ពិចារណាមើល ហេតុនោះ (ទ្រង់ត្រាស់ថា) កាលសម្ធឹងឃើញនូវពួកសត្វដែលជាប់ក្នុងអារម្មណ៍ជាគ្រឿងប្រកាន់ ដូច្នេះ ។

[៦២៨] ពាក្យថា ប្រជាជននេះ ដែលជាប់ចំពាក់ ក្នុងហេតុជាទីតាំងនៃមច្ចុ ត្រង់ពាក្យថា ប្រជាជន គឺជាឈ្មោះ នៃសត្វ ។ ពាក្យថា ហេតុជាទីតាំងនៃមច្ចុ គឺ ពួកកិលេសក្តី ខន្ធក្តី អភិសង្ខារក្តី លោកហៅថា ហេតុជាទីតាំងនៃមច្ចុ ។ ប្រជា-ជន ជាប់ ជាប់ទូទៅ ជ្ជក់ ទាក់ ជាប់ចំពាក់ ក្នុងហេតុជាទីតាំងនៃមច្ចុ ហេតុជាទីតាំងនៃមារ ហេតុជាទីតាំងនៃមរណ: ។

យថា ភិត្តិ១ិលេ វា ជាតឧន្តេ វា ភណ្ឌំ វិសត្តំ អាសត្តំ លគ្គំ លគ្គិតំ បលិពុទ្ធំ ឯវមេវ បជា មចុ្ចនេយ្យ មារនេយ្យ មារណានេយ្យ វិសត្តា អាសត្តា លគ្គា លគ្គិតា បលិពុទ្ធាតិ បជំ ឥមំ មចុ្ចនេយ្យ វិសត្តំ ។ តេនាហ ភគវា

តស្មា បជានំ ន ឧចានិយេថ
ភិក្ខុ សតោ ភិញ្ញំ សព្វលោកេ
អាជានសត្តេ ឥតិ បេក្ខមានោ
បជំ ឥមំ មចុ្ចនេយ្យ វិសត្តន្តិ ។

សហ គាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

ភទ្រាវុធមាណវកប្បញ្ហានិទ្ទេសោ ទ្វាទសមោ ។

វត្ថុដែលជាប់ ជាប់ទួទៅ ជ្ជក់ ទាក់ ជាប់ចំពាក់ ត្រង់ចម្រឹងជញ្ជាំង ឬដៃ-
កែវ យ៉ាងណា ពួកសត្វជាប់ ជាប់ទួទៅ ជ្ជក់ ទាក់ ជាប់ចំពាក់ក្នុងហេតុ
ជាទីតាំងនៃមច្ចុ ក្នុងហេតុជាទីតាំងនៃមារ ក្នុងហេតុជាទីតាំងនៃមរណៈ ក៏
យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រជាជននេះ ដែលជាប់ក្នុង
ហេតុជាទីតាំងនៃមច្ចុ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រោះហេតុដូច្នោះ ភិក្ខុដឹងច្បាស់ នឹកវង្ហកឃើញ កាល
សម្ងឹងឃើញ នូវពួកសត្វដែលជាប់ ក្នុងអារម្មណ៍ជាគ្រឿង
ប្រកាន់ នូវប្រជាជននេះ ដែលជាប់ចំពាក់ ក្នុងហេតុជាទី
តាំងនៃមច្ចុ ដូច្នេះ មិនគប្បីប្រកាន់នូវខន្ធបញ្ចកៈនីមួយ
ក្នុងលោកទាំងពួង ។

ដំណាលគ្នានឹងកាលជាទីចប់នៃគាថា ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន
ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គ ជាសាវ័ក ។

ចប់ ភទ្រាវុធមាណវកប្បញ្ហានិទ្ទេស ទី ១២ ។

ព្រះ
ត្រៃបិដកបាលី
និង
សេចក្តីប្រៀបភាសាខ្មែរ
សុត្តន្តបិដក
ខុទ្ទកនិកាយ ចូឡនិទ្ទេស
ទុតយភាគ
៦៨

ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឆរាជាធិបតី ហ្ស ក្ដី
សម្តេចព្រះមហាសង្ឆរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា

ព. ស. ២៥៥៣

SUTTANTAPIṬAKA

KHUDDAKANIKĀYA

CŪḶANIDDESA

DUTIYABHĀGA

68

Printed for free distribution by
The Corporate Body of the Buddha Educational Foundation
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
This book is strictly for free distribution, it is not to be sold.
សម្រាប់ចែកជាធម្មទាន

សម្តេចព្រះអតិសីរីសុគន្ធាមហាសង្ឆរាជាធិបតី ប៊ូ ត្រី
សម្តេចព្រះមហាសង្ឆរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈ ក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឆបូជា ។

សូមសេចក្ដីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្ដីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបឋុមធ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

ប៊ូ-ត្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

សេចក្តីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរ: **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឆរាជជោតញ្ញាណ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សន្ធឹកច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

សុត្តន្តបិដក

ខុទ្ទកនិកាយ ចូឡនិទ្ទេស

ទុតិយភាគ

៦៨

ព.ស ២៥០៤

សុត្តន្តបិដកេ

ខុទ្ទកនិកាយស្ស ចូឡនិទ្ទេសោ

ទុតិយោ ភាគោ

ឧទយមាណវកប្បញ្ហានិទ្ទេសោ

[១] ឈាយឺ វិរជមាសីនំ (ឥច្ចាយស្មា ឧទយោ)

កតកិច្ចំ អនាសវំ

ចារកុំ សព្វធម្មានំ

អត្តិ បញ្ហេន អាគមំ

អញ្ញាវិមោក្ខំ សំព្រូហិ

អវិជ្ជាយ បភេទនំ ។

[២] ឈាយឺ វិរជមាសីនន្តិ ឈាយិន្តិ ភគវា

បឋមេនបិ ឈានេន ឈាយី ទុតិយេនបិ ឈានេន

ឈាយី តតិយេនបិ ឈានេន ឈាយី ចតុត្ថេនបិ

ឈានេន ឈាយី សវិតក្កសវិចារេនបិ ឈានេន

ឈាយី អវិតក្កវិចារមត្តេនបិ ឈានេន ឈាយី

សុត្តន្តបិដក

ខុទ្ទកនិកាយ ចូឡនិទ្ទេស

ទុតិយភាគ

ឧទយមាណវកប្បញ្ហានិទ្ទេស

[១] *(ឧទយៈមានអាយុក្រាបទូល ដូច្នេះថា) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ (ដើម្បីសួរ) ព្រះអង្គជាអ្នកមានឈាន មានព្រះសន្ដានប្រាសចាកធូលី ទ្រង់គង់នៅ ទ្រង់មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង សូមព្រះអង្គសម្ដែងអញ្ញាវិមោក្ខ ជាគ្រឿងទម្លាយអវិជ្ជា ។*

[២] *អធិប្បាយពាក្យថា ជាអ្នកមានឈាន មានព្រះសន្ដានប្រាសចាកធូលី ទ្រង់គង់នៅ ត្រង់ពាក្យថា មានឈាន គឺព្រះមានព្រះភាគ មានឈាន ដោយបឋមជ្ឈានផង មានឈាន ដោយទុតិយជ្ឈានផង មានឈាន ដោយតតិយជ្ឈានផង មានឈាន ដោយចតុត្ថជ្ឈានផង មានឈាន ដោយឈាន ប្រកបដោយវិតក្កៈនិងវិចារៈផង មានឈាន ដោយឈានមិនមានវិតក្កៈ មានតែវិចារៈផង*

អវិតក្កាវិចារេនបិ ឈានេន ឈាយី សប្បីតិកេ-
នបិ ឈានេន ឈាយី និប្បីតិកេនបិ ឈានេន
ឈាយី សាតសហគតេនបិ ឈានេន ឈាយី
ឧបេក្ខាសហគតេនបិ ឈានេន ឈាយី សុញ្ញ-
តេនបិ ឈានេន ឈាយី អនិមិត្តេនបិ ឈានេន
ឈាយី អប្បណិហិតេនបិ ឈានេន ឈាយី
លោកិយេនបិ ឈានេន ឈាយី លោកុត្តរេនបិ
ឈានេន ឈាយី ឈានរតោ ឯកត្តមនុយុត្តោ
សទត្ថគរុកោតិ ឈាយី ។ វិរជន្តិ រាគោ រជោ
ទោសោ រជោ មោហោ រជោ កោធោ រជោ
ឧបនាហោ រជោ ។ បេ ។ សព្វាកុសលាភិ-
សង្ខារា រជា ។ តេ រជា ពុទ្ធស្ស ភគវតោ
បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្ក-
តា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ អរជោ
វិរជោ រជាបគតោ រជវិប្បហីនោ រជវិប្បមុត្តោ ។

មានឈាន ដោយឈានមិនមានវិតក្ក: មិនមានវិចារ:ផង មានឈាន ដោយឈានប្រកបដោយបីតិផង មានឈាន ដោយឈានមិនមានបីតិផង មានឈាន ដោយឈានប្រកបដោយសុខផង មានឈាន ដោយឈាន ប្រកបដោយឧបេក្ខាផង មានឈាន ដោយឈាន ប្រកបដោយសុញ្ញត-វិមោក្ខផង មានឈាន ដោយឈាន ប្រកបដោយអនិមិត្តវិមោក្ខផង មានឈាន ដោយឈាន ប្រកបដោយអប្បណិហិតវិមោក្ខផង មានឈាន ដោយឈានជាលោកិយផង មានឈាន ដោយឈានជាលោកុត្តរផង ជាបុគ្គលត្រេកអរក្នុងឈាន ប្រកបរឿយៗ នូវភាពជាបុគ្គលម្នាក់ឯង ធ្ងន់ក្នុងប្រយោជន៍របស់ខ្លួន ហេតុនោះ (លោកពោលថា) អ្នកមានឈាន ។ ពាក្យថា ប្រាសចាកធូលី សេចក្ដីថា ធូលីគឺរាគ: ធូលីគឺទោស: ធូលីគឺមោហ: ធូលីគឺកោធ: ធូលីគឺឧបនាហ: ។ បេ ។ ធូលីគឺអកិសង្ខារជាអកុសលទាំងអស់ ។ ធូលីទាំងនោះ ព្រះពុទ្ធមានជោគលះបង់ ផ្ដាច់ ផ្ដិលឫសគល់ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានបែបភាព មានការមិនកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធឈ្មោះថា មិនមានធូលី ប្រាសចាកធូលី មានធូលីទៅប្រាសលះបង់ធូលី ផុតស្រឡះចាកធូលី ។

ឧទយមាណវកប្បញ្ហានិទ្ទេសោ

ភគោ រជោ ន ច បន រេណុ រុច្ចតិ
ភគស្សេតំ អធិវចនំ រជោតិ
ឯតំ រជំ វិប្ផជ្ជហិត្វ ចក្ខុមា[1]
តស្មា ជិនោ វិគតរជោតិ រុច្ចតិ
ទោសោ រជោ ន ច បន រេណុ រុច្ចតិ
ទោសស្សេតំ អធិវចនំ រជោតិ
ឯតំ រជំ វិប្ផជ្ជហិត្វ ចក្ខុមា
តស្មា ជិនោ វិគតរជោតិ រុច្ចតិ
មោហោ រជោ ន ច បន រេណុ រុច្ចតិ
មោហស្សេតំ អធិវចនំ រជោតិ
ឯតំ រជំ វិប្ផជ្ជហិត្វ ចក្ខុមា
តស្មា ជិនោ វិគតរជោតិ រុច្ចតីតិ ។

រជំ ។ អាសីនន្តិ និសិន្នោ ភគវា ចាសាណាកេ ចេ-តិយេតិ អាសីនោ ។

ជនស្ស បស្ស អាសិនំ មុនឺ ឧក្ខ្លស្ស ចារកុំ
សាវកា បយិរុចាសន្តិ តេវិជ្ជា មច្ចុហាយិនោតិ ។

ឯវម្ៀ ភគវា អាសីនោ ។ អថវា ភគវា សញ្ជោស្សុក្ខ្លប្ប-ជិប្ផស្ស ទ្ធត្តា អាសីនោ រុជ្ជវាសោ ចិណ្ណចរណោ ។ បេ ។

---

1 ម. បដិវិនោទេត្វា ន ចក្ខុមា ។

ធូលីសំដៅយករាគ: មិនមែនលម្អងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះរាគ: ព្រះជិនស្រីមានបញ្ញាចក្ខុ លះបង់ធូលីនុ៎ះហើយ ហេតុនោះ ទើបលោកហៅថាអ្នកមានធូលីទៅប្រាស ធូលីសំដៅយកទោស: មិនមែនលម្អងទេ ពាក្យថាធូលីនុ៎ះ ជាឈ្មោះទោស: ព្រះជិនស្រីមានបញ្ញាចក្ខុ លះបង់ធូលីនុ៎ះហើយ ហេតុនោះ ទើបលោកហៅថាអ្នកមានធូលីទៅប្រាស ធូលីសំដៅយកមោហ: មិនមែនលម្អងទេ ពាក្យថាធូលីនុ៎ះ ជាឈ្មោះមោហ: ព្រះជិនស្រីមានបញ្ញា-ចក្ខុ លះបង់ធូលីនុ៎ះហើយ ហេតុនោះ ទើបលោកហៅថាអ្នកមានធូលីទៅប្រាស ។

ហេតុនោះ (លោកពោលថា) ប្រាសចាកធូលី ។ ពាក្យថា ទ្រង់គង់នៅ គឺ ព្រះមានព្រះភាគទ្រង់គង់ក្បែរបាសាណកចេតិយ ហេតុនោះ ទើបឈ្មោះ ថា ទ្រង់គង់នៅ ។

ពួកសាវ័កអ្នកមានត្រៃវិជ្ជា លះបង់មច្ចុហើយ ចូលទៅអង្គុយ
ជិតព្រះមុនី ទ្រង់ដល់ត្រើយនៃទុក្ខ គង់ខាងក្នុ ។

ព្រះមានព្រះភាគឈ្មោះថាទ្រង់គង់នៅ យ៉ាងនេះក៏បាន ។ មួយទៀត ព្រះមានព្រះភាគឈ្មោះថាទ្រង់គង់នៅ ព្រោះព្រះអង្គរម្ងាប់សេចក្ដីខ្ជល់ខ្ជាយទាំងពួង ហើយទ្រង់មានព្រហ្មចរិយ:នៅហើយ មានចរណធម៌សន្សំហើយ ។ បេ ។

ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ ឯវម្បិ ភគវា អាសីនោតិ ឈាយី វិរជមាសីនំ ។ ឥច្ចាយស្មា ឧទយោតិ ឥច្ចាតិ បទសន្ធិ ។ បេ ។ បទានុបុព្វតា-មេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ អាយស្មាតិ ។ ឧទ-យោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលា-បោតិ ឥច្ចាយស្មា ឧទយោ ។

[៣] កតកិច្ចំ អនាសវន្តិ ពុទ្ធស្ស ភគវតោ កិច្ចំ ករណីយាករណីយំ បហីនំ ឧច្ឆិន្នមូលំ តា-លាវត្ថុកតំ អនភាវង្គតំ អាយតឹអនុប្បាទធម្មំ តស្មា ពុទ្ធោ កតកិច្ចោ ។

យស្ស បរិបតា[១] នត្ថិ ឆិន្នសោតស្ស ភិក្ខុនោ
កិច្ចាកិច្ចំ បហីនស្ស បរិឡាហោ ន វិជ្ជតីតិ ។

កតកិច្ចំ ។ អនាសវន្តិ អាសវាតិ ចត្តារោ អាសវា កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។

១ ម. យស្ស ច វិសដា ។

ភពថ្មី គឺ ជាតិជរាមរណៈសង្សារ របស់ព្រះមានព្រះភាគនោះ មិនមាន ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថាទ្រង់គង់នៅ យ៉ាងនេះក៏បាន ហេតុនោះ (លោកពោលថា) អ្នកមានឈានប្រាសចាកធូលីទ្រង់គង់នៅ ។ ពាក្យថាដូច្នេះ ក្នុងបទថា ឧទយៈមានអាយុពោលដូច្នេះ គឺជាការតបទ ។ បេ ។ ពាក្យថាដូច្នេះនេះ ជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុនេះ ជាពាក្យពោលដោយគោរពកោតក្រែង ។ ពាក្យថា ឧទយៈ ជាឈ្មោះ ។ បេ ។ ជាពាក្យហៅ នូវព្រាហ្មណ៍នោះ ហេតុនោះ (ទើបមានពាក្យថា) ឧទយៈមានអាយុពោលដូច្នេះ ។

[៣] ពាក្យថា ទ្រង់មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ គឺកិច្ចគួរធ្វើនិងមិនគួរធ្វើ ព្រះពុទ្ធមានជោគលះបង់ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានបែបភាព មិនមានការកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធឈ្មោះថាមានកិច្ចធ្វើហើយ ។

ភិក្ខុណាមិនមានតណ្ហា សេចក្តីក្តៅក្រហាយ នៃភិក្ខុនោះ
ដែលជាអ្នកកាត់ផ្តាច់នូវខ្សែនៃតណ្ហា លះបង់នូវកិច្ចគួរធ្វើ
និងមិនគួរធ្វើ រមែងមិនមាន ។

ហេតុនោះ(លោកពោលថា) មានកិច្ចធ្វើរួចហើយ ។ ពាក្យថាអាសវៈក្នុងបទថា មិនមានអាសវៈបានដល់អាសវៈ ៤ គឺកាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។

ឧទយមាណវកប្បញ្ហានិទ្ទេសោ

តេ អាសវា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្គតា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ អនាសវោតិ ភតតកិចុ្ចំ អនាសវំ ។

[៤] ចារកុ សព្ធធម្មានន្តិ ភគវា សព្ធធម្មានំ អភិញ្ញាចារកូ បរិញ្ញាចារកូ បហានចារកូ ភាវនាចារកូ សចិ្ឆកិរិយាចារកូ សមាបត្តិចារកូ អភិញ្ញាចារកូ សព្ធធម្មានំ បរិញ្ញាចារកូ សព្ធទុក្ខានំ បហានចារកូ សព្ធក្លិសេសានំ ភាវនាចារកូ ចតុន្ន មគ្គានំ សចិ្ឆ-កិរិយាចារកូ និរោធស្ស សមាបត្តិចារកូ សព្ធសមា-បត្តីនំ ។ សោ វសិប្ប្ត្តោ ចារមិប្ប្ត្តោ អរិយស្ម ីសីលស្ម ី វសិប្ប្ត្តោ ចារមិប្ប្ត្តោ អរិយស្ម ីសមា-ធិស្ម ី វសិប្ប្ត្តោ ចារមិប្ប្ត្តោ អរិយាយ បញ្ញា-យ វសិប្ប្ត្តោ ចារមិប្ប្ត្តោ អរិយាយ វិមុត្តិយា

ឧទយមាណវកប្បញ្ហានិទ្ទេស

អាសវៈទាំងនោះ ព្រះពុទ្ធមានជោគលះបង់ ផ្តិលផ្តាច់ឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានបែបភាព មិនមានការកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធឈ្មោះថាមិនមានអាសវៈ ហេតុនោះ (លោកពោលថា) ទ្រង់មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ ។

[៦] *ពាក្យថា ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង គឺព្រះមានព្រះភាគ ទ្រង់ដល់ត្រើយនៃការត្រាស់ដឹងធម៌ទាំងពួង ដល់ត្រើយនៃការកំណត់ដឹង ដល់ត្រើយនៃការលះបង់ ដល់ត្រើយនៃការចម្រើន ដល់ត្រើយនៃការធ្វើឲ្យជាក់ច្បាស់ ដល់ត្រើយនៃសមាបត្តិ ដល់ត្រើយនៃការត្រាស់ដឹងធម៌ទាំងពួង ដល់ត្រើយនៃការកំណត់ដឹងទុក្ខទាំងពួង ដល់ត្រើយនៃការលះកិលេសទាំងពួង ដល់ត្រើយនៃការចម្រើនមគ្គទាំង ៤ ដល់ត្រើយនៃការធ្វើឲ្យជាក់ច្បាស់នូវនិរោធ ដល់ត្រើយនៃការចូលកាន់សមាបត្តិទាំងពួង ។ ព្រះអង្គដល់នូវការស្អាត់ ដល់ត្រើយក្នុងអរិយសីល ដល់នូវការស្អាត់ ដល់ត្រើយក្នុងអរិយសមាធិ ដល់នូវការស្អាត់ ដល់ត្រើយក្នុងអរិយបញ្ញា ដល់នូវការស្អាត់ ដល់ត្រើយក្នុងអរិយវិមុត្តិ*

សោ ចារកតោ ចារប្បត្តោ អន្តកតោ អន្តប្បត្តោ កោដិកតោ កោដិប្បត្តោ បរិយន្តកតោ បរិយន្តប្បត្តោ វោសានកតោ វោសានប្បត្តោ តាណកតោ តាណប្បត្តោ លេណកតោ លេណប្បត្តោ ចរណកតោ ចរណប្បត្តោ[១] អភយកតោ អភយប្បត្តោ អច្ចុតកតោ អច្ចុតប្បត្តោ អមតកតោ អមតប្បត្តោ និព្វានកតោ និព្វានប្បត្តោ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។ បេ ។ ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ ចារកំ សព្វធម្មានំ ។

[៤] អត្ថិ បញ្ហេន អាគមន្តិ បញ្ហត្ថិកម្ហា អាគតា បញ្ហាបុច្ឆកម្ហា អាគតា បញ្ហំ សោតុកាមា អាគតម្ហាតិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។ អថវា បញ្ហត្ថិកានំ បញ្ហាបុច្ឆកានំ បញ្ហំ សោតុកាមានំ អាគមំ អភិក្កមនំ[២] ឧបសង្កមនំ[៣] អត្ថីតិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។

១ ម. សរណគតោ សរណបត្តោ ។ ២ ម. អាគមនំ ។ ៣ ម. ឯត្ថន្តរេ បយិរុបាសនន្តិ ទិស្សតិ ។

ព្រះអង្គទៅកាន់ត្រើយ ដល់ត្រើយ ទៅកាន់ទីបំផុត ដល់ទីបំផុត ទៅកាន់ទីខាងចុង ដល់ទីខាងចុង ទៅកាន់ទីបំផុតជុំវិញ ដល់ទីបំផុតជុំវិញ ទៅកាន់ទីចុងបំផុត ដល់ទីចុងបំផុត ទៅកាន់ទីជាទីពឹង ដល់ទីជាទីពឹង ទៅកាន់ទីជាទីពួន ដល់ទីជាទីពួន ទៅកាន់ទីជាទីប្រព្រឹត្ត ដល់ទីជាទីប្រព្រឹត្ត ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីទៀងទាត់ ដល់ទីទៀងទាត់ ទៅកាន់ទីមិនស្ងាប់ ដល់ទីមិនស្ងាប់ ទៅកាន់ព្រះនិព្វាន ដល់ព្រះនិព្វាន ព្រះមានព្រះភាគនោះ ទើបឈ្មោះថា ជាបុគ្គលមានអរិយវាសៈនៅរួចហើយ មានចរណធម៌សន្សំហើយ ។ បេ ។ ភពថ្មី គឺជាតិ ជរា និងមរណៈ សង្ខារ របស់ព្រះមានព្រះភាគនោះ មិនមាន ហេតុនោះ (លោកពោលថា) ដល់ត្រើយនៃធម៌ទាំងពួង ។

[ថ] ពាក្យថា ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នាទើបមកគាល់ សេចក្ដីថា ពួកខ្ញុំព្រះអង្គត្រូវការដោយប្រស្នាទើបមក ជាអ្នកសួរប្រស្នាទើបមក ចង់ស្ដាប់ប្រស្នាទើបមក ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នាទើបមកគាល់ យ៉ាងនេះក៏បាន ។ មួយទៀត ការមក ការចូលមក ការចូលមកគាល់ របស់ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ជាអ្នកសួរប្រស្នា ចង់ស្ដាប់ប្រស្នា ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នាទើបមក យ៉ាងនេះក៏បាន ។

៧

អថវា បញ្ហាគមោ តុយ្ហំ អត្ថិ ត្វម្បិ[១] បហុ វិសវី អលមត្តោ មយា សទ្ធឹ បុច្ឆិតុំ កថេតុំ វិសជ្ជេតុំ សន្ទស្សេតុំ ភណិតុន្តិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។

[៦] អញ្ញាវិមោក្ខំ បព្រូហីតិ អញ្ញាវិមោក្ខោ វុច្ចតិ អរហត្តវិមោក្ខោ ។ អរហត្តវិមោក្ខំ បព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ អញ្ញាវិមោក្ខំ បព្រូហិ ។

[៧] អវិជ្ជាយ បភេទនន្តិ អវិជ្ជាយ ភេទនំ បភេ-ទនំ បហានំ វូបសមំ បដិនិស្សគ្គោ បដិប្បស្សទ្ធិ អមតំ និព្វានន្តិ អវិជ្ជាយ បភេទនំ ។ តេនាហ សោ ព្រាហ្មណោ

ឈាយឹ វិរជមាសីនំ (ឥច្ចាយស្មា ឧទយោ)
កតកិច្ចំ អនាសវំ
បារគុំ សព្វធម្មានំ
អត្ថិ បញ្ហេន អាគមំ
អញ្ញាវិមោក្ខំ បព្រូហិ
អវិជ្ជាយ បភេទនន្តិ ។

១ ម. ឯត្ថន្តរេ បារគូតិ ទិស្សតិ ។

ឬថា ការមកដោយប្រស្នាមានដល់ព្រះអង្គ ។ ជាបុគ្គលអាច ជាបុគ្គលមានព្យាយាម ជាបុគ្គលល្មមដើម្បីសួរ សម្តែង ដោះស្រាយ ពន្យល់ពោល ជាមួយនឹងខ្ញុំព្រះអង្គ ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នាទើបមក យ៉ាងនេះក៏បាន ។

[៦] ពាក្យថា សូមព្រះអង្គសម្តែងអញ្ញាវិមោក្ខ សេចក្តីថា អរ-ហត្តវិមោក្ខ លោកហៅថា អញ្ញាវិមោក្ខ ។ សូមព្រះអង្គសម្តែង ប្រាប់ ពន្យល់ ប្រញ័ប្ត តាំងផ្តើម បើក ចែកធ្វើឲ្យងាយ ប្រកាស នូវអរហត្តវិមោក្ខ ហេតុនោះ (លោកពោលថា) សូមព្រះអង្គសម្តែងអញ្ញាវិមោក្ខ ។

[៧] ពាក្យថា ជាគ្រឿងទម្វាយអវិជ្ជា គឺជាគ្រឿងបំបែក ទម្វាយ លះបង់ រម្ងាប់ លះចោល កម្ចាត់បង់នូវអវិជ្ជា គឺអមតនិព្វាន ហេតុនោះ (លោកពោលថា) ជាគ្រឿងទម្វាយអវិជ្ជា ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលហើយថា

> (ឧទយៈមានអាយុក្រាបទូលដូច្នេះថា) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នាទើបមកគាល់ (ដើម្បីសួរ) ព្រះអង្គជាអ្នកមានឈាន មានព្រះសន្ដានប្រាសចាកធូលី ទ្រង់គង់នៅ ទ្រង់មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង សូមព្រះអង្គសម្តែងអញ្ញាវិមោក្ខជាគ្រឿងទម្វាយអវិជ្ជា ។

[៨] បហានំ កាមឆន្ទានំ (ឧទយាតិ ភគវា)
ទោមនស្សាន ចូភយំ
ថីនស្ស ច បនូទនំ
កុក្កុច្ចានំ និវារណំ ។

[៩] បហានំ កាមឆន្ទានន្តិ ឆន្ទាតិ យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាមនន្ទិ កាមតណ្ហា កាមសិនេហោ កាមបិបាសា កាមបរិឡាហោ កាមមុច្ឆា កាមជ្ឈោសានំ កាមោឃោ កាមយោគោ កាមុបាទានំ កាមច្ឆន្ទនីវរណំ ។ បហានំ កាមឆន្ទានន្តិ កាមច្ឆន្ទានំ បហានំ វូបសមោ បដិនិស្សគ្គោ បដិប្បស្សទ្ធិ អមតំ និព្វានន្តិ បហានំ កាមឆន្ទានំ ។ ឧទយាតិ ភគវាតិ ឧទយាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ឧទយាតិ ភគវា ។

[៨] (ព្រះមានព្រះភាគត្រាស់ថា) ម្នាលឧទយៈ តថាគត សម្តែងថា ការលះនូវអកុសលធម៌ទាំងពីរ គឺកាមច្ឆន្ទៈនិង ទោមនស្សផង ការបន្ទោបង់ចិត្តរួញរាផង ការហាមឃាត់ កុក្កុច្ចៈទាំងឡាយផង (ជាអញ្ញាវិមោក្ខ) ។

[៩] ពាក្យថា ការលះកាមច្ឆន្ទៈ ត្រង់ពាក្យថា ឆន្ទៈ បានដល់សេចក្តីពេញចិត្តចំពោះកាម សេចក្តីត្រេកត្រអាលចំពោះកាម សេចក្តីរីករាយចំពោះកាម សេចក្តីប្រាថ្នាក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីស្រេកឃ្លានក្នុងកាម សេចក្តីអន្ទះអន្ទែងក្នុងកាម សេចក្តីជ្រប់ចុះក្នុងកាម សេចក្តីងប់ក្នុងកាម ឱឃៈគឺកាម យោគៈគឺកាម ឧបាទានគឺកាម នីវរណៈគឺកាមឆន្ទៈ ក្នុងកាមទាំងឡាយ ។ ពាក្យថា ការលះកាមច្ឆន្ទៈ គឺការលះ ការរម្ងាប់ ការលះបង់ ការកម្ចាត់បង់កាមច្ឆន្ទៈ អមតនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ការលះកាមច្ឆន្ទៈ ។ ពាក្យថា ឧទយៈ ក្នុងបទថា ព្រះមានព្រះភាគ (ត្រាស់ថា) ម្នាលឧទយៈ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះដោយឈ្មោះ ។ ត្រង់ពាក្យថា ព្រះមានព្រះភាគនុ៎ះ ជាពាក្យនិយាយដោយគោរព ។ បេ ។ បញ្ញត្តិថា មានព្រះភាគ នេះ (កើត) ព្រោះការត្រាស់ដឹង ហេតុនោះ (ទើបមានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលឧទយៈ ។

[១០] ឣោមនស្ឆាន ចូភយន្តិ ឣោមនស្ឆាតិ យំ ចេតសិកំ អសាតំ ចេតសិកំ ទុក្ខំ ចេតោសមួស្ឆជំ អសាតំ ទុក្ខំ វេទយិតំ ចេតោសមួស្ឆជា អសាតា ទុក្ខា វេទនា ។ ឣោមនស្ឆាន ចូភយន្តិ កាមច្ឆន្ទស្ឆ ច ឣោមនស្ឆស្ឆ ច ឆកិន្ទំ បហានំ រូបសមោ បដិនិស្ឆក្តោ បដិប្ឆស្ឆទ្ធិ អមតំ និព្ឆ-ឣន្តិ ឣោមនស្ឆាន ចូភយំ ។

[១១] ថីនស្ឆ ច បន្ទ្ធនន្តិ យា ចិត្តស្ឆ ឣ-ឣកល្ទតា ឣកម្ម្ឆញ្ញតា ឆិលីយនា សល្ទីយនា លីនំ លីយនា លីយិតត្តំ ថីនំ ថីយនា ថីយិតត្តំ ។ ថីនស្ឆ ច បន្ទ្ធនន្តិ ថីនស្ឆ ច បន្ទ្ធនំ បហានំ រូបសមោ បដិនិស្ឆក្តោ បដិប្ឆស្ឆទ្ធិ អមតំ និព្ឆ្ឆនន្តិ ថីនស្ឆ ច បន្ទ្ធនំ ។

[១២] ឣុក្ឆ្ចុ ច្ឆ្ចានំ និវារណន្តិ ឣុក្ឆ្ចុ ច្ឆ្ចានន្តិ ហត្ថឣុក្ឆ្ចូ ចូ ឣ្ឆ ឣុក្ឆ្ចុ ចំ ចាឣឣុក្ឆ្ចូ ចូ ឣ្ឆ ឣុ-ក្ឆ្ចុ ចំ ហត្ថចាឣឣុក្ឆ្ចូ ចូ ឣ្ឆ ឣុ-ក្ឆ្ចុ ចំ ឣ-ឣ-ប្ឆ្ឆ- យ-ឣ-ប-ប-ឆ-ឆ-ញ-ញ-ត-ឣ-ប-ប- យ-ឣ-ប-ប-ឆ-ឆ-ញ-ញ-ត-

ឧទយមាណវកប្បញ្ហានិទ្ទេស

[១០] *ពាក្យថា ការលះបង់នូវអកុសលធម៌ទាំងពីរ គឺទោមនស្ស ត្រង់ពាក្យថា ទោមនស្ស បានដល់ចេតសិកដែលមិនជាទីត្រេកអរ ចេតសិកជាទុក្ខ ការទទួលអារម្មណ៍មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីសម្ផស្សនៃចិត្ត គឺវេទនាមិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីសម្ផស្សនៃចិត្ត ។ ពាក្យថា ការលះនូវអកុសលធម៌ទាំងពីរ គឺទោមនស្ស បានសេចក្តីថា ការលះ ការរម្ងាប់ ការលះបង់ ការកម្ចាត់បង់ នូវអកុសលធម៌ទាំង ២ គឺកាមច្ឆន្ទៈ និងទោមនស្ស (ដោយចំពោះ) អមតនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ការលះនូវអកុសលធម៌ទាំងពីរ គឺពួកទោមនស្ស ។*

[១១] *ពាក្យថា ការបន្ទោបង់ចិត្តរួញរា បានដល់ភាពនៃចិត្តមិនស្រួល មិនគួរដល់ការងារ កិរិយារួញ ការរួញរា ការក្រាញ អាការនៃការក្រាញ ភាពនៃការក្រាញ ការច្រអូស អាការនៃការច្រអូស ភាពនៃការច្រអូស ។ ពាក្យថា ការបន្ទោបង់ចិត្តរួញរា គឺការបន្ទោបង់ ការលះបង់ ការរម្ងាប់ ការលះចោល ការសូន្យរម្ងាប់ចិត្តរួញរា (ដោយចំពោះ) អមតនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ការបន្ទោបង់ចិត្តរួញរា ។*

[១២] *ពាក្យថា កុក្កុច្ចៈទាំងឡាយ ក្នុងបទថា ការហាមឃាត់កុក្កុច្ចៈទាំងឡាយ បានដល់ ការពឹងដៃ ហៅថាកុក្កុច្ចៈក៏បាន ការពឹងជើងហៅថាកុក្កុច្ចៈក៏បាន ការពឹងទាំងដៃទាំងជើង ហៅថា កុក្កុច្ចៈក៏បាន សេចក្តីសម្គាល់ថាគួរ ក្នុងរបស់ដែលមិនគួរ សម្គាល់ថាមិនគួរ ក្នុងរបស់ដែលគួរ*

វេជ្ជេ អវេជ្ជសញ្ញិតា អវេជ្ជេ វេជ្ជសញ្ញិតា យំ ឯវរូបំ កុក្កុច្ចំ កុក្កុច្ចាយនា កុក្កុច្ចាយិតត្តំ ចេតសោ វិប្បដិសារោ មនោវិលេខោ ឥទំ វុច្ចតិ កុក្កុច្ចំ ។ អបិច ទ្វីហិ ការណេហិ ឧប្បជ្ជតិ កុក្កុច្ចំ ចេ-តសោ វិប្បដិសារោ មនោវិលេខោ កតត្តា ច អកតត្តា ច ។ កថំ កតត្តា ច អកតត្តា ច ឧ-ប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេ-ខោ ។ កតំ មេ កាយទុច្ចរិតំ អកតំ មេ កាយ-សុចរិតន្តិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ កតំ មេ វចីទុច្ចរិតំ អកតំ មេ វចីសុចរិតន្តិ កតំ មេ មនោទុច្ចរិតំ អកតំ មេ មនោសុចរិតន្តិ កតោ មេ បាណាតិបាតោ អកតា មេ បាណាតិបាតា វេរមណីតិ កតំ មេ អទិន្នាទានំ អកតា មេ អទិន្នាទានា វេរ-មណីតិ កតោ មេ កាមេសុ មិច្ឆាចារោ អកតា មេ កាមេសុ មិច្ឆាចារា វេរមណីតិ កតោ មេ មុសាវាទោ អកតា មេ មុសាវាទា វេរមណីតិ

សេចក្តីសម្គាល់ថាមិនមានទោសក្នុងរបស់ដែលមានទោស សេចក្តីសម្គាល់ថាមានទោសក្នុងរបស់ដែលមិនមានទោស សេចក្តីរពឹស អាការនៃការប្រ-ព្រឹត្តរពឹស ភាពនៃការប្រព្រឹត្តរពិស សេចក្តីក្តៅក្រហាយចិត្ត គំនូសនៃចិត្ត ណា មានសភាពយ៉ាងនេះ នេះលោកហៅថាកុក្កុច្ច: ។ មួយទៀត សេច-ក្តីរពឹស សេចក្តីក្តៅក្រហាយចិត្ត គំនូសនៃចិត្ត តែងកើតដោយហេតុ ពីរ គឺ ព្រោះភាពនៃការធ្វើ ១ ព្រោះភាពនៃការមិនធ្វើ ១ ។ ចុះសេចក្តី រពឹស សេចក្តីក្តៅក្រហាយចិត្ត គំនូសនៃចិត្ត កើតព្រោះភាពនៃការ ធ្វើ ១ ព្រោះភាពនៃការមិនធ្វើ ១ តើដូចម្តេច ។ សេចក្តីរពឹស សេចក្តី ក្តៅក្រហាយចិត្ត គំនូសនៃចិត្ត កើតឡើងដោយគំនិតដូច្នេះថា កាយ-ទុច្ចរិត អាត្មាអញបានធ្វើ កាយសុចរិត អាត្មាអញមិនបានធ្វើឡើយ ។ សេចក្តីរពឹស សេចក្តីក្តៅក្រហាយចិត្ត គំនូសនៃចិត្ត កើតឡើងដោយ គំនិតដូច្នេះ ថា វចីទុច្ចរិតអាត្មាអញបានធ្វើ វចីសុចរិតអាត្មាអញមិនបានធ្វើ ឡើយ ថា មនោទុច្ចរិត អាត្មាអញបានធ្វើ មនោសុចរិត អាត្មាអញមិនបាន ធ្វើឡើយ ថា បាណាតិបាត អាត្មាអញបានធ្វើ ការវៀរចាកបាណាតិបាត អាត្មាអញមិនបានធ្វើឡើយ ថា អទិន្នាទាន អាត្មាអញបានធ្វើ ការវៀរចាក អទិន្នាទាន អាត្មាអញមិនបានធ្វើឡើយ ថា កាមេសុមិច្ឆាចារ អាត្មាអញ បានធ្វើ ការវៀរចាកកាមេសុមិច្ឆាចារ អាត្មាអញមិនបានធ្វើឡើយ ថា មុសា-វាទអាត្មាអញបានធ្វើ ការវៀរចាកមុសាវាទ អាត្មាអញមិនបានធ្វើឡើយ

ឧទយមាណវកប្បញ្ហានិទ្ទេសោ

កតា មេ បិសុណា វាចា អកតា មេ បិសុណាយ
វាចាយ វេរមណីតិ កតា មេ ផរុសា វាចា អកតា
មេ ផរុសាយ វាចាយ វេរមណីតិ កតោ មេ សម្ផ្ប-
លាបោ អកតា មេ សម្ផ្ប លាបា វេរមណីតិ កតា
មេ អភិជ្ឌា អកតា មេ អនភិជ្ឌាតិ កតោ មេ ព្យ-
ាបាទោ អកតោ មេ អព្យាបាទោតិ កតា មេ មិច្ឆ-
ាទិដ្ឋិ អកតា មេ សម្មាទិដ្ឋីតិ ឧប្បជ្ជតិ កុក្ក្ចំ ចេត-
សោ វិប្ប ដិសារោ មនោវិលេខោ ។ ឯវំ កតត្តា ច
អកតត្តា ច ឧប្បជ្ជតិ កុក្ក្ចំ ចេតសោ វិប្ប ដិសារោ
មនោវិលេខោ ។ អថវា សីលេសុម្ហិ អបរិបូរិការីតិ
ឧប្បជ្ជតិ កុក្ក្ចំ ចេតសោ វិប្ប ដិសារោ មនោវិលេ-
ខោ ។ ឥន្ទ្រិយេសុម្ហិ អគុត្តទ្វារោតិ ភោជនេ អមត្តញ្ញ-
ម្ហីតិ ជាគរិយមនុយុត្តោម្ហីតិ ន សតិសម្ប ជញ្ញេន ស-
មន្នាគតោម្ហីតិ អការិតា មេ ចត្តារោ សតិប្ប ដ្ឋានាតិ
អការិតា មេ ចត្តារោ សម្ម ប្ប ធានាតិ អការិតា មេ
ចត្តារោ ឥទ្ធិ ចាធានាតិ អការិតានិ មេ បញ្ចិ ន្ទ្រិ យានីតិ

ថា បិសុណវាចា អាត្មាអញបានធ្វើ ការវៀរចាកបិសុណវាចា អាត្មាអញមិនបានធ្វើឡើយ ថា ផរុសវាចា អាត្មាអញបានធ្វើ ការវៀរចាកផរុសវាចា អាត្មាអញមិនបានធ្វើឡើយ ថា សម្ផប្បលាបៈ អាត្មាអញបានធ្វើ ការវៀរចាកសម្ផប្បលាបៈ អាត្មាអញមិនបានធ្វើឡើយ ថា អភិជ្ឌា អាត្មាអញបានធ្វើ ការមិនមានអភិជ្ឌា អាត្មាអញមិនបានធ្វើឡើយ ថា ព្យាបាទ អាត្មាអញបានធ្វើ ការមិនព្យាបាទ អាត្មាអញមិនបានធ្វើឡើយ ថា មិច្ឆាទិដ្ឋិអាត្មាអញបានធ្វើ សម្មាទិដ្ឋិ អាត្មាអញមិនបានធ្វើឡើយ ។ សេចក្តីរពឹស សេចក្តីក្តៅក្រហាយចិត្ត គំនូសនៃចិត្ត កើតឡើង ព្រោះភាពនៃការធ្វើ និងភាពនៃការមិនធ្វើ យ៉ាងនេះ ។ មួយទៀត សេចក្តីរពឹស ការក្តៅក្រហាយចិត្ត គំនូសនៃចិត្ត កើតឡើងដោយគំនិតដូច្នេះថា អាត្មាអញមិនបានបំពេញក្នុងសីលទាំង-ឡាយទេ ។ សេចក្តីរពឹស ការក្តៅក្រហាយចិត្ត គំនូសនៃចិត្តកើតឡើងដោយគំនិតដូច្នេះថា អាត្មាអញមិនបានគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ថា អាត្មាអញមិនដឹងប្រមាណក្នុងភោជនទេ ថា អាត្មាអញមិនបានប្រកបរឿយៗ នូវសេចក្តីភ្ញាក់រឭកទេ ថា អាត្មាអញមិនបានប្រកបដោយសតិ និងសម្បជញ្ញៈទេ ថា សតិប្បដ្ឋានទាំង ៤ អាត្មាអញមិនបានចម្រើនទេ ថា សម្មប្បធានទាំង៤អត្មាអញមិនបានចម្រើនទេ ថាឥទ្ធិបាទ ៤ អាត្មាអញមិនបានចម្រើនទេ ថា ឥន្ទ្រិយ ៥ អាត្មាអញមិនបានចម្រើនទេ

អភាវិតានិ មេ បញ្ច ពលានីតិ អភាវិតា មេ សត្ត ពោជ្ឌង្គាតិ អភាវិតោ មេ អរិយោ អដ្ឌង្គិកោ មគ្គោតិ ឧក្ខិ មេ អបរិញ្ញាតន្តិ សមុទយោ មេ អប្ប្ហីនោតិ មគ្គោ មេ អភាវិតោតិ និរោធោ មេ អសច្ឆិកតោតិ ឧប្ប ជ្ជតិ កុក្ក្ចំ ចេតសោ វិប្ប ដិសារោ មនោ-លេ-ខោ ។ កុក្ក្ចានំ និវារណន្តិ កុក្ក្ចានំ អារ-ណ្ណ និវារណ្ណ បហានំ រូបសមោ បដិនិស្ស គ្គោ ប-ដិ ប្ប ស្ស ទ្ធិ អមតំ និព្ជ ានន្តិ កុក្ក្ចានំ និវារណ្ណ ។ ត្ថ ជ ាហ ភ ត ។

បហានំ ការ ណ ន ្ជ ានំ (ឧ ឧ យ ាតិ ភ ត ។)

ន ោ ម ន ស ្ជ ាន ចូ ភ យ ំ

ថ ីន ស ្ជ ។ ច ។ ប ន ្ធ ន ំ

ក ុ ក ្ក ្ជ ានំ ន ិ ។ ណ ន ្ត ិ ។

[១៣] ឧ ប េ ក ្ខ ា ស ត ិ ស ំ ស ុ ទ ្ធ ំ ធ ម ្ម ត ណ ្ណ ប ុ ជ ។

អ ញ ្ញ ា ណ ។ ម ោ ក ្ខ ំ ។ ស ំ ព ្ជ ូ ម ិ ។ អ ។ ិ ជ ្ជ ា យ ។ ប ។ ភ ។ ធ ន ំ ។

ថា ពលៈ ៥ អាត្មាអញមិនបានចម្រើនទេ ថា ពោជ្ឌង្គ៧ទាំង ៧ អាត្មាអញមិនបានចម្រើនទេ ថា មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ អាត្មាអញមិនបានចម្រើនទេ ថា ទុក្ខ អាត្មាអញមិនបានកំណត់ដឹងទេ ថា សមុទ័យ អាត្មាអញមិនបានលះបង់ទេ ថា មគ្គ អាត្មាអញ មិនបានចម្រើនទេ ថា និរោធ អាត្មាអញមិនបានធ្វើឲ្យជាក់ច្បាស់ទេ ។ ពាក្យថា ការហាមឃាត់កុក្កុច្ចៈទាំងឡាយ បានន័យថា ការទប់ ការរារាំង ការលះ ការរម្ងាប់ ការលះចោល ការសូប់រម្ងាប់កុក្កុច្ចៈ (ដើមចំពោះ) អមតនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ការហាមឃាត់កុក្កុច្ចៈទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលឧទយៈតថាគតសម្តែងថា) ការលះនូវអកុសលធម៌ទាំង ២ គឺ កាមច្ឆន្ទៈ និងទោមនស្សផង ការបន្ទោបង់ចិត្តរួញរាផង ការហាមឃាត់កុក្កុច្ចៈទាំងឡាយផង (ជាអញ្ញាវិមោក្ខ) ។

[១៣] មួយទៀត តថាគតសម្តែង នូវឧបេក្ខានិងសតិ ដ៏បរិសុទ្ធ នូវការត្រិះរិះធម៌ស្ទុះទៅមុន ថាជាអញ្ញាវិមោក្ខ ជាគ្រឿងទម្លាយអវិជ្ជា ។

ឧទយមាណវកប្បញ្ហានិទ្ទេសោ

[១៤] ឧបេក្ខាសតិសំសុទ្ធន្តិ ឧបេក្ខាតិ យា ចតុត្ថជ្ឈានេ ឧបេក្ខា ឧបេក្ខនា អជ្ឈុបេក្ខនា ចិត្ត-សមថោ ចិត្តប្បសាទតា មជ្ឈត្តតា ចិត្តស្ស ។ សតីតិ យា ចតុត្ថជ្ឈានេ ឧបេក្ខំ អារព្ភ សតិ អនុស្សតិ ។ បេ ។ សម្មាសតីតិ ឧបេក្ខាសតិ ។ សំសុទ្ធន្តិ ចតុត្ថជ្ឈានេ ឧបេក្ខា ច សតិ ច សុទ្ធា ហោន្តិ សំសុទ្ធា បរិយោទាតា អនង្គណា វិគតុ-បក្កិលេសា មុទុភូតា កម្មនិយា ឋិតា អានេញ្ជ-ប្បត្តាតិ ឧបេក្ខាសតិសំសុទ្ធំ ។

[១៥] ឆម្មតក្ខត្តុបរេជវន្តិ ឆម្មតក្ខោ រុច្ចតិ សម្មាសង្ខប្ប ។ សោ អាទិតោ ហោតិ បុរតោ ហោតិ បុព្ពង្ខណោ ហោតិ អញ្ញាវិមោក្ខស្ស្ចតិ ឯវម្ឆ ឆម្មតក្ខត្តុបរេជវំ ។ អថវា ឆម្មតក្ខោ រុច្ចតិ សម្មាទិដ្ឋិ ។ សា អាទិតោ ហោតិ បុរតោ ហោតិ បុព្ពង្ខណ ហោតិ អញ្ញាវិមោក្ខស្ស្ចតិ ឯវម្ឆ ឆម្មតក្ខត្តុបរេជវំ ។ អថវា ឆម្មតក្ខោ រុច្ចតិ ចតុន្នំ មគ្គានំ បុព្ពភាគេ ១ិបស្ស្ចនា ។

ឧទយមាណរកប្បញ្ហានិទ្ទេស

[១៤] *ពាក្យថា ឧបេក្ខា ក្នុងបទថា ឧបេក្ខា និងសតិដ៏បរិសុទ្ធ បានដល់ការព្រងើយ អាការព្រងើយ អាការនៃចិត្តសោះអង្គើយ ការសូប់ចិត្ត សេចក្តីថ្វាស្អាតនៃចិត្ត ភាពនៃចិត្តជាកណ្តាល ក្នុងចតុត្ថជ្ឌាន ។ ពាក្យថា សតិ បានដល់ស្មារតី ការរលឹករឿយៗ ។ បេ ។ ការរលឹកដោយប្រពៃ ប្រារព្ធឧបេក្ខា ក្នុងចតុត្ថជ្ឌាន ហេតុនោះ (ទ្រង់ត្រាស់ថា) ឧបេក្ខានិងសតិ ។ ពាក្យថា បរិសុទ្ធ បានដល់ឧបេក្ខា និងសតិក្នុងចតុត្ថជ្ឌាន ជាធម្មជាតិដ៏ស្អាត ស្អាតព្រម ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្លិលេស ជាធម្មជាតិទន់ភ្ងន់ គួរដល់ការងារ ជាធម្មជាតិនឹងធឹង ដល់នូវការមិនកម្រើក ហេតុនោះ (ទ្រង់ត្រាស់ថា) ឧបេក្ខា និងសតិ ដ៏បរិសុទ្ធ ។*

[១៥] *ពាក្យថា ការត្រិះរិះធម៌ស្ទុះទៅមុន សេចក្តីថា សម្ម-សង្កប្ប: លោកហៅថា ការត្រិះរិះធម៌ ។ សម្មាសង្កប្ប:នោះ ជាខាងដើម ជាខាងមុខ ជាប្រធាន នៃអញ្ញាវិមោក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) ការត្រិះរិះធម៌ស្ទុះទៅមុន យ៉ាងនេះក៏បាន ។ មួយទៀត សម្មាទិដ្ឋិ លោកហៅថា ការត្រិះរិះធម៌ ។ សម្មាទិដ្ឋិនោះ ជាខាងដើម ជាខាងមុខ ជាប្រធាន នៃអញ្ញាវិមោក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) ការត្រិះរិះធម៌ស្ទុះទៅមុន យ៉ាងនេះក៏បាន ។ ឬថា វិបស្សនា ក្នុងចំណែកខាងដើមនៃមគ្គទាំង ៤ លោកហៅថា ការត្រិះរិះធម៌ ។*

សា អាចិតោ ហោតិ បុរតោ ហោតិ បុព្វង្គមា ហោតិ អញ្ញាវិមោក្ខស្សាតិ ឯវម្បិ ធម្មតក្កបុរេជវំ ។

[១៦] អញ្ញាវិមោក្ខំ សំព្រូមីតិ អញ្ញាវិមោក្ខោ វុច្ចតិ អរហត្តវិមោក្ខោ ។ អរហត្តវិមោក្ខំ សំព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមីតិ អញ្ញាវិមោក្ខំ សំព្រូមិ ។

[១៧] អវិជ្ជាយ បភេទនន្តិ អវិជ្ជាយាតិ ទុក្ខេ អញ្ញាណំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ ។ អវិជ្ជាយ បភេទនន្តិ អវិជ្ជាយ ភេទនំ បភេទនំ បហានំ វូបសមោ បដិនិស្សគ្គោ បដិប្បស្សទ្ធិ អមតំ និព្វានន្តិ អវិជ្ជាយ បភេទនំ ។ តេនាហ ភគវា

ឧបេក្ខាសតិសំសុទ្ធំ ធម្មតក្កបុរេជវំ
អញ្ញាវិមោក្ខំ សំព្រូមិ អវិជ្ជាយ បភេទនន្តិ ។

[១៨]កឹសុ សញ្ញោជនោ លោកោ កឹសុ តស្ស វិចារណំ
កិស្សស្ស[១] វិប្បហានេន និព្វានំ ឥតិ វុច្ចតិ ។

---

១ ម. កឹ យស្ស ។

វិបស្សនានោះ ជាខាងដើម ជាខាងមុខ ជាប្រធាន នៃអញ្ញាវិមោក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) ការត្រិះរិះធម៌ស្ទុះទៅមុន យ៉ាងនេះ ក៏បាន ។

[១៦] *ពាក្យថា តថាគតសម្តែងថា អញ្ញាវិមោក្ខ គឺ អរហត្តវិមោក្ខ លោកហៅថា អញ្ញាវិមោក្ខ តថាគតពោលដោយប្រពៃ ប្រាប់ សម្តែង ប្រញ័ប្ត តាំងផ្តើម បើក រៃកញ្ជែក ធ្វើឲ្យងាយនូវអរហត្តវិមោក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតសម្តែងថា អញ្ញាវិមោក្ខ ។*

[១៧] *ពាក្យថា អវិជ្ជា ក្នុងបទថា ជាគ្រឿងទម្ងាយអវិជ្ជា បានដល់ ការមិនដឹងក្នុងទុក្ខ ។ បេ ។ គន្ធ:គឺអវិជ្ជា មោហ: អកុសលមូល ។ ពាក្យ ថា ជាគ្រឿងទម្ងាយអវិជ្ជា បានន័យថា ការបំបែក ការទម្ងាយ ការលះ ការ រម្ងាប់ ការលះចោល ការកម្ចាត់បង់នូវអវិជ្ជា គឺអមតនិព្វាន ហេតុនោះ (ទ្រង់ ត្រាស់ថា) ជាគ្រឿងទម្ងាយអវិជ្ជា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា*

> *(មួយទៀត) តថាគតសម្តែង នូវឧបេក្ខានិងសតិ ដ៏ បរិសុទ្ធ នូវការត្រិះរិះធម៌ស្ទុះទៅមុន ថាជាអញ្ញាវិមោក្ខ ជាគ្រឿងទម្ងាយអវិជ្ជា ។*

[១៨] *(ឧទយមាណពទូលសួរថា) សត្វលោកមានអ្វីជាគ្រឿង ចងទុក អ្វីជាគ្រឿងត្រាច់ទៅ របស់សត្វលោកនោះ ដែលលោកពោលថា និព្វាន តើព្រោះការលះអ្វីបាន ។*

ឧទយមាណវកប្បញ្ហានិទ្ទេសោ

[១៩] កឹសុ សញ្ញោជនោ លោកោតិ កឹ លោកស្ស សញ្ញោជនំ លត្តនំ ពន្ធនំ ឧបក្លិលេ-សោ កេន លោកោ យុត្តោ បយុត្តោ អាយុត្តោ សមាយុត្តោ លគ្គោ លគ្គិតោ បលិពុជ្ឌោតិ កឹសុ សញ្ញោជនោ លោកោ ។

[២០] កឹសុ តស្ស វិចារណន្តិ កឹ តស្ស ចារណំ វិចារណំ បដិវិចារណំ កេន លោកោ ចរតិ វិចរតិ បដិវិចរតីតិ កឹសុ តស្ស វិចារណំ ។

[២១] កិស្សស្ស វិប្ផហានេន និព្ពានំ ឥតិ វុច្ចតីតិ កិស្សស្ស វិប្ផហានេន រូបសមេន បដិ-និស្សគ្គេន បដិប្ផស្សទ្ធិយា និព្ពានំ ឥតិ វុច្ចតិ បវុច្ចតិ ឥជ្ឌិយតិ ឥណ្ឌិយតិ ឧីបិយតិ ហេមារិយតីតិ កិស្សស្ស វិប្ផហានេន និព្ពានំ ឥតិ វុច្ចតិ ។ ឥតោ ហ សោ ព្រាហ្មណោ

កឹសុ សញ្ញោជនោ លោកោ កឹសុ តស្ស វិចារណំ
កិស្សស្ស វិប្ផហានេន និព្ពានំ ឥតិ វុច្ចតីតិ ។

ឧទយមាណរកប្បញ្ហានិទ្ទេស

[១៩] ពាក្យថា សត្វលោកមានអ្វីជាគ្រឿងចងទុក គឺអ្វីជាគ្រឿងប្រកបព្រម ជាគ្រឿងជាប់ ជាចំណង ជាឧបក្ខិលេសនៃសត្វលោក គឺថា សត្វលោកប្រកប ប្រកបសព្វ ប្រកបទួទៅ ផ្សំ ជាប់ ទាក់ ចំពាក់ ដោយអ្វី ហេតុនោះ (លោកសួរថា) សត្វលោកមានអ្វីជាគ្រឿងប្រកបព្រម ។

[២០] ពាក្យថា អ្វីជាគ្រឿងត្រាច់ទៅរបស់សត្វលោកនោះ គឺអ្វីជាគ្រឿងដើរ ត្រាច់ទៅ ត្រាច់រង្គាត់របស់សត្វលោកនោះ គឺថា សត្វលោកដើរ ត្រាច់ទៅ ត្រាច់រង្គាត់ដោយអ្វី ហេតុនោះ (លោកសួរថា) អ្វីជាគ្រឿងត្រាច់ទៅ របស់សត្វលោកនោះ ។

[២១] ពាក្យថា ដែលលោកពោលថានិព្វាន តើព្រោះការលះអ្វីបាន គឺដែលលោកហៅ ពោល ថ្លែង សម្តែង ពន្យល់ថានិព្វាន តើដោយការលះ ការរម្ងាប់ ការរលាស់ចោល ការសូន្យរម្ងាប់នូវអ្វី ហេតុនោះ (លោកសួរថា) ដែលលោកពោលថា និព្វាន តើព្រោះការលះអ្វីបាន ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

> សត្វលោកមានអ្វីជាគ្រឿងចងទុក អ្វីជាគ្រឿងត្រាច់ទៅ
> របស់សត្វលោកនោះ ដែលលោកពោលថា និព្វាន តើ
> ព្រោះការលះអ្វីបាន ។

[២២]ឆន្ទិសញ្ញោជនោ លោកោ វិតក្កស្ស វិចារណា

តណ្ហាយ វិប្បហានេន និព្វានំ ឥតិ វុច្ចតិ ។

[២៣] ឆន្ទិសញ្ញោជនោ លោកោតិ ឆន្ទិ វុច្ចតិ

តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ

អកុសលមូលំ ។ យា ឆន្ទិ លោកស្ស សញ្ញោជនំ

លគ្គនំ ពន្ធនំ ឧបក្កិលេសោ ឥមាយ ឆន្ទិយា លោ-

កោ យុត្តោ បយុត្តោ អាយុត្តោ សមាយុត្តោ លគ្គោ

លគ្គិតោ បលិពុទ្ធោតិ ឆន្ទិសញ្ញោជនោ លោកោ ។

[២៤] វិតក្កស្ស វិចារណាតិ វិតក្កាតិ នវ វិតក្កា

កាមវិតក្កោ ព្យាបាទវិតក្កោ វិហឹសាវិតក្កោ ញាតិ-

វិតក្កោ ជនបទវិតក្កោ អមរវិតក្កោ បរានុទ្ទយតាបដិ-

សំយុត្តោ វិតក្កោ លាភសក្ការសិលោកប្បដិសំយុត្តោ

[២២] (ព្រះមានព្រះភាគត្រាស់ថា) *សត្វលោកមានសេចក្តីរីករាយជាគ្រឿងចងទុក សេចក្តីត្រិះរិះទាំងឡាយជាគ្រឿងត្រាច់ទៅរបស់សត្វលោកនោះ ដែលលោកពោលថា និព្វានព្រោះការលះតណ្ហាបាន ។*

[២៣] *ពាក្យថា សត្វលោក មានសេចក្តីរីករាយជាគ្រឿងចងទុក សេចក្តីថា តណ្ហា លោកហៅថា សេចក្តីរីករាយ បានខាងសេចក្តីត្រេកត្រអាល ការត្រេកត្រអាលខ្លាំង ។ បេ ។ ការសម្ងឹងរំពៃ (ទ្រព្យអ្នកដទៃ) លោភ: អកុសលមូល ។ សេចក្តីរីករាយណាដែលជាគ្រឿងប្រកបព្រមជាគ្រឿងជាប់ ជាគ្រឿងចង ជាឧបក្លិសនៃលោក សត្វលោកប្រកប ប្រកបសព្វ ប្រកបទូទៅ ផ្សំ ជាប់ ទាក់ ចំពាក់ ដោយសេចក្តីរីករាយនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) សត្វលោកមានសេចក្តីរីករាយជាគ្រឿងចងទុក ។*

[២២] *ពាក្យថា សេចក្តីត្រិះរិះទាំងឡាយ ក្នុងបទថា សេចក្តីត្រិះរិះទាំងឡាយ ជាគ្រឿងត្រាច់ទៅ របស់សត្វលោកនោះ បានដល់សេចក្តីត្រិះរិះ ៩ គឺ សេចក្តីត្រិះរិះក្នុងកាម សេចក្តីត្រិះរិះក្នុងព្យាបាទ សេចក្តីត្រិះរិះក្នុងវិហឹសា សេចក្តីត្រិះរិះក្នុងញាតិ សេចក្តីត្រិះរិះក្នុងជនបទ សេចក្តីត្រិះរិះក្នុងការមិនស្វាប់ សេចក្តីត្រិះរិះប្រកបចំពោះដោយភាពនៃសេចក្តីអាណិតដល់ជនដទៃ សេចក្តីត្រិះរិះប្រកបចំពោះដោយលាភសក្តារ: និងសេចក្តីសរសើរ*

វិតក្កោ អនវញ្ញត្តិប្បដិសំយុត្តោ វិតក្កោ ឥមេ រុច្ចន្តិ ឯវ វិតក្កា ។ ឥមេ ឯវ វិតក្កា អស្ស លោ-កស្ស ចារណា វិចារណា បដិវិចារណា ឥមេហិ ឯវហិ វិតក្កេហិ សោ លោកោ ចរតិ វិចរតិ បដិ-វិចរតីតិ វិតក្កស្ស វិចារណា ។

[២៥] តណ្ហាយ វិប្ផ្ផារានេន ជិញ្ជនំ ឥតិ រុច្ច-តីតិ តណ្ហាយាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្ពតណ្ហា ធម្មតណ្ហា ។ តណ្ហាយ វិប្ផ្ផារានេន ជិញ្ជនំ ឥតិ រុច្ចតីតិ តណ្ហាយ វិប្ផ-ផ្ផារានេន រូបសមេន បដិនិស្សគ្គេន បដិប្ផ្ផស្ស ជ្ជិយា ជិញ្ជនំ ឥតិ រុច្ចតិ បរុច្ចតិ ឆជ្ជិយតិ ឆណ្ណិយតិ ជីរិយតិ ហេមារិយតីតិ តណ្ហាយ វិប្ផ្ផារានេន ជិញ្ជ-នំ ឥតិ រុច្ចតិ ។ តេនាហ ភគវា

ជន្ទ្ធិ សញ្ញោជនោ លោកោ វិតក្កស្ស វិចារណា
តណ្ហាយ វិប្ផ្ផារានេន ជិញ្ជនំ ឥតិ រុច្ចតីតិ ។

[២៦] ឆជ្ជ សតស្ស ចរតោ វិញ្ញាណំ ឧបរុជ្ឌតិ
ភគវន្តំ បុដ្ឋមាគម្ម តំ សុណោម វចោ តវ ។

សេចក្ដីត្រិះរិះ ប្រកបដោយការមិនចង់ឲ្យគេមើលងាយ ទាំងនេះហៅថា សេចក្ដីត្រិះរិះ ៩ ។ សេចក្ដីត្រិះរិះទាំង ៩ នេះ ជាគ្រឿងដើរទៅ ត្រាច់ទៅ ត្រាច់រង្គាត់ទៅនៃសត្វលោកនោះ គឺថា សត្វលោកនោះដើរទៅ ត្រាច់ទៅ ត្រាច់រង្គាត់ទៅដោយសារសេចក្ដីត្រិះរិះ ៩ នេះ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្ដីត្រិះរិះទាំងឡាយ ជាគ្រឿងត្រាច់ទៅរបស់សត្វលោកនោះ ។

[២៥] ពាក្យថា តណ្ហា ក្នុងបទថា ដែលលោកពោលថា និព្វាន ព្រោះការលះបង់តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រស-តណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ដែលលោកពោលថា និព្វាន ព្រោះការលះបង់តណ្ហា គឺថាដែលលោក ហៅ ពោល ថ្លែង សម្ដែង បំភ្ញឹ ពន្យល់ ថានិព្វាន ព្រោះការលះ ការរម្ងាប់ ការរលាស់ចោល ការសូន្យរម្ងាប់ តណ្ហា ហេតុនោះ (ទ្រង់ត្រាស់ថា) ដែលលោកពោលថា និព្វាន ព្រោះការលះតណ្ហា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> *សត្វលោក មានសេចក្ដីរីករាយជាគ្រឿងចងទុក សេចក្ដីត្រិះរិះទាំងឡាយ ជាគ្រឿងត្រាច់ទៅរបស់សត្វលោកនោះ ដែលលោកហៅថា និព្វាន ព្រោះការលះតណ្ហាបាន ។*

[២៦] បុគ្គលមានស្មារតី ប្រព្រឹត្តទៅដូចម្ដេច វិញ្ញាណទើបរលត់ ពួកខ្ញុំព្រះអង្គមកគាល់ ដើម្បីទូលសួរព្រះមានព្រះភាគ នឹងបានស្ដាប់ព្រះពុទ្ធដីកា របស់ព្រះអង្គ ។

[២៧] កថំ សតស្ស ចរតោតិ កថំ សតស្ស សម្ឆជ្ជានស្ស ចរតោ វិចរតោ ឥរិយតោ វត្តយតោ ចាលយតោ យបយតោ យាបយតោតិ កថំ ស-តស្ស ចរតោ ។

[២៨] វិញ្ញាណំ ឧបរុជ្ឈតីតិ វិញ្ញាណំ ជិរុជ្ឈតិ រូបសម្ផតិ អត្តំ ឥច្ឆតិ បជិឃ្ឆស្ឆម្ភតីតិ វិញ្ញាណំ ឧបរុជ្ឈតិ ។

[២៩] ភវតណ្ហំ បុជ្ជមាកម្ហាតិ ពុទ្ធំ ភវតណ្ហំ បុជ្ជ-ំ បុច្ឆិតុំ យាចិតុំ អជ្ឈេសិតុំ បសាទេតុំ អាកម្ហា អាក-តម្ហា ឧចាកតម្ហា សម្ឆត្តម្ហា ឥយ សទ្ធ្ធ សមាក-តម្ហាតិ ភវតណ្ហំ បុជ្ជមាកម្ហា ។

[៣០] តំ សុណោម វចោ ឥវាតិ ឥន្ធ្ធ ឥយ្ហ-ំ ១ចនំ ១ឃ្ឆបចំ ១ទេសនំ អនុសន្ធ្ធ សុណោម ឧក្ក-ណ្ហាម ឧបជ្ជាវេម ឧបលក្ខ្ធមាតិ តំ សុណោម ១ចោ ១ឥ ។ ១ទ្ធជ្ជាហ ១សោ ១ព្រាហ្ម្ណណោ

[២៧] ពាក្យថា បុគ្គលមានស្មារតី ប្រព្រឹត្តទៅដូចម្តេច គឺបុគ្គលមានស្មារតី ដឹងព្រម ត្រាច់ទៅ ត្រាច់ទៅផ្សេង ៗ ដើរទៅ ប្រព្រឹត្តទៅ រក្សា យាត្រា យាត្រាទៅ ដូចម្តេច ហេតុនោះ (លោកសួរថា) បុគ្គលមានស្មារតី ប្រព្រឹត្តទៅ ដូចម្តេច ។

[២៨] ពាក្យថា វិញ្ញាណទើបរលត់ គឺវិញ្ញាណរលត់ សូប់ អស្តង្គត សូប់រម្ងាប់ ហេតុនោះ (លោកសួរថា) វិញ្ញាណទើបរលត់ ។

[២៩] ពាក្យថា ពួកខ្ញុំព្រះអង្គមកគាល់ ដើម្បីទូលសួរព្រះមានព្រះភាគ គឺ ពួកខ្ញុំព្រះអង្គ មក មកដល់ មកគាល់ ដល់ព្រម មកជួបជុំ ជាមួយនឹងព្រះអង្គ ដើម្បីទូលសួរ សាកសួរ អង្វរ អារាធនា ជ្រះថ្លា ចំពោះព្រះពុទ្ធមានជោគ ហេតុនោះ (លោកសួរថា) ពួកខ្ញុំព្រះអង្គមកគាល់ ដើម្បីទូលសួរព្រះមានព្រះភាគ ។

[៣០] ពាក្យថា ព្រះអង្គ ក្នុងបទថា នឹងបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គ គឺពួកខ្ញុំព្រះអង្គ ស្តាប់ រៀន ចងចាំទុក កំណត់ទុក នូវព្រះវាចា ការពោល ការសម្តែង អនុសន្ធិរបស់ព្រះអង្គ ហេតុនោះ (លោកសួរថា) នឹងបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

ឧទយមាណវកប្បញ្ហានិទ្ទេសោ

 កថំ សតស្ស ចរតោ វិញ្ញាណំ ឧបរុជ្ឌតិ

ភគវន្តំ បុដ្ឋមាគម្ម តំ សុណោម វចោ តវាតិ ។

[៣១] អជ្ឌត្តញ្ច ពហិទ្ធា ច វេទនំ ជានិយ ភិក្ខុ

ឯវំ សតស្ស ចរតោ វិញ្ញាណំ ឧបរុជ្ឌតិ ។

[៣២] អជ្ឌត្តញ្ច ពហិទ្ធា ច វេទនំ ជានិយ ភិក្ខុ

អជ្ឌត្តំ វេទនាសុ វេទនានុបស្សី វិហរន្តោ វេទនំ ជានិយ ភិក្ខុ ជានាតិ ន អជ្ឌោសាយ តិដ្ឌតិ អនិយ ភិក្ខុ អនិវេទនំ អជ្ឌោសានំ តាហំ ឧបាមាសំ អនិ-ជិវេសំ ឧជ្ឌហតិ វិនោទេតិ ព្យន្តីករោតិ អនភាវ ភ្លេ-តិ ។ ពហិទ្ធា វេទនាសុ វេទនានុបស្សី វិហរន្តោ វេទនំ ជានិយ ភិក្ខុ ជានាតិ ន អជ្ឌោសាយ តិដ្ឌតិ អនិ-ជ្ឌនំ អនិវេទនំ អជ្ឌោសានំ តាហំ ឧបាមាសំ អនិជិវេសំ ឧជ្ឌហតិ វិនោទេតិ ព្យន្តីករោតិ អនភាវ ភ្លេតិ ។

បុគ្គលមានស្មារតី ប្រព្រឹត្តទៅដូចម្តេច វិញ្ញាណទើប
រលត់ ពួកខ្ញុំព្រះអង្គមកគាល់ ដើម្បីទូលសួរព្រះមានព្រះ
ភាគ នឹងបានស្តាប់ព្រះពុទ្ធដីកា របស់ព្រះអង្គ ។

[៣១] *(ព្រះមានព្រះភាគត្រាស់ថា) កាលបុគ្គលមិនរីក*
រាយ ចំពោះវេទនាទាំងខាងក្នុងទាំងខាងក្រៅ មានស្មារតី
ប្រព្រឹត្តទៅ យ៉ាងនេះ វិញ្ញាណទើបរលត់ ។

[៣២] *អធិប្បាយពាក្យថា កាលបុគ្គលមិនរីករាយ ចំពោះវេទនា ទាំងខាងក្នុង ទាំងខាងក្រៅ គឺបុគ្គលកាលពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយខាងក្នុង មិនរីករាយ មិនសរសើរ មិនបិតនៅ ក្នុងសេចក្តីជ្រប់ចិត្ត ចំពោះវេទនា គឺថា លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ការកួចកាន់ ការស្នាបអង្អែល ការប្រកាន់ ។ បុគ្គលកាលពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយ ខាងក្រៅ មិនរីករាយ មិនសរសើរ មិនបិតនៅក្នុងការជ្រប់ចិត្ត ចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ការកួចកាន់ ការស្នាបអង្អែល ការប្រកាន់ ។*

អជ្ឈត្តពហិទ្ធា វេទនាសុ វេទនានុបស្សី វិហរន្តោ វេទនំ ជានិនន្ធតិ ជានិវនតិ ន អជ្ឈោសាយ តិដ្ឋតិ អកិនន្ធនំ អកិវនំ អជ្ឈោសានំ តាហំ បរាមាសំ អកិនិវេសំ បជហាតិ វិនោទេតិ ព្យន្ត្តីករោតិ អនភាវ ន្ត្តមេតិ ។ អជ្ឈត្តំ សមុទយធម្មានុបស្សី វេទនាសុ វិហរន្តោ អជ្ឈត្តំ វយធម្មានុបស្សី វេទនាសុ វិហរន្តោ អជ្ឈត្តំ សមុទយ-វយធម្មានុបស្សី វេទនាសុ វិហរន្តោ ពហិទ្ធា សមុទយ-ធម្មានុបស្សី វេទនាសុ វិហរន្តោ ពហិទ្ធា វយធម្ម-នុបស្សី វេទនាសុ វិហរន្តោ ពហិទ្ធា សមុទយវយធម្ម-នុបស្សី វេទនាសុ វិហរន្តោ អជ្ឈត្តពហិទ្ធា សមុទយ-ធម្មានុបស្សី វេទនាសុ វិហរន្តោ អជ្ឈត្តពហិទ្ធា វយ-ធម្មានុបស្សី វេទនាសុ វិហរន្តោ អជ្ឈត្តពហិទ្ធា សមុ-ទយវយធម្មានុបស្សី វេទនាសុ វិហរន្តោ វេទនំ ជានិ-នន្ធតិ ជានិវនតិ ន អជ្ឈោសាយ តិដ្ឋតិ អកិនន្ធនំ អកិវនំ អជ្ឈោសានំ តាហំ បរាមាសំ អកិនិវេសំ បជហាតិ វិនោទេតិ ព្យន្ត្តីករោតិ អនភាវ ន្ត្តមេតិ ។

បុគ្គលកាលពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយខាងក្នុងទាំងខាងក្រៅ មិនរីករាយ មិនសរសើរ មិនបិតនៅក្នុងការជ្រប់ចិត្ត ចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ សរសើរ ជ្រប់ចិត្ត ក្លិចកាន់ ស្ទាបអង្អែល ប្រកាន់ ។ បុគ្គលកាលពិចារណាឃើញនូវការកើតឡើងជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុង កាលពិចារណាឃើញនូវការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុង កាលពិចារណាឃើញនូវការកើតឡើងនិងការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុង កាលពិចារណាឃើញ នូវការកើតឡើងជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្រៅ កាលពិចារណាឃើញនូវការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្រៅ កាលពិចារណាឃើញនូវការកើតឡើង និងការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្រៅ កាលពិចារណាឃើញនូវការកើតឡើងជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុងទាំងខាងក្រៅ កាលពិចារណាឃើញនូវការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុងទាំងខាងក្រៅ កាលពិចារណាឃើញនូវការកើតឡើងនិងការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុងទាំងខាងក្រៅ មិនរីករាយ មិនសរសើរ មិនបិតនៅក្នុងសេចក្តីជ្រប់ចិត្ត ចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ សរសើរ ជ្រប់ចិត្ត ក្លិចកាន់ ស្ទាបអង្អែល ប្រកាន់ ។

ឥមេហិ ទ្វាទសហាការេហិ វេទនាសុ វេទនានុបស្សី
វិហរន្តោ វេទនំ ជានាតិ ជានាតិ ន អជ្ឈោសាយ
តិដ្ឋតិ អកិញ្ចនំ អកិវេទនំ អជ្ឈោសានំ ។ បេ ។ អន-
ការវត្តីមេតិ ។ អថវា វេទនំ អនិច្ចតោ បស្សន្តោ
វេទនំ ជានាតិ ជានាតិ ន អជ្ឈោសាយ តិដ្ឋតិ
អកិញ្ចនំ អកិវេទនំ អជ្ឈោសានំ តាហំ បហាសំ
អកិនិវេសំ បជហាតិ វិនោទេតិ ព្យន្តីករោតិ អន-
ការវត្តីមេតិ ។ វេទនំ ទុក្ខតោ រោគតោ គណ្ឌតោ
សល្លតោ អឃតោ អាពាធតោ ។ បេ ។ អនិស្សរណ-
តោ បស្សន្តោ វេទនំ ជានាតិ ជានាតិ ន អ-
ជ្ឈោសាយ តិដ្ឋតិ អកិញ្ចនំ អកិវេទនំ អជ្ឈោសានំ
តាហំ បហាសំ អកិនិវេសំ បជហាតិ វិនោទេតិ
ព្យន្តីករោតិ អនការវត្តីមេតិ ។ ឥមេហិ ទ្វាចត្តាឬ-
សាយ អាការេហិ វេទនាសុ វេទនានុបស្សី វិហរន្តោ
វេទនំ ជានាតិ ជានាតិ ន អជ្ឈោសាយ តិដ្ឋតិ
អកិញ្ចនំ អកិវេទនំ អជ្ឈោសានំ តាហំ បហាសំ
អកិនិវេសំ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនកា-
រវត្តីមេតីតិ អជ្ឈត្តញ្ច ពហិទ្ធា ច វេទនំ ជានាតិ ជានាតោ ។

ឧទយមាណវកប្បញ្ហានិទ្ទេស

បុគ្គលកាលពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយ ដោយអាការទាំង១២ នេះ មិនរីកវាយ មិនសរសើរ មិនបិតនៅក្នុងការជ្រប់ចិត្តចំពោះវេទនា ។ បេ ។ ឲ្យដល់នូវការមិនមានបៃបភាព នូវការរីកវាយ ការសរ-សើរ ការជ្រប់ចិត្ត ។ មួយទៀត បុគ្គលកាលឃើញវេទនាដោយសេចក្តីថា មិនទៀង មិនរីកវាយ មិនសរសើរ មិនបិតនៅក្នុងការជ្រប់ចិត្ត ចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបៃបភាព នូវការរីកវាយ ការសរសើរ ការជ្រប់ចិត្ត ការកួចកាន់ ការស្ទាបអង្អែល ការប្រកាន់ ។ បុគ្គលកាលឃើញវេទនាដោយសេចក្តីថា ជាទុក្ខ ជារោគ ជាពក ជាសរ ជាសេចក្តីលំបាក ជាអាពាធ ។ បេ ។ ដោយសេចក្តីថា មិនជាទីរលាស់ទុក្ខ មិនរីកវាយ មិនសរសើរ មិនបិតនៅក្នុងសេចក្តីជ្រប់ចិត្តចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបៃបភាព នូវការរីកវាយ ការសរសើរ ការជ្រប់ចិត្ត ការកួចកាន់ ការស្ទាបអង្អែល ការប្រកាន់ ។ បុគ្គលកាលពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយ ដោយអាការទាំងសែសិបពីរនេះ មិនរីកវាយ មិនសរសើរ មិនបិតនៅក្នុងសេចក្តីជ្រប់ចិត្ត ចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបៃបភាព នូវការរីកវាយ ការសរសើរ ការជ្រប់ចិត្ត ការកួចកាន់ ការស្ទាបអង្អែល ការប្រកាន់ ហេតុនោះ (ទ្រង់ត្រាស់ថា) កាលបុគ្គលមិនរីកវាយ ចំពោះវេទនាទាំងឡាយទាំងខាងក្នុងទាំងខាងក្រៅ ។

[៣៣] ឯវំ សតស្ស ចរតោតិ ឯវំ សតស្ស សម្ឆជានស្ស ចរតោ វិចរតោ ឥរិយតោ វត្តយតោ ចាលយតោ យបយតោ យាបយតោតិ ឯវំ សតស្ស ចរតោ ។

[៣៤] វិញ្ញាណំ ឧបរុជ្ឈតីតិ បុញ្ញាភិសង្ខារ-សហគតំ វិញ្ញាណំ អបុញ្ញាភិសង្ខារសហគតំ វិ-ញ្ញាណំ អានេញ្ជាភិសង្ខារសហគតំ វិញ្ញាណំ ឧរុជ្ឈតិ រូបសម្ផុតិ អត្តំ ឧបគ្ឆតិ បដិប្ឆស្ឆម្ភតីតិ វិញ្ញាណំ ឧប-រុជ្ឈតិ ។ តេនាហ ភគវា

អជ្ឈត្តញ្ច ពហិទ្ធា ច វេឧនំ ឧាភិនន្ទតោ
ឯវំ សតស្ស ចរតោ វិញ្ញាណំ ឧបរុជ្ឈតីតិ ។

សហ ឧាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

ឧទយមាណវកប្ឍញ្ហានិទ្ទេសោ ឧតរសមោ ។

[៣៣] *ពាក្យថា មានស្មារតី ប្រព្រឹត្តទៅ យ៉ាងនេះ គឺបុគ្គលមានស្មារតី ដឹងខ្លួនយ៉ាងនេះ ត្រាច់ទៅ ត្រាច់ទៅផ្សេងៗ ដើរទៅ ប្រព្រឹត្តទៅ រក្សា យាត្រា យាត្រាទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) មានស្មារតី ប្រព្រឹត្តទៅ យ៉ាងនេះ ។*

[៣៤] *ពាក្យថា វិញ្ញាណទើបរលត់ បានដល់ វិញ្ញាណដែលប្រកបដោយបុញ្ញាភិសង្ខារ វិញ្ញាណដែលប្រកបដោយអបុញ្ញាភិសង្ខារ វិញ្ញាណដែលប្រកបដោយអានេញ្ជាភិសង្ខារ រលត់ សូប់ អស្តង្គតរម្ងាប់ ហេតុនោះ (ទ្រង់ត្រាស់ថា) វិញ្ញាណទើបរលត់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា*

កាលបុគ្គលមិនរីករាយ ចំពោះវេទនាទាំងខាងក្នុងទាំងខាងក្រៅ

មានស្មារតី ប្រព្រឹត្តទៅយ៉ាងនេះ វិញ្ញាណទើបរលត់ ។

លុះចប់គាថា ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមជាសាវ័ក ។

ចប់ ឧទយមាណវកប្បញ្ហានិទ្ទេស ទី ១៣ ។

ចោសាលមាណវកប្បញ្ហានិទ្ទេសោ

[៣៥] យោ អតីតំ អាជិសតិ (ឥច្ចាយស្មា ចោសាលោ)

អនេជោ ឆិន្ទសំសយោ

ចារកូ សព្វធម្មានំ

អត្ថិ បញ្ញេន អាគមំ ។

[៣៦] យោ អតីតំ អាជិសតីតិ យោតិ យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ អនុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឌិ តត្ថ ច សព្វញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ ។ អតីតំ អាជិសតីតិ ភគវា អត្តនោ ច បរេសញ្ច អតីតម្បិ អាជិសតិ អនាគតម្បិ អាជិសតិ បច្ចុប្ប-ន្នម្បិ អាជិសតិ ។

ឥមំ ភគវា អត្តនោ អតីតំ អាជិសតិ ។ ភគវា អត្តនោ អតីតំ ឯកម្បិ ជាតឺ អាជិសតិ ទ្វេបិ ជាតិយោ អាជិសតិ តិស្សោបិ ជាតិយោ អាជិសតិ ចតស្សោបិ ជាតិយោ អាជិសតិ បញ្ចបិ ជាតិយោ អាជិសតិ ទសបិ ជាតិយោ

បោសាលមាណវកប្បញ្ហានិទ្ទេស

[៣៥] (បោសាល:មានអាយុ ក្រាបទូលដូច្នេះថា) ព្រះមានព្រះភាគអង្គណា ពោលអាងកាលជាអតីត មិនមានសេចក្ដីញាប់ញ័រ ទ្រង់កាត់សេចក្ដីសង្ស័យ ទ្រង់ដល់ត្រើយ នៃធម៌ទាំងពួងហើយ ពួកខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នាទើបមកគាល់ (ដើម្បីទូលសួរព្រះមានព្រះភាគនោះ) ។

[៣៦] *អធិប្បាយពាក្យថា ព្រះមានព្រះភាគអង្គណា ពោលអាងកាលជាអតីត ត្រង់ពាក្យថាអង្គណា សំដៅដល់ព្រះមានព្រះភាគ ព្រះអង្គត្រាស់ដឹងឯង ឥតមានអាចារ្យ បានត្រាស់ដឹងសច្ច:ទាំងឡាយ ដោយព្រះអង្គឯង ក្នុងធម៌ដែលព្រះអង្គមិនធ្លាប់បានស្ដាប់មកក្នុងកាលមុន ទ្រង់សម្រេចសព្វញ្ញុតញ្ញាណក្នុងធម៌ទាំងឡាយនោះផង សម្រេចនូវភាពស្ទាត់ក្នុងពលធម៌ទាំងឡាយផង ។ ពាក្យថា ទ្រង់ពោលអាងកាលជាអតីត បានដល់ព្រះមានព្រះភាគ ទ្រង់ពោលអាងកាលជាអតីតផង ទ្រង់ពោលអាងកាលជាអនាគតផង ទ្រង់ពោលអាងកាលជាបច្ចុប្បន្នផង របស់ព្រះអង្គនិងពួកសត្វដទៃ ។*

ព្រះមានព្រះភាគ ទ្រង់ពោលអាងកាលជាអតីតរបស់ព្រះអង្គ តើដូចម្ដេច ។ ព្រះមានព្រះភាគ ទ្រង់ពោលអាងអតីតជាតិ របស់ព្រះអង្គ ១ ជាតិខ្លះ ទ្រង់ពោលអាង ២ ជាតិខ្លះ ទ្រង់ពោលអាង ៣ ជាតិខ្លះ ទ្រង់ពោលអាង ៤ ជាតិខ្លះ ទ្រង់ពោលអាង ៥ ជាតិខ្លះ ទ្រង់ពោលអាង ១០ជាតិខ្លះ

អាជិសតិ វីសម្បិ ជាតិយោ អាជិសតិ តឹសម្បិ ជាតិយោ អាជិសតិ ចត្តាឡីសម្បិ ជាតិយោ អាជិ-សតិ បញ្ញាសម្បិ ជាតិយោ អាជិសតិ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំ-វដ្តកប្បេ អនេកេបិ វិវដ្តកប្បេ អនេកេបិ សំវដ្ត-វិវដ្តកប្បេ អាជិសតិ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវ-មាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហា-រោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អាជិសតិ ឯវំ ភគវា អត្ត-នោ អតីតំ អាជិសតិ ។

កថំ ភគវា បរេសំ អតីតំ អាជិសតិ ។ ភគវា បរេសំ អតីតំ ឯកម្បិ ជាតឹ អាជិសតិ ទ្វេបិ ជាតិយោ អាជិសតិ ។ បេ ។ អនេកេបិ សំវដ្តវិវដ្តកប្បេ អាជិសតិ

ទ្រង់ពោលអាង ២០ ជាតិខ្លះ ទ្រង់ពោលអាង ៣០ ជាតិខ្លះ ទ្រង់ពោលអាង ៤០ ជាតិខ្លះ ទ្រង់ពោលអាង ៥០ ជាតិខ្លះ ទ្រង់ពោលអាងមួយរយជាតិខ្លះ មួយពាន់ជាតិខ្លះ មួយសែនជាតិខ្លះ សំវដ្តកប្បជាច្រើនខ្លះ វិវដ្តកប្បជាច្រើនខ្លះ សំវដ្តវិវដ្តកប្បជាច្រើនខ្លះថា តថាគត បានកើតក្នុងកពងណោះ មាននាមយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ សោយសុខនិងទុក្ខយ៉ាងនេះ មានអាយុត្រឹមប៉ុណ្ណោះ លុះតថាគតនោះច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងកពងណោះដែលកើតក្នុងកពនោះ ក៏មាននាមយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ សោយសុខនិងទុក្ខយ៉ាងនេះ មានអាយុត្រឹមប៉ុណ្ណោះ តថាគតនោះ លុះច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងកពនេះ ព្រះមានព្រះភាគ ទ្រង់ពោលអាងការនៅអាស្រ័យក្នុងកាលមុន ជាច្រើនប្រការ ព្រមទាំងអាការ (គឺវណ្ណៈនិងអាហារជាដើម) ព្រមទាំងឧទ្ទេស (គឺឈ្មោះនិងគោត្រជាដើម) ដោយប្រការដូច្នេះ ព្រះមានព្រះភាគ ទ្រង់ពោលអាងកាលជាអតីត របស់ព្រះអង្គ យ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់ពោលអាងកាលជាអតីតរបស់ពួកសត្វដទៃ តើដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ពោលអាងអតីតជាតិរបស់ពួកសត្វដទៃ ១ ជាតិខ្លះ ទ្រង់ពោលអាង ២ ជាតិខ្លះ ។ លេ ។ ទ្រង់ពោលអាង សំវដ្តវិវដ្តកប្ជ៏ច្រើនខ្លះ

បោសាលមាណវកប្បញ្ហានិទ្ទេសោ

អមុត្រាសិ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទិ តត្រាបាសិ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អាទិសតិ ឯវំ ភគវា បរេសំ អតីតំ អាទិសតិ ។

ភគវា បញ្ច ជាតកសតានិ ភាសន្តោ អត្តនោ ច បរេសញ្ច អតីតំ អាទិសតិ មហាបទានិយសុត្តំ[១] ភាសន្តោ អត្តនោ ច បរេសញ្ច អតីតំ អាទិសតិ មហាសុទស្សនសុត្តំ ភាសន្តោ អត្តនោ ច បរេសញ្ច អតីតំ អាទិសតិ មហាគោវិន្ទសុត្តំ ភាសន្តោ អត្តនោ ច បរេសញ្ច អតីតំ អាទិសតិ មឃទេវសុត្តំ ភាសន្តោ អត្តនោ ច បរេសញ្ច អតីតំ អាទិសតិ ។

១ ម. មហាបទានិយសុត្តន្តំ ។

ថា (សត្វនេះ) បានកើតក្នុងកពងណោះ មាននាមយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានអាយុត្រឹមប៉ុណ្ណោះ សត្វនោះច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងកពងណោះ ដែលកើតក្នុងកពនោះ មាននាមយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានអាយុត្រឹមប៉ុណ្ណោះ សត្វនោះច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងកពនេះ ព្រះមានព្រះភាគទ្រង់ពោលអាងការនៅអាស្រ័យក្នុងកាលមុន ច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ព្រះមានព្រះភាគទ្រង់ពោលអាងកាលជាអតីត របស់ពួកសត្វដទៃ យ៉ាងនេះឯង ។

ព្រះមានព្រះភាគទ្រង់សម្តែងជាតកទាំង ៥០០ ឈ្មោះថាពោលអាងកាលជាអតីតរបស់ព្រះអង្គផង របស់ពួកសត្វដទៃផង ទ្រង់សម្តែងមហាធនិយសូត្រ ឈ្មោះថាពោលអាងកាលជាអតីតរបស់ព្រះអង្គផង របស់ពួកសត្វដទៃផង ទ្រង់សម្តែងមហាសុទស្សនសូត្រ ឈ្មោះថាពោលអាងកាលជាអតីតរបស់ព្រះអង្គផង របស់ពួកសត្វដទៃផង ទ្រង់សម្តែងមហាគោវិន្ទសូត្រ ឈ្មោះថាពោលអាងកាលជាអតីតរបស់ព្រះអង្គផង របស់ពួកសត្វដទៃផង ទ្រង់សម្តែងមឃទេវសូត្រ ឈ្មោះថាពោលអាងកាលជាអតីតរបស់ព្រះអង្គផង របស់ពួកសត្វដទៃផង ។

រុត្តញ្ចេតំ ភគវតា អតីតំ ខោ ចុន្ទ អទ្ធានំ អារព្ភ តថាគតស្ស សតានុសារិ ញាណំ ហោតិ សោ យាវតកំ អាកង្ខតិ តាវតកំ អនុស្សរតិ អនាគតំ ខោ ចុន្ទ ។ បេ ។ បច្ចុប្បន្នំ ខោ ចុន្ទ អទ្ធានំ អារព្ភ តថាគតស្ស ពោធិជំ ញាណំ ឧប្ប-ជ្ជតិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។ ឥន្ទ្រិយបរោបរិយត្តញ្ញាណំ តថាគតស្ស តថាគតពលំ សត្តានំ អាសយានុសយញ្ញាណំ តថាគតស្ស តថា-គតពលំ យមកបាដិហីរិយញ្ញាណំ តថាគតស្ស តថាគតពលំ មហាការុណាសមាបត្តិញ្ញាណំ តថា-គតស្ស តថាគតពលំ សព្វញ្ញុតញ្ញាណំ តថាគតស្ស តថាគតពលំ អនាវរណញ្ញាណំ តថាគតស្ស តថា-គតពលំ សព្វត្ត អសង្គមប្បដិហតមនាវរណញ្ញាណំ តថាគតស្ស តថាគតពលំ ។ ឯវំ ភគវា អត្តនោ ច បរេសញ្ច អតីតម្បិ អានិសតិ អនាគតម្បិ អា-និសតិ បច្ចុប្បន្នម្បិ អានិសតិ អាចិក្ខតិ ទេសេតិ បញ្ញបេតិ បដ្ឋបេតិ វិវរតិ វិភជតិ ឧត្តានី-ករោតិ បកាសេតីតិ យោ អតីតំ អានិសតិ ។

ដូចព្រះពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលចុន្ទ: ញាណជាគ្រឿងរលឹកតាមនូវស្មារតីនៃព្រះតថាគត ប្រារព្ធកាលជាអតីត រមែងមាន ព្រះតថាគតនោះ ប្រាជ្ញាត្រឹមណា រលឹកឃើញបានត្រឹមនោះ ម្នាលចុន្ទ: ញាណជាគ្រឿងរលឹកតាមនូវស្មារតីនៃព្រះតថាគត ប្រារព្ធនូវកាលជាអនាគត ។ បេ ។ ម្នាលចុន្ទ: ញាណដែលកើតអំពីពោធិនៃព្រះតថាគត ប្រារព្ធកាលជាបច្ចុប្បន្ន រមែងកើតឡើងថា ជាតិនេះ មានក្នុងទីបំផុត ការកើតទៀតក្នុងកាលឥឡូវនេះមិនមាន ។ ឥន្ទ្រិយបរោ-បរិយត្តញ្ញាណ ជាតថាគតពល របស់ព្រះតថាគត សត្តានំអាសយា-នុសយញ្ញាណ ជាតថាគតពល របស់ព្រះតថាគត យមកប្បាដិហិរិ-យញ្ញាណ ជាតថាគតពល របស់ព្រះតថាគត មហាករុណាសមាបត្តិញ្ញាណ ជាតថាគតពល របស់ព្រះតថាគត សព្វញ្ញុតញ្ញាណ ជាតថាគតពល របស់ព្រះតថាគត អនាវរណញ្ញាណ ជាតថាគតពល របស់ព្រះតថាគត សព្វត្តអសង្គ្គមប្បដិហតមនាវរណញ្ញាណ ជាតថាគតពល របស់ព្រះតថាគត ។ ព្រះមានព្រះភាគ ទ្រង់ពោលអាងជាតិជាអតីតផង ពោលអាងជាតិជាអនាគតផង ទ្រង់ពោលអាង ប្រាប់ សម្តែង ប្រញ័ប្ត តាំងផ្តើម បើក រៃកញ្ជ្រៃក ធ្វើឲ្យរាក់ ប្រកាស នូវជាតិជាបច្ចុប្បន្ន របស់ព្រះអង្គផង របស់ពួកសត្វដទៃផង យ៉ាងនេះ ហេតុនេះ (លោកពោលថា) ព្រះមានព្រះភាគអង្គណា ពោលអាង កាលជាអតីត ។

ឥច្ចាយស្មា ចោសាលោតិ ឥច្ចាតិ បទសន្ធិ ។ អាយស្មាតិ បិយវចនំ ។ ចោសាលោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អកិលាចោតិ ឥច្ចា-យស្មា ចោសាលោ ។

[៣៧] អនេជោ ធិន្ទសំសយោតិ ឯជា រុច្ចតិ តណ្ហា យោ ភវោ សាភវោ ។ បេ ។ អកិញ្ចោ លោកោ អកុសលមូលំ ។ សា ឯជា តណ្ហា ពុទ្ធស្ស ភគវតោ បហីនា ឧচ্ছិন্নমূলা តាលាវត្ថ-កតា អនភាវង្គតា អាយតឺអនុប្ប្ាទធម្ម តស្មា ពុទ្ធោ អនេជោ ។ ឯជាយ បហីនត្តា អនេជោ ។ ភគវា លោកេបិ ន ឥញ្ជតិ អលោកេបិ ន ឥញ្ជតិ យសេបិ ន ឥញ្ជតិ អយសេបិ ន ឥញ្ជតិ បសំសាយបិ ន ឥញ្ជតិ និន្ទាយបិ ន ឥញ្ជតិ សុខេបិ ន ឥញ្ជតិ ទុក្ខេបិ ន ឥញ្ជតិ ន ចលតិ ន វេធតិ ន បវេធតិ ន សម្ប្ប្ាវេធតីតិ អនេជោ ។ ធិន្ទសំសយោតិ សំសយោ រុច្ចតិ វិចិកិច្ឆា ទុក្ខេ ការ្ខា ។ បេ ។ ធម្មិតត្ថំ ចិត្តស្ស មនោវិលេខោ ។

ពាក្យថា ដូច្នេះ ក្នុងបទថា បោសាលៈ មានអាយុ ពោលដូច្នេះ ជាការតបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា បោសាលៈ ជាឈ្មោះ ។ បេ ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ (ទើបមានពាក្យថា) បោសាលៈមានអាយុពោលដូច្នេះ ។

[៣៧] ពាក្យថា មិនមានសេចក្តីញាប់ញ័រ ទ្រង់កាត់សេចក្តីសង្ស័យ សេចក្តីថា តណ្ហា លោកហៅថា សេចក្តីញាប់ញ័រ បានខាងតម្រេក តម្រេកខ្លាំង ។ បេ ។ អកិញ្ចា លោកៈ អកុសលមូល ។ សេចក្តីញាប់ញ័រគឺតណ្ហានោះ ព្រះពុទ្ធមានជោគ ទ្រង់លះបង់ ផ្តិលផ្តាច់ឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានបែបភាព មិនឲ្យមានការកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមិនមានសេចក្តីញាប់ញ័រ ។ ព្រោះទ្រង់លះសេចក្តីញាប់ញ័រ ទើបឈ្មោះថាមិនមានសេចក្តីញាប់ញ័រ ។ ព្រះមានព្រះភាគមិនញាប់ញ័រក្នុងលាភផង មិនញាប់ញ័រក្នុងអលាភផង មិនញាប់ញ័រក្នុងយសផង មិនញាប់ញ័រក្នុងអយសផង មិនញាប់ញ័រក្នុងសេចក្តីសរសើរផង មិនញាប់ញ័រក្នុងនិន្ទាផង មិនញាប់ញ័រក្នុងសុខផង មិនញាប់ញ័រ មិនកម្រើក មិនរន្ធត់ មិនកក្រើក មិនកក្រើកព្រមក្នុងទុក្ខផង ហេតុនោះ ទើបឈ្មោះថាមិនមានសេចក្តីញាប់ញ័រ ។ ពាក្យថា ទ្រង់កាត់សេចក្តីសង្ស័យ សេចក្តីថា វិចិកិច្ឆា លោកហៅថា សេចក្តីសង្ស័យ គឺសេចក្តីសង្ស័យក្នុងទុក្ខ ។ បេ ។ សេចក្តីញាប់ញ័រនៃចិត្ត សេចក្តីរសេមរសាមនៃចិត្ត ។

សោ សំសយោ ពុទ្ធស្ស ភគវតោ ឆិន្នោ ឧច្ឆិន្នោ សមុច្ឆិន្នោ វូបសន្តោ បដិប្បស្សទ្ធោ អភព្វុប្បត្តិកោ ញាណគ្គិនា ទឌ្ឍោ តស្មា ពុទ្ធោ ឆិន្នសំសយោតិ អនេជោ ឆិន្នសំសយោ ។

[៣៨] ចារត្ថ សព្វធម្មានន្តិ ភគវា សព្វធម្មានំ អភិញ្ញាចារត្ថ បរិញ្ញាចារត្ថ បហានចារត្ថ ភាវនា-ចារត្ថ សច្ឆិកិរិយាចារត្ថ សមាបត្តិចារត្ថ អភិញ្ញាចា-រត្ថ សព្វធម្មានំ ។ បេ ។ ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ ចារត្ថ សព្វធម្មានំ ។

[៣៩] អត្ថិ បញ្ហេន អាគមន្តិ បញ្ហត្ថិកាម្ហា អាគតា ។ បេ ។ សង្ខស្សេតុំ ភណិតុន្តិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។ តេនាហ សោ ព្រាហ្មណោ

សេចក្តីសង្ស័យនោះ ព្រះពុទ្ធមានជោគ ទ្រង់កាត់ ផ្តាច់ ផ្ដិលផ្ដាច់ រម្ងាប់ សូប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណ ហើយ ហេតុនោះ ព្រះពុទ្ធឈ្មោះថា កាត់សេចក្តីសង្ស័យ ហេតុនោះ (លោកពោលថា) មិនមានសេចក្តីញាប់ញ័រ ទ្រង់កាត់សេចក្តីសង្ស័យ ។

[៣៨] ពាក្យថា ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង គឺព្រះមានព្រះភាគទ្រង់ដល់ត្រើយនៃការត្រាស់ដឹង ដល់ត្រើយនៃការកំណត់ដឹង ដល់ត្រើយនៃការលះបង់ ដល់ត្រើយនៃការចម្រើន ដល់ត្រើយនៃការធ្វើឲ្យជាក់ច្បាស់ ដល់ត្រើយនៃសមាបត្តិ នៃធម៌ទាំងពួង គឺថាទ្រង់ដល់ត្រើយនៃការត្រាស់ដឹងនូវធម៌ទាំងពួង ។ បេ ។ ភពថ្មីគឺជាតិ ជរា មរណៈ សង្សារ នៃព្រះមានព្រះភាគនោះ មិនមាន ហេតុនោះ (លោកពោលថា) ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង ។

[៣៩] ពាក្យថា ពួកខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ គឺពួកខ្ញុំព្រះអង្គត្រូវការដោយប្រស្នា ទើបមក ។ បេ ។ ដើម្បីបំភ្ញើ ដើម្បីសម្ដែង ហេតុនោះ (លោកពោលថា) ពួកខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ យ៉ាងនេះក៏បាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

យោ អតីតំ អាទិសតិ (ឥច្ចាយស្មា ធោសាលោ)
អនេជោ ឆិន្នសំសយោ
ចារគូ សព្វធម្មានំ
អត្ថិ បញ្ហេន អាគមន្តិ ។

[៤០] វិភូតរូបសញ្ញិស្ស សព្វកាយប្បហាយិនោ
អជ្ឈត្តញ្ច ពហិទ្ធា ច នត្ថិ កិញ្ចីតិ បស្សតោ
ញាណំ សក្កានុបុច្ឆាមិ កថំ នេយ្យោ តថាវិធោ ។

[៤១] វិភូតរូបសញ្ញិស្សាតិ កតមា រូបសញ្ញា ។ រូបាវចរសមាបត្តឹ សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារស្ស វា សញ្ញា សញ្ជានានា សញ្ជានិតត្តំ អយំ រូបសញ្ញា ។ វិភូតរូបសញ្ញិស្សាតិ ចតស្សោ អរូបសមាបត្តិយោ លាភិស្ស រូបសញ្ញា វិភូតា ហោន្តិ វិភាវិតា អតិក្កន្តា សមតិក្កន្តា វីតិវត្តាតិ វិភូតរូបសញ្ញិស្ស ។

(ចោសាលមានអាយុក្រាបទូលដូច្នេះថា) ព្រះមានព្រះភាគ អង្គណា ពោលអាងកាលជាអតីត មិនមានសេចក្តីញាប់ញ័រ ទ្រង់កាត់សេចក្តីសង្ស័យ ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង ពួកខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ (ដើម្បីទូលសួរព្រះមានព្រះភាគនោះ) ។

[៦០] បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរអំពីញាណរបស់បុគ្គលអ្នកមានរូបសញ្ញាជាក់ច្បាស់ អ្នកលះបង់រូបារម្មណ៍ទាំងអស់ អ្នកឃើញទាំងខាងក្នុងទាំងខាងក្រៅថា វត្ថុបន្ទិចបន្ទួចមិនមាន បុគ្គលមានសភាពដូច្នោះ តើព្រះអង្គជ្រាបដោយប្រការដូចម្តេច ។

[៦១] ពាក្យថា អ្នកមានរូបសញ្ញាជាក់ច្បាស់ មានសំណួរថា រូបសញ្ញាតើដូចម្តេច ។ សេចក្តីសម្គាល់ អាការនៃសេចក្តីសម្គាល់ ភាពនៃសេចក្តីសម្គាល់ របស់បុគ្គលអ្នកចូលកាន់រូបាវចរសមាបត្តិក្តី អ្នកញ៉ាំងរូបាវចរសមាបត្តិឲ្យកើតក្តី អ្នកមានឈានសុខជាគ្រឿងនៅក្នុងបច្ចុប្បន្នក្តី នេះឈ្មោះថា រូបសញ្ញា ។ ពាក្យថា អ្នកមានរូបសញ្ញាជាក់ច្បាស់ បានន័យថា បុគ្គលអ្នកបានអរូបសមាបត្តិទាំង ៤ ហើយ រមែងមានរូបសញ្ញា (ការសម្គាល់រូប) ប្រាកដ ធ្វើឲ្យជាក់ច្បាស់ កន្ទង ១ លង ១ ប្រព្រឹត្ត កន្ទង ១ ហេតុនោះ (លោកពោលថា) អ្នកមានរូបសញ្ញាជាក់ច្បាស់ ។

[៤២] សព្វកាយប្បហាយិនោតិ សព្វោ តស្ស សប្បដិសន្ធិកោ រូបកាយោ បហីនោ តនជ្ជសមតិ-ក្កមវិក្ខម្ភនប្បហានេន បហីនោ តស្ស រូបកាយោតិ សព្វកាយប្បហាយិនោ ។

[៤៣] អជ្ឌត្តញ្ច ពហិទ្ធា ច នត្ថិ កិញ្ចីតិ បស្ស្ឯតោតិ នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនសមា-បត្តិ ។ កីការណា នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញា-យតនសមាបត្តិ ។ វិញ្ញាណញ្ចាយតនសមាបត្តឺ ស-តោ សមាបជ្ជិត្វា តតោ វុដ្ឋហិត្វា តញ្ញេវ វិញ្ញាណំ អភាវេតិ វិភាវេតិ អន្តរធាបេតិ នត្ថិ កិញ្ចីតិ បស្ស-តិ ។ តំការណា នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយត-នសមាបត្តីតិ អជ្ឌត្តញ្ច ពហិទ្ធា ច នត្ថិ កិញ្ចីតិ បស្ស្ឯតោ ។

[៤៤] ញាណំ សក្ខាជុបុច្ឆាមីតិ សក្ខាតិ សក្ខោ ។ ភគវា សក្យកុលា បព្ជិតោតិបិ សក្ខោ ។ បេ ។ បហីនភយភេរវោ វិគតលោមហំសោតិបិ សក្ខោ ។

[៦២] *ពាក្យថា អ្នកលះរូបារម្មណ៍ទាំងអស់ សេចក្តីថា រូបកាយ ប្រ-*
កបដោយបដិសន្ធិទាំងអស់ បុគ្គលនោះលះបង់ហើយ គឺថារូបកាយបុគ្គល
នោះលះបង់ហើយ ដោយវិក្ខម្ភនប្ផហាន ដែលប្រព្រឹត្តកន្ធ ទូវតទង្គ្គ ប្ផ-
ហាន ហេតុនោះ (លោកពោលថា) អ្នកលះរូបារម្មណ៍ទាំងអស់ ។

[៦៣] *ពាក្យថា អ្នកឃើញទាំងខាងក្នុងទាំងខាងក្រៅថា វត្ថុបន្ទិច*
បន្ទ្ចមិនមាន ត្រង់ពាក្យថា វត្ថុបន្ទិចបន្ទ្ចមិនមាន បានដល់អាកិញ្ច-
ញ្ញាយតនសមាបត្តិ ។ អាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា
វត្ថុបន្ទិចបន្ទ្ចមិនមាន តើព្រោះហេតុអ្វី ។ បុគ្គលមានស្មារតីចូលវិញ្ញាណ-
ញ្ចាយតនសមាបត្តិ លុះចេញចាកសមាបត្តិនោះហើយ ក៏ធ្វើវិញ្ញាណ
នោះឯង ឲ្យវិនាស បាត់បង់ សាបសូន្យទៅវិញ ឈ្មោះថាឃើញថា
វត្ថុបន្ទិចបន្ទ្ចមិនមាន ។ អាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា
វត្ថុបន្ទិចបន្ទ្ចមិនមាន ព្រោះហេតុនោះឯង ហេតុនោះ (លោកពោលថា)
អ្នកឃើញទាំងខាងក្នុងទាំងខាងក្រៅថា វត្ថុបន្ទិចបន្ទ្ចមិនមាន ។

[៦៤] *ពាក្យថា សក្យពង្ស ក្នុងបទថា បពិត្រព្រះអង្គជាសក្យពង្ស*
ខ្ញុំព្រះអង្គសូមទូលសួរ អំពីញាណ គឺ ព្រះមានព្រះភាគ ឈ្មោះថា
សក្យពង្ស ។ ដែលព្រះមានព្រះភាគ ឈ្មោះសក្យ: ព្រោះទ្រង់ចេញ
ចាកសក្យត្រកូលហើយបួស ក៏បាន ។ បេ ។ ឈ្មោះសក្យ: ព្រោះព្រះ
អង្គលះបង់ភ័យ និងសេចក្តីតក់ស្ទុត ប្រាសចាកការព្រឺរោម ក៏បាន ។

ញាណំ សត្ថានុបុច្ឆាមីតិ តស្ស ញាណំ បុច្ឆាមិ កីទិសំ កឹសណ្ឋិតំ កឹបការំ កឹបដិភាគំ ឥច្ឆិតព្ព-ន្តិ ញាណំ សត្ថានុបុច្ឆាមិ ។

[៤៥] កថំ នេយ្យោ តថាវិធោតិ កថំ សោ នេតព្វោ វិនេតព្វោ អនុនេតព្វោ បញ្ញាបេតព្វោ អ-ភិនិជ្ឈាបេតព្វោ បេក្ខិតព្វោ បសាទេតព្វោ កថ-មស្ស ឧត្តរិញាណំ ឧប្បាទេតព្វំ ។ តថាវិធោតិ តថាវិធោ តាទិសោ តស្សណ្ឋិតោ តប្បការោ ត-ប្បដិភាគោ យោ សោ អាកិញ្ចញ្ញាយតនសមាប-ត្តិលាភីតិ កថំ នេយ្យោ តថាវិធោ ។ តេនាហ សោ ព្រាហ្មណោ

វិភូតរូបសញ្ញិស្ស សព្វកាយប្បហាយិនោ

អជ្ឈត្តញ្ច ពហិទ្ធា ច នត្ថិ កិញ្ចីតិ បស្សតោ

ញាណំ សត្ថានុបុច្ឆាមិ កថំ នេយ្យោ តថាវិធោតិ ។

ពាក្យថា បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរអំពីញាណ បានន័យថា ខ្ញុំព្រះអង្គសូមទូលសួរញាណ របស់បុគ្គលនោះ ថា ប្រាកដដូចម្តេច មានទ្រង់ទ្រាយដូចម្តេច មានប្រការដូចម្តេច មានចំណែកប្រៀបដូចម្តេច ដែលបុគ្គលគប្បីប្រាជ្ញា ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរអំពីញាណ ។

[៤ថ] ពាក្យថា បុគ្គលមានសភាពដូច្នោះ តើព្រះអង្គជ្រាបដោយប្រការដូចម្តេច សេចក្តីថា បុគ្គលនោះ តើព្រះអង្គជ្រាប ជ្រាបសព្វ ជ្រាបច្បាស់ យល់ច្បាស់ ពិនិត្យច្បាស់ សម្ងឹង ជ្រះថ្លា ដោយប្រការដូចម្តេច គឺថាញាណដ៏ក្រៃលែង របស់បុគ្គលនោះ ព្រះអង្គគប្បីឲ្យកើតឡើងដូចម្តេច ។ ពាក្យថា មានសភាពដូច្នោះ គឺមានប្រការដូច្នោះ ប្រាកដដូច្នោះ មានទ្រង់ទ្រាយដូច្នោះ មានសភាពដូច្នោះ មានចំណែកប្រៀបដូច្នោះ បានដល់បុគ្គលអ្នកបានអាកិញ្ចញ្ញាយតនសមាបត្តិ ហេតុនោះ (លោកពោលថា) បុគ្គលមានសភាពដូច្នោះ តើព្រះអង្គជ្រាបដោយប្រការដូចម្តេច ហេតុនោះ ព្រាហ្មណ៍នោះពោលថា

> បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរអំពីញាណរបស់បុគ្គលអ្នកមានរូបសញ្ញាជាក់ច្បាស់ អ្នកលះបង់រូបារម្មណ៍ទាំងអស់ អ្នកឃើញទាំងខាងក្នុងទាំងខាងក្រៅថា វត្ថុបន្ទិចបន្ទួចមិនមាន បុគ្គលមានសភាពដូច្នោះ តើព្រះអង្គជ្រាប ដោយប្រការដូចម្តេច ។

[៤៦] វិញ្ញាណដ្ឋិតិយោ សព្វា (ចោសាលាតិ ភគវា)
អភិជានំ តថាគតោ
តិដ្ឋន្តមេនំ ជានាតិ
វិមុត្តំ តប្បរាយនំ ។

[៤៧] វិញ្ញាណដ្ឋិតិយោ សព្វាតិ ភគវា អភិសង្ខារវសេន ចតស្សោ វិញ្ញាណដ្ឋិតិយោ ជានាតិ បដិសន្ធិវសេន សត្ត វិញ្ញាណដ្ឋិតិយោ ជានាតិ ។ កថំ ភគវា អភិសង្ខារវសេន ចតស្សោ វិញ្ញាណដ្ឋិតិយោ ជានាតិ ។ វុត្តញ្ហេតំ ភគវតា រូបូបាយ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋតិ រូបារម្មណំ រូបប្បតិដ្ឋំ នន្ទូបសេវនំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជតិ វេទនូបាយ វា ភិក្ខវេ ។ បេ ។ សញ្ញូបាយ វា ភិក្ខវេ ។ បេ ។ សង្ខារូបាយ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋតិ សង្ខារារម្មណំ សង្ខារប្បតិដ្ឋំ នន្ទូបសេវនំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជតីតិ ។ ឯវំ ភគវា អភិសង្ខារវសេន ចតស្សោ វិញ្ញាណដ្ឋិតិយោ ជានាតិ ។

[៤៦] (ព្រះមានព្រះភាគត្រាស់ថា ម្នាលបោសាល:) ព្រះតថាគត ទ្រង់ជ្រាបច្បាស់នូវវិញ្ញាណដ្ឋិតិទាំងពួង ទើបទ្រង់ជ្រាបនូវបុគ្គលនោះដែលកំពុងរស់នៅ មានចិត្តងប់ (ក្នុងអាកិញ្ចញ្ញាយតន:) មានអាកិញ្ចញ្ញាយតន:នោះ ប្រព្រឹត្តទៅខាងមុខ ។

[៤៧] ពាក្យថា វិញ្ញាណដ្ឋិតិទាំងពួង អធិប្បាយថា ព្រះមានព្រះភាគទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៤ ដោយអំណាចអកិសង្ខារ ទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៧ ដោយអំណាចបដិសន្ធិ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៤ ដោយអំណាចអកិសង្ខារ តើដូចម្តេច ។ ព្រះពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ វិញ្ញាណអាស្រ័យរូបខ្លះហើយឋិតនៅ រមែងឋិតនៅ មានរូបជាអារម្មណ៍ មានរូបជាទីតម្កល់ មានសេចក្តីត្រេកអរជាគ្រឿងសេព រមែងដល់នូវសេចក្តីចម្រើន សេចក្តីលូតលាស់ សេចក្តីទូលំទូលាយ ម្នាលភិក្ខុទាំងឡាយ (វិញ្ញាណ) អាស្រ័យវេទនាខ្លះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ (វិញ្ញាណ) អាស្រ័យសញ្ញាខ្លះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណអាស្រ័យសង្ខារខ្លះ ហើយឋិតនៅ រមែងឋិតនៅ មានសង្ខារជាអារម្មណ៍ មានសង្ខារជាទីតម្កល់ មានសេចក្តីត្រេកអរជាគ្រឿងសេព ដល់នូវសេចក្តីចម្រើន សេចក្តីលូតលាស់ សេចក្តីទូលំទូលាយ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៤ ដោយអំណាចអកិសង្ខារ យ៉ាងនេះ ។

កថំ ភគវា បដិសន្ធិវសេន សត្ត វិញ្ញាណដ្ឋិតិយោ ជានាតិ ។ វុត្តញ្ហេតំ ភគវតា សន្តិ ភិក្ខវេ សត្តា ជានត្តកាយា ជានត្តសញ្ញិនោ សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា អយំ បឋមា វិញ្ញាណដ្ឋិតិ សន្តិ ភិក្ខវេ សត្តា ជានត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា ព្រហ្មកាយិកា បឋមាភិនិព្ពត្តា អយំ ទុតិយា វិញ្ញាណដ្ឋិតិ សន្តិ ភិក្ខវេ សត្តា ឯកត្តកាយា ជានត្តសញ្ញិនោ សេយ្យថាបិ ទេវា អាភស្សរា អយំ តតិយា វិញ្ញាណដ្ឋិតិ សន្តិ ភិក្ខវេ សត្តា ឯកត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា សុភកិណ្ហកា អយំ ចតុត្ថា វិញ្ញាណដ្ឋិតិ ស-ន្តិ ភិក្ខវេ សត្តា សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា ជានត្តសញ្ញានំ អមនសិ-ការា អនន្តោ អាកាសោតិ អាកាសានញ្ចាយ-តនុបគា អយំ បញ្ចមា វិញ្ញាណដ្ឋិតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនុបគា អយំ ឆដ្ឋា វិញ្ញាណដ្ឋិតិ

ព្រះមានព្រះភាគទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៧ ដោយអំណាចបដិសន្ធិ តើដូចម្តេច ។ ព្រះមានព្រះភាគ ត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលភិក្ខុទាំងឡាយ មានពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្សនិងទេវតាពួកខ្លះ វិនិបាតិក:ពួកខ្លះ នេះវិញ្ញាណដ្ឋិតិទី ១ ម្នាលភិក្ខុទាំងឡាយ មានពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតា ប្រព្រឹត្តទៅក្នុងពួកព្រហ្ម កើតដោយបឋមជ្ឈាន នេះវិញ្ញាណដ្ឋិតិទី ២ ម្នាលភិក្ខុទាំងឡាយ មានពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកទេវតាជាន់អាភស្សរ: នេះវិញ្ញាណដ្ឋិតិទី ៣ ម្នាលភិក្ខុទាំងឡាយ មានពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាជាន់សុភកិណ្ហក: នេះវិញ្ញាណដ្ឋិតិទី ៤ ម្នាលភិក្ខុទាំងឡាយ មានពួកសត្វព្រោះប្រព្រឹត្តកន្ធងរូបសញ្ញាដោយប្រការទាំងពួង ដល់នូវការវិនាសនៃបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ចូលអាកាសានញ្ចាយ-តន: ដោយបរិកម្មថា អាកាសមិនមានទីបំផុត នេះវិញ្ញាណដ្ឋិតិទី ៥ (ពួកសត្វ) ប្រព្រឹត្តកន្ធងអាកិញ្ចញ្ញាយតន: ដោយប្រការទាំងពួង ចូលវិញ្ញាណ-ញ្ចាយតន: ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត នេះវិញ្ញាណដ្ឋិតិទី ៦

សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម ន ត្ថិ កិញ្ចីតិ
អាកិញ្ចញ្ញាយតនុបគា អយំ សត្តមា វិញ្ញាណដ្ឋិតីតិ ។
ឯវំ ភគវា បដិសន្ធិវសេន សត្ត វិញ្ញាណដ្ឋិយោ ជា-
ជានាតីតិ វិញ្ញាណដ្ឋិតិយោ សព្វា ។ ចោសាលាតិ ភ-
គវាតិ ចោសាលាតិ ភគវា តំ ព្រាហ្មណំ ជាមេន
អាលបតិ ។ ភគវាតិ ការណ្ឌវិវចនមេតំ ។ បេ ។ ស-
ច្ចិកា បញ្ញត្តិ យទិទំ ភគវាតិ ចោសាលាតិ ភគវា ។

[៤៨] អភិជានំ តថាគតោតិ អភិជានន្តិ អភិជា-
នន្តោ បដិវិជានន្តោ បដិវិជ្ឌន្តោ ។ តថាគតោតិ
រុត្តញ្ចេតំ ភគវតា អតីតញ្ចេបិ ចុន្ទ ហោតិ អភូតំ
អតច្ចំ អនត្ថសញ្ហិតំ ន តំ តថាគតោ ព្យាករោតិ
អតីតញ្ចេបិ ចុន្ទ ហោតិ ភូតំ តច្ចំ អនត្ថសញ្ហិតំ
តម្ឃ តថាគតោ ន ព្យាករោតិ អតីតញ្ចេបិ ចុន្ទ
ហោតិ ភូតំ តច្ចំ អត្ថសញ្ហិតំ តត្រ កាលញ្ញូ
តថាគតោ ហោតិ តស្ស បញ្ហស្ស វេយ្យាការ-
ណាយ អនាគតញ្ចេបិ ចុន្ទ ហោតិ ។ បេ ។

ពួកសត្វប្រព្រឹត្តកន្ទ:ងវិញ្ញាណញ្ចាយតន: ដោយប្រការទាំងពួង ចូលអាកិ-ញ្ចញ្ញាយតន: ដោយបរិកម្មថា របស់តិចតួចមិនមាន នេះវិញ្ញាណដ្ឋិតិទី ៧ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៧ ដោយអំណាចបដិសន្ធិ យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) វិញ្ញាណដ្ឋិតិទាំងពួង ។ ពាក្យ ថា បោសាល: ក្នុងបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលបោសាល: គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះ តាមឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ ន:ុះជាពាក្យនិយាយដោយគោរព ។ លេ ។ បញ្ញត្តិថា ព្រះមានព្រះភាគ នេះកើតព្រោះការត្រាស់ដឹង ហេតុនោះ (ទើបមាន ពាក្យថា) ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលបោសាល: ។

[៦៨] អធិប្បាយពាក្យថា ព្រះតថាគតទ្រង់ជ្រាបច្បាស់ ត្រង់ពាក្យថា ជ្រាបច្បាស់ គឺយល់ច្បាស់ ដឹងប្រាកដ ចាក់ធ្ងុ: ។ ពាក្យថា ព្រះតថាគត មានន័យដូចតទៅនេះ មែនពិត ព្រះមានព្រះភាគទ្រង់ត្រាស់ពាក្យនេះថា ម្នាលចុន្ទ: បើពាក្យអតីត ជាពាក្យមិនពិត មិនទៀង មិនប្រកបដោយ ប្រយោជន៍ ព្រះតថាគតមិនពោលពាក្យនោះ ម្នាលចុន្ទ: បើពាក្យ អតីត ជាពាក្យពិត ទៀងត្រង់ តែមិនប្រកបដោយប្រយោជន៍ ព្រះតថាគត ក៏មិនពោលពាក្យនោះ ម្នាលចុន្ទ: បើពាក្យអតីត ជាពាក្យពិត ទៀងត្រង់ ប្រកបដោយប្រយោជន៍ ព្រះតថាគត ជាអ្នកដឹងកាលគួរ ទើបញ្ជាក ប្រស្នានោះ ក្នុងពាក្យនោះ ម្នាលចុន្ទ: បើពាក្យអនាគត ។ លេ ។

បច្ចុប្បន្នញ្ចេបិ ចុន្ទ ហោតិ អភូតំ អតច្ចំ អនត្ថសញ្ហិតំ ន
តំ តថាគតោ ព្យាករោតិ បច្ចុប្បន្នញ្ចេបិ ចុន្ទ ហោតិ
ភូតំ តច្ចំ អនត្ថសញ្ហិតំ តម្បិ តថាគតោ ន ព្យាករោតិ
បច្ចុប្បន្នញ្ចេបិ ចុន្ទ ហោតិ ភូតំ តច្ចំ អត្ថសញ្ហិតំ តត្រ
កាលញ្ញូ តថាគតោ ហោតិ តស្ស បញ្ហស្ស វេយ្យា-
ករណាយ ឥតិ ខោ ចុន្ទ អតីតានាគតប្បច្ចុប្បន្នេសុ
ធម្មេសុ តថាគតោ កាលវាទី ភូតវាទី អត្ថវាទី
ធម្មវាទី វិនយវាទី តស្មា តថាគតោតិ វុច្ចតិ ។
យំ ខោ ចុន្ទ សទេវកស្ស លោកស្ស សមារ-
កស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា
បជាយ សទេវមនុស្សាយ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ
បត្តំ បរិយេសិតំ អនុវិចរិតំ មនសា សព្វន្តំ តថា-
គតេន អភិសម្ពុទ្ធំ តស្មា តថាគតោតិ វុច្ចតិ ។
យញ្ច ចុន្ទ រត្តឺ តថាគតោ អនុត្តរំ សម្មាស-
ម្ពោធឺ អភិសម្ពុជ្ឈតិ យញ្ច រត្តឺ អនុចាទិសេ-
សាយ និព្ពានធាតុយា បរិនិព្ពាយតិ យំ ឯតស្មឺ
អន្តរេ ភាសតិ លបតិ និទ្ទិសតិ សព្វន្តំ តថេវ
ហោតិ នោ អញ្ញថា តស្មា តថាគតោតិ វុច្ចតិ ។

ម្នាលចុន្ទ: បើពាក្យបច្ចុប្បន្ន ជាពាក្យមិនពិត មិនទៀងត្រង់ មិនប្រកបដោយប្រយោជន៍ ព្រះតថាគតមិនពោលពាក្យនោះ ម្នាលចុន្ទ: បើពាក្យបច្ចុប្បន្ន ជាពាក្យពិត ទៀងត្រង់ តែមិនប្រកបដោយប្រយោជន៍ ព្រះតថាគត ក៏មិនពោលពាក្យនោះ ម្នាលចុន្ទ: បើពាក្យបច្ចុប្បន្ន ជាពាក្យពិត ទៀងត្រង់ ប្រកបដោយប្រយោជន៍ ព្រះតថាគតជាអ្នកដឹងកាលគួរ ទើបព្យាករប្រស្នានោះ ក្នុងពាក្យនោះ ម្នាលចុន្ទ: ព្រះតថាគតជាអ្នកពោលតាមកាល ពោលពាក្យពិត ពោលអត្ថ ពោលធម៌ ពោលវិន័យ ក្នុងធម៌ទាំងឡាយជាអតីត អនាគត បច្ចុប្បន្ន ដោយប្រ-ការដូច្នេះឯង ហេតុនោះ ទើបហៅថា ព្រះតថាគត ។ ម្នាលចុន្ទ: ធម្មជាតណា ដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ទាំងពួកសត្ត្ব ព្រមទាំងសមណ:និងព្រាហ្មណ៍ មនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ឃើញ ឮ ប៉ះពាល់ ដឹងច្បាស់ សម្រេច ស្វែងរកពិចារណា ធម្មជាតទាំងអស់នោះ ព្រះតថាគតត្រាស់ដឹងហើយ ដោយចិត្ត ហេតុនោះ ទើបហៅថា ព្រះតថាគត ។ ម្នាលចុន្ទ: ព្រះតថាគតត្រាស់ដឹងសម្មាសម្ពោធិញ្ញាណដ៏ក្រៃលែងក្នុងរាត្រីណា បរិនិព្វានដោយអនុបាទិ-សេសនិព្វានធាតុ ក្នុងរាត្រីណា រមែងពោល ចរចា សម្តែងនូវពាក្យណា ក្នុងចន្លោះនៃការត្រាស់ដឹងនិងការបរិនិព្វាននោះ របស់ទាំងអស់នោះ នៅដូចដែល មិនប្រែប្រួលទេ ហេតុនោះ ទើបហៅថា ព្រះតថាគត ។

យថាវាទី ចុន្ទ តថាគតោ តថាការី យថាការី តថា-
វាទី ឥតិ យថាវាទី តថាការី យថាការី តថាវាទី
តស្មា តថាគតោតិ វុច្ចតិ ។ សទេវកេ ចុន្ទ លោកេ
សមារកេ សព្រហ្មកេ សស្សមណាព្រាហ្មណិយា
បជាយ សទេវមនុស្សាយ តថាគតោ អភិភូ អន-
ភិភូតោ អញ្ញទត្ថុទសោ វសវត្តី តស្មា តថាគតោតិ
វុច្ចតីតិ អភិជានំ តថាគតោ ។

[៤៩] តិដ្ឋន្តមេនំ ជានាតីតិ ភគវា ឥធដ្ឋញ្ញេវ ជា-
ជានាតិ កម្មាភិសង្ខារវសេន អយំ បុគ្គលោ កាយស្ស
ភេទា បរម្មរណា អចាយំ ឧក្ខិត្តឹ រិនិចាតំ និរយំ ឧប-
បជ្ជិស្សតីតិ ។ ភគវា ឥធដ្ឋញ្ញេវ ជានាតិ កម្មាភិស-
សង្ខារវសេន អយំ បុគ្គលោ កាយស្ស ភេទា បរម្មរណា
តិរច្ឆានយោនឹ ឧបបជ្ជិស្សតីតិ ។ ភគវា ឥធដ្ឋញ្ញេវ
ជានាតិ កម្មាភិសង្ខារវសេន អយំ បុគ្គលោ កាយ-
ស្ស ភេទា បរម្មរណា បិត្តិវិសយំ ឧបបជ្ជិស្សតីតិ ។

ម្នាលចុន្ទ: ព្រះតថាគត ពោលយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ពោលយ៉ាងនោះ ព្រោះហេតុតែព្រះតថាគត ពោលយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ពោលយ៉ាងនោះ ហេតុនោះ ទើបហៅថា ព្រះតថាគត ។ ម្នាលចុន្ទ: ព្រះតថាគតគ្របសង្កត់នូវលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពួកសត្ត ព្រមទាំងសមណៈនិងព្រាហ្មណ៍ មនុស្សជាសម្មតិ-ទេពនិងមនុស្សដ៏សេស មិនមានអ្នកណាគ្របសង្កត់បាន តែងឃើញពិតញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅ ហេតុនោះ ទើបហៅថា ព្រះតថាគត ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រះតថាគត ទ្រង់ជ្រាបច្បាស់ ។

[៦៩] ពាក្យថា ទើបទ្រង់ជ្រាបនូវបុគ្គលនោះ ដែលកំពុងរស់នៅ អធិប្បាយថា ព្រះមានព្រះភាគទ្រង់ជ្រាប នូវបុគ្គលដែលឋិតនៅក្នុងទីនេះឯង ដោយអំណាចកម្មាភិសង្ខារថា បុគ្គលនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ព្រះមានព្រះភាគទ្រង់ជ្រាបនូវបុគ្គល ដែលឋិតនៅក្នុងទីនេះឯង ដោយអំណាចកម្មាភិសង្ខារថា បុគ្គលនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ។ ព្រះមានព្រះភាគទ្រង់ជ្រាបនូវបុគ្គលដែលឋិតនៅ ក្នុងទីនេះឯង ដោយអំណាចកម្មាភិសង្ខារថា បុគ្គលនេះលុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងបិត្តិវិស័យ ។

៣៧

ភគវា ឥធដ្ឋញ្ញេវ ជានាតិ កម្មាភិសង្ខារវសេន អយំ បុគ្គលោ កាយស្ស ភេទា បរម្មរណា មនុស្សេសុ ឧប្បជ្ជិស្សតីតិ ។ ភគវា ឥធដ្ឋញ្ញេវ ជានាតិ កម្មាភិសង្ខារវសេន អយំ បុគ្គលោ[១] កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សតីតិ ។ វុត្តញ្ហេតំ ភគវតា ឥធ បនាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារូឡ្ហោ យថា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជិស្សតីតិ ។ ឥធ បនាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារូឡ្ហោ យថា កាយស្ស ភេទា បរម្មរណា តិរច្ឆានយោនឹ ឧបបជ្ជិស្សតីតិ ។ ឥធ បនាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ

១ ម. ឯត្ថន្តរេ សុប្បដិបន្នោតិ ទិស្សតិ ។

ព្រះមានព្រះភាគទ្រង់ជ្រាប នូវបុគ្គលដែលឋិតនៅក្នុងទីនេះឯង ដោយអំណាចកម្មាកិសង្ខារថា បុគ្គលនេះលុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងពួកមនុស្ស ។ ព្រះមានព្រះភាគទ្រង់ជ្រាប នូវបុគ្គលដែលឋិតនៅក្នុងទីនេះឯង ដោយអំណាចកម្មាកិសង្ខារថា បុគ្គលនេះលុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ដូចពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្ត របស់បុគ្គលពួកខ្លះក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្ត របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ។ ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្ត របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ

តថា ច ឥរិយតិ តញ្ច មក្តំ សមារូឡ្ហោ យថា
ការយស្ស ភេជ្ជ បរម្ការណា ឋិត្តិវិសយំ ឧបបជ្ជិស្ស-
តីតិ ។ ឥជ្ជ បជ្ជាហ សារីបុត្ត ឯកចំ បុគ្គលំ ឯវ
ចេតសា ចេតោ បរិច្ច បជ្ជានាមិ តថាយ បុគ្គលោ
បដិបន្ទោ តថា ច ឥរិយតិ តញ្ច មក្តំ សមារូ-
ឡ្ហោ យថា ការយស្ស ភេជ្ជ បរម្ការណា មនុស្ស្ស
ឧបបជ្ជិស្ស្ស្ស្ស្ស ។ ឥជ្ជ បជ្ជាហ សារីបុត្ត ឯកចំ
បុគ្គលំ ឯវ ចេតសា ចេតោ បរិច្ច បជ្ជានាមិ តថាយ
បុគ្គលោ បដិបន្ទោ តថា ច ឥរិយតិ តញ្ច មក្តំ
សមារូឡ្ហោ យថា ការយស្ស ភេជ្ជ បរម្ការណា
សុគតឺ សក្ខ លោកំ ឧប្ជ្ជិស្ស្ស្ស ។ ឥជ្ជ បជ្ជ-
ហ សារីបុត្ត ឯកចំ បុគ្គលំ ឯវ ចេតសា ចេតោ
បរិច្ច បជ្ជានាមិ តថាយ បុគ្គលោ បដិបន្ទោ តថា
ច ឥរិយតិ តញ្ច មក្តំ សមារូឡ្ហោ យថា អាសវានំ
ខយ អជ្ជាសវ ចេតោវិមុត្តឺ បញ្ញាវិមុត្តឺ ឥជ្ជេ ឆម្ម
សយ អភិញ្ញ សច្ឆិកត្ថ ឧបសម្ជ្ជ វិហរិស្ស្ស្ស
ឥជ្ជ ឆ្ជ ឆ្ជ ជ្ជ ។

ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងបិត្តិវិស័យ ។ ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា បុគ្គលនោះ ប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងពួកមនុស្ស ។ ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្ត របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា បុគ្គលនេះ ប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយ រាងកាយស្លាប់ទៅ នឹងទៅកើត ក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្ត របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ នឹងត្រាស់ដឹងដោយខ្លួនឯង ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវ ចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈ ទាំងឡាយ ហើយសម្រេចសម្រាន្តនៅក្នុងបច្ចុប្បន្ន ហេតុនោះ (ទ្រង់ត្រាស់ថា) ទើបទ្រង់ជ្រាបនូវបុគ្គលនោះ ដែលកំពុងរស់នៅ ។

[៤០] វិមុត្តំ តប្ប្រាយនន្តិ វិមុត្តន្តិ អាកិញ្ចញ្ញា-
យតនេ វិមុត្តំ តទធិមុត្តំ តជ្ជាធិបតេយ្យ ។ អថវា
ភគវា ជានាតិ អយំ បុគ្គលោ រូ្ចាធិមុត្តោ សទ្ធាធិ-
មុត្តោ ឧជ្ជាធិមុត្តោ រសាធិមុត្តោ ផោដ្ឋព្ជាធិមុត្តោ
ឥដ្ឋានិមុត្តោ ឧណ្ណាធិមុត្តោ អាវាសាធិមុត្តោ លាភា-
ធិមុត្តោ យសាធិមុត្តោ បសំសាធិមុត្តោ សុខាធិមុត្តោ
ចីវរាធិមុត្តោ បិណ្ឌាចាតាធិមុត្តោ សេនាសនាធិមុត្តោ
គិលានប្ប្ចយភេសជ្ជបរិក្ខារាធិមុត្តោ សុត្តន្តាធិមុត្តោ
វិនយាធិមុត្តោ អភិធម្មាធិមុត្តោ បំសុកូលិកង្គាធិមុត្តោ
តេចីវរិកង្គាធិមុត្តោ បិណ្ឌាចាតិកង្គាធិមុត្តោ សបទា-
នចារិកង្គាធិមុត្តោ ឯកាសនិកង្គាធិមុត្តោ បត្តបិណ្ឌិ-
កង្គាធិមុត្តោ ខលុបច្ឆាភត្តិកង្គាធិមុត្តោ អារញ្ញិក-
ង្គាធិមុត្តោ រុក្ខមូលិកង្គាធិមុត្តោ អព្ភោកាសិកង្គាធិ-
មុត្តោ សោសានិកង្គាធិមុត្តោ យថាសន្ថតិកង្គាធិ-
មុត្តោ ឧសជ្ជិកង្គាធិមុត្តោ បឋមជ្ឈានាធិមុត្តោ ទុតិយ-
ជ្ឈានាធិមុត្តោ តតិយជ្ឈានាធិមុត្តោ ចតុត្ថជ្ឈានាធិមុត្តោ

[៩០] *អធិប្បាយពាក្យថា អ្នកមានចិត្តងប់ (ក្នុងអាកិញ្ចញ្ញាយតនៈ) មានអាកិញ្ចញ្ញាយតនៈនោះប្រព្រឹត្តទៅខាងមុខ ត្រង់ពាក្យថា អ្នកមានចិត្តងប់ គឺមានចិត្តងប់ក្នុងអាកិញ្ចញ្ញាយតនៈ ជ្រប់ក្នុងអាកិញ្ចញ្ញាយតនៈនោះ មានអាកិញ្ចញ្ញាយតនៈនោះជាអធិបតី ។ មួយទៀត ព្រះមានព្រះភាគទ្រង់ជ្រាបថា បុគ្គលនេះងប់ក្នុងរូប ងប់ក្នុងសំឡេង ងប់ក្នុងក្លិន ងប់ក្នុងរស ងប់ក្នុងផោដ្ឋព្វៈ ងប់ក្នុងត្រកូល ងប់ក្នុងគណៈ ងប់ក្នុងអាវាស ងប់ក្នុងលាភ ងប់ក្នុងយស ងប់ក្នុងសេចក្តីសរសើរ ងប់ក្នុងសុខ ងប់ក្នុងចីវរ ងប់ក្នុងបិណ្ឌបាត ងប់ក្នុងសេនាសនៈ ងប់ក្នុងគិលានប្បច្ចយភេសជ្ជបរិក្ខារ ងប់ក្នុងព្រះសូត្រ ងប់ក្នុងព្រះវិន័យ ងប់ក្នុងអភិធម្ម ងប់ក្នុងបំសុកូលិកង្គៈ ងប់ក្នុងតេចីវរិកង្គៈ ងប់ក្នុងបិណ្ឌបាតិកង្គៈ ងប់ក្នុងសបទានចារិកង្គៈ ងប់ក្នុងឯកាសនិកង្គៈ ងប់ក្នុងបត្តបិណ្ឌិកង្គៈ ងប់ក្នុងខលុបច្ឆាកត្តិកង្គៈ ងប់ក្នុងអារញ្ញិកង្គៈ ងប់ក្នុងរុក្ខមូលិកង្គៈ ងប់ក្នុងអព្ភោកាសិកង្គៈ ងប់ក្នុងសោសានិកង្គៈ ងប់ក្នុងយថាសន្ថតិកង្គៈ ងប់ក្នុងនេសជ្ជិកង្គៈ ងប់ក្នុងបឋមជ្ឈាន ងប់ក្នុងទុតិយជ្ឈាន ងប់ក្នុងតតិយជ្ឈាន ងប់ក្នុងចតុត្ថជ្ឈាន*

អាកាសានញ្ចាយតនសមាបត្តាធិមុត្តោ វិញ្ញាណញ្ចា-
យតនសមាបត្តាធិមុត្តោ អាកិញ្ចញ្ញាយតនសមាបត្តា-
ធិមុត្តោ នេវសញ្ញានាសញ្ញាយតនសមាបត្តាធិមុត្តោតិ
វិមុត្តំ ។ តប្ប្រាយនន្តិ អាកិញ្ចញ្ញាយតនមយំ តប្ប-
ព្រាយនំ កម្មប្ប្រាយនំ វិចាកប្ប្រាយនំ កម្មតរុកំ
បដិសន្ធិតរុកំ ។ អថវា ភគវា ជានាតិ អយំ បុគ្គលោ
រូបប្ប្រាយនោ ។ បេ ។ នេវសញ្ញានាសញ្ញាយតនស-
មាបត្តិប្ប្រាយនោតិ វិមុត្តំ តប្ប្រាយនំ ។ តេនាហ
ភគវា

វិញ្ញាណដ្ឋិតិយោ សព្វា (ចោសាលាតិ ភគវា)
អភិជានំ តថាគតោ
តិដ្ឋន្តមេនំ ជានាតិ
វិមុត្តំ តប្ប្រាយនន្តិ ។

ដ៏ប់ក្នុងអាកាសានញ្ចាយតនសមាបត្តិ ដ៏ប់ក្នុងវិញ្ញាណញ្ចាយតនសមាបត្តិ ដ៏ប់ក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ ដ៏ប់ក្នុងនេវសញ្ញានាសញ្ញាយតនសមាបត្តិ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមានចិត្តដ៏ប់ ។ ពាក្យថា មានអាកិញ្ចញ្ញាយតនៈប្រព្រឹត្តទៅខាងមុខ គឺ សម្រេចដោយអាកិញ្ចញ្ញាយ-តនៈ មានសមាបត្តិនោះប្រព្រឹត្តទៅខាងមុខ មានកម្មប្រព្រឹត្តទៅខាងមុខ មានវិបាកប្រព្រឹត្តទៅខាងមុខ ធ្ងន់ដោយកម្ម ធ្ងន់ដោយបដិសន្ធិ ។ មួយវិញទៀត ព្រះមានព្រះភាគទ្រង់ជ្រាបថា បុគ្គលនេះ មានរូបប្រព្រឹត្តទៅខាងមុខ ។ បេ ។ មាននេវសញ្ញានាសញ្ញាយតនសមាបត្តិ ប្រព្រឹត្តទៅខាងមុខ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមានចិត្តដ៏ប់ក្នុងអាកិញ្ចញ្ញាយតនៈ មានអាកិញ្ចញ្ញាយតនៈនោះប្រព្រឹត្តទៅខាងមុខ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលបោសាលៈ) ព្រះតថាគត ទ្រង់ជ្រាបច្បាស់នូវវិញ្ញាណដ្ឋិតិទាំងពួង ទើបទ្រង់ជ្រាបនូវបុគ្គលនោះ ដែលកំពុងរស់នៅ មានចិត្តដ៏ប់ក្នុងអាកិញ្ចញ្ញាយតនៈ មានអាកិញ្ចញ្ញាយតនៈនោះប្រព្រឹត្តទៅខាងមុខ ។

បោសាលមាណវកប្បញ្ហានិទ្ទេសោ

[៤១] អាកិញ្ចញ្ញាសម្ភវំ ញត្វា ឧន្ធិសញ្ញោជនំ ឥតិ
ឯវមេតំ អភិញ្ញាយ តតោ តត្ថ វិបស្សតិ
ឯតំ ញាណំ តថំ តស្ស ព្រាហ្មណស្ស វុសីមតោ ។

[៤២] អាកិញ្ចញ្ញាសម្ភវំ ញត្វាតិ អាកិញ្ចញ្ញ-
សម្ភវោ វុច្ចតិ អាកិញ្ចញ្ញាយតនសំវត្តនិកោ កម្ម-
ភិសង្ខារោ ។ អាកិញ្ចញ្ញាយតនសំវត្តនិកំ កម្មភិ-
សង្ខារំ អាកិញ្ចញ្ញាសម្ភវោតិ ញត្វា លក្ខនន្តិ ញត្វា
ពន្ធនន្តិ ញត្វា បលិពោធោតិ ញត្វា ជានិត្វា
តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ
អាកិញ្ចញ្ញាសម្ភវំ ញត្វា ។

[៤៣] ឧន្ធិសញ្ញោជនំ ឥតីតិ ឧន្ធិសញ្ញោជនំ វុច្ចតិ
អរូបភវោ ។ អរូបភវេន តំ កម្មំ លក្ខំ លក្ខិតំ បលិ-
ពុទ្ធំ អរូបភវំ ឧន្ធិសញ្ញោជនន្តំ ញត្វា លក្ខនន្តិ ញត្វា

[៥១] *បុគ្គលដឹងនូវការកើតព្រមនៃអាកិញ្ចញ្ញា ដឹងនូវសេចក្ដីរីករាយ ជាគ្រឿងប្រកបដូច្នេះ លុះដឹងច្បាស់សេចក្ដីនុ៎ះយ៉ាងនេះ ហើយចេញអំពីសមាបត្តិនោះ រមែងឃើញច្បាស់ក្នុងសមាបត្តិនោះ នេះឯងជាញាណដ៏ពិតប្រាកដ របស់ព្រាហ្មណ៍ដែលមានព្រហ្មចរិយៈនៅរួចហើយនោះ ។*

[៥២] *ពាក្យថា ដឹងនូវការកើតព្រមនៃអាកិញ្ចញ្ញា សេចក្ដីថា កម្មាភិសង្ខារ ដែលញុំងអាកិញ្ចញ្ញាយតនៈ ឲ្យប្រព្រឹត្តទៅព្រម លោកហៅថា ការកើតព្រមនៃអាកិញ្ចញ្ញា ។ បុគ្គល ដឹងនូវកម្មាភិសង្ខារ ដែលញុំងអាកិញ្ចញ្ញាយតនៈឲ្យប្រព្រឹត្តទៅព្រមថា ការកើតព្រម នៃអាកិញ្ចញ្ញា ដឹងថាជាគ្រឿងជាប់ ដឹងថាជាចំណង ដឹង ស្គាល់ ស្ទង់មើល ពិចារណា ចម្រើន ធ្វើឲ្យប្រាកដថាជាគ្រឿងកង្វល់ ហេតុនោះ (ទ្រង់ត្រាស់ថា) ដឹងនូវការកើតព្រមនៃអាកិញ្ចញ្ញា ។*

[៥៣] *ពាក្យថា សេចក្ដីរីករាយជាគ្រឿងប្រកបដូច្នេះ គឺសេចក្ដីត្រេកត្រអាលក្នុងអរូប ហៅថា សេចក្ដីរីករាយជាគ្រឿងប្រកប ។ កម្មនោះជាប់ជាប់ស្អិត ខ្ជ្ល ដោយសេចក្ដីត្រេកត្រអាលក្នុងអរូប បុគ្គលដឹងនូវសេចក្ដីត្រេកត្រអាលក្នុងអរូបថា សេចក្ដីរីករាយជាគ្រឿងប្រកប ដឹងថាជាគ្រឿងជាប់*

ពន្ធនន្តិ ញត្វា បលិពោធោតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ ឥតីតិ បឧសន្ធិ ។ បេ ។ បជានុបុព្វកមេតំ ឥតីតិ ឧន្ធិសញ្ញោ ជនំ ឥតិ ។

[៤៤] ឯវមេតំ អភិញ្ញាយាតិ ឯវំ ឯតំ អភិ-ញ្ញាយ ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ឯវមេតំ អភិញ្ញាយ ។

[៤៥] តតោ តត្ត វិបស្សតីតិ អាកិញ្ចញ្ញាយ-តនំ សមាបជ្ជិត្វា តតោ រុដ្ឋហិត្វា តត្ត ជាតេ ចិត្តចេតសិកេ ធម្មេ អនិច្ចតោ វិបស្សតិ ទុក្ខតោ វិបស្សតិ រោគតោ ។ បេ ។ អនិស្សរណតោ វិប-ស្សតិ ឧក្ខិតិ ឱលោកេតិ ជិជ្ឈាយតិ ឧបបរិក្ខតីតិ តតោ តត្ត វិបស្សតិ ។

[៤៦] ឯតំ ញាណំ តថំ តស្សាតិ ឯតំ ញាណំ តច្ឆំ ភូតំ យាថាវំ អវិបរីតំ តស្សាតិ ឯតំ ញាណំ តថំ តស្ស ។

ដឹងថាជាគ្រឿងចង ដឹង ស្គាល់ ស្ទង់មើល ពិចារណា ចម្រើន ធ្វើឲ្យ ជាក់ច្បាស់ថាជាកង្វល់ ។ ពាក្យថា ដូច្នេះ ជាការតបទ ។ បេ ។ ពាក្យថា ដូច្នេះ នេះជាលំដាប់បទ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្តីរីករាយ ជាគ្រឿងប្រកបដូច្នេះ ។

[៥៤] ពាក្យថា លុះដឹងច្បាស់ សេចក្តីនុ៎ះយ៉ាងនេះហើយ គឺ ដឹង ស្គាល់ ស្ទង់មើល ពិចារណា ចម្រើន ធ្វើឲ្យប្រាកដ នូវសេចក្តីនុ៎ះយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) លុះដឹងច្បាស់សេចក្តីនុ៎ះយ៉ាងនេះហើយ ។

[៥៥] ពាក្យថា ចេញអំពីសមាបត្តិនោះ រមែងឃើញច្បាស់ក្នុង សមាបត្តិនោះ គឺចូលអាកិញ្ចញ្ញាយតនៈ ហើយចេញចាកសមាបត្តិនោះ រមែងឃើញច្បាស់ នូវពួកធម៌គឺចិត្តនិងចេតសិក ដែលកើតក្នុងសមាបត្តិ នោះថា មិនទៀង ឃើញច្បាស់ថាជាទុក្ខ យល់ច្បាស់ ឃើញ ក្រឡេក មើល សម្ងឹងមើល កំណត់មើលថាជារោគ ។ បេ ។ ថាមិនជាទីរលាស់ទុក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) ចេញអំពីសមាបត្តិនោះ រមែងឃើញច្បាស់ ក្នុងសមាបត្តិនោះ ។

[៥៦] ពាក្យថា នេះឯងជាញាណដ៏ពិតប្រាកដ របស់ព្រាហ្មណ៍ នោះ សេចក្តីថា ញាណនុ៎ះរបស់ព្រាហ្មណ៍នោះ ជាធម្មជាតពិត ទៀង ប្រាកដ មិនប្រែប្រួល ហេតុនោះ (ទ្រង់ត្រាស់ថា) នេះឯងជាញាណ ដ៏ពិតប្រាកដ របស់ព្រាហ្មណ៍នោះ ។

បោសាលមាណវកប្បញ្ហានិទ្ទេសោ

[៥៧] ព្រាហ្មណស្ស វុសីមតោតិ ព្រាហ្មណស្សាតិ សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ ។ បេ ។ អនិស្សិតោ តាទិ បវុច្ចតេ ស ព្រហ្មាតិ ព្រាហ្មណស្ស ។ វុសីមតោតិ កល្យាណបុថុជ្ជនេ ឧបាទាយ សត្ត សេក្ខា អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ វសន្តិ សំវសន្តិ អាវសន្តិ បរិវសន្តិ ។ អរហា វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។ បេ ។ ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ ព្រាហ្មណស្ស វុសីមតោ ។ តេនាហ ភគវា

បោសាលមាណវកប្បញ្ហានិទ្ទេស

[៥៧] ពាក្យថា របស់ព្រាហ្មណ៍ ក្នុងបទថា របស់ព្រាហ្មណ៍ដែលមានព្រហ្មចរិយៈនៅរួចហើយ គឺឈ្មោះថាព្រាហ្មណ៍ ព្រោះបន្សាត់បង់ធម៌ទាំង ៧ ។ បេ ។ ជាបុគ្គលមិនអាស្រ័យកិលេស មិនញាប់ញ័ររ បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ហេតុនោះ (ទ្រង់ត្រាស់ថា) របស់ព្រាហ្មណ៍ ។ ពាក្យថា មានព្រហ្មចរិយៈនៅរួចហើយ បានដល់ពួកសេក្ខៈទាំង ៧ រាប់បញ្ចូលទាំងកល្យាណបុថុជ្ជន រមែងនៅ នៅគ្រប់គ្រងនៅថែទាំ នៅនិត្យ ដើម្បីសម្រេចគុណវិសេសដែលមិនទាន់ដល់ ដើម្បីបានធម៌ដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ ។ ព្រះអរហន្តមានព្រហ្មចរិយៈនៅរួចហើយ មានករណីយកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ខ្លួនសម្រេចហើយ មានសញ្ញោជនៈក្នុងភពអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ព្រះអរហន្តនោះ ឈ្មោះថាមានអរិយវាសនៅរួចហើយ មានចរណៈសន្សំហើយ ។ បេ ។ ភពថ្មី គឺ ជាតិ ជរា មរណៈ សង្សារ របស់ព្រះអរហន្តនោះមិនមានទេ ហេតុនោះ (ទ្រង់ត្រាស់ថា) របស់ព្រាហ្មណ៍ ដែលមានព្រហ្មចរិយៈនៅរួចហើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អាកិញ្ចញ្ញាសម្ភវំ ញត្វា ឧន្ធិសញ្ញោជនំ ឥតិ
ឯវមេតំ អភិញ្ញាយ តតោ តត្ថ វិបស្សតិ
ឯតំ ញាណំ តទំ តស្ស ព្រាហ្មណស្ស វុសីមតោតិ ។

សហ គាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

ពោសាលមាណវកប្បញ្ហានិទ្ទេសោ ចុទ្ទសមោ ។

បុគ្គល ដឹងនូវការកើតព្រម នៃអាកិញ្ចញ្ញា ដឹងនូវសេចក្តីរីកវាយជាគ្រឿងប្រកប ដូច្នេះ លុះដឹងច្បាស់សេចក្តីនុ៎ះយ៉ាងនេះ ហើយចេញ អំពីសមាបត្តិនោះ រមែងឃើញច្បាស់ក្នុងសមាបត្តិនោះ នេះឯងជាញាណដ៏ពិតប្រាកដ របស់ព្រាហ្មណ៍ ដែលមានព្រហ្មចរិយធម៌នៅរួចហើយនោះ ។ លុះចប់គាថា ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមជាសាវ័ក ។

ចប់ ឧបាសាលមាណវកឬញ្ជានិទ្ទេស ទី ១៤ ។

មោឃរាជមាណវកបញ្ហានិទ្ទេសោ

[៨៨] ទ្វាហំ សក្ក អបុច្ឆិស្សំ

(ឥច្ចាយស្មា មោឃរាជា)

ន មេ ព្យាកាសិ ចក្ខុមា

យាវតតិយញ្ច ទេវិសិ

ព្យាករោតីតិ មេ សុតំ ។

[៨៩] ទ្វាហំ សក្ក អបុច្ឆិស្សន្តិ សោ ព្រាហ្មណោ ទ្វិក្ខត្តុំ ពុទ្ធំ ភគវន្តំ បញ្ហំ អបុច្ឆិ តស្ស ភគវា បញ្ហំ បុដ្ឋោ ន ព្យាកាសិ ចក្ខុសមនន្តរា[១] ឥមស្ស ព្រាហ្មណស្ស ឥន្ទ្រិយបរិបាកោ ភវិស្សតីតិ ។ សក្កាតិ សក្កោ ។ ភគវា សក្យកុលា បព្វជិតោតិបិ សក្កោ ។ អថវា អឌ្ឍោ មហទ្ធនោ ធនវាតិបិ សក្កោ ។ តស្សិមានិ ធនានិ សេយ្យថីទំ សទ្ធាធនំ សីលធនំ ហិរិធនំ ឱត្តប្បធនំ សុតធនំ ចាគធនំ

១ ម. តទន្តរា ។

មោឃរាជមាណវកปัญญานิទ្ទេส

[៥៨] (មោឃរាជមានអាយុ ទូលដូច្នេះថា) បពិត្រព្រះអង្គជាសក្ក: ខ្ញុំព្រះអង្គបានទូលសួរ អស់វារ:ពីរដងរួចហើយ ព្រះអង្គមានចក្ខុ ទ្រង់មិនទាន់ដោះស្រាយ ចំពោះខ្ញុំព្រះអង្គនៅឡើយ ខ្ញុំព្រះអង្គបានឮថា ព្រះអង្គជាទេវឬសី (កាលបើមានគេសាកសួរ) អស់វារ:បីដង ទ្រង់តែងតែព្យាករពុំខាន ។

[៥៩] ពាក្យថា បពិត្រព្រះអង្គជាសក្ក: ខ្ញុំព្រះអង្គបានទូលសួរ អស់វារ:ពីរដងរួចហើយ អធិប្បាយថា ព្រាហ្មណ៍នោះ បានទូលសួរប្រស្នាចំពោះព្រះពុទ្ធមានព្រះភាគ អស់វារ:ពីរដងរួចហើយ តែព្រះមានព្រះភាគ កាលព្រាហ្មណ៍នោះសួរប្រស្នាហើយ ទ្រង់មិនទាន់ព្យាករនៅឡើយ ដោយទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍នេះ នឹងមានឥន្ទ្រិយចាស់ក្លា ក្នុងកាលជាលំដាប់ស្មើនៃធម្មចក្ខុ ។ ពាក្យថា បពិត្រព្រះអង្គជាសក្ក: គឺព្រះមានព្រះភាគ ឈ្មោះថាសក្ក: ។ ដែលព្រះមានព្រះភាគឈ្មោះសក្ក: ព្រោះហេតុទ្រង់ចេញចាកសក្យត្រកូលហើយបួសក៏បាន ។ ឬថា ឈ្មោះសក្ក: ព្រោះហេតុទ្រង់ស្តុកស្តម្ភ មានទ្រព្យច្រើនមានធនធាន ក៏បាន ។ នេះទ្រព្យរបស់ព្រះអង្គ គឺ ទ្រព្យគឺសទ្ធា ទ្រព្យគឺសីល ទ្រព្យគឺហិរិ ទ្រព្យគឺឱត្តប្ប: ទ្រព្យគឺសុត: ទ្រព្យគឺចាគ:

បញ្ញាធនំ សតិប្ឋានធនំ សម្មប្ឋានធនំ ឥទ្ធិបាទ-
ធនំ ឥន្ទ្រិយធនំ ពលធនំ ពោជ្ឈង្គធនំ មគ្គធនំ
ផលធនំ និព្ឋានធនំ ។ ឥមេហិ អនេកវិធេហិ ធន-
រតនេហិ អង្ខោ មហាទ្ធនោ ធនវាតិបិ សង្ខោ ។
អថវា សង្ខោ បហុ វិសរី អលមត្តោ ស្ងេ រ៉ៃ
រ៉ៃ ក្ខណ្ដោ អកិរុ អច្ឆម្ភី អនុត្រាសី អបលាយី
បហីនភយភេរវោ រ៉ៃតតលោមហំសោតិបិ សង្ខោតិ
ង្ខាហំ សក្ក ។ អបុច្ឆិស្ឆន្ដិ ង្ខាហំ សក្ក អបុច្ឆិស្ឆំ
អយាចិស្ឆំ អជ្ឈេសិស្ឆំ បសាទយិស្ឆន្ដិ ង្ខាហំ
សក្ក អបុច្ឆិស្ឆំ ។ ឥច្ចាយស្ម្ម មោឃរាជាតិ ឥច្ចា-
តិ បទសន្ធិ ។ អាយស្ម្មាតិ បិយវចនំ ។ មោ-
ឃរាជាតិ តស្ស ព្រាហ្ម្ណស្ស នាមំ ។ បេ ។
អកិលាចោតិ ឥច្ចាយស្ម្ម មោឃរាជ ។

ទ្រព្យគឺបញ្ញា ទ្រព្យគឺសតិប្បដ្ឋាន ទ្រព្យគឺសម្មប្បធាន ទ្រព្យគឺឥទ្ធិបាទ ទ្រព្យគឺឥន្ទ្រិយ ទ្រព្យគឺពល: ទ្រព្យគឺពោជ្ឈង្គ: ទ្រព្យគឺមគ្គ ទ្រព្យគឺផល ទ្រព្យគឺនិព្វាន ។ ព្រះនាមសក្ក: ព្រោះហេតុព្រះអង្គស្តុកស្តម្ភ មានទ្រព្យច្រើន មានធនធាន ដោយទ្រព្យដ៏ប្រសើរ ច្រើនប្រការទាំងនេះ ក៏បាន ។ ពុំនោះសោត ឈ្មោះសក្ក: ព្រោះហេតុទ្រង់អង់អាច មោះមុត ក្លាហាន មានព្យាយាមតស៊ូ ក្ងៀវក្ងា សង្វាត ប្រឹងប្រែង មិនខ្ជាច មិនរន្ធត់ មិនតក់ស្ទុត មិនរត់ចោល លះកំ័យគួរខ្ជាច មិនព្រឺរោម ក៏បាន ។ ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាសក្ក: ខ្ញុំព្រះអង្គ (បានទូលសួរ) អស់វារ:ពីរដងរួចហើយ ។ ពាក្យថា ខ្ញុំព្រះអង្គបានទូលសួរ (សេចក្តីថា) បពិត្រព្រះអង្គជាសក្ក: ខ្ញុំព្រះអង្គបានទូលសួរ បានអង្វរ បានអាងធនា បានជ្រះថ្នា អស់វារ:ពីរដងរួចហើយ ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាសក្ក: ខ្ញុំព្រះអង្គបានទូលសួរ អស់វារ:ពីរដងរួចហើយ ។ ពាក្យថា ដូច្នេះ នៃបទថា មោឃរាជមានអាយុទូលដូច្នេះ គឺជាការតបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា មោឃរាជ ជាឈ្មោះ ។ បេ ។ ជាពាក្យសម្រាប់ហៅព្រាហ្មណ៍នោះ ហេតុនោះ (មានពាក្យថា) មោឃរាជមានអាយុទូលដូច្នេះ ។

មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

[៦០] ន មេ ព្យាកាសិ ចក្ខុមាតិ ន មេ ព្យាកាសីតិ មេ ន អាចិក្ខិ[1] ន ទេសេសិ ន បញ្ញបេសិ ន បដ្ឋបេសិ ន វិវរិ ន វិភជិ ន ឧត្តានីម-កាសិ ន បកាសេសិ ។ ចក្ខុមាតិ ភគវា បញ្ចហិ ចក្ខូហិ ចក្ខុមា មំសចក្ខុនាបិ ចក្ខុមា ទិព្វចក្ខុ-នាបិ ចក្ខុមា បញ្ញាចក្ខុនាបិ ចក្ខុមា ពុទ្ធចក្ខុនាបិ ចក្ខុមា សមន្តចក្ខុនាបិ ចក្ខុមា ។

កថំ ភគវា មំសចក្ខុនាបិ ចក្ខុមា ។ មំស-ចក្ខុម្ហិ ភគវតោ បញ្ច វណ្ណា សំវិជ្ជន្តិ នីលោ ច វណ្ណោ បីតកោ ច វណ្ណោ លោហិតកោ ច វណ្ណោ កាឡោ ច វណ្ណោ ឱទាតោ ច វណ្ណោ ។ យត្ត ច អក្ខិលោមានិ បតិដ្ឋិតានិ តំ នីលំ ហោតិ សុនីលំ ចាសាទិកំ ឧស្ឆេយ្យំ ឧម្ការបុប្ផសមានំ ។ តស្ស ឧបរិ បីតកំ ហោតិ សុបីតកំ សុវណ្ណវណ្ណ ចាសាទិកំ ឧស្ឆេយ្យំ កណ្ណិការបុប្ផសមានំ ។

---

1 ម. អាចិក្ខសិ ។

[៦០] *អធិប្បាយពាក្យថា ព្រះអង្គមានចក្ខុ ទ្រង់មិនទាន់ដោះស្រាយចំពោះខ្ញុំព្រះអង្គនៅឡើយ ត្រង់ពាក្យថា មិនទាន់ដោះស្រាយចំពោះខ្ញុំព្រះអង្គ គឺមិនទាន់ប្រាប់ មិនទាន់សម្តែង មិនទាន់បញ្ញត្ត មិនទាន់តាំងទុក មិនទាន់បើក មិនទាន់ចែក មិនទាន់ធ្វើឲ្យងាយ មិនទាន់ប្រកាសដល់ខ្ញុំព្រះអង្គ ។ ពាក្យថា មានចក្ខុ គឺ ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយចក្ខុ ៥ គឺ មានចក្ខុដោយមំសចក្ខុ ១ មានចក្ខុដោយទិព្វចក្ខុ ១ មានចក្ខុដោយបញ្ញាចក្ខុ ១ មានចក្ខុដោយពុទ្ធចក្ខុ ១ មានចក្ខុដោយសមន្តចក្ខុ ១ ។*

ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ដោយមំសចក្ខុ តើដូចម្តេច ។ គឺក្នុងមំសចក្ខុរបស់ព្រះមានព្រះភាគ មានសម្ផុរ ៥ គឺ សម្ផុរខៀវ ១ សម្ផុរលឿង ១ សម្ផុរក្រហម ១ សម្ផុរខ្មៅ ១ សម្ផុរ-ស ១ ។ ទីណា ដែលមានពោមព្រះនេត្រប្រតិស្ឋាននៅ ទីនោះឯង មានសម្ផុរខៀវ ខៀវស្រស់ គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចផ្ការ៉ាត ។ ទីខាងនាយអំពីនោះ មានសម្ផុរលឿង លឿងស្រស់ មានសម្ផុរដូចមាស គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចផ្ការ៉ាកណ្ណិការ ។

ឧភយតោ ច អក្ខិកូចានិ[1] ភវតោ លោហិតកា-
និ ហោន្តិ សុលោហិតកានិ ចាសាទិកានិ ឧស្ស-
ដេយ្យានិ ឥន្ទគោបកសមានានិ ។ មជ្ឌ្យ កណ្ហា
ហោតិ សុកណ្ហា អលូទ្ធ សិនិទ្ធ ចាសាទិកំ ឧស្ស-
ដេយ្យ អច្ឆរិដ្ឌកសមានំ ។ តស្ស ឋ្ឋតោ ឋិតាតំ
ហោតិ សុឋិតាតំ សេតំ បណ្ហារ ចាសាទិកំ ឧស្ស-
ដេយ្យ ឋិសទិតារកសមានំ ។ ដេន ភវ បកតិ-
ម៎ សចក្ខុនា អត្តការបរិយាបន្ដេន បុរិមសុចរិតកម្ម-
ភិនិព្ធ្ធេន សមន្ត យោជនំ បស្ស្ដតិ ទ្ធិ ចេ
ដ្ដ ។ យទាបិ ចតុរ្ដ្ដ សមន្ដ្ដ ដ្ដ ដ្ដ
ហោតិ ស្ដ្ដ ច ដ្ដ ដ្ដ ហោតិ ការ ដ្ដ ដ្ដ
ច ឧ ដ ហោតិ ដ ដ ច ដ ដ ហោតិ
ម ច ដ ដ ដ ដ ដ ដ ដ ដ ។
ដ ដ ដ ដ ដ ដ ដ ដ ។

1 ម. អ្ដ្ដ ។

មួយទៀត រណ្ដៅព្រះនេត្រទាំងពីរខាង របស់ព្រះមានព្រះភាគ មានសម្ផុរក្រហម ក្រហមច្រាល គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចសម្ផុរមេភ្ងៀង ។ ទីត្រង់កណ្ដាល មានសម្ផុរខ្មៅ ខ្មៅស្រស់ មិនសៅហ្នង ស្និទ្ធ គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចសម្ផុរផ្ដែផ្ដាំ ។ ទីខាងនាយពីនោះ មានសម្ផុរ-ស សភ្ងឹង សស្រស់ សថ្ងា គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចផ្ដាយព្រឹក ។ ហេតុនោះ បានជាព្រះមានព្រះភាគតែងទតឃើញមួយយោជន៍ដោយជុំវិញ ទាំងថ្ងៃទាំងយប់ ដោយមំសចក្ខុធម្មតា ដែលរាប់បញ្ចូលក្នុងអត្តភាព កើតដោយផលនៃសុចរិតកម្មក្នុងកាលមុន ។ សូម្បីក្នុងកាលណា ដែលមានងងឹតប្រកបដោយអង្គបួន គឺព្រះអាទិត្យអស្ដង្គត ១ ឧបោសថខាងកាឡបក្ខ ១ ដងព្រៃយ៉ាងក្រាស់ជិត ១ មហាអកាលមេឃ (ភ្ងៀងធំខុសកាល) ប្រាកដឡើង ១ ក្នុងកាលនោះ ព្រះមានព្រះភាគ ទតឃើញមួយយោជន៍ដោយជុំវិញ ក្នុងទីងងឹតប្រកបដោយអង្គបួន មានសភាពយ៉ាងនេះ ។ ផ្ទះកំពូលក្ដី សន្ទឹកទ្វារក្ដី កំពែងក្ដី ភ្នំក្ដី គុម្ពឈើក្ដី រល្ម៉ីក្ដី ជាគ្រឿងរារាំងនូវការឃើញរូបនោះ មិនមានឡើយ ។

ឯកញ្ចេ តិលផលំ ជិមិតំ្ត កត្វា តិលវាហេ បក្ខិ-
ឃេយ្យ តញ្ញេវ តិលផលំ ឧទ្ធរេយ្យ ។ ឯវំ បរិសុទ្ធំ
ភគវតោ បកតិមំសចក្ខុ ។ ឯវំ ភគវា មំសចក្ខុ-
ជាបិ ចក្ខុមា ។

កថំ ភគវា ទិព្វចក្ខុជាបិ ចក្ខុមា ។ ភគវា
ទិព្វេន ចក្ខុជា វិសុទ្ធេន អតិក្កន្តមានុសកេន
។ បេ ។ យថាកម្មុបគេ សត្តេ បជានាតិ ។ អាក-
ង្ខ្ជមានោ ច ភគវា ឯកម្ប៎ិ លោកធាតុំ បស្ស្ជ្ជយ
ទ្ធេបិ លោកធាតុយោ បស្ស្ជ្ជយ្ យ តិស្ស្ជ្ជាបិ លោក-
ធាតុយោ បស្ស្ជ្ជយ្ យ ចតស្ស្ជ្ជាបិ លោកធាតុ-
យោ បស្ស្ជ្ជយ្ យ បញ្ចបិ លោកធាតុយោ បស្ស្ជ-
យ្ យ ទសបិ លោកធាតុយោ បស្ស្ជ្ជយ្ យ វីសម្ប៎ិ
លោកធាតុយោ បស្ស្ជ្ជយ្ យ តឹសម្ប៎ិ លោក-
ធាតុយោ បស្ស្ជ្ជយ្ យ ចត្តាឡ្ីសម្ប៎ិ លោកធាតុយោ
បស្ស្ជ្ជយ្ យ បញ្ញាសម្ប៎ិ លោកធាតុយោ បស្ស្ជ្ជយ្ យ
សតម្ប៎ិ លោកធាតុយោ បស្ស្ជ្ជយ្ យ សហស្ស្ជ្ជិម្ប៎ិ
ចូឡ្ជ្ជនិកំ លោកធាតុំ បស្ស្ជ្ជយ្ យ ទ្ជ្ជិសហស្ស្ជ្ជិម្ប៎ិ

ប្រសិនបើបុគ្គលដាក់គ្រាប់លូមួយគ្រាប់ ក្នុងរនេះ ដែលពេញដោយគ្រាប់លូ ធ្វើឲ្យជាគ្រឿងសម្គាល់ ព្រះមានព្រះភាគ គប្បីរើសយកគ្រាប់លូនោះ ដដែលវិញបាន ។ មំសចក្ខុធម្មតារបស់ព្រះមានព្រះភាគ បរិសុទ្ធយ៉ាងនេះ ។ ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយមំសចក្ខុ យ៉ាងនេះឯង ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយទិព្វចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធកន្ធង់ផុតចក្ខុរបស់មនុស្ស ធម្មតា ។ បេ ។ ទ្រង់ជ្រាបច្បាស់នូវសត្វទាំងឡាយ ដែលរង្គាត់ទៅតាមយថាកម្ម ។ បើព្រះមានព្រះភាគ ប្រាថ្នា (ចង់ឃើញ) គប្បីទតឃើញលោកធាតុមួយក៏បាន ឃើញលោកធាតុ ២ ក៏បាន ឃើញលោកធាតុ ៣ ក៏បាន ឃើញលោកធាតុ ៤ ក៏បាន ឃើញលោកធាតុ ៥ ក៏បាន ឃើញលោកធាតុ ១០ ក៏បាន ឃើញលោកធាតុ ២០ ក៏បាន ឃើញលោក-ធាតុ ៣០ ក៏បាន ឃើញលោកធាតុ ៤០ ក៏បាន ឃើញលោកធាតុ ៥០ ក៏បាន ឃើញលោកធាតុ ១០០ ក៏បាន ឃើញលោកធាតុតូចចំនួន ១ ពាន់ ក៏បាន ឃើញលោកធាតុកណ្តាល ចំនួន ២ ពាន់ ក៏បាន

មជ្ឈិមិកំ លោកធាតុំ បស្សេយ្យ តិសហស្សិម្បិ លោកធាតុំ បស្សេយ្យ មហាសហស្សិម្បិ លោកធាតុំ បស្សេយ្យ ។ យាវតកំ វា បន អាកង្ខេយ្យ តាវតកំ បស្សេយ្យ ។ ឯវំ វិសុទ្ធំ ភិក្ខវេ ទិព្ពចក្ខុ ។ ឯវំ ភិក្ខវ ទិព្ពចក្ខុនាបិ ចក្ខុមា ។

កថំ ភិក្ខវ បញ្ញាចក្ខុនាបិ ចក្ខុមា ។ ភិក្ខវ មហាបញ្ញោ បុថុបញ្ញោ ហាសបញ្ញោ ជវនបញ្ញោ តិក្ខបញ្ញោ និព្ពេធិកបញ្ញោ បញ្ញាភេទកុសលោ បកិន្ទញ្ញាណো អធិគតបដិសម្ភិទោ[1] ចតុវេសារជ្ជ-ប្បត្តោ ទសពលធារី បុរិសាសភោ បុរិសសីហោ បុរិសនាគោ បុរិសាជញ្ញោ បុរិសធោរយ្ហោ អនន្ត-ញ្ញាណো អនន្តតេជো អនន្តយសো អនេ្ត្ត ម-ហាទ្ធនো ធនវា ធេតា វិធេតា អនុធេតា ស-ញ្ញាបេតា និជ្ឌាបេតា បេក្ខេតា បសាទេតា ។

---

1 ម. អធិគតប្បដិសម្ភិទប្បត្តោ ។

ឃើញលោកធាតុចំនួន ៣ពាន់ ក៏បាន ឃើញលោកធាតុមានពាន់ដ៏ច្រើន ក៏បាន ។ មិនតែប៉ុណ្ណោះ ព្រះមានព្រះភាគ មានប្រាជ្ញា (នឹងឃើញ) ត្រឹមណា គប្បីឃើញបានត្រឹមណោះ ។ ទិព្វចក្ខុរបស់ព្រះមានព្រះភាគ បរិសុទ្ធយ៉ាងនេះ ។ ព្រះមានព្រះភាគទ្រង់មានចក្ខុ ដោយទិព្វចក្ខុ យ៉ាងនេះឯង ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ដោយបញ្ញាចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់មានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញារហ័ស មានប្រាជ្ញាមោះមុត មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ទ្រង់ឈ្វាសក្នុងប្រភេទនៃប្រាជ្ញា ទ្រង់បែកព្រះញាណ ទ្រង់បានបដិសម្ភិទា ទ្រង់សម្រេចចតុវេសារជ្ជញ្ញាណ ទ្រទ្រង់នូវកម្លាំង ១០ ជាបុរសប្រសើរ ជាបុរសអង់អាច ជាបុរសនាគ ជាបុរសអាជានេយ្យ ជាបុរសនាំទៅនូវធុរៈ ជាអនន្តញ្ញាណ មានតេជៈមិនមានទីបំផុត មានយសមិនមានទីបំផុត ទ្រង់ស្តុកស្តម្ភ មានទ្រព្យច្រើន មានធនធាន ទ្រង់ដឹកនាំ ទ្រង់ទូន្មាន ប្រៀនប្រដៅ ទ្រង់ពន្យល់ ទ្រង់ដឹកនាំឲ្យគិតគូរ ទ្រង់ឲ្យគយគន់ ទ្រង់ធ្វើឲ្យជ្រះថ្លា ។

សោ ហិ ភគវា អនុប្បន្នស្ស មគ្គស្ស ឧប្ប-
តា អសញ្ជាតស្ស មគ្គស្ស សញ្ជាបេតា[1] អ-
ក្ខាតស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ មគ្គវិទូ ម-
គ្គកោវិទោ ។ មគ្គានុគា ច បន ឯតរហិ សា-
វកា វិហរន្តិ បច្ឆាសមន្នាគតោ ។ សោ ហិ ភគវា
ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ
ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា
អមតស្ស ទាតា ធម្មស្សាមិ តថាគតោ ។ ឧត្តិ
តស្ស ភគវតោ អញ្ញាតំ អទិដ្ឋំ អវិទិតំ អសច្ឆិកតំ
អផុសិតំ បញ្ញាយ ។ អតីតានាគតប្បច្ចុប្បន្នំ ឧចា-
ណាយ សព្វេ ធម្មា សព្វាការេន ពុទ្ធស្ស ភគវតោ
ញាណមុខេ អាចាបមាគច្ឆន្តិ ។ យញ្ហិ ញ្ចិ ដេយ្យំ ជាម
អត្ថិ ជានិតព្ពំ អត្តត្ថោ វ បរត្ថោ វ ឧភយត្ថោ វ
ទិដ្ឋធម្មិកោ វ អត្ថោ សម្ប្រាយិកោ វ អត្ថោ
ឧត្តានោ វ អត្ថោ តម្ហីរោ វ អត្ថោ ភូឡ្ហោ វ
អត្ថោ បដិច្ឆន្នោ វ អត្ថោ ដេយ្យោ វ អត្ថោ ឌីតោ វ

---

1 ម. សញ្ជនេតា ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់ញ៉ាំងមគ្គដែលមិនទាន់កើតឲ្យកើតឡើង ទ្រង់ញ៉ាំងមគ្គដែលមិនទាន់កើតមានឲ្យកើតមាន ទ្រង់ប្រាប់ផ្លូវដែលមិនទាន់ប្រាប់ ទ្រង់ស្គាល់ផ្លូវ ទ្រង់ជ្រាបផ្លូវ ទ្រង់ឈ្វាសវៃក្នុងផ្លូវ ។ ចំណែកពួកសាវ័ក ឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវ ដើរតាមក្រោយ ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបហេតុដែលគួរជ្រាប ទ្រង់ឃើញហេតុដែលគួរឃើញ មានចក្ខុ មានញាណ មានធម៌ មានធម៌ដ៏ប្រសើរ ទ្រង់ជាអ្នកស្តីប្រដៅ ទ្រង់ពោលរំលឹកបង្ហោនទៅរកប្រយោជន៍ឲ្យនូវព្រះនិព្វាន ជាធម្មស្សามិ ជាតថាគត ។ មិនមាន (វត្ថុអ្វីមួយ) ដែលព្រះមានព្រះភាគអង្គនោះ មិនបានដឹង មិនបានឃើញ មិនបានជ្រាប មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានប៉ះពាល់ដោយប្រាជ្ញា ។ ធម៌ទាំងអស់ រាប់ទាំងអតីត អនាគតនិងបច្ចុប្បន្ន រមែងមកកាន់រង្វង់ក្នុងប្រធានៃព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ដោយអាការ: សព្វគ្រប់ ។ ឈ្មោះថាធម្មជាតដែលគប្បីដឹងណាមួយ ដែលជារបស់គួរដឹង គឺប្រយោជន៍ខ្លួនក្តី ប្រយោជន៍ជនដទៃក្តី ប្រយោជន៍ទាំងពីរក្តី ប្រយោជន៍ជាបច្ចុប្បន្នក្តី ប្រយោជន៍ក្នុងលោកខាងមុខក្តី ប្រយោជន៍រាក់ក្តី ប្រយោជន៍ជ្រៅក្តី ប្រយោជន៍លាក់លៀមក្តី ប្រយោជន៍កំបិតកំបាំងក្តី ប្រយោជន៍ដែលគួរដឹងក្តី ប្រយោជន៍ដែលបានដឹងហើយក្តី

អត្តា អនវជ្ជោ វា អត្តា និក្ក្លិលេសោ វា អត្តា ភោគ្គោ វា អត្តា បរមត្តា វា សព្វន្តំ អត្តោ ពុទ្ធញ្ញ-ណេ បរិវត្តតិ ។ សព្វំ កាយកម្មំ ពុទ្ធស្ស ភគវតោ ញាណានុបរិវត្តតិ សព្វំ វចីកម្មំ ញាណានុបរិវត្តតិ សព្វំ មនោកម្មំ ញាណានុបរិវត្តតិ ។ អតីតេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ អនាគតេ ពុទ្ធស្ស ភគ-វតោ អប្បដិហតំ ញាណំ បច្ចុប្បន្នេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ ។ យាវតកំ នេយ្យំ តាវតកំ ញាណំ យាវតកំ ញាណំ តាវតកំ នេយ្យំ នេយ្ស-បរិយន្តិកំ ញាណំ ញាណបរិយន្តិកំ នេយ្យំ នេយ្យំ អតិក្ក្លមិត្វា ញាណំ ឧប្ផវតិ ញាណំ អតិក្ក្លមិត្វា នេយ្យបថោ ឧត្តិ អញ្ញមញ្ញ បរិយន្តដ្ឋាយិនោ តេ ធម្មា ។ យថា ទ្វិន្នំ សមុក្ក្លបជ្ជលានំ ផុសិតានំ ហេដ្ឋិមំ

ប្រយោជន៍មិនមានទោសក្តី ប្រយោជន៍មិនមានកិលេសក្តី ប្រយោជន៍ផ្ទរផង់ក្តី ប្រយោជន៍ដ៏ល្អិតក្តី ធម្មជាតទាំងអស់នោះ រមែងវិលនៅក្នុងខាងក្នុងពុទ្ធញ្ញាណ ។ កាយកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញ្ញាណរបស់ព្រះពុទ្ធមានព្រះភាគ វចីកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញ្ញាណ មនោកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញ្ញាណ (របស់ព្រះពុទ្ធមានព្រះភាគ) ។ ញ្ញាណរបស់ព្រះពុទ្ធមានព្រះភាគ មិនមានទើសទាល់ក្នុងអតីត ញ្ញាណរបស់ព្រះពុទ្ធមានព្រះភាគ មិនមានទើសទាល់ក្នុងអនាគត ញ្ញាណរបស់ព្រះពុទ្ធមានព្រះភាគ មិនមានទើសទាល់ក្នុងបច្ចុប្បន្ន ។ ធម្មជាតដែលគប្បីដឹង មានកំណត់ត្រឹមណា ព្រះញ្ញាណ ក៏មានកំណត់ត្រឹមនោះ ព្រះញ្ញាណមានកំណត់ត្រឹមណា ធម្មជាតដែលគប្បីដឹង ក៏មានកំណត់ត្រឹមនោះ ព្រះញ្ញាណមានធម្មជាតដែលគប្បីដឹង ជាកំណត់ ធម្មជាតដែលគប្បីដឹង ក៏មានព្រះញ្ញាណជាកំណត់ ព្រះញ្ញាណប្រព្រឹត្តកន្ទ ងនូវធម្មជាតដែលគប្បីដឹង មិនបាន គន្ទ ងនៃធម្មជាតដែលគប្បីដឹង ក៏ប្រព្រឹត្តកន្ទ ងនូវព្រះញ្ញាណមិនបាន ធម៌ទាំងនោះ តាំងនៅក្នុងទីបំផុតនៃគ្នានិងគ្នា ។ ដូចបាតស្មុគ្រពីរ ដែលគេគ្របហើយយ៉ាងជិតស្និទ្ធ គឺបាតស្មុគ្រខាងក្រោម

សមុក្ខបដលំ ឧបរិមំ ជានាតិវត្តតិ ឧបរិមំ សមុក្ខ-
បដលំ ហេដ្ឋិមំ ជានាតិវត្តតិ អញ្ញមញ្ញំ បរិយន្តដ្ឋាយិ-
នោ ឯវមេវ ពុទ្ធស្ស ភគវតោ ឧយ្យាតុ ញាណាតុ
អញ្ញមញ្ញំ បរិយន្តដ្ឋាយិនោ យាវតកំ ឧយ្យាំ តាវតកំ
ញាណំ យាវតកំ ញាណំ តាវតកំ ឧយ្យាំ ឧយ្យ-
បរិយន្តិកំ ញាណំ ញាណបរិយន្តិកំ ឧយ្យាំ ឧយ្យាំ
អតិក្កមិត្វា ញាណំ ឧប្បវត្តតិ ញាណំ អតិក្កមិត្វា
ឧយ្យបថោ ឧត្តិ អញ្ញមញ្ញំ បរិយន្តដ្ឋាយិនោ ឧ
ធម្មា ។ សតុ ធម្មេសុ ពុទ្ធស្ស ភគវតោ ញាណំ បវត្ត-
តិ ។ សតុ ធម្មា ពុទ្ធស្ស ភគវតោ អាវជ្ជនប្បដិពទ្ធា អា-
ភោគ្ខ ប្បដិពទ្ធា មនសិការប្បដិពទ្ធា ចិត្តុប្បាទប្បដិពទ្ធា ។
សតុ សត្តេសុ ពុទ្ធស្ស ភគវតោ ញាណំ បវត្តតិ ។

*មិនប្រព្រឹត្តកន្ទ*ង*បាតស្មុគ្រខាងលើ បាតស្មុគ្រខាងលើ ក*៏*មិនប្រព្រឹត្ត*
*កន្ទ*ង*បាតស្មុគ្រខាងក្រោម (បាតស្មុគ្រទាំ*ង*នោ*ះ*) តាំ*ង*នៅក្នុ*ង
*ទីបំផុត នៃគ្នានិ*ង*គ្នា យ*ៅ*ណាមិញ ធ*ម*្ម*ជាតដែលគ*ប*្ប*ីដឹ*ង*ក*ី*ព្រ*ះ
ញា*ណ*ក*ី* ร*ប*ស*់*ព*្រ*ះ*ពុ*ទ*្ធ*ម*ានព*្រ*ះ*ភ*ាគ ក*៏*តាំ*ង*នៅ*ក*្នុ*ង*ទ*ីប*ំ*ផ*ុ*ត*នៃ*គ*្ន*ានិ*ង*គ*្ន*ា
យៅ*ង*នោ*ះ*ដ*ែ*រ *គ*ឺ*ធ*ម*្ម*ជ*ាតដ*ែ*ល*ค*ប*ី*ដ*ឹ*ង*ម*ានក*ំ*ណ*ត*ត*្រ*ីម*ណ*ា ព*្រ*ះ*ញ*ា*ណ
ก៏*ม*ានก*ំ*ណ*ត*ត*្រ*ីម*នោ*ះ* ព*្រ*ះ*ញ*ា*ណ*ม*ានก*ំ*ណ*ត*ត*្រ*ីម*ណ*ា ธ*ม*្ม*ជ*ាតដ*ែ*ล
*ค*ป*ี*ដ*ឹ*ง*ก*ๆ*ม*ានก*ំ*ณ*ต*ต*ร*ีม*นา*ะ ป*ร*ะ*ญ*า*ณ*ม*านธ*ม*ม*ชา*ตด*ี*ล*ค*ป*ี*ด*ี*ง*ช*า
*ก*ำ*ณ*ต*ธ*ม*ม*ชา*ตด*ี*ล*ค*ป*ี*ด*ี*ง*ก*ๆ*ม*านป*ร*ะ*ญ*า*ณ*ช*าก*ำ*ณ*ต*ป*ร*ะ*ญ*า*ณ
*ป*ร*ะ*พ*ร*ึ*ต*ก*น*ท*ง*ธ*ม*ม*ชา*ตด*ี*ล*ค*ป*ี*ด*ี*ง*ม*ิน*ป*าน ค*น*ท*ง*น*ี*ธ*ม*ม*ชา*ตด*ี*ล*ค*ป*ี
ดี*ง ก*ๆ*ป*ร*ะ*พ*ร*ึ*ต*ก*น*ท*ง*ป*ร*ะ*ญ*า*ณ*ม*ิน*ป*าน ธ*ม*ม*ท*ั*ง*น*ោ*ះ* *ต*ាំ*ง*នៅ
กុ*ง*ទ*ីប*ំ*ផ*ុ*ត* *ន*ៃ*ค*ា*ន*ិ*ง*ค*ា* ។ *ป*ร*ะ*ญ*า*ณ*ร*ប*ส*់*ป*ร*ะ*พ*ุ*ท*ธ*ม*ান*ป*ร*ะ*ภ*าค
*ร*ม*ง*ป*ร*ะ*พ*ร*ึ*ต*ต*ท*ง*ก*ุ*ง*ธ*ม*ม*ท*ั*ง*ค*ู*ง ។ ธ*ม*ม*ท*ั*ง*ค*ู*ง ร*ม*ง*ช* า*ป*ช*ิ*ต*ช*ิ*ม*ก*ก*
ดោ*យ*ก*ា*ร*ร*ា*ว*ร*ก ช* า*ป*ช*ิ*ต*ช*ิ*ม*ก*ก*ด*ោ*យ*ก*ា*ร*ป*្រ*ា*ថ*ា ช*า*ป*ช*ิ*ต*ช*ิ*ม*ก*ก*ด*ោ*យ*ก*ា*ร
នឹ*ก ช*า*ป*ช*ิ*ต*ช*ิ*ม*ก*ก*ด*ោ*យ*ก*ា*ร*ต*ាំ*ง*ช*ិ*ต*ត ร*ប*ส*់*ព*្រ*ះ*ពុ*ท*ធ*ม*ានព*្រ*ះ*ภ*าค ។ ព*្រ*ះ
*ญ*า*ณ*ร*ប*ส*់*ព*្រ*ះ*ពុ*ท*ធ*ม*ានព*្រ*ះ*ภ*าค ร*ม*ง*ป*ร*ะ*พ*ร*ึ*ต*ต*ท*ง*ก*ุ*ง*ส*ต*ู*ท*ั*ง*ค*ู*ง ។

សព្វេសំ សត្តានំ ភគវា អាសយំ ជានាតិ អនុសយំ ជានាតិ ចរិតំ ជានាតិ អធិមុត្តឹ ជានាតិ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ ភព្វាភព្វេ សត្តេ បជានាតិ ។ សទេវកោ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា អន្តោពុទ្ធញ្ញាណេ បរិវត្តតិ ។ យថា យេ កេចិ មច្ឆកច្ឆបា អន្តមសោ តិមិតិមិង្គលំ ឧបាទាយ អន្តោមហាសមុទ្ទេ បរិវត្តន្តិ ឯវមេវ សទេវកោ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា អន្តោពុទ្ធញ្ញាណេ បរិវត្តតិ ។ យថា យេ កេចិ បក្ខី អន្តមសោ គរុឡំ វេនតេយ្យំ ឧបាទាយ អាកាសស្ស បទេសេ បរិវត្តន្តិ ឯវមេវ សារីបុត្តសមា បញ្ញាយ[១] តេបិ យេបិ តេ ពុទ្ធញ្ញាណស្ស បទេសេ បរិវត្តន្តិ ។

១ ម. ឯត្ថន្តរេ សមន្នាគតាតិ ទិស្សតិ ។

ព្រះមានព្រះភាគ តែងជ្រាបអាសយធម៌ ជ្រាបអនុសយធម៌ ជ្រាបចរិត ជ្រាបអធិមុត្តិនៃពួកសត្វទាំងពួង តែងជ្រាបពួកសត្វ ដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយរឹង មានឥន្ទ្រិយទន់ មានអាការៈល្អ មានអាការៈអាក្រក់ ជាសត្វឲ្យត្រាស់ដឹងងាយ ឲ្យត្រាស់ដឹងក្រ ជាសត្វមានភ័ព្វនិងឥតភ័ព្វ ។ លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពួកសត្វព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេពនិងមនុស្សសាម័ញ្ញ ក៏រមែងវិលនៅតែខាងក្នុងពុទ្ធ-ញ្ញាណ ។ ដូចហ្វូងត្រីនិងអណ្តើកណាមួយ ដោយហោចទៅ ទោះបីត្រីឈ្មោះតិមិ និងត្រីឈ្មោះតិមិង្គលៈ រមែងវិលនៅតែខាងក្នុងមហាសមុទ្រយ៉ាងណា លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពួកសត្វព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សសាម័ញ្ញ ក៏រមែងវិលនៅតែខាងក្នុងពុទ្ធញ្ញាណ យ៉ាងនោះឯង ។ ដូចពួកបក្សីណាមួយ ដោយហោចទៅ សូម្បីគ្រុឌឈ្មោះវេនតេយ្យៈ តែងវិលនៅតែក្នុងប្រទេសនៃអាកាស យ៉ាងណាមិញ ពួកជនណាដែលមានប្រាជ្ញា ស្មើដោយប្រាជ្ញារបស់ព្រះសារីបុត្ត សូម្បីពួកជនទាំងនោះ ក៏រមែងវិលនៅតែខាងក្នុងប្រទេសនៃពុទ្ធញ្ញាណ យ៉ាងនោះឯង

ពុទ្ធញាណំ ទេវមនុស្សានំ បញ្ញំ ជវិត្វា អភិភវិត្វា តិដ្ឋតិ ។ យេបិ តេ ខត្តិយបណ្ឌិតា ព្រាហ្មណបណ្ឌិតា គហបតិបណ្ឌិតា សមណបណ្ឌិតា និបុណា កតបរប្បវាទា វាលវេធិរូបា តេ ភិន្ទន្តា មញ្ញេ ចរន្តិ បញ្ញាគតេន ទិដ្ឋិគតានិ ។ តេ បញ្ហំ អភិសង្ខរិត្វា អភិសង្ខរិត្វា តថាគតំ ឧបសង្កមិត្វា បុច្ឆន្តិ[២] ។ កថិតា វិសជ្ជិតា ច តេ បញ្ហា ភគវតា ហោន្តិ និទ្ទិដ្ឋការណា ឧបក្ខិត្តកា ច ។ តេ ភគវតោ សម្បជ្ជន្តិ ។ អថខោ ភគវា តត្ថ អតិវិរោចតិ យទិទំ បញ្ញាយាតិ ឯវំ ភគវា បញ្ញាចក្ខុនាបិ ចក្ខុមា ។

កថំ ភគវា ពុទ្ធចក្ខុនាបិ ចក្ខុមា ។ ភគវា ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ អទ្ទស សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ

១ ម. ឯត្ថន្តរេ គុឡ្ហានិ ច បដិច្ឆន្នានីតិ ទិស្សតិ ។

ពុទ្ធញ្ញាណ រមែងផ្សាយគ្របប្រាជ្ញានៃពួកទេវតានិងមនុស្ស ហើយប្រតិ-ស្ឋាននៅ ។ ពួកជនណាមួយ ទោះបីជាខត្តិយបណ្ឌិតក្តី ព្រាហ្មណ-បណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី ដែលមានប្រាជ្ញាស្ងួត ស្គាល់ថ្ងៃមាត់របស់ជនដទៃ ស្រដៀងនឹងខ្ចាន់ធ្ម អ្នកបាញ់ពោមទ្រាយ ពួកជនទាំងនោះ មានអាការៈដូចជាទម្លាយបង់នូវទិដ្ឋិ ដោយប្រាជ្ញា (ខ្ជួន) ហើយប្រព្រឹត្តទៅ ។ ពួកជនទាំងនោះប្រឹងតាក់តែងនូវប្រស្នា លុះតាក់តែងហើយក៏ចូលទៅសួរព្រះតថាគត ។ ប្រស្នាទាំងនោះ លុះព្រះមានព្រះភាគ បានសម្តែង បានដោះស្រាយហើយ ក៏បែរទៅជាប្រស្នាមានហេតុ គួរសម្តែងចេញនិងពង្រីកចេញបាន ។ ពួកជនទាំងនោះ ក៏នាំគ្នាចុះចូលព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់រុង-រឿងកន្ទ្ងដោយប្រាជ្ញាក្នុងទីប្រជុំនោះ ហេតុនោះ ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយបញ្ញាចក្ខុ យ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយពុទ្ធចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលលោកដោយពុទ្ធចក្ខុ បានទតឃើញ ពួកសត្វដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយរឹង មានឥន្ទ្រិយទន់ មានអាការៈល្អ មានអាការៈអាក្រក់ ឲ្យត្រាស់ដឹងងាយ

ឧុវិញ្ញាបយេ អប្ឍេកចេ្ច បរលោកវជ្ជភយទ្ឍស្ឍាវិនោ
វិហរន្តេ ។ សេយ្យថាបិ ជាម ឧប្ឍលិនិយំ វ បទុមិ-
និយំ វ បុណ្ឌរីកិនិយំ វ អប្ឍេកចា្ចនិ ឧប្ឍលានិ វ
បទុមានិ វ បុណ្ឌរីកានិ វ ឧទកេ ជាតានិ
ឧទកេ សំវឌ្ឍានិ ឧទកានុគ្គតានិ អន្តោនិមុគ្គចោ-
សិតានិ អប្ឍេកចា្ចនិ ឧប្ឍលានិ វ បទុមានិ វ
បុណ្ឌរីកានិ វ ឧទកេ ជាតានិ ឧទកេ សំវឌ្ឍា-
និ សមោទកណ្ឋិតានិ អប្ឍេកចា្ចនិ ឧប្ឍលានិ វ
បទុមានិ វ បុណ្ឌរីកានិ វ ឧទកេ ជាតានិ
ឧទកេ សំវឌ្ឍានិ ឧទកា អចុ្ចគ្គម្ម តិដ្ឋន្តិ អនុ-
បលិត្តានិ ឧទកេន ឯវមេវ ភគវា ពុទ្ធចក្ខុនា
លោកំ ឱលោកេន្តោ អទ្ទស សត្តេ អប្ឍរជក្ខេ
មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្ឍាការេ
ទ្ឍាការេ សុវិញ្ញាបយេ ឧុវិញ្ញាបយេ អប្ឍេ-
កចេ្ច បរលោកវជ្ជភយទ្ឍស្ឍាវិនោ វិហរន្តេ ។

ឲ្យត្រាស់ដឹងក្រ សត្វជំពូកខ្ទះ ឃើញកំ្ចយ ក្នុងទោសខាងបរ-
លោក ។ ដូចក្នុងគុម្ពព្រលិតក្តី គុម្ពឈូកក្រហមក្តី គុម្ពឈូកសក្តី
ផ្ការ្ពលិត ឬផ្ការ្ពឈូកក្រហម ឬក៏ផ្ការ្ពឈូកស ជំពូកខ្ទះ កើតក្នុងទឹក
ចម្រើនក្នុងទឹក លូតលាស់ក្នុងទឹក ដុះកប់ខាងក្នុងនៅឡើយ ផ្ការ្ពលិតឬ
ផ្ការ្ពឈូកក្រហម ឬក៏ផ្ការ្ពឈូកស ជំពូកខ្ទះ កើតក្នុងទឹក ចម្រើនក្នុងទឹក
ឋិតនៅស្មើនឹងទឹកហើយ ផ្ការ្ពលិត ឬផ្ការ្ពឈូកក្រហម ឬក៏ផ្ការ្ពឈូកស
ជំពូកខ្ទះ កើតក្នុងទឹក ចម្រើនក្នុងទឹក ឋិតនៅផុតអំពីទឹក មិនទទឹកដោយ
ទឹកឡើយ យ៉ាងណាមិញ ព្រះមានព្រះភាគទ្រង់ប្រមើលមើលលោក
ដោយពុទ្ធចក្ខុ បានឃើញពួកសត្វ ដែលមានធូលីតិចក្នុងភ្នែក មានធូលី
ច្រើនក្នុងភ្នែក មានឥន្ទ្រិយរឹង មានឥន្ទ្រិយទន់ មានអាការៈល្អ មាន
អាការៈមិនល្អ ឲ្យត្រាស់ដឹងងាយ ឲ្យត្រាស់ដឹងក្រ សត្វជំពូកខ្ទះ
ឃើញកំ្ចយ ក្នុងទោសខាងបរលោក ក៏យ៉ាងនោះឯង ។

ជានាតិ ភគវា អយំ បុគ្គលោ រាគចរិតោ អយំ
ទោសចរិតោ អយំ មោហចរិតោ អយំ វិតក្ក្ចរិតោ
អយំ សទ្ធាចរិតោ អយំ ញាណចរិតោតិ ។ រាគ-
ចរិតស្ស ភគវា បុគ្គលស្ស អសុភកថំ កថេតិ ។
ទោសចរិតស្ស ភគវា បុគ្គលស្ស មេត្តាភាវនំ អា-
ចិក្ខតិ ។ មោហចរិតំ ភគវា បុគ្គលំ ឧទ្ទេស-
បរិបុច្ឆាយ ការេន ធម្មស្សវនេ ការេន ធម្ម-
សាកច្ឆាយ ករុសំវាសេ និវេសេតិ ។ វិតក្ក្ចរិត-
ស្ស ភគវា បុគ្គលស្ស អានាបានស្សតឺ អាចិក្ខ-
តិ ។ សទ្ធាចរិតស្ស ភគវា បុគ្គលស្ស បសាទនី-
យំ និមិត្តំ អាចិក្ខតិ ពុទ្ធសុពោធឺ[1] ធម្មសុធម្មតំ
សង្ឆសុបដិបត្តឺ សីលានិ ច អត្តនោ ។ ញាណ-
ចរិតស្ស ភគវា បុគ្គលស្ស វិបស្សនានិមិត្តំ អាចិក្ខតិ
អនិច្ចាការំ ទុក្ខាការំ អនត្តាការំ ។

---

1 ម. ពុទ្ធសុពុទ្ធតំ ។

មោឃរាជមាណវកปัญญานิទ្ទេស

ព្រះមានព្រះភាគ ទ្រង់ជ្រាបថា បុគ្គលនេះជារាគចរិត នេះជាទោសចរិត នេះជាមោហចរិត នេះជាវិតក្ក្ចរិត នេះជាសទ្ធាចរិត នេះជាញាណចរិត ។ ព្រះមានព្រះភាគ ទ្រង់សម្តែងអសុភកថា ចំពោះបុគ្គលជារាគចរិត ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់មេត្តាភាវនា ចំពោះបុគ្គលជាទោសចរិត ។ ព្រះមានព្រះភាគ ទ្រង់ញុំាងបុគ្គលជាមោហចរិត ឲ្យតាំងនៅក្នុងធម្មស្សវ-នៈតាមកាល ក្នុងធម្មសាកច្ឆាតាមកាល និងការនៅរួមជាមួយគ្រូដើម្បីរៀននិងការសាកសួរ ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់អានាបានស្សតិ ចំពោះបុគ្គលជាវិតក្ក្ចរិត ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់និមិត្តដែលគួរជ្រះថ្លា គឺការត្រាស់ដឹងប្រពៃនៃព្រះពុទ្ធ សភាពនៃធម៌ជាធម៌ល្អ ការប្រតិ-បត្តិប្រពៃនៃព្រះសង្ឆ និងសីលរបស់ខ្លួន ចំពោះបុគ្គលជាសទ្ធាចរិត ។ ព្រះមានព្រះភាគទ្រង់ប្រាប់វិបស្សនានិមិត្ត គឺអាការៈមិនទៀង អាការៈជាទុក្ខនិងអាការៈជាអនត្តា ចំពោះបុគ្គលជាញាណចរិត ។

សេលេ យថា បព្ពតមុទ្ធនិដ្ឋិតោ
យថាបិ បស្ស ជនតំ សមន្តតោ
តថូបមំ ធម្ម មយំ សុមេធ
ចាសាធមារុយ្ហ សមន្តចក្ខុ
សោកាវតិណ្ណ ជនតមបេតសោកោ
អវេក្ខស្សុ ជាតិជរាភិភូតន្តិ ។

ឯវំ ភគវា ពុទ្ធចក្ខុជាបិ ចក្ខុមា ។

ភគវា សមន្តចក្ខុជាបិ ចក្ខុមា ។ ស-មន្តចក្ខុ រុច្ចតិ សព្ពញ្ញុតញ្ញាណំ ។ ភគវា សព្ព-ញ្ញុតញ្ញាណេន ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ ។

ន តស្ស អធិដ្ឋមិធត្ថិ កិញ្ចិ
អថោ អវិញ្ញាតមជានិតព្ពំ
សព្ពំ អភិញ្ញាសិ យទត្ថិ នេយ្យំ
តថាគតោ តេន សមន្តចក្ខូតិ ។

បពិត្រព្រះសុមេធ: ព្រះអង្គប្រកបដោយសមន្តចក្ខុ ទ្រង់មិនមានសោក សូមព្រះអង្គឡើងកាន់ប្រាសាទ ជាវិការ:នៃធម៌ ហើយ ក្រឡេកមើលពួកជន ដែលដេរដាសដោយសោក ត្រូវជាតិជរាគ្របសង្កត់ ដូចជាបុរសឈរនៅលើកំពូលភ្នំ ជាវិការ:នៃថ្ម ហើយក្រឡេកមើលពួកជន ដែលឋិតនៅក្នុងទីជុំវិញ ដូច្នោះចុះ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយពុទ្ធចក្ខុ យ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ដោយសមន្តចក្ខុ តើដូចម្តេច ។ សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ ព្រះមានព្រះភាគ ទ្រង់ដល់ ដល់ព្រម មកដល់ មកដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ប្រកបហើយដោយសព្វញ្ញុតញ្ញាណ ។

អ្វីមួយក្នុងលោកនេះ ដែលព្រះតថាគតនោះ មិនឃើញ ឬមិនជ្រាបហើយ មិនគប្បីជ្រាប មិនមានទេ របស់ណា ដែលគួរដឹង ព្រះតថាគត ជ្រាបច្បាស់នូវរបស់នោះទាំងអស់ ហេតុនោះ ទើបឈ្មោះថាសមន្តចក្ខុ ។

ឯវํ ភគវា សមន្តចក្ខុនាបិ ចក្ខុមាតិ ន មេ ព្យា-
ការិ ចក្ខុមា ។

[៦១] យាវតតិយញ្ច ខេវិសិ ព្យាកភោតីតិ មេ
សុតន្តិ យាវតតិយំ ពុទ្ធោ សហធម្មិកំ បញ្ហ បុ-
ដ្ឋោ ព្យាកភោតិ នោ សម្ភាយតីតិ ឯវํ មយា
ឧក្ត្ហិតํ ឯវํ មយា ឧបធារិតํ ឯវํ មយា ឧប-
លក្ខិតํ ។ ខេវិសីតិ ភគវា ខេភោ ចេវ ឥសិ ចា-
តិ ខេវិសិ ។ យថា ភជបព្ជជិតា រុចូន្តិ ភជិសយោ
ព្រាហ្មណបព្ជជិតា រុចូន្តិ ព្រាហ្មណិសយោ ឯវមេវ
ភគវា ខេភោ ចេវ ឥសិ ចាតិ ខេវិសិ ។ អថវា ភគវា
បព្ជជិតោតិបិ ឥសិ ។ មហន្តํ សីលក្ខន្ធํ ឯសិ
ភវេសិ បរិយេសីតិបិ ឥសិ ។ មហន្តํ សមាធិក្ខន្ធํ
មហន្តํ បញ្ញាខន្ធํ មហន្តํ វិមុត្តិក្ខន្ធํ មហន្តํ វិមុត្តិញ្ញា-
ណទស្ឬនក្ខន្ធํ ឯសិ ភវេសិ បរិយេសីតិបិ ឥសិ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយសមន្តចក្ខុ យ៉ាងនេះ ហេតុនោះ (លោកពោលថា) ព្រះអង្គមានចក្ខុ ទ្រង់មិនទាន់ដោះស្រាយ ដល់ខ្ញុំព្រះអង្គនៅឡើយ ។

[៦១] ពាក្យថា ខ្ញុំព្រះអង្គបានឮថា ព្រះអង្គជាទេវឫសី (កាលបើមានគេសាកសួរ) អស់វារៈបីដង ទ្រង់តែងព្យាករពុំខាន អធិប្បាយថា ខ្ញុំព្រះអង្គបានរៀនមកយ៉ាងនេះ ខ្ញុំព្រះអង្គបានចាំទុកមកយ៉ាងនេះ ខ្ញុំព្រះអង្គបានកំណត់ទុកមកយ៉ាងនេះថា ព្រះពុទ្ធដែលគេសួរប្រស្នាប្រកបដោយធម៌ ត្រឹមវារៈជាគម្រប់ ៣ តែងទ្រង់ព្យាករ មិនទើសទាល់ ។ ពាក្យថា ព្រះអង្គជាទេវឫសី គឺព្រះមានព្រះភាគ ឈ្មោះថាទេវឫសី ព្រោះហេតុទ្រង់ជាវិសុទ្ធិទេពផង ជាឫសីផង ។ ដូចពួករាជបព្វជិត គេហៅថា រាជឫសី ពួកព្រាហ្មណបព្វជិត គេហៅថា ព្រាហ្មណឫសី យ៉ាងណាមិញ ព្រះមានព្រះភាគ ឈ្មោះថាទេវឫសី ព្រះហេតុទ្រង់ជាវិសុទ្ធិទេពផង ជាឫសីផង ក៏យ៉ាងនោះដែរ ។ មួយទៀត ព្រះមានព្រះភាគ ឈ្មោះថាឫសី ព្រោះហេតុទ្រង់ជាបព្វជិត ដូច្នេះក៏បាន ។ ព្រះមានព្រះភាគ ឈ្មោះថាឫសី ព្រោះទ្រង់រក ស្វែងរក ស្វះស្វែង នូវសីលក្ខន្ធដ៏ធំ ដូច្នេះដ៏បាន ។ ព្រះមានព្រះភាគ ឈ្មោះថាឫសី ព្រោះទ្រង់រក ស្វែងរក ស្វះស្វែង នូវសមាធិក្ខន្ធដ៏ធំ បញ្ញាខន្ធដ៏ធំ វិមុត្តិក្ខន្ធដ៏ធំ វិមុត្តិញ្ញាណទស្សនក្ខន្ធដ៏ធំ ដូច្នេះក៏បាន ។

មហាតោ តមោកាយស្ស បជាលនំ មហាតោ
រិបណ្ហាសស្ស បភេទនំ មហាតោ តណ្ហាសណ្ឋស្ស
អពុជ្ឌនំ មហាតោ ទិដ្ឋិសង្ខ្យាតស្ស រិនិព្ជេឍនំ ម-
ហាតោ មានទ្ធជស្ស ចាតនំ មហាតោ អកិសង្ខារ-
ស្ស រូបសមំ មហាតោ ឱឃស្ស និត្ថរណំ មហាតោ
ការស្ស និក្ខេបនំ មហាតោ សំសារវដ្ដស្ស ឧបច្ឆេ-
ទំ មហាតោ សន្ដាបស្ស និព្ជាបនំ មហាតោ បរិ-
ឌ្ឌាហស្ស បដិប្ឌស្ឌ្ធ្ជ មហាតោ ធម្មទ្ធជស្ស ឧ-
ស្ឌ្ឌាបនំ ឯសិ ឥវេសិ បរិយេសីតិបិ ឥសិ ។ ម-
ហន្ដ សតិប្ឌដ្ឌានេ មហន្ដ សម្ម្ឌប្ឌធានេ មហន្ដ
ឥទ្ធិចានេ មហន្ដានិ ឥន្ទ្រ្ជិយានិ មហន្ដានិ ពលានិ
មហន្ដ ពោជ្ឌ្ជង្គ មហន្ដ អរិយ អដ្ឌ្ឌ្ជ្ជ្ជ្ជ្ជ្ជ
មហន្ដ និព្ជានំ ឯសិ ឥវេសិ បរិយេសីតិបិ ឥសិ ។
មហេសក្ខេហិ ឬ សត្ដេហិ ឯសិតោ ឥវេសិតោ
បរិយេសិតោ ឥមាំ ពុទ្ធ ឥមាំ ភ្ជ ឥមាំ
ទេវទេវ ឥមាំ ជ្ជ្ជ្ជ្ជ្ជ ឥវេសិ ព្ជ្ជ្ជ្ជ្ជ ។

ព្រះមានព្រះភាគ ឈ្មោះថាឫសី ព្រោះទ្រង់រក ស្វែងរក ស្វះស្វែងនូវការទម្លាយបង់ នូវគំនរងងឹតដ៏ធំ ការទម្លាយបង់នូវវិបល្លាស:ដ៏ធំ ការដកឡើងនូវសរ គឺតណ្ហាដ៏ធំ ការរុះរើចេញ នូវឃ្នាប គឺទិដ្ឋិដ៏ធំ ការទម្លាក់ចុះនូវទង់ជ័យ គឺមានៈដ៏ធំ ការរម្ងាប់នូវអភិសង្ខារដ៏ធំ ការរើចេញចាកឱ្ឃ:ដ៏ធំ ការដាក់ចុះនូវភារ:ដ៏ធំ ការផ្តាច់បង់នូវសំសារវដ្តដ៏ធំ ការរំលត់នូវកម្តៅដ៏ធំ ការរម្ងាប់បង់នូវការក្តៅក្រហាយដ៏ធំ និងការលើកឡើងនូវទង់ជ័យ គឺធម៌ដ៏ធំ ដូច្នេះក៏បាន ។ ព្រះមានព្រះភាគ ឈ្មោះថាឫសី ព្រោះទ្រង់រក ទ្រង់ស្វែងរក ស្វះស្វែងនូវសតិប្បដ្ឋានដ៏ធំ សម្មប្ប-ធានដ៏ធំ ឥទ្ធិបាទដ៏ធំ ឥន្ទ្រិយដ៏ធំ ពល:ដ៏ធំ ពោជ្ឈង្គដ៏ធំ អរិយមគ្គប្រកបដោយអង្គ ៨ ដ៏ធំ និងព្រះនិព្វានដ៏ធំ ដូច្នេះក៏បាន ។ ឈ្មោះថាឫសី ព្រោះ (ព្រះមានព្រះភាគ) ត្រូវពួកសត្វមានស័ក្តិធំ គួររក ស្វែងរក ស្វះស្វែងថា ព្រះពុទ្ធ (គង់នៅ) ក្នុងទីណា ព្រះមានព្រះភាគ (គង់នៅ) ក្នុងទីណា ព្រះវិសុទ្ធិទេព (គង់នៅ) ក្នុងទីណា ព្រះនរាសភ: (គង់នៅ) ក្នុងទីណា ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គបានឮថា ព្រះអង្គជាទេវឫសី (កាលបើមានគេសាកសួរ) អស់វារ:បីដង ទ្រង់តែងព្យាករពុំខាន ។

តេនាហ សោ ព្រាហ្មណោ

ទ្វាហំ សក្ក អបុច្ឆិស្សំ (ឥច្ចាយស្មា
មោឃរាជា)

ន មេ ព្យាកាសិ ចក្ខុមា

យាវតតិយញ្ច ទេវិសិ

ព្យាកភោតីតិ មេ សុតន្តិ ។

[៦២] អយំ លោកោ បរោ លោកោ

ព្រហ្មលោកោ សទេវកោ

ឋិដ្ឋិន្តេ ជានកិជានាតិ

កោតមស្ស យសស្សិនោ ។

[៦៣] អយំ លោកោ បរោ លោកោតិ អយំ លោកោតិ មនុស្សលោកោ ។ បរោ លោកោតិ មនុស្សលោកំ បហាយ សេសា បរោ លោកោតិ អយំ លោកោ បរោ លោកោ ។

[៦៤] ព្រហ្មលោកោ សទេវកោតិ ព្រហ្មលោ-
កោ សទេវកោ សមារកោ សស្សមណាព្រាហ្មណី
បជា សទេវមនុស្សាតិ ព្រហ្មលោកោ សទេវកោ ។

ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

(មោឃរាជមានអាយុ ក្រាបទូលដូច្នេះថា) បពិត្រព្រះអង្គជាសក្ក: ខ្ញុំព្រះអង្គ បានទូលសួរ (ព្រះអង្គ) អស់វារ:ពីរដងរួចហើយព្រះអង្គមានចក្ខុ ទ្រង់មិនទាន់ដោះស្រាយដល់ខ្ញុំព្រះអង្គនៅឡើយ ខ្ញុំព្រះអង្គបានឮថា ព្រះអង្គជាទេវឫសី (កាលបើមានគេសាកសួរ) អស់វារ:បីដង ទ្រង់តែងញ្ញាតរពុំខាន ។

[៦២] លោកនេះ លោកដទៃ ព្រហ្មលោក ព្រមទាំងទេវ-លោក រមែងមិនទាន់ដឹងច្បាស់ នូវសេចក្តីយល់ឃើញរបស់ព្រះអង្គ ជាព្រះគោតម ដ៏ទ្រង់យសទេ ។

[៦៣] ពាក្យថា លោកនេះ របស់បទថា លោកនេះ លោកដទៃ បានដល់មនុស្សលោក ។ ពាក្យថា លោកដទៃ គឺលោកដទៃទាំងអស់លើកលែងតែមនុស្សលោកចេញ ហេតុនោះ (លោកពោលថា) លោកនេះ លោកដទៃ ។

[៦៤] ពាក្យថា ព្រហ្មលោក ព្រមទាំងទេវលោក បានដល់ព្រហ្មលោក ព្រមទាំងទេវលោក មារលោក ពួកសត្វព្រមទាំងសមណ: និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សសាម័ញ្ញ ហេតុនោះ (លោកពោលថា) ព្រហ្មលោក ព្រមទាំងទេវលោក ។

[៦៥] ទិដ្ឋិន្តេ នាភិជានាមីតិ តុយ្ហំ ទិដ្ឋឹ ខន្តឹ រុចឹ លទ្ធឹ អជ្ឈាសយំ អធិប្បាយំ លោកោ ន ជានាតិ អយំ ឯវំទិដ្ឋិកោ ឯវំខន្តិកោ ឯវំរុចិកោ ឯវំលទ្ធិកោ ឯវំអជ្ឈាសយោ ឯវំអធិប្បាយោតិ ន ជានាតិ ន បស្សតិ ន ទក្ខតិ នាធិគច្ឆតិ ន វិន្ទតិ ន បដិលភតីតិ ទិដ្ឋិន្តេ នាភិជានាមិ ។

[៦៦] គោតមស្ស យសស្សិនោតិ ភគវា យសប្បត្តោតិ យសស្សី ។ អថវា ភគវា សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ គោតមស្ស យសស្សិនោ ។ តេនាហ សោ ព្រាហ្មណោ

អយំ លោកោ បរោ លោកោ
ព្រហ្មលោកោ សទេវកោ
ទិដ្ឋិន្តេ នាភិជានាមិ
គោតមស្ស យសស្សិនោតិ ។

[៦៥] *ពាក្យថា មិនទាន់ដឹងច្បាស់ នូវសេចក្តីឃើញរបស់ព្រះអង្គ គឺសត្វលោកមិនទាន់ដឹងនូវសេចក្តីយល់ឃើញ សេចក្តីចូលចិត្ត សេចក្តីគាប់ចិត្ត លទ្ធិ អធ្យាស្រ័យ បំណងរបស់ព្រះអង្គ គឺថាមិនទាន់ដឹង មិនទាន់ឃើញ មិនទាន់យល់ មិនទាន់ជួបប្រទះ មិនទាន់បាន មិនបានចំពោះថា សមណៈនេះ មានសេចក្តីយល់ឃើញយ៉ាងនេះ មានសេចក្តីចូលចិត្ត យ៉ាងនេះ មានសេចក្តីគាប់ចិត្តយ៉ាងនេះ មានលទ្ធិយ៉ាងនេះ មានអធ្យា-ស្រ័យយ៉ាងនេះ មានបំណងយ៉ាងនេះទេ ហេតុនោះ (លោកពោលថា) មិនទាន់ដឹងច្បាស់នូវសេចក្តីយល់ឃើញរបស់ព្រះអង្គទេ ។*

[៦៦] *ពាក្យថា ជាព្រះគោតម ដ៏ទ្រង់យស គឺព្រះមានព្រះភាគ ឈ្មោះថាមានយស ព្រោះហេតុទ្រង់ដល់នូវយស ។ ឬថា ព្រះមានព្រះ ភាគ មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ទ្រង់បាន ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ហេតុនោះ (លោកពោលថា) ជាព្រះគោតមដ៏ទ្រង់យស ។ ហេតុនោះ ព្រាហ្មណ៍ នោះ ពោលថា*

លោកនេះ លោកដទៃ ព្រហ្មលោក ព្រមទាំងទេវលោក
រមែងមិនទាន់ដឹងច្បាស់ នូវសេចក្តីយល់ឃើញរបស់ព្រះអង្គ
ជាព្រះគោតម ដ៏ទ្រង់យសទេ ។

[៦៧] ឯវํ អភិក្ក្ហន្ត ឧស្ហារี អត្ថิ បញ្ហេ អាគមํ

ककंं លោកํ អវេក្ខន្តํ មចฺจุราชา ณ ปสฺสติ ។

[៦៨] ឯวํ អភិក្ក្ហន្ត ឧស្ហារิ ឯวํ អភិក្ក្ហន្ត ឧស្ហารี អត្ត ឧស្ហารี សេដ្ឋ ឧស្ហารี วิเสដ្ឋ ឧស្ហารี ចาโมกฺ-ឧស្ហารี ឧត្ត ឧស្ហารี ปวร ឧស្ហาริ ឯวํ អភิក្ក្ហន្ត-ឧស្ហารี ។

[៦៩] អត្ថิ បញ្ហេ អាគมនฺติ ปญฺญตฺติกมฺมา អา-គតา ។ ปេ ។ สนฺธสฺวิตุํ ภณิตุนฺติ ฯวมฺปิ អត្ថิ ปញ្ហេ អាគมํ ។

[៧០] ककंं លោกํ អវេក្ខន្តนฺติ ककंं អវេក្ខ-ន្តํ ปจฺจเวกฺขนฺตํ ตุลยนฺตํ ตีรยนฺตํ วิภาวยนฺตํ วิภูตํ ककโรนฺตนฺติ ककंं លោกํ អវេក្ខន្តํ ។

[៦៧] ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ (ដើម្បីទូលសួរ) ចំពោះព្រះអង្គទ្រង់ឃើញវិសេសយ៉ាងនេះ ចុះបុគ្គលសម្ងឹងឃើញលោក ដោយប្រការ:ដូចម្តេច មច្ចុ-រាជទើបមិនឃើញ ។

[៦៨] ពាក្យថា ព្រះអង្គទ្រង់ឃើញវិសេសយ៉ាងនេះ គឺទ្រង់ឃើញវិសេស ឃើញច្បាស់ ឃើញប្រសើរផុត ឃើញប្រសើរវិសេស ឃើញជាប្រធាន ឃើញដ៏ឧត្តម ឃើញដ៏ថ្លៃថ្នាយ៉ាងនេះ ហេតុនោះ (លោកពោលថា) ព្រះអង្គឃើញវិសេសយ៉ាងនេះ ។

[៦៩] ពាក្យថា ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នាទើបមកគាល់ គឺពួកខ្ញុំព្រះអង្គមានសេចក្តីត្រូវការដោយប្រស្នា ទើបមកគាល់ ។ បេ ។ ដើម្បីសន្ទនា ដើម្បីក្រាបបង្គំទូលសួរ ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ យ៉ាងនេះក៏មាន ។

[៧០] ពាក្យថា បុគ្គលសម្ងឹងឃើញលោកដោយប្រការដូចម្តេច គឺសម្ងឹងឃើញ ពិចារណាឃើញ រំពឹងឃើញ ត្រិះរិះឃើញ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ (នូវលោក) ដោយប្រការដូចម្តេច ហេតុនោះ (លោកពោលថា) បុគ្គលសម្ងឹងឃើញលោក ដោយប្រការដូចម្តេច ។

[៧១] មច្ចុរាជា ន បស្សតីតិ មច្ចុរាជា ន បស្សតិ ន ឧក្ខិតិ ជាជិកច្ឆតិ ន វិជ្ជតិ ន បដិ-លភតីតិ មច្ចុរាជា ន បស្សតិ ។ តេនាហ សោ ព្រាហ្មណោ

ឯវំ អភិក្ខ្ជនឧស្សាវី អត្ថិ បញ្ញេន អាតមំ
ឧបមំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតីតិ ។

[៧២] សុញ្ញតោ លោកំ អវេក្ខស្សុ មោឃរាជ សទា សតោ
អត្តានុទិដ្ឋិ ឱហច្ច ឯវំ មច្ចុត្តរោ សិយា
ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។

[៧៣] សុញ្ញតោ លោកំ អវេក្ខស្សុតិ លោកន្តិ ឯកាយលោកោ ឯកាវ្ជានលោកោ ឯកាបិត្តិវិសយលោកោ ឯកមនុស្ស្ជលោកោ ឯកាវ្ជាលោកោ ឯកាទ្ជាលោកោ ឯកាតុ-លោកោ ឯកាយតនលោកោ ឯកាយ លោកោ ឯកាភវ លោកោ ព្រហ្មលោកោ ឯកាវ្ជាលោកោ ។

[៧១] *ពាក្យថា មច្ចុរាជទើបមិនឃើញ គឺមច្ចុរាជទើបមិនឃើញ មិនយល់ មិនជួបប្រទះ មិនបាន មិនបានចំពោះ ហេតុនោះ (លោកពោលថា) មច្ចុរាជទើបមិនឃើញ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា*

ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ (ដើម្បីទូលសួរ) ចំពោះព្រះអង្គ ទ្រង់ឃើញវិសេសយ៉ាងនេះ ចុះបុគ្គលសម្ងឹងឃើញលោកដោយប្រការដូចម្តេច មច្ចុរាជទើបមិនឃើញ ។

[៧២] *(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) ម្នាលមោឃរាជ អ្នកចូរមានស្មារតីគ្រប់កាល សម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ (ព្រោះ) បុគ្គលដកអត្តានុទិដ្ឋិចេញ ទើបធ្វើផុតចាកមច្ចុ បុគ្គលសម្ងឹងឃើញលោក យ៉ាងនេះ មច្ចុរាជទើបមិនឃើញ ។*

[៧៣] *អធិប្បាយពាក្យថា អ្នកចូរសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ ត្រង់ពាក្យថា លោក បានដល់ និរយលោក តិរច្ឆានលោក បិត្តិវិសយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក លោកនេះ លោកដទៃ ព្រហ្មលោក ព្រមទាំងទេវលោក ។*

មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច លោកោ លោកោតិ ភន្តេ ភគវតា វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ លោកោតិ វុច្ចតិ ។ លុជ្ជតីតិ ខោ ភិក្ខុ លោកោតិ វុច្ចតិ ។ កិញ្ច លុជ្ជតិ ។ ចក្ខុ លុជ្ជតិ រូបា លុជ្ជន្តិ ចក្ខុវិញ្ញាណំ លុជ្ជតិ ចក្ខុសម្ផស្សោ លុជ្ជតិ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេ-ទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ លុជ្ជតិ សោតំ លុជ្ជតិ សទ្ទា លុជ្ជន្តិ ឃានំ លុជ្ជតិ គន្ធា លុជ្ជន្តិ ជិវ្ហា លុជ្ជតិ រសា លុជ្ជន្តិ កាយោ លុជ្ជតិ ផោដ្ឋព្ពា លុជ្ជន្តិ មនោ លុជ្ជតិ ធម្មា លុជ្ជ-ន្តិ មនោវិញ្ញាណំ លុជ្ជតិ មនោសម្ផស្សោ លុជ្ជតិ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ លុជ្ជតិ លុជ្ជតីតិ ខោ ភិក្ខុ តស្មា លោកោតិ វុច្ចតិ ។

មោឃរាជមាណវកឃ្យញ្ជានិទ្ទេស

ភិក្ខុមួយរូប បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រ ព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ តែងត្រាស់ថា លោក លោក ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន សការ:ដែលហៅថា លោក តើមានកំណត់ដូច ម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ សការ:ដែលហៅថា លោក ព្រោះហេតុវិនាស ។ អ្វីតែងវិនាស ។ ចក្ខុតែងវិនាស ពួករូប តែងវិនាស ចក្ខុវិញ្ញាណតែងវិនាស ចក្ខុសម្ផស្សតែងវិនាស ធម្មជាតណា-មួយ ដែលបុគ្គលទទួល ជាសុខឬទុក្ខ ឬមិនមែនទុក្ខមិនមែនសុខ រមែង កើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតនោះ តែងវិនាសទៅ ត្រចៀកតែងវិនាស ពួកសំឡេងតែងវិនាស ច្រមុះតែងវិនាស ពួកក្លិន តែងវិនាស អណ្ដាតតែងវិនាស ពួករសតែងវិនាស កាយតែងវិនាស ពួកផ្សព្វតែងវិនាស ចិត្តតែងវិនាស ពួកធម្មារម្មណ៍តែងវិនាស មនោ-វិញ្ញាណតែងវិនាស មនោសម្ផស្សតែងវិនាស ធម្មជាតណាមួយដែល បុគ្គលទទួល ជាសុខឬទុក្ខ ឬមិនមែនទុក្ខមិនមែនសុខ កើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ធម្មជាតនោះ រមែងវិនាស ម្នាលភិក្ខុ ហេតុ នោះ សការ:ដែលហៅថា លោក ព្រោះហេតុវិនាស ដូច្នេះឯង ។

សុញ្ញតោ លោកំ អវេក្ខស្សូតិ ឥ្ចហិ ការណេហិ សុញ្ញតោ លោកំ អវេក្ខតិ អវសិយបវត្តសល្ងក្ខ-ណេវសេន វា តុច្ឆសង្ខ្យាវសមនុបស្សនាវសេន វា ។ កថំ អវសិយបវត្តសល្ងក្ខណេវសេន សុញ្ញតោ លោកំ អវេក្ខតិ ។ រូបេ វសោ ន លព្ភតិ វេទនាយ វសោ ន លព្ភតិ សញ្ញាយ វសោ ន លព្ភតិ សង្ខ្យារេសុ វសោ ន លព្ភតិ វិញ្ញាណេ វសោ ន លព្ភតិ ។ រុត្តញ្ហេតំ ភគវតា រូបំ ភិក្ខវេ អនត្តា រូបញ្ច ហិទំ ភិក្ខវេ អត្តា អភវិស្ស នយិទំ រូបំ អាពាធាយ សំវត្តេយ្យ លព្ភេថ ច រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ យស្មា ច ខោ ភិក្ខវេ រូបំ អនត្តា តស្មា រូបំ អាពាធាយ សំវត្តតិ ន ច លព្ភតិ រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ វេទនា អនត្តា វេទនា

ពាក្យថា អ្នកចូរសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ សេចក្ដីថា បុគ្គល សម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយហេតុពីរ គឺដោយអំណាចនៃការកំណត់សង្ខារដែលប្រព្រឹត្តទៅថា មិនមានអំណាច ១ ដោយអំណាចនៃការពិចារណាឃើញរឿយៗ នូវសង្ខារថាជារបស់ទទេ ១ ។

បុគ្គល សម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអំណាចនៃការកំណត់សង្ខារ ដែលប្រព្រឹត្តទៅថាមិនមានអំណាច តើដូចម្ដេច ។ បុគ្គលមិនបានអំណាចក្នុងរូប មិនបានអំណាចក្នុងវេទនា មិនបានអំណាចក្នុងសញ្ញា មិនបានអំណាចក្នុងសង្ខារទាំងឆ្ងាយ មិនបានអំណាចក្នុងវិញ្ញាណ ។ ដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឆ្ងាយ រូប មិនមែនជារបស់ខ្លួន ម្នាលភិក្ខុទាំងឆ្ងាយ ប្រសិនបើរូបនេះ ជារបស់ខ្លួនពិតមែន រូបនេះមិនគប្បីប្រព្រឹត្តទៅ ដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបានក្នុងរូបថា សូមឲ្យរូបអាត្មាមានយ៉ាងនេះ កុំឲ្យរូបអាត្មា មានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឆ្ងាយ ព្រោះហេតុតែរូប មិនមែនជារបស់ខ្លួន ហេតុនោះ រូបទើបប្រព្រឹត្តទៅដើម្បីអាពាធ ទាំងបុគ្គលមិនបានក្នុងរូបថា សូមឲ្យរូបអាត្មា មានយ៉ាងនេះ កុំឲ្យរូបអាត្មា មានយ៉ាងនេះឡើយ វេទនា មិនមែនជារបស់ខ្លួន

៦៧

មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

ច ហិទំ ភិក្ខវេ អត្តា អភវិស្ស នយិទំ វេទនា អាពាធាយ សំវត្តេយ្យ លព្ភេថ ច វេទនាយ ឯវំ មេ វេទនា ហោតុ ឯវំ មេ វេទនា មា អហោសីតិ យស្មា ច ខោ ភិក្ខវេ វេទនា អនត្តា តស្មា វេទនា អាពាធាយ សំវត្តតិ ន ច លព្ភតិ វេទនាយ ឯវំ មេ វេទនា ហោតុ ឯវំ មេ វេទនា មា អហោសីតិ សញ្ញា អនត្តា សញ្ញា ច ហិទំ ភិក្ខវេ អត្តា អភវិស្ស នយិទំ សញ្ញា អាពាធាយ សំវត្តេយ្យ លព្ភេថ ច សញ្ញាយ ឯវំ មេ សញ្ញា ហោតុ ឯវំ មេ សញ្ញា មា អហោសីតិ យស្មា ច ខោ ភិក្ខវេ សញ្ញា អនត្តា តស្មា សញ្ញា អាពាធាយ សំវត្តតិ ន ច លព្ភតិ សញ្ញាយ ឯវំ មេ សញ្ញា ហោតុ ឯវំ មេ សញ្ញា មា អហោសីតិ សង្ខារា អនត្តា សង្ខារា ច ហិទំ ភិក្ខវេ អត្តា អភវិស្សំសុ[១] នយិទំ សង្ខារា អាពាធាយ សំវត្តេយ្យុំ លព្ភេថ ច សង្ខារេសុ

១ ម. អភវិស្ស ។

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើវេទនានេះ ជារបស់ខ្លួនពិតមែន វេទនានេះ មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបានក្នុងវេទនាថា សូមឲ្យវេទនារបស់អាត្មា មានយ៉ាងនេះ កុំឲ្យវេទនារបស់អាត្មា មានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែវេទនា មិនមែនជារបស់ខ្លួន ហេតុនោះ វេទនាទើបប្រព្រឹត្តទៅ ដើម្បីអាពាធ ទាំងបុគ្គលមិនបានក្នុងវេទនាថា សូមឲ្យវេទនារបស់អាត្មាមានយ៉ាងនេះ កុំឲ្យវេទនារបស់អាត្មា មានយ៉ាងនេះឡើយ សញ្ញាមិនមែនជារបស់ខ្លួនទេ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសញ្ញានេះ ជារបស់ខ្លួនពិតមែន សញ្ញានេះមិនគប្បីប្រព្រឹត្តទៅ ដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបានក្នុងសញ្ញាថា សូមឲ្យសញ្ញារបស់អាត្មា មានយ៉ាងនេះ កុំឲ្យសញ្ញារបស់អាត្មាមានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំង-ឡាយ ព្រោះហេតុតែសញ្ញា មិនមែនជារបស់ខ្លួន ហេតុនោះ សញ្ញាទើបប្រព្រឹត្តទៅ ដើម្បីអាពាធ ទាំងបុគ្គលមិនបានក្នុងសញ្ញាថា សូមឲ្យសញ្ញារបស់អាត្មា មានយ៉ាងនេះ កុំឲ្យសញ្ញារបស់អាត្មា មានយ៉ាងនេះឡើយ សង្ខារទាំងឡាយ មិនមែនជារបស់ខ្លួនទេ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសង្ខារទាំងឡាយនេះ ជារបស់ខ្លួនពិតមែន សង្ខារទាំងឡាយនេះ មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបាន ក្នុងសង្ខារទាំងឡាយថា

ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហេ-
សុន្តិ យស្មា ច ខោ ភិក្ខវេ សង្ខារា អនត្តា តស្មា
សង្ខារា អាពាធាយ សំវត្តន្តិ ន ច លព្ភតិ សង្ខារេសុ
ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហេសុន្តិ
វិញ្ញាណំ អនត្តា វិញ្ញាណញ្ច ហិទំ ភិក្ខវេ អត្តា
អភវិស្ស នយិទំ វិញ្ញាណំ អាពាធាយ សំវត្តេយ្យ
លព្ភេថ ច វិញ្ញាណេ ឯវំ មេ វិញ្ញាណំ ហោតុ
ឯវំ មេ វិញ្ញាណំ មា អហោសីតិ យស្មា ច
ខោ ភិក្ខវេ វិញ្ញាណំ អនត្តា តស្មា វិញ្ញាណំ
អាពាធាយ សំវត្តតិ ន ច លព្ភតិ វិញ្ញាណេ ឯវំ
មេ វិញ្ញាណំ ហោតុ ឯវំ មេ វិញ្ញាណំ មា
អហោសីតិ ។ វុត្តញ្ហេតំ ភគវតា ធាយំ ភិក្ខវេ
កាយោ តុម្ហាកំ នបិ បរេសំ បុរាណមិទំ

សូមឲ្យសង្ខារទាំងឡាយរបស់អាត្មាមានយ៉ាងនេះ កុំឲ្យសង្ខារទាំងឡាយ
របស់អាត្មាមានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសង្ខារ
ទាំងឡាយ មិនមែនជារបស់ខ្លួន ហេតុនោះ សង្ខារទាំងឡាយ ទើប
ប្រព្រឹត្តទៅ ដើម្បីអាពាធ ទាំងបុគ្គលមិនបានក្នុងសង្ខារទាំងឡាយថា សូម
ឲ្យសង្ខារទាំងឡាយរបស់អាត្មា មានយ៉ាងនេះ កុំឲ្យសង្ខារទាំងឡាយរបស់
អាត្មាមានយ៉ាងនេះឡើយ វិញ្ញាណមិនមែនជារបស់ខ្លួនទេ ម្នាលភិក្ខុទាំង-
ឡាយ ប្រសិនបើវិញ្ញាណនេះ ជារបស់ខ្លួនពិតមែន វិញ្ញាណនេះមិន
គប្បីប្រព្រឹត្តទៅ ដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបានក្នុងវិញ្ញាណថា
សូមឲ្យវិញ្ញាណរបស់អាត្មា មានយ៉ាងនេះ កុំឲ្យវិញ្ញាណរបស់អាត្មាមាន
យ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែវិញ្ញាណ មិនមែន
ជារបស់ខ្លួន ហេតុនោះ វិញ្ញាណទើបប្រព្រឹត្តទៅ ដើម្បីអាពាធ ទាំងបុគ្គល
មិនបានក្នុងវិញ្ញាណថា សូមឲ្យវិញ្ញាណរបស់អាត្មា មានយ៉ាងនេះ កុំឲ្យ
វិញ្ញាណរបស់អាត្មា មានយ៉ាងនេះឡើយ ។ មួយទៀត ព្រះពុទ្ធដីកា
នេះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាយនេះ មិន
មែនជារបស់អ្នកទាំងឡាយទេ ទាំងមិនមែនជារបស់ជនទាំងឡាយដទៃទេ

មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

ភិក្ខវេ កម្មំ សង្ខតំ អភិសញ្ចេតយិតំ វេទនិយំ ទដ្ឋព្វំ តត្រ ភិក្ខវេ សុតវា អរិយសាវកោ បដិច្ចសមុប្បាទញ្ញេវ សាធុកំ យោនិសោ មនសិករោតិ ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ យទិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ អវិជ្ជាយត្វេវ អសេសវិរាគនិរោធា

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីឃើញថា កាយនេះកើតអំពីកម្ម ចាស់ដែលបច្ច័យប្រជុំតាក់តែង មានចេតនាជាមូល ជាទីតាំងនៃវេទនា ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក អ្នកចេះដឹង តែងធ្វើទុកក្នុងចិត្តដោយ ឧបាយយ៉ាងប្រពៃ ចំពោះធម៌ដែលកើតអាស្រ័យគ្នានិងគ្នាក្នុងកាយនោះថា កាលបើធម្មជាតនេះមាន ធម្មជាតនេះក៏មាន ធម្មជាតនេះកើតឡើងព្រោះ ការកើតឡើងនៃធម្មជាតនេះ កាលបើធម្មជាតនេះមិនមាន ធម្មជាតនេះក៏មិន មាន ធម្មជាតនេះរលត់ ព្រោះការរលត់ធម្មជាតនេះ គឺថាសង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ (កើតមាន) ព្រោះសង្ខារ ជាបច្ច័យ នាមរូប (កើតមាន) ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈ (កើតមាន) ព្រោះនាមរូបជាបច្ច័យ ផស្សៈ (កើតមាន) ព្រោះសឡាយ-តនៈជាបច្ច័យ វេទនា (កើតមាន) ព្រោះផស្សៈជាបច្ច័យ តណ្ហា (កើតមាន) ព្រោះវេទនាជាបច្ច័យ ឧបាទាន (កើតមាន) ព្រោះតណ្ហាជាបច្ច័យ ភព (កើតមាន) ព្រោះឧបាទានជាបច្ច័យ ជាតិ (កើតមាន) ព្រោះភពជា បច្ច័យ ការចាស់ ស្វាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀត ណែនក្នុងចិត្តទាំងឡាយ កើតមាន ព្រោះជាតិជាបច្ច័យ កិរិយាកើតឡើង នៃកងទុក្ខទាំងអស់នេះ រមែងកើតមានយ៉ាងនេះ មួយទៀត កិរិយារលត់ សង្ខារ ព្រោះកិរិយាវិនាសទៅរលត់ទៅ មិនមានសេសសល់ នៃអវិជ្ជា

សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ
វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា
សឬាយតននិរោធោ សឬាយតននិរោធា ផស្ស-
និរោធោ ផស្សនិរោធា វេទនានិរោធោ វេទនានិរោធា
តណ្ហានិរោធោ តណ្ហានិរោធា ឧចាទាននិរោធោ
ឧចាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោ-
ធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខោ-
មនស្សុចាយាសា និរុជ្ឌន្តិ ឯវមេតស្ស កេវលស្ស
ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ ឯវំ អវសិយ-
ឬវត្តសលក្ខណាវសេន សុញ្ញតោ លោកំ អវេក្ខតិ ។
ឥមិនា ។ តុច្ឆសង្ខារសមនុបស្ឬនាវសេន សុញ្ញតោ
លោកំ អវេក្ខតិ ។ ១ រូបេ សារោ ន លព្ភតិ វេទនាយ
សារោ ន លព្ភតិ សញ្ញាយ សារោ ន លព្ភតិ សង្ខារេ-
សុ សារោ ន លព្ភតិ វិញ្ញាណេ សារោ ន លព្ភតិ ។

កិរិយារលត់វិញ្ញាណ ព្រោះកិរិយារលត់សង្ខារ កិរិយារលត់នាមរូប ព្រោះកិរិយារលត់វិញ្ញាណ កិរិយារលត់សឡាយតន: ព្រោះកិរិយារលត់នាមរូប កិរិយារលត់ផស្ស: ព្រោះកិរិយារលត់សឡាយតន: កិរិយារលត់វេទនា ព្រោះកិរិយារលត់ផស្ស: កិរិយារលត់តណ្ហា ព្រោះកិរិយារលត់វេទនា កិរិយារលត់ឧបាទាន ព្រោះកិរិយារលត់តណ្ហា កិរិយារលត់ភព ព្រោះកិរិយារលត់ឧបាទាន កិរិយារលត់ជាតិ ព្រោះកិរិយារលត់ភព ការចាស់ ស្វាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀត ចង្អល់ចិត្តទាំងឡាយ តែងរលត់ទៅ ព្រោះកិរិយារលត់ជាតិ កិរិយារលត់កងទុក្ខទាំងអស់នេះ មានយ៉ាងនេះ ។ បុគ្គលសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអំណាចនៃការកំណត់សង្ខារ ដែលប្រព្រឹត្តទៅថាមិនមានអំណាច យ៉ាងនេះឯង ។

បុគ្គលសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអំណាចនៃការពិចារណាឃើញរឿយៗ នូវសង្ខារថាជារបស់ទទេ តើដូចម្តេច ។ គឺបុគ្គលមិនបានខ្ជឹមក្នុងរូប មិនបានខ្ជឹមក្នុងវេទនា មិនបានខ្ជឹមក្នុងសញ្ញា មិនបានខ្ជឹមក្នុងសង្ខារទាំងឡាយ មិនបានខ្ជឹមក្នុងវិញ្ញាណទេ ។

រូបំ អសារំ និស្សារំ សាភបតតំ និច្ចសារសារេន វា សុខសារសារេន វា អត្តសារសារេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វា ។ វេទនា អស្សាវា និស្សាវា សាភបតតា សញ្ញា អស្សាវា និស្សាវា សាភបតតា សង្ខារា អស្សាវា និស្សាវា សាភបតតា វិញ្ញាណំ អស្សារំ និស្សារំ សាភបតតំ និច្ចសារសារេន វា សុខសារសារេន វា អត្តសារសារេន វា និច្ចេន វា ធុវេន វា សស្ស-តេន វា អវិបរិណាមធម្មេន វា ។ យថា ឧទ្ធោ អស្សាវោ និស្សាវោ សាភបតតោ យថា ច ឯរណ្ឌោ អស្សាវោ និស្សាវោ សាភបតតោ យថា ច ឧទុម្ព-រោ អស្សាវោ និស្សាវោ សាភបតតោ យថា ច សេ-តតច្ឆো អស្សាវោ និស្សាវោ សាភបតតោ យថា ច ចាលិកច្ឆកោ អស្សាវោ និស្សាវោ សាភបតតោ យថា ច ផេណុបិណ្ឌោ អស្សាវោ និស្សាវោ សាភបតតោ

រូបជារបស់មិនមានខ្ញុំ ឥតខ្ញុំ ប្រាសចាកខ្ញុំ ដោយខ្ញុំមានខ្ញុំមគឺទៀងក្តី ដោយខ្ញុំមានខ្ញុំមគឺសុខក្តី ដោយខ្ញុំមានខ្ញុំមគឺរបស់ខ្លួនក្តី ដោយភាពជារបស់ទៀងក្តី យឺនយូរក្តី ឋិតថេរក្តី មិនប្រែប្រួលជាធម្មតាក្តី ។ វេទនាជារបស់មិនមានខ្ញុំ ឥតខ្ញុំ ប្រាសចាកខ្ញុំ សញ្ញាជារបស់មិនមានខ្ញុំ ឥតខ្ញុំ ប្រាសចាកខ្ញុំ សង្ខារទាំងឡាយ ជារបស់មិនមានខ្ញុំ ឥតខ្ញុំ ប្រាសចាកខ្ញុំ វិញ្ញាណ ជារបស់មិនមានខ្ញុំ ឥតខ្ញុំ ប្រាសចាកខ្ញុំ ដោយខ្ញុំមានខ្ញុំមគឺទៀងក្តី ដោយខ្ញុំមានខ្ញុំមគឺសុខក្តី ដោយខ្ញុំមានខ្ញុំមគឺរបស់ខ្លួនក្តី ដោយភាពជារបស់ទៀងក្តី យឺនយូរក្តី ឋិតថេរក្តី មិនប្រែប្រួលជាធម្មតាក្តី ។ ប្រៀបដូចដើមបបុស ជារបស់មិនមានខ្ញុំ ឥតខ្ញុំ ប្រាសចាកខ្ញុំ ឬដូចដើមល្ហុងខ្មៃ ជារបស់មិនមានខ្ញុំ ឥតខ្ញុំ ប្រាសចាកខ្ញុំ យ៉ាងណាមិញ មួយទៀត ដូចដើមល្ងា ជារបស់មិនមានខ្ញុំ ឥតខ្ញុំ ប្រាសចាកខ្ញុំ យ៉ាងណាមិញ ឬដូចដើមសេតគច្ឆព្រឹក្ស (រាក់ស) ជារបស់មិនមានខ្ញុំ ឥតខ្ញុំ ប្រាសចាកខ្ញុំ យ៉ាងណាមិញ មួយទៀត ដូចដើមបាលិកទ្ទកព្រឹក្ស (រលួសបាយ) ជារបស់មិនមានខ្ញុំ ឥតខ្ញុំ ប្រាសចាកខ្ញុំ យ៉ាងណាមិញ ឬដូចជាដុំពពុះទឹក ជារបស់មិនមានខ្ញុំ ឥតខ្ញុំ ប្រាសចាកខ្ញុំ យ៉ាងណាមិញ

យថា ច បុព្ពុលកំ អស្សារំ និស្សារំ សាភបតតំ យថា ច ភកន្ទលិក្ខន្ធោ អស្សារោ និស្សារោ សារបតតោ យថា ច មាយា អស្សារ និស្សារ សាភបតតា ឯវមេវ រូបំ អស្សារំ និស្សារំ សាភបតតំ និច្ចសារ-សារេន វ សុខសារសារេន វ អត្តសារសារេន វ និច្ចេន វ ធុវេន វ សស្សតេន វ អវិបរិណាម-ធម្មេន វ ។ ឯវ អស្សារ និស្សារ សាភបតតា សញ្ញា អស្សារ និស្សារ សាភបតតា សង្ខារ អស្សារ និស្សារ សាភបតតា វិញ្ញាណំ អស្សារំ និស្សារំ សាភបតតំ និច្ចសារសារេន វ សុខសារ-សារេន វ អត្តសារសារេន វ និច្ចេន វ ធុវេន វ សស្សតេន វ អវិបរិណាមធម្មេន ។ ឯវ តុច្ឆសង្ខារសមធុបស្ស ជ្ជារសេន សុញ្ញតោ លោកំ អវេក្ខតិ ។ ឥមេហិ ទ្វីហិ ការណេហិ សុញ្ញតោ លោកំ អវេក្ខតិ ។

មួយទៀត ដូចក្រពេញទឹក ជារបស់មិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹម យ៉ាងណាមិញ ឬដូចដើមចេក ជារបស់មិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹម យ៉ាងណាមិញ មួយទៀត ដូចថ្ងៃបណ្តើរកូន ជារបស់មិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹម យ៉ាងណាមិញ រូបជារបស់មិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹម ដោយខ្ទឹមមានខ្ទឹមគឺទៀងក្តី ដោយខ្ទឹមមានខ្ទឹមគឺសុខក្តី ដោយខ្ទឹមមានខ្ទឹមគឺរបស់ខ្លួនក្តី ដោយភាពជារបស់ទៀងក្តី យឺនយូរក្តី ឋិតថេរក្តី មិនប្រែប្រួលជាធម្មតាក្តី វេទនាជារបស់មិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹម សញ្ញាជារបស់មិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹម សង្ខារទាំង-ឆ្ងាយ ជារបស់មិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹម វិញ្ញាណជារបស់មិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹម ដោយខ្ទឹមមានខ្ទឹមគឺទៀងក្តី ដោយខ្ទឹមមានខ្ទឹមគឺសុខក្តី ដោយខ្ទឹមមានខ្ទឹមគឺរបស់ខ្លួនក្តី ដោយភាពជារបស់ទៀងក្តី យឺនយូរក្តី ឋិតថេរក្តី មិនប្រែប្រួលជាធម្មតាក្តី ក៏យ៉ាងនោះដែរ ។ បុគ្គលសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអំណាចការពិចារណារឿយៗ នូវសង្ខារថាជារបស់ទទេ យ៉ាងនេះ ។ បុគ្គលសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយហេតុពីរប្រការនេះឯង ។

មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

អបិច ឆហាការេហិ សុញ្ញតោ លោកំ អវ-
ក្ខតិ រូបំ អនិស្សរិយតោ អកាមការិយតោ អជា-
សុនិយតោ អវសវត្តនតោ បវុត្តិតោ រិត្តតោ អវ-
ក្ខតិ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អនិស្សរិយ-
តោ អកាមការិយតោ អជាសុនិយតោ អវសវត្តន-
តោ បវុត្តិតោ រិត្តតោ អវេក្ខតិ ។ ឯវំ ឆហាការ-
ហិ សុញ្ញតោ លោកំ អវេក្ខតិ ។ អបិច ឧស-
ហាការេហិ សុញ្ញតោ លោកំ អវេក្ខតិ រូបំ រិត្ត-
តោ តុច្ឆតោ សុញ្ញតោ អនត្តតោ អសារកតោ
រោគតោ ភីរុតោ អឃមូលតោ សាសវតោ
សង្ខតតោ អវេក្ខតិ វេទនំ សញ្ញំ សង្ខារេ
វិញ្ញាណំ រិត្តតោ តុច្ឆតោ សុញ្ញតោ អនត្តតោ
អសារកតោ រោគតោ ភីរុតោ អឃមូលតោ

មួយទៀត បុគ្គលសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការ: ៦ គឺសម្ងឹងឃើញរូប ដោយសភាពជារបស់មិនមានអ្វីជាឥស្សរ: ១ មិនលុះតាមប្រាជ្ញា ១ មិនជាទីសប្បាយ ១ មិនលុះអំណាចខ្លួន ១ ប្រព្រឹត្ត (ជាប់ដោយបច្ច័យ) ១ ជារបស់ទទេ ១ សម្ងឹងឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ដោយសភាពជារបស់មិនមានអ្វីជាឥស្សរ: មិនលុះតាមប្រាជ្ញា មិនជាទីសប្បាយ មិនលុះអំណាចខ្លួន ប្រព្រឹត្ត (ជាប់ដោយបច្ច័យ) ជារបស់ទទេ ។ បុគ្គលសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការ: ៦ យ៉ាងនេះឯង ។ មួយទៀត បុគ្គលសម្ងឹងឃើញលោកដោយសភាពជារបស់សូន្យ ដោយអាការ: ១០ គឺសម្ងឹងឃើញរូប ដោយសភាពជារបស់គ្មាន ១ របស់ទទេ ១ របស់សូន្យ ១ របស់មិនមែនខ្លួនប្រាណ ១ របស់មិនមានខ្ជឹម ១ ជាអ្នកសម្ងាប់ ១ របស់មិនចម្រើន ១ របស់បង្កទុក្ខ ១ របស់ប្រកបដោយអាសវ: ១ របស់ដែលបច្ច័យប្រជុំតាក់តែង ១ សម្ងឹងឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ដោយសភាពជារបស់គ្មាន របស់ទទេ របស់សូន្យ របស់មិនមែនខ្លួនប្រាណ របស់មិនមានខ្ជឹម ជាអ្នកសម្ងាប់ របស់មិនចម្រើន របស់បង្កទុក្ខ

សាសវគោ សង្ខ្ជតគោ អវេក្ខតិ ។ ឯវំ ឧសហា-
ការេហិ សុញ្ញតោ លោកំ អវេក្ខតិ ។ អបិច
ទ្វាឧសហាការេហិ សុញ្ញតោ លោកំ អវេក្ខតិ រូបំ
ន សត្តោ ន ជីវោ ន ចោសោ ន ឆវោ ន
មាណវោ ន ឥត្តី ន បុរិសោ ន អត្តា ន អត្ត-
និយំ ន អហំ ន មម ន កោចិ អត្តិ វេឧនា
សញ្ញា សង្ខ្ជារ វិញ្ញាណំ ន សត្តោ ន ជីវោ ន
ចោសោ ន ឆវោ ន មាណវោ ន ឥត្តី ន បុរិសោ
ន អត្តា ន អត្តនិយំ ន អហំ ន មម ន កោចិ
អត្តិ ។ ឯវំ ទ្វាឧសហាការេហិ សុញ្ញតោ លោកំ
អវេក្ខតិ ។

រុត្តញ្ចេតំ ភគវតា យំ ភិក្ខវេ ន តុម្ហាកំ តំ បជ-
ហថ តំ ហោ បហីនំ ឥយរត្តំ ហិតាយ សុខាយ ភវិស្សតិ
កិញ្ច ភិក្ខវេ ន តុម្ហាកំ រូបំ ភិក្ខវេ ន តុម្ហាកំ

របស់ប្រកបដោយអាសវៈ របស់ដែលបច្ច័យប្រជុំតាក់តែង ។ បុគ្គលសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការៈ ១០ យ៉ាងនេះឯង ។ មួយទៀត បុគ្គលសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការៈ ១២ គឺឃើញថា រូបមិនមែនសត្ត ១ មិនមែនជីវៈ ១ មិនមែនបុរស ១ មិនមែននរៈ ១ មិនមែនមាណព ១ មិនមែនស្រី ១ មិនមែនប្រុស ១ មិនមែនខ្លួន ១ មិនមែនរបស់ខ្លួន ១ មិនមែនយើង ១ មិនមែនរបស់យើង ១ មិនមែនជាបុគ្គលណា ។ ១ ឃើញថា វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែនសត្ត មិនមែនជីវៈ មិនមែនបុរស មិនមែននរៈ មិនមែនមាណព មិនមែនស្រី មិនមែនប្រុស មិនមែនខ្លួន មិនមែនរបស់ខ្លួន មិនមែនយើង មិនមែនរបស់យើង មិនមែនជាបុគ្គលណា ។ ។ បុគ្គលសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការៈ ១២ យ៉ាងនេះឯង ។

ដូចព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ហើយនេះថា ម្នាលភិក្ខុទាំងឡាយ របស់ណា មិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់របស់នោះ របស់នោះដែលពួកអ្នកបានលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្ដីសុខ អស់កាលយូរ ម្នាលភិក្ខុទាំងឡាយ របស់អ្វី ដែលមិនមែនជារបស់ពួកអ្នក ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជារបស់ពួកអ្នក

មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

តំ បជហថ តំ ភោ បហីនំ ឌីឃរត្តំ ហិតាយ
សុខាយ ភវិស្សតិ ឯវមេវ ខោ តុម្ហាកំ
តំ បជហថ សា ភោ បហីនា ឌីឃរត្តំ ហិតាយ
សុខាយ ភវិស្សតិ សញ្ញា ខោ តុម្ហាកំ
តំ បជហថ សា ភោ បហីនា ឌីឃរត្តំ ហិតាយ
សុខាយ ភវិស្សតិ សង្ខារា ខោ តុម្ហាកំ
តេ បជហថ តេ ភោ បហីនា ឌីឃរត្តំ ហិតាយ
សុខាយ ភវិស្សន្តិ វិញ្ញាណំ ខោ តុម្ហាកំ
តំ បជហថ តំ ភោ បហីនំ ឌីឃរត្តំ ហិតាយ
សុខាយ ភវិស្សតិ ។ តំ កិំ មញ្ញថ ខោ យំ
ឥមស្មឹ ជេតវនេ តិណកដ្ឋសាខាបលាសំ តំ ជនো
ហរেយ្យ វា ឌហেយ្យ វា យថាបច្ចយំ វា ករেយ្យ
អបិនុ តុម្ហាកំ ឯវមស្ស អម្ហេ ជនো ហរতি
វা ឌহতি វা យথাপচ্চযং বা করেয্যতি ។
ជនোហেতং ភន্তে ។ តំ កិស្ស ហেতু ។

ពួកអ្នកចូរលះបង់រូបនោះ រូបនោះដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្ដីសុខ អស់កាលយូរ ម្នាលភិក្ខុទាំងឡាយ វេទនាមិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់វេទនានោះ វេទនានោះ ដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្ដីសុខ អស់កាលយូរ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់សញ្ញានោះ សញ្ញានោះ ដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្ដីសុខអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់សង្ខារទាំងនោះ សង្ខារទាំងនោះ ដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្ដីសុខអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណ មិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់វិញ្ញាណនោះ វិញ្ញាណៈនោះដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្ដីសុខ អស់កាលយូរ ។ ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសម្គាល់ហេតុនោះថាដូចម្ដេច ស្មៅ ឈើ មែកឈើ ស្ទឹកឈើណា ក្នុងវត្តជេតពននេះ ជនគប្បីនាំទៅក្ដី ដុតក្ដី ធ្វើឲ្យគួរតាមបច្ច័យក្ដី នូវរបស់នោះ តើពួកអ្នកគិតយ៉ាងនេះថា ជននាំទៅក្ដី ដុតក្ដី ធ្វើឲ្យគួរតាមបច្ច័យក្ដី នូវពួកយើងដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះមិនដូច្នោះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។

ន ឌោ ឯវំ ភន្តេ អត្តា វា អត្តនិយំ វាតិ ។ ឯវមេវ ខោ ភិក្ខវេ យំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ឌីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ កិញ្ច ភិក្ខវេ ន តុម្ហាកំ រូបំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ឌីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ វេឌនា សញ្ញា សង្ខារា វិញ្ញាណំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ឌីឃរត្តំ ហិតាយ សុខាយ ភវិស្សតីតិ ។ ឯវម្ឌិ សុញ្ញតោ លោកំ អវេក្ខតិ ។

អាយស្មា អានន្ឌោ ភគវន្តំ ឯតឌវោច សុញ្ញោ លោកោតិ ភន្តេ វុច្ឌតិ កិត្តាវតា ន-ខោ ភន្តេ សុញ្ញោ លោកោតិ វុច្ឌតិ ។

បពិត្រព្រះអង្គដ៏ចម្រើន (ព្រោះថា) ខ្លួនក្តី របស់សម្រាប់ខ្លួនក្តី មិនមែនជារបស់ពួកខ្ញុំព្រះអង្គឡើយ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ ពិតយ៉ាងនេះហើយ របស់ណាមិនមែនជារបស់ពួកអ្នកទេ ពួកអ្នកចូរលះបង់របស់នោះ របស់នោះដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ របស់អ្វី ដែលមិនមែនជារបស់ពួកអ្នក ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់រូបនោះ រូបនោះដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់ វេទនា សញ្ញា សង្ខារ វិញ្ញាណនោះ វេទនា សញ្ញា សង្ខារ វិញ្ញាណនោះ ដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខអស់កាលយូរ ។ បុគ្គលសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ យ៉ាងនេះឯង ។

ព្រះអានន្ទមានអាយុ បានទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគត្រាស់ថា លោកសូន្យ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ត្រាស់ថា លោកសូន្យ តើដោយហេតុដូចម្តេច ។

យស្មា ខោ អានន្ទ សុញ្ញं អត្តេន វ អត្តនិយេន
វ តស្មា សុញ្ញោ លោកោតិ វុច្ចតិ កិញ្ចានន្ទ សុញ្ញं
អត្តេន វ អត្តនិយេន វ ។ ចក្ខុ សុញ្ញं រូបា សុញ្ញា
ចក្ខុវិញ្ញាណំ សុញ្ញं ចក្ខុសម្ផស្សោ សុញ្ញោ យម្បិទং
ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតं សុខं វ
ទុក្ខं វ អទុក្ខមសុខं វ តម្បि សុញ្ញं អត្តេន វ
អត្តនិយេន វ សោតं សុញ្ញं សទ្ទា សុញ្ញា ឃា-
នं សុញ្ញं គន្ធា សុញ្ញា ជិវ្ហា សុញ្ញា រសា សុញ្ញា
កាយោ សុញ្ញោ ផោដ្ឋព្ពា សុញ្ញា មនោ សុញ្ញោ
ធម្មា សុញ្ញា មនោវិញ្ញាណំ សុញ្ញं មនោសម្ផស្សោ
សុញ្ញោ យម្បិទং មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ
វេទយិតं សុខं វ ទុក្ខं វ អទុក្ខមសុខं វ តម្បि
សុញ្ញं អត្តេន វ អត្តនិយេន វ យស្មា ច ខោ
អានន្ទ សុញ្ញं អត្តេន វ អត្តនិយេន វ តស្មា
សុញ្ញោ លោកោតិ វុច្ចតីតិ ។ ឯវម្បि សុញ្ញតោ
លោកं អវេក្ខតិ ។

មោឃរាជមាណវកឃ្យញ្ជានិទ្ទេស

ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ព្រោះហេតុតែធម្មជាតសូន្យចាកខ្លួន ឬចាកវត្ថុសម្រាប់ខ្លួន ហេតុនោះ ទើបតថាគតពោលថា លោកសូន្យ ម្នាលអានន្ទ ចុះធម្មជាតអ្វី សូន្យចាកខ្លួន ឬចាកវត្ថុសម្រាប់ខ្លួន ។ ភ្នែកសូន្យ រូបទាំងឡាយសូន្យ ចក្ខុវិញ្ញាណសូន្យ ចក្ខុសម្ផស្សសូន្យ សូម្បីធម្មជាតសម្រាប់ទទួលអារម្មណ៍ណា ជាសុខ ឬជាទុក្ខ ឬមិនជាទុក្ខមិនជាសុខ កើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតនោះ ក៏សូន្យចាកខ្លួន ឬចាកវត្ថុសម្រាប់ខ្លួន ត្រចៀកសូន្យ សំឡេងទាំង-ឡាយសូន្យ ច្រមុះសូន្យ ក្លិនទាំងឡាយសូន្យ អណ្ដាតសូន្យ រសទាំងឡាយសូន្យ កាយសូន្យ ផ្សព្វទាំងឡាយសូន្យ មនៈសូន្យ ធម្ម-អារម្មណ៍សូន្យ មនោវិញ្ញាណសូន្យ មនោសម្ផស្សសូន្យ មួយទៀត សូម្បីធម្មជាតសម្រាប់ទទួលអារម្មណ៍ណា ជាសុខ ឬជាទុក្ខ ឬមិនជាទុក្ខមិនជាសុខ កើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ធម្មជាតនោះ ក៏សូន្យចាកខ្លួន ឬចាកវត្ថុសម្រាប់ខ្លួន ម្នាលអានន្ទ ព្រោះហេតុតែធម្ម-ជាតសូន្យចាកខ្លួន ឬចាកវត្ថុសម្រាប់ខ្លួន ទើបតថាគតពោលថា លោកសូន្យ ។ បុគ្គលសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ យ៉ាងនេះឯង ។

សុទ្ធំ ធម្មសមុប្ផាទំ សុទ្ធំ សង្ខារសន្តតឺ
បស្សន្តស្ស យថាភូតំ ន តំ ភយំ ហោតិ តាទិណោ
តិណាកដ្ឋសមំ លោកំ យទា បញ្ញាយ បស្សតិ
ន អញ្ញំ បត្ថយេ កិញ្ចិ អញ្ញត្រ អប្ផដិសន្ធិយាតិ ។

ឯវម្ចិ សុញ្ញតោ លោកំ អវេក្ខតិ ។

រុត្តញ្ចេតំ ភគវតា ឯវមេវ ភិក្ខវេ ភិក្ខុ រូបំ សមន្នេសតិ យាវតា រូបស្ស គតិ វេទនំ សមន្នេសតិ យាវតា វេទនាយ គតិ សញ្ញំ សមន្នេសតិ យាវតា សញ្ញាយ គតិ សង្ខារេ សមន្នេសតិ យាវតា សង្ខា-រានំ គតិ វិញ្ញាណំ សមន្នេសតិ យាវតា វិញ្ញាណស្ស គតិ តស្ស ភិក្ខុនោ រូបំ សមន្នេសតោ យាវតា រូបស្ស គតិ វេទនំ សមន្នេសតោ យាវតា វេទនា-យ គតិ សញ្ញំ សមន្នេសតោ យាវតា សញ្ញាយ គតិ សង្ខារេ សមន្នេសតោ យាវតា សង្ខារានំ គតិ

ម្នាលគាមិណី កាលបុគ្គលឃើញ តាមពិត នូវការកើត ឡើងនៃធម៌ដ៏បរិសុទ្ធ និងការជាប់តនៃសង្ខារដ៏បរិសុទ្ធ ក័យ នោះមិនមានទេ កាលណាបុគ្គលឃើញលោក ថាស្មើគ្នានឹង ស្មៅឬឈើ ដោយប្រាជ្ញា បុគ្គលមិនគប្បីប្រាថ្នារបស់ដទៃ ណាមួយឡើយ រៀរលែងតែព្រះនិព្វានដែលមិនមានបដិសន្ធិ ។ បុគ្គលសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ យ៉ាងនេះឯង ។

មួយទៀត ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំង-ឡាយ យ៉ាងនេះមែនហើយ ភិក្ខុស្វែងរករូប រហូតដល់ដំណើររបស់រូប ស្វែងរកវេទនា រហូតដល់ដំណើររបស់វេទនា ស្វែងរកសញ្ញា រហូតដល់ដំណើររបស់សញ្ញា ស្វែងរកសង្ខារទាំងឡាយ រហូតដល់ដំណើរ-របស់សង្ខារទាំងឡាយ ស្វែងរកវិញ្ញាណ រហូតដល់ដំណើររបស់វិញ្ញាណ កាលភិក្ខុនោះ ស្វែងរករូប រហូតដល់ដំណើររបស់រូប ស្វែងរកវេទនា រហូតដល់ដំណើររបស់វេទនា ស្វែងរកសញ្ញា រហូតដល់ដំណើររបស់-សញ្ញា ស្វែងរកសង្ខារទាំងឡាយ រហូតដល់ដំណើររបស់សង្ខារទាំងឡាយ

វិញ្ញាណំ សមន្នេសតោ យាវតា វិញ្ញាណស្ស គតិ យម្ហិ យស្ស ហោតិ អហន្តិ វ មមន្តិ វ អស្មីតិ វ តម្ហិ តស្ស ន ហោតីតិ ។ ឯវម្ហិ សុញ្ញតោ លោកំ អវេក្ខតិ ។

សុញ្ញតោ លោកំ អវេក្ខស្សូតិ សុញ្ញតោ លោ-កំ អវេក្ខស្ស បច្ចវេក្ខស្ស តុលេហិ តីរេហិ វិភាវ-ហិ វិភូតំ ភវេហីតិ សុញ្ញតោ លោកំ អវេក្ខស្ស ។

[៧៤] មោឃរាជ សជ្ជ សតោតិ មោឃរាជាតិ ភគវា តំ ព្រាហ្មណំ ជាមេន អាលបតិ ។ សជ្ជាតិ សព្វកាលំ ។ បេ ។ បច្ចិមេ វយោខន្ធេ ។ សតោតិ ចតូហិ ការណេហិ សតោ ការយ ការយនុប-ស្សជ្ជាសតិប្បដ្ឋានំ ភាវេន្តោ សតោ ។ បេ ។ សោ រុច្ចតិ សតោតិ មោឃរាជ សជ្ជ សតោ ។

ស្វែងរកវិញ្ញាណ រហូតដល់ដំណើរ របស់វិញ្ញាណ សេចក្ដីប្រកាន់ណា របស់ភិក្ខុណាថា អញក្ដី របស់អញក្ដី អញមានក្ដី សូម្បីសេចក្ដីប្រកាន់នោះ របស់ភិក្ខុនោះ ក៏មិនមានទេ ។ បុគ្គលសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ យ៉ាងនេះឯង ។

ពាក្យថា អ្នកចូរសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ គឺអ្នកចូរសម្ងឹងមើល ចូរពិចារណា ចូរប្រៀបធ្ងឹម ចូររំពឹង ចូរធ្វើឲ្យច្រាកដ ចូរធ្វើឲ្យច្បាស់លាស់ នូវលោក ដោយសភាពជារបស់សូន្យ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកចូរសម្ងឹងឃើញលោក ដោយសភាពជារបស់សូន្យ ។

[៧៤] ពាក្យថា មោឃរាជ របស់បទថា ម្នាលមោឃរាជ អ្នកចូរមានស្មារតីគ្រប់កាល គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះចំឈ្មោះ ។ ពាក្យថា គ្រប់កាល គឺអស់កាលទាំងពួង ។ បេ ។ ក្នុងគំនរវ័យជាបំផុត ។ ពាក្យថា មានស្មារតី គឺមានស្មារតីដោយហេតុ ៤ គឺកំពុងចម្រើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថាមានស្មារតី ។ បេ ។ បុគ្គលនោះ លោកហៅថា មានស្មារតី ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលមោឃរាជ អ្នកចូរមានស្មារតី គ្រប់កាល ។

[៧៤] អត្តានុទិដ្ឋី ឆហាច្ចាតិ អត្តានុទិដ្ឋិ រុច្ចតិ រីសតិវត្ថុកា សក្កាយទិដ្ឋិ ។ ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិ-ទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនី-តោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឿ វា អត្តានំ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តា-នំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឿ វា អត្តានំ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋि-វិសូកាយិកំ ទិដ្ឋិវិបន្ទិតំ ទិដ្ឋិសញ្ញោជនំ តាហោ បដិក្ខាហោ អភិនិវេសោ បរាមាសោ ឥមិ្ជ ក្ខោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសក្ខាហោ វិប-រីតក្ខាហោ វិបល្ហាសក្ខាហោ មិច្ឆាតាហោ អយាថាវ-កស្មឿ យាថាវកន្តិ តាហោ យាវតា ទ្ធាសដ្ឋី ទិដ្ឋि-គតានិ អយំ អត្តានុទិដ្ឋិ ។ អត្តានុទិដ្ឋី ឆហាច្ចាតិ អត្តានុទិដ្ឋី ឆហាច្ចេ សមូហាច្ចេ ឧទ្ធរិត្វា សមុទ្ធរិត្វា ឧប្ផាដយិត្វា សមុប្ផាដយិត្វា បជហិត្វា វិនោទេត្វា

[៧៥] ពាក្យថា បុគ្គលដកអត្តានុទិដ្ឋិចេញ អធិប្បាយថា សក្កាយទិដ្ឋិ មានវត្ថុ ២០ លោកហៅថា អត្តានុទិដ្ឋិ ។ បុថុជ្ជន អ្នកមិនចេះដឹងក្នុងលោកនេះ មិនឃើញពួកព្រះអរិយៈ មិនឈ្វាសវៃចំពោះអរិយធម៌ មិនបានទូន្មានខ្លួន ក្នុងអរិយធម៌ មិនឃើញពួកសប្បុរស មិនឈ្វាសវៃចំពោះសប្បុរិសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញនូវរូបថាខ្លួន នូវខ្លួនថាមានរូបខ្លះ នូវរូបក្នុងខ្លួនខ្លះ នូវខ្លួនក្នុងរូបខ្លះ ពិចារណាឃើញ នូវវេទនា សញ្ញា សង្ខារ វិញ្ញាណថាខ្លួន នូវខ្លួនថាមានវិញ្ញាណខ្លះ នូវវិញ្ញាណក្នុងខ្លួនខ្លះ នូវខ្លួនក្នុងវិញ្ញាណខ្លះ សេចក្តីឃើញ សេចក្តីយល់ ការប្រកាន់តាមយល់ ផ្លូវដាច់ស្រយាល គឺទិដ្ឋិ សត្រូវ គឺទិដ្ឋិ ការញាប់ញ័រ គឺទិដ្ឋិ សំយោជនៈ គឺទិដ្ឋិ ការប្រកាន់ ការប្រកាន់មាំ ការប្រកាន់ស្អិត ការបបោសអង្អែល ផ្លូវអាក្រក់ ផ្លូវខុស សេចក្តីខុស លទ្ធិដូចជាកំពង់ ការប្រកាន់ធ្វេង ការប្រកាន់ឃ្យៀងឃ្វាត ការប្រកាន់វិបល្វាស ការប្រកាន់ខុស ការប្រកាន់ថាពិតក្នុងរបស់មិនពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មាន យ៉ាងនេះ ឯណា នេះជាអត្តានុទិដ្ឋិ ។ ពាក្យថា បុគ្គល ដកអត្តានុទិដ្ឋិចេញ គឺ ដក ដករំលើង ភើច ភើចរំលើង គាស់ គាស់រំលើង លះបង់ បន្ទោបង់

ព្យន្តីកត្វា អនភាវង្គមេត្វាតិ អត្តានុទិដ្ឋឹ ឩហច្ច ។

[៧៦] ឯវំ មច្ចុតរោ សិយាតិ ឯវំ មច្ចុម្បិ តរេយ្យាសិ ជរម្បិ តរេយ្យាសិ មរណម្បិ តរេយ្យាសិ ឧត្តរេយ្យាសិ សមតិក្កមេយ្យាសិ វីតិវត្តេយ្យាសីតិ ឯវំ មច្ចុតរោ សិយា ។

[៧៧] ឯវំ លោកំ អវេក្ខន្តន្តិ ឯវំ លោកំ អវេក្ខន្តំ បច្ចវេក្ខន្តំ តុលយន្តំ តិរយន្តំ វិភាវយន្តំ វិភូតំ ករោន្តន្តិ ឯវំ លោកំ អវេក្ខន្តំ ។

[៧៨] មច្ចុរាជា ន បស្សតីតិ មារោបិ មច្ចុរាជា មរណម្បិ មច្ចុរាជា ។ ន បស្សតីតិ មច្ចុរាជា ន បស្សតិ ន ទក្ខតិ នាធិគច្ឆតិ ន វិន្ទតិ ន បដិលភតិ ។ វុត្តញ្ហេតំ ភគវតា សេយ្យថាបិ ភិក្ខវេ អារញ្ញកោ មិគោ អរញ្ញេ បវនេ ចរមានោ វិស្សត្ថោ គច្ឆតិ វិស្សត្ថោ តិដ្ឋតិ វិស្សត្ថោ និសីទតិ វិស្សត្ថោ សេយ្យំ

ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នៃអត្តានុទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលដកអត្តានុទិដ្ឋិចេញ ។

[៧៦] ពាក្យថា ទើបធ្វើផុតចាកមច្ចុយ៉ាងនេះ គឺនឹងធ្វើចាកមច្ចុផង ធ្វើចាកជរាផង ធ្វើ ធ្វើឡើង ធ្វើរំលង ប្រព្រឹត្តកន្ទងមរណៈផង យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ទើបធ្វើផុតចាកមច្ចុ យ៉ាងនេះ ។

[៧៧] ពាក្យថា បុគ្គលសម្ងឹងឃើញនូវលោកយ៉ាងនេះ គឺបុគ្គលកំពុងសម្ងឹងមើល ពិចារណា ប្រៀបធ្ងឹម ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដនូវលោក យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលសម្ងឹងឃើញលោក យ៉ាងនេះ ។

[៧៨] ពាក្យថា មច្ចុរាជទើបមិនឃើញ អធិប្បាយថា មារឈ្មោះថាមច្ចុរាជ សេចក្តីស្លាប់ ឈ្មោះថាមច្ចុរាជ ។ ពាក្យថា មិនឃើញ គឺមច្ចុរាជ មិនឃើញ មិនយល់ មិនជួបប្រទះ មិនបាន មិនបានចំពោះ ។ ដូចព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ហើយនេះថា ម្នាលភិក្ខុទាំងឡាយ ដូចម្រឹគដែលនៅក្នុងព្រៃ ត្រាច់ទៅក្នុងព្រៃធំ រមែងដើរឥតរង្គៀស ឈរឥតរង្គៀស អង្គុយឥតរង្គៀស ដេកឥតរង្គៀស

កប្បេតិ តំ កិស្ស ហេតុ អជាចាចតោ ភិក្ខវេ លុទ្ទស្ស[១] ឯវមេវ ខោ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ[២] វធិត្វា មារចក្ខុអទស្សនំ គតោ ចាបិមតោ បុនចបរំ ភិក្ខវេ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុអទស្សនំ គតោ ចាបិមតោ បុនចបរំ ភិក្ខវេ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា

១ ម. ទុក្ខស្ស ។ ២ ម. អបរំ ។

ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះម្រ៉ឹគនុ៎ះមិន នៅក្នុងគន្ធងរបស់ព្រាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្ងាត់ ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលបឋម-ជ្ឈាន ដែលមានវិតក្ក:និងវិចារ: មានបីតិនិងសុខ ដែលកើតអំពីសេចក្តី សូ្ងប់ស្ងាត់ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថាបានធ្វើមារឲ្យ ខ្វាក់ សម្ងាប់មិនឲ្យមានស្នាមជើង ដល់នូវការមិនឃើញដោយភ្នែកនៃ មារដែលមានចិត្តបាប ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ ព្រោះរម្ងាប់ វិតក្ក:និងវិចារ: ចូលទុតិយជ្ឈាន ជាធម្មជាតកើតមាន ក្នុងសន្តាន ប្រកបដោយសេចក្តីជ្រះថ្លា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក: និងវិចារ: មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ ចូលតតិយជ្ឈាន ចតុត្ថជ្ឈាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានធ្វើ នូវមារ ឲ្យខ្វាក់ សម្ងាប់មិនឲ្យមានស្នាមជើង ដល់នូវការមិនឃើញ ដោយភ្នែកនៃមារ ដែលមានចិត្តបាប ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ ព្រោះកន្ធងរូបសញ្ញា ដោយសព្វគ្រប់ ធ្វើបដិឃសញ្ញាឲ្យវិនាស មិនធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ហើយចូលអាកាសានញ្ចាយតន: ដោយបរិកម្មថា អាកាស មិនមានទីបំផុត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានធ្វើមារឲ្យខ្វាក់ សម្ងាប់ មិនឲ្យមានស្នាមជើង

៨៣

មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

មារចក្ខុអទស្សនំ គតោ ចាបិមតោ បុនចបរំ ភិក្ខវេ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយ ចស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុអទស្សនំ គតោ ចាបិមតោ តិណ្ណោ លោកេ វិសត្តិកំ សោ វិស្សត្ថោ គច្ឆតិ វិស្សត្ថោ តិដ្ឋតិ វិស្សត្ថោ និសីទតិ វិស្សត្ថោ សេយ្យំ កប្បេតិ តំ កិស្ស ហេតុ អនាចាថគតោ ភិក្ខវេ ចាបិមតោតិ មច្ចុរាជា ន បស្សតិ ។ តេនាហ ភគវា

ដល់នូវការមិនឃើញដោយភ្នែកនៃមារដែលមានចិត្តបាប ម្នាលភិក្ខុទាំង-ឡាយ មួយទៀត ភិក្ខុ កន្ធង់អាកាសានញ្ចាយតនៈដោយសព្វគ្រប់ ហើយចូលវិញ្ញាណញ្ចាយតនៈដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត កន្ធង់វិញ្ញា-ណញ្ចាយតនៈដោយសព្វគ្រប់ ហើយចូលអាកិញ្ចញ្ញាយតនៈដោយបរិកម្មថា អ្វីតិចតួចមិនមាន កន្ធង់អាកិញ្ចញ្ញាយតនៈដោយសព្វគ្រប់ ហើយចូលនេវ-សញ្ញានាសញ្ញាយតនៈ កន្ធង់នេវសញ្ញានាសញ្ញាយតនៈដោយសព្វគ្រប់ ហើយចូលសញ្ញាវេទយិតនិរោធ លុះភិក្ខុនោះ បានឃើញដោយប្រាជ្ញា អាសវៈទាំងឡាយ ក៏អស់រលីង ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានធ្វើមារឲ្យខ្វាក់ សម្ងាប់មិនឲ្យមានស្នាមជើង ដល់នូវការមិនឃើញ ដោយភ្នែក នៃមារដែលមានចិត្តបាប ឆ្ងងតណ្ហាឈ្នោះវិសត្តិកាក្នុងលោក បាន ភិក្ខុនោះ រមែងដើរឥតរង្គៀស ឈរឥតរង្គៀស អង្គុយឥតរង្គៀស ដេកឥតរង្គៀស ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះមិននៅក្នុងគន្ធង់ របស់មារមានចិត្តបាប ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) មច្ចុរាជ ទើបមិនឃើញ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

សុញ្ញតោ លោកំ អវេក្ខស្សុ មោឃរាជ សទា សតោ
អត្តានុទិដ្ឋិ ឱហច្ច ឯវំ មច្ចុតរោ សិយា
ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតីតិ ។

សហ គាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

មោឃរាជមាណវកប្បញ្ហានិទ្ទេសោ បណ្ណរសមោ ។

ម្នាលមោឃរាជ អ្នកចូរមានស្មារតីគ្រប់កាល សម្ងឹងឃើញ លោក ដោយសភាពជារបស់សូន្យ (ព្រោះ) បុគ្គលដកអត្តានុទិដ្ឋិចេញ ទើបឆ្លងផុតចាកមច្ចុ បុគ្គលសម្ងឹងឃើញលោកយ៉ាងនេះ មច្ចុរាជទើបមិនឃើញ ។

ព្រមដោយការចប់គាថា ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមជាសាវ័ក ។

ចប់ មោឃរាជមាណវកប្បញ្ហានិទ្ទេស ទី ១៥ ។

បិដ្ឋិយមាណវកប្បញ្ហានិទ្ទេសោ

[៧៩] ជិណ្ណោហមស្មី អពលោ វិវណ្ណោ

(ឥច្ចាយស្មា បិង្គិយោ)

នេត្តា ន សុទ្ធា សវតិ ន ជាសុ

មាហាម្ឫនសុ្ជ មោមុហោ អន្ធភាយ

អាចិក្ខ ធម្មំ យមហំ វិជញ្ញ

ជាតិជ្ជរាយ ឥធ វិប្ផហាមំ ។

[៨០] ជិណ្ណោហមស្មី អពលោ វិវណ្ណោតិ ជិណ្ណោ រុឡ្ហ[1] មហល្លកោ អទ្ធគតោ វយោអនុប្ប-ត្តោ វីសវស្ស្ឫសតិកោ ជាតិយា ។ អពលោតិ ទុព្ព-លោ អប្ផពលោ អប្ផថាមោ ។ វិវណ្ណោតិ វីតវណ្ណោ វិគតវណ្ណោ យា សា បុរិមា សុភា វណ្ណនិភា សា អន្ត្ឫហិតា អាធីនភោ ចាតុភ្ជតោតិ ជិណ្ណោហមស្មី អពលោ វិវណ្ណោ ។ ឥច្ចាយស្មា បិង្គិយោតិ ឥច្ចាតិ បទសន្ធិ ។ អាយស្មាតិ បិយវចនំ ។

---

1 ម. វីតវណ្ណោតិ ជិណ្ណោហមស្មីតិ ជិណ្ណោ រុឡ្ហ ។

បិङ្គិយមាណវកបញ្ហានិទ្ទេស

[៧៩] (បិङ្គិយៈមានអាយុ ក្រាបទូលដូច្នេះថា) ខ្ញុំព្រះអង្គ ជាមនុស្សគ្រាំគ្រា មានកម្លាំងខ្សោយ ប្រាសចាកសម្ផុរ ទាំងភ្នែកក៏មិនស្អាត ការស្តាប់[1] ក៏មិនស្រួល សូមកុំឲ្យខ្ញុំ ព្រះអង្គជាបុគ្គលវង្វេង ខ្ជិចក្នុងចន្ទោះឡើយ ខ្ញុំព្រះអង្គ គប្បីដឹងធម៌ណា ដែលជាគ្រឿងលះបង់ជាតិនិងជរា ក្នុងទីនេះ សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះឲ្យទាន ។

[៨០] *ពាក្យថា ខ្ញុំព្រះអង្គជាមនុស្សគ្រាំគ្រា មានកម្លាំងខ្សោយ ប្រាសចាកសម្ផុរ គឺជាមនុស្សគ្រាំគ្រា ចម្រើនហើយ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានវ័យដល់ហើយតាមលំដាប់ មានអាយុ ១២០ ឆ្នាំ អំពីកំណើត ។ ពាក្យថា មានកម្លាំងខ្សោយ គឺមានកម្លាំងថយ មានកម្លាំងកាយតិច មានកម្លាំងចិត្តតិច ។ ពាក្យថា ប្រាសចាកសម្ផុរ គឺ ប្រាសចាកសម្ផុរ បាត់សម្ផុរ ពន្ធឹសម្ផុរដ៏ល្អណា មានក្នុងកាលមុន ពន្ធឹសម្ផុរដ៏ល្អនោះបាត់ទៅ ទោសក៏កើតប្រាកដ ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គជាមនុស្សគ្រាំគ្រា មានកម្លាំងខ្សោយ ប្រាសចាកសម្ផុរ ។ ពាក្យថា បិङ្គិយៈមានអាយុក្រាបទូលដូច្នេះ ត្រង់ពាក្យថា ដូច្នេះ គឺជាការតបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។*

---

1 ត្រចៀក ។

បិដ្ឋិយោតិ តស្ស ព្រាហ្មណស្ស ជាមំ ។ បេ ។ អភិលាចោតិ ឥច្ចាយស្មា បិង្គិយោ ។

[៨១] នេត្តា ន សុទ្ធា សវនំ ន ផាសូតិ នេត្តា អសុទ្ធា អវិសុទ្ធា អបរិសុទ្ធា អវោទាតា នោ តថា ចក្ខុនា រូបំ បស្សាមីតិ នេត្តា ន សុទ្ធា ។ សវនំ ន ផាសូតិ សោតំ អសុទ្ធំ អវិសុទ្ធំ អបរិសុទ្ធំ អវោទាតំ នោ តថា សោតេន សទ្ទំ សុណោមីតិ នេត្តា ន សុទ្ធា សវនំ ន ផាសុ ។

[៨២] មាហាម្បនស្សំ មោមុហោ អន្តរាយាតិ មាហំ នស្សំ បនស្សំ វិនស្សំ[១] ។ មោមុហោតិ អវិជ្ជា អវិជ្ជាគតោ អញ្ញាណី អវិភាវី ទុប្បញ្ញោ ។ អន្តរាយាតិ តុយ្ហំ ធម្មំ ទិដ្ឋឹ បដិបទំ មគ្គំ អនញ្ញាយ អជានិត្វា អវិទិតំ កត្វា អប្បដិលភិត្វា អផុសយិត្វា អសច្ឆិកត្វា អន្តរាយេវ កាលំ ករេយ្យន្តិ មាហាម្បនស្សំ មោមុហោ អន្តរាយ ។

១ ម. នស្សន្តិ មាហំ នស្សំ មាហំ វិនស្សំ មាហំ បនស្សំ ។

ពាក្យថា បិង្គិយៈ ជាឈ្មោះ ។ បេ ។ ជាពាក្យសម្រាប់ហៅព្រាហ្មណ៍នោះ ហេតុនោះ (ទើបមានពាក្យថា) បិង្គិយៈ មានអាយុក្រាបទូលដូច្នេះ ។

[៨១] ពាក្យថា ភ្នែកមិនស្អាត ការស្តាប់មិនស្រួល គឺភ្នែកទាំងពីរ មិនស្អាត មិនម៉ត់ចត់ មិនបរិសុទ្ធ មិនផូរផង់ គឺខ្ញុំព្រះអង្គ មិនឃើញរូបដោយភ្នែក ដោយប្រការដូច្នោះ ហេតុនោះ (លោកពោលថា) ភ្នែកមិនស្អាត ។ ពាក្យថា ការស្តាប់មិនស្រួល គឺត្រចៀកមិនស្អាត មិនម៉ត់ចត់ មិនបរិសុទ្ធ មិនផូរផង់ គឺខ្ញុំព្រះអង្គមិនឮសំឡេងដោយត្រចៀក ដោយប្រការដូច្នោះ ហេតុនោះ (លោកពោលថា) ភ្នែកមិនស្អាត ការស្តាប់មិនស្រួល ។

[៨២] ពាក្យថា សូមកុំឲ្យខ្ញុំព្រះអង្គជាបុគ្គលវង្វេង ខ្ជិចក្នុងចន្ទោះឡើយ គឺសូមកុំឲ្យខ្ញុំព្រះអង្គលាញ ខ្ជិច វិនាសឡើយ ។ ពាក្យថា ជាបុគ្គលវង្វេង គឺជាបុគ្គលមិនយល់ ដល់នូវសេចក្តីលូងខ្ជៅ មិនដឹង មិនវាងវៃ ឥតប្រាជ្ញា ។ ពាក្យថា ក្នុងចន្ទោះ គឺខ្ញុំព្រះអង្គមិនដឹង មិនធ្វើឲ្យជាក់ច្បាស់ មិនធ្វើឲ្យប្រាកដ មិនបានចំពោះ មិនពាល់ត្រូវ មិនធ្វើឲ្យជាក់ច្បាស់ នូវធម៌ ទិដ្ឋិ បដិបទា មគ្គ របស់ព្រះអង្គ ហើយធ្វើមរណកាល ក្នុងចន្ទោះ ហេតុនោះ (លោកពោលថា) សូមកុំឲ្យខ្ញុំព្រះអង្គជាបុគ្គលវង្វេង ខ្ជិចក្នុងចន្ទោះឡើយ ។

បិដ្ឋិយមាណវកប្បញ្ហានិទ្ទេសោ

[៨៣] អាចិក្ខ ធម្មំ យមហំ វិជញ្ញន្តិ អាចិក្ខ ធម្មន្តិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសាន-កល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិ-សុទ្ធំ ព្រហ្មចរិយំ ចត្តារោ សតិប្បដ្ឋានេ ចត្តារោ សម្មប្បធានេ ចត្តារោ ឥទ្ធិបាទេ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គេ អរិយំ អដ្ឋង្គិកំ មគ្គំ និព្វានញ្ច និព្វានគាមិនិញ្ច បដិបទំ អាចិក្ខ ទេសេ-ហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តា-នីករោហិ បកាសេហីតិ អាចិក្ខ ធម្មំ ។ យមហំ វិជញ្ញន្តិ យមហំ ជានេយ្យំ វិជានេយ្យំ បដិវិជានេយ្យំ បដិវិជ្ឈេយ្យំ អធិគច្ឆេយ្យំ ផុសេយ្យំ សច្ឆិករេយ្យន្តិ អាចិក្ខ ធម្មំ យមហំ វិជញ្ញំ ។

[៨៤] ជាតិជរាយ ឥធ វិប្បហានន្តិ ឥធេវ ជាតិ-ជរាមរណស្ស បហានំ វូបសមោ បដិនិស្សគ្គោ បដិប្បស្សទ្ធិ អមតំ និព្វានន្តិ ជាតិជរាយ ឥធ វិប្ប-ហានំ ។ តេនាហ សោ ព្រាហ្មណោ

[៨៣] អធិប្បាយពាក្យថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ត្រង់ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ គឺសូមព្រះអង្គប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើក រៃកញ្ជែក ធ្វើឲ្យរាក់ប្រកាសនូវព្រហ្មចរិយៈ មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ដ៏ពេញ បរិបូណ៌ បរិសុទ្ធទាំងអស់ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ និព្វាន និងនិព្វានគামិនីបដិបទា ហេតុនោះ (លោកពោលថា) សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ។ ពាក្យថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា គឺខ្ញុំព្រះអង្គគប្បីដឹង យល់ច្បាស់ ដឹងច្បាស់លាស់ ចាក់ធ្ងុះចំពោះ បានលុះ ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់ នូវធម៌ណា ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ។

[៨៤] ពាក្យថា ជាគ្រឿងលះបង់ជាតិនិងជរា ក្នុងទីនេះ គឺការលះបង់ រម្ងាប់បង់ រលាស់ចោល រម្ងាប់នូវជាតិជរា និងមរណៈ ក្នុងទីនេះឯង គឺអមតនិព្វាន ហេតុនោះ (លោកពោលថា) ជាគ្រឿងលះបង់ជាតិនិងជរា ក្នុងទីនេះ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

ជិណ្ណោហមស្មឺ អពលោ វិវណ្ណោ

(ឥច្ចាយស្មា បិង្គិយោ)

នេត្តា ន សុទ្ធា សវនំ ន ជាសុ

មាហាម្ឆនស្ស៑ មោមុហោ អន្ធភាយ

អាចិក្ខ ធម្មំ យមហំ វិជញ្ញ

ជាតិជ្ជរ ឥធ វិប្ផហានន្តិ ។

[៨៥] ជិស្ណាន រូបេសុ វិហញ្ញមានេ

(បិង្គិយាតិ ភគវា)

រុប្ផន្តិ រូបេសុ ជនា បមត្តា

តស្មា តុវំ បិង្គិយ អប្ផមត្តោ

ជហាស្ឆ រូបំ អបុនព្ភវាយ ។

[៨៦] ជិស្ណាន រូបេសុ វិហញ្ញមានេតិ រូបេសូតិ ចត្តារោ ច មហាភូតា ចតុន្ន្ចំ មហាភូតានំ ឧចាជាយរូបំ ។ សត្តា រូបហេតុ រូបប្ផច្ចយា រូប-ការណា ហញ្ញន្តិ វិហញ្ញន្តិ ឧបហញ្ញន្តិ ឧបឃា-តយន្តិ រូបេ សតិ រ៑ាធកម្មការណា ការេន្តិ

(បិङ្គិយៈមានអាយុក្រាបទូលដូច្នេះថា) ខ្ញុំព្រះអង្គជាមនុស្ស គ្រាំគ្រា មានកម្លាំងខ្សោយ ប្រាសចាកសម្ផ្ស ទាំងភ្នែក ក៏មិនស្អាត ការស្តាប់ ក៏មិនស្រួល សូមកុំឲ្យខ្ញុំព្រះអង្គជាបុគ្គលវង្វេង ខ្ចកក្នុងចន្ទោះឡើយ ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា ដែលជាគ្រឿងលះបង់ជាតិនិងជរា ក្នុងទីនេះ សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះឲ្យទាន ។

[៨៥] (ព្រះមានព្រះភាគត្រាស់ថា ម្នាលបិङ្គិយៈ) ពួកជនដែលប្រហែស ឃើញសត្វទាំងឡាយកំពុងលំបាក ព្រោះរូប ក៏លំបាកព្រោះរូប ម្នាលបិङ្គិយៈ ហេតុនោះ អ្នកចូរជាបុគ្គលមិនប្រហែស លះបង់រូបទៅ ដើម្បីការមិនកើតទៀត ។

[៨៦] *អធិប្បាយពាក្យថា ឃើញសត្វទាំងឡាយកំពុងលំបាកព្រោះរូប ត្រង់ពាក្យថា រូប បានដល់មហាភូតរូបបួនផង រូបដែលអាស្រ័យនឹងមហាភូតរូបបួនផង ។ សត្វទាំងឡាយលំបាក ឈឺចាប់ ក្តៅក្រហាយ ចង្អៀតចង្អល់ ព្រោះហេតុនៃរូប ព្រោះរូបជាបច្ច័យ ព្រោះដំណើរនៃរូប កាលបើរូបមាន សត្វទាំងឡាយ ត្រូវគេធ្វើនូវកម្មការណ៍ផ្សេង ។*

កសាហិបិ តាឡេន្តិ វេត្តេហិបិ តាឡេន្តិ អឌ្ឍឧណ្ហាកេ-
ហិបិ តាឡេន្តិ ហត្ថម្បិ ធិនន្តិ ចាឧម្បិ ធិនន្តិ ហត្ថ-
ចាឧម្បិ ធិនន្តិ កណ្ណម្បិ ធិនន្តិ ជាសម្បិ ធិនន្តិ
កណ្ណជាសម្បិ ធិនន្តិ ពិលង្គថាលិកម្បិ កហេន្តិ
សង្ខមុណ្ឌកម្បិ កហេន្តិ រាហុមុខម្បិ កហេន្តិ ជោតិ-
មាលិកម្បិ កហេន្តិ ហត្ថប្បជ្ជោតិកម្បិ កហេន្តិ
ឱរកវត្តិកម្បិ កហេន្តិ ចិរវាសិកម្បិ កហេន្តិ
ឯណេយ្យកម្បិ កហេន្តិ ពលិសមំសិកម្បិ កហេន្តិ

គឺវាយដោយរំពាត់ខ្លះ វាយដោយផ្តៅខ្លះ វាយដោយកំណាត់ឈើខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ដៃនិងជើងខ្លះ កាត់ត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ត្រចៀកនិងច្រមុះខ្លះ ធ្វើពិលង្គថាលិកកម្ម[១] ខ្លះ ធ្វើសង្ខមុណ្ឌក-កម្ម[២]ខ្លះ ធ្វើរាហុមុខកម្ម[៣]ខ្លះ ធ្វើជោតិមាលិកកម្ម[៤]ខ្លះ ធ្វើហត្ថប្ប-ជ្ជោតិកកម្ម[៥]ខ្លះ ធ្វើឯរកវត្តិកកម្ម[៦]ខ្លះ ធ្វើចិរកវាសិកកម្ម[៧]ខ្លះ ធ្វើ ឯណេយ្យកកម្ម[៨]ខ្លះ ធ្វើពលិសមំសិកកម្ម[៩]ខ្លះ

---

១ ចោះលលាដ៍ក្បាលដាក់ដែកក្តៅឲ្យខ្ជូរពុះខ្ជោលឡើង ។ ២ ពន្លះស្បែកតាំងពីបបូរមាត់លើ, គុម្ពត្រចៀកសងខាង និងកញ្ចឹងកហើយខាត់ឆ្នឹងឲ្យរលីងដូចសម្ផ្ទរស័ង្ខ ។ ៣ យកកង្វារ បើកមាត់ ហើយអុជភ្លើងក្នុងមាត់ ឬដាប់មាត់ឲ្យធ្លាយដល់គុម្ពត្រចៀកទាំងពីរ ធ្វើឲ្យ ឈាមហូរចេញតាមមាត់ ។ ៤ រុំខ្លួនទាំងអស់ដោយសំពត់ប្រេង ហើយដុត ។ ៥ រុំដៃទាំងពីរ ដោយសំពត់ប្រេងហើយដុត ។ ៦ ចៀរស្បែកជាចម្រៀកតាំងពីកដល់កជើងហើយដឹកឲ្យដើរជាន់ លើស្បែកខ្លួន ។ ៧ ចៀរស្បែកពីក ទុកត្រឹមចង្កេះ ហើយចៀរពីចង្កេះដល់កជើង ។ ៨ ស៊ីក ក្រវិលដែកត្រង់កជើង និងជង្គង់ទាំងពីរ ហើយដោតនឹងបង្គោលដែកឲ្យអ្នកទោសឈរ ដុត ភ្លើងជុំវិញ ។ ៩ យកកង្វារដែក មានមុខសងខាង ខ្វារយកស្បែកសាច់សរសៃចេញ ។ តិស្សមេត្តេយ្យសុត្តនិទ្ទេសវណ្ណនា ។

កហាបណិកម្បិ ករោន្តិ ខារាបតច្ឆិកម្បិ ករោន្តិ បលិឃបរិវត្តិកម្បិ ករោន្តិ បលាលបីឋកម្បិ ករោន្តិ តត្តេនបិ តេលេន ឱសិញ្ចន្តិ សុនខេហិបិ ខាទាបេន្តិ ជីវន្តម្បិ សូលេ ឧត្តាសេន្តិ អសិនា សីសំ ឆិន្ទន្តិ ។ ឯវំ សត្តា រូបហេតុ រូបប្បច្ចយា រូបការណា ហញ្ញន្តិ វិហញ្ញន្តិ ឧបហញ្ញន្តិ ឧបឃាតយន្តិ ។ ឯវំ ហញ្ញមានេ វិហញ្ញមានេ ទិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ទិស្វាន រូបេសុ វិហញ្ញមានេ ។ បិង្គិយាតិ ភគវាតិ បិង្គិយាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ យទិទំ ភគវាតិ បិង្គិយាតិ ភគវា ។

ធ្វើកហាបណិកកម្ម[១]ខ្លះ ធ្វើខ្ទាវាបតច្ឆិកកម្ម[២]ខ្លះ ធ្វើបលិឃបរិវត្តិកកម្ម[៣]ខ្លះ ធ្វើបលាលបីឋកកម្ម[៤]ខ្លះ ស្រោចដោយប្រេងដែលក្តៅខ្លះ ឲ្យ ផ្ដែខាំខ្លះ ឲ្យដេកផ្ទារលើឈើអណ្ដាតទាំងរស់ខ្លះ កាត់ក្បាលដោយដាវ ខ្លះ ។ សត្វទាំងឡាយលំបាក ឈឺចាប់ ក្តៅក្រហាយ ចង្អៀតចង្អល់ ព្រោះរូបជាហេតុ ព្រោះរូបជាបច្ច័យ ព្រោះរូបជាដំណើរ ដោយប្រការ យ៉ាងនេះ ។ ឃើញ ចូប ពិចារណា ត្រិះរិះ សម្ដែង ធ្វើឲ្យប្រាកដ នូវសត្វទាំងឡាយ កំពុងលំបាក ក្តៅក្រហាយ យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញសត្វទាំងឡាយ កំពុងលំបាកព្រោះរូប ។ ពាក្យ ថា ម្នាលបិङ្គិយៈ ក្នុងបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលបិङ្គិយៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះចំឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះជាពាក្យពោលដោយគោរព ។ បេ ។ បញ្ញត្តិថា ព្រះមានព្រះភាគ នេះ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគ ត្រាស់ថា ម្នាលបិङ្គិយៈ ។

---

១ អារសាច់ប៉ុន ។ កហាបណៈ ។ ២ យកអាវុធប្រហារសរីរៈ ហើយយកទឹកក្រុតលាប កិនយកស្បែកសាច់សរសៃចេញ ឲ្យនៅសល់តែរាងឆ្អឹង ។ ៣ ឲ្យដេកផ្ដៀងហើយដោតដែក ស្រួចត្រង់រន្ធត្រចៀក កប់ទៅនឹងផែនដី ហើយចាប់ជើងបង្ហិល ។ ៤ ដំឆ្អឹងឲ្យខ្ទេចទក់ តែមិនឲ្យដាច់ស្បែកក្រៅហើយមូរសាច់ជាដុំរ៉ុនឹងសក់ ។ តិស្សមេត្តេយ្យសុត្តនិទ្ទេសវណ្ណនា ។

[៨៧] រុប្បន្តិ រូបេសុ ជនា បមត្តាតិ រុប្បន្តីតិ រុប្បន្តិ កុប្បន្តិ បីឌ្យន្តិ ឃដ្ដយន្តិ ព្យត្ថិតា ឧោមនស្សិតា ហោន្តិ ចក្ខុវោកេន រុប្បន្តិ កុប្បន្តិ បីឌ្យ-យន្តិ ឃដ្ដយន្តិ ព្យត្ថិតា ឧោមនស្សិតា ហោន្តិ សោ-តវោកេន ។ បេ ។ ឆ៉ំសមកសវាតាតបសិរីសបសម្ផ-ស្សេហិ រុប្បន្តិ កុប្បន្តិ បីឌ្យន្តិ ឃដ្ដយន្តិ ព្យត្ថិតា ឧោមនស្សិតា ហោន្តីតិ រុប្បន្តិ រូបេសុ ។ អថវា ចក្ខុស្មឹ ហីយមានេ ហាយមានេ បរិហាយមានេ វេ-មានេ វិកច្ចមានេ អន្តរជាយមានេ រុប្បន្តិ ។ បេ ។ ឧោមនស្សិតា ហោន្តិ សោតស្មឹ ឃានស្មឹ ជិវ្ហាយ កាយស្មឹ រូបស្មឹ សទ្ទស្មឹ គន្ធស្មឹ រសស្មឹ ផោដ្ឋព្ពស្មឹ កុលស្មឹ គណស្មឹ អាវាសស្មឹ លាភស្មឹ យសស្មឹ ប-សំសាយ សុខស្មឹ ចីវរស្មឹ បិណ្ឌបាតស្មឹ សេនាសន-ស្មឹ គិលានប្បច្ចយភេសជ្ជបរិក្ខារស្មឹ ហីយមានេ ហា-យមានេ បរិហាយមានេ វេមានេ វិកច្ចមានេ អន្តរជា-យមានេ រុប្បន្តិ កុប្បន្តិ បីឌ្យន្តិ ឃដ្ដយន្តិ ព្យត្ថិតា ឧោមនស្សិតា ហោន្តីតិ ឯវម្ចិ រុប្បន្តិ រូបេសុ ។

បិដ្ឋិយមាណវកប្បញ្ហានិទ្ទេស

[៨៧] *អធិប្បាយពាក្យថា ពួកជនដែលប្រហែស ក៏លំបាកព្រោះរូប ត្រង់ពាក្យថា លំបាក គឺលំបាក កម្រើក ហៀតហៀន ខ្ជាំងខ្ជប់ ខ្ជាច ដល់នូវទោមនស្ស ដោយរោគក្នុងភ្នែក លំបាក កម្រើក ហៀតហៀន ខ្ជាំងខ្ជប់ ខ្ជាច ដល់នូវទោមនស្ស ដោយរោគក្នុងត្រចៀក ។ បេ ។ លំបាក កម្រើក ហៀតហៀន ខ្ជាំងខ្ជប់ ខ្ជាច ដល់នូវទោមនស្ស ដោយ សម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃ សត្វលូន ហេតុនោះ (ទ្រង់ត្រាស់ថា) ក៏លំបាកព្រោះរូប ។ មួយទៀត សត្វទាំងឡាយ កាលបើភ្នែក សាបសូន្យ បាត់បង់ រលប់រលាយ វិនាស ទៅប្រាស អន្តរធាន ក៏លំបាក ។ បេ ។ ដល់នូវទោមនស្ស សត្វទាំងឡាយ កាលត្រចៀក ច្រមុះ អណ្ដាត កាយ រូប សំឡេង ក្លិន រស ផ្សព្វ ត្រកូល ពួក អាវាស លាភ យស សេចក្ដីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ សាបសូន្យ បាត់បង់ រលប់រលាយ វិនាស ទៅប្រាស អន្តរធាន លំបាក កម្រើក ត្រូវសេចក្ដីវិនាសហៀតហៀន ខ្ជាំងខ្ជប់ ខ្ជាច ដល់នូវទោមនស្ស ហេតុ នោះ (ទ្រង់ត្រាស់ថា) ក៏លំបាកព្រោះរូប យ៉ាងនេះក៏បាន ។*

ជាតិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ច ។ បមត្តាតិ បមាទោ វត្តព្វោ កាយទុច្ចរិតេ វា វចីទុច្ចរិតេ វា មនោទុច្ចរិតេ វា បញ្ចសុ វា កាមគុណេសុ ចិត្តស្ស វោស្សគ្គោ វោស្សគ្គានុប្បទានំ កុសលានំ វា ធម្មានំ ភាវនាយ អសាតច្ចកិរិយតា អនដ្ឋិតកិរិយតា ឱលីនវុត្តិតា និក្ខិត្តច្ឆន្ទតា និក្ខិត្តធុរតា អនាសេវនា អភាវនា អពហុលីកម្មំ អនធិដ្ឋានំ អននុយោគោ បមាទោ យោ ឯវរូបោ បមាទោ បមជ្ជនា បមជ្ជិតត្តំ អយំ វុច្ចតិ បមាទោ ។ ឥមិនា បមាទេន សមន្នាគតា ជនា បមត្តាតិ វុច្ចន្តិ រូបេសុ ជនា បមត្តា ។

[៨៨] តស្មា តុវំ បិង្គិយ អប្បមត្តោតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា ឯវំ អាទីនវំ សម្បស្សមានោ រូបេសូតិ តស្មា តុវំ បិង្គិយ ។

ពាក្យថា ពួកជន បានដល់ពួកក្សត្រ ព្រាហ្មណ៍ អ្នកជំនួញ អ្នកគ្រួ គ្រហស្ថ បព្វជិត ទេវតា មនុស្ស ។ ពាក្យថា ប្រហែស គឺការប្រហែស ខ្ញុំត្រូវពោលដូចតទៅនេះ ការបណ្តោយចិត្ត ការផ្តល់កម្ទាំងដល់ការបណ្តោយចិត្តទៅ ក្នុងកាយទុច្ចរិត ក្នុងវចីទុច្ចរិត ក្នុងមនោទុច្ចរិត ឬក្នុងកាមគុណទាំង ៥ ក្តី ភាពនៃកិរិយាមិនធ្វើរឿយ ៗ ភាពនៃកិរិយាមិនតាំងនៅ ភាពនៃកិរិយាប្រព្រឹត្តធូរថយ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនសេព ការមិនចម្រើន ការមិនធ្វើឲ្យច្រើន ការមិនអធិដ្ឋាន ការមិនប្រកបរឿយ ៗ ក្នុងការចម្រើនធម៌ជាកុសលក្តី ឈ្មោះថាការប្រហែស សេចក្តីធ្វេសប្រហែស ការបណ្តែតបណ្តោយ ភាពនៃសេចក្តីក្ងេចក្ងាំង ដែលមានសភាពយ៉ាងនេះ ឯណា នេះលោកហៅថា ការប្រហែស ។ ពួកជនប្រកបដោយសេចក្តីប្រហែសនេះ ឈ្មោះថា អ្នកប្រហែស ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជនប្រហែស ក៏លំបាកព្រោះរូប ។

[៨៨] *ពាក្យថា ម្នាលបិង្គិយៈ ព្រោះហេតុនោះ អ្នកចូរជាបុគ្គលមិនប្រហែស ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះហេតុដូច្នោះ ព្រោះការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទានៈនោះ បុគ្គលកាលឃើញចាស់នូវទោស ក្នុងរូបយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលបិង្គិយៈ ហេតុនោះ អ្នក (ចូរជាបុគ្គលមិនប្រហែស) ។*

អប្បមត្តោតិ សក្កច្ចការី សាតច្ចការី ។ បេ ។ អប្បមត្តោ កុសលេសុ ធម្មេសូតិ តស្មា តុវំ បិង្គិយ អប្បមត្តោ ។

[៨៩] ជហស្សុ រូបំ អបុនព្ភវាយាតិ រូបន្តិ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ ។ ជហស្សុ រូបន្តិ រូបំ ជហស្សុ រូបំ បជហស្សុ រូបំ វិនោទេហិ រូបំ ព្យន្តីករោហិ រូបំ អនភាវង្គមេហីតិ ជហស្សុ រូបំ ។ អបុនព្ភវាយាតិ យថា តេ រូបំ ឥធេវ និរុជ្ឈេយ្យ បុន បដិសន្ធិកភវោ ន និព្វត្តេយ្យ កាមធាតុយា វា រូបធាតុយា វា អរូបធាតុយា វា កាមភវេ វា រូបភវេ វា អរូបភវេ វា សញ្ញាភវេ វា អសញ្ញាភវេ វា នេវសញ្ញានាសញ្ញាភវេ វា ឯកវោការភវេ វា ចតុវោការភវេ វា បញ្ចវោការភវេ វា បុន គតិយា វា ឧបបត្តិយា វា បដិសន្ធិយា វា សំសារេ វា វដ្ដេ វា ន ជនេយ្យ ន សញ្ជនេយ្យ ន និព្វត្តេយ្យ នាភិនិព្វត្តេយ្យ ឥធេវ និរុជ្ឈេយ្យ វូបសមេយ្យ អត្ថំ គច្ឆេយ្យ

ពាក្យថា ចូរជាបុគ្គលមិនប្រហែស គឺធ្វើដោយគោរព ធ្វើឲ្យរឿយៗ ។ បេ ។ មិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលបិङ្គិយៈ ហេតុនោះ អ្នកចូរជាបុគ្គលមិនប្រហែស ។

[៨៩] អធិប្បាយពាក្យថា ចូរលះបង់រូប ដើម្បីការមិនកើតទៀត ត្រង់ពាក្យថា រូប បានដល់មហាភូតរូប ៤ និងរូបអាស្រ័យមហាភូតរូប ៤ ។ ពាក្យថា ចូរលះបង់រូប គឺចូរលះបង់រូប ចូរចោលរូប ចូរបន្ទោបង់រូប ចូរធ្វើឲ្យវិនាសរូប ចូរឲ្យរូបវិនាស ហេតុនោះ (ទ្រង់ត្រាស់ថា) ចូរលះបង់រូប ។ ពាក្យថា ដើម្បីការមិនឲ្យកើតទៀត អធិប្បាយថា រូបរបស់អ្នកគប្បីរលត់ក្នុងភពនេះ យ៉ាងណា បដិសន្ធិភព មិនគប្បីកើតទៀត ក្នុងកាមធាតុក្តី ក្នុងរូបធាតុក្តី ក្នុងអរូបធាតុក្តី ក្នុងកាមភពក្តី ក្នុងរូបភពក្តី ក្នុងអរូបភពក្តី ក្នុងសញ្ញាភពក្តី ក្នុងអសញ្ញាភពក្តី ក្នុងនេវសញ្ញានាសញ្ញាភពក្តី ក្នុងឯកវោការភពក្តី ក្នុងចតុវោការភពក្តី ក្នុងបញ្ចវោការភពក្តី គឺ មិនគប្បីកើត មិនគប្បីបង្កើត មិនគប្បីកកើត មិនគប្បីកើតចំពោះទៀត ក្នុងគតិក្តី ក្នុងឧបបត្តិក្តី ក្នុងបដិសន្ធិក្តី ក្នុងសំសារក្តី ក្នុងវដ្ដៈក្តី គឺថា គប្បីរលត់ សូប់រម្ងាប់ ដល់នូវការតាំងនៅមិនបាន

បដិប្បស្សម្ភេយ្យាតិ ជហាស្សុ រូបំ អបុនព្ភវាយ ។ តេនាហ ភគវា

និស្វាន រូបេសុ វិហញ្ញមានេ (បិង្គិយាតិ ភគវា)
រុប្បន្តិ រូបេសុ ជនា បមត្តា
តស្មា តុវំ បិង្គិយ អប្បមត្តោ
ជហាស្សុ រូបំ អបុនព្ភវាយាតិ ។

[៩០] ទិសា ចតស្សោ វិទិសា ចតស្សោ
ឧទ្ធំ អធោ ទស ទិសា ឥមាយោ
ន តុយ្ហំ អទិដ្ឋំ អសុតាមុតំ វា
អថោ អវិញ្ញាតំ កិញ្ចិ នមត្ថិ លោកេ
អាចិក្ខ ធម្មំ យមហំ វិជញ្ញំ
ជាតិជរាយ ឥធ វិប្បហានំ ។

[៩១] ទិសា ចតស្សោ វិទិសា ចតស្សោ ឧទ្ធំ អធោ ទស ទិសា ឥមាយោតិ ទស ទិសា ន តុយ្ហំ អទិដ្ឋំ អសុតំ អមុតំ អវិញ្ញាតំ កិញ្ចិ អត្តត្ថោ វា បរត្ថោ វា ឧភយត្ថោ វា

រម្ងាប់ចំពោះ ក្នុងកពនេះឯង ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ចូរលះបង់រូប ដើម្បីការមិនកើតទៀត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> *(ព្រះមានព្រះភាគត្រាស់ថា ម្នាលបិङ្គិយ:) ពួកជនដែលប្រហែស ឃើញសត្វទាំងឡាយ កំពុងលំបាកព្រោះរូប ក៏លំបាកព្រោះរូប ម្នាលបិङ្គិយ: ហេតុនោះ អ្នកចូរជាបុគ្គលមិនប្រហែស លះបង់រូបទៅ ដើម្បីការមិនកើតទៀត ។*

[៩០] *ទិសទាំង ១០ នេះ គឺទិសធំ ៤ ទិសតូច ៤ ទិសខាងលើ ១ ទិសខាងក្រោម ១ របស់អ្វីបន្ទិចបន្ទួច ឈ្មោះថា ព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់ មិនមានទេមួយទៀត របស់អ្វីបន្ទិចបន្ទួច ក្នុងលោក ឈ្មោះថាព្រះអង្គមិនធ្លាប់ជ្រាប មិនមានទេ ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា ដែលជាគ្រឿងលះបង់ជាតិនិងជរា ក្នុងទីនេះ សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះឲ្យទាន ។*

[៩១] *ពាក្យថា ទិសទាំង ១០ នេះ គឺទិសធំ ៤ ទិសតូច ៤ ទិសខាងលើ ១ ទិសខាងក្រោម ១ សេចក្ដីថា ក្នុងទិសទាំង ១០ របស់អ្វីបន្ទិចបន្ទួចដែលជាប្រយោជន៍ខ្លួនក្ដី ប្រយោជន៍អ្នកដទៃក្ដី ប្រយោជន៍ទាំងពីរក្ដី*

ទិដ្ឋធម្មិកោ វា អត្ថោ សម្បរាយិកោ វា អត្ថោ ។ បេ ។ បរមត្ថោ វា នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តីតិ ន តុយ្ហំ អទិដ្ឋំ អសុតាមុតំ វា អថោ អវិញ្ញាតំ កិញ្ចិ នមត្ថិ លោកេ ។

[៩២] អាចិក្ខ ធម្មំ យមហំ វិជញ្ញន្តិ អាចិក្ខ ធម្មន្តិ អាទិកល្យាណំ ។ បេ ។ និព្វានគាមិនិញ្ច បដិបទំ អាចិក្ខ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ អាចិក្ខ ធម្មំ ។ យមហំ វិជញ្ញន្តិ យមហំ ជានេយ្យំ វិជានេយ្យំ បដិវិជានេយ្យំ បដិវិជ្ឈេយ្យំ អធិគច្ឆេយ្យំ ផុសេយ្យំ សច្ឆិករេយ្យន្តិ អាចិក្ខ ធម្មំ យមហំ វិជញ្ញំ ។

[៩៣] ជាតិជរាយ ឥធ វិប្បហានន្តិ ឥធេវ

ប្រយោជន៍ប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ប្រព្រឹត្តទៅក្នុងលោកខាងមុខក្តី ។ បេ ។ ប្រយោជន៍ដ៏ឧត្តមក្តី ឈ្មោះថាព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់ មិនធ្លាប់ជ្រាប មិនមាន គ្មាន ឥតអង្គឺមាន គឺថា មិនទាន់បានទេ ហេតុនោះ (លោកពោលថា) របស់អ្វីបន្ទិចបន្ទួច ឈ្មោះថាព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់ មិនមានទេ មួយទៀត របស់អ្វីបន្ទិចបន្ទួច ក្នុងលោក ឈ្មោះថាព្រះអង្គមិនធ្លាប់ជ្រាប មិនមានទេ ។

[៩២] ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់ធម៌ ក្នុងបទថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ គឺសូមព្រះអង្គប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើក រៃកញ្ជែក ធ្វើឲ្យរាក់ ប្រកាស នូវធម៌ ឲ្យមានពីរោះបទដើម ។ បេ ។ និងនិញ្ជានគាមិនីបដិបទា ហេតុនោះ (លោកពោលថា) សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ។ ពាក្យថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា គឺខ្ញុំព្រះអង្គគប្បីដឹង ដឹងច្បាស់ ដឹងជាក់ ចាក់ធ្លុះ ត្រាស់ដឹង ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ។

[៩៣] ពាក្យថា ជាគ្រឿងលះបង់ជាតិនិងជរា ក្នុងទីនេះ

ជាតិជរាមរណស្ស បហានំ វូបសមោ បដិនិស្សគ្គោ បដិប្បស្សទ្ធិ អមតំ និព្វានន្តិ ជាតិជ្ជរាយ ឥធ វិប្បហានំ ។ តេនាហ សោ ព្រាហ្មណោ

ទិសា ចតស្សោ វិទិសា ចតស្សោ

ឧទ្ធំ អធោ ទស ទិសា ឥមាយោ

ន តុយ្ហំ អទិដ្ឋំ អសុតាមុតំ វា

អថោ អវិញ្ញាតំ កិញ្ចិ នមត្ថិ លោកេ

អាចិក្ខ ធម្មំ យមហំ វិជញ្ញំ

ជាតិជ្ជរាយ ឥធ វិប្បហានន្តិ ។

[៩៤] តណ្ហាធិបន្នេ មនុជេ បេក្ខមានោ

(បិង្គិយាតិ ភគវា)

សន្តាបជាតេ ជរសា បរេតេ

តស្មា តុវំ បិង្គិយ អប្បមត្តោ

ជហស្សុ តណ្ហំ អបុនព្ភវាយ ។

[៩៥] តណ្ហាធិបន្នេ មនុជេ បេក្ខមានោតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។

គឺការលះបង់ ការរម្ងាប់បង់ ការរលាស់ចោល ការរម្ងាប់នូវជាតិជរានិង
មរណៈ គឺអមតនិព្វាន ក្នុងទីនេះឯង ហេតុនោះ (លោកពោលថា) ជា
គ្រឿងលះបង់ជាតិនិងជរាក្នុងទីនេះ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

ទិសទាំង ១០ នេះ គឺទិសធំ ៤ ទិសតូច ៤ ទិសខាងលើ ១ ទិសខាងក្រោម ១ របស់អ្វីបន្ទិចបន្ទូច ឈ្មោះថាព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់ មិនមានទេ មួយទៀត របស់អ្វីបន្ទិចបន្ទូច ក្នុងលោក ឈ្មោះថាព្រះអង្គមិនធ្លាប់ជ្រាប មិនមានទេ ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា ដែលជាគ្រឿងលះបង់ជាតិនិងជរាក្នុងទីនេះ សូមព្រះអង្គ ត្រាស់ប្រាប់ធម៌នោះឲ្យទាន ។

[៩៦] (ព្រះមានព្រះភាគត្រាស់ថា ម្នាលបិङ្គិយៈ) អ្នកកាលបើសម្ងឹងមើល នូវពួកមនុស្សដែលត្រូវតណ្ហាគ្របសង្កត់ ត្រូវសេចក្ដីក្ដៅក្រហាយកើតមាន ត្រូវជរាបៀតបៀន ម្នាលបិङ្គិយៈ អ្នកនឹងទៅជាបុគ្គលមិនប្រហែស ព្រោះការឃើញនោះ ហេតុនេះ អ្នកចូរលះបង់តណ្ហា ដើម្បីការមិនកើតទៀត ។

[៩៧] ពាក្យថា អ្នកកាលបើសម្ងឹងមើល នូវពួកមនុស្ស ដែលត្រូវតណ្ហាគ្របសង្កត់ ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។

តណ្ហាជិបន្នេតិ តណ្ហាអជិបន្នេ តណ្ហាឧកតេ តណ្ហា-ឧសដេ តណ្ហាយាបន្នេ អភិភូតេ បរិយាទិន្នចិត្តេ ។ មនុជេតិ សត្តាធិវចនំ ។ បេក្ខមានោតិ បេក្ខមានោ ឧក្ខមានោ ឱលោកយមានោ និជ្ឌាយមានោ ឧប-បរិក្ខមានោតិ តណ្ហាជិបន្នេ មនុជេ បេក្ខមានោ ។ បិដ្ឋិយាតិ ភគវា ព្រាហ្មណំ ជានមេន អាលបតិ ។

[៩៦] សព្ពាបជាតេ ជរសា បរេតេតិ សព្ពាបជា-តេតិ ជាតិយា សព្ពាបជាតេ ជរាយ សព្ពាបជាតេ ព្យាធិនា សព្ពាបជាតេ មរណេន សព្ពាបជាតេ សោកបរិទេវទុក្ខទោមនស្សុបាយាសេហិ សព្ពាបជា-តេ ទេវយិតេន ទុក្ខេន សព្ពាបជាតេ ។ បេ ។ ទិដ្ឋិព្យសនេន ទុក្ខេន សព្ពាបជាតេ ឦតិជាតេ ឧបទ្ទវជាតេ ឧបសគ្គជាតេតិ សព្ពាបជាតេ ។

ពាក្យថា ដែលត្រូវតណ្ហាគ្របសង្កត់ គឺ តណ្ហាគ្របសង្កត់ ទៅតាមតណ្ហា ទាសទៅតាមតណ្ហា ជ្រមុជចុះក្នុងតណ្ហា ត្រូវតណ្ហាគ្របសង្កត់ មានចិត្តគឹតណ្ហារួបរឹត ។ ពាក្យថា ពួកមនុស្ស គឺជាឈ្មោះនៃសត្ត្ব ។ ពាក្យថា កាលបើសម្ធឹងមើល គឺ កាលបើសម្ធឹងមើល ក្រឡេកមើល រមិលមើល ពិនិត្យមើល ពិចារណាមើល (ហេតុនោះ) ទ្រង់ត្រាស់ថា អ្នកកាលបើសម្ធឹងមើលពួកមនុស្ស ដែលត្រូវតណ្ហាគ្របសង្កត់ ។ ពាក្យថា ម្នាលបិङ្គិយ: គឺ ព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍ចំឈ្មោះ ។

[៩៦] ពាក្យថា ត្រូវសេចក្តីក្តៅក្រហាយកើតមាន ត្រូវជរាបៀតបៀន ត្រង់ពាក្យថា ត្រូវសេចក្តីក្តៅក្រហាយកើតមាន គឺ កើតសេចក្តីក្តៅក្រហាយព្រោះជាតិ កើតសេចក្តីក្តៅក្រហាយព្រោះជរា កើតសេចក្តីក្តៅក្រហាយព្រោះព្យាធិ កើតសេចក្តីក្តៅក្រហាយព្រោះមរណ: កើតសេចក្តីក្តៅក្រហាយព្រោះសោក ខ្សឹកខ្ជូល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ កើតសេចក្តីក្តៅក្រហាយ ព្រោះទុក្ខប្រព្រឹត្តទៅក្នុងនរក ។ បេ ។ កើតសេចក្តីក្តៅក្រហាយ កើតមានចង្រៃ កើតមានឧបទ្រព កើតមានឧបស័គ្គ អំពីទុក្ខ ព្រោះវិនាសទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) ត្រូវសេចក្តីក្តៅក្រហាយកើតមាន ។

ជរសា បរេតេតិ ជរាយ ផុដ្ឋេ បរេតេ សមោហិតេ ជាតិយានុគតេ ជរាយ អនុសដេ ព្យាធិនា អភិភូតេ មរណេន អព្ភាហតេ អតាណេ អលេណេ អសរណេ អសរណីភូតេតិ សត្តោបជាតេ ជរសា បរេតេ ។

[៩៧] តស្មា តុវំ បិង្គិយ អប្បមត្តោតិ តស្មាតិ តស្មា តំការណា តហេតុ តប្បច្ចយា តំនិទានា ឯវំ អាទីនវំ សម្បស្សមានោ តណ្ហាយាតិ តស្មា តុវំ បិង្គិយ ។ អប្បមត្តោតិ សក្កច្ចការី សាតច្ចការី ។ បេ ។ អប្បមត្តោ កុសលេសុ ធម្មេសូតិ តស្មា តុវំ បិង្គិយ អប្បមត្តោ ។

[៩៨] ជហស្សុ តណ្ហំ អបុនព្ភវាយាតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្ព-តណ្ហា ធម្មតណ្ហា ។ ជហស្សុ តណ្ហន្តិ តណ្ហំ ជហ-ស្សុ តណ្ហំ បជហស្សុ តណ្ហំ វិនោទេហិ តណ្ហំ ព្យន្តី-ករោហិ តណ្ហំ អនភាវង្គមេហីតិ ជហស្សុ តណ្ហំ ។

ពាក្យថា ត្រូវជរាបៀតបៀន គឺត្រូវជរាប៉ះពាល់ បៀតបៀន រួបរឹត ប្រព្រឹត្ត ទៅតាមជាតិ ទាសទៅដោយជរា ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈកម្ចាត់ មិនមានទីពំនាក់ មិនមានទីជ្រក មិនមានទីពឹង មិនមានទីរំពឹង ហេតុនោះ (ទ្រង់ត្រាស់ថា) ត្រូវសេចក្ដីក្តៅក្រហាយកើតមាន ត្រូវជរាបៀតបៀន ។

[៩៧] ពាក្យថា ម្នាលបិङ្គិយៈ អ្នកនឹងទៅជាបុគ្គលមិនប្រហែស ព្រោះការឃើញនោះ ត្រង់ពាក្យថា ព្រោះការឃើញនោះ គឺព្រោះ ហេតុនោះ ព្រោះដំណើរនោះ ព្រោះហេតុដូច្នោះ ព្រោះបច្ច័យនោះ ព្រោះ និទាននោះ បុគ្គលកាលបើឃើញទោសនៃតណ្ហាយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលបិङ្គិយៈ អ្នក...ព្រោះការឃើញនោះ ។ ពាក្យថា នឹងជាបុគ្គលមិនប្រហែស គឺនឹងជាបុគ្គលធ្វើដោយគោរព ធ្វើរឿយៗ ។ បេ ។ មិនប្រហែសក្នុងកុសលធម៌ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលបិङ្គិយៈ អ្នកនឹងជាបុគ្គលមិនប្រហែស ព្រោះការឃើញនោះ ។

[៩៨] ពាក្យថា ចូរលះបង់តណ្ហា ដើម្បីការមិនកើតទៀត ត្រង់ ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ចូរលះបង់តណ្ហា គឺចូរលះបង់ តណ្ហា បន្សាត់បង់តណ្ហា បន្ទោបង់តណ្ហា ធ្វើឲ្យវិនាសតណ្ហា ញ៉ាំងតណ្ហា ឲ្យដល់នូវការមិនកើតមាន ហេតុនោះ (ទ្រង់ត្រាស់ថា) ចូរលះបង់តណ្ហា ។

អបុនព្ភវាយាតិ យថា តេ រូបំ ឥធេវ និរុជ្ឌ្យ្ យ
បុន បដិសន្ធិកវោ ន និព្ភ្ជ្ជ្ យ្ យ តាមធាតុយា
 វ រូបធាតុយា វ អរូបធាតុយា វ តាមភវ ១
រូបភវ ១ អរូបភវ ១ សញ្ញាភវ ១ អសញ្ញាភវ
១ នេវសញ្ញានាសញ្ញាភវ ១ ឯកវោការភវ ១
ចតុវោការភវ ១ បញ្ចវោការភវ ១ បុន ១
១ ឧបបត្តិយ ១ បដិសន្ធិយ ១ សំសារ ១ ១
១ ន ជនេយ្ យ ន សញ្ជនេយ្ យ ន និព្ភ្ជ្ជ្ យ
ជាកិនិព្ភ្ជ្ជ្ យ ឥធេវ និរុជ្ឌ្យ្ យ រូបសមេយ្ យ អ
ចេ្ជ យ្ យ បដិប្ជ្ជ្ យ ជ ១ ១
អបុនព្ភវាយ ។ ១ ១

តណ្ហាធិបន្ធ មនុជ ១
(បិ ១ ១)

ស ១ ១ ១ ១
ត ១ ១ ១ ១
ជ ១ ១ ១ ១ ។

ពាក្យថា ដើម្បីការមិនកើតទៀត គឺ រូបរបស់អ្នក គប្បីរលត់ក្នុងទីនេះឯង យ៉ាងណា បដិសន្ធិកព មិនគប្បីកើតទៀត ក្នុងកាមធាតុក្តី រូបធាតុក្តី អរូបធាតុក្តី កាមភពក្តី រូបភពក្តី អរូបភពក្តី សញ្ញាភពក្តី អសញ្ញាភពក្តី នេវសញ្ញានាសញ្ញាភពក្តី ឯកវោការភពក្តី ចតុវោការភពក្តី បញ្ចវោការ-ភពក្តី គឺមិនកើត មិនបង្កើត មិនកកើត មិនកើតចំពោះក្នុងគតិ ឧបបត្តិ បដិសន្ធិ សំសារ និងវដ្ដៈទៀត គឺថាគប្បីរលត់ គប្បីចូលទៅរម្ងាប់ គប្បីដល់នូវការតាំងនៅមិនបាន គប្បីរម្ងាប់ចំពោះក្នុងភពនេះឯង ក៏យ៉ាងនោះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) ចូរលះបង់តណ្ហា ដើម្បីការមិនកើតទៀត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលបិङ្គិយៈ) អ្នកកាលបើសម្ងឹងមើលពួកមនុស្ស ដែលត្រូវតណ្ហាគ្របសង្កត់ ត្រូវសេចក្តីក្តៅក្រហាយកើតមាន ត្រូវជរាបៀតបៀន ម្នាលបិङ្គិយៈ អ្នកនឹងទៅជាបុគ្គលមិនប្រហែស ព្រោះការឃើញនោះ ហេតុនេះ អ្នកចូរលះបង់តណ្ហា ដើម្បីការមិនកើតទៀត ។

[៩៩] សហ គាថាបរិយោសានា តេន ព្រាហ្មណេន សទ្ធឹ ឯកច្ឆន្ទា ឯកប្បយោគា ឯកាធិប្បាយា ឯកវាសនវាសិតា តេសំ អនេកបាណសហស្សានំ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ តស្ស ច ព្រាហ្មណស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។ សហ ចក្ខុប្បដិលាភា អជិនជដាវាកចីរតិទណ្ឌកមណ្ឌលុកេសា ច មស្សុ ច អន្តរហិតា ។ ភណ្ឌកាសាយវត្ថវសនោ សង្ឃាដិបត្តចីវរធរោ ភិក្ខុ អន្វត្ថប្បដិប្បត្តិយា បញ្ជលិកោ ភគវន្តំ នមស្សមានោ និសិន្នោ ហោតិ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

បិង្គិយមាណវកប្បញ្ហានិទ្ទេសោ សោឡសមោ ។

---

[៩៩] ក្នុងពេលដំណាលគ្នានឹងចប់ព្រះគាថា ពួកសត្វទាំងឡាយណា មានធ្នូ:តែមួយ មានប្រយោគតែមួយ មានបំណងតែមួយ នៅដោយការនៅតែមួយ ជាមួយនឹងព្រាហ្មណ៍នោះ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់ពាន់នៃសត្វទាំងឡាយដ៏ច្រើននោះថា ធម្មជាតណានីមួយ មានកិរិយាកើតឡើងជាធម្មតា ធម្ម-ជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា មួយទៀត ធម្ម-ចក្ខុ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់ព្រាហ្មណ៍នោះថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ស្បែកខ្វា ផ្ទ្ធងសក់ សំពត់សម្បកឈើ ឈើច្រត់ កុណ្ឌី សក់និងពុកមាត់ បាត់ទៅក្នុងពេលដំណាលគ្នានឹងការបានចក្ខុ ។ ព្រាហ្មណ៍នោះ ជាកិក្ខុមានកណ្ហ: និងសម្ងៀកបំពាក់សំពត់កាសាយ: ទ្រទ្រង់សង្ឆាដីបាត្រនិងចីវរ អង្គុយប្រណម្យអញ្ជលីនមស្ការព្រះមានព្រះភាគ ដោយការសម្រេចប្រយោជន៍ដ៏សមគួរ បានពោលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាគ្រូនៃខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមជាសាវ័ក ។

ចប់ បិង្គិយមាណវកប្បញ្ហានិទ្ទេស ទី ១៦ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

[១០០] ឥធមវោច ភគវា មគធេសុ

វិហរន្តោ ចាសាណាកេ ចេតិយេ បរិចា-

រិកសោឡសន្តំ ព្រាហ្មណានំ អជ្ឈិដ្ឋោ

បុដ្ឋោ បុដ្ឋោ បញ្ហំ ព្យាការិ ។

[១០១] ឥធមវោច ភគវាតិ ឥមំ ចារាយណំ អ-

វោច ។ ភគវាតិ ការរាជិវចនមេតំ ។ បេ ។ សច្ឆិកា

បញ្ញត្តិ យទិទំ ភគវាតិ ឥធមវោច ភគវា ។

[១០២] មគធេសុ វិហរន្តោតិ មគធជនបទេ

ជនបទេ ។ វិហរន្តោតិ វិហរន្តោ ឥរិយន្តោ វត្ត-

ន្តោ ចារេន្តោ យាបេន្តោ យាបេន្តោ ។ ចាសា-

ណាកេ ចេតិយេតិ ចាសាណាចេតិយំ រុក្ខូតិ ពុទ្ធា-

សនន្តិ មគធេសុ វិហរន្តោ ចាសាណាកេ ចេតិយេ ។

សោឡសមាណវកបញ្ហានិគមនិទ្ទេស

[១០០] ព្រះមានព្រះភាគ កាលគង់នៅ នាបាសាណកចេតិយ ក្នុងមគធជនបទ ទ្រង់បានសម្តែងធម៌នេះ កាលព្រាហ្មណ៍ទាំង ១៦ ជាអ្នកបម្រើ (នៃពាវរីព្រាហ្មណ៍) អាវធនាសួរហើយ ។ ព្រះអង្គក៏បានទ្រង់ដោះស្រាយប្រស្នា ។

[១០១] ពាក្យថា ព្រះមានព្រះភាគ ទ្រង់បានសម្តែងធម៌នេះ គឺ បានសម្តែងបារាយន:នេះ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះ ជាពាក្យពោលដោយគោរព ។ បេ ។ បញ្ញត្តិថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការត្រាស់ដឹង ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគទ្រង់បានសម្តែងធម៌នេះ ។

[១០២] ពាក្យថា កាលគង់នៅក្នុងមគធជនបទ គឺក្នុងជនបទមានឈ្មោះថា មគធ: ។ ពាក្យថា កាលគង់នៅ គឺកាលឋិតនៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ។ ពាក្យថា បាសាណកចេតិយ សេចក្តីថា ពុទ្ធាសន: លោកហៅថា បាសាណចេតិយ ហេតុនោះ (លោកពោលថា) កាលគង់នៅនាបាសាណកចេតិយ ក្នុងមគធជនបទ ។

[១០៣] បរិចារិកសោឡសន្នំ ព្រាហ្មណានន្តិ បិង្គិយោ(១) ព្រាហ្មណោ ពាវរិស្ស ព្រាហ្មណស្ស សេដ្ឋោ សេដ្ឋវរោ(២) បរិចារិកោ បិង្គិយេន(៣) តេ សោឡសាតិ ឯវម្បិ បរិចារិកសោឡសន្នំ ព្រាហ្មណានំ ។ អថវា តេ សោឡស ព្រាហ្មណា ពុទ្ធស្ស ភគវតោ សេដ្ឋា សេដ្ឋវរា បរិចារិកា សិយុន្តិ ឯវម្បិ បរិចារិកសោឡសន្នំ ព្រាហ្មណានំ ។

[១០៤] អជ្ឈិដ្ឋោ បុដ្ឋោ បុដ្ឋោ បញ្ហំ ព្យាកាសីតិ អជ្ឈិដ្ឋោ អជ្ឈេសិតោ ។ បុដ្ឋោ បុដ្ឋោតិ បុដ្ឋោ បុច្ឆិតោ យាចិតោ អជ្ឈេសិតោ បសាទិតោ ។ បញ្ហំ ព្យាកាសីតិ បញ្ហំ ព្យាកាសិ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីមកាសិ បកាសេសីតិ អជ្ឈិដ្ឋោ បុដ្ឋោ បុដ្ឋោ បញ្ហំ ព្យាកាសិ(៤) ។

---

១ ម. សិង្គិយោ ។ ២ បដ្ឋោ បដ្ឋចរោ ។ ៣ សិស្សោ តេន ។ ៤ ម. ព្យាកាសិ តេននេតំ វុច្ចតិ ។ ឥតោ បរំ មរម្មបោត្ថកេ ឥទមវោច ភគវា មគធេសុ វិហរន្តោ បាសាណកេ ចេតិយេ បរិចារិកសោឡសន្នំ ព្រាហ្មណានំ អជ្ឈិដ្ឋោ បុដ្ឋោ បុដ្ឋោ បញ្ហំ ព្យាកាសីតិ ទិស្សតិ ។

[១០៣] *ពាក្យថា កាលត្រូវព្រាហ្មណ៍ជាអ្នកបម្រើទាំង ១៦ សេចក្តីថា បិង្គិយព្រាហ្មណ៍ ជាអ្នកបម្រើ ប្រសើរ ថ្ងៃថ្ងា នៃពាវរីព្រាហ្មណ៍ ព្រាហ្មណ៍ទាំង ១៦ នាក់នោះ រាប់ទាំងបិង្គិយព្រាហ្មណ៍ផង ហេតុនោះ (លោកពោលថា) កាលព្រាហ្មណ៍ទាំង ១៦ ជាអ្នកបម្រើ យ៉ាងនេះក៏បាន ។ ឬថា ព្រាហ្មណ៍ទាំង ១៦ នោះ ជាអ្នកបម្រើ ប្រសើរ ថ្ងៃថ្ងា នៃព្រះពុទ្ធមានព្រះភាគ ហេតុនោះ (លោកពោលថា) កាលព្រាហ្មណ៍ទាំង ១៦ ជាអ្នកបម្រើ យ៉ាងនេះក៏បាន ។*

[១០៤] *ពាក្យថា អាវជនា សួរហើយ ។ ព្រះអង្គក៏បានទ្រង់ដោះស្រាយប្រស្នា គឺ អាវជនាហើយ និមន្តហើយ ។ ពាក្យថា សួរហើយ ។ គឺសួរហើយ សួរបញ្ជាក់ហើយ អង្វរហើយ អាវជនាហើយ ឲ្យជ្រះថ្លាហើយ ។ ពាក្យថា ទ្រង់ដោះស្រាយប្រស្នា គឺទ្រង់ដោះស្រាយ ប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើក រៃកញ្ជែក ធ្វើឲ្យរាក់ ប្រកាសនូវប្រស្នា ហេតុនោះ (លោកពោលថា) អាវជនា សួរហើយ ។ ព្រះអង្គក៏បានទ្រង់ដោះស្រាយប្រស្នា ។*

[១០៥] ឯកមេកស្ស ចេបិ បញ្ហស្ស អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជេយ្យ កច្ចេយ្យេ ជរាមរណស្ស ចារំ ចារកមនីយា ឥមេ ធម្មាតិ តស្មា ឥមស្ស ធម្មបរិយាយស្ស ចារាយនន្ត្វេ អធិវចនំ ។

[១០៦] ឯកមេកស្ស ចេបិ បញ្ហស្ហាតិ ឯកមេកស្ស ចេបិ អជិតប្បញ្ហស្ស ឯកមេកស្ស ចេបិ តិស្សមេត្តេយ្យប្បញ្ហស្ស ឯកមេកស្ស ចេបិ បុណ្ណកប្បញ្ហស្ស ឯកមេកស្ស ចេបិ មេត្តគូបញ្ហស្ស ឯកមេកស្ស ចេបិ ធោតកប្បញ្ហស្ស ឯកមេកស្ស ចេបិ ឧបសីវប្បញ្ហស្ស ឯកមេកស្ស ចេបិ នន្ទប្បញ្ហស្ស ឯកមេកស្ស ចេបិ ហេមកប្បញ្ហស្ស ឯកមេកស្ស ចេបិ តោទេយ្យប្បញ្ហស្ស ឯកមេកស្ស ចេបិ កប្បប្បញ្ហស្ស ឯកមេកស្ស ចេបិ ជតុកណ្ណីបញ្ហស្ស ឯកមេកស្ស ចេបិ ភទ្រាវុធប្បញ្ហស្ស ឯកមេកស្ស ចេបិ ឧទយប្បញ្ហស្ស ឯកមេកស្ស ចេបិ ចោសាលប្បញ្ហស្ស ឯកមេកស្ស

[១០៥] ប្រសិនបើបុគ្គល បានដឹងអត្ត បានដឹងធម៌ នៃប្រស្នាមួយ។ ហើយប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ បុគ្គលនោះ នឹងទៅកាន់ត្រើយនៃជរានិងមរណៈ ពុំខាន (ព្រោះថា) ធម៌ទាំងនេះ ជាធម៌គួរនាំសត្វទៅកាន់ត្រើយគឺព្រះនិព្វាន ហេតុនោះ ពាក្យថា បារាយនៈ ជាឈ្មោះនៃធម្មបរិយាយនេះ ។

[១០៦] ពាក្យថា ប្រសិនបើ នៃប្រស្នាមួយ ។ គឺ ប្រសិនបើ នៃប្រស្នាអជិតមាណពមួយ ។ ប្រសិនបើ នៃប្រស្នាតិស្សមេត្តេយ្យ-មាណពមួយ ។ ប្រសិនបើ នៃប្រស្នាបុណ្ណកមាណពមួយ ។ ប្រសិនបើ នៃប្រស្នាមេត្តគូមាណពមួយ ។ ប្រសិនបើ នៃប្រស្នាធោតក-មាណពមួយ ។ ប្រសិនបើ នៃប្រស្នាឧបសីវមាណពមួយ ។ ប្រសិនបើ នៃប្រស្នានន្ទមាណពមួយ ។ ប្រសិនបើ នៃប្រស្នាហេមកមាណពមួយ ។ ប្រសិនបើ នៃប្រស្នាតោទេយ្យមាណពមួយ ។ ប្រសិនបើ នៃប្រស្នាកប្បមាណពមួយ ។ ប្រសិនបើ នៃប្រស្នាជតុកណ្ណីមាណពមួយ ។ ប្រសិនបើ នៃប្រស្នាកទ្រាវុធមាណពមួយ ។ ប្រសិនបើ នៃប្រស្នាឧទយមាណពមួយ ។ ប្រសិនបើ នៃប្រស្នាបោសាលមាណពមួយ ។

ចេបិ មោឃរាជប្បញ្ហស្ស ឯកមេកស្ស ចេបិ បិង្គិយប្បញ្ហស្សាតិ ឯកមេកស្ស ចេបិ បញ្ហស្ស ។

[១០៧] អត្ថមញ្ញាយ ធម្មមញ្ញាយាតិ ស្វេវ បញ្ហោ ធម្មោ វិសជ្ជនំ អត្ថោតិ អត្ថំ អញ្ញាយ ជានិត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ អត្ថមញ្ញាយ ។ ធម្មមញ្ញាយាតិ ធម្មំ អញ្ញាយ ជានិត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ធម្មមញ្ញាយ ។

[១០៨] ធម្មានុធម្មំ បដិបជ្ជេយ្យាតិ សម្មាបដិបទំ អនុលោមប្បដិបទំ អបច្ចនីកប្បដិបទំ អន្វត្ថប្បដិបទំ ធម្មានុធម្មប្បដិបទំ បដិបជ្ជេយ្យាតិ ធម្មានុធម្មំ បដិបជ្ជេយ្យ ។

[១០៩] គច្ឆេយ្យេវ ជរាមរណស្ស បារង្គតំ ជរាមរណបារំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ គច្ឆេយ្យេវ ជរាមរណស្ស បារន្តិ បារំ គច្ឆេយ្យេវ

ប្រសិនបើ នៃប្រស្នាមោឃរាជមាណពមួយ ។ ប្រសិនបើ នៃប្រស្នាបិङ្គិយមាណពមួយ ។ ហេតុនោះ (លោកពោលថា) ប្រសិនបើ នៃប្រស្នាមួយ ។ ។

[១០៧] ពាក្យថា បានដឹងអត្ត បានដឹងធម៌ គឺបានដឹង យល់ ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យប្រាកដនូវសេចក្តីថា ធម៌គឺប្រស្នានោះឯង អត្តគឺការដោះស្រាយនោះឯង ហេតុនោះ(លោកពោលថា) បានដឹងអត្ត ។ ពាក្យថា បានដឹងធម៌ គឺបានដឹង យល់ ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យប្រាកដនូវធម៌ ហេតុនោះ (លោកពោលថា) បានដឹងធម៌ ។

[១០៧] ពាក្យថា ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ គឺ ប្រតិបត្តិ សម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អនុត្តប្បដិបទា ធម្មានុធម្មប្បដិបទា ហេតុនោះ (លោកពោលថា) ប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ ។

[១០៨] ពាក្យថា ទៅកាន់ត្រើយ នៃជរានិងមរណៈ ពុំខាន សេចក្តីថា អមតនិព្វាន លោកហៅថា ត្រើយនៃជរានិងមរណៈ បានដល់ សេចក្តីរម្ងាប់សង្ខារទាំងពួងការលាស់ចេលឧបធិទាំងពួងការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ ពាក្យថា នឹងទៅកាន់ ត្រើយ នៃជរានិងមរណៈពុំខាន បានសេចក្តីថា នឹងទៅកាន់ត្រើយ

ចារំ អធិកច្ឆេយ្យ ចារំ ផុសេយ្យ ចារំ សច្ឆិកាយ្យាតិ
កច្ឆេយ្យេវ ជរាមរណាស្ស ចារំ ។

[១១០] ចារគមនីយា[1] ឥមេ ធម្មាតិ ឥមេ ធម្មា
ចារគមនីយា ចារំ ចាបេន្តិ ចារំ សម្ភាបេន្តិ ចារំ
សមនុចាបេន្តិ ជរាមរណាស្ស តារណាយ សំវត្តន្តីតិ
ចារគមនីយា ឥមេ ធម្មា ។

[១១១] តស្មា ឥមស្ស ធម្មបរិយាយស្ស តស្មាតិ
តស្មា តំការណា តំហេតុ តប្ប្ចយា តំនិជានជាតិ
តស្មា ។ ឥមស្ស ធម្មបរិយាយស្ស ឥមស្ស
ចាវយនស្ស តស្មា ឥមស្ស ធម្មបរិយាយស្ស ។

[១១២] ចាវយនន្តេវ អធិវចនន្តិ ចារំ វុច្ចតិ
អមតំ និព្ពានំ យោ សោ សព្ពសង្ខារសមថោ
សព្ពូបធិប្ប្ដិនិស្ស្ដ្ដ្ គ្ គ្ តណ្ហាក្ខយោ
វិរាគោ
និរោធោ និព្ពានំ ។ អាយនំ វុច្ចតិ មគ្គោ
សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។
អធិវចនន្តិ នាមំ សង្ខ្យា សមញ្ញា បញ្ញត្តិ ។ បេ ។

---

1 ម. ចារំគមនិយា ។

នឹងបានត្រើយ នឹងប៉ះពាល់ត្រើយ នឹងធ្វើឲ្យជាក់ច្បាស់នូវត្រើយ ហេតុនោះ (លោកពោលថា) នឹងទៅកាន់ត្រើយ នៃជរានិងមរណៈពុំខាន ។

[១១០] ពាក្យថា ធម៌ទាំងនេះ ជាធម៌គួរនាំសត្វទៅកាន់ត្រើយ សេចក្ដីថា ធម៌ទាំងនេះ ជាធម៌គួរនាំសត្វទៅកាន់ត្រើយ គឺ ញ៉ាំងសត្វឲ្យដល់ត្រើយ ឲ្យដល់ព្រមនូវត្រើយ ឲ្យដល់ស៊ប់នូវត្រើយ គឺថា ប្រព្រឹត្តទៅដើម្បីឆ្លងជរានិងមរណៈ ហេតុនោះ (លោកពោលថា) ធម៌ទាំងនេះ ជាធម៌គួរនាំសត្វទៅកាន់ត្រើយ ។

[១១១] ពាក្យថា ហេតុនោះ...នៃធម្មបរិយាយនេះ ត្រង់ពាក្យថា ហេតុនោះ គឺ ព្រោះហេតុនោះ ព្រោះដំណើរនោះ ព្រោះហេតុដូច្នោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ហេតុនោះ (លោកពោលថា) ហេតុនោះ ។ ពាក្យថា នៃធម្មបរិយាយនេះ គឺ នៃបារាយនៈនេះ ហេតុនោះ (លោកពោលថា) ហេតុនោះ.... នៃធម្មបរិយាយនេះ ។

[១១២] ពាក្យថា បារាយនៈ ជាឈ្មោះ សេចក្ដីថា អមតនិព្វាន លោកហៅថា បារៈ បានខាងការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ មគ្គគឺសម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ លោកហៅថា អាយនៈ ។ ពាក្យថា ឈ្មោះ គឺជានាម ការរាប់ សេចក្ដីសម្គាល់ បញ្ញត្ដិ ។ បេ ។

អភិលាបោតិ ចាភយន្តេ អធិវចនំ ។

[១១៣] អជិតោ តិស្សមេត្តេយ្យោ បុណ្ណកោ អថ មេត្តគូ
ធោតកោ ឧបសីវោ ច នន្ទោ ច អថ ហេមកោ
តោទេយ្យកប្បា ទុភយោ ជតុកណ្ណី ច បណ្ឌិតោ
ភទ្រាវុធោ ឧទយោ ច បោសាលោ ចាបិ ព្រាហ្មណោ
មោឃរាជា ច មេធាវី បិង្គិយោ ច មហាឥសិ
ឯតេ ពុទ្ធំ ឧបាគញ្ឆុំ សម្បន្នចរណំ ឥសឹ
បុច្ឆន្តា និបុណេ បញ្ហេ ពុទ្ធសេដ្ឋំ ឧបាគមុំ ។

[១១៤] ឯតេ ពុទ្ធំ ឧបាគញ្ឆន្តិ ឯតេតិ[១] ព្រាហ្មណា ។ ពុទ្ធោតិ យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈិ តត្ថ ច សព្វញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ ។ ពុទ្ធោតិ កេនដ្ឋេន ពុទ្ធោ ។

១ ម. ឯតេតិ សោឡសបារាយនិយា ព្រាហ្មណា ។

ជាពាក្យសម្រាប់ហៅ ហេតុនោះ (លោកពោលថា) ពាក្យថា បាវាយនៈ ជាឈ្មោះ ។

[១១៣] *អជិតៈ ១ តិស្សមេត្តេយ្យៈ ១ បុណ្ណកៈ ១ មេត្តគូ ១ ធោតកៈ ១ ឧបសីវៈ ១ នន្ទៈ ១ ហេមកៈ ១ ជនទាំងពីរនាក់ គឺ តោទេយ្យៈ ១ កប្បៈ ១ និងជតុកណ្ណីបណ្ឌិត ១ ភទ្រាវុធ ១ ឧទយៈ ១ ពោសាលព្រាហ្មណ៍ ១ មោឃ-រាជ ជាអ្នកប្រាជ្ញ ១ បិង្គិយៈ ជាអ្នកស្វែងរកគុណធំ ១ ព្រាហ្មណ៍ទាំង ១៦ នាក់នុ៎ះ ចូលមកគាល់ព្រះពុទ្ធជាឥសី ទ្រង់មានចរណៈបរិបូណ៌ បានចូលមកគាល់ សួរប្រស្នាដ៏ល្អិត ចំពោះព្រះពុទ្ធប្រសើរ ។*

[១១៤] *អធិប្បាយពាក្យថា ព្រាហ្មណ៍ទាំង ១៦ នាក់នុ៎ះ ចូលមកគាល់ព្រះពុទ្ធ ត្រង់ពាក្យថា នុ៎ះ គឺពួកព្រាហ្មណ៍នុ៎ះ ។ ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគទ្រង់ត្រាស់ដឹងឯង មិនមានបុគ្គលជាអាចារ្យ បានត្រាស់ដឹងដោយព្រះអង្គឯង នូវសច្ចៈទាំងឡាយ ក្នុងធម៌ទាំងឡាយដែលព្រះអង្គមិនធ្លាប់ឮហើយក្នុងកាលមុន ទាំងបានដល់សព្ព-ញ្ញុតញ្ញាណក្នុងសច្ចៈទាំងនោះ និងភាវៈស្ទាត់ក្នុងពលៈទាំងឡាយ ។ សំណួរត្រង់ពាក្យថា ព្រះពុទ្ធ ចុះឈ្មោះថាព្រះពុទ្ធ ដោយអត្ថដូចម្តេច ។*

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

ពុជ្ឈិតា សច្ចានីតិ ពុទ្ធោ ។ ពោធេតា បជាយាតិ ពុទ្ធោ ។ សព្វញ្ញុតាយ ពុទ្ធោ ។ សព្វទស្សាវិតាយ ពុទ្ធោ ។ អភិញ្ញេយ្យតាយ ពុទ្ធោ ។ វិកសិតាយ ពុទ្ធោ ។ ទីឃាសវសង្ខ្យាតេន ពុទ្ធោ ។ និរុបក្លិលេ-សសង្ខ្យាតេន ពុទ្ធោ ។ ឯកន្តវីតរាគោតិ ពុទ្ធោ ។ ឯកន្តវីតទោសោតិ ពុទ្ធោ ។ ឯកន្តវីតមោហោតិ ពុទ្ធោ ។ ឯកន្តនិក្លិលេសោតិ ពុទ្ធោ ។ ឯកាយន-មក្តំ ឥតោតិ ពុទ្ធោ ។ ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ពុទ្ធោ ។ អពុជ្ឌិវិហតត្តា ពុជ្ឌិប្ឍដិលា-ភា ពុទ្ធោ ។ ពុទ្ធោតិ ឯតំ ជាមំ មាតរា ឥតំ ន បិតរា ឥតំ ន ភាតរា ឥតំ ន ភគិនិយា ឥតំ

ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ត្រាស់ដឹងសច្ចៈទាំងឡាយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ញ៉ាំងពពួកសត្វឲ្យត្រាស់ដឹង ។ ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គដឹងធម៌ទាំងពួង ។ ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គឃើញធម៌ទាំងពួង ។ ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គដឹងច្បាស់ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គរីកហើយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះគេពោលថា ព្រះអង្គមានអាសវៈអស់ហើយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះគេពោលថា ព្រះអង្គមានឧបក្កិលេសចេញហើយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកភាគៈដោយចំណែកមួយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកទោសៈដោយចំណែកមួយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកមោហៈដោយចំណែកមួយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់មានកិលេសចេញហើយដោយចំណែកមួយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ទៅហើយកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ។ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ជាបុគ្គលឯក ត្រាស់ដឹងចំពោះសម្មាសម្ពោធិញ្ញាណ មិនមានគុណជាតដទៃក្រៃលែងជាង ។ ឈ្មោះថាព្រះពុទ្ធ ព្រោះទ្រង់កម្ចាត់បង់សេចក្តីលង់ព្រោះការបាននូវប្រាជ្ញា ។ ព្រះនាមព្រះពុទ្ធនុ៎ះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ

ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ
កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវ-
តាហិ កតំ វិមោក្ខន្តិកមេតំ ពុជ្ឌានំ ភគវន្តានំ
ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិ-
លាភា សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ ពុទ្ធំ ។
ឯតេ ពុទ្ធំ ឧចាតញ្ជន្តិ ឯតេ ពុទ្ធំ ឧចាតមីសុ
ឧបសន្តមីសុ បយិរ្យុចាសីសុ បរិបុច្ឆីសុ បរិបញ្ហីសូតិ
ឯតេ ពុទ្ធំ ឧចាតញ្ជុ ។

[១១៥] សម្ឆន្ទចរណំ ឥសិន្តិ ចរណំ រុច្ចតិ
សីលាចារនិបួត្តិ ។ សីលសំវរោបិ ចរណំ ឥន្ទ្រិយ-
សំវរោបិ ចរណំ ភោជនេ មត្តញ្ញុតាបិ ចរណំ ជា-
គរិយានុយោគោបិ ចរណំ សត្តបិ សទ្ធម្មា ចរណំ
ចត្តារិបិ ឈានានិ ចរណំ ។ សម្ឆន្ទចរណន្តិ
សម្ឆន្ទចរណំ សេដ្ឋចរណំ ចាមោក្ខចរណំ
ឧត្តមចរណំ ឧរ្ធចរណន្តិ សម្ឆន្ទចរណំ ។

មិនមែនពួកមិត្តនិងអាមាត្យថ្វាយ មិនមែនពួកញាតិនិងសាលោហិតថ្វាយ មិនមែនពួកសមណព្រាហ្មណ៍ថ្វាយ មិនមែនពួកទេវតាថ្វាយទេ ព្រះនាមថា ព្រះពុទ្ធ នុ៎ះ របស់ព្រះពុទ្ធទាំងឡាយមានព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតនៃវិមោក្ខ បញ្ញត្តិថា ព្រះពុទ្ធ នេះ កើតព្រោះការត្រាស់ដឹងព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនោះ (លោកពោលថា) ព្រះពុទ្ធ ។ ពាក្យថា នុ៎ះ ចូលមកគាល់ព្រះពុទ្ធ គឺព្រាហ្មណ៍ទាំងនុ៎ះ ចូលមករក ចូលមកជិត មកអង្គុយជិត សាកសួរ ដណ្តឹងសួរ នូវព្រះពុទ្ធ ហេតុនោះ (លោកពោលថា) ព្រាហ្មណ៍ទាំង ១៦ នាក់នុ៎ះ ចូលមកគាល់ព្រះពុទ្ធ ។

[១១ថ] ពាក្យថា ជាឥសី មានចរណៈបរិបូណ៌ អធិប្បាយថា ការសម្រេចដោយសីលាចារៈ លោកហៅថា ចរណៈ ។ ការសង្រួមសីល ឈ្មោះថាចរណៈ ការសង្រួមឥន្ទ្រិយ ឈ្មោះថាចរណៈ ភាពជាអ្នកដឹងប្រមាណក្នុងភោជន ឈ្មោះថាចរណៈ ការប្រកបរឿយៗ នូវសេចក្តីភ្ញាក់រឭក ឈ្មោះថាចរណៈ ព្រះសទ្ធម្មទាំង ៧ ឈ្មោះថាចរណៈ ឈានទាំង ៤ ឈ្មោះថាចរណៈ ។ ពាក្យថា មានចរណៈបរិបូណ៌ គឺមានចរណៈគ្រប់គ្រាន់ មានចរណៈដ៏ប្រសើរ មានចរណៈជាប្រធាន មានចរណៈដ៏ឧត្តម មានចរណៈដ៏ថ្លៃថ្នូ ហេតុនោះ (លោកពោលថា) មានចរណៈបរិបូណ៌ ។

ឥសិន្តិ ឥសិ ។ ភគវា មហន្តំ សីលក្ខន្ធំ ឯសិ
គវេសិ បរិយេសីតិ ឥសិ ។ បេ ។ មហេសក្ខេហិ
វា សត្តេហិ ឯសិតោ គវេសិតោ បរិយេសិតោ
កហំ ពុទ្ធោ កហំ ភគវា កហំ ទេវទេវោ កហំ
ឧភាសភោតិ ឥសីតិ សម្ឆន្ទចរណំ ឥសី ។

[១១៦] បុច្ឆន្តា ជិបុណោ បញ្ហេតិ បុច្ឆន្តាតិ
បុច្ឆន្តា យាចន្តា អជ្ឈេសន្តា បសាទេន្តា ។ ជិបុ-
ណោ បញ្ហេតិ ឥម្ហីវ ពុទ្ធសេ ពុរនុពោធេ សន្តេ
បណីតេ អតក្ការចរេ ជិបុណោ បណ្ហិតវេទនីយេ
បញ្ហេតិ បុច្ឆន្តា ជិបុណោ បញ្ហេ ។

[១១៧] ពុទ្ធសេដ្ឋំ ឧចាតមុត្តិ ពុទ្ធាតិ យោ សោ
ភគវា ។ បេ ។ សច្ឆិកា បញ្ញត្តិ យជិទំ ពុទ្ធោតិ ។
សេដ្ឋន្តិ អក្ខំ សេដ្ឋំ វិសេដ្ឋំ ចាមោក្ខំ ឧត្តមំ ឧត្តមន្តិ
ពុទ្ធសេដ្ឋំ ។ ឧចាតមុត្តិ ឧចាតមីសុ ឧបសន្តមីសុ

ពាក្យថា ជាតិសី គឺជាអ្នកស្វែង ។ ព្រះមានព្រះភាគ ឈ្មោះថាតិសី ព្រោះហេតុទ្រង់ស្វែង ស្វែងរក ស្វះស្វែងនូវសីលក្ខន្ធដ៏ធំ ។ បេ ។ ឬថា ឈ្មោះថាតិសី ព្រោះហេតុព្រះមានព្រះភាគ ត្រូវសត្វទាំងឡាយមានសក្តិធំ រកស្វែង ស្វះស្វែងថា ព្រះពុទ្ធគង់ក្នុងទីណា ព្រះមានព្រះភាគគង់ក្នុងទីណា ព្រះពុទ្ធជាទេវតាដ៏ធំជាងទេវតា គង់ក្នុងទីណា ព្រះពុទ្ធជានរ:អង់អាចគង់ក្នុងទីណា ហេតុនោះ (លោកពោលថា) ជាតិសី មានចរណ: បរិបូណ៌ ។

[១១៦] ពាក្យថា សួរប្រស្នាដ៏ល្អិត ត្រង់ពាក្យថា សួរ គឺសួរអង្វរ អារាធនា ជ្រះថ្លា ។ ពាក្យថា ប្រស្នាដ៏ល្អិត គឺ ប្រស្នាដ៏ជ្រាលជ្រៅ ដែលបុគ្គលឃើញបានដោយកម្រ ត្រាស់ដឹងបានដោយកម្រ ដ៏ល្អិតឧត្តម មិនជាទីស្ទង់ដោយសេចក្តីត្រិះរិះ ជាប្រស្នាដ៏ម៉ត់ចត់ មានតែបណ្ឌិតទើបដឹងបាន ហេតុនោះ (លោកពោលថា) សួរប្រស្នាដ៏ល្អិត ។

[១១៧] ពាក្យថា ព្រះពុទ្ធ ក្នុងបទថា ចូលមកគាល់ព្រះពុទ្ធប្រសើរ គឺ ព្រះមានព្រះភាគ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធ នេះ (កើត) ព្រោះការត្រាស់ដឹង ។ ពាក្យថា ប្រសើរ គឺលើស ប្រសើរ ប្រសើរវិសេសជាប្រធាន ឧត្តម ថ្លៃថ្នូ ហេតុនោះ (លោកពោលថា) ព្រះពុទ្ធប្រសើរ ។ ពាក្យថា ចូលមកគាល់ គឺ ចូលមករក ចូលមកជិត

បយិរ្ទូចាសីសុ បរិបុច្ឆីសុ បរិបញ្ហីសូតិ ពុទ្ធសេដ្ឋំ ឧចាតមុំ ។ តេនេតំ វុច្ចតិ

ឯតេ ពុទ្ធំ ឧចាតញ្ចុ សម្ឆន្ទចរណំ ឥសឺ
បុច្ឆន្តា និបុណោ បញ្ហេ ពុទ្ធសេដ្ឋំ ឧចាតមុន្តិ ។

[១១៨] តេសំ ពុទ្ធោ ព្យាការិ
បញ្ហេ បុដ្ឋោ យថាតថំ
បញ្ហានំ វេយ្យាការណេន
តោសេសិ ព្រាហ្មណោ មុនិ ។

[១១៩] តេសំ ពុទ្ធោ ព្យាការីតិ តេសន្តិ សោឍ្ឍសន្នំ ចារាយនិយានំ ព្រាហ្មណានំ ។ ពុទ្ធោតិ យោ សោ ភគវា ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ ។ ព្យាការីតិ តេសំ ពុទ្ធោ ព្យាការិ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីមការិ បការេសីតិ តេសំ ពុទ្ធោ ព្យាការិ ។

ចូលមកអង្គុយជិត សាកសួរ ដណ្ដឹងសួរ ហេតុនោះ (លោកពោលថា) ចូលមកគាល់ព្រះពុទ្ធប្រសើរ ។ ហេតុនោះ លោកពោលពាក្យនេះថា

ព្រាហ្មណ៍ទាំង ១៦ នាក់ន៏ុះ ចូលមកគាល់ព្រះពុទ្ធ
ជាឥសី ទ្រង់មានចរណៈបរិបូណ៌ បានចូលមកគាល់
សួរប្រស្នាដ៏ល្អិត ចំពោះព្រះពុទ្ធប្រសើរ ។

[១១៨] ព្រះពុទ្ធ ដែលព្រាហ្មណ៍ទាំងនោះ សួរប្រស្នា
ហើយ ក៏ទ្រង់ព្យាករហើយ តាមសេចក្ដីពិត ព្រះ
មុនិ បានទ្រង់ញ៉ាំងពួកព្រាហ្មណ៍ឲ្យត្រេកអរ
ដោយការព្យាករប្រស្នាទាំងឡាយ ។

[១១៩] ពាក្យថាព្រះពុទ្ធ ដែលព្រាហ្មណ៍ទាំងនោះ (សួរប្រស្នាហើយ) ក៏ទ្រង់ព្យាករហើយ ត្រង់ពាក្យថា ដែលព្រាហ្មណ៍ទាំងនោះ គឺដែលពួកព្រាហ្មណ៍ទាំង ១៦ ជាអ្នកគួរទៅកាន់ត្រើយ ។ ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធ នេះ (កើត) ព្រោះការត្រាស់ដឹង ។ ពាក្យថា ទ្រង់ព្យាករហើយ គឺ ព្រះពុទ្ធទ្រង់ព្យាករ ប្រាប់ សម្ដែង តែងតាំង តាំងផ្ដើម បើក រៃកញ្ជែក ធ្វើឲ្យរាក់ ប្រកាសហើយ ចំពោះជនទាំងនោះ ហេតុនោះ (លោកពោលថា) ព្រះពុទ្ធដែលព្រាហ្មណ៍ទាំងនោះ (សួរប្រស្នាហើយ) ទ្រង់ព្យាករហើយ ។

[១២០] បញ្ហ បុដ្ឋោ យថាតថន្តិ បញ្ហ បុដ្ឋោតិ បញ្ហ បុច្ឆិតោ យាចិតោ អជ្ឈេសិតោ បសាទិតោ ។ យថាតថន្តិ យថា អាចិក្ខិតព្ពំ តថា អាចិក្ខិ យថា ទេសិតព្ពំ តថា ទេសេសិ យថា បញ្ញបេតព្ពំ តថា បញ្ញបេសិ យថា បដ្ឋបេតព្ពំ តថា បដ្ឋបេសិ យថា វិវរិតព្ពំ តថា វិវរិ យថា វិភជិតព្ពំ តថា វិភជិ យថា ឧត្តានីកាតព្ពំ តថា ឧត្តានីមកាសិ យថា បកាសេ-តព្ពំ តថា បកាសេសីតិ បញ្ហ បុដ្ឋោ យថាតថំ ។

[១២១] បញ្ហានំ វេយ្យាការណានាតិ បញ្ហានំ វេយ្យាការណាន អាចិក្ខនេន ទេសនេន បញ្ញបនេ-ន បដ្ឋបនេន វិវរេន វិភជនេន ឧត្តានីកម្មេន បកា-សនេនាតិ បញ្ហានំ វេយ្យាការណាន ។

[១២២] គោសេសិ ព្រាហ្មណោ មុនីតិ គោសេសីតិ គោសេសិ វិគោសេសិ បសាទេសិ អារាធេសិ អត្តមនេ អកាសិ ។

[១២០] *ពាក្យថា សួរប្រស្នាហើយ ... តាមសេចក្ដីពិត ត្រង់ពាក្យថា សួរប្រស្នាហើយ គឺ អង្វរ អារាធនា ឲ្យជ្រះថ្លាហើយ នូវប្រស្នា ។ ពាក្យថា តាមសេចក្ដីពិត គឺ គួរប្រាប់យ៉ាងណា ទ្រង់ប្រាប់យ៉ាងនោះ គួរសម្ដែងយ៉ាងណា ទ្រង់សម្ដែងយ៉ាងនោះ គួរតែងតាំងយ៉ាងណា ទ្រង់តែងតាំងយ៉ាងនោះ គួរតាំងផ្ដើមយ៉ាងណា ទ្រង់តាំងផ្ដើមយ៉ាងនោះ គួរបើកយ៉ាងណា ទ្រង់បើកយ៉ាងនោះ គួរវែកញែកយ៉ាងណា ទ្រង់វែកញែកយ៉ាងនោះ គួរធ្វើឲ្យរាក់យ៉ាងណា ទ្រង់ធ្វើឲ្យរាក់យ៉ាងនោះ គួរប្រកាសយ៉ាងណា ទ្រង់ប្រកាសយ៉ាងនោះ ហេតុនោះ (លោកពោលថា) សួរប្រស្នាហើយ . . . តាមសេចក្ដីពិត ។*

[១២១] *ពាក្យថា ដោយការព្យាករប្រស្នាទាំងឡាយ គឺ ដោយការព្យាករ ការប្រាប់ ការសម្ដែង ការតែងតាំង ការតាំងផ្ដើម ការបើក ការវែកញែក ការធ្វើឲ្យរាក់ ការប្រកាស នូវប្រស្នាទាំងឡាយ ហេតុនោះ (លោកពោលថា) ដោយការព្យាករប្រស្នាទាំងឡាយ ។*

[១២២] *ពាក្យថា ឲ្យត្រេកអរ ក្នុងបទថា ព្រះមុនិបានទ្រង់ញ៉ាំងពួកព្រាហ្មណ៍ឲ្យត្រេកអរ គឺ ឲ្យត្រេកអរ ឲ្យត្រេកអរវិសេស ឲ្យជ្រះថ្លា ឲ្យស្រស់ស្រាយ បានធ្វើពួកព្រាហ្មណ៍ទាំងនោះឲ្យមានចិត្ដរីករាយ ។*

ព្រាហ្មណោតិ សោឍ្ឍស ចារាយនិយេ ព្រាហ្មណោ ។ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជានណា ។ បេ ។ សង្ខ្លជាលមតិចូ សោ មុនីតិ តោសេសិ ព្រាហ្មណោ មុនិ ។ តេនេតំ វុច្ចតិ

តេសំ ពុទ្ធោ ព្យាកាសិ បញ្ហេ បុដ្ឋោ យថាតថំ

បញ្ហានំ វេយ្យាការណេន តោសេសិ ព្រាហ្មណោ មុនីតិ ។

[១២៣] តេ តោសិតា ចក្ខុមតា ពុទ្ធេនាទិចូ ពន្ធុនា

ព្រហ្មចរិយមចរីសុ រាបញ្ញស្ស សន្តិកេ ។

[១២៤] តេ តោសិតា ចក្ខុមតាតិ តេតិ សោឍ្ឍស ចារាយនិយា ព្រាហ្មណា ។ តោ-សិតាតិ តោសិតា រិតោសិតា បសាទិតា អារាធិតា អត្តមនា ឥតាតិ តេ តោសិតា ។

ពាក្យថា ញ៉ាំងពួកព្រាហ្មណ៍ គឺ ពន្យល់ពួកព្រាហ្មណ៍ទាំង ១៦ ដែលជាអ្នកគួរដល់ត្រើយ ។ ពាក្យថា ព្រះមុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ បានដល់ បញ្ញា ការដឹងច្បាស់ ។ បេ ។ បុគ្គលណាកន្ទងបង់នូវបណ្តាញ ជាគ្រឿងជាប់ចំពាក់ បុគ្គលនោះ ឈ្មោះថាមុនិ ហេតុនោះ (លោកពោលថា) ព្រះមុនិបានទ្រង់ញ៉ាំងពួកព្រាហ្មណ៍ឲ្យត្រេកអរ ។ ហេតុនោះ លោកពោលពាក្យនេះថា

ព្រះពុទ្ធ ដែលព្រាហ្មណ៍ទាំងនោះ សួរប្រស្នាហើយ ក៏ទ្រង់ព្យាករហើយ តាមសេចក្តីពិត ព្រះមុនិ បានញ៉ាំងពួកព្រាហ្មណ៍ឲ្យត្រេកអរ ដោយការព្យាករប្រស្នាទាំងឡាយ ។

[១២៣] ជនទាំងនោះ ដែលព្រះពុទ្ធទ្រង់ជាផៅពង្ស នៃព្រះអាទិត្យ មានចក្ខុ បានឲ្យត្រេកអរហើយ ក៏បានប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសម្នាក់ព្រះសាស្តា មានបញ្ញាប្រសើរ ។

[១២៤] ពាក្យថា ជនទាំងនោះ ដែលព្រះពុទ្ធ មានចក្ខុ បានឲ្យត្រេកអរហើយ ត្រង់ពាក្យថា ជនទាំងនោះ គឺពួកព្រាហ្មណ៍ ទាំង ១៦ ដែលគួរទៅកាន់ត្រើយ ។ ពាក្យថា បានឲ្យត្រេកអរ គឺបានឲ្យត្រេកអរ ឲ្យត្រេកអរវិសេស ឲ្យជ្រះថ្លា ឲ្យស្រស់ស្រាយ ធ្វើឲ្យមានចិត្តរីករាយ ហេតុនោះ (លោកពោលថា) ជនទាំងនោះ... បានឲ្យត្រេកអរហើយ ។

ចក្ខុមតាតិ ភគវា បញ្ចហិ ចក្ខូហិ ចក្ខុមា មំស-
ចក្ខុនាបិ ចក្ខុមា ទិព្វចក្ខុនាបិ ចក្ខុមា បញ្ញា-
ចក្ខុនាបិ ចក្ខុមា ពុទ្ធចក្ខុនាបិ ចក្ខុមា សមន្ត-
ចក្ខុនាបិ ចក្ខុមា ។ កថំ ភគវា មំសចក្ខុនាបិ
ចក្ខុមា ។ បេ ។ ឯវំ ភគវា សមន្តចក្ខុនាបិ
ចក្ខុមាតិ តេ តោសិតា ចក្ខុមតា ។

[១២៥] ពុទ្ធេនាធិចូពន្ធូនាតិ ពុទ្ធេនាតិ យោ
សោ ភគវា ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ
ពុទ្ធោតិ ។ អាធិចូពន្ធូនាតិ អាធិចោ រុចូតិ សុរិ-
យោ ។ សោ តោតមោ តោត្តេន ភគវាបិ តោត-
មោ តោត្តេន ភគវា សុរិយស្ស តោត្តញ្ញាតកោ
តោត្តពន្ធូ តស្មា ពុទ្ធោ អាធិចូពន្ធូតិ ពុទ្ធេនាធិចូ-
ពន្ធូនា ។

[១២៦] ព្រហ្មចរិយមចរីសូតិ ព្រហ្មចរិយំ
រុចូតិ អសទ្ធម្មសមាបត្តិយា អារតិ វិរតិ
បដិវិរតិ វេរមណី វិរមណំ អកិរិយា

ពាក្យថា មានចក្ខុ គឺ ព្រះមានព្រះភាគ មានចក្ខុដោយចក្ខុ ៥ គឺមានចក្ខុដោយមំសចក្ខុ ១ មានចក្ខុដោយទិព្វចក្ខុ ១ មានចក្ខុដោយបញ្ញាចក្ខុ ១ មានចក្ខុដោយពុទ្ធចក្ខុ ១ មានចក្ខុដោយសមន្តចក្ខុ ១ ។ ព្រះមានព្រះភាគ មានចក្ខុដោយមំសចក្ខុ តើដូចម្តេច ។ បេ ។ ព្រះមានព្រះភាគ មានចក្ខុដោយសមន្តចក្ខុ យ៉ាងនេះ ហេតុនោះ (លោកពោលថា) ជនទាំងនោះដែលព្រះពុទ្ធមានចក្ខុ បានឲ្យត្រេកអរហើយ ។

[១២៥] ពាក្យថា ព្រះពុទ្ធទ្រង់ជាផៅពង្ស នៃព្រះអាទិត្យ ត្រង់ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធនេះ (កើត) ព្រោះការត្រាស់ដឹង ។ ពាក្យថា ទ្រង់ជាផៅពង្សនៃព្រះអាទិត្យ សេចក្តីថា សុរិយៈ លោកហៅថា ព្រះអាទិត្យ ។ សុរិយៈនោះ ជាគោតមៈដោយគោត្រ ព្រះមានព្រះភាគក៏ជាគោតមៈដោយគោត្រ ព្រះមានព្រះភាគ ជាញាតិដោយគោត្រ ជាផៅពង្សដោយគោត្រនៃសុរិយៈ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាជាផៅពង្សនៃព្រះអាទិត្យ ហេតុនោះ (លោកពោលថា) ដែលព្រះពុទ្ធទ្រង់ជាផៅពង្ស នៃព្រះអាទិត្យ ។

[១២៦] ពាក្យថា បានប្រព្រឹត្តព្រហ្មចរិយៈ សេចក្តីថា ការជៀសការវាង ការវាងស្រឡះ ចេតនាជាហេតុវៀរ ការវៀរ ការមិនធ្វើ

អការណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ ។ អបិច ជិប្ជរិយាយវសេន ព្រហ្មចរិយំ រុច្ចតិ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ថិ សម្មាសង្កប្ប សម្មាវាចា សម្មាកម្មន្ត សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ ព្រហ្មចរិយមចរីសូតិ ព្រហ្មចរិយំ អចរីសុ សមាចាយ វត្តីសូតិ ព្រហ្មចរិយមចរីសុ ។

[១២៧] ឃ្ឃប្ញញ្ញ សន្តិកេតិ ឃ្ឃប្ញញ្ញ អក្ខ-ប្ញញ្ញ សេដ្ថប្ញញ្ញ ចាមោក្ខប្ញញ្ញ ឧត្ត-មប្ញញ្ញ ឧ្ឃ្ឃប្ញញ្ញ ។ សន្តិកេតិ សន្តិកេ សាមន្ត អាសន្ន អវិទូរេ ឧបក្ក្ដេតិ ឃ្ឃប្ញញ្ញ សន្តិកេ ។ តេនេតំ រុច្ចតិ

ការមិនសាង ការមិនសម្ពព ការមិនប្រព្រឹត្តកន្ទ ងកម្រិត ការផ្ដាច់ស្ពាន ក្នុងការប្រកបដោយអសទ្ធម្ម លោកហៅថា ព្រហ្មចរិយ: ។ មួយទៀត បើពោលដោយអំណាចនិប្ឋរិយាយ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺ ប្រាជ្ញាយល់ឃើញត្រូវ សេចក្ដីត្រិះរិះត្រូវ សម្ដីត្រូវ ការងារត្រូវ ការចិញ្ចឹមជីវិតត្រូវ ការព្យាយាមត្រូវ សេចក្ដីរលឹកត្រូវ ការតម្កល់ចិត្តឲ្យនឹងត្រូវ លោកហៅថា ព្រហ្មចរិយ: ។ ពាក្យថា បានប្រព្រឹត្តព្រហ្មចរិយ: គឺ បានប្រព្រឹត្ត ប្រព្រឹត្តសមាទានព្រហ្មចរិយ: ហេតុនោះ (លោកពោលថា) ក៏បានប្រព្រឹត្តព្រហ្មចរិយ: ។

[១២៧] ពាក្យថា ក្នុងសម្ផាក់ព្រះសាស្ដា មានប្រាជ្ញាប្រសើរ គឺ ព្រះសាស្ដាមានប្រាជ្ញាប្រសើរ មានប្រាជ្ញាដ៏លើស មានប្រាជ្ញាប្រសើរបំផុត មានប្រាជ្ញាជាប្រធាន មានប្រាជ្ញាដ៏ឧត្ដម មានប្រាជ្ញាដ៏ថ្លៃថ្នូ ។ ពាក្យថា ក្នុងសម្ផាក់ គឺ ក្នុងសម្ផាក់ ក្បែរ ជិត មិនឆ្ងាយ ក្ងៀក ហេតុនោះ (លោកពោលថា) ក្នុងសម្ផាក់ព្រះសាស្ដា មានប្រាជ្ញាប្រសើរ ។ ហេតុនោះ លោកពោលពាក្យនេះថា

តេ តោសិតា ចក្ខុមតា ពុទ្ធេនាទិច្ចពន្ធុនា
ព្រហ្មចរិយមចរឹសុ រាវប្បញ្ញស្ស សន្តិកេតិ ។

[១២៨] ឯកមេកស្ស បញ្ហស្ស យថា ពុទ្ធេន ទេសិតំ
តថា យោ បដិបជ្ជេយ្យ កច្ឆេ ចារំ អចារតោ ។

[១២៩] ឯកមេកស្ស បញ្ហស្សាតិ ឯកមេកស្ស អជិតប្បញ្ហស្ស ឯកមេកស្ស តិស្សមេត្តេយ្យប្បញ្ហស្ស ។ បេ ។ ឯកមេកស្ស បិង្ខិយប្បញ្ហស្សាតិ ឯកមេ-កស្ស បញ្ហស្ស ។

[១៣០] យថា ពុទ្ធេន ទេសិតន្តិ ពុទ្ធោតិ យោ សោ ភគវា ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិ-ទំ ពុទ្ធោតិ ។ យថា ពុទ្ធេន ទេសិតន្តិ យថា ពុទ្ធ-ន អាចិក្ខិតំ ទេសិតំ បញ្ញបិតំ បដ្ឋបិតំ វិវរិតំ វិ-ភត្តំ ឧត្តានីកតំ បកាសិតន្តិ យថា ពុទ្ធេន ទេ-សិតំ ។

ជនទាំងនោះដែលព្រះពុទ្ធទ្រង់ជាផៅពង្សនៃព្រះអាទិត្ស
មានចក្ខុ បានឲ្យត្រេកអរហើយ ក៏បានប្រព្រឹត្តព្រហ្ម-
ចរិយៈ ក្នុងសម្នាក់ព្រះសាស្តា មានប្រាជ្ញាប្រសើរ ។
[១២៨] សេចក្តីនៃប្រស្នាមួយ ៗ ដែលព្រះពុទ្ធសម្តែងហើយ
យ៉ាងណា បើបុគ្គលណាប្រតិបត្តិតាមយ៉ាងនោះ បុគ្គល
នោះ នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយបាន ។

[១២៩] ពាក្យថា នៃប្រស្នាមួយ ៗ គឺនៃប្រស្នាអជិតមាណពមួយ ៗ នៃប្រស្នាតិស្សមេត្តេយ្យមាណពមួយ ៗ ។ បេ ។ នៃប្រស្នាបិङ្គិយមាណពមួយ ៗ ហេតុនោះ (លោកពោលថា) នៃប្រស្នាមួយ ៗ ។

[១៣០] ពាក្យថា ដែលព្រះពុទ្ធសម្តែងហើយ យ៉ាងណា ត្រង់ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធ នេះ (កើត) ព្រោះការត្រាស់ដឹង ។ ពាក្យថា ដែលព្រះពុទ្ធសម្តែងហើយ យ៉ាងណា សេចក្តីថា ដែលព្រះពុទ្ធប្រាប់ សម្តែង តែងតាំងតាំងផ្តើម បើក រៃកញ្ជ្រៃ ធ្វើឲ្យរាក់ ប្រកាសហើយ យ៉ាងណា ហេតុនោះ (លោកពោលថា) ដែលព្រះពុទ្ធសម្តែងហើយ យ៉ាងណា ។

[១៣១] តថា យោ បដិបជ្ជេយ្យាតិ សម្មាបដិ-
បត្តិ អនុលោមប្បដិបត្តិ អបច្ចនីកប្បដិបត្តិ អនុ-
ប្បដិបត្តិ ធម្មានុធម្មប្បដិបត្តិ បដិបជ្ជេយ្យាតិ តថា
យោ បដិបជ្ជេយ្យ ។

[១៣២] កច្ចេ ចារំ អចារតោតិ ចារំ វុច្ចតិ
អមតំ និព្ពានំ យោ សោ សព្ពសង្ខារសមថো ស-
ព្ពុបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ
និព្ពានំ ។ អចារំ វុច្ចន្តិ កិលេសា ច ខន្ធា ច
អភិសង្ខារា ច ។ កច្ចេ ចារំ អចារតោតិ អចារតោ
ចារំ កច្ចេយ្យ ចារំ អនិកច្ចេយ្យ ចារំ ផុសេយ្យ
ចារំ សច្ឆិកយេយ្យាតិ កច្ចេ ចារំ អចារតោ ។
តេនេតំ វុច្ចតិ

[១៣១] *ពាក្យថា បើបុគ្គលណាប្រតិបត្តិតាម យ៉ាងនោះ គឺ បើបុគ្គលប្រតិបត្តិសម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អនុត្តប្បដិបទា ធម្មានុធម្មប្បដិបទា ហេតុនោះ (លោកពោលថា) បើបុគ្គលណាប្រតិបត្តិតាម យ៉ាងនោះ ។*

[១៣២] *ពាក្យថា បុគ្គលនោះនឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ សេចក្តីថា អមតនិព្វាន លោកហៅថា ត្រើយ បានដល់ សេចក្តីរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក សេចក្តីរលត់ និព្វាន ។ កិលេសទាំងឡាយ ខន្ធទាំងឡាយ និងអភិសង្ខារទាំងឡាយ លោកហៅថា ទីមិនមែនត្រើយ ។ ពាក្យថា បុគ្គលនោះ នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ គឺ បុគ្គលនោះនឹងចេញ អំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ បានត្រើយ ពាល់ត្រូវត្រើយ ធ្វើឲ្យជាក់ច្បាស់ត្រើយ ហេតុនោះ (លោកពោលថា) បុគ្គលនោះ នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ ។ ហេតុនោះ លោកពោលពាក្យនេះថា*

១១៧

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

ឯកមេកស្ស បញ្ហស្ស   យថា ពុទ្ធេន ទេសិតំ
តថា យោ បដិបជ្ជេយ្យ   គច្ឆេ បារំ អបារតោតិ ។
[១៣៣] អបារា បារំ គច្ឆេយ្យ   ភាវេន្តោ មគ្គមុត្តមំ
មគ្គោ សោ បារគមនាយ   តស្មា បារាយនំ ឥតិ ។

[១៣៤] អបារា បារំ គច្ឆេយ្យាតិ អបារំ វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ បារំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ អបារា បារំ គច្ឆេយ្យាតិ អបារា បារំ គច្ឆេយ្យ បារំ អធិគច្ឆេយ្យ បារំ ផុសេយ្យ បារំ សច្ឆិករេយ្យាតិ អបារា បារំ គច្ឆេយ្យ ។

សេចក្ដីនៃប្រស្នាមួយ ៗ ដែលព្រះពុទ្ធសម្ដែងហើយ យ៉ាងណា បើបុគ្គលណាប្រតិបត្តិតាម យ៉ាងនោះ បុគ្គលនោះ នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយបាន ។

[១៣៣] បុគ្គលកាលចម្រើនមគ្គដ៏ឧត្តម នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយបាន មគ្គនោះតែងប្រព្រឹត្តទៅដើម្បីទៅកាន់ត្រើយ ហេតុនោះ មគ្គ (លោកពោលថា) បារាយនៈ ដោយប្រការដូច្នេះ ។

[១៣៤] ពាក្យថា នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ សេចក្ដីថា កិលេសទាំងឡាយ ខន្ធទាំងឡាយ និងអភិសង្ខារទាំងឡាយ លោកហៅថា ទីមិនមែនត្រើយ ។ អមតនិព្វាន លោកហៅថា ត្រើយ បានដល់សេចក្ដីរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា សេចក្ដីប្រាសចាកតម្រេក សេចក្ដីរលត់ និព្វាន ។ ពាក្យថា នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ បានសេចក្ដីថា នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ បានត្រើយ ពាល់ត្រើយ ធ្វើឲ្យជាក់ច្បាស់នូវត្រើយ ហេតុនោះ (លោកពោលថា) នឹងចេញអំពីទីមិនមែនត្រើយទៅកាន់ត្រើយ ។

[១៣៥] ភាវេន្តោ មក្គមុត្តមន្តិ មក្គន្តិ មគ្គោ រុច្ចតិ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្ម-ាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ឧត្តមន្តិ អគ្គំ សេ-ដ្ឋំ វិសេដ្ឋំ ចាមោក្ខំ ឧត្តមំ បវរន្តិ មក្គមុត្តមំ ។ ភាវេន្តោតិ ភាវេន្តោ អាសេវន្តោ ពហុលីករោន្តោតិ ភាវេន្តោ មក្គមុត្តមំ ។

[១៣៦] មគ្គោ សោ ចារកមជាយាតិ មគ្គោ បន្ថោ បថো បជ្ជោ អញ្ជសំ វដុមាយនំ ណាវ ឧត្ត-រសេតុ បតុ្ថ សង្ក្រមោ ។ ចារកមជាយាតិ ចារ-កមជាយ ចារសម្ជាបជាយ ចារសមជុចាបជាយ ជរាមរណាស្ស តរណាយាតិ មគ្គោ សោ ចារកម-ជាយ ។

[១៣៧] តស្ម ចារយនំ ឥតីតិ តស្មាតិ តស្ម តំការណា តំហេតុ តប្ប ច្ចយា តំនិទានា ។

[១៣៥] ពាក្យថា មគ្គ ក្នុងបទថា កាលចម្រើនមគ្គ ដ៏ឧត្តម សេចក្តីថា មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺ ប្រាជ្ញាយល់ឃើញត្រូវ ។ បេ ។ ការតម្កល់ចិត្តឲ្យនឹងត្រូវ លោកហៅថា មគ្គ ។ ពាក្យថា ដ៏ឧត្តម គឺ ដ៏លើស ដ៏ប្រសើរ ដ៏ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្នូ ហេតុនោះ (លោកពោលថា) មគ្គដ៏ឧត្តម ។ ពាក្យថា កាលចម្រើន គឺ កាលចម្រើន កាលសេព កាលធ្វើឲ្យច្រើន ហេតុនោះ (លោកពោលថា) កាលចម្រើនមគ្គដ៏ឧត្តម ។

[១៣៦] ពាក្យថា មគ្គនោះតែងប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រើយ សេចក្តីថា ឈ្មោះថាមគ្គបានដល់ តម្រាយ គន្ធង ប្រទេសសម្រាប់ទៅ ដោយជើង ទីសម្រាប់ដើរ ទីសម្រាប់ដើរទៅដើរមក ទូក ស្ពានសម្រាប់ឆ្លងផែ ពោងពាយ ។ ពាក្យថា ដើម្បីទៅកាន់ត្រើយ គឺ ដើម្បីទៅកាន់ត្រើយ ដើម្បីដល់ព្រមនូវត្រើយ ដើម្បីដល់ធាប់នូវត្រើយ គឺថាដើម្បីឆ្លងជរានិងមរណៈ ហេតុនោះ (លោកពោលថា) មគ្គនោះតែងប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រើយ ។

[១៣៧] ពាក្យថា ហេតុនោះ ក្នុងបទថា ហេតុនោះ (លោកពោលថា) បាវាយនៈ ដោយប្រការដូច្នេះ គឺ ព្រោះហេតុនោះ ព្រោះដំណើរនោះ ព្រោះដូច្នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ។

ចារំ វុច្ចតិ អមតំ និព្ពានំ យោ សោ សព្ពសង្ខារ-
សមថো សព្ពុបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរ-
គោ និរោធោ និព្ពានំ ។ អាយនំ វុច្ចតិ មគ្គោ ។
ឥតីតិ បឋមត្ថ ។ បេ ។ បជានុបុព្ពកមេតំ ឥតីតិ
តស្មា ចារាយនំ ឥតិ ។ តេនេតំ វុច្ចតិ

អចារ ចារំ តច្ឆេយ្យ ភាវេន្តោ មគ្គមុត្តមំ
មគ្គោ សោ ចារតមនាយ តស្មា ចារាយនំ ឥតីតិ ។

[១៣៨] ចារាយនមនុតាយិស្សុ (ឥច្ចាយស្ម បិង្គិយោ)

(យថា អទ្ធក្ខិ តថា អក្ខាសិ)

រិមលោ ភូរិមេធសោ
និក្ខ្លាមោ និព្ពនោ ឌាតោ
ភិស្ស ហេតុ មុសា ភណោ ។

អមតនិព្វាន លោកហៅថា ត្រើយ បានដល់សេចក្តីរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា សេចក្តីប្រាសចាកតម្រេក សេចក្តីរលត់ និព្វាន ។ មគ្គ លោកហៅថា អាយនៈ ។ ពាក្យថា ដោយប្រការដូច្នេះ គឺជាការតបទ ។ បេ ។ ពាក្យថា ដូច្នេះ ទុំៈជាលំដាប់បទ ហេតុនោះ (លោកពោលថា) បាវាយនៈ ដោយប្រការដូច្នេះ ។ ហេតុនោះ លោកពោលពាក្យនេះថា

បុគ្គលកាលចម្រើនមគ្គដ៏ឧត្តម នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយបាន មគ្គនោះតែងប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រើយ ហេតុនោះ មគ្គ (លោកពោលថា) បាវាយនៈ ដោយប្រការដូច្នេះ ។

[១៣៨] (បិង្គិយៈមានអាយុពោលដូច្នោះថា) ខ្ញុំនឹងច្រៀងតាមបាវាយនៈ ព្រះមានព្រះភាគ ព្រះអង្គមានមន្ទិលគឺកិលេសទៅប្រាសហើយ មានប្រាជ្ញាដូចផែនដី មានកាមចេញហើយ មានព្រៃចេញហើយ ជាព្រះពុទ្ធនាគ (ទ្រង់ឃើញហើយយ៉ាងណា ទ្រង់ពោលយ៉ាងនោះ) ទ្រង់នឹងពោលមុសាព្រោះហេតុដូចម្តេចកើត ។

[១៣៩] ចារាយនមនុតាយិស្សន្តិ តីតមនុតាយិ-
ស្សំ កាថិតមនុតាយិស្សំ លបិតមនុតាយិស្សំ ភាសិ-
តមនុតាយិស្សន្តិ ចារាយនមនុតាយិស្សំ ។ ឥច្ចាយ-
ស្មា បិដ្ឋិយោតិ ឥច្ចាតិ បឧសន្ធិ ។ បេ ។ បជានុបុព្ព-
ការមេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវចនំ ការុវចនំ
សការវសប្ឋតិសប្ឋាជិវចនមេតំ អាយស្មាតិ ។ បិដ្ឋិ-
យោតិ ឥស្ស ជេវស្ស ជាមំ សង្ខា សមញ្ញា ប-
ញ្ញត្តិ ហេហាហេ ជាមំ ជាមការ្ម ជាមជេយ្យ និរុត្តិ
ព្យញ្ជនំ អភិលាបោតិ ឥច្ចាយស្ម បិដ្ឋិយោ ។

[១៤០] យថា អជ្ជក្ខិ ឥថា អក្ខាសីតិ យថា
អជ្ជក្ខិ ឥថា អក្ខាសិ អាចិក្ខិ ជេសេសិ
បញ្ញបេសិ បជ្ជបេសិ វិវរិ វិភជិ ឧត្តានីមការ
បការសេសិ សព្ជ សង្ខារ អនិច្ចាតិ ។ បេ ។

[១៣៩] ពាក្យថា ខ្ញុំនឹងច្រៀងតាមបាវយនៈ គឺ ខ្ញុំនឹងច្រៀងតាមចម្រៀង នឹងច្រៀងតាមកាសិតដែលព្រះមានព្រះភាគសម្តែងហើយ នឹងច្រៀងតាមកាសិត ដែលព្រះមានព្រះភាគពោលហើយ នឹងច្រៀងតាមកាសិត (របស់ព្រះមានព្រះភាគ) ហេតុនោះ (លោកពោលថា) ខ្ញុំនឹងច្រៀងតាមបាវយនៈ ។ ពាក្យថា ដូច្នោះ ក្នុងបទថា បិង្គិយៈមានអាយុ ពោលដូច្នេះ គឺជាការតបទ ។ បេ ។ ពាក្យថា ដូច្នេះ នុ៎ះជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យពោលដោយគោរព ពាក្យថា មានអាយុ នុ៎ះ ជាពាក្យពោលដោយការគោរពកោតក្រែង ។ ពាក្យថា បិង្គិយៈ គឺ ជាឈ្មោះ ជាពាក្យសម្រាប់រាប់ ជាគ្រឿងសម្គាល់ ជាបញ្ញត្តិ ជាវោហារ ជានាម ជានាមកម្ម ជានាមប្បញ្ញត្តិ ជាសម្តី ជាគ្រឿងបញ្ជាក់ ជាគ្រឿងប្រកាស នៃព្រះថេរៈនោះ ហេតុនោះ (លោកពោលថា) បិង្គិយៈមានអាយុពោលដូច្នេះ ។

[១៤០] ពាក្យថា ទ្រង់ឃើញយ៉ាងណា ទ្រង់ពោលយ៉ាងនោះ គឺ ទ្រង់ឃើញយ៉ាងណា ទ្រង់ពោល ប្រាប់ សម្តែង តែងតាំង តាំងផ្តើម បើកដែកញ្ជែក ធ្វើឲ្យរាក់ ប្រកាស យ៉ាងនោះថា សង្ខារទាំងពួងមិនទៀង ។ បេ ។

យញ្ជ្ជិញ្ជ សមុទយធម្មំ សព្វន្តំ ជិរោធធម្មន្តិ យថា អជ្ជក្ខិ តថា អក្ខាសិ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីមការិ បការេសីតិ យថា អជ្ជក្ខិ តថា អក្ខាសិ ។

[១៤១] វិមលោ ភូរិមេធសោតិ វិមលោតិ ក-តោ មលំ ទោសោ មលំ មោហោ មលំ កោ-ធោ មលំ ឧបនាហោ មលំ ។ បេ ។ សព្វាកុស-លាភិសង្ខ្ជារ មលា ។ តេ មលា ពុទ្ធ្ធស្ស ភគវ-តោ បហីនា ឧច្ឆិន្ទមូលា តាលាវត្ថុកតា អនភាវ-ត្ត អាយតឺអនុប្ប្ជាធធម្ម តស្ម ពុទ្ធ្ធ អមលោ វិ-មលោ ជិម្ម្ជលោ មលាបកតោ មលវិប្ជហីនោ មល-វិប្ជមុត្តោ សព្វមលវីតិវត្តោ ។ ភូរិ ១ុ១ូ១ិ ១ប១ី ។

ធម្មជាតឯណានីមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់ នោះមានកិរិយារលត់ទៅវិញជាធម្មតា ទ្រង់ឃើញយ៉ាងណា ទ្រង់ពោលប្រាប់ សម្តែង តែងតាំង តាំងផ្តើម បើក រៃកញ្ជែក ធ្វើឲ្យរាក់ ប្រកាសហើយ យ៉ាងនោះ ហេតុនោះ (លោកពោលថា) ទ្រង់ឃើញយ៉ាងណា ទ្រង់ពោលយ៉ាងនោះ ។

[១២១] អធិប្បាយពាក្យថា មានមន្ទិលទៅប្រាសហើយ មានប្រាជ្ញាដូចផែនដី ត្រង់ពាក្យថា មានមន្ទិលទៅប្រាសហើយ សេចក្តីថា រាគ:ឈ្មោះថាមន្ទិល ទោស:ឈ្មោះថាមន្ទិល មោហ:ឈ្មោះថាមន្ទិល ក្រោធឈ្មោះថាមន្ទិល ការចងក្រោធទុក ឈ្មោះថាមន្ទិល ។ បេ ។ អកិសង្ខារ ជាអកុសលទាំងពួង ឈ្មោះថាមន្ទិល ។ មន្ទិលទាំងនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់លះបង់ កាត់ផ្តាច់ឫសចេញ ហើយ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន មានកិរិយាមិនកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធឈ្មោះថាមិនមានមន្ទិល មានមន្ទិលទៅប្រាសហើយ ដ៏ស្អាតចាកមន្ទិល ប្រាសចាកមន្ទិល លះបង់មន្ទិល រួចស្រឡះចាកមន្ទិល ប្រព្រឹត្តកន្ទង នូវមន្ទិលទាំងពួង ។ ប្រឹថពី លោកហៅថា ផែនដី ។

ភគវា ឥមាយ បឋវីសមាយ វិបុលាយ វិត្ថតាយ បញ្ញាយ សមន្នាគតោ ។ មេធា វុច្ចតិ បញ្ញា យា បញ្ញា បជានណា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ ភគវា ឥមាយ មេធាយ បញ្ញាយ ឧបេ-តោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា ពុទ្ធោ ភូរិមេធ-សោតិ រិមសោ ភូរិមេធសោ ។

[១៤២] និក្ខាមោ និព្ពានោ ធាតោតិ ឥមានិ ឧច្ចានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកា-មា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ ពុទ្ធស្ស ភគវតោ វត្ថុកាមា បរិញ្ញាតា កិលេសកាមា បហីនា ។ វត្ថុកាមានំ បរិញ្ញាតត្តា កិលេសកាមានំ បហីនត្តា ភគវា ន កាមេ កាមេតិ ន កាមេ បត្ថេតិ ន កាមេ បិហេតិ ន កាមេ អភិជ្ឈតិ ។

ព្រះមានព្រះភាគ ប្រកបព្រមហើយ ដោយប្រាជ្ញាដ៏ធំទូលាយ ស្មើ ដោយប្រឹថពីនេះ ។ ប្រាជ្ញា លោកហៅថា មេធា បានដល់បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្តីឃើញត្រូវ ។ ព្រះមានព្រះភាគ អែប អែបនៃប កប ប្រកប ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រម ដោយមេធាគឺប្រាជ្ញានេះ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមានប្រាជ្ញាដូចផែនដី ហេតុនោះ (លោកពោលថា) មានមន្ទិលទៅប្រាសហើយ មានប្រាជ្ញាដូចផែនដី ។

[១៦២] *អធិប្បាយពាក្យថា* មានកាមចេញហើយ មានព្រៃចេញហើយ ជាព្រះពុទ្ធនាគ ត្រង់ពាក្យថា កាម បើពោលតាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះ លោកហៅថា វត្ថុកាម ។ បេ ។ ទាំងនេះ លោកហៅថា កិលេសកាម ។ វត្ថុកាម ព្រះពុទ្ធមានព្រះភាគកំណត់ដឹងហើយ កិលេសកាម ទ្រង់លះបង់ហើយ ។ ព្រោះទ្រង់កំណត់ដឹងវត្ថុកាម ព្រោះទ្រង់លះកិលេសកាម ព្រះមានព្រះភាគ ឈ្មោះថាមិនប្រាថ្នាកាមទាំងឡាយ មិនចង់បានកាមទាំងឡាយ មិនស្រឡាញ់កាមទាំងឡាយ មិនជាប់ព្រះហឫទ័យនឹងកាមទាំងឡាយ ។

យេ កាមេ កាមេន្តិ កាមេ បត្ថេន្តិ កាមេ បិហយន្តិ
កាមេ អភិជប្បន្តិ តេ កាមកាមិនោ ភតភតិនោ
សញ្ញសញ្ញិនោ ។ ភតវា ន កាមេ កាមេតិ ន
កាមេ បត្ថេតិ ន កាមេ បិហេតិ ន កាមេ អ-
ភិជប្បតិ តស្មា ពុទ្ធោ អកាមោ និក្កាមោ ចត្តកា-
មោ វន្តកាមោ មុត្តកាមោ បហីនកាមោ បដិនិស្ស-
ដ្ឋកាមោ វីតរាគោ វិតតរាគោ ចត្តរាគោ វន្តរាគោ
មុត្តរាគោ បហីនរាគោ បដិនិស្សដ្ឋរាគោ និច្ឆោ
និព្ពុតោ សីតភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន
អត្តនា វិហរតីតិ និក្កាមោ ។ និព្ពុតោតិ រាគោ វុំ
ដោសោ វុំ មោហោ វុំ កោដោ វុំ ឧបនាហោ
វុំ ។ បេ ។ សព្ពាកុសលាភិសង្ខារា វូបា ។ តេ វូបា
ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា

ជនទាំងឡាយណា នៅប្រាថ្នាកាមទាំងឡាយ ចង់បានកាមទាំងឡាយ ស្រឡាញ់កាមទាំងឡាយ ជាប់ចិត្តនឹងកាមទាំងឡាយ ជនទាំងឡាយនោះ ឈ្មោះថាមានសេចក្តីប្រាថ្នាកាម មានសេចក្តីរីករាយដោយរាគ: មានសេចក្តីសម្គាល់ដោយកាមសញ្ញា ។ ព្រះមានព្រះភាគ មិនប្រាថ្នាកាមទាំងឡាយ មិនចង់បានកាមទាំងឡាយ មិនស្រឡាញ់កាមទាំងឡាយ មិនជាប់ព្រះហឫទ័យនឹងកាមទាំងឡាយ ហេតុនោះ ព្រះពុទ្ធឈ្មោះថាមិនមានកាម មានកាមចេញហើយ ចាលកាម ខ្ជាក់កាម លៃងកាម លះកាម រលាស់ចាលកាម ប្រាសចាករាគ: មានរាគ:ទៅបាត់ហើយ ចាលរាគ: ខ្ជាក់រាគ: លៃងរាគ: លះរាគ: រលាស់ចាលរាគ: ប្រាសចាកសេចក្តីប្រាថ្នា មានទុក្ខរលត់ហើយ មានសេចក្តីត្រជាក់កើតហើយ សោយសុខ មានខ្លួនដូចជាព្រហ្ម សម្រេចសម្រាន្តនៅ ហេតុនោះ (លោកពោលថា) មានកាមចេញហើយ ។ ពាក្យថា មានព្រៃចេញហើយ សេចក្តីថា រាគ:ឈ្មោះថាព្រៃ ទោស:ឈ្មោះថាព្រៃ មោហ:ឈ្មោះថាព្រៃ ក្រោធឈ្មោះថាព្រៃ ការចងក្រោធទុកឈ្មោះថាព្រៃ ។ បេ ។ អកិ-សង្ខារជាអកុសលទាំងពួងឈ្មោះថាព្រៃ ។ ព្រៃទាំងនោះ ព្រះពុទ្ធមានព្រះភាគលះបង់ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យមានទីនៅដូចជាទីនៅនៃដើមត្នោត

អនភាវង្គតា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ អវ-ដោ និព្វុដោ វដាបគតោ វដវិប្បហីនោ វដវិប្បមុត្តោ សព្វវដវីតិវត្តោតិ និព្វុដោ ។ ដាគោតិ ភគវា អាគុំ ន ករោតីតិ ដាគោ ។ ន គច្ឆតីតិ ដាគោ ។ ន អាគច្ឆតីតិ ដាគោ ។ បេ ។ ឯវំ ភគវា ន អាគច្ឆតីតិ ដាគោតិ និក្ខាមោ និព្វុដោ ដាគោ ។

[១៤៣] កិស្ស ហេតុ មុសា ភណេតិ កិស្ស ហេតូតិ កិស្ស ហេតុ កឹការណា កឹបច្ចយាតិ កិស្ស ហេតុ ។ មុសា ភណេតិ មោសវជ្ជំ ភ-ណេយ្យ មុសាវាទំ ភណេយ្យ អនរិយវាទំ ភណេ-យ្យ ។ ឥធេកច្ចោ សភគ្គតោ វា បរិសគ្គតោ វា ញាតិមជ្ឈគតោ វា[១] រាជកុលមជ្ឈគតោ វា អភិនី-តោ សក្ខិបុដ្ឋោ ឯហិ ភោ បុរិស យំ ជានាសិ តំ

១ ម. ឯត្ថន្តរេ បូគមជ្ឈគតោវាតិ បាឋោ ទិស្សតិ ។

ឲ្យដល់នូវការមិនមានទីកើត មានកិរិយាមិនកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមិនមានព្រៃ មានព្រៃចេញហើយ ប្រាសចាកព្រៃ លះបង់ព្រៃ រួចស្រឡះចាកព្រៃ ប្រព្រឹត្តកន្ទ្ធងព្រៃទាំងអស់ ហេតុនោះ (លោកពោលថា) មានព្រៃចេញហើយ ។ ពាក្យថា ព្រះពុទ្ធនាគ គឺ ព្រះមានព្រះភាគ ឈ្មោះថានាគ ព្រោះហេតុទ្រង់មិនធ្វើអំពើអាក្រក់ ។ ឈ្មោះថានាគ ព្រោះហេតុទ្រង់មិនលុះ ។ ឈ្មោះថានាគ ព្រោះហេតុ ទ្រង់មិនមក ។ បេ ។ ព្រះមានព្រះភាគ ឈ្មោះថានាគ ព្រោះហេតុ ទ្រង់មិនមក យ៉ាងនេះ ហេតុនោះ (លោកពោលថា) មានកាមចេញ ហើយ មានព្រៃចេញហើយ ជាព្រះពុទ្ធនាគ ។

[១២៣] អធិប្បាយពាក្យថា គប្បីពោលមុសា ព្រោះហេតុដូច ម្តេចកើត ត្រង់ពាក្យថា ព្រោះហេតុដូចម្តេចកើត គឺ ព្រោះហេតុអ្វី ព្រោះការណ៍អ្វី ព្រោះបច្ច័យអ្វី ហេតុនោះ (លោកពោលថា) ព្រោះ ហេតុដូចម្តេចកើត ។ ពាក្យថា គប្បីពោលមុសា គឺគប្បីពោលពាក្យមុសា ពោលមុសាវាទ ពោលពាក្យមិនប្រសើរ ។ បុគ្គលពួកខ្លះ ក្នុងលោក នេះ ទៅក្នុងទីប្រជុំក្តី នៅក្នុងបរិសទ្យក្តី ទៅក្នុងកណ្តាលពួកញាតិក្តី ទៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេកោះទៅសួរជាសាក្សីថា ម្នាល បុរសដ៏ចម្រើន អ្នកចូរមក អ្នកដឹងហេតុណា ចូរពោលហេតុនោះ

វទេហីតិ អជានំ អាហ ជានាមីតិ ជានំ វា អាហ ន ជានាមីតិ អបស្សំ វា អាហ បស្សាមីតិ បស្សំ វា អាហ ន បស្សាមីតិ ឥតិ អត្តហេតុ វា បរហេតុ វា អាមិសកិញ្ចិក្ខហេតុ វា សម្បជានមុសា ភណាតិ ឥទំ វុច្ចតិ មោសវជ្ជំ ។ អបិច តីហាការេហិ មុសាវាទោ ហោតិ បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិតន្តិ ឥមេហិ តីហាការេហិ មុសាវាទោ ហោតិ ។ អបិច ចតូហាការេហិ មុសាវាទោ ហោតិ បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ។ បេ ។ បញ្ចហាការេហិ ឆហាការេហិ សត្តហាការេហិ អដ្ឋហាការេហិ មុសាវាទោ ហោតិ បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិតន្តិ វិនិធាយ ទិដ្ឋឹ វិនិធាយ ខន្តឹ វិនិធាយ រុចឹ វិនិធាយ សញ្ញំ វិនិធាយ ភាវំ ឥមេហិ អដ្ឋហាការេហិ មុសាវាទោ ហោតិ ។

កាលមិនដឹង ពោលថាខ្ញុំដឹងក្តី កាលដឹង ពោលថាខ្ញុំមិនដឹងក្តី កាលមិនឃើញ ពោលថាខ្ញុំឃើញក្តី កាលឃើញ ពោលថាខ្ញុំមិនឃើញក្តី ពោលសម្បជានមុសាវាទ ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះហេតុតែសំណូកណាមួយក្តី នេះលោកហៅថា ពាក្យមុសា ។ មួយទៀត ការពោលមុសាដោយអាការ ៣ គឺ មុនដំបូង មុសាវាទរបស់បុគ្គលនោះថា អញនឹងពោលមុសា ១ មុសាវាទរបស់បុគ្គលកំពុងពោលថា អញកំពុងពោលមុសា ១ មុសាវាទរបស់បុគ្គលពោលរួចហើយថា អញពោលមុសាហើយ ១ នេះការពោលមុសា ដោយអាការ ៣ ។ មួយទៀត ការពោលមុសា ដោយអាការ ៤ យ៉ាង គឺ មុនដំបូង មុសាវាទរបស់បុគ្គលនោះថា អញនឹងពោលមុសា ១ ។ បេ ។ ការពោលមុសាដោយអាការ ៥ ដោយអាការ ៦ ដោយអាការ ៧ ដោយអាការ ៨ គឺ មុនដំបូង មុសាវាទរបស់បុគ្គលនោះថា អញនឹងពោលមុសា ១ មុសាវាទរបស់បុគ្គលកំពុងពោលថា អញកំពុងពោលមុសា ១ មុសាវាទរបស់បុគ្គលពោលរួចហើយថា អញពោលមុសាហើយ ១ ពោលបិទបាំងទិដ្ឋិ ១ បិទបាំងខន្តី ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសញ្ញា ១ បិទបាំងសេចក្តីពិត ១ នេះការពោលមុសាដោយអាការ ៨ ។

កិស្ស ហេតុ មុសា ភណេយ្យ កថេយ្យ ទីបេយ្យ វោហរេយ្យាតិ កិស្ស ហេតុ មុសា ភណេ ។ តេ-នាហ បិង្គិយត្ថេរោ

ចារាយនមនុកាយិស្សំ (ឥច្ចាយស្មា បិង្គិយោ)
(យថា អទ្ទក្ខិ តថា អក្ខាសិ)
វិមលោ ភូរិមេធសោ
និក្កាមោ និព្វនោ នាគោ
កិស្ស ហេតុ មុសា ភណេតិ ។

[១៤៤] បហីនមលមោហស្ស មានមក្ខប្បហាយិនោ
ហន្ទាហំ កិត្តយិស្សាមិ គិរំ វណ្ណូបសញ្ហិតំ ។

[១៤៥] បហីនមលមោហស្សាតិ មលាតិ រាគោ មលំ ទោសោ មលំ មោហោ មលំ មានោ មលំ ទិដ្ឋិ មលំ កិលេសោ មលំ សព្វទុច្ចរិតំ មលំ ។ មោហោតិ ទុក្ខេ អញ្ញាណំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ មោហោ ។

ព្រះអង្គគប្បីពោល និយាយ សម្តែង ថ្លែងនូវមុសា ព្រោះហេតុ ម្តេចបាន ហេតុនោះ (លោកពោលថា) គប្បីពោលមុសា ព្រោះហេតុដូច ម្តេចកើត ។ ហេតុនោះ បិङ្គិយត្តេរពោលថា

(បិङ្គិយមានអាយុ ពោលដូច្នេះថា) ខ្ញុំនឹងច្រៀងតាម បាវាយនៈ ព្រះមានព្រះភាគ ព្រះអង្គមានមន្ទិលគឺកិលេស ទៅប្រាសហើយ មានប្រាជ្ញាដូចផែនដី មានកាមចេញហើយ មានព្រៃចេញហើយ ជាព្រះពុទ្ធនាគ (ទ្រង់ឃើញហើយ យ៉ាងណា ទ្រង់ពោលយ៉ាងនោះ) ទ្រង់គប្បីពោលមុសា ព្រោះហេតុដូចម្តេចកើត ។

[១៤៤] បើដូច្នោះ ខ្ញុំនឹងសម្តែងពាក្យ ដ៏ប្រកបដោយគុណ របស់ព្រះមានព្រះភាគ ព្រះអង្គលះបង់មន្ទិលនិងមោហៈ ហើយ លះបង់មានៈនិងមក្ខៈហើយ ។

[១៤៥] អធិប្បាយពាក្យថា ព្រះអង្គលះបង់មន្ទិលនិងមោហៈហើយ ត្រង់ពាក្យថា មន្ទិល បានដល់ រាគៈ ឈ្មោះថាមន្ទិល ទោសៈឈ្មោះ ថាមន្ទិល មោហៈ ឈ្មោះថាមន្ទិល មានៈ ឈ្មោះថាមន្ទិល ទិដ្ឋិឈ្មោះ ថាមន្ទិល កិលេសឈ្មោះថាមន្ទិល ទុច្ចរិតទាំងពួង ឈ្មោះថាមន្ទិល ។ ពាក្យថា មោហៈ គឺ ការមិនដឹងក្នុងកងទុក្ខ ។ បេ ។ បង្គោល គឺអវិជ្ជា សេចក្តីវង្វេង ឫសនៃអកុសល នេះលោកហៅថា មោហៈ ។

មលញ្ច មោហោ ច ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្គតា អាយតឹអ-ណុប្បាទធម្មា តស្មា ពុទ្ធោ បហីនមលមោហោតិ បហីនមលមោហស្ស ។

[១៤៦] មានមក្ខូប្ប្ហាយិនោតិ មានាតិ ឯកវិធេន មានោ យា ចិត្តស្ស ឧណ្ណតិ ។ ទុវិធេន មានោ អត្តុក្កំសនមានោ បរវម្ភនមានោ ។ តិវិធេ-ន មានោ សេយ្យោហមស្មីតិ មានោ សទិសោហ-មស្មីតិ មានោ ហីនោហមស្មីតិ មានោ ។ ចតុព្ពិ-ធេន មានោ លាភេន មានំ ជនេតិ យសេន មា-នំ ជនេតិ បសំសាយ មានំ ជនេតិ សុខេន មានំ ជនេតិ ។ បញ្ចវិធេន មានោ លាភិម្ហិ មទាបិ ការានំ រូចានន្តិ មានំ ជនេតិ លាភិម្ហិ មទាបិ ការានំ សក្ខានំ ឥន្ធានំ រសានំ ផោដ្ឋព្ពានន្តិ មានំ ជនេតិ ។

មន្ទិលនិងមោហ: ព្រះពុទ្ធមានព្រះភាគបានលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យមានតែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន មិនឲ្យមានកិរិយាកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធឈ្មោះថាមានមន្ទិលនិងមោហ:លះបង់ហើយ ហេតុនោះ (លោកពោលថា) ព្រះអង្គលះបង់មន្ទិលនិងមោហ:ហើយ ។

[១៨៦] *អធិប្បាយពាក្យថា លះបង់មានៈនិងមក្ខ:ហើយ ត្រង់ពាក្យថា មានៈ សេចក្តីថា មានៈដោយប្រការមួយ បានដល់ការប៉ោងឡើងនៃចិត្ត ។ មានៈដោយប្រការ ២ គឺមានៈដោយការលើកតម្កើងខ្លួន ១ មានៈដោយការបន្ទុះបង្ហាប់អ្នកដទៃ ១ ។ មានៈដោយប្រការ ៣ គឺ មានៈថាអញជាបុគ្គលប្រសើរ ១ មានៈថាអញជាបុគ្គលស្មើ ១ មានៈថាអញជាបុគ្គលថោកទាប ១ ។ មានៈដោយប្រការ ៤ គឺបុគ្គលញ៉ាំងមានៈឲ្យកើតព្រោះលាភ ១ ញ៉ាំងមានៈឲ្យកើតព្រោះយស ១ ញ៉ាំងមានៈឲ្យកើតព្រោះសេចក្តីសរសើរ ១ ញ៉ាំងមានៈឲ្យកើតព្រោះសុខ ១ ។ មានៈដោយប្រការ ៥ គឺ បុគ្គលញ៉ាំងមានៈឲ្យកើតថា អញបានរូបជាទីគាប់ចិត្ត ១ ញ៉ាំងមានៈឲ្យកើតថាអញបានសំឡេង ១ ក្លិន ១ រស ១ ផ្សព្វជាទីគាប់ចិត្ត ១ ។*

ធញ្ញិនេន មានោ ចក្ខុសម្ផ្ទាយ មានំ ជនេតិ
សោតសម្ផ្ទាយ ឃានសម្ផ្ទាយ ជិវ្ហាសម្ផ្ទាយ
កាយសម្ផ្ទាយ មនោសម្ផ្ទាយ មានំ ជនេតិ ។
សត្តវិនេន មានោ មានោ អតិមានោ មានាតិមានោ
ឱមានោ អវមានោ[១] អស្មិមានោ មិច្ឆាមានោ ។ អដ្ឋ-
វិនេន មានោ លាភេន មានំ ជនេតិ អលាភេន
ឱមានំ ជនេតិ យសេន មានំ ជនេតិ អយសេន
ឱមានំ ជនេតិ បសំសាយ មានំ ជនេតិ និន្ទាយ
ឱមានំ ជនេតិ សុខេន មានំ ជនេតិ ទុក្ខេន
ឱមានំ ជនេតិ ។ នវវិនេន មានោ សេយ្យស្ស
សេយ្យោហមស្មីតិ មានោ សេយ្យស្ស សទិសោហ-
មស្មីតិ មានោ សេយ្យស្ស ហីនោហមស្មីតិ មានោ

---

១ អដ្ឋកថាយំ អធិមានោតិ ទិស្សតិ ។

មានៈដោយប្រការ ៦ គឺ បុគ្គលញ៉ាំងមានៈឲ្យកើត ព្រោះការបរិបូណ៌ដោយចក្ខុ ១ ញ៉ាំងមានៈឲ្យកើត ព្រោះការបរិបូណ៌ដោយសោតៈ ១ ព្រោះការបរិបូណ៌ដោយឃានៈ ១ ព្រោះការបរិបូណ៌ដោយជិវ្ហា ១ ព្រោះការបរិបូណ៌ដោយកាយ ១ ព្រោះការបរិបូណ៌ដោយមនៈ ១ ។ មានៈដោយប្រការ ៧ គឺ ការក្រអឺតក្រអោង ១ ការប្រកាន់គ្រាន់ ១ ការមើលងាយដោយសេចក្ដីប្រកាន់ ១ ការប្រកាន់ទាប ១ ការប្រកាន់ថោក ១ ការប្រកាន់ថាអញមាន ១ ការប្រកាន់ខុស ១ ។ មានៈដោយប្រការ ៨ គឺ បុគ្គលញ៉ាំងការក្រអឺតក្រអោងឲ្យកើតព្រោះលាភ ១ ញ៉ាំងការប្រកាន់ទាបឲ្យកើត ព្រោះការមិនមានលាភ ១ ញ៉ាំងការក្រអឺតក្រអោងឲ្យកើតព្រោះយស ១ ញ៉ាំងការប្រកាន់ទាបឲ្យកើតព្រោះការមិនមានយស ១ ញ៉ាំងការក្រអឺតក្រអោងឲ្យកើតព្រោះសេចក្ដីសរសើរ ១ ញ៉ាំងការប្រកាន់ទាបឲ្យកើតព្រោះសេចក្ដីតិះដៀល ១ ញ៉ាំងការក្រអឺតក្រអោងឲ្យកើតព្រោះសុខ ១ ញ៉ាំងការប្រកាន់ទាបឲ្យកើតព្រោះទុក្ខ ១ ។ មានៈដោយប្រការ ៩ គឺ បុគ្គលអ្នកខ្ពង់ខ្ពស់មានមានៈថា អញខ្ពង់ខ្ពស់ជាងគេ ១ បុគ្គលអ្នកខ្ពង់ខ្ពស់ មានមានៈថា អញស្មើ ១ បុគ្គលអ្នកខ្ពង់ខ្ពស់មានមានៈថា អញថោកទាប ១

សទិសស្ស សេយ្យោហមស្មីតិ មានោ សទិសស្ស
សទិសោហមស្មីតិ មានោ សទិសស្ស ហីនោហម-
ស្មីតិ មានោ ហីនស្ស សេយ្យោហមស្មីតិ មានោ
ហីនស្ស សទិសោហមស្មីតិ មានោ ហីនស្ស ហីនោ-
ហមស្មីតិ មានោ ។ ឯសវិធេន មានោ ឥធេកច្ចោ
មានំ ជនេតិ ជាតិយា វា គោត្តេន វា កោលបុត្តិ-
យេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេ-
ន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេ-
ន វា សុតេន វា បដិភាណេន វា អញ្ញតរញ្ញតរេន វា
វត្ថុនា យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណ-
តិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្ត-
ស្ស អយំ វុច្ចតិ មានោ ។ មក្ខាតិ មក្ខោ មក្ខាយ-
នា មក្ខាយិតត្តំ និដ្ឋុរិយកម្មំ អយំ វុច្ចតិ មក្ខោ ។
ពុទ្ធស្ស ភគវតោ មានោ ច មក្ខោ ច បហីនា ឧច្ឆិ-
ន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បា-
ទធម្មា តស្មា ពុទ្ធោ មានមក្ខប្បហាយីតិ មានមក្ខ-
ប្បហាយិនោ ។

បុគ្គលអ្នកស្មើនឹងគេមានមានៈថាអញខ្ពង់ខ្ពស់ ១ បុគ្គលអ្នកស្មើនឹងគេមានមានៈថាអញស្មើ ១ បុគ្គលអ្នកស្មើនឹងគេមានមានៈថាអញថោកទាប១ បុគ្គលអ្នកថោកទាបមានមានៈថាអញខ្ពង់ខ្ពស់ ១ បុគ្គលអ្នកថោកទាបមានមានៈថាអញស្មើ ១ បុគ្គលអ្នកថោកទាបមានមានៈថាអញថោកទាប ១ ។ មានៈដោយប្រការ ១០ គឺ បុគ្គលខ្ទុះក្នុងលោកនេះ ញ៉ាំងមានៈឲ្យកើតព្រោះជាតិ ឬគោត្រឬការកើតជាកូនអ្នកមានត្រកូល ១ ព្រោះភាពជាអ្នកមានរូបល្អ ១ ព្រោះទ្រព្យ ១ ព្រោះការរៀន ១ ព្រោះការងារ ១ ព្រោះសិល្ប: ១ ព្រោះទីតាំងនៃវិជ្ជា ១ ព្រោះការចេះដឹង ១ ព្រោះសេចក្តីធ្វៀវធ្វាស ១ ព្រោះវត្ថុណាមួយ ១ ការមើលងាយ អាការនៃការមើលងាយ ភាពនៃការមើលងាយ ការលើកកម្ពស់ ការប្រកាន់ខ្ពស់ ការផ្គងចិត្ត ភាពនៃចិត្តប្រាថ្នាដូចទង់ មានសភាពយ៉ាងនេះឯណា នេះលោកហៅថា មានៈ ។ ពាក្យថា មក្ខ: បានដល់សេចក្តីលុបគុណ អាការលុបគុណ ភាពនៃសេចក្តីលុបគុណ អំពើនៃសេចក្តីច្រណែន នេះលោកហៅថា មក្ខ: ។ មានៈនិងមក្ខ: ព្រះពុទ្ធមានព្រះភាគបានលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យមានតែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានទីកើត មិនឲ្យមានកិរិយាកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាលះបង់មានៈនិងមក្ខ: ហេតុនោះ (លោកពោលថា) លះបង់មានៈនិងមក្ខ:ហើយ ។

[១៤៧] ហន្ទាហំ កិត្តយិស្សាមិ តិរំ វណ្ណូបសញ្ហិ-
តន្តិ ហន្ទាហន្តិ បទសន្ធិ ។ បេ ។ បជានុបុព្ពកមេ-
តំ ហន្ទាតិ ។ កិត្តយិស្សាមីតិ វណ្ណេន ឧបេតំ
សមុបេតំ ឧចាកតំ សមុចាកតំ ឧបបន្នំ សមុបបន្នំ
សមន្ទាកតំ តិរំ ភាចំ ព្យបថំ ឱិរណ្ណំ កិត្តយិ-
ស្សាមិ ទេសិស្សាមិ បញ្ញបេស្សាមិ បដ្ឋបេស្សាមិ
វិវរិស្សាមិ វិភជិស្សាមិ ឧត្តានីការិស្សាមិ បកាសិ-
ស្សាមីតិ ហន្ទាហំ កិត្តយិស្សាមិ តិរំ វណ្ណូបសញ្ហិ-
តំ ។ តេនាហ បិង្ខិយត្ថេរោ

បហីនមលមោហស្ស មានមក្ខូប្ប្ហាយិនោ
ហន្ទាហំ កិត្តយិស្សាមិ តិរំ វណ្ណូបសញ្ហិតន្តិ ។

[១៤៨] តមោនុទោ ពុទ្ធោ សមន្តចក្ខុ
លោកន្តគូ សព្ពភវាតិវត្តោ
អនាសវោ សព្ពទុក្ខ្ប្ប្ហីនោ
សច្ចូ្ហយោ ព្រហ្មុចាសិតោ មេ ។

[១៦៧] *អធិប្បាយពាក្យថា បើដូច្នោះ ខ្ញុំនឹងសម្តែងពាក្យប្រកបដោយគុណ ត្រង់ពាក្យថា បើដូច្នោះខ្ញុំ គឺ ការតបទ ។ បេ ។ ពាក្យថា បើដូច្នោះខ្ញុំ ទ្ញុះជាលំដាប់បទ ។ ពាក្យថា សម្តែង គឺ នឹងពោល បង្ហាញ ឲ្យដឹងច្បាស់ តាំងផ្តើម បើក រៃកញ្ជែក ធ្វើឲ្យរាក់ ប្រកាស នូវពាក្យ វាចា គន្ធង់ពាក្យ និងសម្តី ដែលកប កបព្រម ប្រកប ប្រកបព្រម ចូលដល់ ចូលដល់ព្រម មកដល់ព្រម ដោយគុណ ហេតុនោះ (លោកពោលថា) បើដូច្នោះ ខ្ញុំនឹងសម្តែងពាក្យប្រកបដោយគុណ ។ ហេតុនោះ បិដ្ឋិយត្ថេរពោលថា*

បើដូច្នោះ ខ្ញុំនឹងសម្តែងពាក្យប្រកបដោយគុណ របស់ព្រះមានព្រះភាគ ទ្រង់លះបង់មន្ទិលនិងមោហៈហើយ លះបង់មានៈនិងមក្ខៈហើយ ។

[១៦៨] ព្រះពុទ្ធទ្រង់បន្ទោបង់ងងឹត មានសមន្តចក្ខុ ទ្រង់ដល់ទីបំផុតលោក ប្រព្រឹត្តកន្ទង់ហើយនូវភពទាំងពួង មិនមានអាសវៈ ទ្រង់លះបង់ទុក្ខទាំងពួងហើយ មានព្រះនាមដ៏ទៀងទាត់ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគប្រសើររួចហើយ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

[១៤៩] តមោនុទោ ពុទ្ធោ សមន្តចក្ខូតិ តមោ-
នុទោតិ ភគវា រាគតមំ ទោសតមំ មោហតមំ មា-
នតមំ ទិដ្ឋិតមំ កិលេសតមំ ទុច្ចរិតតមំ អន្ធការណំ
អចក្ខុការណំ អញ្ញាណការណំ បញ្ញានិរោធិកំ វិឃា-
តបក្ខិកំ អនិញ្ជានសំវត្តនិកំ ទុនិ បទុនិ ជហិ វិនោ-
ទយិ ព្យន្តីមការិ អនភាវគ្គមេសីតិ តមោនុទោ ។
ពុទ្ធោតិ យោ សោ ភគវា ។ បេ ។ សច្ឆិកា បញ្ញត្តិ
យទិទំ ពុទ្ធោតិ ។ សមន្តចក្ខូតិ សមន្តចក្ខុ រុច្ចតិ
សព្វញ្ញុតញ្ញាណំ ។ បេ ។ តថាគតោ តេន សមន្តច-
ក្ខូតិ តមោនុទោ ពុទ្ធោ សមន្តចក្ខុ ។

[១៥០] លោកន្តគូ សព្វភវាតិវត្តោតិ លោកោតិ
ទ្វេ លោកោ ភវលោកោ ។ ទ្វេ លោកា ស-
ម្ផត្តិ ច ភវលោកោ វិបត្តិ ច ភវលោកោ ។ ត-
យោ លោកា តិស្សោ វេទនា ។ ចត្តារោ លោកា
ចត្តារោ អាហារា ។ បញ្ច លោកា បញ្ចុបាទាន-
ក្ខន្ធា ។ ឆ លោកា ឆ អជ្ឌត្តិកានិ អាយតនានិ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេស

[១៤៩] *អធិប្បាយពាក្យថា ព្រះពុទ្ធទ្រង់បន្ទោបង់ផងនឹត មានសមន្តចក្ខុ ត្រង់ពាក្យថា បន្ទោបង់ផងនឹត គឺ ព្រះមានព្រះភាគបានបន្ទោបង់ កម្ចាត់បង់ លះបង់ បន្សាត់បង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវផងនឹត គឺរាគ: ផងនឹតគឺទោស: ផងនឹតគឺមោហ: ផងនឹតគឺមានៈ ផងនឹតគឺទិដ្ឋិ ផងនឹតគឺកិលេស ផងនឹតគឺទុច្ចរិត ធម្មជាតធ្វើឲ្យផងនឹត ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យមានញាណ រំលត់ប្រាជ្ញា ប្រព្រឹត្តទៅក្នុងពួកនៃសេចក្តីចង្អៀត ចង្អ្ល់ មិនប្រព្រឹត្តទៅដើម្បីនិព្វាន ហេតុនោះ (លោកពោលថា) បន្ទោបង់ផងនឹត ។ ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធ នេះ (កើត) ព្រោះការត្រាស់ដឹង ។ ពាក្យថា សមន្តចក្ខុ សេចក្តីថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ បេ ។ ព្រះតថាគត ព្រះនាមថាសមន្តចក្ខុ ដោយហេតុនោះ ហេតុនោះ (លោកពោលថា) ព្រះពុទ្ធទ្រង់បន្ទោបង់ផងនឹត មានសមន្តចក្ខុ ។*

[១៥០] *អធិប្បាយពាក្យថា ទ្រង់ដល់ទីបំផុតលោក ប្រព្រឹត្តកន្ទងហើយនូវកពទាំងពួង ត្រង់ពាក្យថា លោក គឺ លោក ១ បានដល់ភវ-លោក ។ លោក ២ បានដល់សម្បត្តិភវលោក ១ វិបត្តិភវលោក ១ ។ លោក ៣ បានដល់វេទនា ៣ ។ លោក ៤ បានដល់អាហារ ៤ ។ លោក ៥ បានដល់ឧបាទានក្ខន្ធ ៥ ។ លោក ៦ បានដល់អាយតនៈខាងក្នុង ៦ ។*

សត្ត លោកា សត្ត វិញ្ញាណដ្ឋិតិយោ ។ អដ្ឋ លោកា អដ្ឋ លោកធម្មា ។ នវ លោកា នវ សត្តាវាសា ។ ទស លោកា ទស ឧបក្លិលេ-សា ។ ឯកាទស លោកា ឯកាទស កាម-ភវា ។ ទ្វាទស លោកា ទ្វាទសាយតនានិ ។ អដ្ឋារស លោកា អដ្ឋារស ធាតុយោ ។ លោកន្ត-ភូតិ ភតវា លោកស្ស អន្តតោ អន្តប្ឋត្តោ កោដិ-តោ កោដិប្ឋត្តោ ។ បេ ។ ជិញ្ជានតោ ជិញ្ជានប្ឋ-ត្តោ សោ រុជ្ជវាសោ ចិណ្ណាចរណោ ។ បេ ។ ជាតិជរ-មរណសំសារេ ន ត្ថិ ឥស្ស បុនព្ភវោតិ លោកន្ត្ថ ។ សព្ពភវាតិវត្តោតិ ភវាតិ ទ្វេ ភវ កម្ម្ភវេ ច បដិ-សន្ធិភោ ច បុនព្ភវេ ។ ភតមោ ភម្ម្ភវេ ។ បុ-ញ្ញាភិសង្ខារេ អបុញ្ញាភិសង្ខារេ អានេញ្ជាភិសង្ខារេ អយំ ភម្ម្ភវេ ។ ភតមោ បដិសន្ធិភោ បុនព្ភវេ ។ បដិសន្ធិភ ១ចា ១េ១ា ១ញ្ញ ១ង្ខ១ ១ិញ្ញ១ណ អយ១ បដិ១ន្ធ១ភ១ ១ុ១ព្ភ១ ។ ១ភ១ ១ម្ម១ភ១ញ ១-ដ១ន្ធ១ភ១ ១ុ១ព្ភ១ ១ុ១ ១ តិ១ត្ត១ ១ តិ១ត្ត១ ១ លោ១ន្ត១ ១ ១ព្ព១ភ១ តិ១ត្ត១ ។

លោក ៧ បានដល់វិញ្ញាណដ្ឋិតិ ៧ ។ លោក ៨ បានដល់លោកធម៌ ៨ ។ លោក ៩ បានដល់សត្តាវាស: ៩ ។ លោក ១០ បានដល់ឧបក្ខិ-លេស ១០ ។ លោក ១១ បានដល់កាមភព ១១ ។ លោក ១២ បានដល់អាយតន: ១២ ។ លោក ១៨ បានដល់ធាតុ ១៨ ។ ពាក្យថា ទ្រង់ដល់ទីបំផុតលោក បានសេចក្តីថា ព្រះមានព្រះភាគទៅកាន់ទីបំផុត ដល់ទីបំផុត ទៅកាន់ទីខាងចុង ដល់ទីខាងចុងនៃលោក ។ បេ ។ ទៅនិព្វាន ដល់និព្វាន ព្រះមានព្រះភាគនោះមានការនៅរួចហើយ មានចរណ:សន្សំហើយ ។ បេ ។ ភពថ្មីគឺការអន្ទោលទៅកាន់ជាតិ ជរា និងមរណ: របស់ព្រះអង្គមិនមានឡើយ ហេតុនោះ (លោកពោលថា) ទ្រង់ដល់ទីបំផុតលោក ។ ពាក្យថា ភព ក្នុងបទថា ប្រព្រឹត្តកន្ទងហើយនូវភពទាំងពួង បានដល់ភព ២ គឺកម្មភព ១ បដិសន្ធិកបុនព្ភព ១ ។ កម្មភព តើដូចម្តេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ នេះឈ្មោះថាកម្មភព ។ បដិសន្ធិកបុនព្ភព តើដូចម្តេច ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលប្រកបដោយបដិសន្ធិ នេះឈ្មោះថាបដិសន្ធិកបុនព្ភព ។ ព្រះមានព្រះភាគបានកន្ទង ឈានកន្ទង ប្រព្រឹត្តកន្ទង នូវកម្មភពនិងបដិសន្ធិកបុនព្ភព ហេតុនោះ (លោកពោលថា) ទ្រង់ដល់ទីបំផុតលោក ប្រព្រឹត្តកន្ទងហើយនូវភពទាំងពួង ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

[១៨១] អជាសវោ សព្វទុក្ខប្បហីនោតិ អជាសវោតិ ចត្តារោ អាសវា កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។ តេ អាសវា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ អជាសវោ ។ សព្វទុក្ខប្បហីនោតិ សព្វំ តស្ស បដិសន្ធិកំ ជាតិទុក្ខំ ជរាទុក្ខំ ព្យាធិទុក្ខំ មរណទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខំ ។ បេ ។ ទិដ្ឋិព្យសនទុក្ខំ បហីនំ សមុច្ឆិន្នំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍំ តស្មា ពុទ្ធោ សព្វទុក្ខប្បហីនោ ។

[១៨២] សច្ចវ្ហយោ ព្រហ្មុបាសិតោ មេតិ សច្ចវ្ហយោតិ សច្ចសទិសវ្ហយោ ។ វិបស្សី ភគវា សិខី ភគវា វេស្សភូ ភគវា កកុសន្ធោ ភគវា កោនាគមនោ ភគវា កស្សបោ ភគវា ពុទ្ធា ភគវន្តោ សទិសនាមា សច្ចសទិសវ្ហយា ។

[១៥១] *អធិប្បាយពាក្យថា មិនមានអាសវៈ ទ្រង់លះបង់ទុក្ខទាំងពួងហើយ ត្រង់ពាក្យថា មិនមានអាសវៈ សេចក្តីថា អាសវៈ ៤ គឺកាមាសវៈ ១ ភវាសវៈ ១ ទិដ្ឋាសវៈ ១ អវិជ្ជាសវៈ ១ ។ អាសវៈទាំងនោះ ព្រះពុទ្ធមានព្រះភាគបានលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យមានតែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន មិនឲ្យមានកិរិយាកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធឈ្មោះថាមិនមានអាសវៈ ។ ពាក្យថា ទ្រង់លះបង់ទុក្ខទាំងពួងហើយ សេចក្តីថា ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកទុក្ខ បរិទេវទុក្ខ ទោមនស្សុបាយាសទុក្ខ ។ បេ ។ ទិដ្ឋិព្យសនទុក្ខ ទាំងពួង ដែលប្រកបដោយបដិសន្ធិ ព្រះពុទ្ធនោះបានលះបង់ កាត់ផ្តាច់ រម្ងាប់បង់ ធ្វើមិនឲ្យកើតវិញ បានដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមានទុក្ខទាំងពួងលះបង់ហើយ ។*

[១៥២] *ពាក្យថា មានព្រះនាមដ៏ទៀងទាត់ ក្នុងបទថា មានព្រះនាមដ៏ទៀងទាត់ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគប្រសើររួចហើយ សេចក្តីថា ព្រះពុទ្ធ មានព្រះនាមដ៏ទៀងទាត់ដូចគ្នា ។ គឺ ព្រះវិបស្សី ព្រះនាមថាភគវា ព្រះសិខី ព្រះនាមថាភគវា ព្រះវេស្សភូ ព្រះនាមថាភគវា ព្រះកកុសន្ធៈ ព្រះនាមថាភគវា ព្រះកោនាគមនៈ ព្រះនាមថាភគវា ព្រះកស្សបៈ ព្រះនាមថាភគវា ព្រះពុទ្ធដ៏មានព្រះភាគទាំងឦ្ចាយ សឹងមានព្រះនាមដូចគ្នា មានព្រះនាមដ៏ទៀងទាត់ស្មើគ្នា ។*

ភគវា សក្យមុនិ តេសំ ពុទ្ធានំ ភគវន្តានំ សជិសជា-
មោ សច្ចសជិសស្ហយោតិ តស្មា ពុទ្ធោ សច្ចវ្ហយោ ។
ព្រហ្មុចាសិតោ មេតិ សោ ភគវា មយា អា-
សិតោ ឧចាសិតោ បយិរុចាសិតោ បរិបុច្ឆិតោ
បរិបញ្ហិតោតិ សច្ចវ្ហយោ ព្រហ្មុចាសិតោ មេ ។
តេនាហ បិង្គិយត្ថេរោ

តមោនុទោ ពុទ្ធោ សមន្តចក្ខុ
លោកន្តគូ សព្វភវាតិវត្តោ
អនាសវោ សព្វទុក្ខប្បហីនោ
សច្ចវ្ហយោ ព្រហ្មុចាសិតោ មេតិ ។

[១៥៣] ទិជោ យថា កុព្វនកំ បហាយ
ពហុប្ផលំ កាននំ អាវសេយ្យ
ឯវមាហំ អប្បទស្សេ បហាយ
មហោទធឹ ហំសរិវជ្ឈបត្តោ ។

ព្រះសក្យមុនីមានព្រះភាគ មានព្រះនាមដូចគ្នា មានព្រះនាមដ៏ទៀងទាត់ ស្មើនឹងព្រះពុទ្ធ មានព្រះភាគទាំងឡាយនោះ ព្រោះហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមានព្រះនាមដ៏ទៀងទាត់ ។ ពាក្យថា ខ្ញុំបានចូលទៅគាល់ព្រះ មានព្រះភាគប្រសើររួចហើយ គឺ ព្រះមានព្រះភាគនោះ ខ្ញុំបានចូលទៅ ចូលទៅជិត ចូលទៅអង្គុយជិត សាកសួរ ចោទសួរហើយ ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគ មានព្រះនាមដ៏ទៀងទាត់ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគប្រសើររួចហើយ ។ ហេតុនោះ បិង្គិយត្ថេរពោលថា

ព្រះពុទ្ធ ទ្រង់បន្ទោបង់ងងឹត មានសមន្តចក្ខុ ទ្រង់ដល់ទីបំផុតលោក ប្រព្រឹត្តកន្ទងហើយនូវភពទាំងពួង មិនមានអាសវៈ ទ្រង់លះបង់ទុក្ខទាំងពួងហើយ មានព្រះនាមដ៏ទៀងទាត់ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគប្រសើររួចហើយ ។

[១៥៣] (ព្រះបិង្គិយត្ថេរពោលថា) ទិជសត្វ លះបង់ព្រៃតូច (មានផ្លែតិច) មកនៅអាស្រ័យ នឹងព្រៃធំ មានផ្លែច្រើន ដូចម្តេចមិញ ខ្ញុំលះបង់បុគ្គលទាំងឡាយ ដែលមានការឃើញតិច (មកចូលប្រសព្ធនឹងព្រះពុទ្ធទ្រង់មានប្រាជ្ញាច្រើន) ដូចហង្សចូលប្រសព្ធនូវស្រះ ដែលមានទឹកច្រើន ដូច្នោះឯង ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

[១៩៤] ឥធេកោ យថា កុព្ពនកំ បហាយ ពហុ-
ប្ធលំ កាននំ អាវសេយ្យាតិ ឥធេកោ វុច្ចតិ បក្ខី ។
កតមោ ឥធេកោ វុច្ចតិ បក្ខី ។ ទិជស្ស ជាយតិ
ឥធេកោ មាតុកុច្ឆិម្ហា ច អណ្ឌកោសម្ហា ច តំការណា
ឥធេកោ វុច្ចតិ បក្ខីតិ ឥធេកោ ។ យថា កុព្ពនកំ បហា-
យាតិ យថា ឥធេកោ កុព្ពនកំ រិត្តវនកំ អប្បភក្ខំ
អប្បោទកំ បហាយ ជហិត្វា អតិក្កមិត្វា វីតិវត្តេត្វា
អញ្ញំ ពហុប្ផលំ ពហុភក្ខំ ពហុរុក្ខំ(១) មហន្តំ កាននំ
វនសណ្ឌំ អជ្ឈោគាហេយ្យ វិគ្គេយ្យ បដិលភេយ្យ តស្មឹ
វនសណ្ឌេ វាសំ កប្បេយ្យាតិ ឥធេកោ យថា កុព្ពនកំ
បហាយ ពហុប្ផលំ កាននំ អាវសេយ្យ ។

[១៩៥] ឯវមាហំ អប្បទស្សេ បហាយ មហោទធឹ
ហំសោរិវជ្ឈុបត្តោតិ ឯវន្តិ ឱបម្មសម្បដិបាទនំ ។

១ ម. ពហុទកំ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេស

[១៥៤] ពាក្យថា ទិជសត្ត លះបង់ព្រៃតូច មកនៅអាស្រ័យនឹងព្រៃធំ ដែលមានផ្ទៃច្រើន ដូចម្តេចមិញ អធិប្បាយថា សត្ត្ថាប លោកហៅថា ទិជសត្ត ។ ហេតុអ្វី សត្ត្ថាប លោកហៅថា ទិជសត្ត ។ ទិជសត្ត្ថតែងកើត ២ លើក គឺកើតអំពីផ្ទៃមេ ១ លើក អំពីស្រោមស៊ុត ១ លើក ហេតុនោះ សត្ត្ថាបទើបលោកហៅថា ទិជសត្ត ហេតុនោះ (លោកពោលថា) ទិជសត្ត ។ ពាក្យថា លះបង់ព្រៃតូច ដូចម្តេចមិញ គឺ ទិជសត្ត្ថលះបង់ ចោះបង់ កន្ទង កន្ទងបង់ នូវព្រៃតូច ព្រៃស្តើង ដែលមានចំណីតិច មានទឹកតិច ហើយបាន ចូបប្រសព្ធ បានចំពោះ នូវព្រៃធំ ដ៏ទៃ ដែលមានផ្ទៃច្រើន មានចំណីច្រើន មានឈើច្រើន គឺថា គប្បីសម្រេចការនៅក្នុងដងព្រៃនោះ ដូចម្តេចមិញ ហេតុនោះ (លោកពោលថា) ទិជសត្ត្ថលះបង់ព្រៃតូច មកនៅអាស្រ័យនឹងព្រៃធំ ដែលមានផ្ទៃច្រើន ដូចម្តេចមិញ ។

[១៥៥] អធិប្បាយពាក្យថា ខ្ញុំលះបង់បុគ្គលទាំងឡាយ ដែលមានការឃើញតិច (មកចូបប្រសព្ធព្រះពុទ្ធ ទ្រង់មានប្រាជ្ញាច្រើន) ដូចហង្សចូបប្រសព្ធ នូវស្រះដែលមានទឹកច្រើន ដូច្នោះឯង ត្រង់ពាក្យថា ដូច្នោះឯង គឺ ជាពាក្យញ្ជាំងសេចក្តីឧបមាឲ្យសម្រេច ។

អប្បនស្សេ បហាយាតិ យោ ច ពាវរី ព្រាហ្មណោ យេ ចញ្ញេ តស្ស អាចរិយា ពុទ្ធំ ភគវន្តំ ឧចាទាយ អប្ប-នស្សា បរិត្តនស្សា ថោកនស្សា ឱមកនស្សា លា-មកនស្សា ជតុក្កនស្សា ។ តេ ព្រាហ្មណោ អប្បន-ស្សេ បរិត្តនស្សេ ថោកនស្សេ ឱមកនស្សេ លាម-កនស្សេ ជតុក្កនស្សេ បហាយ បជហិត្វា អតិក្កមិ-ត្វា សមតិក្កមិត្វា ពុទ្ធំ ភគវន្តំ អគ្គនស្សំ សេដ្ឋនស្សំ វិសេដ្ឋនស្សំ ឧត្តមនស្សំ បវរំ អសមំ អសមសមំ អប្បដិភាគំ អប្បដិបុគ្គលំ ទេវាតិទេវំ នរាសភំ បុរិសសីហំ បុរិសនាគំ បុរិសាជញ្ញំ បុរិសនិសភំ បុរិសធោរយ្ហំ ទសពលំ តាទឹ អធិគច្ឆឹ វិន្ទឹ បដិលភឹ ។

ពាក្យថា លះបង់បុគ្គលទាំងឡាយ ដែលមានការឃើញតិច សេចក្ដីថា ពាវរីព្រាហ្មណ៍ណា និងពួកជនដទៃណាជាអាចារ្យ របស់ពាវរីព្រាហ្មណ៍នោះ បើប្រៀបផ្ទឹមនឹងព្រះពុទ្ធមានព្រះភាគ ទៅជាអ្នកមានការឃើញតិច មានការឃើញស្ពួចស្ដើង មានការឃើញថោកថយ មានការឃើញអូនថយ មានការឃើញលាមក មានការឃើញអាក្រក់ ។ ខ្ញុំលះបង់ បោះបង់ កន្ទង កន្ទងបង់នូវព្រាហ្មណ៍ទាំងនោះ ដែលមានការឃើញតិច មានការឃើញស្ដើងស្ពួច មានការឃើញថោកថយ មានការឃើញអូនថយ មានការឃើញលាមក មានការឃើញអាក្រក់ មកជួប ប្រសព្ធ បានចំពោះនូវព្រះពុទ្ធមានព្រះភាគ ទ្រង់ឃើញដ៏លើស ទ្រង់ឃើញដ៏ប្រសើរ ទ្រង់ឃើញវិសេស ទ្រង់ឃើញឧត្ដម ព្រះអង្គជាបុគ្គលប្រសើរ រកបុគ្គលស្មើមិនមាន ព្រះអង្គស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ គ្មានចំណែកប្រៀប មិនមានបុគ្គលប្រៀប ទ្រង់ជាទេវតាវិសេសជាងទេវតា ទ្រង់ជានរាសភ: ជាបុរិសសីហ: ជាបុរិសនាគ ជាបុរសអាជានេយ្យ ជាបុរិសនិសភ: ជាអ្នកនាំទៅនូវធុរ:របស់បុរស ជាទសពល ជាតាទិបុគ្គល ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

យថាវ ហំសោ មហន្តំ មានុសកាតំ វា សរំ អនោតត្តំ វា ទហំ មហាសមុទ្ទំ វា អក្ខោព្ភំ អមិតោទកំ អធិគច្ឆេយ្យ វិន្ទេយ្យ បដិលភេយ្យ ឯវមេវ បិង្គិយោ ព្រាហ្មណោ ពុទ្ធំ ភគវន្តំ អក្ខោព្ភំ អមិតតេជំ បភិន្នញាណំ វិវដចក្ខុំ បញ្ញាបភេទកុសលំ អធិគតប្បដិសម្ភិទំ ចតុវេសារជ្ជប្បត្តំ សុទ្ធាធិមុត្តំ សេតប្បច្ចត្តំ អទ្វយភាណឹ តាទឹ តថាបដិញ្ញំ អបរិត្តំ មហន្តំ គម្ភីរំ អប្បមេយ្យំ ទុប្បរិយោគាឡ្ហំ ពហុរតនំ សាគរសមំ ឆឡង្គុបេក្ខាយ សមន្នាគតំ អតុលំ វិបុលំ អប្បមេយ្យំ តំ តាទិសំ បវទតមគ្គវាទិនំ សិនេរុមិវ[១] នគានំ គរុឡមិវទិជានំ សីហមិវ មិគានំ

---

១ ម. មេរុមិវ ។

ដូចហង្ស គប្បីចូប ប្រសព្ធ បានចំពោះ នូវស្រះធំដែលមនុស្សកសាងក្តី អនោតត្តស្រះក្តី មហាសមុទ្រក្តី ដែលមិនកម្រើក មានទឹករាប់មិនអស់យ៉ាងណា ខ្ញុំឈ្មោះបិង្គិយព្រាហ្មណ៍ បានចូប ប្រសព្ធ បានចំពោះនូវព្រះពុទ្ធមានព្រះភាគ ព្រះអង្គមិនកម្រើក មានតេជះរាប់មិនបាន មានញាណបែកធ្លាយ មានចក្ខុបើកហើយ ព្រះអង្គធ្វៀរធ្លាសក្នុងប្រភេទនៃប្រាជ្ញា ព្រះអង្គបានបដិសម្ភិទា បានចតុវេសារជ្ជញ្ញាណ ទ្រង់មានព្រះទ័យស៊ប់ក្នុងផលសមាបត្តិដ៏បរិសុទ្ធ ទ្រង់មានអត្តភាពមិនផ្សេងគ្នា ទ្រង់មិនពោលពីរព្រះឱស្ឋ ទ្រង់មិនញាប់ញ័រ ទ្រង់មានការប្តេជ្ញាទ្រៀង ទ្រង់មិនតូច ទ្រង់ធំ ទ្រង់មានប្រាជ្ញាជ្រៅ ទ្រង់មានប្រាជ្ញាប្រមាណមិនបាន ទ្រង់មានប្រាជ្ញាមិនអាចអ្នកណាស្ទង់បាន ទ្រង់មានរតនៈច្រើន ទ្រង់ស្មើដោយសាគរ ទ្រង់ប្រកបដោយឧបេក្ខា ៦ ទ្រង់មានព្រះគុណធំទូលាយ ថ្វីងមិនបាន ប្រមាណមិនត្រូវ ព្រះមានព្រះភាគនោះ ទ្រង់ប្រកបដោយតាទិគុណ ទ្រង់ជាអ្នកពោលដ៏ប្រសើរ ជាងជនអ្នកពោលទាំងឡាយ ដូចភ្នំសិនេរុ ប្រសើរជាងភ្នំទាំងឡាយ ឬដូចគ្រុឌ ប្រសើរជាងទិជសត្ធទាំងឡាយ ឬក៏ដូចសីហៈ ប្រសើរជាងពួកម្រឹគ ពុំនោះសោត

ឧបដ្ឋិតំ អញ្ញាណំ ជិនបវរំ អបិតច្ចំ វិឆ្ជំ បដិលភិន្តិ ឯវមាហំ អប្បមស្សេ បហាយ មហោឃំ ហំសវិ-វជ្ជបត្តោ ។ តេនាហ បិង្គិយត្ថេរោ

ទិជោ យថា កុព្ពនកំ បហាយ
ពហុប្ផលំ កាននំ អាវសេយ្យ
ឯវមាហំ អប្បទស្សេ បហាយ
មហោទធឹ ហំសរិវជ្ជបត្តោតិ ។

[១៨៦] យេមេ បុព្វេ វិយាកំសុ (ហុរំ
គោតមសាសនា)
ឥច្ចាសិ ឥតិ ភវិស្សតិ
សព្វន្តំ ឥតិហីតិហំ
សព្វន្តំ តក្កវឌ្ឍនំ ។

ដូចសមុទ្រ ប្រសើរជាងអន្ទង់ទឹកទាំងឡាយ ព្រះអង្គជាព្រះជិនស្រី ដ៏ប្រ-
សើរ ក៏យ៉ាងនោះដែរ ហេតុនោះ (លោកពោលថា) ខ្ញុំលះបង់បុគ្គល
ទាំងឡាយដែលមានការឃើញតិច (មកចូបប្រសព្វព្រះពុទ្ធទ្រង់មានប្រាជ្ញា
ច្រើន) ដូចហង្សដែលចូបប្រសព្វនូវស្រះ មានទឹកច្រើន ដូច្នោះឯង ។
ហេតុនោះ ព្រះបិង្គិយត្តេរពោលថា

ទិជសត្វលះបង់ព្រៃតូច (មានផ្លែតិច) មកនៅអាស្រ័យនឹង
ព្រៃធំ មានផ្លែច្រើន ដូចម្តេចមិញ ខ្ញុំលះបង់បុគ្គលទាំង-
ឡាយ ដែលមានការឃើញតិច (មកចូបប្រសព្វនឹងព្រះពុទ្ធ
ទ្រង់មានប្រាជ្ញាច្រើន) ដូចហង្សចូបប្រសព្វនូវស្រះ មាន
ទឹកច្រើន ដូច្នោះឯង ។

[១៥៦] ជនទាំងឡាយណា ក្នុងកាលមុន (អំពីសាសនា
នៃព្រះគោតម) ជនទាំងឡាយនោះ បានព្យាករហើយថា
ហេតុមានមកហើយ ដូច្នេះ ។ នឹងមានតទៅ ដូច្នេះ ។
ពាក្យទាំងអស់នោះ (មិនទាន់ប្រាកដទេ) ជាពាក្យជឿស្តាប់
បុគ្គលដទៃ ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យ
ចម្រើន (ខ្ញុំមិនពេញចិត្តនឹងពាក្យនោះឡើយ) ។

[១៥៧] យេមេ បុព្វេ វិយាកំសូតិ យេតិ យោ ច ពាវរី ព្រាហ្មណោ យេ ចញ្ញេ តស្ស អាចរិយា តេ សកំ ជិដ្ឋឿ សកំ ១ន្ត្ថ សកំ រុចឿ សកំ លទ្ធឿ សកំ អជ្ឈាសយំ សកំ អធិប្ប៉ាយំ ព្យ៉ាកំសុ អ-ចិក្ខឿសុ ឣេសយឿសុ បញ្ញបឿសុ បដ្ឋបឿសុ ១ារ១ឿសុ ១ាក-ជឿសុ ១ត្ថានីមកំសុ បកាសេសុន្តិ យេមេ បុព្វេ ១ិយាកំសុ ។

[១៥៨] ហុរំ គោតមសាសនាតិ ហុរំ គោតម-សាសនា ២ុរំ គោតមសាសនា ២ុ១ គោតមសា-សនា ២ម្ម១ត១ំ គោតមសាសនា ពុទ្ធសាសនា ជិ-ឣសាសនា ១ថាគ១ត១ាសនា ឣ១ហ-ន្ត១ាសនាតិ ហុរំ គោតមសាសនា ។

[១៥៧] ពាក្យថា ជនទាំងឡាយណា ... ជនទាំងឡាយនោះបានព្យាករហើយ ត្រង់ពាក្យថា ជនទាំងឡាយណា គឺ ពាវរីព្រាហ្មណ៍ណា និងពួកជនដទៃណា ជាអាចារ្យរបស់ពាវរីព្រាហ្មណ៍នោះ ព្រាហ្មណ៍ទាំងនោះបានព្យាករ ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក រៃកញ្ជែក ធ្វើឲ្យងាយ ប្រកាសនូវទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីគាប់ចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន អធ្យាស្ស័យរបស់ខ្លួន សេចក្តីប៉ុនប៉ងរបស់ខ្លួន ហេតុនោះ (លោកពោលថា) ជនទាំងឡាយណា ... ជនទាំងឡាយនោះបានព្យាករហើយ ។

[១៥៨] ពាក្យថា ក្នុងកាលមុនអំពីសាសនានៃព្រះគោតម គឺ ក្នុងកាលមុនអំពីសាសនាព្រះគោតម ដទៃអំពីសាសនាព្រះគោតម ក្នុងកាលមុនដំបូងអំពីសាសនាព្រះគោតម ក្នុងកាលមុនបង្ហ្ស ់ អំពីសាសនាព្រះគោតម អំពីសាសនាព្រះពុទ្ធ អំពីសាសនាព្រះជិនស្រី អំពីសាសនាព្រះតថាគត អំពីសាសនាព្រះពុទ្ធជាទេវតា អំពីសាសនាអរហន្ត ហេតុនោះ (លោកពោលថា) ក្នុងកាលមុន អំពីសាសនានៃព្រះគោតម ។

[១៥៩] ឥច្ចាសិ ឥតិ ភវិស្សតីតិ ឯវํ ការ អសិ ឯវํ ការ ភវិស្សតីតិ ឥច្ចាសិ ឥតិ ភវិស្សតិ ។

[១៦០] សព្វន្តํ ឥតិហីតិហន្តិ សព្វํ តํ ឥតិ-ហីតិហํ ឥតិកិរាយ បរម្ប្រាយ បិដកសម្ប្ដាយ តក្ការហេតុ ជយហេតុ អាការបរិវិតក្ខេន ទិដ្ឋិនិជ្ឈា-ឧក្ខន្តិយា ន សាមํ សយមភិញ្ញាតํ ន អត្ដប្ប្ដចូក្ខํ ឆម្ម ការ ថយីសូតិ សព្វន្តํ ឥតិហីតិហํ ។

[១៦១] សព្វន្តํ តក្ការ ឆ្ឆ ន ន្ដិ សព្វន្តํ តក្ការ ឆ្ឆ ន ។ តក្ការ ឆ្ឆ ន ។ សង្ខ្ដ ប្ប ឆ្ឆ ន ។ ការ-ការ ឆ្ឆ ន ។ ព្យាចារ ឆ្ឆ ន ។ ញ្ញាតិ-ការ ឆ្ឆ ន ។ ជនបទ ការ ឆ្ឆ ន ។ អមការ ឆ្ឆ ន ។

[១៥៩] ពាក្យថា ហេតុមានមកហើយ ដូច្នេះ ។ នឹងមានតទៅ ដូច្នេះ ។ គឺ ពួកថា ហេតុយ៉ាងនេះ ធ្លាប់មានមកហើយ ពួកថា ហេតុយ៉ាងនេះ នឹងមានតទៅខាងមុខ ហេតុនោះ (លោកពោលថា) ហេតុមានហើយ ដូច្នេះ ។ នឹងមានតទៅដូច្នេះ ។ ។

[១៦០] ពាក្យថា ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ គឺពាក្យទាំងអស់នោះ ជាពាក្យជឿ ស្តាប់បុគ្គលដទៃ ដោយពួកដូច្នេះ ។ ដោយពួត ។ គ្នា ដោយការផ្ទេរផ្ទ ។ នឹងក្ជួន ដោយហេតុនៃការត្រិះរិះ ដោយហេតុនៃការគ្នេរគ្នាន់ ដោយការជញ្ជឹងគិតតាមអាការ: ដោយការយល់ ការពិនិត្យ និងការគិតគូរ គឺថា ជនទាំងនោះសម្តែងធម៌ ដែលមិនបានត្រាស់ដឹងចំពោះខ្លួនឯង មិនជាក់ច្បាស់ចំពោះខ្លួនឯង ហេតុនោះ (លោកពោលថា) ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ ។

[១៦១] ពាក្យថា ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះ ឲ្យចម្រើន គឺពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះ ឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះផ្សេង ។ ឲ្យចម្រើន ធ្វើតម្រិះ ឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះក្នុងកាម ឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះ ក្នុងព្យាបាទនិងការបៀតបៀនឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះ ក្នុងញាតិឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះ ក្នុងជនបទឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះ ក្នុងការមិនស្លាប់ ឲ្យចម្រើន

បរានុទ្ទយតាបដិសំយុត្តវិតក្កវឌ្ឍនំ លាភសក្ការសិ-លោកប្បដិសំយុត្តវិតក្កវឌ្ឍនំ អនវញ្ញត្តិប្បដិសំយុត្ត-វិតក្កវឌ្ឍនន្តិ សព្វន្តំ តក្កវឌ្ឍនំ ។ តេនាហ បិង្គិយត្ថេរោ

យេមេ បុព្វេ វិយាកំសុ (ហុរំ គោតមសាសនា)

ឥច្ចាសិ ឥតិ ភវិស្សតិ

សព្វន្តំ ឥតិហីតិហំ

សព្វន្តំ តក្កវឌ្ឍនន្តិ ។

[១៦២] ឯកោ តមនុទាសីនោ ជុតិមា សោ បភង្ករោ គោតមោ ភូរិបញ្ញាណោ គោតមោ ភូរិមេធសោ ។

ធ្វើសេចក្ដីត្រិះរិះ ដែលប្រកបដោយសេចក្ដីអាណិត ចំពោះបុគ្គលដទៃឲ្យ
ចម្រើន ធ្វើសេចក្ដីត្រិះរិះប្រកបដោយលាភសក្ការៈនិងសេចក្ដីសរសើរឲ្យ
ចម្រើន ធ្វើសេចក្ដីត្រិះរិះ ប្រកបដោយការមិនចង់ឲ្យគេមើលងាយឲ្យ
ចម្រើន ហេតុនោះ (លោកពោលថា) ពាក្យទាំងអស់នោះ ជាពាក្យ
ធ្វើសេចក្ដីត្រិះរិះឲ្យចម្រើន ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ជនទាំងឡាយណា ក្នុងកាលមុន (អំពីសាសនានៃព្រះគោតម)
ជនទាំងឡាយនោះបានព្យាករហើយថា ហេតុមានមកហើយ
ដូច្នេះ ។ នឹងមានតទៅដូច្នេះ ។ ពាក្យទាំងអស់នោះ (មិនទាន់
ប្រាកដទេ) ជាពាក្យជឿស្ដាប់បុគ្គលដទៃ ពាក្យទាំងអស់នោះ
ជាពាក្យធ្វើសេចក្ដីត្រិះរិះឲ្យចម្រើន (ខ្ញុំមិនពេញចិត្តនឹងពាក្យ
នោះឡើយ) ។

[១៦២] ព្រះគោតមនោះ តែមួយព្រះអង្គឯង ទ្រង់បន្ទោបង់
ងងឹត គង់នៅជាសុខ ទ្រង់មានរស្មីរុងរឿង ទ្រង់ធ្វើពន្ធឺ
(ដល់លោក) ព្រះគោតម មានប្រាជ្ញាជាគ្រឿងប្រាកដ
ព្រះគោតម មានប្រាជ្ញាដូចផែនដី ។

[១៦៣] ឯកោ តមនុជាសីយោតិ ឯកោតិ ភគវា បញ្ញាសង្ខ្យាតេន ឯកោ អទុតិយដ្ឋេន ឯកោ តណ្ហាបហានដ្ឋេន ឯកោ ឯកន្តវីតរាគោតិ ឯកោ ឯកន្តវីតទោសោតិ ឯកោ ឯកន្តវីតមោហោតិ ឯកោ ឯកន្តនិក្កិលេសោតិ ឯកោ ឯកាយនមក្ខំ គតោតិ ឯកោ ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឌោតិ ឯកោ ។

ឯកមំ ភគវា បញ្ញាសង្ខ្យាតេន ឯកោ ។ ភគវា ឧមាហេវ សមាយោ សុសូកាឧ្យកេ-សោ ភគ្ដ្ដេន យោព្ជ្ជេន សមន្ជ្ជាតតោ ឧប-មេន វយសា អកាមកានំ មាតាបិតូនំ អស្សុ-មុខានំ ពោទន្ជ្ជានំ វិលបន្ជ្ជានំ ញ្ជាតិសង្ជ្ជំ ឧហាយ

[១៦៣] *អធិប្បាយពាក្យថា តែមួយព្រះអង្គឯង ទ្រង់បន្ទោបង់ងងឹត គង់នៅជាសុខ ត្រង់ពាក្យថា តែមួយព្រះអង្គឯង គឺ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយចំណែកនៃបព្វជ្ជា តែមួយព្រះអង្គឯង ដោយសេចក្តីថាមិនមានបុគ្គលជាគម្រប់ពីរ តែមួយព្រះអង្គឯង ដោយសេចក្តីថាលះបង់តណ្ហា តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាករាគៈដោយចំណែកមួយ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាកទោសៈដោយចំណែកមួយ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាកមោហៈ ដោយចំណែកមួយ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់មិនមានកិលេសដោយចំណែកមួយ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ស្តេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលមួយនាក់ តែមួយព្រះអង្គឯង ព្រោះហេតុត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ដ៏ប្រសើរ តែមួយព្រះអង្គ ។*

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយចំណែកបព្វជ្ជា តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់នៅក្មេង មានព្រះកេសាខ្មៅស្រិល ប្រកបដោយវ័យដ៏ចម្រើន គឺបឋមវ័យ កាលព្រះមាតានិងព្រះបិតា មិនសព្វព្រះទ័យ (នឹងការចេញបព្វជ្ជា) មានព្រះភ័ក្ត្រជោកដោយទឹកព្រះនេត្រ ទ្រង់ព្រះកន្សែង ពិលាប ទ្រង់ក៏លះបង់ពពួកញាតិ

សពុ្ធ ឃរាវាសបលិពោធំ ឆិន្ទិត្វា បុត្តទារបលិពោធំ ឆិន្ទិត្វា ញាតិបលិពោធំ ឆិន្ទិត្វា មិត្តាមចូបលិពោធំ ឆិន្ទិត្វា កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្ជិត្វា អកិញ្ចនភាវំ ឧបគន្ត្វា ឯកោ ចរតិ វិចរតិ ឥរិយតិ វត្តេតិ ចាលេតិ យបេតិ យាបេតីតិ ឯវំ ភគវា បព្ជ្ជាសង្ខ្ជាតេន ឯកោ ។

ភគវំ ភគវា អនុតិយដ្ឋេន ឯកោ ។ សោ ឯវំ បព្ជិតោ សមានោ អរញ្ញវនបត្ថានិ បន្ថានិ សេនាសនានិ បដិសេវតិ អប្ប្ជសទ្ជានិ អប្ប្ជនិគ្ឆ្ជាសានិ វិជនវាតានិ មនុស្ស្ជរាហាសេយ្យកានិ បដិសល្ជានសារុប្ជានិ សោ ឯកោ គច្ជតិ ឯកោ តិដ្ជតិ ឯកោ និសីទតិ ឯកោ សេយ្ជំ កប្ជេតិ ឯកោ គាមំ បិណ្ជ្ជាយ បវិសតិ ឯកោ បដិក្ជ្ជមតិ[1] ឯកោ រហោ និសីទតិ ឯកោ ចង្ជ្ជមំ អធិដ្ជាតិ ឯកោ ចរតិ វិចរតិ[2] ឥរិយតិ វត្តេតិ ចាលេតិ យបេតិ យាបេតីតិ ឯវំ ភគវា អនុតិយដ្ឋេន ឯកោ ។

---

១ ម. ឯកោ អតិក្ជមតិ ឯកោ បដិក្ជមតិ ។ ២ វិហរតិ ។

កាត់បលិពោធ ក្នុងឃរាវាសទាំងអស់ កាត់បលិពោធ ក្នុងបុត្រនិងព្រះជាយា កាត់បលិពោធ ក្នុងញាតិ កាត់បលិពោធ ក្នុងមិត្តនិងអាមាត្យ ទ្រង់ដាក់ព្រះកេសានិងព្រះមស្សុ ទ្រង់ប្រដាប់ព្រះព័ស្ត្រជ្រលក់ទឹកចត់ ស្តេចចេញចាកព្រះរាជដំណាក់ ចូលទៅកាន់ផ្នួស ដល់ស៊ីប់នូវភាពជាអ្នកមិនមានកង្វល់ តែមួយព្រះអង្គឯង ទ្រង់ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយចំណែកបព្វជ្ជា យ៉ាងនេះ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយសេចក្តីថាមិនមានបុគ្គលជាគម្រប់ពីរ តើដូចម្តេច ។ ព្រះអង្គទ្រង់ផ្នួសយ៉ាងនេះហើយ ទ្រង់សេពចំពោះព្រៃតូចនិងព្រៃធំ ជាសេនាសនៈស្ងាត់ មិនមានសំឡេង មិនមានសូរគឹកកង ប្រាសចាកខ្យល់ដែលកើតអំពីសរីរៈនៃជន ជាសេនាសនៈដ៏ស្ងប់ស្ងាត់របស់មនុស្ស ដ៏សមគួរដល់ការពួនសម្ងំ ព្រះអង្គទ្រង់ពុទ្ធដំណើរ តែមួយអង្គឯង ទ្រង់ឋិត តែមួយអង្គឯង ទ្រង់គង់ តែមួយអង្គឯង ទ្រង់សម្រេចការផ្ទំ តែមួយអង្គឯង ទ្រង់ចូលទៅបិណ្ឌបាតក្នុងស្រុក តែមួយអង្គឯង ទ្រង់ត្រឡប់មកវិញ តែមួយអង្គឯង ទ្រង់គង់ក្នុងទីរហោស្ថាន តែមួយអង្គឯង ទ្រង់អធិដ្ឋានចង្ក្រម តែមួយអង្គឯង ទ្រង់ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ តែមួយអង្គឯង ហេតុនោះ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយសេចក្តីថាមិនមានបុគ្គលជាគម្រប់ពីរ យ៉ាងនេះ ។

កថំ ភគវា តណ្ហាបហានជ្ឌេន ឯកោ ។ សោ ឯវំ ឯកោ អនុតិយោ អប្ប្ឌមត្តោ អាតាបី បហិ-តត្តោ វិហរន្តោ ជជ្ឌ នេរញ្ជរាយ តីរេ ពោធិរុក្ខ-ម្ហូលេ មហាបធានំ បធហន្តោ មារំ សសេនំ[1] ជ-ម្ម ុ ចឺ បមត្តពន្ធុ រ ិ ជ ិ ត្ វា តណ្ហ ា ជ ាលិ ន ី សរ ិ ត ំ រ ិ ស ត ្ ត ិ ក ំ ប ជ ហ ិ រ ិ ន ោ ជ េ ស ិ ព ្ យ ន ្ ត ី ម ក ា ស ិ អ ន ភ ា-រ ង ្ ក ម េ ស ិ ។

តណ្ហាទុតិយោ បុរិសោ ទីឃមទ្ធាន សំសរំ
ឥត្ថភាវញ្ញថាភាវំ សំសារំ ជាតិវត្តតិ
ឯតមាទីនវំ ញត្វា តណ្ហា ទុក្ខស្ស សម្ភវំ
វីតតណ្ហោ អនាទានោ សតោ ភិក្ខុ បរិព្ជ្ជតិ ។

ឯវំ ភគវា តណ្ហាបហានជ្ឌេន ឯកោ ។

កថំ ភគវា ឯកន្តវីតរាគោតិ ឯកោ ។ ភគស្ស បហីនត្តា ឯកន្តវីតរាគោតិ ឯកោ ។

---

1 សសេនំ ក ណ្ណ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយសេចក្តីថាលះបង់តណ្ហា តើដូចម្តេច ។ ព្រះអង្គតែមួយព្រះអង្គឯង មិនមានបុគ្គលជាគម្រប់ពីរយ៉ាង-នេះហើយ ទ្រង់មិនប្រហែស មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានព្រះទ័យបញ្ជូនទៅកាន់ព្រះនិព្វាន ទ្រង់តាំងសេចក្តីព្យាយាមធំ ទៀបគល់ពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹងនេរញ្ជរា ទ្រង់កម្ចាត់បង់មារព្រមទាំងសេនា ដែលជាអ្នកមិនលះបង់អកុសលធម៌ ជាផៅពង្សនៃបុគ្គលប្រហែស ទ្រង់លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវតណ្ហាមានបណ្តាញ ដែលហូរទៅ ផ្សាយទៅ ក្នុងអារម្មណ៍ផ្សេង ៗ ។

> បុរសដែលមានតណ្ហាជាគម្រប់ពីរ រមែងអន្ទោលទៅកាន់ភាពនៃប្រការនេះ និងភាពនៃប្រការដទៃ អស់កាលដ៏វែង មិនកន្ធងនូវសង្សារបាន ភិក្ខុអ្នកមានស្មារតី មិនមានសេចក្តីប្រកាន់ ប្រាសចាកតណ្ហា ដឹងទោសនេះហើយ តែងជៀសវាង នូវការកើតនៃទុក្ខ ព្រោះតណ្ហា ។

ព្រះមានព្រះភាគតែមួយព្រះអង្គឯង ដោយសេចក្តីថាលះបង់តណ្ហា យ៉ាងនេះ។

ព្រះមានព្រះភាគតែមួយព្រះអង្គឯងព្រោះហេតុទ្រង់ប្រាសចាករាគៈដោយចំណែកមួយ តើដូចម្តេច ។ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាករាគៈដោយចំណែកមួយ ព្រោះទ្រង់លះរាគៈហើយ ។

ឧោសស្ស បហីនត្តា ឯកន្តវីតឧោសោតិ ឯកោ ។

មោហស្ស បហីនត្តា ឯកន្តវីតមោហោតិ ឯកោ ។

កិលេសានំ បហីនត្តា ឯកន្តនិក្កិលេសោតិ ឯកោ ។

ឯកមំ ភគវា ឯកាយនមក្តំ ឯតោតិ ឯកោ ។

ឯកាយនមក្តោ រុច្ចន្តិ ចត្តារោ សតិប្បដ្ឋានា ។ បេ ។

អរិយោ អដ្ឋង្គិកោ មក្តោ ។

ឯកាយនំ ជាតិខយន្តទស្សី

មក្តំ បជានាតិ ហិតានុកម្បី

ឯតេន មក្តេន តរឹសុ បុព្វេ

តរិស្សន្តិ ចេវ តរន្តិ ឱឃន្តិ ។

ឯវំ ភគវា ឯកាយនមក្តំ ឯតោតិ ឯកោ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាកទោស: ដោយចំណែកមួយ ព្រោះទ្រង់លះទោស:ហើយ ។ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាកមោហ:ដោយចំណែកមួយ ព្រោះទ្រង់លះមោហ:ហើយ ។ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់មិនមានកិលេស ដោយចំណែកមួយ ព្រោះទ្រង់លះកិលេសទាំងឡាយហើយ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ស្តេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង តើដូចម្តេច ។ សតិប្បដ្ឋាន ៤ ។ លេ ។ មគ្គដ៏ប្រសើរមានអង្គ ៨ លោកហៅថា ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ។

ព្រះពុទ្ធទ្រង់ឃើញ នូវទីបំផុតនៃធម៌ជាទីអស់ជាតិ ទ្រង់អនុ-គ្រោះ នូវប្រយោជន៍ ទ្រង់ជ្រាបច្បាស់នូវផ្លូវ ជាទីទៅនៃបុគ្គលម្នាក់ឯង ចំណែកអ្នកប្រាជ្ញទាំងឡាយ ធ្វើតាមហើយក្នុងអតីត នឹងធ្វើតាមក្នុងអនាគត កំពុងធ្វើតាមក្នុងបច្ចុប្បន្ន នូវឱ្យ: តាមផ្លូវនេះ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ស្តេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង យ៉ាងនេះ ។

ឥមំ ភិក្ខវ ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិ-
សម្ពុជ្ឌោតិ ឯកោ ។ ពោធិ រុច្ចតិ ចតូសុ មគ្គេសុ
ញាណំ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ។ បេ ។ ធម្ម-
វិចយសម្ពោជ្ឌង្គោ រីមំសា វិបស្សនា សម្មាទិដ្ឋិ ។
ភិក្ខវ តេន ពោធិញ្ញាណេន សព្ពេ សង្ខារា អនិច្ចា-
តិ ពុជ្ឌឺ ។ បេ ។ យង្គ្ជិញ្ចិ សមុទយធម្មំ សព្ពន្ត
ជិរោធធម្មន្ត ពុជ្ឌឺ ។ អថវ យំ ពុជ្ឌឺតព្ពំ អនុពុជ្ឌ-
តព្ពំ បដិពុជ្ឌឺតព្ពំ សម្ពុជ្ឌឺតព្ពំ អធិគន្តព្ពំ ផុសិតព្ពំ
សច្ឆិកាតព្ពំ សព្ពន្ត តេន ពោធិញ្ញាណេន ពុជ្ឌឺ
អនុពុជ្ឌឺ បដិពុជ្ឌឺ សម្ពុជ្ឌឺ អធិគច្ឆិ ផុសេសិ សច្ឆា-
កាសិ ។ ឯវំ ភិក្ខវ ឯកោ អនុត្តរំ សម្មាសម្ពោធឹ
អភិសម្ពុជ្ឌោតិ ឯកោ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ត្រាស់ដឹង សម្មាសម្ពោធិញ្ញាណដ៏ប្រសើរ តែមួយព្រះអង្គឯង តើដូចម្តេច ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ។ បេ ។ ធម្មវិចយសម្ពោជ្ឌង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិ ក្នុងមគ្គ ៤ លោកហៅថា ពោធិ ។ ដោយសារ ពោធិញ្ញាណនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ដឹងថា សង្ខារទាំង-ពួងមិនទៀង ។ បេ ។ ត្រាស់ដឹងថា របស់ណានីមួយ មានការកើត ឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ ម៉្យាងទៀត ធម្មជាតណា ដែលបណ្ឌិត គប្បីដឹង គប្បីត្រាស់ដឹង តាម គប្បីត្រាស់ដឹងចំពោះ គប្បីត្រាស់ដឹងព្រម គប្បីបាន គប្បីពាល់ ត្រូវ គប្បីធ្វើឲ្យជាក់ច្បាស់ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹង ត្រាស់ ដឹងតាម ត្រាស់ដឹងចំពោះ ត្រាស់ដឹងព្រម បានពាល់ត្រូវ ធ្វើឲ្យ ជាក់ច្បាស់ នូវធម្មជាតទាំងអស់នោះ ដោយសារពោធិញ្ញាណនោះ ។ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ត្រាស់ដឹង សម្មាសម្ពោធិញ្ញាណដ៏ប្រសើរ តែមួយព្រះអង្គ យ៉ាងនេះ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

តមនុនោតិ ភគវា រាគតមំ នោសតមំ មោហតមំ មានតមំ ទិដ្ឋិតមំ កិលេសតមំ ទុច្ចរិតតមំ អន្ធការណំ អចក្ខុការណំ អញ្ញាណការណំ បញ្ញានិរោធិកំ វិឃាតបក្ខិកំ អនិញ្ជនសំវត្តនិកំ ឧនិ បនុនិ បជហិ វិនោ-ទេសិ ព្យន្តីមការិ អនភាវគ្គមេសិ ។ អាសីនោតិ និសិន្នោ ភគវា ចាសាណកេ ចេតិយេតិ អាសីនោ ។

ឧតស្ស បស្ស អាសីនំ មុនឺ ទុក្ខស្ស ចារកុំ

សាវកា បយិរុចាសន្តិ តេវិជ្ជា មចុហាយិនោតិ ។ ឯវំ ភគវា អាសីនោ ។ អថវា ភគវា សញ្ជោស្ស-ក្ខប្ជដិប្ជស្ស[1] ទ្ធត្តា អាសីនោ សោ រុជ្ជវាសោ ចិណ្ណាចរណោ ។ បេ ។ ជាតិជរាមរណសំសារោ ឧត្តិ តស្ស បុនព្ភវោតិ ឯវម្ជ ភគវា អាសីនោតិ ឯកោ តមនុជាសីនោ ។

---

1 ម. អប្ជោស្ស្ជ្ជ្ជ្ជ្ជ្ជ្ជ ។

ពាក្យថា ទ្រង់បន្ទោបង់ផងដឹត គឺ ព្រះមានព្រះភាគ ទ្រង់បន្ទោបង់ ទម្លាក់ចោល លះបង់ ចោះបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវផងដឹតគឺរាគ: ផងដឹតគឺទោស: ផងដឹតគឺមោហ: ផងដឹតគឺមានៈ ផងដឹតគឺទិដ្ឋិ ផងដឹតគឺកិលេស ផងដឹតគឺទុច្ចរិត គ្រឿងធ្វើឲ្យផងដឹត ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យមានការដឹង នាំឲ្យរលត់បញ្ញា ជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីនិព្វាន ។ ពាក្យថា ទ្រង់គង់នៅជាសុខ គឺ ព្រះមានព្រះភាគ ទ្រង់គង់ជិតបាសាណកចេតិយ ហេតុនោះ ឈ្មោះថាទ្រង់គង់នៅជាសុខ ។

ពួកសាវ័កដែលបានវិជ្ជា ៣ លះបង់នូវមច្ចុ តែងចូលទៅអង្គុយ
ជិតព្រះមុនិ ទ្រង់ដល់ត្រើយនៃទុក្ខ ទ្រង់គង់នៅក្បែរខាងក្នុ ។

ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថាទ្រង់គង់នៅជាសុខ យ៉ាងនេះ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់គង់នៅជាសុខ ព្រោះព្រះអង្គគ្របសង្កត់សេចក្ដីខ្ជល់ខ្ជាយទាំងអស់ ព្រះអង្គមានការនៅ (ក្នុងអរិយវាស) នៅរួចហើយ មានចរណ:សន្សំហើយ ។ បេ ។ ភពថ្មី គឺជាតិ ជរ មរណ: សង្សារ នៃព្រះអង្គមិនមាន ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថាទ្រង់គង់នៅជាសុខ យ៉ាងនេះឯង ហេតុនោះ (លោកពោលថា) តែមួយព្រះអង្គឯង ទ្រង់បន្ទោបង់ផងដឹត គង់នៅជាសុខ ។

[១៦៤] ជុតិមា សោ បភង្ករោតិ ជុតិមាតិ ជុតិមា[១] បណ្ហិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវី ។ បភង្ករោតិ អាលោកករោ ឱភាសករោ ទីបង្ករោ ឧជ្ជោតករោ បជ្ជោតករោតិ ជុតិមា សោ បភង្ករោ ។

[១៦៥] គោតមោ ភូរិបញ្ញោណោតិ គោតមោ ភូរិប្បញ្ញោណោ ញាណប្បញ្ញោណោ បញ្ញាឆជោ បញ្ញាកេតុ បញ្ញាធិបតេយ្យោ វិចយពហុលោ បវិចយពហុលោ ឱក្ខាយនពហុលោ សមោក្ខាយ-ឆជម្ហោ វិភូតវិហារី តច្ចរិតោ តព្ពហុលោ តក្ក-រុកោ តន្ធិន្ធោ តប្ជាណោ តប្ជញ្ជរោ តទធិមុត្តោ តទាធិបតេយ្យោ ។

ឆជោ រថស្ស បញ្ញាណំ ធូមោ បញ្ញាណមក្ខិនោ
ភជា រជ្ជស្ស បញ្ញាណំ ភត្តា បញ្ញាណមិត្ថិយាតិ ។

---

១ ម. ជុតិមា មតិមា ។

[១៦៤] ពាក្យថា ព្រះគោតមនោះ ទ្រង់មានរស្មីរុងរឿង ទ្រង់ធ្វើពន្ធឺ (ដល់លោក) ត្រង់ពាក្យថា ទ្រង់មានរស្មីរុងរឿង គឺ ទ្រង់មានពន្ធឺជាបណ្ឌិត មានប្រាជ្ញា មានប្រាជ្ញាជាគ្រឿងត្រាស់ដឹង មានញាណ មានប្រាជ្ញាក្ងីច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ។ ពាក្យថា ទ្រង់ធ្វើពន្ធឺ គឺ ទ្រង់ធ្វើឲ្យឃើញច្បាស់ ទ្រង់ធ្វើពន្ធឺ ទ្រង់ធ្វើប្រទីប ទ្រង់ធ្វើរស្មី ទ្រង់ធ្វើពន្ធឺសព្វ ហេតុនោះ (លោកពោលថា) ព្រះគោតមនោះ ទ្រង់មានរស្មីរុងរឿង ទ្រង់ធ្វើពន្ធឺ (ដល់លោក) ។

[១៦៥] ពាក្យថា ព្រះគោតមមានបញ្ញាជាគ្រឿងប្រាកដ គឺ ព្រះគោតម ទ្រង់មានបញ្ញាជាគ្រឿងប្រាកដ មានញាណជាគ្រឿងប្រាកដ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ មានប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិចារណាសព្វ ច្រើនដោយការប្រមើលមើល មានការប្រមើលមើលជាធម្មតា ជ្រាបច្បាស់ជាប្រក្រតី ប្រព្រឹត្តដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ធ្ងន់ដោយប្រាជ្ញានោះ ទេរទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ បង្ហោនទៅរកប្រាជ្ញានោះ ជាអធិបតី ។

រថមានទង់ជាគ្រឿងប្រាកដ ក្ងើងមានផ្ទៃងជាគ្រឿងប្រាកដ ដែនមានស្តេចជាគ្រឿងប្រាកដ ស្ត្រីមានកស្តាជាគ្រឿងប្រាកដ ។

ឯវមេវ គោតមោ ភូរិប្បញ្ញាណោ ញាណប្បញ្ញាណោ បញ្ញាធជោ បញ្ញាកេតុ បញ្ញាធិបតេយ្យោ វិចយពហុលោ បវិចយពហុលោ ឱក្ខាយនពហុលោ សមោក្ខាយនធម្មោ វិភូតវិហារី តច្ចរិតោ តព្ពហុលោ តគ្គរុកោ តន្និន្នោ តប្បោណោ តប្បព្ភារោ តទធិមុត្តោ តទាធិបតេយ្យោតិ គោតមោ ភូរិបញ្ញាណោ ។

[១៦៦] គោតមោ ភូរិមេធសោតិ ភូរិ វុច្ចតិ បថវី ។ បថវីសមាយ[១] វិបុលាយ វិត្ថតាយ បញ្ញាយ សមន្នាគតោ ។ មេធា វុច្ចតិ បញ្ញា យា បញ្ញា បជានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ ភគវា ឥមាយ មេធាយ បញ្ញាយ ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ[២] សមន្នាគតោ តស្មា ពុទ្ធោ ភូរិមេធសោតិ[៣]

១ ម. តាយ បថវីសមាយ បញ្ញាយ ។ ២ ម. សម្បន្នោ ។ ៣ ម. សុមេធសោតិ ។

ព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ មានញាណជាគ្រឿងប្រាកដ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ មានប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិចារណាសព្វ ច្រើនដោយការប្រមើលមើល មានការប្រមើលមើលជាធម្មតា ជ្រាបច្បាស់ជាប្រក្រតី ប្រព្រឹត្តដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ធ្ងន់ដោយប្រាជ្ញានោះ ទេរទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ បង្ហើនទៅរកប្រាជ្ញានោះ យកប្រាជ្ញានោះជាអធិបតី យ៉ាងនេះឯង ហេតុនោះ (លោកពោលថា) ព្រះគោតមមានប្រាជ្ញាជាគ្រឿងប្រាកដ ។

[១៦៦] ពាក្យថា ព្រះគោតមទ្រង់មានប្រាជ្ញាដូចផែនដី អធិប្បាយថា ប្រឹថពី លោកហៅថា ផែនដី ។ ព្រះគោតម ទ្រង់ប្រកបដោយប្រាជ្ញាស្មើដោយប្រឹថពី ដ៏ធំទូលាយ ។ បញ្ញា លោកហៅថា មេធា បានដល់ ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិ-ចារណាធម៌ ការយល់ត្រូវ ។ ព្រះមានព្រះភាគ ទ្រង់ប្រកប ប្រកបព្រមចូលទៅជិតដល់ ចូលទៅជិតដល់ព្រម ដល់ស៊ប់ ដល់ស៊ប់ព្រម រួបរួមដោយមេធាគឺប្រាជ្ញានេះ ហេតុនោះព្រះពុទ្ធ ឈ្មោះថាមានប្រាជ្ញាដូចផែនដី

គោតមោ ភូរិមេធសោ ។ តេជាមា បិជ្ជិយត្ថេ

ឯកោ តមនុជាសីនោ ជុតិមា សោ បភង្ករោ

គោតមោ ភូរិបញ្ញាណោ គោតមោ ភូរិមេធសោតិ ។

[១៦៧] យោ មេ ធម្មមនេសេសិ សន្ទិដ្ឋិកមកាលិកំ

តណ្ហាក្ខយមនីតិកំ យស្ស ឧត្តិ ឧបមា ក្វចិ ។

[១៦៨] យោ មេ ធម្មមនេសេសីតិ យោតិ

យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ

អនុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឌ

ឥត្ថ ច សព្ពញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ ។

ហេតុនោះ (លោកពោលថា) ព្រះគោតមទ្រង់មានប្រាជ្ញាដូចផែនដី ។ ហេតុនោះ ព្រះបិङ្គិយត្តេរពោលថា

ព្រះគោតមអង្គនោះ តែមួយព្រះអង្គឯង ទ្រង់បន្ទោបង់ងងឹត គង់នៅជាសុខ ទ្រង់មានរស្មីរុងរឿង ធ្វើពន្ធឺ (ដល់លោក) ព្រះគោតមមានប្រាជ្ញា ជាគ្រឿងប្រាកដ ព្រះគោតមមានប្រាជ្ញាដូចផែនដី ។

[១៦៧] ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ហើយ ដល់ខ្ញុំ ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ។

[១៦៨] ពាក្យថា ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់ខ្ញុំ ត្រង់ពាក្យថា អង្គណា គឺ ព្រះមានព្រះភាគអង្គណា ទ្រង់កើតឯង មិនមានអាចារ្យ ត្រាស់ដឹងសច្ចៈទាំងឡាយដោយព្រះអង្គឯង ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮមកក្នុងកាលមុន ព្រះអង្គទ្រង់ដល់នូវភាពជាសព្វញ្ញូក្នុងសច្ចៈទាំងនោះផង ទ្រង់ដល់នូវភាពជាអ្នកស្ទាត់ក្នុងពលៈទាំងឡាយផង ។

ធម្មមនេសេសីតិ ធម្មន្តិ អាទិកល្យាណំ មជ្ឈេក-
ល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ
កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ សតិប្ផ្ឋានេ[១]
។ បេ ។ អរិយំ អដ្ឋង្គិកំ មគ្គំ និញ្ជានញ្ច និញ្ជានគា-
មិនិញ្ច បដិបទំ អាចិក្ខិ ទេសេសិ បញ្ញបេសិ
បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីមការិ បការេសីតិ
យោ មេ ធម្មមនេសេសិ ។

[១៦៩] សន្ទិដ្ឋិកមការិកន្តិ សន្ទិដ្ឋិកំ អការ-
លិកំ ឯហិបស្សិកំ ឱបនយិកំ បច្ចត្តំ វេទិតព្ពំ
វិញ្ញូហីតិ ឯវំ សន្ទិដ្ឋិកមការិកំ ។ អថវា យោ
និដ្ឋេ ធម្មេ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ តស្ស
មគ្គស្ស អនន្តរា សមនន្តរា អធិកច្ចតេ ផលំ
ទិន្នតិ បដិលភតីតិ ឯវម្ប្យិ សន្ទិដ្ឋិកមការិកំ ។

---

១ ម. ចត្តារោ សតិប្ផ្ឋានេ ។

ពាក្យថា ទ្រង់សម្តែងនូវធម៌ ត្រង់ពាក្យថា នូវធម៌ គឺ ទ្រង់ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក រៃកញ្ជែក ធ្វើឲ្យរាក់ ប្រកាស នូវព្រហ្មចរិយធម៌ មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ផង សតិប្បដ្ឋានផង ។ បេ ។ អដ្ឋង្គិកមគ្គដ៏ប្រសើរផង និព្វានផង បដិបទាជាដំណើរទៅកាន់ព្រះនិព្វានផង ហេតុនោះ (លោកពោលថា) ព្រះគោតមអង្គណា ទ្រង់សម្តែងនូវធម៌ដល់ខ្ញុំ ។

[១៦៥] ពាក្យថា ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល គឺ ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី គួរបង្ហោនមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងចំពោះខ្លួន ហេតុនោះ (លោកពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះ ។ មួយទៀត បុគ្គលណា ចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរក្នុងបច្ចុប្បន្ន បុគ្គលនោះរមែងចូប បាន បានចំពោះ នូវផលក្នុងលំដាប់ លំ-ដាប់ស្មើនៃមគ្គនោះ ហេតុនោះ (លោកពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះក៏បាន ។

យថា មនុស្សា កាលិកំ ធនំ ទត្វា អនន្តរា ន លភន្តិ កាលំ អាគមេន្តិ នេវាយំ ធម្មោ ។ យោ និព្វានេ ធម្មេ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ តស្ស មគ្គស្ស អនន្តរា សមនន្តរា អធិគច្ឆតេវ ផលំ វិន្ទតិ បដិលភតិ ន បរត្ថ ន បរលោកេ ឯវំ អកាលិកន្តិ សន្ទិដ្ឋិកមកាលិកំ ។

[១៧០] តណ្ហាក្ខយមនីតិកន្តិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហាក្ខយន្តិ តណ្ហាក្ខយំ រាគក្ខយំ ទោសក្ខយំ មោហក្ខយំ គតិក្ខយំ ឧបបត្តិក្ខយំ បដិសន្ធិក្ខយំ ភវក្ខយំ សំសារក្ខយំ វដ្ដក្ខយំ ។ អនីតិកន្តិ ឦតិ វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ ឦតិប្បហានំ ឦតិវូបសមោ ឦតិប្បដិនិស្សគ្គោ ឦតិប្បដិប្បស្សទ្ធិ អមតំ និព្វានន្តិ តណ្ហាក្ខយមនីតិកំ ។

មនុស្សទាំងឡាយឲ្យទ្រព្យ ប្រកបដោយកាល មិនបានផលក្នុងលំដាប់ រមែងរង់ចាំកាលយ៉ាងណា ធម៌នេះមិនមែនយ៉ាងនោះទេ ។ បុគ្គលណា ចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរក្នុងបច្ចុប្បន្ន បុគ្គលនោះ រមែងចួប បាន បានចំពោះ នូវផលក្នុងលំដាប់ លំដាប់ស្មើនៃមគ្គនោះ មិនមែនបានក្នុងពេលដទៃ មិនមែនបានក្នុងលោកដទៃទេ ជាធម៌ឲ្យផលមិនរង់ចាំកាលយ៉ាងនេះ ហេតុនោះ (លោកពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ។

[១៧០] ពាក្យថា ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ត្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ជាគ្រឿងអស់តណ្ហា គឺ ជាគ្រឿងអស់តណ្ហា អស់រាគ: អស់ទោស: អស់មោហ: អស់គតិ អស់ឧប-បត្តិ អស់បដិសន្ធិ អស់ភព អស់សង្សារ អស់វដ្ត: ។ ពាក្យថា មិនមានចង្រៃ សេចក្តីថា កិលេស ខន្ធ និងអភិសង្ខារ លោកហៅថា ចង្រៃ ។ ការលះចង្រៃ ការសូប់ចង្រៃ ការរលាស់ចោលចង្រៃ ការគ្របសង្កត់ចង្រៃ អមតនិព្វាន ហេតុនោះ (លោកពោលថា) ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ។

១៨៣

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

[១៧១] យស្ស នត្ថិ ឧបមា ក្វចីតិ យស្សាតិ និព្វានស្ស ។ នត្ថិ ឧបមាតិ ឧបមា នត្ថិ ឧបនិធា នត្ថិ សទិសំ នត្ថិ បដិភាគោ នត្ថិ ន សំវិជ្ជតិ នុបល-ព្ភតិ ។ ក្វចីតិ ក្វចិ កិម្ហិចិ កត្ថចិ អជ្ឈត្តំ វា ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វាតិ យស្ស នត្ថិ ឧបមា ក្វចិ ។ តេនាហ បិង្គិយត្ថេរោ

យោ មេ ធម្មមទេសេសិ សន្ទិដ្ឋិកមកាលិកំ
តណ្ហាក្ខយមនីតិកំ យស្ស នត្ថិ ឧបមា ក្វចីតិ ។

[១៧២] កិន្នុ តម្ហា វិប្បវសសិ មុហុត្តមបិ បិង្គិយ
គោតមា ភូរិបញ្ញាណា គោតមា ភូរិមេធសា ។

[១៧១] *អធិប្បាយពាក្យថា ដែលជាធម៌មិនមានឧបមាក្នុងទីណាមួយ ត្រង់ពាក្យថា ធម៌ បានដល់ និព្វាន ។ ពាក្យថា មិនមានឧបមា គឺ មិនមានការប្រៀប មិនមានសេចក្ដីប្រៀបធៀប មិនមានភាពស្មើគ្នា មិនមាន មិនមានព្រម មិនបាន នូវចំណែកប្រៀប ។ ពាក្យថា ក្នុងទីណាមួយ គឺ ក្នុងទីណាមួយ ក្នុងទីណា ។ ក្នុងទីនីមួយ ជាខាងក្នុង ឬខាងក្រៅ ឬទាំងខាងក្នុង ទាំងខាងក្រៅ ហេតុនោះ (លោកពោលថា) ដែលជាធម៌មិនមានឧបមាក្នុងទីណាមួយ ។ ហេតុនោះ ព្រះបិង្គិយត្តេរពោលថា*

ព្រះគោតមអង្គណា ទ្រង់សម្ដែងធម៌ហើយ ដល់ខ្ញុំ ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផល មិនរង់ចាំកាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ។

[១៧២] *(ពាវរីព្រាហ្មណ៍សួរថា) បពិត្រព្រះបិង្គិយ: ចុះ លោកម្ចាស់ ធ្លាប់ឃ្លាតអំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ អំពីព្រះគោតម មានប្រាជ្ញាដូចផែនដីនោះ សូម្បីមួយរំពេចដែរឬ ។*

[១៧៣] កិន្នុ តម្ហា វិប្បវសសីតិ កិន្នុ តម្ហា ពុទ្ធម្ហា វិប្បវសសិ[១] អបេសិ អបគច្ឆសិ វិនា ហោសីតិ កិន្នុ តម្ហា វិប្បវសសិ ។

[១៧៤] មុហុត្តមបិ បិង្គិយាតិ មុហុត្តម្បិ ខណម្បិ លយម្បិ វស្សម្បិ អត្ថម្បីតិ មុហុត្តមបិ[២] ។ បិង្គិ-យាតិ ពាវរី តំ នត្តារំ នាមេន អាលបតិ[៣] ។

[១៧៥] គោតមា ភូរិប្បញ្ញាណាតិ គោតមា ភូរិប្បញ្ញាណា ញាណប្បញ្ញាណា បញ្ញាធជា បញ្ញា-កេតុម្ហា បញ្ញាធិបតេយ្យម្ហា វិចយពហុលា បវិចយ-ពហុលា ឱក្ខាយនពហុលា សមោក្ខាយនធម្មា វិភូតវិហារិម្ហា តច្ចរិតា តព្ពហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា តទធិមុត្តា តទាធិបតេយ្យម្ហាតិ គោតមា ភូរិប្បញ្ញាណា ។

---

១ ម. កឹនុ តម្ហា វិប្បវសីតិ កឹនុ ពុទ្ធម្ហា វិប្បវសិ ។ ២ ម. មុហុត្តមបិ សិង្គិយាតិ មុហុត្តំបិ ខណំបិ លយំបិ វយំបិ អទ្ធំបីតិ មុហុត្តមបិ សិង្គិយ ។ ៣ ម. សិង្គិយាតិ ពាវរី តំ នត្តារំ នាមេន អាលបតីតិ នត្ថិ ។

[១៧៣] ពាក្យថា ចុះលោកម្ចាស់ ធ្លាប់ឃ្លាតអំពីព្រះគោតមនោះដែរឬ គឺ ចុះលោកម្ចាស់ ធ្លាប់ឃ្លាតឃ្លា ឃ្លាតចេញ ថយចេញ រៀរចេញ អំពីព្រះពុទ្ធនោះដែរឬ ហេតុនោះ (ព្រាហ្មណ៍ពោលថា) ចុះលោកម្ចាស់ ធ្លាប់ឃ្លាតអំពីព្រះគោតមនោះដែរឬ ។

[១៧៤] ពាក្យថា បពិត្រព្រះបិង្គិយៈ... សូម្បីមួយរំពេច គឺ សូម្បីមួយរំពេច មួយខណៈ មួយស្រមៃ មួយចំណែក មួយថ្ងៃ ហេតុនោះ (ព្រាហ្មណ៍ពោលថា) សូម្បីមួយរំពេច ។ ពាក្យថា បពិត្រព្រះបិង្គិយៈ គឺ ពាវរីព្រាហ្មណ៍ ហៅចៅនោះដោយនាម ។

[១៧៥] ពាក្យថា អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ គឺ អំពីព្រះគោតមទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ មានញាណជាគ្រឿងប្រាកដ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ យកប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិចារណាសព្វ ច្រើនដោយការប្រមើលមើល មានការប្រមើលមើលព្រមជាធម្មតា ជ្រាបច្បាស់ជាប្រក្រតី ប្រព្រឹត្តដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ធ្ងន់ដោយប្រាជ្ញានោះ ទេរទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ ឱនទៅរកប្រាជ្ញានោះ យកប្រាជ្ញានោះជាអធិបតី ហេតុនោះ (ព្រាហ្មណ៍ពោលថា) អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

[១៧៦] គោតមា ភូរិមេធសាតិ ភូរិ វុច្ចតិ បឋវី ។ ភគវា ឥមាយ បឋវីសមាយ វិបុលាយ វិត្ថតាយ បញ្ញាយ សមន្នាគតោ ។ មេធា វុច្ចតិ បញ្ញា យា បញ្ញា បជានណា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ ភគវា ឥមាយ មេធាយ បញ្ញាយ ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា ពុទ្ធោ ភូរិមេធសោតិ គោតមា ភូរិមេធសា ។ តេនាហ សោ ពាវរី ព្រាហ្មណោ

កិន្តុ តម្ហា វិប្ផ្ផវសិ មុហុត្តមបិ ឋិត្តិយ
គោតមា ភូរិប្ផ្ផញ្ញាណា គោតមា ភូរិមេធសាតិ ។

[១៧៧] យោ តេ ធម្មមទេសេសិ សន្ទិដ្ឋិកមកាលិកំ
តណ្ហាក្ខយមនីតិកំ យស្ស ន ត្ថិ ឧបមា ក្វចិ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេស

[១៧៦] ពាក្យថា អំពីព្រះគោតម មានប្រាជ្ញាដូចផែនដី សេចក្ដីថា ប្រឹថពី លោកហៅថា ផែនដី ។ ព្រះមានព្រះភាគ ទ្រង់ប្រកបដោយប្រាជ្ញា ស្មើដោយផែនដី ដ៏ធំទូលាយនេះ ។ ប្រាជ្ញា លោកហៅថា មេធា បានដល់ ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារ-ណាធម៌ ការយល់ត្រូវ ។ ព្រះមានព្រះភាគ ប្រកប ប្រកបព្រម ចូលទៅជិតដល់ ចូលទៅជិតដល់ព្រម ដល់ស៊ីប់ ដល់ស៊ីប់ព្រម រួបរួម ដោយមេធាគឺប្រាជ្ញានេះ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមានប្រាជ្ញាដូច ផែនដី ។ ហេតុនោះ (ព្រាហ្មណ៍ពោលថា) អំពីព្រះគោតម មាន ប្រាជ្ញាដូចផែនដី ។ ហេតុនោះ ពាវរីព្រាហ្មណ៍នោះពោលថា

> បពិត្រព្រះបិង្គិយៈ ចុះលោកម្ចាស់ ធ្លាប់ឃ្លាតអំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ អំពីព្រះគោតម មាន ប្រាជ្ញាដូចផែនដីនោះ សូម្បីមួយរំពេចដែរឬ ។
>
> [១៧៧] ព្រះគោតមអង្គណា ទ្រង់សម្ដែងធម៌ដល់លោកម្ចាស់ ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ ចាំកាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌មិន មានឧបមា ក្នុងទីណាមួយ ។

[១៧៨] យោ តេ ធម្មមនេសេសីតិ យោតិ យោ សោ ភគវា ។ បេ ។ តត្ត ច សព្ពញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ ។ ធម្មមនេសេសីតិ ធម្មន្តិ អាទិកល្យាណំ ។ បេ ។ និព្ពានគាមិនិញ្ច បដិបទំ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីមកាសិ បកាសេសីតិ យោ តេ ធម្មមនេសេសិ ។

[១៧៩] សន្ទិដ្ឋិកមកាលិកន្តិ សន្ទិដ្ឋិកំ អកា-លិកំ ឯហិបស្សិកំ ឱបនយិកំ បច្ចត្តំ វេទិតព្ពំ វិញ្ញូហីតិ ឯវំ សន្ទិដ្ឋិកមកាលិកំ ។ អថវា យោ ជិនេ្ជ ធម្ម អរិយ អដ្ឋង្គិកំ មគ្គ ភាវេតិ តស្ស មគ្គស្ស អនន្តរា សមនន្តរា អធិកច្ចតេ ផលំ ទិន្ទតិ បដិលភតីតិ ឯវម្ៀ សន្ទិដ្ឋិកមកាលិកំ[1] ។

---

១ ម. សន្ទិដ្ឋិកំ អកាលិកន្តិ យថា ។

[១៧៨] ត្រង់ពាក្យថា ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់លោកម្ចាស់ ត្រង់ពាក្យថា អង្គណា គឺ ព្រះមានព្រះភាគអង្គណា ។ បេ ។ ទ្រង់ដល់នូវភាពជាសព្វញ្ញូ ក្នុងសច្ចៈនោះផង នូវភាពជាអ្នកស្ទាត់ក្នុងពលៈទាំងឡាយផង ។ ពាក្យថា ទ្រង់សម្តែងធម៌ ត្រង់ពាក្យថា ធម៌ គឺ ទ្រង់ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក រៃកញ្ជែក ធ្វើឲ្យរាក់ប្រកាស នូវព្រហ្មចរិយធម៌ មានពីរោះបទដើម ។ បេ ។ នូវបដិបទាជាដំណើរទៅកាន់ព្រះនិព្វានផង ហេតុនោះ (ព្រាហ្មណ៍ពោលថា) ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់លោកម្ចាស់ ។

[១៧៩] ពាក្យថា ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល គឺ ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី គួរបង្ហោនមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនទាំងឡាយគប្បីដឹងចំពោះខ្លួន ហេតុនោះ (ព្រាហ្មណ៍ពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះ ។ មួយទៀត បុគ្គលណាចម្រើនអដ្ឋង្គិកមគ្គ ដ៏ប្រសើរក្នុងបច្ចុប្បន្ន បុគ្គលនោះ រមែងចួប បាន បានចំពោះនូវផលក្នុងលំដាប់លំដាប់ស្មើនៃមគ្គនោះ ហេតុនោះ (ព្រាហ្មណ៍ពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះក៏បាន ។

យថា មនុស្ស កាលិកំ ឆនំ ឆត្វា អនន្តរា ន លភន្តិ កាលំ អាគមេន្តិ ឌេវាយំ ឆម្មោ ។ យោ ជិជ្ជេ ឆម្ម អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ តស្ស មគ្គស្ស អនន្តរា សមនន្តរា អធិកច្ចតេ ផលំ ទ្ធិតិ បដិលភតិ ន ឋត្ត ន ឋរលោកេ ឯ អកាលិកន្តិ សន្ធិដ្ឋិកមកាលិកំ ។

[១៨០] តណ្ហាក្ខយមនីតិកន្តិ តណ្ហាតិ ១ូបត-ណ្ហា សទ្ទតណ្ហា ១ន្ធតណ្ហា ១សតណ្ហា ១ោដ្ឋព្ព-តណ្ហា ឆម្មតណ្ហា ។ តណ្ហាក្ខយន្តិ តណ្ហាក្ខយំ ១ាតក្ខយំ ១ោសក្ខយំ ១ោហក្ខយំ ១តិក្ខយំ ១ុបបត្តិ-ក្ខយំ បដិសន្ធិក្ខយំ ១ាវក្ខយំ សំសារក្ខយំ ១ដ្ឋក្ខ-យំ ។ អនីតិកន្តិ ១ាតិ ១ុ១ូន្តិ ១ិលេសា ១ ១ន្ធា ១ អ១ិសង្ខារា ១ ។ ១ាតិ១ូ១ហានំ ១ាតិ១ូ១សមោ ១ាតិ១ូ១ដិនិ១ូ១ក្ខោ ១ាតិ១ូ១ដិ១ូ១ស្ស១ន្ធិ អ១ត១ំ ១ិ១ាន១ន្តិ តណ្ហាក្ខយមនីតិកំ ។

មនុស្សទាំងឡាយឲ្យទ្រព្យ ប្រកបដោយកាល រមែងមិនបានផល ក្នុងលំដាប់ តែងរង់ចាំកាលយ៉ាងណា ធម៌នេះមិនមែនយ៉ាងនោះទេ ។ បុគ្គលណាចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរក្នុងបច្ចុប្បន្ន បុគ្គលនោះរមែងចូប បានបានចំពោះនូវផលក្នុងលំដាប់ លំដាប់ស្មើនៃមគ្គនោះ មិនមែនបានក្នុងពេលដទៃ មិនមែនបានក្នុងលោកដទៃទេ ជាធម៌ឲ្យផលមិនរង់ចាំកាលយ៉ាងនេះ ហេតុនោះ (ព្រាហ្មណ៍ពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ។

[១៨០] *ពាក្យថា ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ត្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ជាគ្រឿងអស់តណ្ហា គឺ ជាគ្រឿងអស់តណ្ហា អស់រាគៈ អស់ទោសៈ អស់មោហៈ អស់គតិ អស់ឧបបត្តិ អស់បដិសន្ធិ អស់ភព អស់សង្សារ អស់វដ្តៈ ។ ពាក្យថា មិនមានចង្រៃ សេចក្តីថា កិលេស ខន្ធ និងអភិសង្ខារ លោកហៅថាចង្រៃ ។ ការលះចង្រៃ ការសូប់ចង្រៃ ការរលាស់ចោលចង្រៃ ការគ្របសង្កត់ចង្រៃ អមតនិព្វាន ហេតុនោះ (ព្រាហ្មណ៍ពោលថា) ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ។*

[១៨១] យស្ស នត្ថិ ឧបមា ក្វចីតិ យស្សាតិ និព្វានស្ស ។ នត្ថិ ឧបមាតិ ឧបមា នត្ថិ ឧបនិធា នត្ថិ សទិសំ នត្ថិ បដិភាគោ នត្ថិ ន សំវិជ្ជតិ នុបលព្ភតីតិ នត្ថិ ឧបមា ។ ក្វចីតិ ក្វចិ កិម្ហិចិ កត្ថចិ អជ្ឈត្តំ វា ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វាតិ យស្ស នត្ថិ ឧបមា ក្វចិ ។ តេនាហ សោ ពាវរី ព្រាហ្មណោ

យោ តេ ធម្មមទេសេសិ   សន្ទិដ្ឋិកមកាលិកំ
តណ្ហាក្ខយមនីតិកំ   យស្ស នត្ថិ ឧបមា ក្វចីតិ ។

[១៨២] នាហំ តម្ហា វិប្បវសាមិ   មុហុត្តមបិ ព្រាហ្មណ
គោតមា ភូរិបញ្ញាណា   គោតមា ភូរិមេធសា ។

[១៨១] ពាក្យថា ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ត្រង់ពាក្យថា ដែលជាធម៌ បានដល់និព្វាន ។ ពាក្យថា មិនមានឧបមា គឺ មិនមានការប្រៀប មិនមានសេចក្ដីប្រៀបធៀប មិនមានភាពស្មើគ្នា មិនមាន មិនមានព្រម មិនបាននូវចំណែកប្រៀប ហេតុនោះ (ព្រាហ្មណ៍ពោលថា) មិនមានឧបមា ។ ពាក្យថា ក្នុងទីណាមួយ គឺ ក្នុងទីណាមួយ ក្នុងទីណា ។ ក្នុងទីនីមួយ ជាខាងក្នុង ឬខាងក្រៅ ឬទាំងខាងក្នុងទាំងខាងក្រៅ ហេតុនោះ (ព្រាហ្មណ៍ពោលថា) ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ។ ហេតុនោះ ពាវរីព្រាហ្មណ៍នោះ ពោលថា

ព្រះគោតមអង្គណា ទ្រង់សម្ដែងធម៌ដល់លោកម្ចាស់ ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ។

[១៨២] (ព្រះបិង្គិយត្ថេរពោលថា) បពិត្រព្រាហ្មណ៍ អាត្មាមិនធ្លាប់ឃ្លាត អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ អំពីព្រះគោតម មានប្រាជ្ញាដូចផែនដីនោះ សូម្បីមួយរំពេចទេ ។

[១៨៣] ជាហំ តម្ហា វិប្ផ្ជវសាមីតិ អហំ តម្ហា ពុទ្ធម្ហា ន វិប្ផ្ជវសាមិ ន អបេមិ ន អបកច្ឆামি ន វិជា ហោមីតិ ជាហំ តម្ហា វិប្ផ្ជវសាមិ ។

[១៨៤] មុហុត្តមបិ ព្រាហ្មណាតិ មុហុត្តម្ជិ ខណម្ជិ លយម្ជិ រស្ជម្ជិ អត្តម្ជីតិ មុហុត្តមបិ ។ ព្រាហ្មណាតិ តារវេន មាតុលំ អាលបតិ ។

[១៨៥] គោតមា ភូរិប្ជញ្ញាណាតិ គោតមា ភូរិប្ជញ្ញាណា ញាណប្ជញ្ញាណា បញ្ញាឆជា បញ្ញា-ភេតុម្ហា បញ្ញាជិបតេយ្យម្ហា វិចយពហុលា បវិចយ-ពហុលា ឱក្ខាយនពហុលា សមោក្ខាយនធម្មា វិភូតវិហារិម្ហា តចូរិតា តព្ជហុលា តក្ជុកា តន្ជិន្ជា តប្ជោណា តប្ជញ្ជាភ តឧជិមុត្តា តជាជិបតេយ្ជ-ម្ហាតិ គោតមា ភូរិប្ជញ្ញាណា ។

[១៨៣] ពាក្យថា អាត្មាមិនធ្លាប់ឃ្លាតអំពីព្រះគោតមនោះ គឺ អាត្មាមិនធ្លាប់ឃ្លាតឃ្លា មិនគេចចេញ មិនថយចេញ មិនវៀរចេញ ចាកព្រះពុទ្ធនោះទេ ហេតុនោះ (លោកពោលថា) អាត្មាមិនធ្លាប់ឃ្លាតអំពីព្រះគោតមនោះទេ ។

[១៨៤] ពាក្យថា បពិត្រព្រាហ្មណ៍ . . . សូម្បីមួយរំពេច គឺ សូម្បីមួយរំពេច មួយខណៈ មួយស្រមៃ មួយចំណែក មួយថ្ងៃ ហេតុនោះ (លោកពោលថា) សូម្បីមួយរំពេច ។ ពាក្យថា បពិត្រព្រាហ្មណ៍ គឺ ព្រះបិង្គិយត្តេរ ហៅឪពុកធំដោយគោរព ។

[១៨៥] ពាក្យថា អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ គឺ អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ មានញាណជាគ្រឿងប្រាកដ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ យកប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិចារណាសព្វ ច្រើនដោយការប្រមើលមើល មានការប្រមើលមើលព្រមជាធម្មតា ជ្រាបច្បាស់ជាប្រក្រតី ប្រព្រឹត្តដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ធ្ងន់ដោយប្រាជ្ញានោះ ទេរទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ បង្អោនទៅរកប្រាជ្ញានោះ យកប្រាជ្ញានោះជាអធិបតី ហេតុនោះ (លោកពោលថា) អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ ។

[១៨៦] គោតមា ភូរិមេធសាតិ ភូរិ វុច្ចតិ
បឋវី ។ ភគវា ឥមាយ បឋវីសមាយ វិបុលាយ
វិត្ថតាយ បញ្ញាយ សមន្នាគតោ ។ មេធា វុច្ចតិ
បញ្ញា យា បញ្ញា បជានណា ។ បេ ។ អមោហោ
ធម្មវិចយោ សម្មាទិដ្ឋិ ។ ភគវា ឥមាយ មេធាយ
បញ្ញាយ ឧបេតោ សមុបេតោ ឧបាគតោ សមុបា-
គតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា
ពុទ្ធោ ភូរិមេធសោតិ គោតមា ភូរិមេធសា ។
តេនាហ បិដ្ឋិយត្ថេរោ

ជាហំ តម្ហា វិប្ផ្ផរសាមិ មុហុត្តមបិ ព្រាហ្មណ
គោតមា ភូរិប្ផ្ផញ្ញាណា គោតមា ភូរិមេធសាតិ ។

[១៨៧] យោ មេ ធម្មមទេសេសិ សន្ទិដ្ឋិកមកាលិកំ
តណ្ហាក្ខយមនីតិកំ យស្ស ឧត្តិ ឧបមា ក្វចិ ។

[១៨៦] *ពាក្យថា អំពីព្រះគោតម មានប្រាជ្ញាដូចផែនដី សេចក្តីថា ប្រឹថពី លោកហៅថា ផែនដី ។ ព្រះមានព្រះភាគ ទ្រង់ប្រកបដោយ ប្រាជ្ញាស្មើដោយផែនដី ដ៏ធំទូលាយនេះ ។ ប្រាជ្ញា លោកហៅថា មេធា បានដល់ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារ-ណាធម៌ ការយល់ត្រូវ ។ ព្រះមានព្រះភាគទ្រង់ប្រកប ប្រកបព្រម ចូលទៅជិតដល់ ចូលទៅជិតដល់ព្រម ដល់ស៊ីប់ ដល់ស៊ីប់ព្រម រួបរួម ដោយមេធា គឺប្រាជ្ញានេះ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមានប្រាជ្ញា ដូចផែនដី ហេតុនោះ (លោកពោលថា) អំពីព្រះគោតម មានប្រាជ្ញា ដូចផែនដី ។ ហេតុនោះ ព្រះបិង្គិយត្តេរពោលថា*

បពិត្រព្រាហ្មណ៍ អាត្មាមិនធ្លាប់ឃ្លាតអំពីព្រះគោតម ទ្រង់មាន ប្រាជ្ញាជាគ្រឿងប្រាកដ អំពីព្រះគោតម មានប្រាជ្ញាដូចផែន ដីនោះ សូម្បីមួយរំពេចទេ ។

[១៨៧] *ព្រះគោតម អង្គណា ទ្រង់សម្តែងធម៌ដល់អាត្មា ជា ធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំ កាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌ មិនមានឧបមា ក្នុងទីណាមួយ ។*

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

[១៨៨] យោ មេ ធម្មមទេសេសីតិ យោតិ យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ អនុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុ-ជ្ឈិ តត្ថ ច សព្វញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ ។ ធម្មមទេសេសីតិ ធម្មន្តិ អាទិកល្យាណំ មជ្ឈេក-ល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចត្តារោ សតិ-ប្បដ្ឋានេ ចត្តារោ សម្មប្បធានេ ចត្តារោ ឥទ្ធិបាទេ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គេ អរិយំ អដ្ឋង្គិកំ មគ្គំ និព្វានញ្ច និព្វានគាមិនិញ្ច បដិបទំ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីមការិ បការាសេសីតិ យោ មេ ធម្មមទេសេសិ ។

[១៨៩] សន្ទិដ្ឋិកមការិកន្តិ សន្ទិដ្ឋិកំ អការិកំ ឯហិបស្សិកំ ឱបនយិកំ បច្ចត្តំ វេទិតព្ពំ វិញ្ញូហីតិ ឯវំ សន្ទិដ្ឋិកមការិកំ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេស

[១៨៨] ពាក្យថា ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់អាត្មា ត្រង់ពាក្យថា អង្គណា គឺ ព្រះមានព្រះភាគអង្គណា ទ្រង់កើតឯង មិនមានអាចារ្យ ត្រាស់ដឹងសច្ចៈទាំងឡាយដោយព្រះអង្គឯង ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮមកក្នុងកាលមុនផង ទ្រង់ដល់នូវភាពជាសព្វញ្ញូក្នុងសច្ចៈទាំងនោះផង ទ្រង់ដល់នូវភាពជាអ្នកស្ទាត់ ក្នុងពលៈទាំងឡាយផង ។ ពាក្យថា ទ្រង់សម្តែងធម៌ ត្រង់ពាក្យថា ធម៌ គឺទ្រង់ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក រៃកញ្ជែក ធ្វើឲ្យរាក់ ប្រកាសនូវព្រហ្មចរិយធម៌ មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ព្រមទាំងអត្ថទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ នូវសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អដ្ឋង្គិកមគ្គដ៏ប្រសើរ និព្វាន និងបដិបទាជាដំណើរទៅកាន់ព្រះនិព្វាន ហេតុនោះ (លោកពោលថា) ព្រះគោតមអង្គណា ទ្រង់សម្តែងធម៌ដល់អាត្មា ។

[១៨៩] ពាក្យថា ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល គឺ ជាធម៌ដែលបុគ្គលគប្បីឃើញច្បាស់ចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី គួរបង្ហោនមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនគប្បីដឹងចំពោះខ្លួន ហេតុនោះ (លោកពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះ ។

អថវា យោ ឥធ្លេវ ឆម្មេ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ តស្ស មគ្គស្ស អនន្តរា សមនន្តរា អធិកច្ចតេវ ផលំ វិន្ទតិ បដិលភតីតិ ឯវម្ៀ សន្ទិដ្ឋិកមកាលិកំ ។ យថា មនុស្សា កាលិកំ ឆនំ ឆត្វា អនន្តរា ន លភន្តិ កាលំ អាគមេន្តិ ឆេវាយំ ឆម្ហា ។ យោ ឥធ្លេវ ឆម្មេ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ តស្ស មគ្គស្ស អនន្តរា សមនន្តរា អធិកច្ចតេវ ផលំ វិន្ទតិ បដិលភតិ ន ឋត្ត ន ឋរលោកេ ឯវ អកាលិកន្តិ សន្ទិដ្ឋិកមកាលិកំ ។

[១៩០] តណ្ហាក្ខយមនីតិកន្តិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្ពតណ្ហា ឆម្មតណ្ហា ។ តណ្ហាក្ខយន្តិ តណ្ហាក្ខយំ រាគក្ខយំ ទោសក្ខយំ មោហក្ខយំ កតិក្ខយំ ឧបបត្តិក្ខយំ បដិសន្ធិក្ខយំ ភវក្ខយំ សំសារក្ខយំ វដ្ដក្ខយំ ។

មួយទៀត បុគ្គលណាចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរក្នុងបច្ចុប្បន្ន បុគ្គលនោះ រមែងចួប បាន បានចំពោះនូវផលក្នុងលំដាប់ លំដាប់ស្មើ នៃមគ្គនោះ ហេតុនោះ (លោកពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះក៏បាន ។ មនុស្សទាំងឡាយ ឲ្យទ្រព្យ ប្រកបដោយកាល មិនបានផលក្នុងលំដាប់ រមែងរង់ចាំកាល យ៉ាងណា ធម៌នេះ មិនមែនយ៉ាងនោះទេ បុគ្គលណាចម្រើនអដ្ឋង្គិកមគ្គ ដ៏ប្រសើរ ក្នុងបច្ចុប្បន្ន បុគ្គលនោះ រមែងចួប បាន បានចំពោះនូវផល ក្នុងលំដាប់ លំដាប់ស្មើនៃមគ្គនោះ មិនមែនបានក្នុងពេលដទៃ មិនមែន បានក្នុងលោកដទៃទេ ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះ ហេតុនោះ (លោកពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផល មិនរង់ចាំកាល ។

[១៩០] *អធិប្បាយពាក្យថា ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ជាគ្រឿងអស់ តណ្ហា គឺ ជាគ្រឿងអស់ចំណង់ អស់រាគ: អស់ទោស: អស់មោห: អស់គតិ អស់ឧបបត្តិ អស់បដិសន្ធិ អស់ភព អស់សង្សារ អស់វដ្ត: ។*

អនីតិកន្តិ ឦតិ វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ ឦតិប្បហានំ ឦតិវូបសមោ ឦតិប្បដិនិស្សគ្គោ ឦតិប្បដិប្បស្សទ្ធិ អមតំ និព្វានន្តិ តណ្ហក្ខយមនីតិកំ ។

[១៩១] យស្ស នត្ថិ ឧបមា ក្វចីតិ យស្សាតិ និព្វានស្ស ។ នត្ថិ ឧបមាតិ ឧបមា នត្ថិ ឧបនិធា នត្ថិ សទិសំ នត្ថិ បដិភាគោ នត្ថិ ន សំវិជ្ជតិ នុបលព្ភតីតិ នត្ថិ ឧបមា ។ ក្វចីតិ ក្វចិ កិម្ហិចិ កត្ថចិ អជ្ឈត្តំ វា ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វាតិ យស្ស នត្ថិ ឧបមា ក្វចិ ។ តេនាហ បិង្គិយត្ថេរោ

យោ មេ ធម្មមទេសេសិ សន្ទិដ្ឋិកមកាលិកំ

តណ្ហក្ខយមនីតិកំ យស្ស នត្ថិ ឧបមា ក្វចីតិ ។

ពាក្យថា មិនមានចង្រៃ សេចក្ដីថា កិលេស ខន្ធ និងអភិសង្ខារ លោកហៅថា ចង្រៃ ។ ការលះចង្រៃ ការសូប់ចង្រៃ ការរលាស់ចោលចង្រៃ ការគ្របសង្កត់ចង្រៃ អមតនិព្វាន ហេតុនោះ (លោកពោលថា) ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ។

[១៩១] ពាក្យថា ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ត្រង់ពាក្យថា ដែលជាធម៌ បានដល់និព្វាន ។ ពាក្យថា មិនមានឧបមា គឺ មិនមានការប្រៀបផ្ទឹម មិនមានសេចក្ដីប្រៀបធៀប មិនមានភាពស្មើគ្នា មិនមាន មិនមានព្រម មិនបាន នូវចំណែកប្រៀប ហេតុនោះ (លោកពោលថា) មិនមានឧបមា ។ ពាក្យថា ក្នុងទីណាមួយ គឺ ក្នុងទីណាមួយ ក្នុងទីណា ។ ក្នុងទីនីមួយ ជាខាងក្នុង ឬខាងក្រៅ ឬទាំងខាងក្នុងទាំងខាងក្រៅ ហេតុនោះ (លោកពោលថា) ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ព្រះគោតមអង្គណា ទ្រង់សម្ដែងធម៌ដល់អាត្មា ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផល មិនរង់ចាំកាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ។

[១៩២] បស្ឆាមិ នំ មនសា ចក្ខុនា ឯ
រត្តិន្ទិវំ ព្រាហ្មណ អប្ឆមត្តោ
ឧមស្ឆមានោ ឱ្យសាមិ[1] រត្តឺ
ឯនេវ មញ្ញាមិ អវិប្ឆាសំ ។

[១៩៣] បស្ឆាមិ នំ មនសា ចក្ខុនា ឯតិ យថា ចក្ខុមា បុរិសោ អាលោកេយ្យ រូបកតានិ បស្ស្ដយ្យ ឧក្ខ្ដយ្យ ឱ្យលោកេយ្យ និជ្ឌ្ឌាបេយ្យ ឧបបរិក្ខ្ដយ្យ ឯវមេវាហំ ពុទ្ធ ភគវន្ត មនសា បស្ឆាមិ ឧក្ខ្ដាមិ ឱ្យលោកេមិ និជ្ឌ្ឌាបយាមិ ឧប-បរិក្ខ្ដាមីតិ បស្ឆាមិ នំ មនសា ចក្ខុនា ឯ ។

[១៩៤] រត្តិន្ទិវំ ព្រាហ្មណ អប្ឆមត្តោតិ រត្តិញ្ច ទិវ ច មនសា[2] ភាវេន្ដោ អប្ឆមត្តោតិ រ្ដិត្ដិន្ទ្ធិវ ព្រាហ្មណ អប្ឆមត្ដោ ។

---

១ ម. ឱ្យសេមិ ។ ២ ម. ពុទ្ធានុស្ស្ដតឺ ។

[១៩២] *បពិត្រព្រាហ្មណ៍ អាត្មាជាអ្នកមិនប្រហែស តែងឃើញព្រះពុទ្ធនោះ ដោយចិត្ត ហាក់ដូចឃើញដោយភ្នែក ទាំងយប់ទាំងថ្ងៃ អាត្មាតែងនមស្ការ នៅរហូតយប់និងថ្ងៃ ទើបអាត្មាសម្គាល់ថា ការមិនឃ្លាត ដោយហេតុនោះឯង ។*

[១៩៣] *ពាក្យថា អាត្មាតែងឃើញព្រះពុទ្ធនោះដោយចិត្ត ហាក់ដូចឃើញដោយភ្នែក គឺ បុរសមានភ្នែកគប្បីរមិលមើល គប្បីឃើញ គប្បីចួប គប្បីគន់មើល គប្បីសម្ងឹងមើល គប្បីពិចារណាមើល នូវរូបទាំង-ឡាយ យ៉ាងណា អាត្មាតែងឃើញ ចួប គន់មើល សម្ងឹងមើល ពិចារណាមើល នូវព្រះពុទ្ធមានព្រះភាគ ដោយចិត្ত ក៏យ៉ាងនោះដែរ ហេតុនោះ (លោកពោលថា) អាត្មាតែងឃើញព្រះពុទ្ធនោះ ដោយចិត្ত ហាក់ដូចឃើញដោយភ្នែក ។*

[១៩៤] *ពាក្យថា បពិត្រព្រាហ្មណ៍ អាត្មាជាអ្នកមិនប្រហែសទាំងយប់ទាំងថ្ងៃ គឺ អាត្មាខំចម្រើនដោយចិត្ত ទាំងយប់ទាំងថ្ងៃ ឈ្មោះថាជាអ្នកមិនប្រហែស ហេតុនោះ (លោកពោលថា) បពិត្រព្រាហ្មណ៍ អាត្មាជាអ្នកមិនប្រហែស ទាំងយប់ទាំងថ្ងៃ ។*

[១៩៥] ឧមស្សមានោ រាសាមិ រត្តិន្តិ ឧមស្ស-
មានោតិ ការយេន វ ឧមស្សមានោ វាចាយ វ
ឧមស្សមានោ ចិត្តេន វ ឧមស្សមានោ អន្ធត្ថ្ប-
បដិបត្តិយា វ ឧមស្សមានោ ធម្មានុធម្មប្បដិបត្តិយា
វ ឧមស្សមានោ សក្ការមានោ ករុការមានោ
មានយមានោ បូជយមានោ រត្តិន្ទិវំ រសាមិ រីតិជ-
មេមីតិ ឧមស្សមានោ រាសាមិ រត្តឺ ។

[១៩៦] តេនេវ មញ្ញាមិ អរិប្ប្ជាសន្តិ តាយ
ពុទ្ធានុស្សតិយា ភាវេន្តោ អរិប្ប្ជាសោតិ តំ មញ្ញាមិ
អរិប្ប្ជុជ្ជោតិ តំ មញ្ញាមិ ជានាមិ ឍវំ ជានាមិ ឍវំ
អាជានាមិ ឍវំ រិជានាមិ ឍវំ បដិរិជានាមីតិ[1]
តេនេវ មញ្ញាមិ អរិប្ប្ជាសំ ។ តេនាហ ២ិ្ជ្ជ្ជ្ជ្ជ្ជ

បស្ប្ជាមិ ជំ មនសា ចក្ខុនា វ
រត្តិន្ទិវំ ព្រាហ្មណ អប្ប្ជមត្តោ
ឧមស្សមានោ រាសាមិ រត្តឺ
តេនេវ មញ្ញាមិ អរិប្ប្ជាសន្តិ ។

---

1 ម. បដិរិជ្ជ្ជ្ជ្ជ្ជ្ជ្ជ្ជ្ជ្ជ្ជ ។

[១៩៥] ពាក្យថា អាត្មាតែងនមស្ការនៅរហូតយប់និងថ្ងៃ ត្រង់ពាក្យថា នមស្ការ គឺ នមស្ការដោយកាយក្តី នមស្ការដោយវាចាក្តី នមស្ការដោយចិត្តក្តី នមស្ការដោយការប្រតិបត្តិ ទៅតាមប្រយោជន៍ក្តី នមស្ការ ធ្វើសក្ការ: ធ្វើសេចក្តីគោរពរាប់អាន បូជា ដោយការប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ក្តី នៅរហូតយប់និងថ្ងៃ គឺ ញ្ចាំងយប់និងថ្ងៃឲ្យប្រព្រឹត្តកន្ទងទៅ ហេតុនោះ (លោកពោលថា) អាត្មាតែងនមស្ការនៅរហូតយប់និងថ្ងៃ ។

[១៩៦] ពាក្យថា ទើបអាត្មាសម្គាល់ថា ការមិនឃ្លាតដោយហេតុនោះឯង គឺ អាត្មាកាលអប់រំដោយពុទ្ធានុស្សតិនោះ ទើបសម្គាល់នូវអំពើនោះថា ជាការមិនឃ្លាត សម្គាល់ គឺដឹង ដឹងយ៉ាងនេះ យល់យ៉ាងនេះ ដឹងច្បាស់យ៉ាងនេះ ដឹងចំពោះយ៉ាងនេះ នូវព្រះពុទ្ធនោះថា ព្រះអង្គមិនធ្លាប់ឃ្លាត ហេតុនោះ (លោកពោលថា) ទើបអាត្មាសម្គាល់ថា ការមិនឃ្លាត ដោយហេតុនោះឯង ។ ហេតុនោះ ព្រះបិដ្ដ្ដិយត្ថេរពោលថា

> *បពិត្រព្រាហ្មណ៍ អាត្មាជាអ្នកមិនប្រហែស តែងឃើញព្រះពុទ្ធនោះ ដោយចិត្ត ហាក់ដូចឃើញដោយភ្នែក ទាំងយប់ទាំងថ្ងៃ អាត្មាតែងនមស្ការ នៅរហូតយប់និងថ្ងៃ ទើបអាត្មាសម្គាល់ថាការមិនឃ្លាត ដោយហេតុនោះឯង ។*

[១៩៧] សទ្ធា ច បីតិ ច មនោ សតិ ច
ជាមេន្តិមេ[១] តោតមសាសនម្ហា
យំ យំ ទិសំ វជ្ជតិ ភូរិបញ្ញោ
ស តេន តេនេវ ឧតោហមស្មិ ។

[១៩៨] សទ្ធា ច បីតិ ច មនោ សតិ ចាតិ សទ្ធាតិ យា ច ភតវន្តំ អារព្ភ សទ្ធា សទ្ធហនា ឱកប្បនា អភិប្បសាទោ សទ្ធា សទ្ធិន្ទ្រិយំ សទ្ធាពលំ ។ បីតីតិ យា ច ភតវន្តំ អារព្ភ បីតិ ចាមុជ្ជោ មោទនា បមោទនា រតិ ឱទគ្យំ អត្តមនតា អតិប្ប-សាទនតា ចិត្តស្ស[២] ។ មនោតិ យញ្ច ភតវន្តំ អារព្ភ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ។ សតីតិ យា ច ភតវន្តំ អារព្ភ សតិ អនុស្សតិ ។ បេ ។ សម្ម្ទាសតីតិ សទ្ធា ច បីតិ ច មនោ សតិ ច ។

---

១ ម. នាបេន្តិមេ ។ ២ ម. មោទនា អាមោទនា បមោទនា ហាសោ បហាសោ រតិ ឱទគ្យំ អត្តមនតា ចិត្តស្ស ។

[១៩៧] ធម៌ទាំង ៤ នេះ គឺ សទ្ធា បីតិ មនោ និង សតិ (របស់អាត្មា) តែងមិនឃ្លាតចាកសាសនារបស់ព្រះគោតម ឡើយ ព្រះគោតម ទ្រង់មានប្រាជ្ញាដូចផែនដី ស្តេចទៅ កាន់ទិសណា ៗ អាត្មានោះ ក៏ជាអ្នកឱនទៅរកទិសនោះ ៗ ។

[១៩៨] *អធិប្បាយពាក្យថា* សទ្ធា បីតិ មនោ និងសតិ *ត្រង់ ពាក្យថា* សទ្ធា *បានដល់ ជំនឿ ការជឿ ការចុះចិត្ត សេចក្តី ជ្រះថ្លាខ្លាំង* សទ្ធា *សទ្ធិន្ទ្រិយ* សទ្ធាពលៈ *ប្រារព្ធព្រះមានព្រះភាគ ។ ពាក្យថា* បីតិ *បានដល់ ការផ្ទៃត បាមោជ្ជៈ ការរីករាយ ការរីករាយចំពោះ ការត្រេកអរ ការត្រេកអរស៊ីប់ ភាពនៃចិត្តរបស់ខ្លួន ភាពនៃចិត្តជ្រះថ្លាក្រៃ ពេក ប្រារព្ធព្រះមានព្រះភាគ ។ ពាក្យថា* មនោ *បានដល់ចិត្ត ធម្មជាតសម្រាប់បង្ហោនទៅ សេចក្តីប្រាថ្នាក្នុងចិត្ត ហឫទ័យ បណ្ណរៈ* មនោ *មនាយតនៈ* មនិន្ទ្រិយ *វិញ្ញាណ វិញ្ញាណក្ខន្ធ* មនោវិញ្ញាណ-ធាតុ *ដែលកើតអំពីវិញ្ញាណក្ខន្ធនោះ ប្រារព្ធព្រះមានព្រះភាគ ។ ពាក្យ ថា* សតិ *បានដល់ស្មារតី ការរឭកវឿយ ៗ ។ បេ ។ ការរឭកត្រូវ ប្រារព្ធព្រះមានព្រះភាគ ហេតុនោះ (លោកពោលថា)* សទ្ធា *បីតិ* មនោនិងសតិ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

[១៩៩] ជាមេន្តិមេ គោតមសាសនម្ហាតិ ឥមេ ចត្តារោ ឯម្ហ គោតមសាសនា ពុទ្ធសាសនា ជិន-សាសនា តថាគតសាសនា អរហន្តសាសនា ជា-មេន្តិ ជាតច្ចន្តិ ន វិជហន្តិ ន វិជាសេន្តីតិ ជាមេ-ន្តិមេ គោតមសាសនម្ហា ។

[២០០] យំ យំ ទិសំ វជ្ជតិ ភូរិបញ្ញោតិ យំ យំ ទិសន្តិ បុរត្ថិមំ វា ទិសំ បច្ឆិមំ វា ទិសំ ទក្ខិ-ណំ វា ទិសំ ឧត្តរំ វា ទិសំ វជតិ គច្ឆតិ ឆមតិ អតិក្កមតិ ។ ភូរិបញ្ញោតិ ភូរិប្បញ្ញោ មហាបញ្ញោ តិក្ខប្បញ្ញោ បុថុប្បញ្ញោ ហាសប្បញ្ញោ ជវនប្បញ្ញោ ជិញ្ជិកប្បញ្ញោតិ[(១)] យំ យំ ទិសំ វជ្ជតិ ភូរិបញ្ញោ ។

[២០១] ស តេន តេនេវ ឧតោហមស្មីតិ សោ យេន ពុទ្ធោ តេន តេនេវ ឧតោ

---

១ ម. និញ្ជិកប្បញ្ញោ ភូរិ រុច្ចតិ បហរី តាយ បហរីសមាយ បញ្ញាយ វិបុលាយ វិត្ថតាយ សមន្នាគតោតិ ទិស្សន្តិ ។

[១៩៩] ពាក្យថា ធម៌ទាំង ៤ នេះ តែងមិនឃ្លាតចាកសាសនា របស់ព្រះគោតម គឺ ធម៌ទាំង ៤ នេះ តែងមិនប្រាសចេញ មិនមក មិនលះបង់ មិនវិនាស ចាកសាសនាព្រះគោតម ចាកសាសនាព្រះពុទ្ធ ចាកសាសនាព្រះជិនស្រី ចាកសាសនាព្រះតថាគត ចាកសាសនាព្រះអរហន្ត ហេតុនោះ (លោកពោលថា) ធម៌ទាំង ៤ នេះ តែងមិនប្រាសចាកសាសនា របស់ព្រះគោតម ។

[២០០] ពាក្យថា ទ្រង់មានប្រាជ្ញាដូចផែនដី ស្តេចទៅកាន់ទិសណា ។ ត្រង់ពាក្យថា ទិសណា ។ គឺ ទ្រង់ទៅ ដល់ ឈាន ឈានកន្ទង ទៅកាន់ទិសខាងកើតក្តី ទិសខាងលិចក្តី ទិសខាងត្បូងក្តី ទិសខាងជើងក្តី ។ ពាក្យថា មានប្រាជ្ញាដូចផែនដី គឺ ទ្រង់មានប្រាជ្ញាដូចប្រឹថពី មានប្រាជ្ញាច្រើន មានប្រាជ្ញាមុត មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញារហ័ស មានប្រាជ្ញាធ្ងុះធ្ងាយ ហេតុនោះ (លោកពោលថា) ទ្រង់មានប្រាជ្ញាដូចផែនដី ស្តេចទៅកាន់ទិសណា ។ ។

[២០១] ពាក្យថា អាត្មានោះ ជាអ្នកឱនទៅរកទិសនោះ ។ គឺព្រះពុទ្ធទ្រង់គង់នៅ ក្នុងទិសណា អាត្មានោះ ជាអ្នកឱនទៅរកទិសនោះ

តន្និន្នោ តប្បោណោ តប្បព្ភារោ តទធិមុត្តោ តទា-
ធិបតេយ្យោតិ ស តេន តេនេវ នតោហមស្មិ ។
តេនាហ បិង្គិយត្ថេរោ

សទ្ធា ច បីតិ ច មនោ សតិ ច
នាមេន្តិមេ គោតមសាសនម្ហា
យំ យំ ទិសំ វជតិ ភូរិបញ្ញោ
ស តេន តេនេវ នតោហមស្មីតិ ។

[២០២] ជិណ្ណស្ស មេ ទុព្វលថាមកស្ស
តេនេវ កាយោ ន បលេតិ តត្ថ
សង្កប្បយន្តាយ វជាមិ និច្ចំ
មនោ ហិ មេ ព្រាហ្មណ តេន យុត្តោ ។

[២០៣] ជិណ្ណស្សុ មេ ទុព្វលថាមកស្សាតិ
ជិណ្ណស្សាតិ ជិណ្ណស្ស វុឌ្ឍស្ស មហល្លកស្ស
អទ្ធគតស្ស វយោអនុប្បត្តស្សាតិ ជិណ្ណស្ស ។
ទុព្វលថាមកស្សាតិ ទុព្វលថាមកស្ស អប្បថាមក-
ស្ស បរិត្តថាមកស្សាតិ ជិណ្ណស្ស មេ ទុព្វលថាម-
កស្ស ។

ទេរទៅរកទិសនោះ ទោរទៅរកទិសនោះ ឈមទៅរកទិសនោះ បង្ហោនទៅរកទិសនោះ យកទិសនោះជាអធិបតី ហេតុនោះ (លោកពោលថា) អាត្មានោះ ជាអ្នកឱនទៅរកទិសនោះ ។ ។ ហេតុនោះ ព្រះបិង្គិយ-ត្តេរពោលថា

ធម៌ទាំង ៤ នេះ គឺ សទ្ធា បីតិ មនោ និងសតិ (របស់អាត្មា) តែងមិនឃ្លាតចាកសាសនា របស់ព្រះគោតមឡើយ ព្រះគោតម ទ្រង់មានប្រាជ្ញាដូចផែនដី ស្តេចទៅកាន់ទិសណា ។ អាត្មានោះ ក៏ជាអ្នកឱនទៅរកទិសនោះ ។ ។

[២០២] អាត្មាជាបុគ្គលគ្រាំគ្រា មានកម្ទាំងថយហើយ ហេតុនោះ កាយទៅក្នុងទិសនោះ មិនបានទេ តែអាត្មាទៅដោយដំណើរនៃសេចក្តីត្រិះរិះ អស់កាលជានិច្ច បពិត្រព្រាហ្មណ៍ ព្រោះថា ចិត្តរបស់អាត្មា ប្រកបតាមទិសនោះ ។

[២០៣] ពាក្យថា អាត្មាជាបុគ្គលគ្រាំគ្រា មានកម្ទាំងថយហើយ ត្រង់ពាក្យថា គ្រាំគ្រា គឺ ចាស់ ចម្រើន មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានវ័យដល់ហើយតាមលំដាប់ ហេតុនោះ (លោកពោលថា) គ្រាំគ្រា ។ ពាក្យថា មានកម្ទាំងថយ គឺ មានកម្ទាំងខ្សោយ មានកម្ទាំងតិច មានកម្ទាំងស្ពួចស្ដើង ហេតុនោះ (លោកពោលថា) អាត្មាជាបុគ្គលគ្រាំគ្រា មានកម្ទាំងថយហើយ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

[២០៤] តេនេវ កាយោ ន បលេតិ តត្ថាតិ កាយោ យេន ពុទ្ធោ តេន ន បលេតិ ន វជតិ ន គច្ឆតិ នាភិក្កមតីតិ តេនេវ កាយោ ន បលេតិ តត្ថ ។

[២០៥] សង្កប្បយន្តាយ វជាមិ និច្ចន្តិ សង្កប្ប-គមនេន វិតក្កគមនេន ញាណគមនេន បញ្ញាគម-នេន ពុទ្ធិគមនេន វជាមិ គច្ឆាមិ អភិក្កមាមីតិ ស-ង្កប្បយន្តាយ វជាមិ និច្ចំ ។

[២០៦] មនោ ហិ មេ ព្រាហ្មណ តេន យុត្តោ-តិ មនោតិ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខ-ន្ធោ តជ្ជា មនោវិញ្ញាណធាតុ ។ ព្រាហ្មណ តេន យុត្តោតិ មនោ មម យេន ពុទ្ធោ តេន យុត្តោ សំយុត្តោតិ មនោ ហិ មេ ព្រាហ្មណ តេន យុត្តោ ។ តេនាហ បិង្គិយត្ថេរោ

[២០៤] *ពាក្យថា កាយទៅក្នុងទិសនោះមិនបានទេ គឺ ព្រះពុទ្ធគង់ក្នុងទិសណា កាយទៅមិនបាន ចេញទៅមិនបាន ដើរទៅមិនបាន ឈានទៅមិនបាន ក្នុងទិសនោះទេ ហេតុនោះ (លោកពោលថា) កាយទៅក្នុងទិសនោះ មិនបានទេ ។*

[២០៥] *ពាក្យថា តែអាត្មាទៅដោយដំណើរ នៃសេចក្តីត្រិះរិះ អស់កាលជានិច្ច គឺ អាត្មាទៅ ដើរទៅ ឈានទៅ ដោយដំណើរនៃតម្រិះ ដោយដំណើរវិតក្ក: ដោយដំណើរញាណ ដោយដំណើរបញ្ញា ដោយដំណើរប្រាជ្ញាជាគ្រឿងត្រាស់ដឹង ហេតុនោះ (លោកពោលថា) តែអាត្មាទៅដោយដំណើរនៃសេចក្តីត្រិះរិះ អស់កាលជានិច្ច ។*

[២០៦] *ពាក្យថា បពិត្រព្រាហ្មណ៍ ព្រោះថា ចិត្តរបស់អាត្មាប្រកបតាមទិសនោះ ត្រង់ពាក្យថា ចិត្ត បានដល់គំនិត ធម្មជាតសម្រាប់បង្អោនទៅ សេចក្តីប្រាថ្នាក្នុងចិត្ត ហឫទ័យ បណ្ណារ: មនោ មនាយតន: មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណក្ខន្ធនោះ ។ ពាក្យថា បពិត្រព្រាហ្មណ៍ . . . ប្រកប ហើយតាមទិសនោះ គឺ ព្រះពុទ្ធគង់ក្នុងទិសណា ចិត្តរបស់អាត្មាក៏ប្រកប ប្រកបព្រម តាមទិសនោះ ហេតុនោះ (លោកពោលថា) បពិត្រព្រាហ្មណ៍ ព្រោះថា ចិត្តរបស់អាត្មាប្រកបតាមទិសនោះ ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា*

ជិណ្ណស្ស មេ ទុព្វលថាមកស្ស
តេនេវ កាយោ ន បលេតិ តត្ថ
សង្កប្បយន្តាយ វជាមិ និច្ចំ
មនោ ហិ មេ ព្រាហ្មណ តេន យុត្តោតិ ។

[២០៧] បង្កេ (សយានោ) បរិផន្ទមានោ
ទីបា ទីបំ[១] ឧបល្លវឹ
អថទ្ទសាសឹ សម្ពុទ្ធំ
ឱឃតិណ្ណមនាសវំ ។

[២០៨] បង្កេ សយានោ បរិផន្ទមានោតិ បង្កេ សយានោតិ កាមបង្កេ កាមកទ្ទមេ កាមកិលេសេ កាមពលិសេ កាមបរិឡាហេ កាមបលិពោធេ សេមានោ អវសេមានោ បរិសេមានោតិ បង្កេ សយានោ ។

១ ម. ទិសា ទិសំ ។

អាត្មាជាបុគ្គលគ្រាំគ្រា មានកម្ទាំងថយហើយ ហេតុនោះ
កាយទៅក្នុងទិសនោះ មិនបានទេ តែអាត្មាទៅដោយ
ដំណើរនៃសេចក្តីត្រិះរិះ អស់កាលជានិច្ច បពិត្រព្រាហ្មណ៍
ព្រោះថា ចិត្តរបស់អាត្មា ប្រកបតាមទិសនោះ ។

[២០៧] អាត្មាដេកក្នុងកក់ បម្រះនៀល ស្ទុះចេញអំពីទី
ពឹង ទៅរកទីពឹង គ្រានោះ អាត្មាបានឃើញព្រះសម្ពុទ្ធ
ទ្រង់ធ្វងអន្ទង់ហើយ ទ្រង់មិនមានអាសវៈទេ ។

[២០៨] អធិប្បាយពាក្យថា ដេកក្នុងកក់ បម្រះនៀល ត្រង់ពាក្ស
ថា ដេកក្នុងកក់ គឺ ដេក ដេកស៊ប់ ដេកត្រាំ ក្នុងកក់គឺកាម ក្នុងល្បាប់
គឺកាម ក្នុងកិលេសគឺកាម ក្នុងសន្ធ្ងួចគឺកាម ក្នុងសេចក្តីក្តៅក្រហាយ
គឺកាម ក្នុងកង្ងល់គឺកាម ហេតុនោះ (លោកពោលថា) ដេកក្នុងកក់ ។

បរិជន្ធមានោតិ តណ្ហាជន្ធនាយ ជន្ធមានោ ទិដ្ឋិជ-
ន្ធនាយ ជន្ធមានោ កិលេសជន្ធនាយ ជន្ធមានោ
បយោគជន្ធនាយ[1] ជន្ធមានោ វិចាគជន្ធនាយ
ជន្ធមានោ ទុច្ចរិតជន្ធនាយ[2] ជន្ធមានោ រត្តោ
រាគេន ជន្ធមានោ ទុដ្ឋោ ទោសេន ជន្ធមានោ
មូឡ្ហោ មោហេន ជន្ធមានោ វិនិពន្ធោ មានេន ជន្ធ-
មានោ បរាមដ្ឋោ ទិដ្ឋិយា ជន្ធមានោ វិក្ខេបគតោ
ឧទ្ធច្ចេន ជន្ធមានោ អនិដ្ឋង្គតោ វិចិកិច្ឆាយ ជន្ធមា-
នោ ថាមគតោ អនុសយេហិ ជន្ធមានោ លាភេន
ជន្ធមានោ អលាភេន ជន្ធមានោ យសេន ជន្ធមានោ
អយសេន ជន្ធមានោ និន្ទាយ ជន្ធមានោ បសំសាយ
ជន្ធមានោ សុខេន ជន្ធមានោ ទុក្ខេន ជន្ធមានោ
ជាតិយា ជន្ធមានោ ជរាយ ជន្ធមានោ ព្យាធិនា

---

១ ម. សំយោគជន្ធនាយ ។ ២ ម. មនោទុច្ចរិតជន្ធនាយ ។

ពាក្យថា បម្រះនៀល គឺ បម្រះនៀល ដោយការបម្រះនៀលគឺតណ្ហា បម្រះនៀល ដោយការបម្រះនៀលគឺទិដ្ឋិ បម្រះនៀលដោយការបម្រះនៀលគឺកិលេស បម្រះនៀល ដោយការបម្រះនៀលគឺប្រយោគ បម្រះនៀល ដោយការបម្រះនៀលគឺវិបាក បម្រះនៀលដោយការបម្រះនៀល គឺទុច្ចរិត ជាអ្នកត្រេកអរ បម្រះនៀល ដោយរាគ: ជាអ្នកប្រទូស្ត បម្រះនៀល ដោយទោស: ជាអ្នកវង្វេង បម្រះនៀលដោយមោហ: ជាអ្នកជាប់ចំពាក់ បម្រះនៀលដោយមាន: ជាអ្នកស្ងាបអង្ហែល បម្រះនៀល ដោយទិដ្ឋិ ជាអ្នករវើរវាយ បម្រះនៀលដោយឧទ្ធច្ច: ជាអ្នកដល់នូវការមិនជាច់ស្រេច បម្រះនៀល ដោយវិចិកិច្ឆា ជាអ្នកដល់នូវកម្ទាំង បម្រះនៀល ដោយអនុស័យ បម្រះនៀល ដោយលាភ បម្រះនៀល ដោយអលាភ បម្រះនៀលដោយយស បម្រះនៀល ដោយអយស បម្រះនៀល ដោយនិន្ទា បម្រះនៀល ដោយសេចក្តីសរសើរ បម្រះនៀលដោយសុខ បម្រះនៀលដោយទុក្ខ បម្រះនៀល ដោយជាតិ បម្រះនៀលដោយជរា បម្រះនៀលដោយព្យាធិ

ផន្ធមានោ មរណេន ផន្ធមានោ សោកបរិទេវទុក្ខោ-
មនស្សុបាយាសេហិ ផន្ធមានោ ឥរយិកេន ទុក្ខេន
ផន្ធមានោ តិរច្ឆានយោនិកេន ទុក្ខេន ផន្ធមានោ
បិត្តិវិសយិកេន ទុក្ខេន ផន្ធមានោ មានុសកេន
ទុក្ខេន កញ្ញាកត្តិមូលកេន ទុក្ខេន កញ្ញដ្ឋិតិមូលកេន
ទុក្ខេន កញ្ញវុដ្ឋានមូលកេន ទុក្ខេន ជាតស្ស្ឍបនិពន្ធ-
កេន ទុក្ខេន ជាតស្ស្ឍបវាឡេយ្យកេន ទុក្ខេន អត្ត-
បក្ខមេន ទុក្ខេន បរុបក្ខមេន ទុក្ខេន ទុក្ខទុក្ខេន
សង្ខារទុក្ខេន វិបរិណាមទុក្ខេន ចក្ខុរោគេន ទុក្ខេ-
ន សោតរោគេន ទុក្ខេន ឃានរោគេន ទុក្ខេន
ជិវ្ហារោគេន ទុក្ខេន កាយរោគេន ទុក្ខេន សីសរោ-
គេន ទុក្ខេន កណ្ណរោគេន ទុក្ខេន មុខរោគេន
ទុក្ខេន ទន្តរោគេន ទុក្ខេន កាសេន សាសេន
បិនាសេន ឌហេន ជរេន កុច្ឆិរោគេន មុច្ឆាយ បក្ខ-
ន្ធិកាយ សុលាយ វិសូចិកាយ កុដ្ឋេន គណ្ឌេន
កិលាសេន សោសេន អបមារេន ទទ្ទុយា កណ្ឌូ-
យា កច្ឆុយា រេឆសាយ វិតច្ឆិកាយ លោហិតេន

បម្រះនៀលដោយមរណៈ បម្រះនៀលដោយសោកៈ ខ្សឹកខ្ជូល ទុក្ខ ទោមនស្ស សេចក្តីតានតឹង បម្រះនៀលដោយទុក្ខក្នុងនរក បម្រះនៀលដោយទុក្ខក្នុងតិរច្ឆានកំណើត បម្រះនៀល ដោយទុក្ខ ក្នុងប្រេតវិស័យ បម្រះនៀល អន្ទះសា ញាប់ញ័រ ញ័ររន្ធត់ ដោយទុក្ខ ជារបស់មនុស្ស ដោយទុក្ខមានការចុះកាន់គភ៌ជាមូល ដោយទុក្ខមានការតាំងនៅក្នុងគភ៌ជាមូល ដោយទុក្ខមានការចេញចាកគភ៌ជាមូល ដោយទុក្ខដែលទាក់ទងនឹងសត្វកើតហើយ ដោយទុក្ខដែលបណ្តាលអំពីរឿងដទៃនៃសត្វកើតហើយ ដោយទុក្ខព្រោះសេចក្តីព្យាយាមរបស់ខ្លួន ដោយទុក្ខព្រោះសេចក្តីព្យាយាមរបស់បុគ្គលដទៃ ដោយទុក្ខទុក្ខ សង្ខារទុក្ខ វិបរិណាមទុក្ខ ចក្ខុរោគទុក្ខ សោតរោគទុក្ខ ឃានរោគទុក្ខ ជិវ្ហារោគទុក្ខ កាយរោគទុក្ខ សីសរោគទុក្ខ កណ្ណរោគទុក្ខ មុខរោគទុក្ខ ទន្តរោគទុក្ខ ដោយទុក្ខព្រោះរោគក្អក ហឺត ឫសដូងច្រមុះ ក្តៅក្រហាយ ស្តាំងស្តម ឈឺពោះ រៀលមុខ ធ្លាក់ឈាម ចុកសៀត ចុកផ្ទៃ ឃ្លង់ ពក ស្រែង រីងរៃ ធ្ពត់ជ្រូក ដំណួចពិស រមាស់ កម រោគកើតក្នុងទីខ្ទារដោយក្រចក ឃ្លង់ដៃក ឈាម

បិត្តេន មជ្ជមេហេន អំសាយ បិប្ផកាយ ភតន្ធលា-
យ[1] បិត្តសមុដ្ឋានេហិ អាពាធេហិ សេម្ហសមុដ្ឋានេ-
ហិ អាពាធេហិ វាតសមុដ្ឋានេហិ អាពាធេហិ សន្និ-
ចាតិកេហិ អាពាធេហិ ឧតុបរិណាមជេហិ អាពាធេ-
ហិ វិសមបរិហារជេហិ អាពាធេហិ ឱបក្កមិកេហិ
អាពាធេហិ កម្មវិបាកជេហិ អាពាធេហិ សីតេន
ឧណ្ហេន ជិឃច្ឆាយ បិបាសាយ ឧច្ចារេន បស្សាវេន
ឌំសមកសវាតាតបសិរីសបសម្ផស្សេហិ មាតុមរណេ-
ន ទុក្ខេន បិតុមរណេន ទុក្ខេន ភាតុមរណេន
ទុក្ខេន ភគិនីមរណេន ទុក្ខេន បុត្តមរណេន ទុក្ខេ-
ន ធីតុមរណេន ទុក្ខេន ញាតិព្យសនេន ទុក្ខេន
ភោគព្យសនេន ទុក្ខេន រោគព្យសនេន ទុក្ខេន
សីលព្យសនេន ទុក្ខេន ទិដ្ឋិព្យសនេន ទុក្ខេន
ផដ្ឋមានោ បរិផដ្ឋមានោ បរេតមានោ សម្ផរេតមា-
នោតិ បង្ហេ សយានោ បរិផដ្ឋមានោ ។

---

១ ម. ភគន្ធលេន បិត្តសមុដ្ឋានេន អាពាធេន ។ ល ។ ឌំសមកសវាតាតបសិរីសប-
សម្ផស្សេន ទុក្ខេន ។

ប្រមាត់ ប្រមេះ ឫសដូងជុះ បូស ឫសដូងបាត ព្រោះអាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីធាតុប្រជុំគ្នា អាពាធកើតអំពីការប្រែប្រួលរដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើ អាពាធកើតអំពីសេចក្តីព្យាយាម មានវាយចង់ជាដើម អាពាធកើតអំពីកម្មវិបាក ព្រោះត្រជាក់ ក្តៅ ឃ្លាន ស្រេកឧច្ចារៈ បស្សាវៈ សម្ផស្សរបោម មូស ខ្យល់ កម្តៅថ្ងៃ សត្វលូនវារ ដោយទុក្ខព្រោះស្លាប់មាតា ដោយទុក្ខព្រោះស្លាប់បិតា ដោយទុក្ខព្រោះស្លាប់បងប្អូនប្រុស ដោយទុក្ខព្រោះស្លាប់បងប្អូនស្រី ដោយទុក្ខព្រោះស្លាប់កូនប្រុស ដោយទុក្ខព្រោះស្លាប់កូនស្រី ដោយទុក្ខព្រោះវិនាសញាតិ ដោយទុក្ខព្រោះវិនាសភោគសម្បត្តិ ដោយទុក្ខព្រោះវិនាសដោយសារពោគ ដោយទុក្ខ ព្រោះវិនាសសីល ដោយទុក្ខ ព្រោះវិនាសទិដ្ឋិ ហេតុនេះ (លោកពោលថា) ដេកក្នុងកក់ បម្រះនទៀល ។

[២០៩] ឥីចា ឥីបំ ឧបល្ហវិន្តិ សត្ថារតោ សត្ថារំ ធម្មក្ខានតោ ធម្មក្ខានំ កណតោ កណំ ឥិដ្ឋិយា ឥិដ្ឋឿ បដិបជ្ជតោ បដិបជ្ជនំ មក្ខតោ មក្ខំ ឧបល្ហឿ សមុបល្ហវិន្តិ ឥីចា ឥីបំ ឧបល្ហឿ ។

[២១០] អជ្ជសាសឿ សម្ពុទ្ធន្តិ អជ្ជាតិ បឋមន្ទិ ។ បេ ។ បជ្ជាជុបុព្ជកមេតំ អជ្ជាតិ ។ អជ្ជសាសិន្តិ អជ្ជសំ អជ្ជក្ខឿ អបស្ឆឿ បដិវិជ្ឈឿ ។ សម្ពុទ្ធន្តិ យោ សោ ភគវា ។ បេ ។ សច្ឆិកា បញ្ញត្តិ យឥិទំ ពុជ្ជោតិ អជ្ជសាសឿ សម្ពុទ្ធំ ។

[២១១] ឱឃតិណ្ណោន្តិ ភគវា ការាមោឃំ តិណ្ណោ ភវោឃំ តិណ្ណោ ឥិជ្ជោឃំ តិណ្ណោ អវិជ្ជោឃំ តិណ្ណោ ឧត្តិណ្ណោ និត្តិណ្ណោ អតិក្ខន្តោ សមតិក្ខ-ន្តោ វីតិវត្តោ សោ រុជ្ជវាសោ ចិណ្ណចរណោ ។ បេ ។

[២០៩] ពាក្យថា ស្ទុះចេញអំពីទីពឹង ទៅរកទីពឹង គឺ ស្ទុះ ស្ទុះចេញ អំពីសាស្តា ទៅរកសាស្តា អំពីអ្នកប្រាប់ធម៌ ទៅរកអ្នកប្រាប់ធម៌ អំពីគណៈ ទៅរកគណៈ អំពីទិដ្ឋិ ទៅរកទិដ្ឋិ អំពីបដិបទា ទៅរកបដិបទា អំពីមគ្គ ទៅរកមគ្គ ហេតុនោះ (លោកពោលថា) ស្ទុះចេញអំពីទីពឹង ទៅរកទីពឹង ។

[២១០] ពាក្យថា គ្រានោះ អាត្មាបានឃើញព្រះសម្ពុទ្ធ ត្រង់ពាក្យថា គ្រានោះ គឺជាការតបទ ។ បេ ។ ពាក្យថា គ្រានោះ ជាលំដាប់នៃបទ ។ ពាក្យថា បានឃើញ គឺ បានឃើញ បានជួប បានប្រសព្ធ បានចាក់ធ្លុះ ។ ពាក្យថា ព្រះសម្ពុទ្ធ បានដល់ព្រះមានបុណ្យ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធ នេះ កើតអំពីការត្រាស់ដឹង ហេតុនោះ (លោកពោលថា) គ្រានោះ អាត្មាបានឃើញព្រះសម្ពុទ្ធ ។

[២១១] ពាក្យថា ទ្រង់ធ្វងអន្ទង់ហើយ គឺ ព្រះមានព្រះភាគទ្រង់ធ្វងអន្ទង់គឺកាម ធ្វងអន្ទង់គឺភព ធ្វងអន្ទង់គឺទិដ្ឋិ ធ្វង ធ្វងឡើង ធ្វងចេញ កន្ទង កន្ទងព្រម ប្រព្រឹត្តកន្ទង អន្ទង់គឺអវិជ្ជា គឺថា ព្រះអង្គទ្រង់មានការនៅក្នុងអរិយវាស នៅរួចហើយ មានចរណៈសន្សំហើយ ។ បេ ។

ជាតិជរាមរណសំសារេ ឧត្តិ តស្ស បុនព្ភវេតិ ឱ-ឃតិណ្ណំ ។ អដ្ឋាសវន្តិ ចត្តារោ អាសវា កាមាស-វោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។ តេ អា-សវា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តា-លវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ អនាសវោតិ ឱឃតិណ្ណមនាសវំ ។ តេនាហ បិង្គិយត្ថេរោ

បង្កេ (សយានោ) បរិឌយ្ហមានោ

ទីបា ទីបំ ឧបល្លវឹ

អថទ្ទសាសឹ សម្ពុទ្ធំ

ឱឃតិណ្ណមនាសវន្តិ ។

[២១២] យថា អហូ វក្កលិ មុត្តសទ្ធោ

ភទ្រាវុធោ អាឡវិគោតមោ ច

ឯវមេវ ត្វម្បិ បមុញ្ចស្សុ សទ្ធំ

គមិស្សសិ (ត្វំ) បិង្គិយ មច្ចុធេយ្យស្ស បារំ ។

ភពថ្មី គឺ ជាតិ ជរា មរណៈ សង្ខារ នៃព្រះអង្គមិនមាន ហេតុនោះ (លោកពោលថា) ទ្រង់ធ្វើអន្ទង់ហើយ ។ ពាក្យថា មិនមានអាសវៈ សេចក្តីថា អាសវៈ ៤ គឺ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។ អាសវៈទាំងនោះ ព្រះពុទ្ធមានជោគ ទ្រង់លះបង់ហើយ មានឫសគល់ផ្តាច់ផ្តិលហើយ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យដល់នូវការមិនកើតមាន ឲ្យជាធម៌លែងកើតតទៅទៀត ហេតុនោះ ព្រះពុទ្ធឈ្មោះថាមិនមានអាសវៈ ហេតុនោះ (លោកពោលថា) ទ្រង់ធ្វើអន្ទង់ហើយ មិនមានអាសវៈ ។ ហេតុនោះ ព្រះបិង្គិយត្ថេរ ពោលថា

អាត្មាដេកក្នុងកក់ បម្រះនទៀល ស្ទុះចេញអំពីទីពឹង ទៅរកទីពឹង គ្រានោះ អាត្មាបានឃើញព្រះសម្ពុទ្ធ ព្រះអង្គទ្រង់ធ្វើអន្ទង់ហើយ ទ្រង់មិនមានអាសវៈទេ ។

[២១២] (ព្រះមានព្រះភាគត្រាស់ថា) វក្កលិ ភទ្រាវុធ និងអាឡវិគោតម សុទ្ធតែជាអ្នកមានសទ្ធាបញ្ញេញហើយ យ៉ាងណា សូម្បីអ្នកក៏ចូរបញ្ញេញ នូវសទ្ធា យ៉ាងនោះចុះ ម្នាលបិង្គិយៈ អ្នកនឹងដល់នូវត្រើយ នៃលំនៅរបស់មច្ចុ ។

[២១៣] យថា អហូ វក្កលិ មុត្តស្ទ្ធោ ភទ្រាវុធោ អាឧ្យវិកោតមោ ចាតិ យថា វក្កលិ មុត្ត-ស្ទ្ធោ សទ្ធាករុកោ សទ្ធាបុព្ជ្ជមោ សទ្ធាធិមុត្តោ សទ្ធាធិបតេយ្យោ អរហាត្តប្ជត្តោ យថា ភទ្រាវុធោ មុត្តស្ទ្ធោ សទ្ធាករុកោ សទ្ធាបុព្ជ្ជមោ សទ្ធាធិ-មុត្តោ សទ្ធាធិបតេយ្យោ អរហាត្តប្ជត្តោ យថា អា-ឧ្យវិកោតមោ មុត្តស្ទ្ធោ សទ្ធាករុកោ សទ្ធាបុព្ជ្ជ-មោ សទ្ធាធិមុត្តោ សទ្ធាធិបតេយ្យោ អរហាត្តប្ជត្តោតិ យថា អហូ វក្កលិ មុត្តស្ទ្ធោ ភទ្រាវុធោ អាឧ្យវិកោតមោ ច ។

[២១៤] ឯវមេវ ត្វម្ជិ បមុញ្ចស្ទ្ធ សទ្ធន្តិ ឯវ-មេវ ត្វំ សទ្ធំ មុញ្ចស្ទ្ធ បមុញ្ចស្ទ្ធ សម្ជមុញ្ចស្ទ្ធ អធិមុញ្ចស្ទ្ធ ឱ្ការប្ជហិ សព្ជ សជ្ជ្ជ្ជ អនិច្ជ្ជាតិ ។ បេ ។ យជ្ជ្ជ្ជ្ជ សមុទយធម្ម សព្ជ្ជ និរោធធម្មន្តិ សទ្ធំ មុញ្ចស្ទ្ធ បមុញ្ចស្ទ្ធ សម្ជមុញ្ចស្ទ្ធ អធិមុញ្ច-ស្ទ្ធ ឱ្ការប្ជហ្ជ្ជ្ជ្ជ ឯវមេវ ត្វម្ជិ បមុញ្ចស្ទ្ធ សទ្ធំ ។

[២១៣] *ពាក្យថា វក្កលិ ភទ្រាវុធ និងអាឡវិគោតម សុទ្ធតែជាអ្នកមានសទ្ធាបញ្ញេញហើយ យ៉ាងណា អធិប្បាយថា វក្កលិ មានសទ្ធាបញ្ញេញហើយ ជាអ្នកធ្ងន់ក្នុងសទ្ធា មានសទ្ធាជាប្រធាន មានចិត្តចុះស៊ប់ក្នុងសទ្ធា មានសទ្ធាជាអធិបតី បានសម្រេចព្រះអរហត្ត យ៉ាងណា ភទ្រាវុធ មានសទ្ធាបញ្ញេញហើយ ជាអ្នកធ្ងន់ក្នុងសទ្ធា មានសទ្ធាជាប្រធាន មានចិត្តចុះស៊ប់ក្នុងសទ្ធា មានសទ្ធាជាអធិបតី បានសម្រេចព្រះអរហត្ត យ៉ាងណា អាឡវិគោតម មានសទ្ធាបញ្ញេញហើយ ជាអ្នកធ្ងន់ក្នុងសទ្ធា មានសទ្ធាជាប្រធាន មានចិត្តចុះស៊ប់ក្នុងសទ្ធា មានសទ្ធាជាអធិបតី បានសម្រេចព្រះអរហត្ត យ៉ាងណា ហេតុនោះ (ទ្រង់ត្រាស់ថា) វក្កលិ ភទ្រាវុធ និងអាឡវិគោតម សុទ្ធតែជាអ្នកមានសទ្ធាបញ្ញេញហើយ យ៉ាងណា ។*

[២១៤] *ពាក្យថា សូម្បីអ្នកក៏ចូរបញ្ញេញនូវសទ្ធាយ៉ាងនោះចុះ សេចក្ដីថា អ្នកចូរលែង ចូរបញ្ញេញ ចូរបញ្ញេញព្រម ចូរចុះស៊ប់ កាន់សទ្ធា គឺចូរជឿថា សង្ខារទាំងពួងមិនទៀង ។ បេ ។ អ្នកចូរលែង ចូរបញ្ញេញ ចូរបញ្ញេញព្រម ចូរចុះស៊ប់កាន់សទ្ធា គឺចូរជឿថា របស់ណាមានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) សូម្បីអ្នកក៏ចូរបញ្ញេញនូវសទ្ធាយ៉ាងនោះចុះ ។*

[២១៥] កថិស្សសិ (ត្វំ) បិង្គិយ មច្ចុធេយ្យស្ស បារន្តិ មច្ចុធេយ្យា វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ មច្ចុធេយ្យស្ស បារំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិប្ប-ដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ កថិស្សសិ (ត្វំ) បិង្គិយ មច្ចុធេយ្យស្ស បារន្តិ ត្វំ បារំ កមិស្សសិ អធិគមិស្សសិ ផុសិស្សសិ សច្ឆិ-ករិស្សសីតិ កថិស្សសិ (ត្វំ) បិង្គិយ មច្ចុធេយ្យស្ស បារំ ។ តេនាហ ភគវា

យថា អហូ វក្កលិ មុត្តសទ្ធោ
ភទ្រាវុធោ អាឡវិគោតមោ ច
ឯវមេវ ត្វម្បិ បមុញ្ចស្សុ សទ្ធំ
កថិស្សសិ (ត្វំ) បិង្គិយ មច្ចុធេយ្យស្ស បារន្តិ ។

[២១៦] ឯស ភិយ្យោ បសីទាមិ សុត្វាន មុនិនោ វចោ
វិវដច្ឆទោ[១] សម្ពុទ្ធោ អខិលោ បដិភាណវា ។

១ ម. វិវដច្ឆទនោ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេស

[២១៥] ពាក្យថា ម្នាលបិङ្គិយៈ អ្នកនឹងដល់ត្រើយ នៃលំនៅរបស់មច្ចុ សេចក្ដីថា កិលេស ខន្ធ និងអភិសङ្ខារ លោកហៅថា លំនៅរបស់មច្ចុ ។ អមតនិព្វាន លោកហៅថា ត្រើយនៃលំនៅរបស់មច្ចុ បានដល់ការរម្ងាប់សङ្ខារទាំងពួង ការលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក សេចក្ដីរលត់ និព្វាន ។ ពាក្យថា ម្នាលបិङ្គិយៈ អ្នកនឹងដល់ត្រើយ នៃលំនៅរបស់មច្ចុ បានសេចក្ដីថា អ្នកនឹងដល់ នឹងបាន នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់នូវត្រើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលបិङ្គិយៈ អ្នកនឹងដល់ត្រើយ នៃលំនៅរបស់មច្ចុ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> វក្កលិ ភទ្រាវុធ និងអាឡវិគោតម សុទ្ធតែជាអ្នកមានសទ្ធាបញ្ចេញហើយ យ៉ាងណា សូម្បីអ្នកក៏ចូរបញ្ចេញសទ្ធា យ៉ាងនោះចុះ ម្នាលបិङ្គិយៈ អ្នកនឹងដល់ត្រើយ នៃលំនៅរបស់មច្ចុ ។

[២១៦] (ព្រះបិङ្គិយត្តេរទូលថា) ខ្ញុំព្រះអង្គនេះជ្រះថ្លាក្រៃពេក ព្រោះបានស្ដាប់ព្រះបន្ទូលនៃព្រះអង្គ ជាព្រះមុនិ ព្រះអង្គទ្រង់មានគ្រឿងបិទ បើកហើយ ព្រះអង្គមិនមានគ្រឿងរឹងរូស ទ្រង់មានបដិភាណ ។

[២១៧] ឯស ភិយ្យោ បសីទាមីតិ ឯស ភិយ្យោ បសីទាមិ សទ្ទហាមិ អធិមុច្ចាមិ ឱកប្បេមិ សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ភិយ្យោ បសីទាមិ សទ្ទហាមិ អធិមុច្ចាមិ ឱកប្បេមីតិ ឯស ភិយ្យោ បសីទាមិ ។

[២១៨] សុត្វាន មុនិនោ វចោតិ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជានានា ។ បេ ។ សង្គ-ជាលមតិច្ច សោ មុនិ ។ សុត្វាន មុនិនោ វចោតិ តុយ្ហំ វចនំ ព្យបថំ ទេសនំ អនុសន្ធឹ សុត្វា សុណិត្វា ឧគ្គហេត្វា ឧបធារយិត្វា ឧបលក្ខយិត្វាតិ សុត្វាន មុនិនោ វចោ ។

[២១៩] វិវដច្ឆទោ សម្ពុទ្ធោតិ ឆទនន្តិ បញ្ច ឆទនានិ តណ្ហាឆទនំ ទិដ្ឋិឆទនំ កិលេសឆទនំ

[២១៧] ពាក្យថា ខ្ញុំព្រះអង្គនេះជ្រះថ្លាក្រៃពេក គឺ ខ្ញុំព្រះអង្គនេះ ជ្រះថ្លា ជឿ ចុះចិត្តស៊ប់ ជឿមាំក្រៃពេកថា សង្ខារទាំងពួងមិនទៀង ។ បេ ។ ខ្ញុំព្រះអង្គនេះ ជ្រះថ្លា ជឿ ចុះចិត្តស៊ប់ ជឿមាំក្រៃពេកថា របស់ណា មានការកើតឡើងជាធម្មតា របស់នោះ មានការរលត់ទៅវិញជាធម្មតា ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គនេះជ្រះថ្លាក្រៃពេក ។

[២១៨] ពាក្យថា ព្រោះបានស្តាប់ព្រះបន្ទូលនៃព្រះអង្គជាព្រះមុនិ ត្រង់ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ បានដល់បញ្ញា ការដឹងច្បាស់ ។ បេ ។ មុនិនោះ កន្ធ៨នូវបណ្តាញគឺកិលេសជាគ្រឿងចំពាក់ ។ ពាក្យថា ព្រោះបានស្តាប់ព្រះបន្ទូលនៃព្រះអង្គជាព្រះមុនិ បានសេចក្តីថា ព្រោះបានស្តាប់ ឮ រៀន ចងចាំទុក កំណត់ទុកនូវព្រះបន្ទូល គន្ធ៨នៃព្រះបន្ទូល ទេសនា អនុសន្ធិ នៃព្រះអង្គ ហេតុនោះ (លោកពោលថា) ព្រោះបានស្តាប់ព្រះបន្ទូល នៃព្រះអង្គជាព្រះមុនិ ។

[២១៩] ពាក្យថា ព្រះសម្ពុទ្ធទ្រង់មានគ្រឿងបិទបើកហើយ ត្រង់ពាក្យថា គ្រឿងបិទ បានដល់គ្រឿងបិទ ៥ គឺ គ្រឿងបិទគឺតណ្ហា គ្រឿងបិទគឺទិដ្ឋិ គ្រឿងបិទគឺកិលេស គ្រឿងបិទ

ទុច្ចរិតឆទនំ អវិជ្ជាឆទនំ ។ តានិ ឆទនានិ ពុទ្ធស្ស ភគវតោ វិវដានិ វិទ្ធំសិតានិ សមុគ្ឃាតិតានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ តស្មា ពុទ្ធោ វិវដច្ឆទោ ។ ពុទ្ធោតិ យោ សោ ភគវា ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ វិវដច្ឆទោ សម្ពុទ្ធោ ។

[២២០] អវិឃោ បដិភាណវាតិ អវិឃោតិ រាគោ វិឃោ ទោសោ វិឃោ មោហោ វិឃោ កោធោ វិឃោ ឧបនាហោ វិឃោ ។ បេ ។ សព្វាកុសលាភិសង្ខារា វិឃា ។ តេ វិឃា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ អវិឃោ ។

គឺទុច្ចរិត គ្រឿងបិទគឺអវិជ្ជា ។ គ្រឿងបិទទាំងនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់បើក គឺកម្ចាត់បង់ ដកឡើង លះបង់ ផ្តាច់ផ្តិល រម្ងាប់ គ្របសង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមានគ្រឿងបិទបើកហើយ ។ ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធ នេះ កើត ព្រោះការត្រាស់ដឹង ហេតុនោះ (លោកពោលថា) ព្រះសម្ពុទ្ធទ្រង់ មានគ្រឿងបិទបើកហើយ ។

[២២០] *អធិប្បាយពាក្យថា ព្រះអង្គមិនមានគ្រឿងរឹងរូស ទ្រង់មានបដិភាណ ត្រង់ពាក្យថា មិនមានគ្រឿងរឹងរូស សេចក្តីថា រាគ:ឈ្មោះថាគ្រឿងរឹងរូស ទោស: ឈ្មោះថាគ្រឿងរឹងរូស មោហ: ឈ្មោះថាគ្រឿងរឹងរូស ក្រោធ ឈ្មោះថាគ្រឿងរឹងរូស ការចងគំនុំ ឈ្មោះថាគ្រឿងរឹងរូស ។ បេ ។ អកុសលាកិសង្ខារទាំងអស់ ឈ្មោះថាគ្រឿងរឹងរូស ។ គ្រឿងរឹងរូសទាំងនោះព្រះពុទ្ធមានជោគ ទ្រង់លះបង់ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន ធ្វើឲ្យជាធម៌លែងកើតតទៅទៀត ហេតុនោះ ព្រះពុទ្ធឈ្មោះថាមិនមានគ្រឿងរឹងរូស ។*

បដិកាណវាតិ តយោ បដិកាណវន្តោ បរិយត្តិប្ប-ដិកាណវា ច បរិបុច្ឆាបដិកាណវា ច អធិគមប្ប-ដិកាណវា ច ។

កតមោ បរិយត្តិប្បដិកាណវា ។ ឥធេកចូ្ស្ស ពុទ្ធវចនំ បរិយាបុដំ ហោតិ សុត្តំ គេយ្យំ វេយ្យា-ការណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភូត-ធម្មំ វេទល្លំ តស្ស បរិយត្តឺ និស្សាយ បដិកាតិ អយំ បរិយត្តិប្បដិកាណវា ។

កតមោ បរិបុច្ឆាបដិកាណវា ។ ឥធេកចោ្ច បរិបុច្ឆិតា ហោតិ អត្ថេ ច ញ្ហាយេ ច លក្ខ្ហណេ ច ការណេ ច ហានាហានេ ច តស្ស បរិបុច្ឆំ និស្សាយ បដិកាតិ អយំ បរិបុច្ឆាបដិកាណវា ។

កតមោ អធិគមប្បដិកាណវា ។ ឥធេកចូ្ស្ស អធិគតា ហោន្តិ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្ម-ប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិ្ទ្រិយានិ បញ្ច ពលានិ

ពាក្យថា ទ្រង់មានបដិភាណ បានដល់បុគ្គលមានបដិភាណ ៣ ពួក គឺ បុគ្គលមានបដិភាណព្រោះបរិយត្តិ ១ បុគ្គលមានបដិភាណព្រោះបរិបុច្ឆា ១ បុគ្គលមានបដិភាណព្រោះអធិគម: ១ ។

បុគ្គលមានបដិភាណព្រោះបរិយត្តិ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ រៀនពុទ្ធវចន: គឺសុត្ត: គេយ្យ: វេយ្យាករណ: គាថា ឧទាន: ឥតិវុត្តក: ជាតក: អព្ភូតធម្ម: វេទល្ល: ពុទ្ធវចន:នោះ រមែងភ្ញឹកប្រាស់ដល់បុគ្គលនោះ ព្រោះអាស្រ័យបរិយត្តិ នេះឈ្មោះថា បុគ្គលមានបដិភាណព្រោះបរិយត្តិ ។

បុគ្គលមានបដិភាណព្រោះបរិបុច្ឆា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសាកសួរក្នុងអត្ថ ក្នុងធម៌គួរដឹង ក្នុងលក្ខណ: ក្នុងហេតុ ក្នុងឋាន:និងអដ្ឋាន: សភាវ:មានអត្ថជាដើមនោះ រមែងភ្ញឹកប្រាស់ដល់បុគ្គលនោះ ព្រោះអាស្រ័យការសាកសួរ នេះ ឈ្មោះថាបុគ្គលមានបដិភាណព្រោះបរិបុច្ឆា ។

បុគ្គលមានបដិភាណព្រោះអធិគម: តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ត្រាស់ដឹងសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល: ៥

សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ចត្តារោ អរិយមគ្គា ចត្តារិ សាមញ្ញផលានិ ចតស្សោ បដិសម្ភិទាយោ ឆ អភិញ្ញាយោ តស្ស អត្ថោ ញាតោ ធម្មោ ញាតោ និរុត្តិ ញាតា អត្ថេ ញាតេ អត្ថោ បដិភាតិ ធម្មេ ញាតេ ធម្មោ បដិភាតិ និរុត្តិយា ញាតាយ និរុត្តិ បដិភាតិ ឥមេសុ តីសុ ញាណំ បដិភាណប្បដិសម្ភិទា ។ ភគវា ឥមាយ បដិសម្ភិទាយ ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា ពុទ្ធោ បដិភាណវា ។ យស្ស បរិយត្តិ នត្ថិ បរិបុច្ឆា នត្ថិ អធិគមោ នត្ថិ កឹ តស្ស បដិភាយិស្សតីតិ អខិលោ បដិភាណវា ។ តេនាហ បិង្គិយត្ថេរោ

ឯស ភិយ្យោ បសីទាមិ សុត្វាន មុនិនោ វចោ
វិវដច្ឆទោ សម្ពុទ្ធោ អខិលោ បដិភាណវាតិ ។

[២២១] អធិទេវេ អភិញ្ញាយ សព្វំ វេទិ បរោវរំ[១]
បញ្ហានន្តករោ សត្ថា កង្ខីនំ បដិជានតំ ។

១ ម. បរោបរំ ។

ពោជ្ឈង្គ ៧ អដ្ឋង្គិកមគ្គដ៏ប្រសើរ អរិយមគ្គ ៤ សាមញ្ញផល ៤ បដិសម្ភិ-ទា ៤ អភិញ្ញា ៦ បុគ្គលនោះ ដឹងអត្ថ ដឹងធម៌ ដឹងនិរុត្តិ កាលបុគ្គលដឹងអត្ថហើយ អត្ថក៏ភ្ញឺច្បាស់ កាលបុគ្គលដឹងធម៌ហើយ ធម៌ក៏ភ្ញឺច្បាស់ កាលបុគ្គលដឹងនិរុត្តិហើយ និរុត្តិក៏ភ្ញឺច្បាស់ ការដឹងក្នុងធម៌ទាំង ៣ នេះ ឈ្មោះថាបដិភាណប្បដិសម្ភិទា ។ ព្រះមានព្រះភាគ ទ្រង់ប្រកបហើយ ប្រកបព្រម ចូលទៅជិតដល់ ចូលទៅជិតដល់ព្រម ចូលទៅជិតសម្រេច ចូលទៅជិតសម្រេចព្រម រួបរួម ដោយបដិសម្ភិទានេះ ហេតុនោះ ព្រះ ពុទ្ធ ឈ្មោះថាទ្រង់មានបដិភាណ ។ បុគ្គលណា ពុំមានបរិយត្តិ ពុំមាន បរិបុច្ឆា ពុំមានអធិគម:ទេ អ្វីនឹងភ្ញឺច្បាស់ដល់បុគ្គលនោះ ហេតុនោះ (លោកពោលថា) ព្រះអង្គមិនមានគ្រឿងរឹងរូស ទ្រង់មានបដិភាណ ។ ហេតុនោះ ព្រះបិង្គិយត្ថេរ ពោលថា

ខ្ញុំព្រះអង្គនេះជ្រះថ្លាក្រៃពេក ព្រោះបានស្តាប់ព្រះបន្ទូលនៃ
ព្រះអង្គជាព្រះមុនិ ព្រះសម្ពុទ្ធទ្រង់មានគ្រឿងបិទបើកហើយ
ព្រះអង្គមិនមានគ្រឿងរឹងរូស ទ្រង់មានបដិភាណ ។

[២២១] ព្រះសាស្តាទ្រង់ជ្រាបច្បាស់ នូវអធិទេវតាទាំងឡាយ
ទ្រង់ជ្រាបនូវធម្មជាតទាំងអស់ ដែលថោកទាបនិងប្រសើរ
ទ្រង់ធ្វើទីបំផុត នៃប្រស្នាទាំងឡាយ ដល់ពួកជនអ្នក
សង្ស័យដែលប្តេជ្ញា (ថាអស់សង្ស័យ) ។

[២២២] អជ្ឌិនេវ អភិញ្ញាយាតិ នេវាតិ តយោ នេវ សម្មតិនេវ ច ឧបបត្តិនេវ ច វិសុទ្ធិនេវ ច ។

កតមេ សម្មតិនេវ ។ រាជានោ ច រាជកុមារា ច នេវិយោ ច ឥមេ សម្មតិនេវ រុច្ចន្តិ ។

កតមេ ឧបបត្តិនេវ ។ ចាតុម្មហារាជិកា នេវ តាវតឹ្ងសា នេវ ។ បេ ។ ព្រហ្មកាយិកា នេវ យេ ច នេវ តត្រូបរិ[1] ឥមេ ឧបបត្តិនេវ រុច្ចន្តិ ។

កតមេ វិសុទ្ធិនេវ ។ តថាគតស្សាវកា អរហន្តោ ខីណាសវា យេ ច បច្ចេកសម្ពុទ្ធា ឥមេ វិសុទ្ធិនេវ រុច្ចន្តិ ។

ភគវា សម្មតិនេវ អជ្ឌិនេវាតិ អភិញ្ញាយ ឧបប-ត្តិនេវ អជ្ឌិនេវាតិ អភិញ្ញាយ វិសុទ្ធិនេវ អជ្ឌិនេវាតិ អភិញ្ញាយ ជានិត្វា តុលយិត្វា តីរយិត្វា វិការយិត្វា វិភូតំ កត្វាតិ អជ្ឌិនេវ អភិញ្ញាយ ។

---

១ ម. តទុបរិ ។

[២២២] *អធិប្បាយពាក្យថា ទ្រង់ជ្រាបច្បាស់នូវអធិទេវតាទាំងឡាយ ត្រង់ពាក្យថា ទេវតាទាំងឡាយ បានដល់ទេវតា ៣ ពួក គឺ ពួកសម្មតិ-ទេវតា ១ ឧបបត្តិទេវតា ១ វិសុទ្ធិទេវតា ១ ។*

សម្មតិទេវតា តើដូចម្តេច ។ ព្រះរាជា ព្រះរាជកុមារ និងព្រះរាជ-ទេពី ទាំងនេះ ហៅថា សម្មតិទេវតា ។ ឧបបត្តិទេវតា តើដូចម្តេច ។ ពួកទេវតាជាន់ចាតុម្មហារាជិក: ពួកទេវតាជាន់តាវត្តិង្ស ។ បេ ។ ពួកទេវតាជាន់ព្រហ្មកាយិក: និងពួកទេវតាជាន់ខាងលើអំពីនោះ ទាំងនេះ ហៅថា ឧបបត្តិទេវតា ។

វិសុទ្ធិទេវតា តើដូចម្តេច ។ ព្រះអរហន្តខីណាស្រព ជាសាវ័ករបស់ តថាគត និងព្រះបច្ចេកសម្ពុទ្ធ ទាំងនេះ ហៅថា វិសុទ្ធិទេវតា ។

ព្រះមានព្រះភាគជ្រាបច្បាស់ នូវសម្មតិទេវតាទាំងឡាយថា ជាអធិ-ទេវតា ទ្រង់ជ្រាបច្បាស់នូវពួកឧបបត្តិទេវតាថា ជាអធិទេវតា ទ្រង់ជ្រាប ច្បាស់ ទ្រង់យល់ ទ្រង់ច្បីង ទ្រង់ត្រិះរិះ ទ្រង់ជាក់ច្បាស់ ទ្រង់ធ្វើឲ្យ ប្រាកដ នូវពួកវិសុទ្ធិទេវតាថា ជាអធិទេវតា ហេតុនោះ (លោក ពោលថា) ទ្រង់ជ្រាបច្បាស់ នូវអធិទេវតាទាំងឡាយ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

[២២៣] សព្វំ វេទិ បរោវរន្តិ ភគវា អត្តនោ ច បរេសញ្ច អធិទេវករេ ធម្មេ វេទិ អញ្ញាសិ អផុសិ បដិវិជ្ឈិ ។ កតមេ អត្តនោ អធិទេវករា ធម្មា ។ សម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា ធម្មានុធម្មប្បដិបទា សីលេសុ បរិបូរិការិតា ឥន្ទ្រិយេសុ គុត្តទ្វារតា ភោជនេ មត្តញ្ញុតា ជាគរិយានុយោគោ សតិសម្បជញ្ញំ ចត្តារោ សតិប្បដ្ឋានា ។ បេ ។ អរិយោ អដ្ឋង្គិកោ មគ្គោ ឥមេ វុច្ចន្តិ អត្តនោ អធិទេវករា ធម្មា ។ កតមេ បរេសំ អធិទេវករា ធម្មា ។ សម្មាបដិបទា ។ បេ ។ អរិយោ អដ្ឋង្គិកោ មគ្គោ ឥមេ វុច្ចន្តិ បរេសំ អធិទេវករា ធម្មា ។ ឯវំ ភគវា អត្តនោ ច បរេសញ្ច អធិទេវករេ ធម្មេ វេទិ អញ្ញាសិ អផុសិ បដិវិជ្ឈីតិ សព្វំ វេទិ បរោវរំ ។

សោឡសមាណវកបញ្ហានិគមនិទ្ទេស

[២២៣] *ពាក្យថា ទ្រង់ជ្រាបច្បាស់ធម្មជាតទាំងអស់ ដ៏ថោកទាប និងប្រសើរ អធិប្បាយថា ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ ទ្រង់យល់ ទ្រង់ប៉ះពាល់ ទ្រង់ចាក់ធ្ងុះ នូវពួកធម៌ ដែលធ្វើព្រះអង្គនិងបុគ្គលដទៃ ឲ្យជាអធិទេវតា ។ ពួកធម៌ដែលធ្វើព្រះអង្គ ឲ្យជាអធិទេវតា តើដូចម្តេច ។ សេចក្តីប្រតិបត្តិដោយប្រពៃ សេចក្តីប្រតិបត្តិបណ្តាយតាម សេចក្តីប្រតិ-បត្តិមិនទំនាស់ សេចក្តីប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ការធ្វើបំពេញក្នុងសីល ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ការដឹងប្រមាណក្នុងភោជន ការប្រកបរឿយ ៗ នូវសេចក្តីភ្ញាក់រឭក សតិសម្បជញ្ញៈ សតិប្បដ្ឋាន ៤ ។ បេ ។ អដ្ឋង្គិកមគ្គដ៏ប្រសើរ ទាំងនេះហៅថា ធម៌ដែលធ្វើព្រះអង្គឲ្យជាអធិទេវតា ។ ធម៌ធ្វើបុគ្គលដទៃឲ្យជាអធិទេវតា តើដូចម្តេច ។ សេចក្តីប្រតិបត្តិដោយប្រពៃ ។ បេ ។ អដ្ឋង្គិកមគ្គដ៏ប្រសើរ ទាំងនេះ ហៅថា ធម៌ធ្វើបុគ្គលដទៃឲ្យជាអធិទេវតា ។ ព្រះមានព្រះភាគទ្រង់ជ្រាប ទ្រង់យល់ ទ្រង់ប៉ះពាល់ ទ្រង់ចាក់ធ្ងុះ នូវធម៌ដែលធ្វើព្រះអង្គនិងបុគ្គលដទៃ ឲ្យជាអធិទេវតា ហេតុនោះ (លោកពោលថា) ទ្រង់ជ្រាបធម្មជាតទាំងអស់ដ៏ថោកទាប និងប្រសើរ ។*

[២២៤] បញ្ហានន្តកោ សត្ថាតិ ភគវា ចាកយ-និកប្បញ្ហានំ អន្តកោ បរិយន្តកោ បរិច្ឆេទកោ បរិវដុមកោ បរិសប្បញ្ហានំ(១) អន្តកោ បរិយន្ត-កោ បរិច្ឆេទកោ បរិវដុមកោ ទិដ្ឋិយប្បញ្ហានំ អន្តកោ បរិយន្តកោ បរិច្ឆេទកោ បរិវដុមកោ សក្កប្បញ្ហានំ អមនុស្សប្បញ្ហានំ ភិក្ខុប្បញ្ហានំ ភិក្ខុ-នីបញ្ហានំ ឧបាសកប្បញ្ហានំ ឧបាសិកាបញ្ហានំ រាជប្បញ្ហានំ ខត្តិយប្បញ្ហានំ ព្រាហ្មណប្បញ្ហានំ វេស្ស-ប្បញ្ហានំ សុទ្ទប្បញ្ហានំ ព្រហ្មប្បញ្ហានំ អន្តកោ បរិ-យន្តកោ បរិច្ឆេទកោ បរិវដុមកោតិ បញ្ហានន្ត-កោ ។ សត្ថាតិ ភគវា សត្ថវាហោ ។ យថា សត្ថវា-ហោ សត្តេ កន្តារំ តារេតិ ចោរកន្តារំ តារេតិ វាឡ-កន្តារំ តារេតិ ទុព្ភិក្ខកន្តារំ តារេតិ និរុទកកន្តារំ តារេតិ ឧត្តារេតិ និត្តារេតិ ខេមន្តភូមឹ សម្បាបេតិ ឯវមេវ

១ ម. សីគិបញ្ហានំ ។

[២២៤] ពាក្យថា ព្រះសាស្តា ទ្រង់ធ្វើទីបំផុតនៃប្រស្នា អធិប្បាយ ថា ព្រះមានព្រះភាគទ្រង់ធ្វើទីបំផុត ធ្វើទីបំផុតជុំវិញ ធ្វើការកំណត់ ធ្វើផ្លូវជុំវិញ នៃបារាយនិកប្បញ្ហា ទ្រង់ធ្វើទីបំផុត ធ្វើទីបំផុតជុំវិញ ធ្វើការកំណត់ ធ្វើផ្លូវជុំវិញ នៃបរិសប្បញ្ហា ទ្រង់ធ្វើទីបំផុត ធ្វើទីបំផុតជុំវិញ ធ្វើការកំណត់ ធ្វើផ្លូវជុំវិញ នៃបិង្គិយប្បញ្ហា ទ្រង់ធ្វើទីបំផុត ធ្វើទីបំផុត ជុំវិញ ធ្វើការកំណត់ ធ្វើផ្លូវជុំវិញ នៃសក្ខប្បញ្ហា អមនុស្សប្បញ្ហា ភិក្ខុប្បញ្ហា ភិក្ខុនីបញ្ហា ឧបាសកប្បញ្ហា ឧបាសិកាបញ្ហា រាជប្បញ្ហា ខត្តិយប្បញ្ហា ព្រាហ្មណប្បញ្ហា វេស្សប្បញ្ហា សុទ្ធប្បញ្ហា ព្រហ្មប្បញ្ហា ហេតុនោះ (លោកពោលថា) ទ្រង់ធ្វើនូវទីបំផុតនៃបញ្ហាទាំងឡាយ ។ ពាក្យថា ព្រះសាស្តា បានន័យថា ព្រះមានព្រះភាគ ទ្រង់ជាអ្នកនាំពួក ។ អ្នកនាំពួក ញ្ចាំងពួកឲ្យឆ្លងផ្លូវលំបាក គឺឲ្យឆ្លងផ្លូវលំបាកគឺចោរ ឲ្យ ឆ្លងផ្លូវលំបាកគឺសត្វសាហាវ ឲ្យឆ្លងផ្លូវលំបាកគឺទ្រុក្ស ឲ្យឆ្លង ឲ្យឆ្លង ឡើង ឲ្យឆ្លងចេញអំពីផ្លូវលំបាកគឺមិនមានទឹក ឲ្យដល់ខេមន្តភូមិ

ភគវា សត្ថវាហោ សត្តេ ភណ្ដារំ តារេតិ ជាតិជរាព្យា-ធិ មរណសោកបរិទេវទុក្ខទោមនស្សុបាយាសភណ្ដារំ តារេតិ រាគភណ្ដារំ តារេតិ ទោសមោហមានទិដ្ឋិក្លេ-សទុច្ចរិតភណ្ដារំ តារេតិ រាគភហានំ តារេតិ ទោសភ-ហានំ តារេតិ មោហភហានំ តារេតិ ទិដ្ឋិក្លេសទុច្ចរិ-តភហានំ តារេតិ ឧត្ដារេតិ និត្ដារេតិ ខេមន្ដភូមឺ អមតំ និព្ជានំ សម្ផាបេតីតិ ឯវំ ភគវា សត្ថវាហោ ។ អថវា ភគវា ឌេតា រិឌេតា អនុឌេតា សញ្ញាបេតា និជ្ជា-បេតា បេក្ខេតា បសាឌេតាតិ ឯវម្ជិ ភគវា សត្ថ-វាហោ ។ អថវា ភគវា អនុប្ជន្ធស្ស មត្ដស្ស ឧប្ជា-ឌេតា អសញ្ជាតស្ស មត្ដស្ស សញ្ជនេតា អនត្ជាត-ស្ស មត្ដស្ស អត្ជាតា មត្ដញ្ជ មត្ដវិជ្ជ មត្ដកោវិ-ឌោ មត្ដានុតា ច បន ឯតរហិ សាវកា រិហរន្ដិ បច្ជា សមន្ជាតតាតិ ឯវម្ជិ ភគវា សត្ថវាហោតិ បញ្ជានន្ដករោ សត្ថា ។

យ៉ាងណា ព្រះមានព្រះភាគ ទ្រង់ជាអ្នកនាំពួក ញ៉ាំងសត្វឲ្យធ្វេងផ្លូវ លំបាក គឺ ឲ្យធ្វេងផ្លូវលំបាក គឺ ជាតិ ជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ និងឧបាយាសៈ ឲ្យធ្វេងផ្លូវលំបាក គឺរាគៈ ឲ្យធ្វេងផ្លូវលំបាក គឺទោសៈ មោហៈ មានៈ ទិដ្ឋិ កិលេស ទុច្ចរិត ឲ្យធ្វេងព្រៃស្បាត គឺរាគៈ ឲ្យធ្វេងព្រៃស្បាត គឺទោសៈ ឲ្យធ្វេងព្រៃស្បាត គឺមោហៈ ឲ្យធ្វេង ឲ្យធ្វេងឡើង ឲ្យធ្វេងចេញអំពីព្រៃស្បាត គឺទិដ្ឋិ កិលេស និងទុច្ចរិត ឲ្យដល់ខេមន្តភូមិ គឺអមតនិព្វាន ក៏យ៉ាងនោះដែរ ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថា ជាអ្នកនាំពួក យ៉ាងនេះ ។ មួយទៀត ព្រះមានព្រះភាគ ទ្រង់នាំ ទូន្មាន ទូន្មានរឿយ ៗ ទ្រង់ឲ្យយល់ ឲ្យចូលចិត្ត ឲ្យឃើញ ឲ្យជ្រះថ្លា ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថា ជាអ្នកនាំពួក យ៉ាងនេះក៏បាន ។ ឬថា ព្រះមានព្រះភាគទ្រង់ញ៉ាំងមគ្គ ដែលមិនទាន់កើតឲ្យកើតបាន ញ៉ាំងមគ្គដែលមិនទាន់កើតឲ្យកើតបាន ទ្រង់ប្រាប់មគ្គដែលគេមិនទាន់ប្រាប់ ទ្រង់ជ្រាបមគ្គ ទ្រង់ស្គាល់មគ្គ ទ្រង់ឈ្វាសក្នុងមគ្គ ចំណែកខាងពួកសាវ័ក ក្នុងកាលឥឡូវនេះ ជាអ្នកដើរទៅតាមមគ្គ ជាអ្នកប្រកបក្នុងកាលខាងក្រោយ ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថាជាអ្នកនាំពួក យ៉ាងនេះក៏បាន ហេតុនោះ (លោកពោលថា) ព្រះសាស្តា ទ្រង់ធ្វើទីបំផុត នៃប្រស្នាទាំងឡាយ ។

[២២៥] កត្ថីនំ បដិជានន្តិ សកង្ខា អាគន្ត្វា និក្កង្ខា សម្បជ្ជន្តិ សលេខា អាគន្ត្វា និល្លេខា សម្បជ្ជន្តិ សទ្វេឡ្ហកា អាគន្ត្វា និទ្វេឡ្ហកា សម្បជ្ជន្តិ សវេចិកិច្ឆា អាគន្ត្វា និព្វេចិកិច្ឆា សម្បជ្ជន្តិ សរាគា អាគន្ត្វា វីតរាគា សម្បជ្ជន្តិ សទោសា អាគន្ត្វា វីតទោសា សម្បជ្ជន្តិ សមោហា អាគន្ត្វា វីតមោហា សម្បជ្ជន្តិ សក្កិលេសា អាគន្ត្វា និក្កិលេសា សម្បជ្ជន្តីតិ កត្ថីនំ បដិជានតំ ។ តេនាហ បិង្គិយត្ថេរោ

អជិនេវ អភិញ្ញាយ សព្វំ វេទិ បរោវរំ

បញ្ហានន្តករោ សត្ថា កត្ថីនំ បដិជានតន្តិ ។

[២២ថ] *ពាក្យថា ដល់ពួកជនអ្នកសង្ស័យ ដែលប្តេជ្ញា (ថាជាអ្នកអស់សង្ស័យ) អធិប្បាយថា ជនទាំងឡាយ ដែលមានសេចក្តីងឿងឆ្ងល់ មកសម្រេចថា ជាអ្នកមិនមានសេចក្តីងឿងឆ្ងល់ អ្នកដែលមានចិត្តរសេមរសាម មកសម្រេចថា ជាអ្នកមានចិត្តមិនរសេមរសាម អ្នកដែលមានចិត្តបែកជាពីរ មកសម្រេចថា ជាអ្នកមានចិត្តមិនបែកជាពីរ អ្នកដែលមានសេចក្តីស្ទាក់ស្ទើរ មកសម្រេចថា ជាអ្នកមិនមានសេចក្តីស្ទាក់ស្ទើរ អ្នកដែលមានរាគ: មកសម្រេចថា ជាអ្នកមិនមានរាគ: អ្នកដែលមានទោស: មកសម្រេចថា ជាអ្នកមិនមានទោស: អ្នកដែលមានមោហ: មកសម្រេចថា ជាអ្នកមិនមានមោហ: អ្នកដែលមានកិលេស មកសម្រេចថា ជាអ្នកមិនមានកិលេស ហេតុនោះ (លោកពោលថា) ដល់ពួកជនអ្នកសង្ស័យ ដែលប្តេជ្ញា (ថាជាអ្នកអស់សង្ស័យ) ។ ហេតុនោះ ព្រះបិङ្គិយត្តេរពោលថា*

ព្រះសាស្តា ទ្រង់ជ្រាបច្បាស់នូវអធិទេវតាទាំងឡាយ ទ្រង់ជ្រាបនូវធម្មជាត ទាំងអស់ ដែលថោកទាបនិងប្រសើរ ទ្រង់ធ្វើទីបំផុត នៃប្រស្នាទាំងឡាយ ដល់ពួកជនអ្នកសង្ស័យ ដែលប្តេជ្ញា (ថាជាអ្នកអស់សង្ស័យ) ។

[២២៦] អសំហិរំ អសង្ក្ដុប្បំ យស្ស ន ត្ថិ ឧបមា ក្វចិ
អជ្ជ តមិស្សាមិ ន មេត្ថ ការ្ជ
ឯវំ មំ ជានេហិ អនិមុត្តចិត្តំ ។

[២២៧] អសំហិរំ អសង្ក្ដុប្បន្តិ អសំហិរំ រុច្ចតិ អមតំ និព្ជានំ យោ សោ សព្ជសង្ខ្ជារសមថោ ស-ព្ជុបធិប្ជដិនិស្ស្ជគ្គោ តណ្ហាក្ខ្ជយោ វិរ្ជាគោ និរ្ជោធោ និព្ជានំ ។ អសំហិរន្តិ ភ្ជគ្ជេន ទ្ជោសេន មោហេន ក្ជោធេន ឧបនាហេន មក្ខ្ជេន បឬ្ជាសេន ឥស្ស្ជាយ មច្ជ្ជរិយេន មាយ្ជាយ សាឋេយ្ជ្ជេន ថម្ភេន សារម្ភេន មានេន អតិមានេន មទេន បមាទេន សព្ជក្ជិលេសេ-ហិ សព្ជទុច្ជ្ជរិតេហិ សព្ជបរិឬ្ជាហេហិ[1] សព្ជសន្ត-ាបេហិ សព្ជាកុសលាភិសង្ខ្ជារេហិ អសំហ្ជារិយំ[2] និច្ជ្ជំ ធ្ជុវំ សស្ស្ជតំ អ្ជវិបរិណ្ជាមធ្ជម្ជន្តិ អសំហិរំ ។

---

១ ម. ឯត្ថន្តរេ សព្ជាសវេហិ សព្ជទ្ជរថេហ្ជីតិ ទិស្ស្ជតិ ។ ២ ម. និព្ជានំ ។

[២២៦] ទីណា ដែលកិលេសនាំទៅមិនបាន ដែលមិនកម្រើក មួយទៀត ទីណា ដែលមិនមានឧបមាក្នុងហានណាមួយ ខ្ញុំនឹងទៅកាន់ទីនោះដោយពិត ខ្ញុំមិនមានសេចក្តីងឿងឆ្ងល់ក្នុងទីនោះទេ សូមព្រះអង្គចាំទុក នូវខ្ញុំព្រះអង្គ ថាជាអ្នកមានចិត្តចុះស៊ប់ហើយ យ៉ាងនេះចុះ ។

[២២៧] ពាក្យថា ទីណា ដែលកិលេសនាំទៅមិនបាន ដែលមិនកម្រើក អធិប្បាយថា អមតនិព្វាន ហៅថា ទីដែលកិលេសនាំទៅមិនបាន បានដល់ការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកវាគៈ សេចក្តីរលត់ទុក្ខ និព្វាន ។ ត្រង់ពាក្យថា ដែលកិលេសនាំទៅមិនបាន គឺ ដែលរាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួង នាំទៅមិនបាន គឺថាជាទីទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតា ហេតុនោះ (លោកពោលថា) ដែលកិលេសនាំទៅមិនបាន ។

អសង្ខ្យុប្ផន្តិ អសង្ខ្យុប្ផं វុច្ចតិ អមតं និព្ពានं យោ សោ សព្ពសង្ខារសមថោ សព្ពុបធិប្ផដិនិស្ស្ស្ គ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្ពានं ។ យស្ស ឧប្ផាទោ[១] បញ្ញាយតិ វយោ ជត្តិ តស្ស អញ្ញ-ជត្ត[២] បញ្ញាយតិ និព្ពានं និច្ចं ធុវं សស្សតं អវិបរិណាមធម្មន្តិ អសំហារិ អសង្ខ្យុប្ផं ។

[២២៨] យស្ស ជត្តិ ឧបមា ក្ខ្ចីតិ យស្ស្ គ្ គ្ គ្ តិ និព្ពានស្ស ។ ជត្តិ ឧបមាតិ ឧបមា ជត្តិ ឧបនិជា ជត្តិ សនិសं ជត្តិ បដិភាគោ ជត្តិ ន សំវិជ្ជតិ ឧប-លព្ភតីតិ ជត្តិ ឧបមា ។ ក្ខ្ចីតិ ក្ខ្ចិ កិម្ហិចិ ក្ត-ចិ អជ្ឌត្តং វ ពហិទ្ធា វ អជ្ឌត្តពហិទ្ធា វ យស្ស ជត្តិ ឧបមា ក្ខ្ចិ ។

---

១ ម. និព្ពានស្ស ន ឧប្ផាទោ ។ ២ ម. អញ្ញថត្តं ។

ត្រង់ពាក្យថា មិនកម្រើក សេចក្តីថា អមតនិព្វាន ហៅថា ទីមិនកម្រើក បានដល់ ការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកវាគៈ សេចក្តីរលត់ និព្វាន ។ ការកើតឡើងនៃធម្មជាតណា ប្រាកដ ការវិនាសនៃធម្មជាតណា មិនមាន ការពិតនៃធម្មជាតនោះ ក៏រមែងប្រាកដ គឺថា ព្រះនិព្វាន ទៀង ជាធម្មជាតទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតា ហេតុនោះ (លោកពោលថា) ទីណា ដែលកិលេសនាំទៅមិនបាន ដែលមិនកម្រើក ។

[២២៨] *អធិប្បាយ*ពាក្យថា ទីណាដែលមិនមានឧបមាក្នុងឋានណាមួយ ត្រង់ពាក្យថា ទីណា បានដល់និព្វាន ។ ពាក្យថា មិនមានឧបមា គឺ មិនមានសេចក្តីប្រៀបផ្ទឹម មិនមានការប្រៀបធៀប មិនមានភាពស្មើគ្នា មិនមាន មិនមានព្រម មិនបាននូវចំណែកប្រៀប ហេតុនោះ (លោកពោលថា) មិនមានឧបមា ។ ពាក្យថា ក្នុងឋានណាមួយ គឺ ក្នុងទីណាមួយ ក្នុងទីដូចម្តេច ក្នុងទីណា ជាខាងក្នុងឬខាងក្រៅ ឬទាំងខាងក្នុងទាំងខាងក្រៅ ហេតុនោះ (លោកពោលថា) ទីណា ដែលមិនមានឧបមាក្នុងឋានណាមួយ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

[២២៩] អទ្ធា គមិស្សាមិ ន មេត្ថ ការ្ហាតិ អទ្ធា គមិស្សាមីតិ អទ្ធា គមិស្សាមិ អធិគមិស្សាមិ ផុសយិស្សាមិ សច្ឆិការិស្សាមីតិ អទ្ធា គមិស្សាមិ[(១)] ។ ន មេត្ថ ការ្ហាតិ ឯត្ថ ឥញ្ជានេ ការ្ហា ន ត្ថិ វិចិកិច្ឆា ន ត្ថិ ទ្វេជ្ឈកំ ន ត្ថិ សំសយោ ន ត្ថិ ន សំវិជ្ជតិ ឧបលព្ភតិ បហីនោ សមុច្ឆិន្នោ វូបសន្តោ បដិប្ប-ស្សទ្ធោ អភព្ពុប្បត្តិកោ ញាណាគ្គិនា ឌឌ្ឍោតិ អទ្ធា គមិស្សាមិ ន មេត្ថ ការ្ហា ។

---

១ ម. អទ្ធាតិ ឯកំសវចនំ និស្សំសយវចនំ និក្កង្ខវចនំ អទ្វេជ្ឈវចនំ អទ្វេទ្ធាកវចនំ និយោគ-វចនំ អបណ្ណកវចនំ អវិរុទ្ធវចនំ អវត្ថាបនវចនមេតំ អទ្ធាតិ គមិស្សាមីតិ គមិស្សាមិ អធិគមិស្សាមិ បស្សយិស្សាមិ សច្ឆិការិស្សាមីតិ អទ្ធា គមិស្សាមិ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេស

[២២៩] *អធិប្បាយពាក្យថា ខ្ញុំនឹងទៅកាន់ទីនោះដោយពិត ខ្ញុំមិនមានសេចក្តីជឿងធ្ងល់ក្នុងទីនោះទេ ត្រង់ពាក្យថា ខ្ញុំនឹងទៅដោយពិត គឺ ខ្ញុំនឹងដើរទៅ នឹងបាន នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់ដោយពិត ហេតុនោះ (លោកពោលថា) ខ្ញុំនឹងទៅដោយពិត ។ ពាក្យថា ខ្ញុំមិនមានសេចក្តីជឿងធ្ងល់ក្នុងទីនោះទេ គឺសេចក្តីជឿងធ្ងល់មិនមាន ការស្នាក់ស្ទើរមិនមាន ការគិតបែកជាពីរមិនមាន ការសង្ស័យ មិនមាន មិនមានព្រម មិនកើតមានក្នុងនិព្វានៃ នោះទេ គឺថា ខ្ញុំលះបង់ ផ្តាច់ផ្តិល រម្ងាប់ ត្រូបសង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ(លោកពោលថា) ខ្ញុំនឹងទៅកាន់ទីនោះដោយពិត ខ្ញុំមិនមានសេចក្តីជឿងធ្ងល់ក្នុងទីនោះទេ ។*

[២៣០] ឯវํ មํ ជានេហិ អធិមុត្តចិត្តន្តិ ឯវํ មํ ជានេហីតិ ឯវํ មํ ឧបលក្ខេហិ ។ អធិមុត្តចិត្តន្តិ និញ្ជានជិដ្ឋํ និញ្ជានចោណํ និញ្ជានបញ្ហារํ និញ្ជានាធិ-មុត្តន្តិ ឯវํ មํ ជានេហិ អធិមុត្តចិត្តํ ។ តេនាហ បិដ្ឋិយត្ថេរោ

អសំហិរํ អសង្ខុប្ប យស្ស ជត្តុ ឧបមា ក្វចិ
អជ្ជា តមិស្សាមិ ន មេត្ត ការ្ជ
ឯវํ មํ ជានេហិ អធិមុត្តចិត្តន្តិ ។

បារាយនវគ្គោ និដ្ឋិតោ ។

[២៣០] *ពាក្យថា សូមព្រះអង្គចាំទុក នូវខ្ញុំព្រះអង្គ ថាជាអ្នកមានចិត្តចុះស៊ប់ហើយយ៉ាងនេះចុះ ត្រង់ពាក្យថា សូមព្រះអង្គចាំទុកនូវខ្ញុំព្រះអង្គយ៉ាងនេះ គឺ សូមព្រះអង្គកំណត់ទុក នូវខ្ញុំព្រះអង្គ យ៉ាងនេះ ។ ពាក្យថា មានចិត្តចុះស៊ប់ហើយ គឺ មានចិត្តទេរទៅរកព្រះនិព្វាន ទោរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ខ្ជិនទៅរកព្រះនិព្វាន ហេតុនោះ (លោកពោលថា) សូមព្រះអង្គចាំទុក នូវខ្ញុំព្រះអង្គ ថា ជាអ្នកមានចិត្តចុះស៊ប់ហើយ យ៉ាងនេះចុះ ។ ហេតុនោះ ព្រះបិង្គិយត្តេរពោលថា*

ទីណា ដែលកិលេសនាំទៅមិនបាន ដែលមិនកម្រើកមួយទៀត ទីណា ដែលមិនមានឧបមាក្នុងឋានណាមួយ ខ្ញុំនឹងទៅកាន់ទីនោះដោយពិត ខ្ញុំមិនមានសេចក្តីងឿងឆ្ងល់ក្នុងទីនោះទេ សូមព្រះអង្គចាំទុក នូវខ្ញុំព្រះអង្គ ថាជាអ្នកមានចិត្តចុះស៊ប់ហើយ យ៉ាងនេះចុះ ។

ចប់ បារាយនវគ្គ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

[២៣១] សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
អហេឋយំ[1] អញ្ញតរម្បិ តេសំ
ន បុត្តមិច្ឆេយ្យ កុតោ សហាយំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[២៣២] សព្វេសុ ភូតេសុ និធាយ ទណ្ឌន្តិ សព្វេសូតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ សព្វេសូតិ ។ ភូតេ-សូតិ ភូតា វុច្ចន្តិ តសា ច ថាវរា ច ។ តសាតិ យេសំ តណ្ហា[2] អប្ប្ហីនា យេសញ្ច ភយភេរវ អប្ប្ហីនា ។ ភីតការណា វុច្ចន្តិ តសា ។ តេ តសន្តិ ឧត្តសន្តិ បរិតសន្តិ សន្ធាសំ អាបជ្ជន្តិ តំការ-ណា វុច្ចន្តិ តសា ។ ថាវរាតិ យេសំ តណ្ហា ប្ប្ហីនា យេសញ្ច ភយភេរវ ប្ប្ហីនា ។ ភីតការណា វុច្ចន្តិ ថាវរា ។ តេ ន តសន្តិ ន ឧត្តសន្តិ ន បរិតសន្តិ ន សន្ធាសំ អាបជ្ជន្តិ តំការណា វុច្ចន្តិ ថាវរា ។

---

១ ម. អវិហេឋយំ ។ ២ ម. យេសំ តសិតតណ្ហា ។

ខគ្គវិសាណសុត្តនិទ្ទេស

[២៣១] (ព្រះបច្ចេកពុទ្ធត្រាស់ថា) បុគ្គលទម្លាក់ចេញនូវអាជ្ញា ចំពោះពួកសត្វទាំងពួង មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ គេមិនចង់បានបុត្រទៅហើយ តើនឹងប្រាថ្នាសម្ងាញ់អំពីណាកើត បុគ្គលនោះតែងប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៣២] *អធិប្បាយពាក្យថា* បុគ្គលទម្លាក់ចេញនូវអាជ្ញាចំពោះពួកសត្វទាំងពួង ត្រង់ពាក្យថា ទាំងពួង គឺ គ្រប់ទាំងអស់ សព្វទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ទាំងពួង នុ៎ះ ជាពាក្យពោលរួម ។ ពាក្យថា ពួកសត្វ សេចក្តីថា ពួកសត្វតក់ស្ទុត និងពួកសត្វនឹងនួន ហៅថា ពួកសត្វ ។ ពាក្យថា ពួកសត្វតក់ស្ទុត បានខាងពួកសត្វ មិនទាន់លះបង់តណ្ហា និងពួកសត្វ មិនទាន់លះបង់ភ័យដែលគួរខ្លាច ។ ដែលលោកពោលថា ពួកសត្វតក់ស្ទុត តើព្រោះហេតុដូចម្តេច ។ សត្វទាំងនោះ រមែងតក់ស្ទុត ញ័រចំប្រប់ ញាប់ញ័រ ដល់នូវសេចក្តីតក់ស្ទុត ព្រោះហេតុនោះ លោកពោលថា ពួកសត្វតក់ស្ទុត ។ ពាក្យថា ពួកសត្វនឹងនួន បានខាងពួកសត្វ លះបង់តណ្ហាហើយ និងពួកសត្វលះបង់ភ័យដែលគួរខ្លាច ។ ដែលលោកពោលថា ពួកសត្វនឹងនួន តើព្រោះហេតុ ដូចម្តេច ។ សត្វទាំងនោះមិនតក់ស្ទុត មិនញ័រចំប្រប់ មិនញាប់ញ័រ មិនដល់នូវសេចក្តីតក់ស្ទុត ព្រោះហេតុនោះ លោកពោលថា ពួកសត្វនឹងនួន ។

ឧណ្ហាតិ តយោ ឧណ្ហា កាយឧណ្ហោ ច វចីឧណ្ហោ ច មនោឧណ្ហោ ច ។ តិវិធំ កាយទុច្ចរិតំ កាយ-ឧណ្ហោ ចតុព្វិធំ វចីទុច្ចរិតំ វចីឧណ្ហោ តិវិធំ មនោទុច្ចរិតំ មនោឧណ្ហោ ។ សព្វេសុ ភូតេសុ និធាយ ឧណ្ហន្តិ សព្វេសុ ភូតេសុ ឧណ្ហំ និធាយ និឧហិត្វា ហេហេបយិត្វា[1] និក្ខិបិត្វា បដិប្ឋស្ឆម្ភិត្វាតិ សព្វេសុ ភូតេសុ និធាយ ឧណ្ហំ ។

[២៣៣] អហេបយំ អញ្ញតរម្ឫ តេសន្តិ ឯក-មត្តម្ឫ[2] សត្តំ ចាណិនា វ លេឌ្ឌុនា វ ឧណ្ហោ-ន វ សត្ថេន វ អុយ្យា[3] វ រជ្ជុយា វ អវិ-ហេបយន្តោ សព្វេបិ សត្ថ ចាណិនា វ លេឌ្ឌុនា វ ឧណ្ហេន វ សត្ថេន វ អុយ្យា វ រជ្ជុយា វ អវិហេបយន្តោតិ អហេបយំ អញ្ញតរម្ឫ តេសំ ។

---

១ ម. ឱរោបយិត្វា សមោរោចយិត្វា ។ ២ ម. ឯកមេកម្ឫ ។ ៣ ម. អទ្ទុយ្យា ។

ពាក្យថា អាជ្ញា បានដល់អាជ្ញា ៣ គឺ អាជ្ញាគឺកាយ ១ អាជ្ញាគឺវាចា ១ អាជ្ញាគឺចិត្ត ១ ។ កាយទុច្ចរិត ៣ ឈ្មោះថាអាជ្ញាគឺកាយ វចីទុច្ចរិត ៤ ឈ្មោះថាអាជ្ញាគឺវាចា មនោទុច្ចរិត ៣ ឈ្មោះថាអាជ្ញាគឺចិត្ត ។ ពាក្យថា បុគ្គលទម្លាក់ចេញ នូវអាជ្ញា ចំពោះពួកសត្វទាំងពួង បានន័យថា បុគ្គលទម្លាក់ចេញ ដាក់ចេញ បោះបង់ រលាស់ចោល រម្ងាប់ នូវអាជ្ញា ចំពោះពួកសត្វទាំងពួង ហេតុនោះ (លោកពោលថា) បុគ្គលទម្លាក់ចេញនូវអាជ្ញា ចំពោះពួកសត្វទាំងពួង ។

[២៣៣] ត្រង់ពាក្យថា មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ គឺ មិនបៀតបៀននូវសត្វសូម្បីតែមួយ ដោយដៃក្តី ដោយដុំដីក្តី ដោយដំបងក្តី ដោយសស្ត្រាក្តី ដោយពួរក្តី ដោយខ្សែក្តី មិនបៀតបៀននូវពួកសត្វទាំងអស់ ដោយដៃក្តី ដោយដុំដីក្តី ដោយដំបងក្តី ដោយសស្ត្រាក្តី ដោយពួរក្តី ដោយខ្សែក្តី ហេតុនោះ (លោកពោលថា) មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

[២៣៤] ន បុត្តមិច្ឆេយ្យ ការោ សហាយន្តិ ជាតិ បដិក្ខេបោ ។ បុត្តាតិ ចត្តារោ បុត្តា អត្តជោ បុត្តោ ខេត្តជោ បុត្តោ ធិន្នការោ បុត្តោ អន្តេវាសិ-ការោ បុត្តោ ។ សហាយន្តិ[១] សហាយា រុច្ចន្តិ យេហិ សហ ការមនំ ជាសុ អាការមនំ ជាសុ ការ-ជាការមនំ ជាសុ និសជ្ជនំ ជាសុ និបជ្ជនំ ជាសុ អាលបនំ ជាសុ សល្លបនំ ជាសុ សមុល្លបនំ ជាសុ ។ ន បុត្តមិច្ឆេយ្យ ការោ សហាយន្តិ បុត្ត-ម្បិ ន ឥច្ឆេយ្យ ន សាធិយេយ្យ[២] ន បិហាយេ-យ្យ ជាភិជប្បេយ្យ ការោ មិត្តំ វា សន្ធិដ្ឋំ វា សម្ភត្តំ វា សហាយំ វា ឥច្ឆិស្សតិ សាធិយិស្សតិ បិហាយិស្សតិ អភិជប្បិស្សតីតិ[៣] ន បុត្តមិច្ឆេយ្យ ការោ សហាយំ ។

---

១ ម. សហាយន្តិ នត្ថិ ។ ២ ម. ន សាទិយេយ្យ ន បត្ថយេយ្យ ។ ៣ ម. ឥច្ឆេយ្យ សាទិយេយ្យ បត្ថយេយ្យ បិហាយេយ្យ អភិជប្បេយ្យាតិ ។

ខគ្គវិសាណសុត្តនិទ្ទេស

[២៣២] *អធិប្បាយពាក្យថា មិនចង់បានបុត្រទៅហើយ តើនឹងប្រាថ្នាសម្ងាញ់អំពីណាកើត ត្រង់ពាក្យថា មិន គឺជាពាក្យបដិសេធ ។ ពាក្យថា បុត្រ បានដល់បុត្រ ៤ គឺ បុត្រកើតអំពីខ្លួន ១ បុត្រកើតអំពីខែត្រ ១ បុត្រដែលគេឲ្យ ១ បុត្រគឺសិស្ស ១ ។ ពាក្យថា សម្ងាញ់ សេចក្តីថា ការទៅសប្បាយ ការមកសប្បាយ ការទៅមកសប្បាយ ការអង្គុយសប្បាយ ការដេកសប្បាយ ការហៅរកសប្បាយ ការនិយាយសប្បាយ ការនិយាយធ្វើយធ្វងរកគ្នាសប្បាយ ជាមួយនឹងពួកជនណា ពួកជននោះ លោកហៅថា សម្ងាញ់ ។ ពាក្យថា មិនចង់បានបុត្រទៅហើយ តើនឹងប្រាថ្នាសម្ងាញ់អំពីណាកើត បានសេចក្តីថា មិនប្រាថ្នា មិនត្រេកអរ មិនស្រឡាញ់ មិនជាប់ចំពាក់ សូម្បីនូវបុត្រទៅហើយ តើនឹងប្រាថ្នា នឹងត្រេកអរ នឹងស្រឡាញ់ នឹងជាប់ចំពាក់ ចំពោះមិត្តក្តី ចំពោះជនដែលធ្លាប់ឃើញគ្នាក្តី ចំពោះមិត្រធ្លាប់បរិភោគរួមគ្នាក្តី ចំពោះសម្ងាញ់ក្តី អំពីណាកើត ហេតុនោះ (លោកពោលថា) មិនចង់បានបុត្រទៅហើយ តើនឹងប្រាថ្នាសម្ងាញ់អំពីណាកើត ។*

[២៣៥] ឯកោ ចរេ ខគ្គវិសាណកប្បោតិ ឯកោតិ សោ បច្ចេកសម្ពុទ្ធោ បញ្ញាសង្ខ្យាតេន ឯកោ អទុតិយដ្ឋេន ឯកោ តណ្ហាបហានដ្ឋេន ឯកោ ឯកន្តវីតរាគោតិ ឯកោ ឯកន្តវីតទោសោតិ ឯកោ ឯកន្តវីតមោហោតិ ឯកោ ឯកន្តនិក្កិលេ-សោតិ ឯកោ ឯកាយនមគ្គំ គតោតិ ឯកោ ឯកោ អនុត្តរំ បច្ចេកសម្ពោធឹ អភិសម្ពុទ្ធោតិ ឯកោ ។

កថំ សោ បច្ចេកសម្ពុទ្ធោ បញ្ញាសង្ខ្យាតេន ឯកោ ។ សោ បច្ចេកសម្ពុទ្ធោ ឃរាវាសបលិពោ-ធំ[1] ឆិន្ទិត្វា បុត្តទារបលិពោធំ ឆិន្ទិត្វា ញាតិបលិ-ពោធំ ឆិន្ទិត្វា សន្និធិបលិពោធំ ឆិន្ទិត្វា កេសមស្សុ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អការ-ស្មា អនការិយំ បព្វជិត្វា អកិញ្ចនភាវំ ឧបគន្ត្វា ឯកោ ចរតិ វិចរតិ ឥរិយតិ វត្តេតិ ចាលេតិ យបេតិ យាបេតីតិ ឯវំ សោ បច្ចេកសម្ពុទ្ធោ បញ្ញាសង្ខ្យាតេន ឯកោ ។

---

១ ម. សព្វឃរាវាសបលិពោធំ ។

[២៣៥] *អធិប្បាយពាក្យថា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ត្រង់ពាក្យថា ម្នាក់ឯង គឺ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថាមិនមានបុគ្គលជាគម្រប់ពីរ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថាលះបង់តណ្ហា ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកទោសៈដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកមោហៈដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុមិនមានកិលេសដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់ផ្លូវជាទីទៅតែម្នាក់ឯង ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹងនូវបច្ចេកសម្ពោធិដ៏ប្រសើរ តែម្នាក់ឯង ។*

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ ទ្រង់កាត់បលិពោធក្នុងឃរាវាស កាត់បលិពោធ ក្នុងបុត្តនិងកវិយា កាត់បលិពោធក្នុងញាតិ កាត់បលិពោធក្នុងការសន្សំ ការសក់ពុកមាត់និងពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ដល់នូវភាពមិនមានកង្វល់ ជាបុគ្គលម្នាក់ឯង ចរទៅ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា យ៉ាងនេះ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

កថំ សោ បច្ចេកសម្ពុទ្ធោ អនុតិយដ្ឋេន ឯកោ ។ សោ ឯវំ បញ្ញត្តោ សមានោ ឯកោ អរញ្ញវនបត្ថានិ បន្ថានិ សេនាសនានិ បដិសេវតិ អប្ប សទ្ទានិ អប្ប និគ្ឃោ សានិ វិជនវាតានិ មនុស្ស-រាហាសេយ្យកានិ បដិ សល្លានសារុប្បានិ សោ ឯកោ គច្ឆតិ ឯកោ តិដ្ឋតិ ឯកោ និសីទតិ ឯកោ សេយ្យំ កប្បេតិ ឯកោ គាមំ បិណ្ឌាយ បវិសតិ ឯកោ បដិ ក្កមតិ ឯកោ រហោ និសីទតិ ឯកោ ចង្កមំ អធិ ដ្ឋាតិ ឯកោ ចរតិ វិចរតិ ឥរិ យតិ រត្តេតិ ចាលេតិ យបេតិ យាបេតីតិ ឯវំ សោ បច្ចេកសម្ពុទ្ធោ អនុតិយដ្ឋេន ឯកោ ។

កថំ សោ បច្ចេកសម្ពុទ្ធោ តណ្ហាបហានដ្ឋេន ឯកោ ។ សោ ឯវំ ឯកោ អនុតិយោ អប្ប មត្តោ អាតាបី បហិ តត្តោ វិហ រន្តោ មហាបធានំ បធ ហន្តោ មារ ំ ससेनं ជ មុ ចឺ បមត្ត ពន្ធុ ំ វិ ធ មិ ត្វា តណ្ហា ជាលិ ឌ ំ សរិ ត ំ វិ សត្ត ិ ក ំ ប ជ ហិ វិ ធោ ធ េ ស ិ ព ្យ ន្ត ីម-ការ ិ អ ន ការ ជ ្ជ ម េ ស ិ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថាមិនមានបុគ្គលជាគម្រប់ពីរ តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ កាលបួសយ៉ាងនេះហើយ ជាបុគ្គលម្នាក់ឯង គប់រកសេនាសនៈ ដ៏ស្ងាត់ គឺព្រៃរបោះ និងព្រៃញៀតស្ងាត ជាទីមិនមានសំឡេង មិនមានសំឡេងគឹកកង ប្រាសចាកខ្យល់ដែលកើតអំពីសរីរៈមនុស្ស ជាទីស្ងាត់កំចាំងរបស់មនុស្ស សមគួរដល់ទីពួនសម្ងំ លោកដើរទៅម្នាក់ឯង ឈរនៅម្នាក់ឯង អង្គុយម្នាក់ឯង សម្រេចសេយ្យាម្នាក់ឯង ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង អង្គុយក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានចង្ក្រមម្នាក់ឯង ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅតែម្នាក់ឯង ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាជាបុគ្គលម្នាក់ឯង ព្រោះអត្ថថាមិនមានបុគ្គលជាគម្រប់ពីរ យ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថាលះបង់តណ្ហា តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ឥតមានបុគ្គលជាគម្រប់ពីរយ៉ាងនេះហើយ ជាអ្នកមិនប្រហែស មានព្យាយាមដុតកម្ចៅកិលេស មានចិត្តស្ទុង (ទៅកាន់ព្រះនិព្វាន) ផ្គងព្យាយាមធំ កម្ចាត់បង់មារព្រមទាំងសេនានៃមារ ដែលមិនដោះលែង ជាផៅពង្សនៃបុគ្គលប្រហែស គឺថា លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ញ៉ាំងតណ្ហាដូចជាបណ្តាញ ដែលហូរទៅ ផ្សាយទៅ ឲ្យដល់នូវការមិនកើតមាន ។

តណ្ហាឧតិយោ បុរិសោ ឧីឃមទ្ធាន សំសរំ
ឥត្ថភាវញ្ញថាភាវំ សំសារំ ជាតិវត្តតិ
ឯវមាឧីនវំ ញត្វា តណ្ហំ ឧុក្ខស្ស សម្ភវំ
វីតតណ្ហោ អនាទានោ សតោ ភិក្ខុ បរិព្ជេតិ ។

ឯវំ សោ បចេ្ចកសម្ពុទ្ធោ តណ្ហាបហានដ្ឋេន ឯកោ ។

ឯកំ សោ បចេ្ចកសម្ពុទ្ធោ ឯកន្តវីតរាគោតិ ឯកោ ។ រាគស្ស បហីនត្តា ឯកន្តវីតរាគោតិ ឯកោ ។ ឧោសស្ស បហីនត្តា ឯកន្តវីតឧោសោតិ ឯកោ ។ មោហស្ស បហីនត្តា ឯកន្តវីតមោហោតិ ឯកោ ។ កិលេសានំ បហីនត្តា ឯកន្តនិក្ខិលេ-សោតិ ឯកោ ។ ឯវំ សោ បចេ្ចកសម្ពុទ្ធោ ឯកន្តវីតរាគោតិ ឯកោ ។

បុរសមានតណ្ហាជាគម្រប់ពីរ កាលអន្ទោលទៅអស់កាលដ៏វែង រមែងមិនកន្ទ្ធងផុតសង្សារ មានភាពបែបនេះ និងភាពដទៃ ភិក្ខុអ្នកមានសតិ ប្រាសចាកតណ្ហា មិនមានសេចក្ដីប្រកាន់ លុះឃើញទោសយ៉ាងនេះហើយ គួរវៀរនូវតណ្ហា ជាដែនកើតទុក្ខចេញ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថាលះបង់តណ្ហាយ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាត តើដូចម្ដេច ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាត ព្រោះលោកលះរាគៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកទោសៈដោយដាច់ខាត ព្រោះលោកលះទោសៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកមោហៈដោយដាច់ខាត ព្រោះលោកលះមោហៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុមិនមានកិលេសដោយដាច់ខាត ព្រោះលោកលះកិលេសទាំងឡាយហើយ ។ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាត យ៉ាងនេះ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

កថំ សោ បច្ចេកសម្ពុទ្ធោ ឯកាយនមក្ខំ កតោតិ ឯកោ ។ ឯកាយនមក្ខោ វុច្ចន្តិ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិ-ចាតា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មក្ខោ ។

ឯកាយនំ ជាតិខយន្តទស្សី
មក្ខំ បជានាតិ ហិតានុកម្បី
ឯតេន មក្ខេន តរីសុ បុព្វេ
តរិស្សន្តិ ចេវ តរន្តិ ឱឃន្តិ ។

ឯវំ សោ បច្ចេកសម្ពុទ្ធោ ឯកាយនមក្ខំ កតោតិ ឯកោ ។

កថំ សោ បច្ចេកសម្ពុទ្ធោ ឯកោ អនុត្តរំ បច្ចេកសម្ពោធឹ អភិសម្ពុទ្ធោតិ ឯកោ ។ ពោធិ វុច្ចតិ ចតូសុ មក្ខេសុ ញាណំ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ធម្មវិចយសម្ពោជ្ឈង្គោ វីមំសា វិបស្សនា សម្មាទិដ្ឋិ ។

ខគ្គវិសាណសុត្តនិទ្ទេស

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់ផ្លូវជាទីទៅម្នាក់ឯង តើដូចម្តេច ។ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អរិយមគ្គប្រកបដោយអង្គ ៨ លោកហៅថា ផ្លូវជាទីទៅម្នាក់ឯង ។

បុគ្គលអ្នកឃើញទីបំផុតនៃកិរិយាអស់ជាតិ ជាអ្នកអនុគ្រោះនូវ
ប្រយោជន៍ រមែងដឹងច្បាស់នូវផ្លូវជាទីទៅម្នាក់ឯង ពួកអរិយ-
បុគ្គល បានធ្វើហើយក្នុងអតីតកាលក្តី នឹងធ្វើក្នុងអនាគត
ក្តី កំពុងធ្វើក្នុងបច្ចុប្បន្ននេះក្តី នូវឱឃៈ តាមផ្លូវនេះឯង ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់ផ្លូវជាទីទៅម្នាក់ឯង យ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹង នូវបច្ចេកសម្ពោធិដ៏ប្រសើរ តែម្នាក់ឯង តើដូចម្តេច ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ធម្មវិចយសម្ពោជ្ឈង្គ វីមំសា វិបស្សនា សម្មាទិដ្ថិ ក្នុងមគ្គទាំង ៤ លោកហៅថា ពោធិ ។

សោ បចេ្ចកសម្ពុទ្ធោ បចេ្ចកពុទ្ធញ្ញាណេន សច្ចានិ ពុជ្ឈិ សពេ្វ សង្ខារា អនិច្ចាតិ ពុជ្ឈិ សពេ្វ សង្ខារា ទុក្ខាតិ ពុជ្ឈិ សពេ្វ ធម្មា អនត្តាតិ ពុជ្ឈិ អវិជ្ជា-បចេ្ចយា សង្ខារាតិ ពុជ្ឈិ សង្ខារប្បចេ្ចយា វិញ្ញាណន្តិ ពុជ្ឈិ វិញ្ញាណប្បចេ្ចយា នាមរូបន្តិ ពុជ្ឈិ នាមរូប-ប្បចេ្ចយា សឬាយតនន្តិ ពុជ្ឈិ សឬាយតនប្បចេ្ចយា ផស្សោតិ ពុជ្ឈិ ផស្សប្បចេ្ចយា វេទនាតិ ពុជ្ឈិ វេទនាបចេ្ចយា តណ្ហាតិ ពុជ្ឈិ តណ្ហាបចេ្ចយា ឧចានន្តិ ពុជ្ឈិ ឧចានប្បចេ្ចយា ភវោតិ ពុជ្ឈិ ភវប្បចេ្ចយា ជាតីតិ ពុជ្ឈិ ជាតិប្បចេ្ចយា ជរាមរណន្តិ ពុជ្ឈិ អវិជ្ជានិរោធា សង្ខារនិរោធោតិ ពុជ្ឈិ

ព្រះបច្ចេកសម្ពុទ្ធនោះ ត្រាស់ដឹងហើយនូវសច្ចៈទាំងឡាយ ដោយបច្ចេក-ពុទ្ធញ្ញាណ ត្រាស់ដឹងហើយថា សង្ខារទាំងពួងមិនទៀង ត្រាស់ដឹងហើយថា សង្ខារទាំងពួងជាទុក្ខ ត្រាស់ដឹងហើយថា ធម៌ទាំងពួងជាអនត្តា ត្រាស់ដឹងហើយថា សង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ ត្រាស់ដឹងហើយថា វិញ្ញាណ (កើតមាន) ព្រោះសង្ខារជាបច្ច័យ ត្រាស់ដឹងហើយថា នាមនិងរូប (កើតមាន) ព្រោះវិញ្ញាណជាបច្ច័យ ត្រាស់ដឹងហើយថា អាយតនៈ ៦ (កើតមាន) ព្រោះនាមរូបជាបច្ច័យ ត្រាស់ដឹងហើយថា ផស្សៈ (កើតមាន) ព្រោះអាយតនៈ ៦ ជាបច្ច័យ ត្រាស់ដឹងហើយថា វេទនា (កើតមាន) ព្រោះផស្សៈជាបច្ច័យ ត្រាស់ដឹងហើយថា តណ្ហា (កើតមាន) ព្រោះវេទនាជាបច្ច័យ ត្រាស់ដឹងហើយថា ឧបាទាន (កើតមាន) ព្រោះតណ្ហាជាបច្ច័យ ត្រាស់ដឹងហើយថា ភព (កើតមាន) ព្រោះឧបាទានជាបច្ច័យ ត្រាស់ដឹងហើយថា ជាតិ (កើតមាន) ព្រោះភពជាបច្ច័យ ត្រាស់ដឹងហើយថា ជរានិងមរណៈ (កើតមាន) ព្រោះជាតិជាបច្ច័យ ត្រាស់ដឹងហើយថា ការរលត់សង្ខារ ព្រោះការរលត់ទៅ នៃអវិជ្ជា

ខគ្គវិសាណសុត្តនិទ្ទេសោ

សង្ខារនិរោធា វិញ្ញាណនិរោធោតិ ពុជ្ឈ៎ិ វិញ្ញាណនិ-
រោធា នាមរូបនិរោធោតិ ពុជ្ឈ៎ិ នាមរូបនិរោធា សឬ្ឬ-
យតននិរោធោតិ ពុជ្ឈ៎ិ សឬ្ឬយតននិរោធា ផស្ឬនិ-
រោធោតិ ពុជ្ឈ៎ិ ផស្ឬនិរោធា វេទនានិរោធោតិ ពុជ្ឈ៎ិ
វេទនានិរោធា តណ្ហានិរោធោតិ ពុជ្ឈ៎ិ តណ្ហានិរោធា
ឧចាទាននិរោធោតិ ពុជ្ឈ៎ិ ឧចាទាននិរោធា ភវនិរោ-
ធោតិ ពុជ្ឈ៎ិ ភវនិរោធា ជាតិនិរោធោតិ ពុជ្ឈ៎ិ
ជាតិនិរោធា ជរាមរណនិរោធោតិ ពុជ្ឈ៎ិ ឥទំ ទុក្ខន្តិ
ពុជ្ឈ៎ិ អយំ ទុក្ខសមុទយោតិ ពុជ្ឈ៎ិ អយំ ទុក្ខនិ-
រោធោតិ ពុជ្ឈ៎ិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ
ពុជ្ឈ៎ិ ឥមេ អាសវាតិ ពុជ្ឈ៎ិ អយំ អាសវសមុទ-
យោតិ ពុជ្ឈ៎ិ អយំ អាសវនិរោធោតិ ពុជ្ឈ៎ិ អយំ
អាសវនិរោធគាមិនី បដិបទាតិ ពុជ្ឈ៎ិ ឥមេ ធម្មា
អភិញ្ញាតព្ពាតិ ពុជ្ឈ៎ិ ឥមេ ធម្មា បហាតព្ពាតិ ពុជ្ឈ៎ិ

ត្រាស់ដឹងហើយថា ការរលត់វិញ្ញាណ ព្រោះការរលត់សង្ខារ ត្រាស់ដឹងហើយថា ការរលត់នាមរូប ព្រោះការរលត់វិញ្ញាណ ត្រាស់ដឹងហើយថា ការរលត់អាយតនៈ ៦ ព្រោះការរលត់នាមនិងរូប ត្រាស់ដឹងហើយថា ការរលត់ផស្សៈ ព្រោះការរលត់អាយតនៈ ៦ ត្រាស់ដឹងហើយថា ការរលត់វេទនា ព្រោះការរលត់ផស្សៈ ត្រាស់ដឹងហើយថា ការរលត់តណ្ហាព្រោះការរលត់វេទនា ត្រាស់ដឹងហើយថា ការរលត់ឧបាទាន ព្រោះការរលត់តណ្ហា ត្រាស់ដឹងហើយថា ការរលត់ភព ព្រោះការរលត់ឧបាទាន ត្រាស់ដឹងហើយថា ការរលត់ជាតិ ព្រោះការរលត់ភព ត្រាស់ដឹងហើយថា ការរលត់ជរាមរណៈ ព្រោះការរលត់ជាតិ ត្រាស់ដឹងហើយថា នេះទុក្ខ ត្រាស់ដឹងហើយថា នេះការកើតទុក្ខ ត្រាស់ដឹងហើយថា នេះការរលត់ទុក្ខ ត្រាស់ដឹងហើយថា នេះបដិបទាជាដំណើរទៅកាន់ការរលត់ទុក្ខ ត្រាស់ដឹងហើយថា ទាំងនេះអាសវៈ ត្រាស់ដឹងហើយថា នេះការកើតអាសវៈ ត្រាស់ដឹងហើយថា នេះការរលត់អាសវៈ ត្រាស់ដឹងហើយថា នេះបដិបទាជាដំណើរទៅកាន់ការរលត់អាសវៈ ត្រាស់ដឹងហើយថា ធម៌ទាំងនេះ គួរដឹងច្បាស់ ត្រាស់ដឹងហើយថា ធម៌ទាំងនេះគួរលះបង់

ឥមេ ជម្ម ភាវេតញ្ចាតិ ពុជ្ឈ ឆន្ទំ ជស្ឆាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អាទីនវញ្ច និស្ឆ្ឬណាញ្ច ពុជ្ឈ បញ្ចន្នំ ឧចាជានក្ខន្ធានំ សមុទយញ្ច អត្ថង្គមញ្ច អាទីនវញ្ច និស្ឆ្ឬណាញ្ច ពុជ្ឈ ចតុន្នំ មហាភូតានំ សមុទយញ្ច អត្ថង្គមញ្ច អាទីនវញ្ច និស្ឆ្ឬណាញ្ច ពុជ្ឈ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ពុជ្ឈ[1] យំ ពុជ្ឈិតព្ពំ អនុពុជ្ឈិតព្ពំ សម្ពុជ្ឈិតព្ពំ ផុសិតព្ពំ សច្ឆិកាតព្ពំ សព្វន្តំ តេន បច្ចេកពោធិញ្ញាណេន ពុជ្ឈ អនុពុជ្ឈ សម្ពុជ្ឈ ផុសេសិ សច្ឆាកាសីតិ ឯវំ សោ បច្ចេកសម្ពុទ្ធោ ឯកោ អនុត្តរំ បច្ចេកសម្ពោធិ អភិសម្ពុទ្ធោតិ ឯកោ ។

ចរេតិ អដ្ឋ ចរិយាយោ ឥរិយាបថចរិយា អាយតនចរិយា សតិចរិយា សមាធិចរិយា ញាណចរិយា មក្ខចរិយា បដិបត្តិចរិយា លោកត្ថចរិយា ។ ឥរិយាបថចរិយាតិ ចតូសុ ឥរិយាបថេសុ ។

---

១ ម. ឯត្ថន្តរេ អថវាតិ ទិស្សតិ ។

ត្រាស់ដឹងហើយថា ធម៌ទាំងនេះគួរចម្រើន ត្រាស់ដឹងហើយ នូវការកើតឡើងផង ការវិនាសផង ទោសផង ការរលាស់ចេញនូវផស្សាយតនៈ ៦ ផង ត្រាស់ដឹងហើយនូវការកើតឡើងផង ការវិនាសផង ទោសផង ការរលាស់ចេញនូវឧបាទានក្ខន្ធ ៥ ផង ត្រាស់ដឹងហើយ នូវការកើតឡើងផង ការវិនាសផង ទោសផង ការរលាស់ចេញនូវមហាភូតរូប ៤ ផង ត្រាស់ដឹងហើយថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្ម-ជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា គឺថា ត្រាស់ដឹង ត្រាស់ដឹងតាម ត្រាស់ដឹងឯង ប៉ះពាល់ ធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលត្រូវត្រាស់ដឹង ដែលត្រូវត្រាស់ដឹងតាម ដែលត្រូវត្រាស់ដឹងឯង ដែលត្រូវប៉ះពាល់ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ទាំងអស់ ដោយបច្ចេកពោធិញ្ញាណនោះ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹងនូវបច្ចេកសម្ពោធិដ៏ប្រសើរ ម្នាក់ឯង យ៉ាងនេះ ។

ពាក្យថា គប្បីប្រព្រឹត្ត បានដល់ការប្រព្រឹត្ត ៨ គឺ ការប្រព្រឹត្តឥរិយាបថ ១ ការប្រព្រឹត្តអាយតនៈ ១ ការប្រព្រឹត្តសតិ ១ ការប្រព្រឹត្តសមាធិ ១ ការប្រព្រឹត្តញាណ ១ ការប្រព្រឹត្តមគ្គ ១ ការប្រព្រឹត្តបដិបត្តិ ១ ការប្រព្រឹត្តជាប្រយោជន៍លោក ១ ។ ពាក្យថា ការប្រព្រឹត្តឥរិយាបថ បានដល់ ការប្រព្រឹត្ត ក្នុងឥរិយាបថ ៤ ។

អាយតនចរិយាតិ ឆសុ អជ្ឈត្តិកពាហិរេសុ អាយ-
តនេសុ ។ សតិចរិយាតិ ចតូសុ សតិប្បដ្ឋានេសុ ។
សមាធិចរិយាតិ ចតូសុ ឈានេសុ ។ ញាណចរិ-
យាតិ ចតូសុ អរិយសច្ចេសុ ។ មក្គចរិយាតិ ចតូសុ
មគ្គេសុ[1] ។ បដិបត្តិចរិយាតិ ចតូសុ សាមញ្ញផ-
លេសុ ។ លោកត្ថចរិយាតិ តថាគតេសុ អរហ-
ន្តេសុ សម្មាសម្ពុទ្ធេសុ បនេសតោ បច្ចេកសម្ពុទ្ធេសុ
បនេសតោ សាវកេសុ ។ ឥរិយាបថចរិយា ច
បណិធិសម្ប្បជ្ជានំ អាយតនចរិយា ច ឥន្ទ្រិយេសុ
ગુત្តទ្វារានំ សតិចរិយា ច អប្ប្រមាទវិហារីនំ សមា-
ធិចរិយា ច អធិចិត្តមនុយុត្តានំ ញាណចរិយា ច
ពុទ្ធិសម្ប្បជ្ជានំ មក្គចរិយា ច សម្ម្ទាបដិបជ្ជានំ បដិ-
បត្តិចរិយា ច អធិកតផលានំ លោកត្ថចរិយា ច
តថាគតានំ អរហន្តានំ សម្ម្ទាសម្ពុទ្ធានំ បនេសតោ
បច្ចេកសម្ពុទ្ធានំ បនេសតោ សាវកានំ ។

---

1 ម. អរិយមគ្គេសុ ។

ពាក្យថា ការប្រព្រឹត្តអាយតនៈ បានដល់ ការប្រព្រឹត្ត ក្នុងអាយតនៈ ៦ ទាំងខាងក្នុងទាំងខាងក្រៅ ។ ពាក្យថា ការប្រព្រឹត្តសតិ បានដល់ការប្រព្រឹត្ត ក្នុងសតិប្ឋាន ៤ ។ ពាក្យថា ការប្រព្រឹត្តសមាធិ បានដល់ការប្រព្រឹត្ត ក្នុងឈាន ៤ ។ ពាក្យថា ការប្រព្រឹត្តញាណ បានដល់ការប្រព្រឹត្តក្នុងអរិយសច្ច ៤ ។ ពាក្យថា ការប្រព្រឹត្តមគ្គ បានដល់ការប្រព្រឹត្តក្នុងមគ្គ ៤ ។ ពាក្យថា ការប្រព្រឹត្តប្រតិបត្តិ បានដល់ការប្រព្រឹត្ត ក្នុងសាមញ្ញផល ៤ ។ ពាក្យថា ការប្រព្រឹត្តជាប្រយោជន៍លោក បានដល់ការប្រព្រឹត្តមានក្នុងព្រះតថាគតទាំងឡាយ ជាអរហន្តសម្មាសម្ពុទ្ធ ក្នុងព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ដោយឯកទេស ក្នុងសាវ័កទាំងឡាយ ដោយឯកទេស ។ ការប្រព្រឹត្ត ឥរិយាបថ សម្រាប់ពួកបុគ្គលអ្នកបរិបូណ៌ដោយសេចក្តីកសាង ការប្រ-ព្រឹត្តអាយតនៈ សម្រាប់បុគ្គលអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ការប្រព្រឹត្តសតិ សម្រាប់ពួកបុគ្គលអ្នកមានកិរិយានៅ ដោយសេចក្តីមិនប្រហែស ការប្រព្រឹត្តសមាធិ សម្រាប់ពួកបុគ្គលអ្នកប្រកបរឿយ ៗ នូវអធិចិត្ត ការប្រព្រឹត្តញាណ សម្រាប់ពួកបុគ្គលអ្នកបរិបូណ៌ដោយបញ្ញា ការប្រព្រឹត្តមគ្គ សម្រាប់ពួកបុគ្គលអ្នកប្រតិបត្តិត្រូវ ការប្រព្រឹត្តបដិបត្តិ សម្រាប់ពួកបុគ្គលអ្នកសម្រេចផល ការប្រព្រឹត្តជាប្រយោជន៍ សម្រាប់ព្រះតថាគតទាំងឡាយ ជាអរហន្តសម្មាសម្ពុទ្ធ និងសម្រាប់ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ដោយឯកទេស សម្រាប់សាវ័កទាំងឡាយ ដោយឯកទេស ។

ឥមា អដ្ឋ ចរិយាយោ ។ អបរាបិ អដ្ឋ ចរិយាយោ អធិមុចូន្ដោ សទ្ធាយ ចរតិ បត្ដណ្ហាន្ដោ វីរិយេន ចរតិ ឧបដ្ឋបេន្ដោ សតិយា ចរតិ អវិក្ខេបំ ករោន្ដោ សមាធិនា ចរតិ បជានន្ដោ បញ្ញាយ ចរតិ វិជា-នន្ដោ វិញ្ញាណេន ចរតិ ឯវំ បដិបន្ដស្ស កុសលា ធម្មា អាយាបេន្ដីតិ អាយតនចរិយាយ ចរតិ ឯវំ បដិបន្ដោ វិសេសមធិគច្ឆតីតិ វិសេសចរិយាយ ចរតិ ឥមា អដ្ឋ ចរិយាយោ ។ អបរាបិ អដ្ឋ ចរិយាយោ ឧស្សន្ដចរិយា ច សម្មាទិដ្ឋិយា អភិនិរោបនចរិយា ច សម្មាសង្កប្បស្ស បរិត្ដមាចរិយា ច សម្មាវាចាយ សមុដ្ឋានចរិយា ច សម្មាកម្មន្ដស្ស ឱទានចរិយា ច សម្មាអាជីវស្ស បត្ដមាចរិយា ច សម្មាវាយាមស្ស ឧបដ្ឋានចរិយា ច សម្មាសតិយា អវិក្ខេបចរិយា ច សម្មាសមាធិស្ស ឥមា អដ្ឋ ចរិយាយោ ។

ខត្ដវិសាណកប្បោតិ យថា ខត្ដស្ស ជាម វិសា-ណំ ឯកំ ហោតិ អនុតិយំ ឯវមេវ សោ បច្ចេក-សម្ពុទ្ធោ តក្ដប្បោ ឥស្ស្ដិសោ ឥប្ស្ដិកាតោ ។

នេះការប្រព្រឹត្ត ៨ ។ ការប្រព្រឹត្ត ៨ ដោយឡែកទៀត គឺ បុគ្គលជឿប្រ-ព្រឹត្តដោយសទ្ធា ១ ប្រឹងប្រព្រឹត្តដោយវិរិយៈ ១ ប្រុងប្រព្រឹត្តដោយសតិ ១ ធ្វើសេចក្តីមិនរាយមាយ ប្រព្រឹត្តដោយសមាធិ ១ ដឹងច្បាស់ ប្រព្រឹត្តដោយ បញ្ញា ១ ដឹងវិសេស ប្រព្រឹត្តដោយវិញ្ញាណ ១ បុគ្គលប្រព្រឹត្តដោយការ ប្រព្រឹត្តអាយតនៈថា ពួកធម៌ជាកុសល របស់បុគ្គលអ្នកប្រតិបត្តិយ៉ាងនេះ រមែងប្រព្រឹត្តទៅ ១ បុគ្គលប្រព្រឹត្តដោយវិសេសចរិយាថា បុគ្គលប្រតិបត្តិ យ៉ាងនេះ រមែងបានទទួលគុណវិសេស ១ នេះការប្រព្រឹត្ត ៨ ។ ការ ប្រព្រឹត្ត ៨ ដោយឡែកទៀត គឺ ការប្រព្រឹត្តដោយការឃើញ របស់ សម្មាទិដ្ឋិ ១ ការប្រព្រឹត្តដោយការលើកចិត្ត របស់សម្មាសង្កប្ប: ១ ការ ប្រព្រឹត្តដោយការរក្សា របស់សម្មាវាចា ១ ការប្រព្រឹត្តដោយការតាំងឡើង របស់សម្មាកម្មន្ត: ១ ការប្រព្រឹត្តដោយការផ្ទរផង់ របស់សម្មាអាជីវ: ១ ការប្រព្រឹត្តដោយការផ្គង់ របស់សម្មាវាយាម: ១ ការប្រព្រឹត្តដោយការ ប្រុង របស់សម្មាសតិ ១ ការប្រព្រឹត្តដោយការមិនរាយមាយ របស់សម្ម-សមាធិ ១ នេះការប្រព្រឹត្ត ៨ ។

ពាក្យថា ដូចកុយរមាស គឺ កុយរមាសមានតែមួយ មិនមានពីរ យ៉ាងណា ព្រះបច្ចេកសម្ពុទ្ធនោះ ប្រហែលនឹងកុយរមាសនោះ ប្រាកដស្មើ ដោយកុយរមាសនោះ មានការប្រៀបដោយកុយរមាសនោះ យ៉ាងនោះ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

យថា អតិលោណំ រុច្ចតិ លោណកប្បោ អតិតិត្តិកំ រុច្ចតិ តិត្តិកប្បោ អតិមធុរំ រុច្ចតិ មធុកប្បោ អតិ-ឧណ្ហោ រុច្ចតិ អក្ខិកប្បោ អតិសីតលំ រុច្ចតិ ហិមក-ប្បោ មហាឧទកក្ខន្ធោ រុច្ចតិ សមុទ្ទកប្បោ មហា-ភិញ្ញាពលប្បត្តោ សាវកោ រុច្ចតិ សត្ថុកប្បោ ឯវំ សោ បច្ចេកសម្ពុទ្ធោ តក្ការប្បោ តស្សជិសោ តប្ប-ជ្ជាតោ ឯកោ អនុតិយោ មុត្តពន្ធោ សម្ម លោកេ ចរតិ វិចរតិ ឥរិយតិ វត្តេតិ ចាលេតិ យបេតិ យាបេ-តីតិ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
អហេឋយំ អញ្ញតរម្បិ តេសំ
ន បុត្តមិច្ឆេយ្យ កុតោ សហាយំ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

វត្ថុមានរសប្រៃក្រៃលែង អ្នកផងតែងនិយាយថាដូចអំបិល វត្ថុមានរសល្វីងក្រៃលែង អ្នកផងតែងនិយាយថាដូចម្រះ វត្ថុមានរសផ្អែមក្រៃលែង អ្នកផងតែងនិយាយថា ដូចទឹកឃ្មុំ កម្ពាន់ក្រៃលែង អ្នកផងតែងនិយាយថា ដូចភ្លើង វត្ថុត្រជាក់ក្រៃលែង អ្នកផងតែងនិយាយថា ដូចត្រីល (ឬ ទឹកកក) ជារនៃទឹកច្រើន អ្នកផងតែងនិយាយថា ដូចសមុទ្រ សាវ័កដែលដល់នូវកម្ទាំងអកិញ្ចាដ៏ច្រើន អ្នកផងតែងនិយាយថា ដូចព្រះសាស្តា យ៉ាងណាមិញ ព្រះបច្ចេកសម្ពុទ្ធនោះ ដូចកុយរមាសនោះ ប្រាកដស្មើដោយកុយរមាសនោះ មានការប្រៀបដោយកុយរមាសនោះ ជាបុគ្គលឯក មិនមានបុគ្គលជាគម្រប់ពីរ របូតចាកចំណងហើយ តែងចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ក្នុងលោកដោយប្រពៃ ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ លោកពោលថា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលទម្ទាក់ចេញនូវអាជ្ញា ចំពោះពួកសត្វទាំងពួង មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ គេមិនចង់បានបុត្តទៅហើយ តើនឹងប្រាថ្នាសម្ទាញ់អំពីណាកើត បុគ្គលនោះគប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៣៦] សំសគ្គជាតស្ស ភវន្តិ ស្នេហា
ស្នេហន្វយំ ទុក្ខមិទំ បហោតិ
អាទីនវំ ស្នេហជំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[២៣៧] សំសគ្គជាតស្ស ភវន្តិ ស្នេហាតិ សំសគ្គាតិ ទ្វេ សំសគ្គា ទស្សនសំសគ្គោ ច សវនសំសគ្គោ ច ។

កតមោ ទស្សនសំសគ្គោ ។ ឥធេកច្ចោ បស្សតិ ឥត្ថឹ វា កុមារឹ វា អភិរូបំ ទស្សនីយំ បាសាទិកំ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតំ ទិស្វា បស្សិត្វា អនុព្យញ្ជនសោ និមិត្តំ គណ្ហាតិ កេសា វា សោភណា មុខំ វា សោភណំ អក្ខិ វា សោភណំ កណ្ណា វា សោភណា នាសា វា សោភណា ឱដ្ឋំ វា សោភណំ ទន្តា វា សោភណា មុខំ វា សោភណំ គីវា វា សោភណា ថនា វា សោភណា ឧរំ វា សោភណំ ឧទរំ វា សោភណំ កដិ វា សោភណា ឩរុ វា សោភណា ជង្ឃា វា សោភណា

[២៣៦] *សេចក្តីស្នេហា របស់បុគ្គលអ្នកមានការជាប់ចំពាក់ រមែងមាន សេចក្តីទុក្ខនេះ មានឡើង ព្រោះអាស្រ័យ សេចក្តីស្នេហា បុគ្គលកាលសម្ងឹងឃើញទោសដែលកើត អំពីសេចក្តីស្នេហា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។*

[២៣៧] *អធិប្បាយពាក្យថា សេចក្តីស្នេហា របស់បុគ្គលអ្នកមាន ការជាប់ចំពាក់ រមែងមាន ត្រង់ពាក្យថា ការជាប់ចំពាក់ បានដល់ ការជាប់ចំពាក់ ២ គឺការជាប់ចំពាក់ដោយការឃើញ ១ ការជាប់ចំពាក់ ដោយការស្តាប់ ១ ។*

ការជាប់ចំពាក់ ដោយការឃើញ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ឃើញស្ត្រីឬកុមារី ដែលមានរូបល្អ គួរមិលមើល ជាទីជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង លុះមើលឃើញហើយ ក៏កាន់យកនិមិត្ត ដោយអនុព្យញ្ជនៈថា សក់ល្អ មុខល្អ ភ្នែកល្អ ត្រចៀកល្អ ច្រមុះល្អ បបូរមាត់ល្អ ធ្មេញល្អ មាត់ល្អ កល្អ ដោះល្អ ទ្រូងល្អ ពោះល្អ ចង្កេះល្អ ភ្លៅល្អ ជង្គង់ល្អ

ហត្ថា វា សោភណា អង្គុលិយោ វា សោភណា នខា វា សោភណាតិ ទិស្វា បស្សិត្វា អភិនន្ទតិ អភិវទតិ អភិបត្ថេតិ អនុប្បាទេតិ អនុពន្ធតិ រាគពន្ធនំ អយំ ទស្សនសំសគ្គោ ។

កតមោ សវនសំសគ្គោ ។ ឥធេកច្ចោ សុណាតិ អមុកស្មឹ គាមេ វា និគមេ វា ឥត្ថី វា កុមារី វា អភិរូបា ទស្សនីយា បាសាទិកា បរមាយ វណ្ណបោក្ខរតាយ សមន្នាគតាតិ សុត្វា សុណិត្វា អភិនន្ទតិ អភិវទតិ អភិបត្ថេតិ អនុប្បាទេតិ អនុពន្ធតិ រាគពន្ធនំ អយំ សវនសំសគ្គោ ។

ស្នេហាតិ ទ្វេ ស្នេហា តណ្ហាស្នេហោ ច ទិដ្ឋិ-ស្នេហោ ច ។

កតមោ តណ្ហាស្នេហោ ។ យាវតា តណ្ហាស-ង្ខាតេន សីមកតំ មរិយាទិកតំ ឱធិកតំ បរិយន្តិ-កតំ បរិគ្គហិតំ មមាយិតំ ឥទំ មមំ ឯតំ មមំ ឯត្តកំ មមំ ឯត្តាវតា មមំ មម រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា អត្ថរណា បាបុរណា ទាសីទាសា

ដៃល្អ ម្រាមដៃល្អ ក្រចកល្អ លុះមើលឃើញហើយ រមែងត្រេកអរ សរសើរ ប៉ុនប៉ង ក្រវៃលរក ជាប់តាម នូវចំណងគឺរាគ: នេះការជាប់ចំពាក់ដោយការឃើញ ។

ការជាប់ចំពាក់ដោយការឮ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ឮថា ស្ត្រីឬកុមារី ក្នុងស្រុកក្តី ក្នុងនិគមក្តី ឈ្មោះឯណោះ មានរូបល្អ គួររមិលមើល ជាទីជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង លុះស្តាប់ឮហើយ រមែងត្រេកអរ សរសើរ ប៉ុនប៉ង ក្រវៃលរក ជាប់តាម នូវចំណងគឺរាគ: នេះការជាប់ចំពាក់ដោយការឮ ។

ពាក្យថា សេចក្តីស្នេហា បានដល់សេចក្តីស្នេហា ២ គឺ តណ្ហា-ស្នេហា ១ ទិដ្ឋិស្នេហា ១ ។

តណ្ហាស្នេហា តើដូចម្តេច ។ អំពើដែលបុគ្គលធ្វើឲ្យមានដៃន ធ្វើឲ្យមានខាន់ ធ្វើឲ្យមានជួរ ធ្វើឲ្យមានទីបំផុត ហួងហែង ប្រកាន់ដោយចំណែកតណ្ហា ទាំងប៉ុន្មានថា នេះ របស់អញ ន៏ុ៎ះ របស់អញ វត្ថុប៉ុណ្ណោះរបស់អញ វត្ថុមានប្រមាណប៉ុណ្ណោះរបស់អញ រូប សំឡេង ក្លិន រស ផ្សព្វ កម្រាល ប្រដាប់ស្មៀកពាក់ ខ្ញុំស្រីប្រុស

អជេឡកា កុក្កុដសូករា ហត្ថិគវាស្សវឡវា ខេត្តំ វត្ថុ ហិរញ្ញំ សុវណ្ណំ គាមនិគមរាជធានិយោ រដ្ឋញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច កេវលម្បិ មហាបឋវឹ តណ្ហាវសេន មមាយតិ យាវតា អដ្ឋសត-តណ្ហាវិចរិតា អយំ តណ្ហាស្នេហោ ។

កតមោ ទិដ្ឋិស្នេហោ ។ វីសតិវត្ថុកា សក្កាយ-ទិដ្ឋិ ទសវត្ថុកា មិច្ឆាទិដ្ឋិ ទសវត្ថុកា អន្តគ្គាហិកា ទិដ្ឋិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិក-ន្តារោ[១] ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ គាហោ បដិគ្គាហោ អភិនិវេសោ បរាមាសោ កុម្ម-គ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសគ្គាហោ វិបរីតគ្គាហោ វិបល្លាសគ្គាហោ មិច្ឆាគាហោ អយា-ថាវកស្មឹ យាថាវកន្តិ គាហោ យាវតា ទ្វាសដ្ឋី ទិដ្ឋិគតានិ អយំ ទិដ្ឋិស្នេហោ ។

១ ម. ទិដ្ឋិកន្តារំ ។

ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះឈ្មោល សេះញី ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ ជង្រុក ឃ្វាំង របស់អញ ប្រកាន់ ទ្ធូវមហាប្រឹថពី សូម្បីទាំងអស់ ដោយ អំណាចតណ្ហា តណ្ហាវិបរីត ១០៨ ទាំងប៉ុន្មាន នេះតណ្ហាស្នេហា ។

ទិដ្ឋិស្នេហា តើដូចម្តេច ។ សក្កាយទិដ្ឋិមានវត្ថុ ២០ មិច្ឆាទិដ្ឋិ មាន វត្ថុ ១០ អន្តគ្គាហិកទិដ្ឋិ មានវត្ថុ ១០ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ការសាំញ៉ាំគឺទិដ្ឋិ ផ្លូវលំបាកគឺទិដ្ឋិ គ្រឿងចាក់ដោតគឺទិដ្ឋិ ការអន្ទះសាគឺទិដ្ឋិ គ្រឿងប្រកប ទុក្ខគឺទិដ្ឋិ សេចក្តីប្រកាន់ សេចក្តីប្រកាន់ខ្ជាប់ ការជាប់ចំពាក់ ការស្ទាប អង្អែល ផ្លូវអាក្រក់ ផ្លូវខុស សភាពខុស លទ្ធិដូចជាកំពង់ សេចក្តី ប្រកាន់ក្នុងការស្វែងរកខុស ការប្រកាន់ឃ្យៀងឃ្ងាត ការប្រកាន់ឃ្ងាង ការប្រកាន់ខុស ការប្រកាន់ថាពិតក្នុងវត្ថុមិនពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មាន នេះទិដ្ឋិស្នេហា ។

ខគ្គវិសាណសុត្តនិទ្ទេសោ

សំសក្តជាតស្ស ភវន្តិ ស្នេហាតិ វិបស្ស្ យ្ យ-
យា ច ឧស្ស្ យ្ ជនសវនសំសក្តប្ យ្ ចូ យ្ យា ច តណ្ហាស្នេ-
ហោ ច ទិដ្ឋិស្នេហោ ច ភវន្តិ ជាយន្តិ សញ្ជាយន្តិ
និព្ភ្ យ ត្តន្តិ អភិនិព្ភ្ យ ត្តន្តិ ចាតុភវន្តីតិ សំសក្តជាតស្ស ភ-
វន្តិ ស្នេហា ។

[២៣៨] ស្នេហន្ត្ យ យំ ទុក្ខមិទំ បហោតីតិ ស្នេ-
ហោតិ ទ្វេ ស្នេហា តណ្ហាស្នេហោ ច ទិដ្ឋិស្នេហោ
ច ។ បេ ។ អយំ តណ្ហាស្នេហោ ។ បេ ។ អយំ ទិដ្ឋិ-
ស្នេហោ ។ ទុក្ខមិទំ បហោតីតិ ឥធេកច្ចោ កា-
យេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា
ទុច្ចរិតំ ចរតិ ចាណាម្ យ ហានតិ អទិន្នម្ យ អាទិយតិ
សន្ធិម្ យ ធិន្ធតិ រិលោបម្ យ ហរតិ ឯកាគារិកម្ យ
ករោតិ បរិបន្ថេបិ តិដ្ឋតិ បរទារម្ យ គច្ឆតិ មុសាបិ
ភណតិ ។ តមេនំ ឥហេត្ថ រញ្ញោ ឧស្ស្ យ ន្តិ អយំ
ឧេវ ចោរោ អាកុចារី ឥមស្ស យំ ឥច្ឆសិ តំ
ឧណ្ហ្ យ បណោហីតិ ។ តមេនំ រាជា បរិភាសតិ ។

ខគ្គវិសាណសុត្តនិទ្ទេស

ពាក្យថា សេចក្តីស្នេហា របស់បុគ្គលអ្នកមានការជាប់ចំពាក់ រមែងមាន បានន័យថា តណ្ហាស្នេហាក្តី ទិដ្ឋិស្នេហាក្តី រមែងមានកើត កើតព្រម លូតលាស់ ចម្រើនឡើង កើតប្រាកដឡើង ព្រោះវិប្ផារៈជាបច្ច័យផង ព្រោះការជាប់ចំពាក់ដោយការមើលឃើញនិងការឮជាបច្ច័យផង ហេតុនោះ (លោកពោលថា) សេចក្តីស្នេហារបស់បុគ្គលអ្នកមានការជាប់ចំពាក់ រមែងមាន ។

[២៣៨] អធិប្បាយពាក្យថា សេចក្តីទុក្ខនេះ មានឡើងព្រោះអាស្រ័យសេចក្តីស្នេហា ត្រង់ពាក្យថា សេចក្តីស្នេហា បានដល់សេចក្តីស្នេហា ២ យ៉ាង គឺ តណ្ហាស្នេហា ១ ទិដ្ឋិស្នេហា ១ ។ បេ ។ នេះតណ្ហា-ស្នេហា ។ បេ ។ នេះទិដ្ឋិស្នេហា ។ ពាក្យថា សេចក្តីទុក្ខនេះ មានឡើង សេចក្តីថា បុគ្គលពួកខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត សម្រាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ កាត់ទី-តខ្លះ ប្លន់ផ្ទះខ្លះ ប្លន់ផ្លូវខ្លះ ចាំស្កាត់ផ្លូវខ្លះ គប់រកកវិយាបុគ្គលដទៃខ្លះ ពោលពាក្យកុហកខ្លះ ។ ពួករាជបុរស ចាប់បុគ្គលនុ៎ះ ថ្វាយព្រះរាជាថា បពិត្រព្រះសម្មតិទេព ចោរនេះ ប្រព្រឹត្តអាក្រក់ ទ្រង់សព្វព្រះហឫទ័យអាជ្ញាណា សូមទ្រង់ដាក់អាជ្ញានោះដល់ចោរនេះចុះ ។ ព្រះរាជាទ្រង់ដៀលត្មុះចោរនោះ ។

សោ បរិកាសប្បច្ចយាបិ ឧក្ខោមនស្សំ បដិសំវេ-
ទេតិ ។ ឯតំ ភយំ ឧក្ខោមនស្សំ ភុតោ ជាតំ ។
តស្ស ស្នេហប្បច្ចយា ច ឆន្ទិប្បច្ចយា ច ភាគប្បច្ចយា
ច ឆន្ទិភាគប្បច្ចយា ច ជាតំ ។ ឯត្តកេនបិ ភជ្ជ ន
ត្ថុស្ស្ដតិ ។ តមេនំ ភជ្ជ ពន្ធាបេតិ អន្ធុពន្ធនេន ភ
រជ្ជុពន្ធនេន ភ សង្ខ្លិកាពន្ធនេន ភ លតាពន្ធនេ-
ន ភ បរិក្ខ្ជេបពន្ធនេន ភ ភាមពន្ធនេន ភ និគម-
ពន្ធនេន ភ ឆ្ការពន្ធនេន ភ រដ្ឋពន្ធនេន ភ ជនប-
ទពន្ធនេន ភ អន្ដមសោ សវចនីយម្ជ្ជ ភ ភ ភ ន ភ
លញ្ជ ឥតោ និក្ខ្ជមិតុន្ដ ។ សោ ពន្ធនប្បច្ចយាបិ
ឧក្ខ្ជោមនស្សំ បដិសំវេទេតិ ។ ឯតំ ភយំ ឧក្ខ្ជោ-
មនស្សំ ភ្ជ ជាតំ ។ តស្ស ស្នេហប្បច្ចយា ច
ឆន្ទិប្ដ្ជ ច ភ ភ ច ឆ្ការ ច ជាតំ ។ ឯត្ដ ភ ន ត្ថ ។ ។ ។
ជ ជ ជ ។ ។ ។
ជ ជ ជ ។ ។ ។

ចោរនោះ រងទុក្ខ ទោមនស្ស ព្រោះការដៀលត្មះជាបច្ច័យ ។ ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ។ កើតហើយដល់ចោរនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយនិងតម្រេកជាបច្ច័យខ្លះ ។ បើព្រះរាជាមិនសព្វព្រះហឫទ័យ ដោយហេតុមានប្រមាណប៉ុណ្ណោះទេ ។ ព្រះរាជាញ៉ាំងរាជបុរសឲ្យចងចោរនោះ ដោយចំណងគឺខ្នោះក្តី ដោយចំណងគឺខ្សែក្តី ដោយចំណងគឺច្រវាក់ក្តី ដោយចំណងគឺវល្ល៍ក្តី ដោយចំណងគឺរបងក្តី ដោយចំណងគឺស្រុកក្តី ដោយចំណងគឺនិគមក្តី ដោយចំណងគឺនគរក្តី ដោយចំណងគឺដែនក្តី ដោយចំណងគឺជនបទក្តី ដោយហោចទៅ ព្រះរាជាធ្វើការហាមប្រាម ដោយព្រះបន្ទូលថា អ្នកមិនត្រូវបានចេញអំពីទីនេះទេ ។ ចោរនោះរងទុក្ខទោមនស្ស ព្រោះការចងជាបច្ច័យ ។ ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ។ កើតហើយដល់ចោរនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយនិងតម្រេកជាបច្ច័យខ្លះ ។ បើព្រះរាជាមិនសព្វព្រះហឫទ័យ ដោយហេតុត្រឹមប៉ុណ្ណោះទេ ។ ព្រះរាជាទ្រង់ឲ្យរឹបយកទ្រព្យនោះ រាប់រយឬរាប់ពាន់ របស់ចោរនោះ ។ ចោរនោះ ក៏រងទុក្ខទោមនស្ស ព្រោះការសាបសូន្យទ្រព្យជាបច្ច័យ ។

២០៩

ឯតំ ភយំ ទុក្ខោមនស្សំ កុតោ ជាតំ ។ តស្ស ស្នេហប្បច្ចយា ច នន្ទិប្បច្ចយា ច រាគប្បច្ចយា ច នន្ទិរាគប្បច្ចយា ច ជាតំ ។ ឯត្តកេនបិ រាជា ន តុស្សតិ ។ រាជា តស្ស វិវិធា កម្មការណា ការាបេតិ កសាហិបិ តាឡេតិ វេត្តេនបិ តាឡេតិ អឌ្ឍទណ្ឌេនបិ តាឡេតិ ហត្ថម្បិ ឆិន្ទតិ បាទម្បិ ឆិន្ទតិ ហត្ថបាទម្បិ ឆិន្ទតិ កណ្ណម្បិ ឆិន្ទតិ នាសម្បិ ឆិន្ទតិ កណ្ណនាសម្បិ ឆិន្ទតិ ពិលង្គថាលិកម្បិ ករោតិ សង្ខមុណ្ឌិកម្បិ ករោតិ រាហុមុខម្បិ ករោតិ ជោតិមាលិកម្បិ ករោតិ ហត្ថប្បជ្ជោតិកម្បិ ករោតិ ឯរកវត្តិកម្បិ ករោតិ ចិរវាសិកម្បិ ករោតិ ឯណេយ្យកម្បិ ករោតិ ពលិសមំសិកម្បិ ករោតិ កហាបណិកម្បិ ករោតិ ខារាបតច្ឆិកម្បិ ករោតិ បលិឃបរិវត្តិកម្បិ ករោតិ បលាលបីឋកម្បិ ករោតិ តត្តេនបិ តេលេន ឱសិញ្ចតិ សុនខេនបិ ខាទាបេតិ ជីវន្តម្បិ សូលេ ឧត្តាសេតិ អសិនាបិ សីសំ ឆិន្ទតិ ។ សោ កម្មការណាប្បច្ចយាបិ ទុក្ខោមនស្សំ បដិសំវេទេតិ ។

ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ។ កើតហើយដល់ចោរនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយនិងតម្រេកជាបច្ច័យខ្លះ ។ បើព្រះរាជាមិនសព្វព្រះរាជហឫទ័យ ដោយហេតុប៉ុណ្ណោះទេ ។ ព្រះរាជាក៏ទ្រង់ឲ្យធ្វើកម្មករណ៍ផ្សេង ៗ ដល់ចោរនោះ គឺឲ្យវាយដោយសៃខ្លះ ឲ្យវាយដោយរំពាត់ផ្តៅខ្លះ ឲ្យវាយដោយដំបងខ្ចីខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ទាំងដៃទាំងជើងខ្លះ កាត់ស្លឹកត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ធ្វើពិលង្គថាលិកកម្មខ្លះ ធ្វើសង្ខមុណ្ឌកកម្មខ្លះ ធ្វើរាហុមុខកម្មខ្លះ ធ្វើជោតិមាលិកកម្មខ្លះ ធ្វើហត្ថប្ប-ជ្ជោតិកកម្មខ្លះ ធ្វើឯរកវដ្តិកកម្មខ្លះ ធ្វើចិរវាសិកកម្មខ្លះ ធ្វើឯណេយ្យកកម្មខ្លះ ធ្វើពលិសមំសិកកម្មខ្លះ ធ្វើកហាបណិកកម្មខ្លះ ធ្វើខារាបតច្ឆិកកម្មខ្លះ ធ្វើបលិឃបរិវត្តិកកម្មខ្លះ ធ្វើបលាលបីឋកកម្មខ្លះ ស្រោចដោយប្រេងក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ទាលើឈើអណ្តាតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ ។ ចោរនោះក៏រងទុក្ខទោមនស្ស ព្រោះកម្មករណ៍ជាបច្ច័យ ។

ឯតំ ភយំ ទុក្ខទោមនស្សំ កុតោ ជាតំ ។ តស្ស ស្នេហប្បច្ចយា ច នន្ទិប្បច្ចយា ច រាគប្បច្ចយា ច នន្ទិរាគប្បច្ចយា ច ជាតំ ។ រាជា ឥមេសំ ចតុន្នំ ទណ្ឌានំ ឥស្សរោ ។ សោ សកេន កម្មេន កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ តមេនំ និរយបាលា បញ្ចវិធពន្ធនំ នាម កម្មការណំ ការេន្តិ តត្តំ អយោខិលំ ហត្ថេ គមេន្តិ តត្តំ អយោខិលំ ទុតិយេ ហត្ថេ គមេន្តិ តត្តំ អយោខិលំ បាទេ គមេន្តិ តត្តំ អយោខិលំ ទុតិយេ បាទេ គមេន្តិ តត្តំ អយោខិលំ មជ្ឈេ ឧរស្មឹ គមេន្តិ ។ សោ តត្ថ ទុក្ខា តិប្បា កដុកា វេទនា បដិសំវេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។ ឯតំ ភយំ ទុក្ខទោមនស្សំ កុតោ ជាតំ ។ តស្ស ស្នេហប្បច្ចយា ច នន្ទិប្បច្ចយា ច រាគប្បច្ចយា ច នន្ទិរាគប្បច្ចយា ច ជាតំ ។ តមេនំ និរយបាលា សំវេសិត្វា កុធារីហិ តច្ឆន្តិ ។

ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ។ កើតហើយដល់ចោរនោះ ព្រោះសេចក្ដីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្ដីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្ដីរីករាយនិងតម្រេកជាបច្ច័យខ្លះ ។ ព្រះរាជា ជាឥស្សរៈនៃអាជ្ញាទាំង ៤ នេះ ។ ចោរនោះលុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើត ឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះកម្ម ជារបស់ខ្លួន ។ ពួកនាយនិរយបាល ឲ្យធ្វើកម្មករណ៍ ឈ្មោះចំណាង ៥ ប្រការនុ៎ះ គឺ បោះដែកគោលក្ដៅត្រង់ដៃ ១ បោះដែកគោលក្ដៅត្រង់ដៃទីពីរ ១ បោះដែកគោលក្ដៅត្រង់ជើង ១ បោះដែកគោលក្ដៅត្រង់ជើងទីពីរ ១ បោះដែកគោលក្ដៅត្រង់កណ្ដាលទ្រូង ១ ។ សត្វនោះរងទុក្ខវេទនា ខ្លោចផ្សាដ៏ក្លាខ្លាំង ក្នុងទីនោះ បាបកម្មនោះមិនទាន់អស់ ដរាបណា សត្វនោះក៏មិនទាន់ធ្វើមរណកាល ដរាបនោះ ។ ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ។ កើតហើយដល់សត្វនោះ ព្រោះសេចក្ដីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្ដីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្ដីរីករាយ និងតម្រេកជាបច្ច័យខ្លះ ។ ពួកនាយនិរយ-បាល ញ៉ាំងសត្វនុ៎ះឲ្យដេកសន្ធឹង ហើយចាំងដោយដឹងទាំងឡាយ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

តមេនំ ជិរយចាលា ឧជ្ជំចាជំ អជោសិរ៎ កហោត្វា ឱ្ហសីហិ តច្ចន្តិ ។ តមេនំ ជិរយចាលា រថ យោ-ជេត្វា អាជិត្តាយ បបរិយា សម្ឆ្ជលិតាយ សញ្ជោ-តិភូតាយ សារេន្តិបិ បច្ចាសារេន្តិបិ ។ តមេនំ ជិរ-យចាលា មហន្តំ អជ្ជារបព្ជតំ អាជិត្តំ សម្ឆ្ជលិតំ សញ្ជោតិភូតំ អារោបេន្តិបិ ឱ្ហរោបេន្តិបិ ។ តមេនំ ជិរយចាលា ឧជ្ជំចាជំ អជោសិរ៎ កហោត្វា តត្ថាយ លោហកុម្ភិយា បក្ខិបន្តិ អាជិត្តាយ សម្ឆ្ជលិតាយ សញ្ជោតិភូតាយ ។ សោ តត្ថ ផេណុទ្ធេហកំ បច្ជតិ ។ សោ តត្ថ ផេណុទ្ធេហកំ បច្ជមានោ សកិម្ឆ ឧជ្ជំ កច្ជតិ សកិម្ឆ អជោ កច្ជតិ សកិម្ឆ តិរិយំ កច្ជតិ ។ សោ តត្ថ ជុក្ខា តិប្ជា ភជុកា ជេជនា បជិសំវេជេតិ ន ច តាវ ការ៎ កាលំ ភវោតិ យាវ ន តំ ចាបកម្ជ៎ ឲ្ជន្តីហោតិ ។ ឯតំ ភយ៎ ជុក្ខជោមនស្ជ៎ ភុតោ ជាតំ ។

ខគ្គវិសាណសុត្តនិទ្ទេស

ពួកនាយនិរយបាលចាប់សត្វនុ៎ះឲ្យមានជើងឡើងលើ មានក្បាលចុះក្រោម ហើយច្រាសដោយកាំបិតទាំងឡាយ ។ ពួកនាយនិរយបាល ទឹមសត្វនុ៎ះក្នុងរថហើយបរទៅខ្ទះ បត្រឡប់មកវិញខ្ទះ លើផែនដីដែលភ្លើងឆេះ សន្ធោសន្ធៅរន្ធាលច្រាលឆ្ពៅ ។ ពួកនាយនិរយបាល ឲ្យសត្វនុ៎ះឡើងកាន់ភ្នំរងើកភ្លើងដ៏ធំ ដែលភ្លើងឆេះសន្ធោសន្ធៅ រន្ធាលច្រាលឆ្ពៅខ្ទះ ឲ្យចុះមកវិញខ្ទះ ។ ពួកនាយនិរយបាល ចាប់សត្វនុ៎ះឲ្យមានជើងឡើងលើ មានក្បាលចុះក្រោម ហើយបោះទៅក្នុងខ្ទះដែកដ៏ក្តៅ ដែលភ្លើងឆេះសន្ធោសន្ធៅ រន្ធាលច្រាលឆ្ពៅ ។ សត្វនោះពុះផុសឡើងដូចពពុះក្នុងខ្ទះនោះ ។ សត្វនោះកាលពុះផុសឡើងដូចពពុះក្នុងខ្ទះនោះ អណ្តែតឡើងលើម្តង លិចចុះក្រោមម្តង ទៅទទឹងម្តង ។ សត្វនោះរងទុក្ខវេទនាដ៏ក្លាខ្លាំងខ្ញាចផ្សាក្នុងខ្ទះនោះ បាបកម្មនោះមិនទាន់អស់ ដរាបណា សត្វនោះក៏មិនទាន់ធ្វើមរណកាល ដរាបនោះ ។ ភ័យ ទុក្ខ ទោមនស្សនុ៎ះកើតហើយព្រោះអ្វី ។

តស្ស ស្នេហាឃ្ចយា ច ឆន្ទិឃ្ចយា ច ភាគឃ្ចយា ច ឆន្ទិភាគឃ្ចយា ច ជាតំ ។ តមេតំ និរយចា-លា និរយេ បក្ខិបន្តិ ។ សោ ខោ បន មហានិរយោ

ចតុក្ការណ្ណោ ចតុទ្វារោ វិភត្តោ ភាគសោ មិតោ
អយោចាការបរិយន្តោ អយសា បដិកុជ្ជិតោ ។
តស្ស អយោមយា ភូមិ ជលិតា តេជសា យុតា
សមន្តា យោជនសតំ ផរិត្វា តិដ្ឋតិ សព្វទា ។
ភាគរិយា តបនា ឃោរ អច្ចិមន្តោ ទុរាសទា
លោមហំសនរូបា ច ភិស្ម បដិភយា ទុក្ខា ។
បុរត្ថិមាយ ច ភិត្តិយា អច្ចិក្ខន្ធោ សមុដ្ឋិតោ
ឧហន្ត្វា ចាបកម្ម្ហេ បច្ឆិមាយ បដិហញ្ញតិ ។
បច្ឆិមាយ ច ភិត្តិយា អច្ចិក្ខន្ធោ សមុដ្ឋិតោ
ឧហន្ត្វា ចាបកម្ម្ហេ បុរត្ថិមាយ បដិហញ្ញតិ ។
ទក្ខិណាយ ច ភិត្តិយា អច្ចិក្ខន្ធោ សមុដ្ឋិតោ
ឧហន្ត្វា ចាបកម្ម្ហេ ឧត្តរាយ បដិហញ្ញតិ ។

កើតហើយដល់សត្វនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយនិងតម្រេកជាបច្ច័យខ្លះ ។ ពួកនាយនិរយបាល ក៏បោះសត្វនោះទៅក្នុងនរក ។ មហានរកនោះសោត

មានជ្រុង ៤ មានទ្វារ ៤ ដែលធម្មតាចែករាប់តាមចំណែកព័ន្ធព័ទ្ធដោយកំពែងដែក គ្របដោយបន្ទះដែក ។ ផ្ទៃមហានរកនោះ សុទ្ធដែកច្រាលឆ្ពៅ ប្រកបដោយកម្តៅ ផ្សាយទៅមួយរយយោជន៍ដោយជុំវិញ សព្វកាល ។ មហានរកទាំងនោះ មានអណ្តាតភ្លើងអាក្រក់ក្តៅពន្ទឹក ពុំគួរត្រេកអរ មានសភាពគួរព្រឺរោម គួរតក់ស្លុត គួរជាទុក្ខ គួរខ្ជាប ។ គំនរអណ្តាតភ្លើង ដែលតាំងឡើងអំពីជញ្ជាំងខាងកើត ធាបនេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅត្រង់ជញ្ជាំងខាងលិច ។ គំនរអណ្តាតភ្លើង ដែលតាំងឡើងអំពីជញ្ជាំងខាងលិច ធាបនេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅត្រង់ជញ្ជាំងខាងកើត ។ គំនរអណ្តាតភ្លើង ដែលតាំងឡើង អំពីជញ្ជាំងខាងត្បូង ធាបនេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅត្រង់ជញ្ជាំងខាងជើង ។

ខគ្គវិសាណសុត្តនិទ្ទេសោ

ឧត្តរាយ ច ភិត្តិយា អច្ចិក្ខន្ធោ សមុដ្ឋិតោ
ឱហន្ត្វោ ចាបកម្មន្តេ ឧក្ខិណាយ បដិហញ្ញតិ ។
ហេដ្ឋិតោ ច សមុដ្ឋិតោ អច្ចិក្ខន្ធោ ភយានកោ
ឱហន្ត្វោ ចាបកម្មន្តេ ឆឌ្ឌនម្ហិ បដិហញ្ញតិ ។
ឆឌ្ឌនម្ហា សមុដ្ឋិតោ អច្ចិក្ខន្ធោ ភយានកោ
ឱហន្ត្វោ ចាបកម្មន្តេ ភូមិយំ បដិហញ្ញតិ ។
អយោកចាលំ អាឌិត្តំ សន្តត្តំ ជលិតំ យថា
ឯវំ អវីចិនិរយោ ហេដ្ឋា ឧបរិ បស្សតោ ។
តត្ត សត្តា មហាលុទ្ធា មហាកិព្ពិសការិនោ
អច្ចន្តចាបកម្មន្តា បច្ចន្តិ ន ច មិយ្យរេ ។
ជាតវេឌសមោ ការោ តេសំ និរយវាសិនំ
បស្ស ការ្ម្ហានំ ឧជ្ជ្ហត្តំ ន ភស្ម ហោន្តិ ឌបិ មសិ[1] ។
បុរត្ថិមេឌបិ ជាវន្តិ តតោ ជាវន្តិ បច្ឆតោ
ឧត្តរេឌបិ ជាវន្តិ តតោ ជាវន្តិ ឧក្ខិណំ ។

---

១ ម. ន ភស្មំ ហោតិ មំ សិបិ ។

គំនរអណ្ណាតក្ងើងដែលតាំងឡើងអំពីជញ្ជាំងខាងជើង ធាបនេះ សត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅត្រង់ជញ្ជាំងខាងត្បូង ។ គំនរអណ្ណាតក្ងើងគួរខ្ជាច តាំងឡើងអំពីខាងក្រោម ធាបនេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅនឹងដំបូល ។ គំនរអណ្ណាតក្ងើងគួរខ្ជាច តាំងឡើងអំពីដំបូល ធាបនេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់មកនឹងផ្ទៃ ។ អំបែងដែក កំពុងនេះ ក្តៅសព្ទ រុងរឿងយ៉ាងណា នរកអវីចិ (ក៏ប្រាកដ) ដល់សត្វដែលតាំងនៅខាងក្រោមនិងខាងលើ យ៉ាងនោះដែរ ។ សត្វទាំងឡាយជាអ្នកអាក្រក់ខ្លាំង ធ្វើអំពើអាក្រក់ច្រើន មានអំពើបាបតែមួយយ៉ាង រមែងនេះ តែមិនស្លាប់ ក្នុងនរកនោះទេ ។ កាយសត្វនរកទាំងឡាយដែលអាស្រ័យនៅក្នុងនរកនោះ ប្រាកដស្មើដោយក្ងើង អ្នកចូរមើលនូវភាពនៃបាបកម្មដ៏មាំមួនចុះ សត្វទាំងនោះមិនទៅជានេះ ទាំងមិនទៅជាធ្ងូង ។ សត្វនរកទាំងឡាយរមែងស្ទុះទៅតាមទិសខាងកើតខ្ជះ ស្ទុះចេញអំពីទិសខាងកើតនោះ មកកាន់ទិសខាងលិចខ្ជះ ស្ទុះទៅតាមទិសខាងជើងខ្ជះ ស្ទុះចេញអំពីទិសខាងជើងនោះ មកកាន់ទិសខាងត្បូងខ្ជះ ។

យំ យំ ឧិសម្ប៎ ជាវន្តិ តំ តំ ភ្ជារ៎ បិថ៎ិយ្យតិ
អកិនិក្ខ្ជមិតាសា តេ សត្តា ម្ហោ ក្ខ៎ ករ៎ សិ ណ ។
ន តេ ត្ត ណ ម ិ ក្ខ្ជ ម ិ ត ុ ំ ល ភ ន ្ត ិ ក ម ្ម ប ្ប ច ូ យ ា
ត េ ស ញ ្ជ ូ ច ា ប ក ំ ក ម ្ម ំ អ ា ប ក ្ក ំ ក ត ំ ព ហ ុ ន ្ត ិ ។

ឯតំ ភយ ំ ខ ុ ក ្ខ ោ ម ន ស ្ស ំ ក ុ ត ោ ជ ា ត ំ ។ ត ស ្ស ។ ស្នេហប្បច្ចយា ច ឆន្ទិប្បច្ចយា ច ភាគប្បច្ចយា ច ឆន្ទិភាគប្បច្ចយា ច ជាតំ ។ យានិ ច ឆេរយិកានិ ខុក្ខានិ យានិ ច តិរច្ឆានយោនិកានិ ខុក្ខានិ យានិ ច បិត្តិវិសយិកានិ ខុក្ខានិ យានិ ច មានុសកានិ ខុក្ខានិ តានិ ក ុ ត ោ ជ ា ត ា ន ិ ក ុ ត ោ ស ញ ្ជ ា ត ា ន ិ ក ុ ត ោ ជ ិ ព ្ព ា ន ិ ក ុ ត ោ អ ភ ិ ជ ិ ព ្ព ា ន ិ ក ុ ត ោ ច ា ត ុ ភ ូ ត ា ន ិ ។ ស ្ន េ ហ ប ្ប ច ូ យ ា ច ឆ ន ្ទ ិ ប ្ប ច ូ យ ា ច ភ ា ค ប ្ป ច ូ យ ា ច ឆ ន ្ទ ិ ภ ค ป ្ป ច ូ យ ា ច ค ว ร ្ត ិ ส ม ្ภ ว ร ្ត ិ ช า ย ร ្ត ิ ส ญ ្ช า ย ร ្ត ิ ช ิ ว ร ្ត ร ្ត ิ อ ค ช ิ ว ร ្ត ร ្ত ิ ช า ต ุ ค ว ร ្ត ี ต ิ ส ្ន ห ว ร ្ម (ข ุ ค ្ค ม ิ ข ํ ป ห ោ ต ิ ។

សត្វនរកទាំងនោះ ស្ទុះទៅកាន់ទិសណា ។ ទ្វារក្នុងទិសនោះ ។ ក៏បិទជិតឯង សត្វទាំងនោះ សុទ្ធតែមានសេចក្តីប្រាថ្នាដើម្បីចេញ ស្វែងរកនូវការចេញ ។ សត្វនរកទាំងនោះ ចេញអំពីនរកនោះមិនបាន ព្រោះកម្មជាបច្ច័យ ព្រោះថាបាបកម្មរបស់សត្វទាំងនោះ មានច្រើនយ៉ាង ដែលខ្លួនធ្វើហើយ ជាកម្មមិនទាន់ទុំ ។

ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ។ កើតហើយដល់សត្វនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយនិងតម្រេកជាបច្ច័យខ្លះ ។ ទុក្ខណាមានក្នុងនរកក្តី ទុក្ខណាមានក្នុងកំណើតតិរច្ឆានក្តី ទុក្ខណាមានក្នុងបិត្តិវិស័យក្តី ទុក្ខណាមានក្នុងពួកមនុស្សក្តី ទុក្ខទាំងនោះ កើតហើយព្រោះអ្វី កើតព្រមហើយព្រោះអ្វី ដុះដាលហើយព្រោះអ្វី ចម្រើនហើយព្រោះអ្វី កើតប្រាកដហើយព្រោះអ្វី ។ ទុក្ខទាំងនោះ មាន មានព្រម កើត កើតព្រម ដុះដាល ចម្រើន កើតប្រាកដ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយនិងតម្រេកជាបច្ច័យខ្លះ ហេតុនោះ (លោកពោលថា) សេចក្តីទុក្ខនេះ មានឡើង ព្រោះអាស្រ័យសេចក្តីស្នេហា ។

ខគ្គវិសាណសុត្តនិទ្ទេសោ

[២៣៩] អាទីនវំ ស្នេហជំ បេក្ខមានោតិ ស្នេហោតិ ទ្វេ ស្នេហា តណ្ហាស្នេហោ ច ទិដ្ឋិស្នេហោ ច ។ បេ ។ អយំ តណ្ហាស្នេហោ ។ បេ ។ អយំ ទិដ្ឋិស្នេហោ ។ អាទីនវំ ស្នេហជំ បេក្ខមានោតិ តណ្ហាស្នេហេ ច ទិដ្ឋិស្នេហេ ច អាទីនវំ បេក្ខមានោ[១] ឱលោកយមានោ និជ្ឈាយមានោ ឧបបរិក្ខមានោតិ អាទីនវំ ស្នេហជំ បេក្ខមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

សំសគ្គជាតស្ស ភវន្តិ ស្នេហា
ស្នេហន្វយំ ទុក្ខមិទំ បហោតិ
អាទីនវំ ស្នេហជំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

---

១ ម. បេក្ខមានោ ទក្ខមានោ ។

ខគ្គវិសាណសុត្តនិទ្ទេស

[២៣៥] *អធិប្បាយពាក្យថា បុគ្គលកាលសម្ងឹងឃើញទោសដែលកើតអំពីសេចក្តីស្នេហា ត្រង់ពាក្យថា សេចក្តីស្នេហា បានដល់សេចក្តីស្នេហា ២ គឺ តណ្ហាស្នេហា ១ ទិដ្ឋិស្នេហា ១ ។ បេ ។ នេះតណ្ហាស្នេ-ហា ។ បេ ។ នេះទិដ្ឋិស្នេហា ។ ពាក្យថា បុគ្គលកាលសម្ងឹងឃើញទោសដែលកើតអំពីសេចក្តីស្នេហា បានសេចក្តីថា បុគ្គលកាលសម្ងឹងឃើញ រមិលមើល ពិនិត្យមើល ពិចារណាមើល នូវទោសក្នុងតណ្ហា-ស្នេហាផង ក្នុងទិដ្ឋិស្នេហាផង ហេតុនោះ (លោកពោលថា) បុគ្គលកាលសម្ងឹងឃើញទោស ដែលកើតអំពីសេចក្តីស្នេហា ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា*

សេចក្តីស្នេហា របស់បុគ្គលអ្នកមានការជាប់ចំពាក់ រមែងមាន សេចក្តីទុក្ខនេះ មានឡើង ព្រោះអាស្រ័យសេចក្តីស្នេហា បុគ្គលកាលសម្ងឹងឃើញទោស ដែលកើតអំពីសេចក្តីស្នេហា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៤០] មិត្តេ សុហាជ្ជេ អនុកម្បមានោ
ហាបេតិ អត្តំ បដិពទ្ធចិត្តោ
ឯតំ ភយំ សន្តវ បេក្ខមានោ
ឯកោ ចរ ខ្គវិសាណកប្បោតិ ។

[២៤១] មិត្តេ សុហាជ្ជេ អនុកម្បមានោ ហាបតិ អត្តំ បដិពទ្ធចិត្តោតិ មិត្តោតិ ទ្វេ មិត្តា អាការិកមិត្តោ ច អនាការិកមិត្តោ ច ។

កតមោ អាការិកមិត្តោ ។ ឥធេកច្ចោ ឧច្ចំ ឧជាតិ ឧច្ចំ ចជតិ ឧក្ការំ ករោតិ ឧក្ខេបំ ខមតិ ឧយ្ហមស្ស អាចិក្ខតិ ឧយ្ហមស្ស បរិឧយ្ហតិ អាបជ្ជាសុ ន រិជ្ជតិ ជីវិតំ ចស្ស អត្ថាយ បរិចត្តំ ហោតិ ទ្វីណោ ជាតិមញ្ញតិ អយំ អាការិកមិត្តោ ។

កតមោ អនាការិកមិត្តោ[1] ។ ឥធ ភិក្ខុ បិយោ ច ហោតិ មនាបោ ច ហោតិ ឥរ ច ភាវនីយោ ច វចនក្ខមោ ច ឥម្ភីរញ្ច កថំ កត្តា អដ្ឋានេ ច ន និយោជេតិ[2] អធិសីលេ សមាទបេតិ

---

1 ម. បព្ជិតមិត្តោ ។ ២ ម. នោ ច អដ្ឋានេ និយោជេតិ ។

[២៨០] *បុគ្គលអ្នកមានចិត្តជាប់ចំពាក់ កាលអនុគ្រោះចំពោះ មិត្ត និងអ្នកមានចិត្តល្អ រមែងញ៉ាំងប្រយោជន៍ ឲ្យវិនាស បុគ្គលកាលសម្ងឹងឃើញភ័យ ក្នុងការស្និទ្ធស្នាលនុ៎ះ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។*

[២៨១] *អធិប្បាយពាក្យថា បុគ្គលអ្នកមានចិត្តជាប់ចំពាក់ កាលអនុគ្រោះចំពោះមិត្តអ្នកមានចិត្តល្អ រមែងញ៉ាំងប្រយោជន៍ឲ្យវិនាស ត្រង់ពាក្យថា មិត្ត បានដល់មិត្ត ២ គឺ អាគារិកមិត្ត ១ អនាគារិកមិត្ត ១ ។*

អាគារិកមិត្ត តើដូចម្តេច ។ បុគ្គលខ្ះក្នុងលោកនេះ ឲ្យវត្ថុដែលគេឲ្យបានដោយក្រ លះបង់វត្ថុដែលគេលះបង់បានដោយក្រ ធ្វើអំពើដែលគេធ្វើបានដោយក្រ អត់ទ្រាំហេតុដែលគេអត់ទ្រាំបានដោយក្រ ប្រាប់ការកំបាំងដល់មិត្តនោះ លាក់ការកំបាំងរបស់មិត្តនោះ មិនលះបង់គ្នាក្នុងកាលមានអន្តរាយ សូម្បីជីវិតក៏ហ៊ានលះបង់ ដើម្បីប្រយោជន៍ដល់មិត្តនោះ មិនមើលងាយមិត្ត ក្នុងកាលមិត្តអស់ទ្រព្យ នេះអាគារិកមិត្ត ។

អនាគារិកមិត្ត តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ រមែងជាទីស្រឡាញ់ផង ជាទីពេញចិត្តផង គួរគោរពផង គួរអ្នកផងស្ងើចផង អត់ធន់ក្នុងពាក្យពោលផង ធ្វើពាក្យឲ្យជ្រាលជ្រៅផង មិនដឹកនាំក្នុងហេតុមិនគួរផង ដឹកនាំក្នុងអធិសីល ដឹកនាំក្នុងការប្រកបរឿយ ១

ចតុន្នំ សតិប្បដ្ឋានានំ ភាវនានុយោគេ សមានឧបេតិ ចតុន្នំ សម្មប្បធានានំ ។ បេ ។ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈ-ង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ភាវនានុយោគេ សមានឧបេតិ អយំ អនាការិកមិត្តោ ។

សុហជ្ជា រុចូត្តិ យេហិ សហ គមនំ ជាសុ អ-គមនំ ជាសុ គមនាគមនំ ជាសុ ឋានំ ជាសុ និសជ្ជ-ន្ធនំ ជាសុ សយនំ ជាសុ អាលបនំ ជាសុ សល្ល-បនំ ជាសុ ឧល្លបនំ ជាសុ សមុល្លបនំ ជាសុ ។

មិត្តេ សុហជ្ជេ អនុកម្បមានោ ហាបេតិ អត្ថន្តិ មិត្តេ ច សុហជ្ជេ ច សន្ធិជ្ជេ ច សម្ភត្តេ ច ស-ហាយេ ច អនុកម្បមានោ អនុបេក្ខមានោ អនុក្ក-ឃ្ជមានោ អត្ថត្ថម្បិ បរត្ថម្បិ ហាបេតិ ឧភយត្ថម្បិ ហាបេតិ ជិដ្ឋធម្មិកម្បិ អត្តំ ហាបេតិ សម្ផរាយិកម្បិ អត្តំ ហាបេតិ បរមត្ថម្បិ ហាបេតិ បរិជ៎ំសេតិ បរិ-សជ្ជេតិ អន្ធរជាបេតីតិ មិត្តេ សុហជ្ជេ អនុកម្ប-មានោ ហាបេតិ អត្តំ ។

នូវការចម្រើនសតិប្បដ្ឋាន ៤ ដឹកនាំក្នុងការប្រកបរឿយៗ នូវការចម្រើនសម្ម-ប្បធាន ៤ ។ បេ ។ នូវឥទ្ធិបាទ ៤ នូវឥន្ទ្រិយ ៥ នូវពល: ៥ នូវពោជ្ឌង្គ: ៧ នូវអរិយមគ្គមានអង្គ ៨ ផង នេះអនាគារិកមិត្ត ។

ការដើរទៅជាសុខ ការមកជាសុខ ការទៅមកជាសុខ ការឈរជាសុខ ការអង្គុយជាសុខ ការដេកជាសុខ ការហៅរកជាសុខ ការនិយាយរកគ្នាជាសុខ ការនិយាយធ្វើយធ្ងន់គ្នាជាសុខ ការនិយាយស្រុះស្រួលគ្នាជាសុខ ជាមួយនឹងពួកជនណា ពួកជននោះ លោកហៅថា អ្នកមានចិត្តល្អ ។

ពាក្យថា បុគ្គលកាលអនុគ្រោះចំពោះមិត្តនិងអ្នកមានចិត្តល្អ រមែងញ៉ាំងប្រយោជន៍ឲ្យវិនាស គឺបុគ្គលកាលអនុគ្រោះ ទំនុកបម្រុង ផ្ទុងផ្ដើមចំពោះមិត្តផង ចំពោះអ្នកមានចិត្តល្អផង ចំពោះជនដែលធ្លាប់ឃើញគ្នាផង ចំពោះជនដែលរាប់គ្នាស្និទ្ធផង ចំពោះសម្ងាញ់ផង រមែងញ៉ាំងប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃឲ្យវិនាស ញ៉ាំងប្រយោជន៍ទាំងពីរឲ្យវិនាស ញ៉ាំងប្រយោជន៍បច្ចុប្បន្ន ឲ្យវិនាស ញ៉ាំងប្រយោជន៍បរលោកឲ្យវិនាស ញ៉ាំងប្រយោជន៍ដ៏ក្រៃលែងឲ្យវិនាស ឲ្យខ្ជាត់ខ្ជាយ ឲ្យបាត់បង់ ឲ្យអន្ត-ធាន ហេតុនោះ (លោកពោលថា) បុគ្គលកាលអនុគ្រោះចំពោះមិត្ត និងអ្នកមានចិត្តល្អ រមែងញ៉ាំងប្រយោជន៍ឲ្យវិនាស ។

បដិពទ្ធចិត្តោតិ ទ្វីហិ ការណេហិ បដិពទ្ធចិត្តោ ហោតិ អត្តានំ វា នីចំ ឋបេត្តា បរំ ឧច្ចំ ឋបេ-ត្តា បដិពទ្ធចិត្តោ ហោតិ អត្តានំ វា ឧច្ចំ ឋបេ-ត្តា បរំ នីចំ ឋបេត្តា បដិពទ្ធចិត្តោ ហោតិ ។

កថំ អត្តានំ នីចំ ឋបេត្តា បរំ ឧច្ចំ ឋបេ-ត្តា បដិពទ្ធចិត្តោ ហោតិ ។ តុម្ហេ មេ ពហូប-ការកា អហំ តុម្ហេ និស្សាយ លភামិ ចីវរបិ-ណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ យ-ម្ហិ[1] មេ អញ្ញេ ជានុំ វា ការុំ វា មញ្ញន្តិ តុម្ហេ និស្សាយ តុម្ហេ សម្ឋស្ឋត្តា យម្ហិ មេ ចោរាណំ មាតាបេត្តិកំ ជាមកោត្តំ តម្ហិ[2] អន្តរហិតំ តុម្ហេហិ អហំ ញ្ញាយាមិ អសុកស្ស ការុបកោ អសុកាយ ការុបកោតិ ឯវំ អត្តានំ នីចំ ឋបេត្តា បរំ ឧច្ចំ ឋបេត្តា បដិពទ្ធចិត្តោ ហោតិ ។

---

១ ម. យេបិ ។ ២ ម. តម្ហិ មេ ។

ពាក្យថា អ្នកមានចិត្តជាប់ចំពាក់ គឺ ជាអ្នកមានចិត្តជាប់ចំពាក់ដោយហេតុ ២ គឺ ជាអ្នកមានចិត្តជាប់ចំពាក់ តាំងខ្លួនឲ្យទាប តាំងអ្នកដទៃឲ្យខ្ពស់ ឬជាអ្នកមានចិត្តជាប់ចំពាក់ តាំងខ្លួនឲ្យខ្ពស់ តាំងអ្នកដទៃឲ្យទាប ។

បុគ្គលជាអ្នកមានចិត្តជាប់ចំពាក់ តាំងខ្លួនឲ្យទាប តាំងបុគ្គលដទៃឲ្យខ្ពស់ តើដូចម្តេច ។ បុគ្គលនោះពោលថា លោកមានឧបការៈច្រើនដល់ខ្ញុំ ខ្ញុំបានចីវរ បិណ្ឌបាត សេនាសនៈ និងថ្នាំគ្រឿងរក្សារោគជាបរិក្ខារបស់ជីវិត ព្រោះអាស្រ័យលោក ជនទាំងឡាយដទៃ កាលអាស្រ័យលោក ឃើញលោក ទើបសម្គាល់ដើម្បីឲ្យ ឬដើម្បីធ្វើវត្ថុណា ដល់ខ្ញុំក្តី នាមនិងគោត្រណា ជារបស់មាតាបិតាដែលមានពីមុន របស់ខ្ញុំក្តី សូម្បីវត្ថុនោះ ទាំងនាមនិងគោត្រនោះ ក៏បាត់បង់ទៅហើយ (ហេតុនោះ) ខ្ញុំសុំទទួលស្គាល់លោកថា ជាជីតុនរបស់បុរសឯណោះ ជាជីតុនរបស់ស្ត្រីឯណោះ បុគ្គលជាអ្នកមានចិត្តជាប់ចំពាក់ តាំងខ្លួនឲ្យទាប តាំងអ្នកដទៃឲ្យខ្ពស់ យ៉ាងនេះឯង ។

ខគ្គវិសាណសុត្តនិទ្ទេសោ

កេចំ អត្តានំ ឧច្ចំ ឋបេន្តោ ឋរំ ឌីចំ ឋបេន្តោ ឋដិពទ្ធចិត្តោ ហោតិ ។ អហំ តុម្ហាកំ ពហូឧបការោ តុម្ហេ មំ អាគម្ម ពុទ្ធំ សរណំ គតា ធម្មំ សរណំ គតា សង្ឆំ សរណំ គតា ចាណាតិចាតា ឋដិវិរតា អទិន្នាទានា ឋដិវិរតា ការាមេសុមិច្ឆាចារ ឋដិវិរតា មុសាវាទា ឋដិវិរតា សុរាមេរយមជ្ជឋ្ឋមាទដ្ឋានា ឋដិវិរតា អហំ តុម្ហាកំ ឧទ្ទេសម្ឆិ ឋរិឋុច្ឆម្ឆិ សីលម្ឆិ ឧចោសថម្ឆិ អាចិក្ខាមិ ឌវកម្មំ អទិដ្ឋាមិ អថ ច ឋន តុម្ហេ មំ ឋរិចូដិត្វា អញ្ញេ សក្ការោថ ករុការោ-ថ មានេថ ឋូជេថាតិ ឋរំ អត្តានំ ឧច្ចំ ឋបេន្តោ ឋរំ ឌីចំ ឋបេន្តោ ឋដិពទ្ធចិត្តោ ហោតីតិ មិត្តេ សុហជ្ជេ អនុកម្ឆមានោ ហាឋេតិ អត្តំ ឋដិពទ្ធចិត្តោ ។

[២៤២] ឋតំ ភយំ សន្តវ ឋេក្ខូមានោតិ ភយ-ន្តិ ជាតិភយំ ជរាភយំ ព្យាធិភយំ មរណភយំ រាជ-ភយំ ចោរភយំ អគ្គិភយំ ឧទកភយំ អត្តានុវាទភយំ ឋរានុវាទភយំ ទណ្ឌភយំ ទុគ្គតិភយំ ឆ្ងមិភយំ

ខគ្គវិសាណសុត្តនិទ្ទេស

បុគ្គលជាអ្នកមានចិត្តជាប់ចំពាក់ តាំងខ្ជួនឲ្យខ្ពស់ តាំងអ្នកដទៃឲ្យ ទាប តើដូចម្តេច ។ បុគ្គលនោះពោលថា ខ្ញុំមានឧបការៈច្រើនដល់ លោក លោកអាស្រ័យខ្ញុំ ទើបដល់ព្រះពុទ្ធជាទីពឹង ដល់ព្រះធម៌ជាទីពឹង ដល់ព្រះសង្ឆជាទីពឹង រៀរចាកបាណាតិបាត រៀរចាកអទិន្នាទាន រៀរ ចាកកាមេសុមិច្ឆាចារៈ រៀរចាកមុសាវាទ រៀរចាកហេតុជាទីតាំងនៃ សេចក្តីប្រមាទ ក្នុងទឹកស្រវឹងគឺសុរានិងមេរ័យ ខ្ញុំបានប្រាប់ឧទ្ទេសផង បរិបុច្ឆាផង សីលផង ឧបោសថផង អធិដ្ឋានទវកម្ម ដល់លោក ប៉ុន្តែ លោកលះបង់ខ្ញុំ ទៅធ្វើសក្ការៈ គោរព រាប់អាន បូជា ចំពោះបុគ្គល ដទៃវិញ បុគ្គលជាអ្នកមានចិត្តជាប់ចំពាក់ តាំងខ្ជួនឲ្យខ្ពស់ តាំងអ្នកដទៃ ឲ្យទាប យ៉ាងនេះឯង ហេតុនោះ (លោកពោលថា) បុគ្គលអ្នកមាន ចិត្តជាប់ចំពាក់ កាលអនុគ្រោះចំពោះមិត្តនិងអ្នកមានចិត្តល្អ រមែងញ៉ាំង ប្រយោជន៍ឲ្យវិនាស ។

[២៦២] *អធិប្បាយពាក្យថា បុគ្គលកាលសម្ងឹងឃើញភ័យ ក្នុង ការស្ថិទ្ធស្ទាលនុ៎ះ ត្រង់ពាក្យថា ភ័យ បានដល់ភ័យអំពីជាតិ ភ័យអំពី ជរា ភ័យអំពីព្យាធិ ភ័យអំពីមរណៈ ភ័យអំពីព្រះរាជា ភ័យអំពីចោរ ភ័យអំពីភ្លើង ភ័យអំពីទឹក ភ័យអំពីការតិះដៀលខ្ជួនឯង ភ័យអំពីការតិះ ដៀលរបស់បុគ្គលដទៃ ភ័យអំពីអាជ្ញា ភ័យអំពីទុគ្គតិ ភ័យអំពីរលកទឹក*

កុម្ភិលភយំ អាវដ្ដភយំ សុំសុមារភយំ អាជីវិកាភយំ អសិលោកភយំ បរិសសារជ្ជភយំ[១] ភយានកំ ឆម្ភិតត្តំ លោមហំសោ ចេតសោ ឧព្វេគ្គោ ឧត្រាសោ ។ សង្គវេតិ ទ្វេ សង្គា តណ្ហាសង្គោ ច ទិដ្ឋិសង្គោ ច ។ បេ ។ អយំ តណ្ហាសង្គោ ។ បេ ។ អយំ ទិដ្ឋិសង្គោ ។ ឯតំ ភយំ សង្គវេ បេក្ខមានោតិ ឯតំ ភយំ សង្គវេ បេក្ខមានោ[២] ឱលោកយមានោ និជ្ឈាយមានោ ឧបបរិក្ខមានោតិ ឯតំ ភយំ សង្គវេ បេក្ខមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

មិត្តេ សុហជ្ជេ អនុកម្បមានោ
ហាបេតិ អត្ថំ បដិពទ្ធចិត្តោ
ឯតំ ភយំ សង្គវេ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

១ ម. បរិស្សយសារជ្ជភយំ មទនភយំ ។ ២ ម. បេក្ខមានោ ទក្ខមានោ ។

ភ័យអំពីក្រពើ ភ័យអំពីទឹកកួច ភ័យអំពីត្រីសាហាវ ភ័យអំពីការរកចិញ្ចឹមជីវិត ភ័យអំពីការមិនសរសើរ ភ័យអំពីសេចក្តីរញ្ជោចរញ្ជើមក្នុងបរិស័ទ ហេតុគួរខ្ជាច ការញាប់ញ័រ ការព្រឺរោម ការរន្ធត់ចិត្ត ការតក់ស្លុត ។ ពាក្យថា ការស្និទ្ធស្នាល បានដល់សេចក្តីស្និទ្ធស្នាល ២ គឺ សេចក្តីស្និទ្ធស្នាលគឺតណ្ហា ១ សេចក្តីស្និទ្ធស្នាលគឺទិដ្ឋិ ១ ។ បេ ។ នេះ សេចក្តីស្និទ្ធស្នាល គឺតណ្ហា ។ បេ ។ នេះ សេចក្តីស្និទ្ធស្នាលគឺទិដ្ឋិ ។ ពាក្យថា បុគ្គល កាលសម្ងឹងឃើញភ័យ ក្នុងសេចក្តីស្និទ្ធស្នាលនុ៎ះ បានសេចក្តីថា បុគ្គលកាលសម្ងឹងឃើញ ក្រឡេកមើល ពិនិត្យមើល ពិចារណាមើល នូវភ័យក្នុងសេចក្តីស្និទ្ធស្នាលនុ៎ះ ហេតុនោះ (លោកពោលថា) បុគ្គលកាលសម្ងឹងឃើញភ័យ ក្នុងសេចក្តីស្និទ្ធស្នាលនុ៎ះ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលអ្នកមានចិត្តជាប់ចំពាក់ កាលអនុគ្រោះចំពោះ
មិត្តនិងអ្នកមានចិត្តល្អ រមែងញ៉ាំងប្រយោជន៍ឲ្យវិនាស
បុគ្គលកាលសម្ងឹងឃើញភ័យ ក្នុងការស្និទ្ធស្នាលនុ៎ះ
គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

ខគ្គវិសាណសុត្តនិទ្ទេសោ

[២៤៣] វំសោ វិសាលោវ យថា វិសត្តោ
បុត្តេសុ ទារេសុ ច យា អបេក្ខា
វំសកឡីរោវ(១) អសជ្ជមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[២៦៧] សញ្ជិន្ទ្រិយត្តោ យថា ភោវិជ្ជាហោតិ យ-ថា ភោវិជ្ជាវស្ស បត្តានិ សីតានិ ធិជ្ជានិ បតិតា-និ ឯវមេវ តស្ស បច្ចេកសម្ពុទ្ធស្ស ភិហិញ្ញាណ-និ ធិជ្ជានិ បតិតានីតិ សញ្ជិន្ទ្រិយត្តោ យថា ភោវិ-ជ្ជាហោ ។

[២៦៨] ឆេត្វាន រីហោ ភិហិពន្ធនានីតិ រីយ្យាតិ រីហោ ។ បហ្ហូតិ រីហោ ។ វិសរីតិ រីហោ ។ អលមត្តោ-តិ រីហោ ។ ស្ស្ហោតិ រីហោ ។ រិត្ត្ហោ អភិរ្ យ្ធ្ម្ អនុ្ត្ថាសី អបលាយី បហីនភយភេរវោ រ្ត្ត លោ-មហំសោតិ រីហោ ។

អ្ យ្ យ ឥ ស ព្ ចាបភោ ហ

 និ យ ធ ក្ ម ត ច ្ រ ្ យ ្ ស

ស ្ ្ យ ្ ប ្ ន ្

រ ្ ហ ្ ត ្ ន ្ ្ ្ ។

[២៦៧] ពាក្យថា ដូចរលួសផ្ទុង ដែលជម្រុះស្ទឹក សេចក្ដីថា ស្ទឹកទាំងឡាយ របស់រលួសផ្ទុង ដែលរបេះ ដាច់ ជ្រុះ យ៉ាងណា រ៉ាត្ដ ទាំងឡាយ ជាគ្រឿងប្រាកដរបស់គ្រហស្ថ នៃព្រះបច្ចេកសម្ពុទ្ធនោះ ក៏ដាច់ជ្រុះ យ៉ាងនោះដែរ ហេតុនោះ (លោកពោលថា) ដូចរលួសផ្ទុង ដែលជម្រុះស្ទឹក ។

[២៦៨] ពាក្យថា វីរបុរស កាត់ចំណងរបស់គ្រហស្ថទាំងឡាយ អធិប្បាយថា ឈ្មោះថាវីរបុរស ព្រោះហេតុមានសេចក្ដីព្យាយាម ។ ឈ្មោះ ថាវីរបុរស ព្រោះហេតុជាអ្នកអាច ។ ឈ្មោះថាវីរបុរស ព្រោះហេតុ ញ៉ាំងសេចក្ដីព្យាយាមឲ្យកើត ។ ឈ្មោះថាវីរបុរស ព្រោះហេតុមាន ចិត្ដអង់អាច ។ ឈ្មោះថាវីរបុរស ព្រោះហេតុជាអ្នកហ៊ាន ។ ឈ្មោះ ថាវីរបុរស ព្រោះហេតុជាអ្នកមោះមុត មិនខ្ជាច មិនរន្ធត់ មិនស្រឡាំង កាំង មិនរត់ លះបង់សេចក្ដីខ្ជាចនិងសេចក្ដីញ័រចំប្រប់ហើយ ប្រាស ចាកសេចក្ដីព្រឺរោម ។

ព្រះខីណាស្រព រៀរចាកបាបទាំងពួង ក្នុងលោក
នេះឯង មានការព្យាយាមជាលំនៅ កន្ទ្ធងទុក្ខក្នុងនរក
លោកមានព្យាយាម មានសេចក្ដីប្រឹងប្រែង ជាអ្នកនឹង
ធឹង មានសភាពដូច្នោះ ទើបលោកហៅថា វីរបុរស ។

គិហិពន្ធនានិ វុច្ចន្តិ បុត្តា ច ទាសីទាសា ច អជេឡកា ច កុក្កុដសូករា ច ហត្ថិគវាស្សវឡវា ច ខេត្តញ្ច វត្ថុ ច ហិរញ្ញញ្ច សុវណ្ណញ្ច គាមនិគមរាជធានិយោ ច រដ្ឋញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច យង្កិញ្ចិ រជនីយវត្ថុ ។ ឆេត្វាន វីរោ គិហិពន្ធនានីតិ សោ បច្ចេកសម្ពុទ្ធោ វីរោ គិហិពន្ធនានិ ឆិន្ទិត្វា សមុច្ឆិន្ទិត្វា ជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ ឆេត្វាន វីរោ គិហិពន្ធនានិ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

ឱរោបយិត្វា គិហិព្យញ្ជនានិ
សញ្ឆិន្នបត្តោ យថា កោវិឡារោ
ឆេត្វាន វីរោ គិហិពន្ធនានិ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

ខគ្គវិសាណសុត្តនិទ្ទេស

ពួកកូន ខ្ញុំស្រី និងខ្ញុំប្រុស ពពែ និងចៀម មាន់ និងជ្រូក ដំរី គោ សេះឈ្មោល សេះញី ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ បន្ទាយ ឃ្លាំង និងវត្ថុជាទីត្រេកត្រអាលណាមួយ លោកហៅថា ចំណងរបស់គ្រហស្ថ ។ ពាក្យថា វីរបុរស កាត់ចំណង របស់គ្រហស្ថទាំងឡាយ បានសេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាវីរបុរស កាត់ ក្របែល លះ បន្ទោបង់ ធ្វើឲ្យវិនាសនូវចំណងរបស់គ្រហស្ថទាំងឡាយ ធ្វើឲ្យដល់នូវកិរិយាលែងកើត ហេតុនោះ (លោកពោលថា) វីរបុរស កាត់ចំណងរបស់គ្រហស្ថទាំងឡាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

> វីរបុរស លះបង់វត្ថុទាំងឡាយ ជាគ្រឿងប្រាកដ
> របស់គ្រហស្ថ កាត់ចំណងរបស់គ្រហស្ថទាំងឡាយ
> ដូចរលួសផ្ទុង ដែលជម្រុះស្ងឹក គប្បីប្រព្រឹត្តម្នាក់
> ឯង ដូចកុយរមាស ។

[២៦៩] សចេ លភេថ និបកំ សហាយំ
សទ្ធឹចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតិមា ។

[២៧០] សចេ លភេថ និបកំ សហាយន្តិ ស-
ចេ និបកំ បណ្ឌិតំ បញ្ញវន្តំ ពុទ្ធិមន្តំ ញាណី វិការី
មេធាវី សហាយំ លភេយ្យ បដិលភេយ្យ អធិគច្ឆ-
យ្យ វិន្ទេយ្យាតិ សចេ លភេថ និបកំ សហាយំ ។

[២៧១] សទ្ធឹចរំ សាធុវិហារិ ធីរន្តិ សទ្ធឹចរន្តិ
ឯកតោ ចរំ ។ សាធុវិហារិន្តិ បឋមេនបិ ឈានេន
សាធុវិហារី ទុតិយេនបិ ឈានេន តតិយេនបិ ឈា-
នេន ចតុត្ថេនបិ ឈានេន សាធុវិហារី មេត្តាយបិ
ចេតោវិមុត្តិយា សាធុវិហារី ការុណាយបិ មុទិ-
តាយបិ ឧបេក្ខាយបិ ចេតោវិមុត្តិយា សាធុវិហារី

[២៦៩] *បើបុគ្គល បានសម្ងាញ់ មានប្រាជ្ញាចាស់ទុំ ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ អាចគ្របសង្កត់អន្តរាយទាំងពួងបាន គប្បីមានស្មារតី មានចិត្តត្រេកអរ ប្រព្រឹត្តនៅជាមួយសម្ងាញ់នោះចុះ ។*

[២៧០] *ពាក្យថា បើបុគ្គលបានសម្ងាញ់ មានប្រាជ្ញាចាស់ទុំ គឺ បើបុគ្គលគប្បីបាន គប្បីជួប គប្បីប្រទះ គប្បីពើបពះ នូវសម្ងាញ់ មានប្រាជ្ញាចាស់ទុំ ជាបណ្ឌិត ជាបញ្ញវន្ត មានសេចក្តីចេះ មានសេចក្តីដឹង មានសេចក្តីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ (លោកពោលថា) បើបុគ្គលបានសម្ងាញ់ មានប្រាជ្ញា ។*

[២៧១] *អធិប្បាយពាក្យថា ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ ត្រង់ពាក្យថា ជាអ្នកប្រព្រឹត្តត្រូវគ្នា គឺ ប្រព្រឹត្តក្នុងមុខការជាមួយគ្នា ។ ពាក្យថា មានការនៅប្រពៃ គឺ មានការនៅដ៏ប្រពៃ ដោយបឋមជ្ឈានក៏បាន មានការនៅដ៏ប្រពៃ ដោយទុតិយជ្ឈានក៏បាន ដោយតតិយជ្ឈានក៏បាន ដោយចតុត្ថជ្ឈានក៏បាន មានការនៅដ៏ប្រពៃ ដោយចេតោវិមុត្តិគឺមេត្តាក៏បាន មានការនៅដ៏ប្រពៃដោយចេតោវិមុត្តិ គឺករុណាក៏បាន មុទិតាក៏បាន ឧបេក្ខាក៏បាន មានការ*

អាកាសានញ្ចាយតនសមាបត្តិយាបិ សាធុវិហារី វិ-ញ្ញាណញ្ចាយតនសមាបត្តិយាបិ អាកិញ្ចញ្ញាយតនស-មាបត្តិយាបិ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា-បិ សាធុវិហារី និរោធសមាបត្តិយាបិ សាធុវិហារី ផលសមាបត្តិយាបិ សាធុវិហារី ។ ជីវន្តិ ជីវំ បណ្ហា-តំ បញ្ញវន្តំ ពុទ្ធិមន្តំ ញាណី វិការី មេធាវិន្តិ សទ្ធឹចរំ សាធុវិហារិ ជីវំ ។

[២៧២] អកិកុយ្យ សញ្ញានិ បរិស្សយានីតិ បរិ-ស្សយាតិ ទ្វេ បរិស្សយា ចាកកជបរិស្សយា ច បដិ-ច្ចន្ទបរិស្សយា ច ។ បេ ។ ឥមេ រុច្ចន្តិ ចាកកជបរិ-ស្សយា ។ បេ ។ ឥមេ រុច្ចន្តិ បដិច្ចន្ទបរិស្សយា ។ អកិកុយ្យ សញ្ញានិ បរិស្សយានីតិ សញ្ញានិ បរិស្សយា-និ អកិកុយ្យ អកិកវិត្វា អជ្ឌោត្ថរិត្វា បរិយាទយិត្វាតិ អកិកុយ្យ សញ្ញានិ បរិស្សយានិ ។

នៅដ៏ប្រពៃ ដោយអាកាសានញ្ចាយតនសមាបត្តិក៏បាន មានការនៅ
ដ៏ប្រពៃ ដោយវិញ្ញាណញ្ចាយតនសមាបត្តិក៏បាន ដោយអាកិញ្ចញ្ញាយ-
តនសមាបត្តិក៏បាន ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិក៏បាន មាន
ការនៅដ៏ប្រពៃ ដោយនិរោធសមាបត្តិក៏បាន មានការនៅដ៏ប្រពៃ ដោយ
ផលសមាបត្តិក៏បាន ។ ពាក្យថា ជាអ្នកប្រាជ្ញ គឺជាអ្នកមានប្រាជ្ញា
ជាបណ្ឌិត ជាបញ្ញវន្ត មានសេចក្តីចេះ មានសេចក្តីដឹង មានសេចក្តី
យល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្ងាយកិលេស ហេតុនោះ (លោក
ពោលថា) ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ ។

[២៧២] អធិប្បាយពាក្យថា គ្របសង្កត់អន្តរាយទាំងពួង ត្រង់
ពាក្យថា អន្តរាយ បានដល់ អន្តរាយ ២ គឺ អន្តរាយ ប្រាកដ ១ អន្តរាយ
កំបាំង ១ ។ បេ ។ ទាំងនេះ ហៅថា អន្តរាយប្រាកដ ។ បេ ។ ទាំង
នេះហៅថា អន្តរាយកំបាំង ។ ពាក្យថា គ្របសង្កត់អន្តរាយទាំងពួង
បានសេចក្តីថា គ្រប គ្របសង្កត់ បង្ក្រាប រួបរឹត នូវពួកអន្តរាយ
ទាំងពួង ហេតុនោះ (លោកពោលថា) គ្របសង្កត់អន្តរាយទាំង
ពួង ។

[២៧៣] ចវេយ្យ តេនត្តមនោ សតិមាតិ សោ បច្ចេកសម្ពុទ្ធោ តេន ឯបកេន បណ្ហិតេន បញ្ញវ-ន្តេន ពុទ្ធិមន្តេន ញាណិនា វិភាវិនា មេធាវិនា សហាយេន សទ្ធឹ អត្តមនោ តុដ្ឋមនោ ហដ្ឋមនោ បហដ្ឋមនោ ឧទគ្គមនោ បមុទិតមនោ ចវេយ្យ វិចវេ-យ្យ[1] ឥរិយេយ្យ វត្តេយ្យ ចាលេយ្យ យបេយ្យ យា-បេយ្យាតិ ចវេយ្យ តេនត្តមនោ ។ សតិមាតិ សោ បច្ចេកសម្ពុទ្ធោ សតិមា ហោតិ បរមេន សតិនេ-បកេន សមន្នាគតោ ចិរកតំបិ ចិរភាសិតំបិ សរិតា អនុស្សរិតាតិ ចវេយ្យ តេនត្តមនោ សតិមា ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

---

១ ម. វិហរេយ្យ ។

[២៧៣] ពាក្យថា គប្បីមានស្មារតី មានចិត្តត្រេកអរ ប្រព្រឹត្តនៅជាមួយសម្ងាញ់នោះចុះ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ មានចិត្តត្រេកអរ មានចិត្តសប្បាយ មានចិត្តរីករាយ មានចិត្តស្រស់ស្រាយ មានចិត្តអណ្តែត មានចិត្តពព្រាយ គប្បីត្រាច់ទៅ គប្បីទៅផ្សេងៗ ទៅប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ជាមួយនឹងសម្ងាញ់ ជាអ្នកមានប្រាជ្ញាចាស់ទុំ ជាបណ្ឌិត ជាបញ្ញវន្ត មានសេចក្តីចេះ មានសេចក្តីដឹង មានសេចក្តីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេសនោះ ហេតុនោះ (លោកពោលថា) គប្បីមានចិត្តត្រេកអរ ប្រព្រឹត្តនៅ ជាមួយសម្ងាញ់នោះចុះ ។ ពាក្យថា មានស្មារតី គឺព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលមានស្មារតី ប្រកបដោយស្មារតីនិងប្រាជ្ញាដ៏ក្រៃលែង រឭក រឭកឃើញនូវអំពើដែលលោកធ្វើយូរមកហើយផង នូវពាក្យដែលលោកពោលយូរមកហើយផង ហេតុដូច្នោះ (លោកពោលថា) គប្បីមានស្មារតី មានចិត្តត្រេកអរ ប្រព្រឹត្តនៅជាមួយសម្ងាញ់នោះចុះ ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ខគ្គវិសាណសុត្តនិទ្ទេសោ

សចេ លភេថ និបកំ សហាយំ
សទ្ធឹចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតិមាតិ ។

[២៧៤] នោ ចេ លភេថ និបកំ សហាយំ
សទ្ធឹចរំ សាធុវិហារិ ធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[២៧៥] នោ ចេ លភេថ និបកំ សហាយន្តិ នោ ចេ និបកំ បណ្ឌិតំ បញ្ញវន្តំ ពុទ្ធិមន្តំ ញា-ណី វិការី មេធាវី សហាយំ លភេយ្យ បដិល-ភេយ្យ អនិកនេ្ជយ្យ វិនេ្ជយ្យាតិ នោ ចេ លភេថ និបកំ សហាយំ ។

បើបុគ្គលបានសម្ងាញ់ មានប្រាជ្ញាចាស់ទុំ ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ អាចគ្របសង្កត់អន្តរាយទាំងពួងបាន គប្បីមានស្មារតី មានចិត្តត្រេកអរ ប្រព្រឹត្តនៅជាមួយសម្ងាញ់នោះចុះ ។

[២៧៦] *បើបុគ្គលរកមិនបានសម្ងាញ់ មានប្រាជ្ញាចាស់ទុំ ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញទេ គប្បីប្រព្រឹត្តម្នាក់ឯង ដូចព្រះរាជាលះបង់ដែនដែលទ្រង់ឈ្នះហើយ ឬដូចកុយរមាស ។*

[២៧៧] *ពាក្យថា បើបុគ្គលរកមិនបានសម្ងាញ់មានប្រាជ្ញាចាស់ទុំ គឺ បើបុគ្គលរកមិនបាន មិនជួប មិនប្រទះ មិនពើបពះ នូវសម្ងាញ់ដែលមានប្រាជ្ញាចាស់ទុំ ជាបណ្ឌិត ជាបញ្ញវន្ត មានសេចក្តីចេះ មានសេចក្តីដឹង មានសេចក្តីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេសហេតុនោះ (លោកពោលថា) បើបុគ្គលរកមិនបានសម្ងាញ់មានប្រាជ្ញាចាស់ទុំ ។*

[២៧៦] សទ្ធឹចរំ សាធុវិហារិ ជីវន្តិ សទ្ធឹចរន្តិ ឯកតោ ចរំ ។ សាធុវិហារិន្តិ បឋមេនបិ ឈានេន សាធុវិហារី ។ បេ ។ ឯកេ ឧសមាបត្តិយាបិ សាធុវិ-ហារី ផលសមាបត្តិយាបិ សាធុវិហារី ។ ជីវន្តិ ជីវំ បណ្ហិតំ បញ្ញវន្តំ ពុទ្ធិមន្តំ ញាណី វិការី មេធាវិន្តិ សទ្ធឹចរំ សាធុវិហារិ ជីវំ ។

[២៧៧] រាជាវ រដ្ឋំ វិជិតំ បហាយាតិ រាជា ខត្តិយោ មុទ្ធាភិសិត្តោ វិជិតសង្គ្រាមោ ឯកាតបច្ចា-មិត្តោ លទ្ធាធិប្ប្រាយោ បរិបុណ្ណកោដ្ឋាគារោ រដ្ឋញ្ច ជនបទញ្ច កោដ្ឋាគារញ្ច បហាតហិរញ្ញសុវណ្ណោ ឧតរ-ញ្ច បរិចូជិត្វា កេសមស្សុំ ឱហារេត្វា កាសា-យានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិត្វា អកិញ្ចនភាវំ ឧបគន្ត្វា ឯកោ ចរតិ វិចរតិ ឥរិយតិ វត្តេតិ ចាលេតិ យបេតិ យាបេតិ ឯវំ បច្ចេកសម្ពុទ្ធោបិ សញ្ញំ ឃរាវាសបលិពោធំ ឆិន្ទិត្វា

[២៧៦] *អធិប្បាយពាក្យថា ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ ត្រង់ពាក្យថា ជាអ្នកប្រព្រឹត្តត្រូវគ្នា គឺជាអ្នកប្រព្រឹត្តក្នុងមុខការជាមួយគ្នា ។ ពាក្យថា មានការនៅប្រពៃ គឺមានការនៅប្រពៃ ដោយបឋមជ្ឈានក៏បាន ។ បេ ។ មានការនៅប្រពៃ ដោយនិរោធសមាបត្តិក៏បាន មានការនៅប្រពៃ ដោយផលសមាបត្តិក៏បាន ។ ពាក្យថា ជាអ្នកប្រាជ្ញ គឺជាអ្នកមានប្រាជ្ញា ជាបណ្ឌិត ជាបញ្ញវន្ត មានសេចក្តីចេះ មានសេចក្តីដឹង មានសេចក្តីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ (លោកពោលថា) ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ ។*

[២៧៧] *ពាក្យថា ដូចព្រះរាជាលះបង់ដែន ដែលទ្រង់ឈ្នះហើយ អធិប្បាយថា ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេក បានឈ្នះសង្គ្រាម បានកម្ចាត់បច្ចាមិត្រ បានសម្រេចតាមព្រះបំណងហើយ មានឃ្វាំងបរិបូណ៌ ទ្រង់លះបង់ដែនផង ជនបទផង ឃ្វាំងដាក់ប្រាក់និងមាសច្រើនផង នគរផង ហើយកោរព្រះកេសនិងព្រះមស្សុ ទ្រង់កាសាយពស្ត្រ ចេញចាកដំណាក់ ហើយទ្រង់ព្រះផ្នួស ដល់នូវភាពមិនមានកង្វល់ ត្រាច់ត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ មួយអង្គឯង (យ៉ាងណា) ឯព្រះបច្ចេកសម្ពុទ្ធ កាត់សេចក្តីកង្វល់ក្នុងឃរាវាសទាំងអស់*

ខគ្គវិសាណសុត្តនិទ្ទេសោ

បុត្តជាវបលិពោធំ ឆិន្ទិត្វា ញាតិបលិពោធំ ឆិន្ទិត្វា មិត្តាមច្ចបលិពោធំ ឆិន្ទិត្វា តោសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អការស្មា អនការិយំ បព្វជិត្វា អកិញ្ចនភាវំ ឧបគន្ត្វា ឯកោ ចរតិ វិចរតិ ឥរិយតិ វត្តេតិ ចាលេតិ យបេតិ យាបេតីតិ ភជាវ រដ្ឋំ វិជិតំ បហាយ ។ ឯកោ ចរ ខគ្គវិសា-ណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

ជោ ចេ លភេថ និបកំ សហាយំ
សទ្ធឹចរំ សាធុវិហារិ ធីរំ
ភជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរ ខគ្គវិសាណកប្បោតិ ។

[២៧៨] អត្ថា បសំសាម សហាយសម្បទំ
សេដ្ឋា សមា សេវិតព្វា សហាយា
ឯតេ អលត្ថា អនវជ្ជភោជី
ឯកោ ចរ ខគ្គវិសាណកប្បោ ។

កាត់សេចក្ដីកង្វល់ក្នុងកូននិងប្រពន្ធ កាត់សេចក្ដីកង្វល់ក្នុងញាតិ កាត់សេចក្ដីកង្វល់ក្នុងមិត្តនិងអាមាត្យ ការសក់ពុកមាត់ពុកចង្កា ស្លៀកដណ្ដប់កាសាយពស្ត្រ ចេញចាកគេហដ្ឋាន ហើយដល់នូវភាពមិនមានកង្វល់ត្រាច់ ត្រាច់ទៅផ្សេង ៗ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅតែម្នាក់ឯង ក៏យ៉ាងនោះ ហេតុនោះ (លោកពោលថា) ដូចព្រះរាជាលះបង់ដែន ដែលទ្រង់ឈ្នះហើយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បើបុគ្គលរកមិនបានសម្ងាញ់ មានប្រាជ្ញាចាស់ទុំ ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញទេ គប្បីប្រព្រឹត្តម្នាក់ឯង ដូចព្រះរាជាលះបង់ដែន ដែលទ្រង់ឈ្នះហើយ ឬដូចកុយរមាស ។

[២៧៨] តាមពិត យើងសរសើរនូវការបរិបូណ៌ដោយសម្ងាញ់ហើយ តែបុគ្គលគួរគប់រកសម្ងាញ់ មានគុណប្រសើរជាងខ្លួន និងសម្ងាញ់មានគុណស្មើនឹងខ្លួន បើរកមិនបានសម្ងាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគភោជនមិនមានទោស ហើយប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៧៩] អត្ថា បសំសាម សហាយសម្បទន្តិ អត្ថា-
តិ ឯកំសវចនំ និស្ឆិតវចនំ និក្ខន្ថវចនំ អនេជ្ជ-
វចនំ អនេជ្ជកវចនំ និយោតវចនំ អបណ្ណកវចនំ
អវត្ថានវចនមេតំ អត្ថាតិ ។ សហាយសម្បទន្តិ
សហាយសម្បទា រុច្ចតិ យោ សោ សហាយោ
អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ
អសេក្ខេន សមាធិក្ខន្ធេន អសេក្ខេន បញ្ញាខន្ធេន
អសេក្ខេន វិមុត្តិក្ខន្ធេន អសេក្ខេន វិមុត្តិញ្ញាណ-
ទស្សនក្ខន្ធេន សមន្នាគតោ ហោតិ ។ អត្ថា បសំ-
សាម សហាយសម្បទន្តិ សហាយសម្បទំ បសំសា-
ម ថោមេម កិត្តេម វណ្ណេមាតិ អត្ថា បសំសាម
សហាយសម្បទំ ។

[២៨០] សេដ្ឋា សមា សេវិតព្ពា សហាយាតិ
សេដ្ឋា ហោន្តិ សហាយា សីលេន សមាធិនា ប-
ញ្ញាយ វិមុត្តិយា វិមុត្តិញ្ញាណទស្សនេន សមា ហោន្តិ

[២៧៩] *អធិប្បាយពាក្យថា តាមពិត យើងសរសើរនូវការបរិបូណ៌ដោយសម្ងាញ់ហើយ ត្រង់ពាក្យថា តាមពិត គឺ ជាពាក្យពោលដោយចំណែកមួយ ជាពាក្យពោលដោយឥតមានសង្ស័យ ជាពាក្យពោលដោយឥតងឿងឆ្ងល់ ជាពាក្យមិនបែកជាពីរ ជាពាក្យមិនព្រែកជាពីរ ជាពាក្យប្រកបអស់ដើង ជាពាក្យមិនខុស ពាក្យថា តាមពិត នុ៎ះ ជាពាក្យកំណត់ ។ ពាក្យថា ការបរិបូណ៌ដោយសម្ងាញ់ សេចក្តីថា ដែលហៅថា ការបរិបូណ៌ដោយសម្ងាញ់ បានដល់សម្ងាញ់ ប្រកបដោយអសេក្ខសីលក្ខន្ធ ប្រកបដោយអសេក្ខសមាធិក្ខន្ធ ដោយអសេក្ខប្ញញ្ញាខន្ធ ដោយអសេក្ខវិមុត្តិក្ខន្ធ ដោយអសេក្ខវិមុត្តិញ្ញាណទស្សនក្ខន្ធ ។ ពាក្យថា តាមពិត យើងសរសើរនូវការបរិបូណ៌ ដោយសម្ងាញ់ហើយ គឺ យើងសរសើរ ស្ទើច កោត ថ្វៃងគុណ នូវការបរិបូណ៌ដោយសម្ងាញ់ ហេតុនោះ (លោកពោលថា) តាមពិត យើងសរសើរនូវការបរិបូណ៌ដោយសម្ងាញ់ហើយ ។*

[២៨០] *ពាក្យថា បុគ្គលគួរគប់រកសម្ងាញ់ មានគុណប្រសើរជាងខ្លួន និងសម្ងាញ់មានគុណស្មើនឹងខ្លួន អធិប្បាយថា សម្ងាញ់ជាបុគ្គលប្រសើរជាងដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ*

សហាយា សីលេន សមាធិនា បញ្ញាយ វិមុត្តិយា វិមុត្តិញ្ញាណទស្សនេន សេដ្ឋា វ សហាយា សមា ។ សហាយា សេវិតព្វា ភជិតព្វា បយិរុ្ទបាសិតព្វា បរិបុច្ឆិតព្វា បរិបញ្ហិតព្វាតិ សេដ្ឋា សមា សេវិតព្វា សហាយា ។

[២៨១] ឯតេ អលទ្ធា អនវជ្ជភោជីតិ អត្ថិ បុក្ក-លោ សាវជ្ជភោជី អត្ថិ បុក្ខលោ អនវជ្ជភោជី ។

 កតមោ ច បុក្ខលោ សាវជ្ជភោជី ។ ឥធេក-ច្ចោ បុក្ខលោ ឃុមានាយ លបនាយ នេមិត្តក-តាយ និប្បេសិកតាយ លាភេន លាភំ និជិគីសន-តាយ ជារុជានេន រេជ្ជុជានេន បត្តជានេន បុប្ផ-ជានេន[1] សិនានជានេន ចុណ្ណជានេន មត្តិកជា-នេន ទន្តកដ្ឋជានេន មុខោទកជានេន ចាតុក-ម្យតាយ មុក្ខសូបតាយ ចារិកជ្ជតាយ បរបិដ្ឋ-មំសិកតាយ រត្តវិជ្ជាយ ឥរ្ឋានវិជ្ជាយ អង្គ-វិជ្ជាយ ឧក្ខត្តវិជ្ជាយ ទូតកម្មនេន បហីនកម្មនេន

1 ម. បុប្ផទានេន ផលទានេន ។

សម្ងាញ់ ជាបុគ្គលស្មើដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញា-ណទស្សនៈ បុគ្គលត្រូវសេពគប់ ត្រូវគប់រក ត្រូវចូលទៅអង្គុយជិត ត្រូវសាកសួរ ត្រូវដេញដោល នូវសម្ងាញ់មានគុណប្រសើរជាងខ្លួន ឬសំ-ឡាញ់មានគុណស្មើនឹងខ្លួន ហេតុនោះ (លោកពោលថា) បុគ្គលគួរគប់រកសម្ងាញ់មានគុណប្រសើរជាងខ្លួននិងសម្ងាញ់មានគុណស្មើនឹងខ្លួន ។

[២៨១] *ពាក្យថា បើរកមិនបានសម្ងាញ់ ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគភោជនមិនមានទោស អធិប្បាយថា បុគ្គលបរិភោគភោជនប្រកបដោយទោសក៏មាន បុគ្គលបរិភោគភោជនមិនមានទោសក៏មាន ។*

ចុះបុគ្គលបរិភោគភោជន ប្រកបដោយទោស តើដូចម្តេច ។ បុគ្គលខ្ទះក្នុងលោកនេះ បាន ចួប ប្រទះ ពើបពះ ប្រសព្ធ ដោយអធម៌មិនរាបទាបហើយចិញ្ចឹមជីវិត គឺដោយកិរិយាបំភាន់ កិរិយារួសរ៉ាវ កិរិយាបញ្ជិតបញ្ជៀង កលល្បិច កិរិយាស្ទង់លាភដោយលាភ ដោយការឲ្យឈើ ឲ្យឫស្សី ឲ្យស្ទឹកឈើ ឲ្យផ្ការ ឲ្យគ្រឿងសម្រាប់ងូត ឲ្យលំអិត ឲ្យដីស្អិត ឲ្យឈើស្ទន់ ឲ្យទឹកសម្រាប់លាងមុខ ដោយការបន្ទាបខ្លួនចំពោះត្រកូល ដោយសម្ដីដូចជាសម្ងសណ្ដែកបាយ ដោយការបី-ពបញ្ជិះសេះកូនត្រកូល ដោយការស៊ីសាច់ខ្នងគេ ដោយវត្ថុវិជ្ជា តិរច្ឆានវិជ្ជា អង្គវិជ្ជា នក្ខត្តវិជ្ជា ដោយធ្វើទូតេយ្យកម្ម ហើយទៅ ដោយការទៅកាន់ទីដែលគេប្រើទៅ

ជង្ឃប្បេសនីយេន វេជ្ជកម្មេន ទូតកម្មេន បិណ្ឌប្បដិបិណ្ឌកេន ទានានុប្បទានេន អធម្មេន វិសមេន លទ្ធា លភិត្វា បដិលភិត្វា អធិគន្ត្វា វិន្ទិត្វា ជីវិកំ[១] កប្បេតិ អយំ វុច្ចតិ បុគ្គលោ សាវជ្ជភោជី ។

កតមោ ច បុគ្គលោ អនវជ្ជភោជី ។ ឥធេកច្ចោ បុគ្គលោ ន កុហនាយ ន លបនាយ ន នេមិត្តកតាយ ន និប្បេសិកតាយ ន លាភេន លាភំ និជិគីសនតាយ ន ទារុទានេន ន វេឡុទានេន ន បត្តទានេន ន បុប្ផទានេន[២] ន សិនានទានេន ន ចុណ្ណទានេន ន មត្តិកាទានេន ន ទន្តកដ្ឋទានេន ន មុខោទកទានេន ន ចាតុកម្យតាយ ន មុគ្គសូបតាយ ន ចារិភដ្យតាយ ន បរបិដ្ឋិមំសិកតាយ ន វត្ថុវិជ្ជាយ ន តិរច្ឆានវិជ្ជាយ ន អង្គវិជ្ជាយ ន នក្ខត្តវិជ្ជាយ ន ទូតគមនេន ន បហីនគមនេន ន ជង្ឃប្បេសនីយេន ន វេជ្ជកម្មេន ន ទូតកម្មេន ន

---

១ ម. ជីវិតំ ។ ២ ម. ន បុប្ផទានេន ន ផលទានេន ។

ដោយការបម្រើគេដោយស្នង ដោយវេជ្ជកម្ម ទូតកម្ម ដោយដុំបាយតបដុំបាយ ដោយការឲ្យវត្ថុដែលគេឲ្យដល់ខ្លួនវិញ នេះ លោកហៅថា បុគ្គល បរិភោគភោជនប្រកបដោយទោស ។

ចុះបុគ្គលបរិភោគភោជន មិនមានទោស តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បាន ចួប ប្រទះ ពើបពះ ប្រសព្ធ ដោយធម៌ដ៏រាបទាប ហើយចិញ្ចឹមជីវិត គឺ មិនមែនដោយការបំភាន់ មិនមែនដោយការរួសរ៉ាវ មិនមែនដោយការបញ្ជិតបញ្ជៀង មិនមែនដោយកលល្បិច មិនមែនដោយការស្វែងលាភដោយលាភ មិនមែនដោយការឲ្យឈើ មិនមែនដោយការឲ្យឫស្សី មិនមែនដោយការឲ្យស្លឹកឈើ មិនមែនដោយការឲ្យផ្កាឈើ មិនមែនដោយការឲ្យគ្រឿងសម្រាប់ផ្ងូត មិនមែនដោយការឲ្យលំអិត មិនមែនដោយការឲ្យដីស្អិត មិនមែនដោយការឲ្យឈើស្នង់ មិនមែនដោយការឲ្យទឹកសម្រាប់លាងមុខ មិនមែនដោយការបន្ទន់បន្ទាបខ្លួនចំពោះត្រកូល មិនមែនដោយសម្តីដូចសម្ងសណ្ដែកបាយ មិនមែនដោយការបី-ពបញ្ជិះសេះកូនត្រកូល មិនមែនដោយការស៊ីសាច់ខ្នងគេ មិនមែនដោយវត្ថុវិជ្ជា មិនមែនដោយតិរច្ឆានវិជ្ជា មិនមែនដោយអង្គវិជ្ជា មិនមែនដោយនក្ខត្តវិជ្ជា មិនមែនដោយទូតេយ្យ-កម្មហើយទៅ មិនមែនដោយកិរិយាទៅកាន់ទីដែលគេបញ្ជូនទៅ មិនមែនដោយការបម្រើគេដោយស្នង មិនមែនដោយវេជ្ជកម្ម មិនមែនដោយទូតកម្ម

បិណ្ឌាឃ្យជិបិណ្ឌាកោន ន ជានានុឃ្យជានេន ឆម្មេន សមេន លទ្ធា លភិត្វា បដិលភិត្វា អធិគន្ត្វា វិន្ទិ-ត្វា ជីវិកំ កប្បេតិ អយំ វុច្ចតិ បុគ្គលោ អនវជ្ជ-ភោជី ។

ឯតេ អលទ្ធា អនវជ្ជភោជីតិ ឯតេ អលទ្ធា អលភិត្វា អប្បដិលភិត្វា អនធិគន្ត្វា អវិន្ទិត្វាតិ ឯតេ អលទ្ធា អនវជ្ជភោជី ។ ឯកោ ចរេ ខគ្គវិសាណ-កប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

អទ្ធា បសំសាម សហាយសម្បទំ
សេដ្ឋា សមា សេវិតព្វា សហាយា
ឯតេ អលទ្ធា អនវជ្ជភោជី
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[២៨២] ឧិស្វា សុវណ្ណស្ស បភស្សរានិ
កម្មារបុត្តេន សុនិដ្ឋិតានិ
សង្ឃ្ជ្ជយន្តានិ ឧរេ ភុជស្មឹ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

មិនមែនដោយដុំបាយតបដុំបាយ មិនមែនដោយការឲ្យនូវវត្ថុដែលគេឲ្យដល់ខ្លួនវិញ នេះលោកហៅថា បុគ្គលបរិភោគភោជនមិនមានទោស ។

ពាក្យថា បើរកមិនបានសម្ងាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគភោជនមិនមានទោស គឺ មិនបាន មិនជួប មិនប្រទះ មិនពើបពះ មិនប្រសព្វនូវសម្ងាញ់នុ៎ះ ហេតុនោះ (លោកពោលថា) បើរកមិនបានសម្ងាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគភោជនមិនមានទោស ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

តាមពិត យើងសរសើរ នូវការបរិបូណ៌ដោយសម្ងាញ់ ហើយ តែបុគ្គលគួរគប់រកសម្ងាញ់មានគុណប្រសើរជាងខ្លួន និងសម្ងាញ់មានគុណស្មើនឹងខ្លួន បើរកមិនបានសម្ងាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគភោជនមិនមានទោស ហើយប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៨២] បុគ្គលឃើញកងមាសទាំងពីរ ដ៏ភ្លឺផ្លេកៗ ដែលកម្មារបុត្ត ធ្វើសម្រេចល្អហើយ ទង្គិចគ្នា ឮដ៏ដែ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៨៣] និស្វា សុវណ្ណស្ស បកស្សរានីតិ និស្វា បស្សិត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ សុវណ្ណស្សាតិ ជាតរូបស្ស ។ បកស្សរានីតិ បរិសុទ្ធានិ បរិយោទាតានីតិ និស្វា សុវណ្ណស្ស បក-ស្សរានិ ។

[២៨៤] កម្មារបុត្តេន សុនិដ្ឋិតានីតិ កម្មារបុត្តោ វុច្ចតិ សុវណ្ណការោ ។ កម្មារបុត្តេន សុនិដ្ឋិតានីតិ កម្មារបុត្តេន សុនិដ្ឋិតានិ សុកតានិ សុបរិកម្មានីតិ កម្មារបុត្តេន សុនិដ្ឋិតានិ ។

[២៨៥] សង្ឃដ្ដយន្តានិ ទុវេ ភុជស្មិន្តិ ភុជោ វុច្ចតិ ហត្ថោ ។ យថា ឯកស្មឹ ហត្ថេ ទ្វេ នុវរានិ ឃដេន្តិ ឯវមេវ សត្តា តណ្ហាវសេន ឃដេន្តិ តិរច្ឆា-នយោនិយំ ឃដេន្តិ បិត្តិវិសយេ ឃដេន្តិ មនុស្ស-លោកេ ឃដេន្តិ ទេវលោកេ ឃដេន្តិ គតិយា គតឹ ឧបបត្តិយា ឧបបត្តឹ បដិសន្ធិយា បដិ-សន្ធឹ ភវេន ភវំ សំសារេន សំសារំ វដ្ដេន វដ្ដំ

[២៨៣] *ពាក្យថា ឃើញកងមាស ដ៏ក្ងីផ្ទេកៗ គឺ ឃើញ មើល ស្ងង់ ត្រួត បញ្ជាក់ ធ្វើឲ្យច្បាស់ ។ ពាក្យថា មាស គឺ ជាតរូប ។ ពាក្យថា ក្ងីផ្ទេកៗ គឺស្អាត ផ្ងូរផង់ ហេតុនោះ (លោកពោលថា) ឃើញ កងមាស ដ៏ក្ងីផ្ទេក ។ ។*

[២៨៤] *ពាក្យថា ដែលកម្មារបុត្តធ្វើសម្រេចល្អហើយ សេចក្ដីថា ជាងមាស លោកហៅថា កម្មារបុត្ត ។ ពាក្យថា ដែលកម្មារបុត្ត ធ្វើសម្រេចល្អហើយ បានសេចក្ដីថា ដែលកម្មារបុត្តឲ្យសម្រេចល្អហើយ ធ្វើល្អហើយ មានការសម្រិតសម្រាំងល្អហើយ ហេតុនោះ (លោកពោល ថា) ដែលកម្មារបុត្តធ្វើសម្រេចល្អហើយ ។*

[២៨៥] *ពាក្យថា កងមាសទាំងពីរ ដែលទង្គិចគ្នា ឮដ៏ដៃ អធិប្បាយ ថា ហត្ថ លោកហៅថា ដៃ ។ កងមាសទាំងពីរ ឮដ៏ដៃមួយ ទង្គិចគ្នា យ៉ាងណា ពួកសត្វតែងទង្គិច ដោយអំណាចតណ្ហា គឺទង្គិចក្នុងកំណើត តិរច្ឆាន ទង្គិចក្នុងបិត្តិវិស័យ ទង្គិចក្នុងមនុស្សលោក ទង្គិចក្នុងទេវលោក គឺថា ទង្គិច ត្រាច់ នៅ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ កាន់ គតិ ដោយគតិ កាន់ឧបបត្តិ ដោយឧបបត្តិ កាន់បដិសន្ធិ ដោយបដិសន្ធិ កាន់ភព ដោយភព កាន់សង្សារ ដោយសង្សារ កាន់វដ្ដៈ ដោយវដ្ដៈ*

ឃដេន្តិ ចរន្តិ វិហរន្តិ ឥរិយន្តិ វត្តេន្តិ ចាលេន្តិ យបេន្តិ យាបេន្តីតិ សង្ឃដ្ដយន្តានិ ខុវ ភុជស្មឿ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

ជិណ្ណា សុវណ្ណាសុ បភស្សរានិ
ឆម្ភារបុត្តេន សុនិដ្ឋិតានិ
សង្ឃដ្ដយន្តានិ ខុវ ភុជស្មឿ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[២៨៦] ឯវំ ខុតិយេន សហា មមស្ស
ឱចាកិលាចោ អកិសជ្ជនា ឯ
ឯតំ ភយំ អាយតឺ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[២៨៧] ឯវំ ខុតិយេន សហា មមស្សាតិ តណ្ហាខុតិយេន ។ តណ្ហាខុតិយោ ឯ ហោតិ បុត្ត-លខុតិយោ ឯ ។ ឯកមិ តណ្ហាខុតិយោ ហោតិ ។ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្ពតណ្ហា ធម្មតណ្ហា ។ យស្សេសា តណ្ហា អប្ប្ហីនា សោ រុច្ចតិ តណ្ហាខុតិយោ ។

ហេតុនោះ (លោកពោលថា) កងមាសទាំងពីរ ដែលទង្គិចគ្នា ឲ្យដ៏ដែ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធ នោះ ពោលថា

> បុគ្គលឃើញ កងមាសទាំងពីរ ដ៏ភ្ជឿផ្ទេកៗ ដែល
> កម្មារបុត្ត ធ្វើសម្រេចល្អហើយ ទង្គិចគ្នា ឲ្យដ៏ដែ
> គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។
> [២៨៦] ការរួសរាយ ដោយវាចាក្តី ការជាប់ចំពាក់ក្តី
> ជាមួយនឹងបុគ្គលជាគម្រប់ពីរ របស់អញ យ៉ាងនេះ
> បុគ្គលកាលសម្ងឹងឃើញភ័យនុ៎ះ ក្នុងអនាគត គប្បី
> ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៨៧] អធិប្បាយពាក្យថា ជាមួយនឹងបុគ្គលជាគម្រប់ពីរ របស់អញ យ៉ាងនេះ គឺ បុគ្គល មានតណ្ហាជាគម្រប់ពីរ ។ បុគ្គលមានតណ្ហាជាគម្រប់ពីរក៏មាន មានបុគ្គលជាគម្រប់ពីរក៏មាន ។ បុគ្គលមានតណ្ហាជាគម្រប់ពីរ តើដូចម្តេច ។ ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ បុគ្គលណាមិនបានលះបង់តណ្ហានេះ បុគ្គលនោះ លោកហៅថា មានតណ្ហាជាគម្រប់ពីរ ។

តណ្ហាឧតិយោ បុរិសោ ឧីឃមទ្ធាន សំសរំ
ឥត្ថភាវញ្ញថាភាវំ សំសារំ ជាតិវត្តតិ[1] ។

ឯវំ តណ្ហាឧតិយោ ហោតិ ។ កថំ បុត្តលឧតិយោ ហោតិ ។ ឥធេកច្ចោ ន អត្តហេតុ ន ការណហេ-តុ ឧទ្ធតោ អវូបសន្តចិត្តោ ឯកស្ស វា ឧតិយោ ហោតិ ទ្វិន្នំ វា តតិយោ ហោតិ តិណ្ណំ វា ចតុត្ថោ ហោតិ តត្ត ពហុំ សម្ផប្ផលាបំ លបតិ សេយ្យថីទំ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយ-កថំ យុទ្ធកថំ អន្នកថំ ចានកថំ វត្ថកថំ មាលា-កថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ បុរិសកថំ សូរកថំ វិសិក្ខាកថំ កុម្ភដ្ឋានកថំ លោកក្ខាយិកំ សមុទ្ទ-ក្ខាយិកំ ឥតិភវាភវកថំ ឥតិ វា កថេតិ ឯវំ បុត្តល-ឧតិយោ ហោតីតិ ឯវំ ឧតីយេន សហ មមស្ស ។

---

1 ម. នាតិវត្តតីតិ ។

បុរស មានតណ្ហាជាគម្រប់ពីរ តែងអន្ទោលទៅអស់កាលយូរ មិនប្រព្រឹត្តកន្ទ ងនូវសង្សារដែលមានភាពនេះនិងភាពដទៃបានទេ ។

បុគ្គលមានតណ្ហាជាគម្រប់ពីរ យ៉ាងនេះឯង ។ បុគ្គលមានបុគ្គលគម្រប់ពីរ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពាយមាយ មានចិត្តមិនស្ងប់រម្ងាប់ មិនមែនព្រោះហេតុខ្លួន មិនមែនព្រោះហេតុដំណើរទេ ជាគម្រប់ពីរនឹងបុគ្គលមួយនាក់ក៏មាន ជាគម្រប់បី នឹងបុគ្គលពីរនាក់ក៏មាន ជាគម្រប់បួន នឹងបុគ្គលបីនាក់ក៏មាន និយាយសម្ផប្បលាបៈ ច្រើនក្នុងទីនោះ គឺ និយាយរាជកថា ចោរកថា មហាមត្តកថា សេនាកថា ភយកថា យុទ្ធកថា អន្នកថា បានកថា វត្ថកថា មាលាកថា ញាតិកថា យានកថា គាមកថា និគមកថា នគរកថា ជនបទកថា ឥត្ថីកថា បុរិសកថា សូរកថា វិសិក្ខាកថា កុម្ភដ្ឋានកថា លោកក្ខាយិកកថា សមុទ្ទក្ខាយិកកថា ឥតិភវាភវកថា ដូច្នេះ។ ខ្លះ បុគ្គល មានបុគ្គលជាគម្រប់ពីរ យ៉ាងនេះឯង ហេតុនោះ (លោកពោលថា) ជាមួយនឹងបុគ្គលជាគម្រប់ពីរ របស់អញ យ៉ាងនេះ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

[២៨៨] វាចាកិលាចោ អកិសជ្ជនា វាតិ វាចាកិ-លាចោ រុច្ចតិ ពត្តឹស តិរច្ឆានកថា សេយ្យថីទំ រាជកថា ចោរកថា ។ បេ ។ ឥតិភវាភវកថា ឥតិ វា ។ អកិសជ្ជនាតិ ទ្វេ សជ្ជនា តណ្ហាសជ្ជនា ច ទិដ្ឋិសជ្ជនា ច ។ បេ ។ អយំ តណ្ហាសជ្ជនា ។ បេ ។ អយំ ទិដ្ឋិសជ្ជនាតិ វាចាកិលាចោ អកិសជ្ជនា វា ។

[២៨៩] ឯតំ ភយំ អាយតឹ បេក្ខមានោតិ ភយ-ន្តិ ជាតិភយំ ជរាភយំ ព្យាធិភយំ មរណភយំ រាជ-ភយំ ចោរភយំ អគ្គិភយំ ឧទកភយំ អត្តានុវាទ-ភយំ បរានុវាទភយំ ទណ្ឌភយំ ទុគ្គតិភយំ ឱ្ឆិត-យំ ការ្ម្ភិលភយំ អាវដ្ដភយំ សុំសុការភយំ[1] អាជី-វិការភយំ អសិលោកភយំ បរិសារជ្ជភយំ[2] ភយានកំ ឆម្ភិតត្តំ លោមហំសោ ចេតសោ ឧព្វេគ្គោ ឧត្រាសោ ។ ឯតំ ភយំ អាយតឹ បេក្ខមានោតិ

---

១ ម. សុសុមារភយំ ។ ២ ម. បរិសារជ្ជភយំ មទនភយំ ។

ខគ្គវិសាណសុត្តនិទ្ទេស

[២៨៨] ពាក្យថា ការរួសរាយដោយវាចាក្តី ការជាប់ចំពាក់ក្តី អធិប្បាយថា ការរួសរាយដោយវាចា លោកសំដៅយកតិរច្ឆានកថា ៣២ គឺ រាជកថា ចោរកថា ។ បេ ។ ឥតិភវាភវកថា ដូច្នេះៗ ខ្ញុះ ។ ពាក្យថា ការជាប់ចំពាក់ បានដល់ការជាប់ចំពាក់ ២ គឺ ការជាប់ចំពាក់គឺតណ្ហា ១ ការជាប់ចំពាក់គឺទិដ្ឋិ ១ ។ បេ ។ នេះ ការជាប់ចំពាក់គឺតណ្ហា ។ បេ ។ នេះ ការជាប់ចំពាក់គឺទិដ្ឋិ ហេតុនោះ (លោកពោលថា) ការរួសរាយដោយវាចាក្តី ការជាប់ចំពាក់ក្តី ។

[២៨៩] អធិប្បាយពាក្យថា បុគ្គលកាលសម្ងឹងឃើញភ័យនុ៎ះ ក្នុងអនាគត ត្រង់ពាក្យថា ភ័យ បានដល់ភ័យអំពីជាតិ ភ័យអំពីជរា ភ័យអំពីព្យាធិ ភ័យអំពីមរណៈ ភ័យអំពីព្រះរាជា ភ័យអំពីចោរ ភ័យអំពីភ្លើង ភ័យអំពីទឹក ភ័យអំពីការតិះដៀលរបស់ខ្លួន ភ័យអំពីការតិះដៀលរបស់បុគ្គលដទៃ ភ័យអំពីអាជ្ញា ភ័យអំពីទុគ្គតិ ភ័យអំពីរលក ភ័យអំពីក្រពើ ភ័យអំពីកន្ទ្រែងទឹកវល់ ភ័យអំពីធ្វាម ភ័យអំពីការចិញ្ចឹមជីវិត ភ័យអំពីដំណៀល ភ័យអំពីការញ្ជ្រៀតបរិស័ទ អារម្មណ៍គួរស្បើម សេចក្តីរន្ធត់ សេចក្តីព្រឺរោម សេចក្តីតក់ស្ទុតចិត្ត សេចក្តីស្រឡាំងកាំងចិត្ត ។ ពាក្យថា បុគ្គលកាលសម្ងឹងឃើញភ័យនុ៎ះ ក្នុងអនាគត

ឯតំ ភយំ អាយតឹ បេក្ខមានោ ឧក្ខមានោ ឱ-លោកយមានោ ឧជ្ឈាយមានោ ឧបបរិក្ខមានោតិ ឯតំ ភយំ អាយតឹ បេក្ខមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកស-ម្ពុទ្ធោ

ឯវំ ឧតីយេន សហា មមស្ស
ភាចាកិលាចោ អកិសជ្ជនា ភ
ឯតំ ភយំ អាយតឹ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[២៩០] កាមា ហិ ចិត្រា មធុភ មនោរមា
វិរូបរូបេន មថេន្តិ ចិត្តំ
អាទីនវំ កាមគុណេសុ ឥស្ម
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[២៩១] កាមា ហិ ចិត្រា មធុភ មនោរមាតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេ-សកាមា ច ។ បេ ។ ឥមេ រុច្ចន្តិ វត្ថុកាមា ។ បេ ។

សេចក្ដីថា បុគ្គលកាលសម្ងឹងឃើញ មើល រមិលមើល ពិនិត្យ ជញ្ជឹងនូវភ័យនុ៎ះក្នុងអនាគត ហេតុនោះ (លោកពោលថា) បុគ្គលកាលសម្ងឹងឃើញភ័យនុ៎ះ ក្នុងអនាគត ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

> ការរួសរាយ ដោយវាចាក្ដី ការជាប់ចំពាក់ក្ដី ជាមួយនឹងបុគ្គលជាគម្រប់ពីរ របស់អញ យ៉ាងនេះ បុគ្គលកាលសម្ងឹងឃើញភ័យនុ៎ះ ក្នុងអនាគត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។
>
> [២៩០] ពិតណាស់ កាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ ជាទីត្រេកអរនៃចិត្ត តែងញ៉ាំញៀចិត្ត ដោយសភាពនៃរូបផ្សេង ៗ បុគ្គលឃើញទោស ក្នុងកាមគុណទាំង-ឡាយហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៩១] អធិប្បាយពាក្យថា ពិតណាស់ កាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ ជាទីត្រេកអរនៃចិត្ត ត្រង់ពាក្យថា កាម តាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះហៅថា វត្ថុកាម

ខគ្គវិសាណសុត្តនិទ្ទេសោ

ឥមេ វុច្ចន្តិ កិលេសកាមា ។ ចិត្រាតិ នានាវណ្ណរូបា នានាវណ្ណសទ្ទា នានាវណ្ណគន្ធា នានាវណ្ណរសា នានាវណ្ណផោដ្ឋព្វា ។ មធុរាតិ វុត្តញ្ហេតំ ភគវតា បញ្ចិមេ ភិក្ខវេ កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមុបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមុបសញ្ហិតា រជនីយា ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណា យំ ខោ ភិក្ខវេ ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ ឥទំ វុច្ចតិ កាមសុខំ មិឡ្ហសុខំ បុថុជ្ជនសុខំ អនរិយសុខំ ន សេវិតព្វំ ន ភជិតព្វំ ន ភាវេតព្វំ ន ពហុលីកាតព្វំ ភាយិតព្វំ ឯតស្ស សុខស្សាតិ វទាមីតិ កាមា ហិ ចិត្រា មធុរា ។

ฯ លេ ฯ ទាំងនេះហៅថា កិលេសកាម ฯ ពាក្យថា ដ៏វិចិត្រ គឺរូបមានបែបផ្សេងៗ សំឡេងមានបែបផ្សេងៗ ក្លិនមានបែបផ្សេងៗ រសមានបែបផ្សេងៗ ផោដ្ឋព្វ:មានបែបផ្សេងៗ ฯ ពាក្យថា មានរសធ្វាញ់ សេចក្តីថា មែនពិត ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ កាមគុណ ៥ គឺអ្វីខ្លះ គឺ រូបដែលត្រូវដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីស្រឡាញ់ ជាទីគាប់ចិត្ត មានភាពជាទីស្រឡាញ់ ប្រកបដោយកាម គួរឲ្យត្រេកត្រអាល ១ សំឡេងដែលត្រូវដឹងដោយសោត: ១ ក្លិនដែលត្រូវដឹងដោយឃាន: ១ រសដែលត្រូវដឹងដោយជិវ្ហា ១ ផោដ្ឋព្វ: ដែលត្រូវដឹងដោយកាយ ជាទីប្រាថ្នា ជាទីស្រឡាញ់ ជាទីគាប់ចិត្ត មានភាពជាទីស្រឡាញ់ ប្រកបដោយកាម គួរឲ្យត្រេកត្រអាល ១ ម្នាលភិក្ខុទាំងឡាយ នេះឯង កាមគុណ ៥ ម្នាលភិក្ខុទាំងឡាយ សុខ សោមនស្សណា កើតឡើងព្រោះអាស្រ័យកាមគុណ ៥ នេះ សុខ សោមនស្សនេះ តថាគតហៅថា សុខក្នុងកាម សុខដូចលាមក សុខរបស់បុថុជ្ជន សុខមិនប្រសើរ តថាគតពោលថា បុគ្គលមិនគួរសេព មិនគួរគប់ មិនគួរចម្រើន មិនគួរធ្វើឲ្យរឿយៗ បុគ្គលគួរខ្លាចសុខនុ៎ះ ហេតុនោះ (លោកពោលថា) ពិតណាស់ កាមទាំងឡាយ ដ៏វិចិត្រ មានរសធ្វាញ់ ฯ

មនោវមាតិ មនោតិ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ។

[២៩២] វិរូបរូបេន មថេន្តិ ចិត្តន្តិ នានាវណ្ណេហិ រូបេហិ ។ បេ ។ នានាវណ្ណេហិ ផោដ្ឋព្វេហិ ចិត្តំ មថេន្តិ តាសេន្តិ[១] ហាបេន្តិ បហាបេន្តីតិ វិរូបរូបេន មថេន្តិ ចិត្តំ ។

[២៩៣] អាទីនវំ កាមគុណេសុ ទិស្វាតិ វុត្តំ ហេតំ ភគវតា កោ ច ភិក្ខវេ កាមានំ អាទីនវោ ឥធ ភិក្ខវេ កុលបុត្តោ យេន សិប្បដ្ឋានេន ជីវិកំ កប្បេតិ យទិ មុទ្ទាយ យទិ គណនាយ យទិ សង្ខាយ យទិ កសិយា យទិ វណិជ្ជាយ យទិ គោរក្ខេន យទិ ឥស្សត្ថេន យទិ រាជបោរិសេន យទិ សិប្បាយតនេន សីតស្ស បុរក្ខតោ ឧណ្ហស្ស បុរក្ខតោ ឌំសមកសវាតាតបសិរឹសបសម្ផស្សេហិ រិស្សមានោ ខុប្បិបាសាយ មិយ្យមានោ[២]

១ ម. តោសេន្តិ ។ ២ ម. បិឡិយមានោ ។

ពាក្យថា ជាទីត្រេកអរនៃចិត្ត ត្រង់ពាក្យថា ចិត្ត បានដល់ ចិត្ត មនៈ មានសៈ ហទយៈ បណ្ឌរៈ មនៈ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណក្ខន្ធនោះ ។

[២៩២] ពាក្យថា តែងញ៉ាំញ៉ីចិត្ត ដោយសភាពនៃរូបផ្សេងៗ គឺ តែងញ៉ាំញ៉ី ញ៉ាំងចិត្តឲ្យតក់ស្ទុត ឲ្យសាបសូន្យ ឲ្យសាបរលាបដោយ រូបទាំងឡាយ មានបែបផ្សេងៗ ។ បេ ។ ដោយផោដ្ឋព្វៈទាំងឡាយ មានបែបផ្សេងៗ ហេតុនោះ (លោកពោលថា) តែងញ៉ាំញ៉ីចិត្ត ដោយ សភាពនៃរូបផ្សេងៗ ។

[២៩៣] ពាក្យថា បុគ្គលឃើញទោស ក្នុងកាមគុណទាំងឡាយ អធិប្បាយថា មែនពិត ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ទោសរបស់កាមទាំងឡាយ តើដូចម្តេច ម្នាល ភិក្ខុទាំងឡាយ កុលបុត្រក្នុងលោកនេះ ចិញ្ចឹមជីវិត ដោយថ្នាក់នៃសិប្ប: ណា គឺ ការរាប់ដោយដៃទទេក្តី ការរាប់មិនជាច់ក្តី ការរាប់ហ្ជូកក្តី ការ ក្ជួរវាស់ក្តី ជំនួញក្តី ការរក្សាគោក្តី ការកាន់អាវុធបម្រើក្តី ភាពជារាជបុរស ក្តី សិប្ប: មានហត្ថិសិប្ប:ជាដើមក្តី ជាអ្នកត្រូវត្រជាក់ហ្ជៀតហ្ជៀន ត្រូវ ក១ម្ដៅហ្ជៀតហ្ជៀន ប៉ះ ទង្គិច ទង្គ្ជុក ដោយសមួសរ្ស នៃរបោម មូស ខ្យល់ ក១ម្ដៅថ្ងៃ និងសត្វលូន ស្ងាប់ដោយគម្ងាននិងសម្រេក

ខគ្គវិសាណសុត្តនិទ្ទេសោ

អយំ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខ-ក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិការណំ កាមានមេវ ហេតុ តស្ស ចេ ភិក្ខវេ កុលបុត្តស្ស ឋវំ ឧដ្ឋហតោ ឃដតោ វាយមតោ តេ ភោគា ជ-ភិនិប្ផជ្ជន្តិ សោ សោចតិ កិលមតិ បរិទេវតិ ឧរត្តា-ឬ្ឍ_ កន្ទតិ សម្មោហំ អាបជ្ជតិ មោឃំ វត មេ ឧ-ដ្ឋានំ អផលោ វត មេ វាយាមោតិ អយម្ឪ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាម-ហេតុ កាមនិទានំ កាមាធិការណំ កាមានមេវ ហេតុ តស្ស ចេ ភិក្ខវេ កុលបុត្តស្ស ឋវំ ឧដ្ឋហ-តោ ឃដតោ វាយមតោ តេ ភោគា អភិនិប្ផជ្ជន្តិ សោ តេសំ ភោគានំ អារក្ខាធិការណំ ទុក្ខទោមន-ស្ស_ បដិសំវេទេតិ កិន្តិ មេ ភោគេ នេវ រាជានោ ហរេយ្យុ ន ចោរា ហរេយ្យុ ន អគ្គិ ឌហេយ្យ ន ឧទកំ វហេយ្យ ន អ_ប្ឪិយា ទាយាទា ហរេយ្យុន្តិ

ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ម្នាលភិក្ខុទាំងឡាយ បើកាលកុលបុត្រនោះ ខ្នះខ្នែង ប្រឹងប្រែង ព្យាយាមយ៉ាងម្ល៉ះហើយ ភោគៈទាំងនោះ មិនសម្រេចទេ កុលបុត្រនោះ តែងក្រៀមក្រំ លំបាក ខ្សឹកខ្សួល កន្ទក់កន្ទេញ គក់ទ្រូង ដល់នូវសេចក្តីវង្វេងងោងងកថា ការប្រឹងប្រែងរបស់អញ ឥតអំពើហើយតើ សេចក្តីព្យាយាមរបស់អញ មិនមានផលហើយតើ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ម្នាលភិក្ខុទាំងឡាយ បើកាលកុលបុត្រនោះ ខ្នះខ្នែង ប្រឹងប្រែង ព្យាយាមយ៉ាងម្ល៉ះហើយ ភោគៈទាំងនោះ សម្រេច កុលបុត្រនោះ ក៏គង់រងទុក្ខនិងទោមនស្ស ដែលមានការហួងហែងភោគៈទាំងនោះ ជាហេតុថា ធ្វើដូចម្តេច កុំឲ្យព្រះរាជានាំយកទៅបាន កុំឲ្យចោរនាំយកទៅបាន កុំឲ្យភ្លើងឆេះ កុំឲ្យទឹកនាំយកទៅបាន កុំឲ្យពួកជនជាទាយាទមិនជាទីស្រឡាញ់នាំយកទៅបាន នូវភោគៈទាំងឡាយរបស់អញ

តស្ស ឯវํ អារក្ខោ គោបយតោ តេ ភោគេ ភជាគោ វ ហរន្តិ ចោរា វ ហរន្តិ អគ្គិ វ ឌហតិ ឧទកํ វ វហតិ អប្បិយា ឌាយាទា វ ហរន្តិ សោ សោចតិ ។ បេ ។ សម្ភោហํ អាបជ្ជតិ យម្ប៎ិ មេ អហោសិ តម្ប៎ិ នោ នត្ថីតិ អយម្ប៎ិ ភិក្ខវេ ការណំ អាឌីនវោ សន្ទិដ្ឋិកោ ឧក្ខក្ខោ ការមហេតុ ការមនិទានํ ការមាធិការ-ណํ ការមានមេវ ហេតុ ។ បុន ចបរํ ភិក្ខវេ ការមហេតុ ការមនិទានํ ការមាធិការណํ ការមានមេវ ហេតុ ភជាគោបិ ភជ្ជហិ រាជនិ ខត្តិយាបិ ខត្តិយេ-ហិ រាជនិ ព្រាហ្មណាបិ ព្រាហ្មណេហិ រាជនិ គហ-បតីបិ គហបតីហិ រាជនិ មាតាបិ បុត្តេន រាជតិ បុត្តោបិ មាតរា រាជតិ បិតាបិ បុត្តេន រាជតិ បុត្តោ-បិ បិតរា រាជតិ ភាតាបិ ភគិនិយា រាជតិ ភគិនីបិ ភាតរា រាជតិ សហាយោបិ សហាយេន រាជតិ តេ តត្ត ការណហេតុ ការណនិទានា អញ្ញមញ្ញ ចាណីហិបិ ឧប-ក្ខមន្តិ លេឌ្ឌូហិបិ ឧបក្ខមន្តិ ឌណ្ឌេហិបិ ឧបក្ខមន្តិ

កាលបើកុលបុត្រនោះ ហួងហែង គ្រប់គ្រង យ៉ាងម្ះ៉ះហើយ ព្រះរាជ ទាំងឡាយនាំយកទៅក្តី ចោរទាំងឡាយនាំយកទៅក្តី ភ្លើងឆេះក្តី ទឹក នាំទៅក្តី ពួកជនជាទាយាទមិនជាទីស្រឡាញ់នាំយកទៅក្តី នូវភោគៈទាំង-ឡាយនោះ កុលបុត្រនោះ តែងក្រៀមក្រំ ។ បេ ។ ដល់នូវសេចក្តីផេងផ ងោងថា ទ្រព្យណា របស់អញមានហើយ អញមិនមានទ្រព្យនោះវិញ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញ ផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើម ចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។ ម្នាល ភិក្ខុទាំងឡាយ មួយទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ពួកព្រះរាជ ក៏វិវាទដោយពួកព្រះរាជ ពួកក្សត្រិយ៍ក៏វិវាទដោយពួកក្សត្រិយ៍ ពួក ព្រាហ្មណ៍ក៏វិវាទដោយពួកព្រាហ្មណ៍ ពួកគហបតីក៏វិវាទដោយពួកគហបតី មាតាក៏វិវាទដោយបុត្រ បុត្រក៏វិវាទដោយមាតា បិតាក៏វិវាទដោយបុត្រ បុត្រក៏វិវាទដោយបិតា បងប្អូនប្រុសក៏វិវាទដោយបងប្អូនស្ត្រី បងប្អូនស្ត្រី ក៏វិវាទដោយបងប្អូនប្រុស សម្វាញ់ក៏វិវាទដោយសម្វាញ់ ពួកជន នោះដល់នូវជម្លោះ និងការវិវាទ ក្នុងទីនោះ ប្រហារគ្នាដោយដៃខ្លះ

ខគ្គវិសាណសុត្តនិទ្ទេសោ

សត្ថេហិបិ ឧបក្កមន្តិ តេ តត្ថ មរណម្បិ និកច្ឆន្តិ[១] មរណមត្តម្បិ ទុក្ខំ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិការណំ កាមានមេវ ហេតុ ។ បុន ចបរំ ភិក្ខវេ កាមហេតុ កាមនិទានំ កាមាធិការណំ កាមានមេវ ហេតុ អសិចម្មំ តហេត្វា ឆនុកាលាបំ សន្ធយ្ហិត្វា ឧភតោវិយូឡ្ហ[២] សង្គ្រាមំ បក្ខន្ទន្តិ ឧសូ-សុបិ ទិប្ផមានេសុ សត្តីសុបិ ទិប្ផមានាសុ អសីសុបិ វិជ្ជោតលន្តេសុ[៣] តេ តត្ថ ឧសូហិបិ វិជ្ឈន្តិ សត្តីហិបិ វិជ្ឈន្តិ អសិនាបិ សីសំ ឆិន្ទន្តិ តេ តត្ថ មរណម្បិ និកច្ឆន្តិ មរណមត្តម្បិ ទុក្ខំ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិការណំ កាមានមេវ ហេតុ ។

---

១ ម. គច្ឆន្តិ ។ ២ ម. ឧភតោវ្យូឡ្ហំ ។ ៣ ម. រជ្ជោតន្តេសុ ។

ប្រហារគ្នាដោយដុំដីខ្លះ ប្រហារគ្នាដោយដំបងខ្លះ ប្រហារគ្នាដោយសស្ត្រាខ្លះ ពួកជននោះ ដល់នូវសេចក្ដីស្លាប់ខ្លះ ដល់នូវទុក្ខស្ទើរស្លាប់ខ្លះ ព្រោះតែការប្រហារគ្នានោះ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ជនទាំងឡាយក៏កាន់ដាវនិងខែល សៀតធ្នូនិងបំពង់ព្ជួញ ហើយរុករានគង្គានទៅកាន់សង្គ្រាម ដែលពពាក់ពពួនទាំងសងខាង កាលបើព្ជួញទាំងឡាយ ដែលគេបាញ់ទៅខ្លះ លំពែងទាំងឡាយដែលគេពួយទៅខ្លះ ដាវទាំងឡាយដែលគេគ្រវីគ្រវាត់ខ្លះ ជនទាំងនោះបាញ់ដោយព្ជួញទាំងឡាយ ក្នុងសង្គ្រាមនោះខ្លះ ចាក់ដោយលំពែងទាំងឡាយខ្លះ កាត់ក្បាលដោយដាវខ្លះ ជនទាំងនោះ ដល់នូវសេចក្ដីស្លាប់ខ្លះ ដល់នូវទុក្ខស្ទើរស្លាប់ខ្លះ ក្នុងសង្គ្រាមនោះ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។

បុន ចបរំ ភិក្ខវេ កាមហេតុ កាមនិទានំ កាមា-
ធិការណំ កាមានមេវ ហេតុ អសិចម្មំ តហេត្វា
ឆត្តុកលាបំ សន្ធយ្ហិត្វា អង្ខារលេបនា ឧបការិយោ
បក្ខន្ទន្តិ ឧសូសុបិ ទិប្ឆមានេសុ សត្តីសុបិ ទិប្ឆ-
មានាសុ អសីសុបិ វិជ្ជោតលន្តេសុ តេ តត្ថ ឧសូ-
ហិបិ វិជ្ឈន្តិ សត្តីហិបិ វិជ្ឈន្តិ ឆកណាដិយាបិ[1]
ឋិសិញ្ចន្តិ អភិវក្ខេន ឋិមន្ទន្តិ អសិនាបិ សីសំ ឆិន្ទន្តិ
តេ តត្ថ មរណម្ប៎ិ ឯកច្ចន្តិ មរណមត្តម្ប៎ិ ឧក្ខ
អយម្ប៎ិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ
ឧក្ខ្ចក្ខ្ចោ កាមហេតុ កាមនិទានំ កាមាធិការណំ
កាមានមេវ ហេតុ ។ បុន ចបរំ ភិក្ខវេ កាមហេតុ
កាមនិទានំ កាមាធិការណំ កាមានមេវ ហេតុ
សន្ធិម្ប៎ិ ឆិន្ទន្តិ និលោ្ហបម្ប៎ិ ឌីហន្តិ ឯកាតារិកម្ប៎ិ
ឧកេ្ខ្ចន្តិ បរិបន្ថេបិ តិដ្ឋន្តិ បរទារម្ប៎ិ ឧបគ្ចន្តិ
តមេនំ រាជានោ ឧហេត្វា វិវិធា ឧកម្មការណា
ការេន្តិ ឧសាហិបិ តាឡេន្តិ វេត្តេហិបិ តាឡេន្តិ

---

1 ម. ឆកកាឋិយាបិ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ជនទាំងឡាយ ក៏កាន់ដាវនិងខែល សៀតធ្នូនិងបំពង់ព្ជួញ រុកវានគង្គានទៅកាន់ជើងកំ-ពែង មានប៉ម្ដមដែលបូកដោយបាយអ កាលបើព្ជួញទាំងឡាយដែលគេ បាញ់ទៅខ្លះ លំពែងទាំងឡាយដែលគេពួយទៅខ្លះ ដាវទាំងឡាយដែល គេគ្រវីគ្រវាត់ខ្លះ ជនទាំងនោះបាញ់ដោយព្ជួញទាំងឡាយ ក្នុងសង្គ្រាម នោះខ្លះ ចាក់ដោយលំពែងទាំងឡាយខ្លះ ស្រោចចុះដោយអាចម៍គោ កំពុងពុះខ្លះ ច្រំដោយអាវុធមានធ្នេញ ៧ ខ្លះ កាត់ក្បាលដោយដាវខ្លះ ជន ទាំងនោះដល់នូវសេចក្ដីស្ងាប់ខ្លះ ដល់នូវទុក្ខស្ទើរស្ងាប់ខ្លះ ក្នុងសង្គ្រាមនោះ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញ ផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើម ចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមតែម្យ៉ាង ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះ កាមជាដើមទង ព្រោះហេតុនៃកាមតែម្យ៉ាង ជនទាំងឡាយកាត់ទីតផ្ទះ ខ្លះ ឫន់ធំខ្លះ ធ្វើនូវការឫន់ផ្ទះមួយខ្លះ ឈរស្ការ៉ាត់ផ្លូវខ្លះ គប់រកប្រពន្ធគេខ្លះ ព្រះរាជាទាំងឡាយ ប្រើឲ្យចាប់ជននោះ ហើយឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺ ឲ្យវាយដោយសែតីទាំងឡាយខ្លះ ឲ្យវាយដោយរំពាត់ផ្ដៅទាំងឡាយខ្លះ

អឌ្ឍឧណ្ហាកោហិបិ តាឡេន្តិ ហត្ថម្ហិ ធិន្ធន្តិ ចាឧម្ហិ ធិន្ធន្តិ ។ បេ ។ អសិនាបិ សីសំ ធិន្ធន្តិ តេ ឥត្ត មរណម្ហិ ជិតច្ចន្តិ មរណមត្តម្ហិ ឧក្ខំ អយម្ហិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ឧក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិការណំ កាមានមេវ ហេតុ ។ បុន ចបរំ ភិក្ខវេ កាមហេតុ កាមនិទានំ កាមាធិការណំ កាមានមេវ ហេតុ កាយេន ឧច្ចរិតំ ចរន្តិ វាចាយ ឧច្ចរិតំ ចរន្តិ មនសា ឧច្ចរិតំ ចរន្តិ តេ កាយេន ឧច្ចរិតំ ចរិត្វា វាចាយ ឧច្ចរិតំ ចរិត្វា មនសា ឧច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អចាយំ ឧក្ខតឹ វិនិចាតំ និរយំ ឧបបជ្ជន្តិ អយម្ហិ ភិក្ខវេ កាមានំ អាទីនវោ សម្ផ្ទាយិកោ ឧក្ខក្ខន្ធោ កាមហេតុ កាម-និទានំ កាមាធិការណំ កាមានមេវ ហេតូតិ ។

ឲ្យដំដោយអន្ទងទាំងឡាយខ្លះ ឲ្យកាត់ដៃខ្លះ ឲ្យកាត់ជើងខ្លះ ។ បេ ។ ឲ្យ
កាត់ក្បាលដោយដាវខ្លះ ជនទាំងនោះ ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវទុក្ខ
ស្ទើរស្លាប់ខ្លះ ព្រោះតែដំណើរនោះ ម្នាលភិក្ខុទាំងឡាយ នេះទោស
របស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង)
ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះ
ហេតុនៃកាមទាំងឡាយតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត
ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះ
ហេតុនៃកាមទាំងឡាយតែម្យ៉ាង ជនទាំងឡាយប្រព្រឹត្តទុច្ចរិតដោយកាយ
ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ជនទាំងនោះ ប្រព្រឹត្ត
ទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ
លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងទុគ្គតិ វិនិបាត នរក
ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលត្រូវឃើញក្នុង
លោកខាងនាយ ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជា
ដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។

អាធីនវំ កាមកុណេសុ ជិស្វាតិ កាមកុណេសុ អាធីនវំ ជិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវ-យិត្វា វិភូតំ កត្វាតិ អាធីនវំ កាមកុណេសុ ជិស្វា ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

កាមា ហិ ចិត្រា មធុរា មនោរមា
វិរូបរូបេន មថេន្តិ ចិត្តំ
អាធីនវំ កាមកុណេសុ ជិស្វា
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[២៩៤] ឆ្លៀតី ច ឥណ្ហោ ច ឧបទ្ទវោ ច
ភោគោ ច សល្ងញ្ច ភយញ្ច មេតំ
ឯតំ ភយំ កាមកុណេសុ ជិស្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[២៩៥] ឆ្លៀតី ច ឥណ្ហោ ច ឧបទ្ទវោ ច ភោគោ ច សល្ងញ្ច ភយញ្ច មេតន្តិ រុត្តញ្ហេតំ ភគ-វតា ភយន្តិ ភិក្ខវេ កាមានមេតំ អធិវចនំ ឧក្ខន្តិ

ពាក្យថា បុគ្គលឃើញទោស ក្នុងកាមគុណទាំងឡាយ បានសេចក្តីថា ឃើញ មើល ថ្វឹង ត្រួត បញ្ជាក់ ធ្វើឲ្យជាក់ នូវទោសក្នុងកាម-គុណទាំងឡាយ ហេតុនោះ (លោកពោលថា) បុគ្គលឃើញទោសក្នុងកាមគុណទាំងឡាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ពិតណាស់ កាមទាំងឡាយ ដ៏វិចិត្រ មានរសធ្ងាញ់
ជាទីត្រេកអរនៃចិត្ត តែងញ៉ាំញ៉ីចិត្ត ដោយសភាពនៃ
រូបផ្សេង បុគ្គលឃើញទោស ក្នុងកាមគុណទាំងឡាយ
ហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៩២] បុគ្គលឃើញភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយថា
នេះជាចង្រៃ ជាបូស ជាឧបទ្រព ជារោគ ជាព្រួញ
និងជាភ័យ របស់អញហើយ គប្បីប្រព្រឹត្តម្នាក់ឯង
ដូចកុយរមាស ។

[២៩៥] ពាក្យថា នេះជាចង្រៃ ជាបូស ជាឧបទ្រព ជារោគ ជាព្រួញ និងជាភ័យរបស់អញ អធិប្បាយថា ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យ នេះជាឈ្មោះនៃកាមទាំងឡាយ

ខគ្គវិសាណសុត្តនិទ្ទេសោ

ភិក្ខវេ កាមានមេតំ អធិវចនំ ហោតោតិ ភិក្ខវេ
កាមានមេតំ អធិវចនំ តណ្ហោតិ ភិក្ខវេ កាមាន-
មេតំ អធិវចនំ លត្តន្តិ[(១)] ភិក្ខវេ កាមានមេតំ អធិ-
វចនំ សត្តោតិ[(២)] ភិក្ខវេ កាមានមេតំ អធិវចនំ
បង្ហោតិ ភិក្ខវេ កាមានមេតំ អធិវចនំ តណ្ហោតិ
ភិក្ខវេ កាមានមេតំ អធិវចនំ យស្មា ច ភិក្ខវេ
ភយន្តិ កាមានមេតំ អធិវចនំ កាមរាគវត្ថាយ
ភិក្ខវេ ឆន្ទរាគវិនិពន្ធো ជិជ្ជធម្មិកាបិ ភយា ន បរិ-
មុចូតិ សម្ជ្ជាយិកាបិ ភយា ន បរិមុចូតិ តស្មា
ភយន្តិ កាមានមេតំ អធិវចនំ យស្មា ច ភិក្ខវេ
ជុក្ខន្តិ ហោតោតិ តណ្ហោតិ លត្តន្តិ សត្តោតិ បង្ហោតិ
តណ្ហោតិ កាមានមេតំ អធិវចនំ កាមរាគវត្ថាយ
ភិក្ខវេ ឆន្ទរាគវិនិពន្ធো ជិជ្ជធម្មិកាបិ តញ្ហា ន
បរិមុចូតិ សម្ជ្ជាយិកាបិ តញ្ហា ន បរិមុចូតិ តស្មា
តណ្ហោតិ កាមានមេតំ អធិវចនន្តិ ។

---

១ ម. សល្លន្តិ ។ ២ ម. សង្ហោតិ ។ ៣ ម. កស្មា ។

ម្នាលភិក្ខុទាំងឡាយ ពាក្យថា ទុក្ខ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា រោគ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បូស នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ការថ្ពក់ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភាវៈជាប់ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភក់ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា គក់ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែពាក្យថា ភ័យ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ បានជាសត្វអ្នកត្រេកត្រអាលដោយកាម-រាគនេះ ជាប់ចំពាក់ដោយឆន្ទរាគ ទើបមិនរួចចាកភ័យ ដែលមានក្នុងបច្ចុ-ប្បន្នផង មិនរួចចាកភ័យដែលមានក្នុងបរលោកផង ព្រោះហេតុនោះ ពាក្យ ថា ភ័យ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ព្រោះ ហេតុតែពាក្យថា ទុក្ខ ថារោគ ថាបូស ថាការថ្ពក់ ថាភាវៈជាប់ ថាភក់ ថាគក់ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ បានជាសត្វ អ្នកត្រេកត្រអាលដោយកាមរាគៈនេះ ជាប់ចំពាក់ដោយឆន្ទរាគ ទើបមិនរួច ចាកគក់ ដែលមានក្នុងបច្ចុប្បន្នផង មិនរួចចាកគក់ដែលមានក្នុងបរលោក ផង ព្រោះហេតុនោះ ពាក្យថា គក់ នេះ ជាឈ្មោះនៃកាមទាំងឡាយ ។

ភយញ្ច ទុក្ខញ្ច រោគោ ច សល្លោ បង្កោ ច ទូភយំ
ឯតេ កាមា បវុច្ចន្តិ យត្ថ សត្តោ បុថុជ្ជនោ
ឱតិណ្ណោ សាតរូបេន កញ្ចាយ ច និគច្ឆតិ ។
យតោ ច ភិក្ខវេ ភិក្ខុ ឈានញ្ច ន រិញ្ចតិ
សោឃំ បលិបថំ ទុគ្គំ អតិក្កម្ម តថាវិធំ
បជំ ជាតិជរូបេតំ ផន្ទមានំ(១) អវេក្ខតីតិ ។
ឦតី ច គណ្ឌោ ច ឧបទ្ទវោ ច រោគោ ច សល្លញ្ច ភយញ្ច មេតំ ។

[២៩៦] ឯតំ ភយំ កាមគុណេសុ ទិស្វាតិ ឯតំ ភយំ កាមគុណេសុ ទិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ឯតំ ភយំ កាមគុណេសុ ទិស្វា ។ ឯកោ ចរេ ខគ្គវិសាណ-កប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

១ ម. ពន្ទមានំ ។

បុថុជ្ជន ជាប់ក្នុងកាមទាំងឡាយណា កាមទាំងឡាយ នុ៎ះ ព្រះមានព្រះភាគត្រាស់ហៅថា ភ័យផង ទុក្ខផង ពោគផង ភារៈជាប់ផង ភក់ផង ធម្មជាតិទាំងពីរគឺ ការថ្ពក់ផង គក់ផង ជាសត្វត្រូវរាគៈមានសភាពធ្ងាញ់ សម្រុតហើយ តែងទៅកាន់គក់ ។ ម្នាលភិក្ខុទាំង-ឡាយ លុះណាតែភិក្ខុ មិនលះបង់ឈាន ទើបភិក្ខុ នោះកន្ទងផ្លូវ មានភក់ គឺកាមនេះ ជាជង្ហុក មាន បែបដូច្នោះ ហើយសម្ងឹងមើល នូវពួកសត្វដែល ប្រកបដោយជាតិនិងជរា កំពុងញញាក់ញញ័រ ។

ហេតុនោះ (លោកពោលថា) នេះជាចង្រៃ ជាបូស ជាឧបទ្រព ជាពោគ ជាព្ងួញ និងជាភ័យ របស់អញ ។

[២៩៦] *ពាក្យថា បុគ្គលឃើញភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយ គឺឃើញ មើល ច្បឹង ត្រួត បញ្ជាក់ ធ្វើឲ្យច្បាស់ នូវភ័យនុ៎ះ ក្នុង កាមគុណទាំងឡាយ ហេតុនោះ (លោកពោលថា) បុគ្គលឃើញភ័យ នុ៎ះ ក្នុងកាមគុណទាំងឡាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា*

ឦតី ច គណ្ឌោ ច ឧបទ្ទវោ ច
រោគោ ច សល្លញ្ច ភយញ្ច មេតំ
ឯតំ ភយំ កាមគុណេសុ ទិស្វា
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[២៩៧] សីតញ្ច ឧណ្ហញ្ច ខុទំ បិបាសំ
វាតាតបេ ឌំសសិរីសបេ ច
សព្វានិបេតានិ អភិសំភវិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[២៩៨] សីតញ្ច ឧណ្ហញ្ច ខុទំ បិបាសន្តិ ទ្វីហិ ការណេហិ សីតំ ហោតិ អព្ភន្តរធាតុបកោបវសេន វា សីតំ ហោតិ ពហិទ្ធាឧតុវសេន វា សីតំ ហោតិ ។ ឧណ្ហន្តិ ទ្វីហិ ការណេហិ ឧណ្ហំ ហោតិ អព្ភន្តរធាតុបកោបវសេន វា ឧណ្ហំ ហោតិ ពហិទ្ធាឧតុវសេន វា ឧណ្ហំ ហោតិ ។ ខុទ្ទា វុច្ចតិ ឆាតកោ ។ បិបាសា វុច្ចតិ ឧទកម្បីតិ សីតញ្ច ឧណ្ហញ្ច ខុទំ បិបាសំ ។

បុគ្គលឃើញភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយថា នេះ ជាចង្រៃ ជាបូស ជាឧបទ្រព ជាពោគ ជាព្ពួញ និងជាភ័យ របស់អញហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៩៧] *បុគ្គលគ្របសង្កត់ នូវធម្មជាតទាំងអស់នុ៎ះ គឺ ត្រជាក់ កម្តៅ គម្ងាន សម្រេក ខ្យល់និងកម្តៅ ថ្ងៃ របោមនិងសត្វលូនហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។*

[២៩៨] *ពាក្យថា ត្រជាក់ កម្តៅ គម្ងាន សម្រេក សេចក្តីថា ត្រជាក់ ដោយហេតុ ២ គឺ ត្រជាក់ដោយអំណាចកម្រើកធាតុខាងក្នុង ឬត្រជាក់ដោយអំណាចរដូវខាងក្រៅ ។ ពាក្យថា កម្តៅ បានដល់ កម្តៅដោយហេតុ ២ គឺ កម្តៅដោយអំណាចកម្រើកធាតុខាងក្នុង ឬ កម្តៅដោយអំណាចរដូវខាងក្រៅ ។ ដែលហៅថា គម្ងាន បានដល់ សេចក្តីឃ្ងាន ។ ដែលហៅថា សម្រេក បានដល់ ការស្រេកទឹក ហេតុនោះ (លោកពោលថា) ត្រជាក់ កម្តៅ គម្ងាន សម្រេក ។*

[២៩៩] ភាគតេ ឪសសិរីសេ ចាតិ ភាគាតិ បុរត្ថិមា ភាគា បច្ឆិមា ភាគា ឧត្តរា ភាគា ទក្ខិណា ភាគា សរជោ ភាគា សីតា ភាគា ឧណ្ហា ភាគា បរិត្តា ភាគា អជិមត្តា ភាគា វេរម្ភភាគា សុបណ្ណភាគា តាលបណ្ណភាគា វិជូបនភាគា ។ អាតចោ វុច្ចតិ សុរិយសន្តាចោ ។ ឪសា វុច្ចន្តិ បិង្គលមក្ខិកា ។ សិរីសបា វុច្ចន្តិ អហីតិ ភាគាតបេ ឪសសិរីសបេ ច ។

[៣០០] សព្វានិ បេតានិ អភិសំភវិត្វាតិ អភិ-ភវិត្វា អជ្ឈោត្ថរិត្វា បរិយាទិយិត្វា មទ្ទិត្វាតិ សព្វានិ បេតានិ អភិសំភវិត្វា ។ ឯកោ ចរេ ខគ្គវិសាណ-កប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

សីតញ្ច ឧណ្ហញ្ច ខុទំ បិចាសំ
ភាគាតបេ ឪសសិរីសបេ ច
សព្វានិ បេតានិ អភិសំភវិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[២៩៩] *ពាក្យថា ខ្យល់និងកម្តៅថ្ងៃ របោមនិងសត្វលូន ត្រង់ពាក្យថា ខ្យល់ គឺខ្យល់ខាងកើត ខ្យល់ខាងលិច ខ្យល់ខាងជើង ខ្យល់ខាងត្បូង ខ្យល់មានធូលី ខ្យល់ត្រជាក់ ខ្យល់ក្តៅ ខ្យល់រំកើយ ខ្យល់យ៉ាងខ្លាំង ខ្យល់កំបុតត្បូង ខ្យល់គ្រុន ខ្យល់ស្វឹកស្នោត ខ្យល់ផ្ទ្រិត ។ ដែលហៅថា កម្តៅថ្ងៃ បានដល់ កម្តៅព្រះអាទិត្យ ។ ដែលហៅថា របោម បានដល់ ពួកមក្ខិកាលឿង ។ ដែលហៅថា សត្វលូន បានដល់ពួកសត្វពស់ ហេតុនោះ (លោកពោលថា) ខ្យល់និងកម្តៅថ្ងៃ របោមនិងសត្វលូន ។*

[៣០០] *ពាក្យថា បុគ្គលគ្របសង្កត់ នូវធម្មជាតទាំងអស់ទុ៎ះ គឺគ្របសង្កត់ បង្ត្រាប សង្កត់សង្កិន ញ្ចាំញ៉ី ហេតុនោះ (លោកពោលថា) បុគ្គលគ្របសង្កត់ នូវធម្មជាតទាំងអស់ទុ៎ះ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា*

បុគ្គលគ្របសង្កត់ នូវធម្មជាតទាំងអស់ទុ៎ះ គឺត្រជាក់ កម្តៅ គម្ងាន សម្រេក ខ្យល់និងកម្តៅថ្ងៃ របោមនិងសត្វលូនហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

ខគ្គវិសាណសុត្តនិទ្ទេសោ

[៣០១] ជាតោវ យូថានិ វិវជ្ជយិត្វា
សញ្ជាតខន្ធោ បឋុមី ឧឬ្ឍ
យថាភិរន្តំ វិហរេ អរញ្ញេ
ឯកោ ចរេ ខគ្គវិសាណកប្ប ។

[៣០២] ជាតោវ យូថានិ វិវជ្ជយិត្វាតិ ជាតោ រុច្ចតិ ហត្ថិជាតោ ។ បច្ចេកសម្ពុទ្ធោបិ ជាតោ ។ ភ្លឹការណា បច្ចេកសម្ពុទ្ធោ ជាតោ ។ អាកុំ ន ករោតីតិ ជាតោ ។ ន ករណ្ដតីតិ ជាតោ ។ ន អាករណ្ដតីតិ ជាតោ ។

ករណ្ដំ សោ បច្ចេកសម្ពុទ្ធោ អាកុំ ន ករោតីតិ ជាតោ ។ អាកូ រុច្ចន្តិ ចាបការ អកុសលា ធម្មា សង្ខ្លិលេសិការ ចោជោពូវិការ សឧរ ឧក្ខូវិចាការ អាយតឹជាតិជរាមរណីយា ។

ខគ្គវិសាណសុត្តនិទ្ទេស

[៣០១] *បុគ្គលដូចនាគ មានខន្ធកើតព្រមហើយ មានសម្បុរផ្ការីឈូក ជាសត្វខ្ពង់ខ្ពស់ គេចចាកហ្វូងហើយនៅក្នុងព្រៃតាមសប្បាយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។*

[៣០២] *ពាក្យថា ដូចនាគ គេចចាកហ្វូង អធិប្បាយថា ដំរីដ៏ប្រសើរ លោកហៅថា នាគ ។ ព្រះបច្ចេកសម្ពុទ្ធ ក៏ឈ្មោះនាគដែរ ។ ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថា នាគ ព្រោះហេតុអ្វី ។ ឈ្មោះថានាគ ព្រោះហេតុមិនធ្វើអំពើអាក្រក់ ។ ឈ្មោះថានាគ ព្រោះហេតុមិនលុះ ។ ឈ្មោះថានាគ ព្រោះហេតុមិនមក ។*

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថានាគ ព្រោះហេតុមិនធ្វើអំពើអាក្រក់ តើដូចម្តេច ។ ធម៌ទាំងឡាយ ជាអកុសល ដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង នាំសត្វឲ្យកើតក្នុងភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ជាទីតាំងនៃជាតិជរានិងមរណៈតទៅ លោកហៅថា អំពើអាក្រក់ ។

អាកុំ ន ការោតីតិ កិញ្ចិ លោកេ
សព្វសំយោគេ វិសជ្ជ ពន្ធនានិ
សព្វត្ត ន សជ្ជតិ វិប្ប មុត្តោ
ជាតោ តាទិ បរុច្ចតេ តថត្តា ។

ឯវំ សោ បច្ចេកសម្ពុទ្ធោ អាកុំ ន ការោតីតិ ជាតោ ។

ការ ចំ សោ បច្ចេកសម្ពុទ្ធោ ន ករោតីតិ ជាតោ ។ សោ បច្ចេកសម្ពុទ្ធោ ន ឆន្ទាគតឹ ករោតិ ន ទោ-សាគតឹ ករោតិ ន មោហាគតឹ ករោតិ ន ភយាគតឹ ករោតិ ន រាគវសេន ករោតិ ន ទោសវសេន ករោតិ ន មោហវសេន ករោតិ ន មានវសេន ករោតិ ន ទិដ្ឋិវសេន ករោតិ ន ឧទ្ធច្ចវសេន ករោតិ ន វិចិកិច្ឆាវសេន ករោតិ ន អនុសយវសេន ករោតិ ន រាគ្គេហិ ឆម្ភេហិ យាយតិ ជិយ្យតិ រុយ្ហតិ សំហរិយតិ ឯវំ សោ បច្ចេកសម្ពុទ្ធោ ន ករោតីតិ ជាតោ ។

ការ ចំ បច្ចេកសម្ពុទ្ធោ ន អាករោតីតិ ជាតោ ។

ព្រះបច្ចេកសម្ពុទ្ធ មិនធ្វើអំពើអាក្រក់តិចតួចក្នុងលោក លះបង់កិលេស ជាគ្រឿងប្រកបទាំងពួង និងចំណងទាំងឡាយ ផុតស្រឡះ មិនជាប់ចំពាក់ក្នុងអារម្មណ៍ទាំងពួង មិនរំភើបដោយលោកធម៌ លោកហៅថា នាគ ព្រោះទ្រង់គុណប្រាកដដូច្នោះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថានាគ ព្រោះហេតុមិនធ្វើនូវអំពើអាក្រក់យ៉ាងនេះឯង ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា នាគ ព្រោះហេតុមិនលុះ តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ មិនលុះឆន្ទាគតិ មិនលុះទោសាគតិ មិនលុះមោហាគតិ មិនលុះកយាគតិ មិនលុះដោយអំណាចរាគ: មិនលុះដោយអំណាចទោស: មិនលុះដោយអំណាចមោហ: មិនលុះដោយអំណាចមាន: មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ច: មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ មិនត្រូវធម៌ជាពួកនាំទៅ ដឹកទៅ បន្សាត់ទៅ ក្ងេចទៅ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថានាគ ព្រោះហេតុមិនលុះ យ៉ាងនេះឯង ។

ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថានាគ ព្រោះហេតុមិនមក តើដូចម្តេច ។

ខគ្គវិសាណសុត្តនិទ្ទេសោ

សោតាបត្តិមគ្គេន យេ កិលេសា បហីនា តេ
កិលេសេ ន បុនេតិ ន បចេតិ ន បច្ចាកច្ឆតិ
សកទាគាមិមគ្គេន អនាគាមិមគ្គេន អរហត្តមគ្គេន
យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ
ន បចេតិ ន បច្ចាកច្ឆតិ ឯវំ សោ បចេកសម្ពុទ្ធោ
ន អាគច្ឆតីតិ ជានាតោ ។ ជានាតោ យូថានិ វិវជ្ជយិ-
ត្វាតិ យថា សោ ហត្ថិជានាតោ យូថានិ វិវជ្ជេត្វា
បរិវជ្ជេត្វា អភិនិវជ្ជេត្វា ឯកោ អរញ្ញេ រមតិ ឯវ
អជ្ឌោតាហេត្វា ចរតិ វិចរតិ ឥរិយតិ វត្តេតិ ចាលេតិ
យបេតិ យាបេតិ បចេកសម្ពុទ្ធោបិ តណ្ហំ វជ្ជេត្វា
បរិវជ្ជេត្វា អភិវជ្ជេត្វា ឯកោ ចរេ ខគ្គវិសាណកប្បោ
អរញ្ញវនបត្ថានិ បន្ថានិ សេនាសនានិ បដិសេវតិ អប្ប-
សទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេ-
យ្យកានិ បដិសល្លានសារុប្បានិ សោ ឯកោ គច្ឆតិ
ឯកោ តិដ្ឋតិ ឯកោ និសីទតិ ឯកោ សេយ្យំ កប្បេតិ

ខគ្គវិសាណសុត្តនិទ្ទេស

កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសោតាបត្តិមគ្គ លោកមិនមក មិនត្រឡប់មក មិនវិលមក រកកិលេសទាំងនោះទៀត កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសកទាគាមិ-មគ្គ អនាគាមិមគ្គ អរហត្តមគ្គ លោកមិនមក មិនត្រឡប់មក មិនវិលមករកកិលេសទាំងនោះទៀត ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថានាគ ព្រោះហេតុមិនមក យ៉ាងនេះឯង ។ ពាក្យថា ដូចនាគ គេចចាកហ្វូង បានសេចក្តីថា ដំរីដ៏ប្រសើរនោះ រៀរលែង ជៀសវាង រៀរស្រឡះនូវហ្វូងទាំងឡាយ ចូលទៅនៅកណ្តាលព្រៃក្នុងអរញ្ញប្រទេស ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ តែម្នាក់ឯង យ៉ាងណា ចំណែកព្រះបច្ចេកសម្ពុទ្ធ ក៏រៀរលែង ជៀសវាង រៀរស្រឡះនូវពួក ប្រព្រឹត្តនៅតែមួយអង្គឯង ដូចកុយរមាស ទ្រង់គប់រកព្រៃតូចនិងព្រៃធំ ជាសេនា-សនៈដ៏ស្ងាត់ មិនមានសំឡេង មិនមានសូរគឹកកង ប្រាសចាកខ្យល់ ដែលកើតអំពីសរីរៈនៃជន ជាសេនាសនៈដ៏ស្ងាត់ចាកមនុស្ស សមគួរដល់ការពួនសម្ងំ ព្រះបច្ចេកសម្ពុទ្ធនោះ និមន្តទៅតែមួយអង្គឯង ឈរតែមួយអង្គឯង គង់នៅតែមួយអង្គឯង សម្រេចការសិងតែមួយអង្គឯង

ឯកោ គាមំ បិណ្ឌាយ បវិសតិ ឯកោ បដិក្កមតិ ឯកោ រហោ និសីទតិ ឯកោ ចង្កមំ អធិដ្ឋាតិ ឯកោ ចរតិ វិចរតិ ឥរិយតិ វត្តេតិ បាលេតិ យបេតិ យាបេតីតិ ឯកោ វ យូថានិ វិវជ្ជយិត្វា ។

[៣០៣] សញ្ជាតខន្ធោ បទុមី ឧឡារោតិ យថា សោ ហត្ថិនាគោ សញ្ជាតក្ខន្ធោ សត្តរតនោ វា ហោតិ អដ្ឋរតនោ វា បច្ចេកសម្ពុទ្ធោបិ សញ្ជាតក្ខន្ធោ អសេក្ខេន សីលក្ខន្ធេន អសេក្ខេន សមាធិក្ខន្ធេន អសេក្ខេន បញ្ញាខន្ធេន អសេក្ខេន វិមុត្តិក្ខន្ធេន អសេក្ខេន វិមុត្តិញ្ញាណទស្សនក្ខន្ធេន ។ យថា សោ ហត្ថិនាគោ បទុមី បច្ចេកសម្ពុទ្ធោបិ សត្តហិ ពោជ្ឈង្គបុប្ផេហិ បទុមី សតិសម្ពោជ្ឈង្គបុប្ផេន ធម្មវិចយសម្ពោជ្ឈង្គបុប្ផេន វីរិយសម្ពោជ្ឈង្គបុប្ផេន បីតិសម្ពោជ្ឈង្គបុប្ផេន បស្សទ្ធិសម្ពោជ្ឈង្គបុប្ផេន សមាធិសម្ពោជ្ឈង្គបុប្ផេន ឧបេក្ខាសម្ពោជ្ឈង្គបុប្ផេន ។ យថា សោ ហត្ថិនាគោ ឧឡារោ ថាមេន ពលេន ជវេន

ចូលទៅបិណ្ឌបាតក្នុងស្រុកតែមួយអង្គឯង ត្រឡប់មកវិញតែមួយអង្គឯង គង់ក្នុងទីស្ងាត់តែមួយអង្គឯង អធិដ្ឋានចង្ក្រមតែមួយអង្គឯង ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ តែមួយអង្គឯង (ក៏យ៉ាងនោះដែរ) ហេតុនោះ (លោកពោលថា) ដូចនាគ គេចចាកហ្វូង ។

[៣០៣] ពាក្យថា មានខន្ធកើតព្រមហើយ មានសម្បុរដូចផ្កាឈូក ជាសត្វខ្ពង់ខ្ពស់ អធិប្បាយថា ដំរីដ៏ប្រសើរនោះ មានខន្ធកើតព្រមហើយ ជាដំរី ៧ ហត្ថ ឬ ៨ ហត្ថ យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ក៏មានខន្ធកើតព្រមហើយ ដោយអសេក្ខសីលក្ខន្ធ អសេក្ខសមាធិក្ខន្ធ អសេក្ខ-បញ្ញាខន្ធ អសេក្ខវិមុត្តិក្ខន្ធ អសេក្ខវិមុត្តិញ្ញាណទស្សនក្ខន្ធ ក៏យ៉ាងនោះ ។ ដំរីដ៏ប្រសើរនោះ មានផ្កាឈូក យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថាមានផ្កាឈូក ដោយផ្កាគឺពោជ្ឌង្គ ៧ គឺដោយផ្កាគឺសតិសម្ពោ-ជ្ឌង្គ ១ ផ្កាគឺធម្មវិចយសម្ពោជ្ឌង្គ ១ ផ្កាគឺវីរិយសម្ពោជ្ឌង្គ ១ ផ្កាគឺបីតិ-សម្ពោជ្ឌង្គ ១ ផ្កាគឺបស្សទ្ធិសម្ពោជ្ឌង្គ ១ ផ្កាគឺសមាធិសម្ពោជ្ឌង្គ ១ ផ្កាគឺឧបេក្ខាសម្ពោជ្ឌង្គ ១ (យ៉ាងនោះដែរ) ។ ដំរី ដ៏ប្រសើរនោះ ជាសត្វលើសលុប ដោយកម្លាំងកាយ កម្លាំងចិត្ត សន្ទុះ

ស្ងរេន បច្ចេកសម្ពុទ្ធោបិ ឧជ្ជាហេ សីលេន សមា-
ធិនា បញ្ញាយ វិមុត្តិយា វិមុត្តិញ្ញាណទស្សនេនាតិ
សញ្ជាតទ្ធោ បធុមី ឧជ្ជាហេ ។

[៣០៤] យថាកិរន្តំ វិហរេ អរញ្ញេតិ យថា សោ
ហត្ថិនាគោ យថាកិរន្តំ អរញ្ញេ វិហរតិ បច្ចេកសម្ពុ-
ទ្ធោបិ យថាកិរន្តំ អរញ្ញេ វិហរតិ បឋមេនបិ ឈានេន
យថាកិរន្តំ អរញ្ញេ វិហរតិ ទុតិយេនបិ តតិយេនបិ
ចតុត្ថេនបិ ឈានេន យថាកិរន្តំ អរញ្ញេ វិហរតិ
មេត្តាយបិ ចេតោវិមុត្តិយា យថាកិរន្តំ អរញ្ញេ វិហរតិ
ករុណាយបិ មុទិតាយបិ ឧបេក្ខាយបិ ចេតោវិមុត្តិ-
យា យថាកិរន្តំ អរញ្ញេ វិហរតិ អាកាសានញ្ចាយត-
នសមាបត្តិយាបិ យថាកិរន្តំ អរញ្ញេ វិហរតិ វិញ្ញាណ-
ញ្ចាយតនសមាបត្តិយាបិ អាកិញ្ចញ្ញាយតនសមាបត្តិ-
យាបិ នេវសញ្ញានាសញ្ញាយតនសមាបត្តិយាបិ ផល-
សមាបត្តិយាបិ យថាកិរន្តំ អរញ្ញេ វិហរតីតិ យថាកិ-
រន្តំ វិហរេ អរញ្ញេ ។ ឯតោ ចរេ ខគ្គវិសាណកប្ប-
ហ្ម ។ ត្ថ ជ្ជ ហ សោ បច្ចេកសម្ពុទ្ធោ

និងសេចក្ដីក្ងៀវក្ងា យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ក៏ជាបុគ្គលលើសលុបដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈ (យ៉ាងនោះដែរ) ហេតុនោះ (លោកពោលថា) មានខន្ធកើតព្រមហើយ មានសម្បុរដូចផ្កាឈូក ជាសត្វខ្ពង់ខ្ពស់ ។

[៣០៤] ពាក្យថា នៅក្នុងព្រៃតាមសប្បាយ សេចក្ដីថា ដំរីដ៏ប្រសើរនោះ នៅក្នុងព្រៃតាមសប្បាយ យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ក៏នៅក្នុងព្រៃតាមសប្បាយ (យ៉ាងនោះដែរ) គឺនៅក្នុងព្រៃតាមសប្បាយ ដោយបឋមជ្ឈានខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយទុតិយជ្ឈានខ្លះ តតិយជ្ឈានខ្លះ ចតុត្ថជ្ឈានខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយមេត្តាចេតោវិមុត្តិខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយករុណាចេតោវិមុត្តិខ្លះ មុទិតាចេតោវិមុត្តិខ្លះ ឧបេក្ខាចេតោវិមុត្តិខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយអាកាសានញ្ចាយតនសមាបត្តិខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយវិញ្ញាណញ្ចាយតនសមាបត្តិខ្លះ ដោយអាកិញ្ចញ្ញាយតនសមាបត្តិខ្លះ ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិខ្លះ ដោយផលសមាបត្តិខ្លះ ហេតុនោះ (លោកពោលថា) នៅក្នុងព្រៃតាមសប្បាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ជាតោវ យូថានិ វិវជ្ជយិត្វា
សញ្ជាតខន្ធោ បឧមី ឧឬ្ឆ
យថាកិរន្តំ វិហរេ អរញ្ញ
ឯកោ ចរេ ខគ្គវិសាណកប្ប ។

[៣០៥] អដ្ឋាន តំ សន្ថណ្ឋិការតស្ស
យំ ផុស្ស្ស យេ សាមយិកំ វិមុត្តឺ
អានិចូ្ចពន្ធុ្ស្ស ១ចោ ជិសម្ម
ឯកោ ចរេ ខគ្គវិសាណកប្ប ។

[៣០៦] អដ្ឋាន តំ សន្ថណ្ឋិការតស្ស យំ ផុស្ស្ស យេ សាមយិកំ វិមុត្តិន្ធិ រុត្តំ ហេតំ ភគ្ការតា យ១ារតានន្ធ ភិក្ខ ១ សន្ថណ្ឋិការ១ាមោ សន្ថណ្ឋិការ-ោ សន្ថណ្ឋិការ១ាមតំ អនុ១ុ១ត្ត ១ណ១ារ១ាមោ

បុគ្គលដែលដូចនាគ មានខន្ធកើតព្រមហើយ មានសម្ព្ធរដូចផ្ការ ជាសត្វខ្ពង់ខ្ពស់ គេចចាកហ្ងូងហើយនៅក្នុងព្រៃតាមសប្បាយ គប្បីប្រព្រឹត្តម្នាក់ឯងដូចកុយរមាស ។

[៣០៥] *បុគ្គលគប្បីបានសាមយិកវិមុត្តិ[1] ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំង នៃបុគ្គលអ្នកត្រេកអរក្នុងពួកទេ បុគ្គលពិចារណាពាក្យ នៃព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។*

[៣០៦] *ពាក្យថា បុគ្គល គប្បីបានសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំង នៃបុគ្គលអ្នកត្រេកអរក្នុងពួកទេ អធិប្បាយថា មែនពិត ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលអានន្ទ ភិក្ខុមានការនៅច្រឡូកច្រឡំដោយពួកជាទីត្រេកអរ ត្រេកអរក្នុងការនៅច្រឡូកច្រឡំដោយពួក ប្រកបរឿយៗ នូវសេចក្តីត្រេកអរ ក្នុងការនៅច្រឡូកច្រឡំដោយពួក មានពួកជាទីត្រេកអរ*

---

1 វិមុត្តិប្រព្រឹត្តទៅតាមសម័យ គឺ វិមុត្តិជាលោកិយ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

តណ្ហាតោ តណ្ហាសម្ទ្ធិតោ តណ្ហាវាមតំ អនុយុត្តោ យន្តំ នេក្ខម្មសុខំ បវិវេកសុខំ ឧបសមសុខំ សម្ពោធិសុខំ ឥស្ស សុខស្ស និកាមលាភី ភវិស្សតិ អកិច្ចលាភី អកសិរលាភីតិ នេតំ ឋានំ វិជ្ជតិ ។ យោ ច ខោ សោ អានន្ទ ភិក្ខុ ឯកោ តណ្ហាវ្ហបកង្ខោ វិហរតិ ឥស្សេតំ ភិក្ខុនោ ចាដិកង្ខំ យន្តំ នេក្ខម្មសុខំ បវិវេកសុខំ ឧបសមសុខំ សម្ពោធិ-សុខំ ឥស្ស សុខស្ស និកាមលាភី ភវិស្សតិ អកិច្ច-លាភី អកសិរលាភីតិ ឋានមេតំ វិជ្ជតិ ។ យាវតា-នន្ទ ភិក្ខុ សន្ត្ថណ្ហិការាមោ សន្ត្ថណ្ហិការតោ សន្ត្ថ-ណ្ហិការាមតំ អនុយុត្តោ តណ្ហារាមោ តណ្ហារតោ តណ្ហាសម្ទ្ធិតោ តណ្ហាវាមតំ អនុយុត្តោ សាមយិកំ វា ចេតោវិមុត្តឺ ឧបសម្ជ្ជ វិហរិស្សតិ អសាម-យិកំ វា អកុប្ជន្តិ នេតំ ឋានំ វិជ្ជតិ ។

ត្រេកអរក្នុងពួក រួសរាយក្នុងពួក ប្រកបរឿយៗ នូវសេចក្ដីត្រេកអរក្នុងពួក ជាកំណត់ សេចក្ដីសុខក្នុងការចេញបួស សេចក្ដីសុខក្នុងការស្ងាត់ សេចក្ដីសុខក្នុងការសូប់ សេចក្ដីសុខក្នុងការត្រាស់ដឹង ណា (ភិក្ខុនោះ) នឹងជាអ្នកបានតាមប្រាថ្នា បានដោយមិនក្រ បានដោយមិនលំបាក នូវសេចក្ដីសុខនោះ ហេតុការណ៍បែបនេះ មិនមានទេ ។ ម្នាលអានន្ទ លុះតែភិក្ខុណា ជៀសចេញចាកពួក ហើយនៅតែម្នាក់ឯង សេចក្ដីសុខនុ៎ះ ទើបមានប្រាកដដល់ភិក្ខុនោះ គឺថា សេចក្ដីសុខក្នុងការចេញបួស សេចក្ដីសុខក្នុងការស្ងាត់ សេចក្ដីសុខក្នុងការសូប់ សេចក្ដីសុខក្នុងការត្រាស់ដឹងណា (ភិក្ខុនោះ) នឹងជាអ្នកបានតាមប្រាថ្នា បានដោយមិនក្រ បានដោយមិនលំបាក នូវសេចក្ដីសុខនោះ ហេតុការណ៍បែបនេះ ទើបមាន ។ ម្នាលអានន្ទ ភិក្ខុមានការនៅច្រឡូកច្រឡំដោយពួកជាទីត្រេកអរ ត្រេកអរក្នុងការនៅច្រឡូកច្រឡំដោយពួក ប្រកបរឿយៗ នូវសេចក្ដីត្រេកអរក្នុងការនៅច្រឡូកច្រឡំដោយពួក មានពួកជាទីត្រេកអរ ត្រេកអរក្នុងពួក រួសរាយក្នុងពួក ប្រកបរឿយៗនូវសេចក្ដីត្រេកអរក្នុងពួក ជាកំណត់ (ភិក្ខុនោះ) នឹងបានសាមយិកចេតោវិមុត្តិ (ចេតោវិមុត្តិជាលោកិយ) ឬអសាមយិក-អកុប្បធម៌ (មគ្គជាលោកុត្តរ:) ហេតុការណ៍បែបនេះ មិនមានទេ ។

យោ ច ខោ សោ អានន្ទ ភិក្ខុ ឯកោ គណស្មា វូបកដ្ឋោ វិហរតិ តស្សេតំ ភិក្ខុនោ ចាដិកង្ខំ សាមយិកំ វា ចេតោវិមុត្តឹ ឧបសម្បជ្ជ វិហរិស្សតិ អសាមយិកំ វា អកុប្បន្តិ ឋានមេតំ វិជ្ជតីតិ អដ្ឋាន តំ សង្គណិការតស្ស យំ ផុស្សយេ សាមយិកំ វិមុត្តឹ ។

[៣០៧] អាជិច្ចពន្ធុស្ស វចោ និសម្មាតិ អាទិច្ចោ វុច្ចតិ សុរិយោ ។ សោ គោតមោ គោត្តេន បច្ចេកសម្ពុទ្ធោបិ គោតមោ គោត្តេន សោ បច្ចេកសម្ពុទ្ធោបិ សុរិយស្ស គោត្តញាតកោ[១] គោត្តពន្ធុ តស្មា បច្ចេកសម្ពុទ្ធោ អាជិច្ចពន្ធុ ។ អាជិច្ចពន្ធុស្ស វចោ និសម្មាតិ អាជិច្ចពន្ធុស្ស វចនំ ព្យបថំ ទេសនំ អនុសន្ធឹ សុត្វា សុណិត្វា ឧគ្គហេត្វា ឧបធារយិត្វា ឧបលក្ខយិត្វាតិ អាជិច្ចពន្ធុស្ស វចោ និសម្ម ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

១ ម. អយំ បាឋោ នត្ថិ ។

ម្នាលអានន្ទ លុះតែភិក្ខុណា ជៀសចេញចាកពួក ហើយនៅតែម្នាក់ឯង សេចក្តីសុខនោះ ទើបមានប្រាកដដល់ភិក្ខុនោះ គឺថា (ភិក្ខុនោះ) នឹងបានសាមយិកចេតោវិមុត្តិ ឬអសាមយិកអកុប្បធម៌ ហេតុការណ៍បែបនេះ ទើបមាន ហេតុនោះ (លោកពោលថា) បុគ្គលគប្បីបានសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំងនៃបុគ្គល អ្នកត្រេកអរ ក្នុងពួកទេ ។

[៣០៧] ពាក្យថា បុគ្គលពិចារណាពាក្យនៃព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុ សេចក្តីថា ព្រះអាទិត្យ លោកហៅថា អាទិច្ច: ។ ព្រះអាទិត្យ នោះជាគោតមដោយគោត្ត ចំណែកព្រះបច្ចេកសម្ពុទ្ធ ក៏ជាគោតមដោយ គោត្ត ព្រះបច្ចេកសម្ពុទ្ធនោះ ជាញាតិដោយគោត្ត ជាផៅពង្សដោយ គោត្តនៃព្រះអាទិត្យ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថា ព្រះអាទិច្ចពន្ធុ ។ ពាក្យថា បុគ្គលពិចារណាពាក្យនៃព្រះពុទ្ធ ជាព្រះ អាទិច្ចពន្ធុ បានសេចក្តីថា បុគ្គលបានស្តាប់ ឮ រៀន ចាំទុក កំណត់ នូវពាក្យ គន្ធង៏ពាក្យ ទេសនា អនុសន្ធិ នៃព្រះពុទ្ធជាព្រះអាទិច្ចពន្ធុ ហេតុនោះ (លោកពោលថា) បុគ្គលពិចារណាពាក្យនៃព្រះពុទ្ធ ជាព្រះ អាទិច្ចពន្ធុ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

ខគ្គវិសាណសុត្តនិទ្ទេសោ

អដ្ឋាន តំ សង្ខ្លណិកាការតស្ស
យំ ផុស្សយេ សាមយិកំ វិមុត្តឺ
អាឥិចូពន្ធុស្ស វចោ និសម្ម
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[៣០៨] ឥិដ្ឋីវិសូកានិ ឧចាតិវត្តោ
បត្តោ និយាមំ បដិលទ្ធមគ្គោ
ឧប្ឆន្ទញ្ញាណោម្ហិ អនញ្ញនេយ្យោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[៣០៩] ឥិដ្ឋីវិសូកានិ ឧចាតិវត្តោតិ ឥិដ្ឋីវិសូ-
កានិ វុច្ចន្តិ រាសតិវត្តុកា សក្កាយឥិដ្ឋី ។ ឥធ
អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្ម-
ស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ
អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិស-
ធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ
វា អត្តានំ អត្តនិ វា រូបំ រូបស្មឺ វា អត្តានំ វេទនំ
សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សតិ

បុគ្គលគប្បីបានសាមយិកវិមុត្តិ ដោយហេតុណា ហេតុ
នោះ មិនមែនជាទីតាំងនៃបុគ្គលអ្នកត្រេកអរក្នុងពួកទេ
បុគ្គលពិចារណាពាក្យថា នៃព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុ
ហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣០៨] បុគ្គលប្រព្រឹត្តកន្ទ្ធ នូវចម្រូងគឺទិដ្ឋិទាំងឡាយ
បានសម្រេចធម៌ដ៏ទៀងទាត់ បានចំពោះនូវមគ្គ មិន
មានបុគ្គលដទៃណែនាំ (ព្រោះដឹងថា) អាត្មាអញមាន
ញាណកើតហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយ
រមាស ។

[៣០៩] ពាក្យថា បុគ្គលប្រព្រឹត្តកន្ទ្ធ នូវចម្រូងគឺទិដ្ឋិទាំងឡាយ សេចក្ដីថា សក្កាយទិដ្ឋិមានវត្ថុ ២០ ហៅថា ចម្រូងគឺទិដ្ឋិ ។ បុថុជ្ជន ក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនឃើញនូវពួកព្រះអរិយៈ មិនឈ្វាសវៃក្នុងអរិយធម៌ មិនបានទូន្មានខ្ជួនក្នុងអរិយធម៌ មិនឃើញពួកសប្បុរស មិនឈ្វាសវៃក្នុងសប្បុរិសធម៌ មិនបានទូន្មានខ្ជួនក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញរូបថាខ្ជួន នូវខ្ជួនថាមានរូបខ្ជះ នូវរូបក្នុងខ្ជួនខ្ជះ នូវខ្ជួនក្នុងរូបខ្ជះ ពិចារណាឃើញនូវវេទនា សញ្ញា សង្ខារ វិញ្ញាណថាខ្ជួន

វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញា-ណស្មឿ វា អត្តានំ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ តាហោ បដិត្តាហោ[១] អភិនិវេសោ បរាមាសោ ឧម្មុគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្តា-យតនំ វិបរិយេសត្តាហោ វិបរីតត្តាហោ វិបល្លាសត្តា-ហោ មិច្ឆាតាហោ អយាថាវកស្មឿ យាថាវកន្តិ តា-ហោ យាវតា ទ្វាសដ្ឋី ទិដ្ឋិគតានិ ឥមានិ ទិដ្ឋិវិសូ-កានិ[២] ។ ឧចាតិវត្តោតិ ទិដ្ឋិវិសូកានិ ឧចាតិវត្តោ អតិក្កន្តោ សមតិក្កន្តោ[៣] វីតិវត្តោតិ ទិដ្ឋីវិសូកានិ ឧចាតិវត្តោ ។

[៣១០] បត្តោ និយាមំ បដិលទ្ធមត្តោតិ និយាមា រុច្ចន្តិ ចត្តារោ មត្តា អរិយោ អដ្ឋង្គិ-កោ មត្តោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្ក-ប្ប សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។

---

១ ម. បតិគ្គាហោ ។ ២ ម. អយំ ទិដ្ឋិវិសូកា ។ ៣ ម. ទិដ្ឋីវិសូកានិ ឧបាតិវត្តោតិ ទិដ្ឋិវិសូកានិ ឧបាតិវត្តោ អតិក្កន្តោ សមតិក្កន្តោ ។

នូវខ្ជួនថា មានវិញ្ញាណខ្លះ នូវវិញ្ញាណក្នុងខ្ជួនខ្លះ នូវខ្ជួនក្នុងវិញ្ញាណ ខ្លះ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃស្បាតគឺទិដ្ឋិ ផ្លូវដាច់ស្រយាលគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ សេចក្តីញាប់ញ័រគឺទិដ្ឋិ ចំណងគឺទិដ្ឋិ ការប្រកាន់ ការ ប្រកាន់ខ្ជាប់ ការប្រកាន់មាំ ការស្ទាបអង្អែល ផ្លូវខុស គន្ធង ខុស សេចក្តីខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ដោយការស្វែង រកខុស ការប្រកាន់វិបរីត ការប្រកាន់វិបល្វាស ការប្រកាន់ខុស ការប្រកាន់ថាពិត ក្នុងរបស់ដែលមិនពិត ទិដ្ឋិ ៦២ ទាំងប៉ុន្ម្មាន មានសភាពយ៉ាងនេះ ឯណា នេះ ឈ្មោះថាចម្រូងគឺទិដ្ឋិ ។ ពាក្យថា ប្រព្រឹត្តកន្ទង គឺ ប្រព្រឹត្តរំលង ឈានកន្ទលង ឈានរំលង ប្រព្រឹត្ត កន្ទង នូវចម្រូងគឺទិដ្ឋិទាំងឡាយ ហេតុនោះ (លោកពោលថា) បុគ្គល ប្រព្រឹត្តកន្ទង នូវចម្រូងគឺទិដ្ឋិទាំងឡាយ ។

[៣១០] *ពាក្យថា បានសម្រេចធម៌ដ៏ទៀងទាត់ បានចំពោះ នូវមគ្គ សេចក្តីថា មគ្គ ៤ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្ប: ១ សម្មាវាចា ១ សម្មាកម្មន្ត: ១ សម្មាអាជីវ: ១ សម្ម-វាយាម: សម្មាសតិ ១ សម្មាសមាធិ ១ លោកហៅថា ធម៌ដ៏ទៀង ។*

ចតូហិ អរិយមគ្គេហិ សមន្ថ្ការតោ សម្ឫត្តោ អធិ-
តោ ផុសិតោ សច្ឆិកតោតិ បត្តោ ឌិយាមំ ។ បដិ-
លទ្ធមគ្គោតិ លទ្ធមគ្គោ បដិលទ្ធមគ្គោ អធិតតមគ្គោ
ផុសិតមគ្គោតិ បត្តោ ឌិយាមំ បដិលទ្ធមគ្គោ ។

[៣១១] ឧឬន្ទញ្ញាណោម្ហិ អនញ្ញនេយ្យោតិ
តស្ស បច្ចេកសម្ពុទ្ធស្ស ញាណំ ឧឬន្ទំ សមុឬន្ទំ
ឌិឬ្ធតំ អភិឌិឬ្ធតំ ចាតុភូតំ សព្ពេ សង្ខ្ការ អនិច្ចាតិ
ញាណំ ឧឬន្ទំ សមុឬន្ទំ ឌិឬ្ធតំ អភិឌិឬ្ធតំ ចាតុភូ-
តំ សព្ពេ សង្ខ្ការ ទុក្ខាតិ ។ បេ ។ យង្កិញ្ចិ សមុ-
ឌយឌម្មំ សឬ្ធតំ ឌិរោឌឌម្មន្តិ ញាណំ ឧឬន្ទំ សមុ-
ឬ្ធតំ ឌិឬ្ធតំ អភិឌិឬ្ធតំ ចាតុភូតន្តិ ឧឬន្ទញ្ញាណោ-
ម្ហិ ។ អនញ្ញនេយ្យោតិ សោ បច្ចេកសម្ពុទ្ធោ ន បរ-
នេយ្យោ ន បរបត្តិយោ ន បរឬ្ឬចូយោ ន បរឬ្ឬដិ-
ពទ្ធកូ យថាភូតំ ជានាតិ បស្ឬតិ អសម្ម្ងុទ្ធោ សម្ឬ-
ជានោ បដិស្ឬតោ សព្ពេ សង្ខ្ការ អនិច្ចាតិ ។ បេ ។

បុគ្គលប្រកប សម្រេច បាន ប៉ះពាល់ ធ្វើឲ្យជាក់ច្បាស់ដោយអរិយមគ្គ ទាំង ៤ ហេតុនោះ (លោកពោលថា) បានសម្រេចធម៌ដ៏ទៀងទាត់ ។ ពាក្យថា បានចំពោះនូវមគ្គ គឺបានមគ្គ បានចំពោះមគ្គ បានសម្រេចមគ្គ បានប៉ះពាល់មគ្គ ហេតុនោះ (លោកពោលថា) បានសម្រេចធម៌ដ៏ទៀងទាត់ បានចំពោះនូវមគ្គ ។

[៣១១] *ពាក្យថា មិនមានបុគ្គលដទៃ ណែនាំ (ព្រោះដឹងថា) អាត្មាអញមានញាណកើតហើយ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ មានញាណកើតឡើង កើតឡើងព្រម កើត កើតចំពោះ កើតប្រាកដ គឺ មានញាណកើតឡើង កើតឡើងព្រម កើត កើតចំពោះ កើតប្រាកដថា សង្ខារទាំងពួងមិនទៀង ថា សង្ខារទាំងពួងជាទុក្ខ ។ បេ ។ មានញាណ កើតឡើង កើតឡើងព្រម កើត កើតចំពោះ កើតប្រាកដថា របស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការ រលត់ទៅវិញជាធម្មតា ហេតុនោះ (លោកពោលថា) អាត្មាអញ មានញាណកើតហើយ ។ ពាក្យថា មិនមានបុគ្គលដទៃ ណែនាំ គឺ ព្រះបច្ចេកសម្ពុទ្ធនោះ មិនមានបុគ្គលដទៃណែនាំ មិនមានបុគ្គលដទៃ ឲ្យជឿ មិនមានបុគ្គលដទៃជាទីអាង មិនដល់នូវការជាប់ចំពាក់ដោយ បុគ្គលដទៃ រមែងដឹង ឃើញតាមពិត ជាបុគ្គលមិនវង្វេង ជាអ្នក ដឹងច្បាស់ មានស្មារតីប្រុងជានិច្ចថា សង្ខារទាំងពួងមិនទៀង ។ បេ ។*

យន្តិ៍ញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ន បរនេយ្យោ ន បរបត្តិយោ ន បរប្បច្ចយោ ន បរប្បដិពទ្ធគូ យថាភូតំ ជានាតិ បស្សតិ អសម្មូឡ្ហោ សម្បជានោ បដិស្សតោតិ ឧប្បន្នញាណោម្ហិ អនញ្ញ-នេយ្យោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

ទិដ្ឋីវិសូកានិ ឧបាតិវត្តោ
បត្តោ និយាមំ បដិលទ្ធមគ្គោ
ឧប្បន្នញាណោម្ហិ អនញ្ញនេយ្យោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[៣១២] និល្លោលុបោ និក្កុហោ និប្បិបាសោ
និម្មក្ខោ និទ្ធន្តកសាវមោហោ
និរាសសោ សព្វលោកេ ភវិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

មិនមានបុគ្គលដទៃណែនាំ មិនមានបុគ្គលដទៃឲ្យជឿ មិនមានបុគ្គលដទៃជាទីអាង មិនដល់នូវការជាប់ចំពាក់ដោយបុគ្គលដទៃ រមែងដឹង ឃើញតាមពិត ជាបុគ្គលមិនវង្វេង ជាអ្នកដឹងច្បាស់ មានស្មារតីប្រុងជានិច្ច ថារបស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ហេតុនោះ (លោកពោលថា) មិនមានបុគ្គលដទៃណែនាំ (ព្រោះដឹងថា) អាត្មាអញមានញាណកើតហើយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

> *បុគ្គលប្រព្រឹត្តកន្ទ្ធ នូវចម្រូងគឺទិដ្ឋិទាំងឡាយ បានសម្រេចធម៌ដ៏ទៀងទាត់ បានចំពោះនូវមគ្គ មិនមានបុគ្គលដទៃណែនាំ (ព្រោះដឹងថា) អាត្មាអញមានញាណកើតហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។*

[៣១២] *បុគ្គលអ្នកមិនលោភ អ្នកមិនកុហក អ្នកមិនមានការស្រេកឃ្ងាន អ្នកមិនមានការលុបគុណគេ មានទឹកចត់និងមោហ:កម្ចាត់ចេញហើយ មិនមានសេចក្តីប្រាថ្នា ក្នុងលោកទាំងមូល គប្បីប្រព្រឹត្ត ម្នាក់ឯង ដូចកុយរមាស ។*

ខគ្គវិសាណសុត្តនិទ្ទេសោ

[៣១៣] និលោ្ហលុចោ និក្ក្ហោ និប្ជិចាសោតិ លោលុប្ជា រុចូតិ តណ្ហា យោ ភគោ សារគោ ។ បេ ។ អកិជ្ជា លោភោ អកុសលមូលំ ។ សា លោលុប្ជា តណ្ហា តស្ស បចេ្ចកសម្ពុទ្ធស្ស បហីនា ឧច្ឆិន្ទមូលា តាលាវត្ថុកតា អនភាវង្គតា អាយតឹអនុប្ជាទធម្មា តស្មា បចេ្ចកសម្ពុទ្ធោ និលោ្ហ-លុចោ ។ និក្ក្ហោតិ តីណិ កុហនវត្ថូនិ បចូយ-ប្ជដិសេវនសង្ខ្ជាតំ កុហនវត្ថុ ឥរិយាបថសង្ខ្ជាតំ កុហនវត្ថុ សាមន្ជជប្ជនសង្ខ្ជាតំ កុហនវត្ថុ ។

កតមំ បចូយប្ជដិសេវនសង្ខ្ជាតំ កុហនវត្ថុ ។ ឥធ ភិក្ខុ ជីវិតហេតុ ជីវិតការណា ជីវិតបរិក្ខ្ជារហេតុ ។ សោ ចាបិ ច្ជោ ឥច្ជាបកតោ អត្ថិ ចីវរបិណ្ឌ្ជបាតសេនាសនគិលា-ជប្ជចូយភេសជ្ជបរិក្ខ្ជារានំ ភិយ្យោ ការណ្ជ្ជ ឧចាជាយ ចីវរំ បចូក្ខ្ជាតិ បិណ្ឌ្ជបាតំ បចូក្ខ្ជាតិ សេនាសនំ បចូក្ខ្ជាតិ គិលានប្ជចូយភេសជ្ជបរិក្ខ្ជារំ បចូក្ខ្ជាតិ ។

ខគ្គវិសាណសុត្តនិទ្ទេស

[៣១៣] ពាក្យថា បុគ្គលអ្នកមិនលោភ អ្នកមិនកុហក អ្នកមិនមានការស្រេកឃ្វាន អធិប្បាយថា តណ្ហា ហៅថា សេចក្តីលោភ បានដល់តម្រេក តម្រេកខ្លាំង ។ បេ ។ អកិញ្ចា លោភ: អកុសលមូល ។ តណ្ហាគឺសេចក្តីលោភនោះ ព្រះបច្ចេកសម្ពុទ្ធនោះ បានលះបង់ គាស់រំលើងឫស ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន ឲ្យជាធម៌លែងកើតឡើងតទៅទៀត ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាអ្នកមិនមានលោភ ។ ពាក្យថា អ្នកមិនកុហក សេចក្តីថា កុហនវត្ថុ មាន ៣ គឺកុហនវត្ថុប៉ៃកខាងការសេពបច្ច័យ ១ កុហនវត្ថុប៉ៃកខាងឥរិយាបថ ១ កុហនវត្ថុប៉ៃកខាងការខ្សឹប ១ ។

កុហនវត្ថុ ប៉ៃកខាងការសេពបច្ច័យ តើដូចម្តេច ។ ពួកគហបតី ក្នុងសាសនានេះ និមន្តភិក្ខុដោយចីវរ បិណ្ឌបាត សេនាសន: និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ ភិក្ខុនោះ ជាអ្នកមានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ មានសេចក្តីត្រូវការដោយចីវរ បិណ្ឌបាត សេនាសន: និងគិលានប្បច្ចយភេសជ្ជបរិក្ខារ អស្រ័យសេចក្តីប្រាថ្នាខ្លាំង ក៏ពោលឃាត់ចីវរ ពោលឃាត់បិណ្ឌបាត ពោលឃាត់សេនាសន: ពោលឃាត់គិលានប្បច្ចយភេសជ្ជបរិក្ខារ ។

សោ ឯវមាហ កឹ សមណាស្ស មហាក្ឍេន ចីវរេន ឯតំ សារុប្បំ យំ សមណោ សុសានា វ សង្ការកូដា វ ចាបណិកា វ ឆន្ទកានិ ឧច្ចិនិត្វា សង្ឆាដឺ កត្វា[1] ជាវេយ្យ កឹ សមណាស្ស មហាក្ឍេន បិណ្ឌាចាតេន ឯតំ សារុប្បំ យំ សមណោ ឧញ្ឆាចរិយាយ បិណ្ឌិយាលោបេន ជីវិកំ កប្ប្យ្យ កឹ សមណាស្ស មហាក្ឍេន សេនាសនេន ឯតំ សារុប្បំ យំ សមណោ រុក្ខមូលិកោ វ អស្ស អព្ភោកាសិកោ វ កឹ សមណាស្ស មហាក្ឍេន គិលានប្ប្ចយភេសជ្ជបរិក្ខារេន ឯតំ សារុប្បំ យំ សមណោ ឫតិមុត្តេន វ ហរិជកីឃណ្ឌេន វ ឋិ-ឃ-ដ-ំ ការេយ្យាតិ ឥតុចាជាយ លូ-ំ ចីវរ-ំ ជាវេតិ លូ-ំ បិណ្ឌាចាត-ំ ភុញ្ជតិ លូ-ំ សេនាសន-ំ បដិសេវតិ លូ-ំ គិលានប្ប្ចយភេសជ្ជបរិក្ខារ-ំ បដិសេវតិ ។ ឥមេ-ំ ឥហ-ាបតិ-ា ឯ-ំ ជានន្ត្ិ អយ-ំ ស-មណោ អ-ប្ប-ិ-ច្ឆ-ោ ស-ន្ត-ុ-ដ្ឋ-ោ ប-វ-ិ-ត្ត-ោ អ-ស-ំ-ស-ដ្ឋ-ោ

---

1 ម. សង្ឆាដិកំ ករិត្វា ។

ភិក្ខុនោះ បាននិយាយយ៉ាងនេះថា សមណៈមានប្រយោជន៍អ្វី ដោយ ចីវរ ដែលមានថ្ងៃច្រើន ឯអំពើដ៏សមគួរនុ៎ះ ត្រង់សមណៈវើស កំណាត់សំពត់ អំពីព្រៃស្មសាន អំពីគំនរសម្រាម ឬអំពីវានផ្សារ ធ្វើជា សង្ឆាដីហើយទ្រទ្រង់ សមណៈមានប្រយោជន៍អ្វី ដោយបិណ្ឌបាតដែល មានថ្ងៃច្រើន ឯអំពើដ៏សមគួរនុ៎ះ ត្រង់សមណៈចិញ្ចឹមជីវិតដោយពំនូត អាហារដោយការដើរស្វែង សមណៈមានប្រយោជន៍អ្វី ដោយសេនាសនៈ ដែលមានថ្ងៃច្រើន ឯអំពើដ៏សមគួរនុ៎ះ ត្រង់សមណៈគួរជាអ្នកនៅជិត គល់ឈើ ឬនៅក្នុងទីវាល សមណៈមានប្រយោជន៍អ្វី ដោយគិលានប្ប-ច្ចយភេសជ្ជបរិក្ខារ ដែលមានថ្ងៃច្រើន ឯអំពើដ៏សមគួរនុ៎ះ ត្រង់សមណៈធ្វើ ថ្នាំដោយទឹកមូត្រគោ ឬដោយចំណិតផ្ទៃសម៉ ភិក្ខុអាស្រ័យដំណើរនោះ ក៏ទ្រទ្រង់ចីវរសៅហ្មង បរិភោគបិណ្ឌបាតសៅហ្មង ប្រើប្រាស់សេនា-សនៈសៅហ្មង សេពគិលានប្បច្ចយភេសជ្ជបរិក្ខារសៅហ្មង ។ ពួក គហបតី ដឹងនូវភិក្ខុនោះយ៉ាងនេះថា សមណៈនេះ ជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកសូប់ស្ងាត់ ជាអ្នកមិនច្រឡូកច្រឡំ (ដោយពួក)

អារទ្ធវីរិយោ ឧតកាទោតិ ភិយ្យោ និមន្តេន្តិ ចីវរបិណ្ឌ-
បាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ ។

សោ ឯវមាហ តិណ្ណំ សម្មុខីភាវា សទ្ធោ
កុលបុត្តោ ពហុំ បុញ្ញំ បសវតិ សទ្ធាយ សម្មុខីភាវា
សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ទេយ្យធម្មស្ស
សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បស-
វតិ ទក្ខិណេយ្យានំ សម្មុខីភាវា សទ្ធោ កុលបុ-
ត្តោ ពហុំ បុញ្ញំ បសវតិ តុម្ហាកញ្ចេវាយំ សទ្ធា
អត្ថិ ទេយ្យធម្មោ ច សំវិជ្ជតិ អហញ្ច បដិគ្គាហកោ
សចាហំ ន បដិគ្គហេស្សាមិ ឯវំ តុម្ហេ បុញ្ញេន បរិ-
ពាហិរា ភវិស្សថ ន មយ្ហំ ឥមិនា អត្ថោ អបិច
តុម្ហាកញ្ចេវ អនុកម្បាយ បដិគ្គណ្ហាមីតិ តទុបាទា-
យ ពហុម្បិ ចីវរំ បដិគ្គណ្ហាតិ ពហុម្បិ បិណ្ឌបាតំ
បដិគ្គណ្ហាតិ ពហុម្បិ សេនាសនំ បដិគ្គណ្ហាតិ ពហុ-
ម្បិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បដិគ្គណ្ហាតិ ។
យា ឯវរូបា ភាកុដិកា ភាកុដិយំ កុហនា កុ-
ហាយនា កុហិតត្តំ ឥទំ វុច្ចតិ បច្ចយប្បដិសេវនស-
ង្ខាតំ កុហនវត្ថុ ។

ប្រារព្ធព្យាយាម ពោលពាក្យជាគ្រឿងកម្ចាត់បង់កិលេស ក៏រឹតតែនិមន្ត ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។

ភិក្ខុនោះ បាននិយាយយ៉ាងនេះថា កុលបុត្រអ្នកមានសទ្ធា បានបុណ្យច្រើនព្រោះធម៌ ៣ មានចំពោះមុខ គឺ កុលបុត្រអ្នកមានសទ្ធា បានបុណ្យច្រើន ព្រោះមានសទ្ធាចំពោះមុខ ១ កុលបុត្រអ្នកមានសទ្ធា បានបុណ្យច្រើន ព្រោះមានទេយ្យធម៌ចំពោះមុខ ១ កុលបុត្រអ្នកមានសទ្ធា បានបុណ្យច្រើន ព្រោះពួកទក្ខិណេយ្យបុគ្គលមានចំពោះមុខ ១ (ឥឡូវ) សទ្ធានេះ របស់អ្នកទាំងឡាយក៏មានផង ទេយ្យធម៌ក៏មានផង ទាំងអាត្មាក៏ជាអ្នកទទួលស្រាប់ បើអាត្មាមិនទទួលទេ អ្នកទាំងឡាយនឹងសាបសូន្យ ចាកបុណ្យយ៉ាងនេះ មិនខាន អាត្មាមិនមានសេចក្តីត្រូវការ ដោយទេយ្យធម៌នេះទេ ប៉ុន្តែអាត្មាទទួលដើម្បីអនុគ្រោះ ដល់អ្នកទាំង-ឡាយប៉ុណ្ណោះ (ភិក្ខុ) អាស្រ័យដំណើរនោះ ក៏ទទួលចីវរយ៉ាងច្រើនផង ទទួលបិណ្ឌបាតយ៉ាងច្រើនផង ទទួលសេនាសនៈយ៉ាងច្រើនផង ទទួលគិលានប្បច្ចយភេសជ្ជបរិក្ខារ យ៉ាងច្រើនផង ។ អាការធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន ការកុហក អាការនៃកុហក ភាពនៃកុហក មានសភាពយ៉ាងនេះ ឯណា នេះលោកហៅថា កុហនវត្ថុ ប៉ែកខាងការសេពបច្ច័យ ។

កតមំ ឥរិយាបថសង្ខាតំ កុហនវត្ថុ ។ ឥធេកច្ចោ ចាបិច្ឆោ ឥច្ឆាបកតោ សម្ភាវនាធិប្ប្ាយោ ឯវំ មំ ជនো សម្ភាវេស្ស្ាតីតិ កមនំ សណ្ឋាបេតិ ឋានំ សណ្ឋាបេតិ និសជ្ជំ សណ្ឋាបេតិ សេយ្យំ សណ្ឋាបេតិ បណិធាយ កច្ឆតិ បណិធាយ តិដ្ឋតិ បណិធាយ និសីទតិ បណិធាយ សេយ្យំ កប្ប្ាតិ សមាហិតោ វិយ កច្ឆតិ សមាហិតោ វិយ តិដ្ឋតិ សមាហិតោ វិយ និសីទតិ សមាហិតោ វិយ សេយ្យំ កប្ប្ាតិ អាចាថកជ្ឌ្ាយីវ ហោតិ ។ យា ឯវ្ូចា ឥរិយាបថស្ស អាបបនា បបនា សណ្ឋាបនា ភាកុដិកា ភាកុដិយំ កុហនា កុហាយនា កុហាយិតត្តំ ឥទំ ឥរិយាបថសង្ខាតំ កុហនវត្ថុ ។

កុហនវត្ថុ ប៉ែកខាងឥរិយាបថ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ មានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ មានបំណងនូវការសរសើរថា អ្នកផងនឹងសរសើរអញយ៉ាងនេះ ក៏រៀបចំដំណើរ រៀបចំដំហរ រៀបចំបង្គុយ រៀបចំដំណេក រៀបឫកដើរ រៀបឫកឈរ រៀបឫកអង្គុយ រៀបឫកសម្រេចការដេក ដើរដូចជាមានចិត្តតម្កល់មាំ ឈរដូចជាមានចិត្តតម្កល់មាំ អង្គុយដូចជាមានចិត្តតម្កល់មាំ សម្រេចការដេកដូចជាមានចិត្តតម្កល់មាំ ហាក់ដូចជាចូលឈានក្នុងទីចំពោះមុខ (នៃអ្នកផង) ។ ការតាំងក្នុងខាងដើម ការតាំងទុក ការរៀបចំឥរិយាបថ អាការធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន ការកុហក អាការនៃកុហក ភាពនៃកុហក មានសភាពយ៉ាងនេះ ឯណា នេះហៅថា កុហនវត្ថុ ប៉ែកខាងឥរិយាបថ ។

កតមំ សាមញ្ញជប្បសង្ខាតំ កុហនវត្ថុ ។ ឥធេកច្ចោ បាបិច្ឆោ ឥច្ឆាបកតោ សម្ភាវនាធិប្បាយោ ឯវំ មំ ជនោ សម្ភាវេស្សតីតិ អរិយធម្មសន្និស្សិតំ វាចំ ភាសតិ យោ ឯវរូបំ ចីវរំ ធារេតិ សោ សមណោ មហេសក្ខោតិ ភណតិ ។ យោ ឯវរូបំ បត្តំ ធារេតិ លោហថាលកំ ធារេតិ ធម្មករកំ ធារេតិ បរិស្សាវនំ ធារេតិ កុញ្ចិកំ ធារេតិ ឧបាហនំ ធារេតិ កាយពន្ធនំ ធារេតិ អាយោគពន្ធនំ ធារេតិ សោ សមណោ មហេសក្ខោតិ ភណតិ ។ យស្ស ឯវរូបោ ឧបជ្ឈាយោ សោ សមណោ មហេសក្ខោតិ ភណតិ ។ យស្ស ឯវរូបោ អាចរិយោ សមានុបជ្ឈាយកា សមានាចរិយកា មិត្តា សន្ទិដ្ឋា សម្ភត្តា សហាយា សោ សមណោ មហេសក្ខោតិ ភណតិ ។ យោ ឯវរូបេ វិហារេ វសតិ សោ សមណោ មហេសក្ខោតិ ភណតិ ។

ខគ្គវិសាណសុត្តនិទ្ទេស

កុហនវត្ថុ ប៉ែកខាងការខ្សឹប តើដូចម្តេច ។ ភិក្ខុខ្ជិះក្នុងសាសនានេះ មានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ មានបំណង នូវការសរសើរថា អ្នកផងនឹងសរសើរអញយ៉ាងនេះ ក៏ពោលវាចាផ្ទួលទៅរកអរិយធម៌ គឺពោលថា សមណៈណា ទ្រទ្រង់ចីវរមានសភាពយ៉ាងនេះ សមណៈនោះ មានសក្តិធំ ។ ពោលថា សមណៈណា ទ្រទ្រង់បាត្រ ទ្រទ្រង់ផ្ដិលលោហៈ ទ្រទ្រង់ធម្មក្រក ទ្រទ្រង់សំពត់តម្រងទឹក ទ្រទ្រង់កូនសោ ទ្រទ្រង់ស្បែកជើង ទ្រទ្រង់វត្ថុពន្ធន៍ចង្កេះ ទ្រទ្រង់សំពត់អាយោគពន្ធន៍ មានសភាពយ៉ាងនេះ ។ សមណៈនោះ មានសក្តិធំ ។ ពោលថា ឧបជ្ឈាយ៍នៃសមណៈណា មានសភាពយ៉ាងនេះ សមណៈនោះមានសក្តិធំ ។ ពោលថា សមណៈណា មានអាចារ្យ មានពួកភិក្ខុដែលមានឧបជ្ឈាយ៍ស្មើគ្នា មានពួកភិក្ខុដែលមានអាចារ្យស្មើគ្នា មានមិត្ត មានមិត្តស្នាក់ស្ទើរ មានមិត្តស៊ីប់សួន មានសម្ងាញ់ មានសភាពយ៉ាងនេះ ។ សមណៈនោះ មានសក្តិធំ ។ ពោលថា សមណៈណា នៅក្នុងវិហារ មានសភាពយ៉ាងនេះ សមណៈនោះមានសក្តិធំ ។

យោ ឯវរូបេ អជ្ឈាយោគេ វសតិ[1] ហម្មិយេ វសតិ គុហាយំ វសតិ[2] កុដិយា វសតិ កូដាគារេ វសតិ អដ្ដេ វសតិ មាឡេ វសតិ ឧទ្ទណ្ឌេ វសតិ ឧបដ្ឋានសាលាយំ វសតិ មណ្ឌបេ វសតិ រុក្ខមូលេ វសតិ សោ សមណោ មហេសក្ខោតិ ភណាតិ ។ អថវា កោរជិកកោរជិកោ ភាកុដិកភាកុដិកោ កុហកុហោ លបលបោ មុខសម្ភាវិតោ អយំ សមណោ ឥមាសំ ឯវរូបានំ សន្តានំ វិហារសមាបត្តីនំ លាភីតិ តាទិសំ គម្ភីរំ គូឡ្ហំ និបុណំ បដិច្ឆន្នំ លោកុត្តរសុញ្ញតាបដិសញ្ញុត្តំ កថំ កថេតិ ។ យា ឯវរូបា ភាកុដិកា ភាកុដិយំ កុហនា កុហាយនា កុហាយិតត្តំ ឥទំ សាមន្តជប្បនសង្ខាតំ កុហនវត្ថុ ។

១ ម. ឯត្ថន្តរេ បាសាទេ វសតីតិ ទិស្សតិ ។ ២ ម. ឯត្ថន្តរេ លេណេ វសតីតិ ទិស្សតិ ។

ពោលថា សមណៈណា នៅក្នុងអឌ្ឍយោគ (បង្ហា) នៅក្នុងប្រាសាទ មានកំពូល នៅក្នុងគុហា នៅក្នុងខ្ទម នៅក្នុងផ្ទះកំពូល នៅក្នុងប៉ម នៅក្នុងពោងមូល នៅក្នុងថែវ នៅក្នុងឧបដ្ឋានសាលា នៅក្នុងមណ្ឌប (បាវ៉ាំ) នៅក្បែរគល់ឈើ មានសភាពយ៉ាងនេះ ។ សមណៈនោះ មានសក្តិធំ ។ ម្យ៉ាងទៀត ភិក្ខុជាអ្នកស្រគត់ស្រគំពេក មានមុខស្រពាប់ស្រពោនពេក ជាអ្នកកុហកពេក ជាអ្នករួសរាយពេក ដែលត្រូវគេសរសើរ ដោយអំណាចមាត់ (របស់ខ្លួន) ថា សមណៈនេះ ជាអ្នកបាននូវវិហារសមាបត្តិទាំងនេះ ជាគុណដ៏ស្ងប់ស្ងាត់ មានសភាពយ៉ាងនេះ តែងពោលពាក្យប្រាកដដូច្នេះ ជាពាក្យជ្រាលជ្រៅ លំបាកយល់ដ៏ល្អិត កំបិទបំបាំង ជាវាចាប្រកបដោយលោកុត្តរធម៌ និងសុញ្ញត-និព្វាន ។ អាការធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន ការកុហក អាការនៃកុហក ភាពនៃកុហក មានសភាពយ៉ាងនេះ ឯណានេះហៅថា កុហនវត្ថុ ប៉ែកខាងការខ្សឹប ។

ខគ្គវិសាណសុត្តនិទ្ទេសោ

តស្ស បចេ្ចកសម្ពុទ្ធស្ស ឥមានិ តីណិ ការ-
ណានិ បហីនានិ សមុច្ឆិន្នានិ រុបសន្តានិ បដិប្ប-
ស្ស-ទ្ធានិ អភព្ពុប្ប-ត្តិ-កានិ ញាណ-ក្ខិ-ន ឌ-ឌ្ឍ-
ានិ តស្មា សោ បចេ្ចកសម្ពុ-ទ្ធោ និ-ក្ក-ុ-ហោ ។ និ-ប្ប-ិ-ចា-សោ-ត-ិ
ប-ិ-ចា-ស-ា រ-ុ-ច-ូ-ត-ិ ត-ណ-្ហ-ា យ-ោ ភ-ោ-ត-ោ ស-ា-ភ-ោ-ត-ោ ។ ប-េ ។
អ-ភ-ិ-ជ-្ឌ-ា ល-ោ-ភ-ោ អ-ក-ុ-ស-ល-ម-ូ-ល-ំ ។ ស-ា ប-ិ-ចា-ស-ា
ត-ណ-្ហ-ា ត-ស-្ស ប-ចេ-ក-ស-ម-្ព-ុ-ទ-្ធ-ស-្ស ប-ហ-ីន-ា ឧ-ច-្ឆ-ិ-ន-្ន-ម-ូ-
ល-ា ត-ាល-ាវ-ត-ុ-ក-ត-ា អ-ន-ា-ម-ត-ិ-ក-ត-ា អ-ាយ-ត-ឹ-អ-ន-ុ-ប-្ប-ាទ-
ធ-ម-្ម-ា ត-ស-្ម-ា ស-ោ ប-ចេ-ក-ស-ម-្ព-ុ-ទ-្ធ-ោ និ-ប-្ប-ិ-ចា-ស-ោ-ត-ិ
និ-ល-្ម-ោ-ល-ុ-ចោ និ-ក-្ក-ុ-ហោ និ-ប-្ប-ិ-ចា-ស-ោ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

កុហនវត្ថុទាំង ៣ នេះ ព្រះបច្ចេកសម្ពុទ្ធនោះ បានលះបង់ ផ្តាច់ ផ្តិល រម្ងាប់ គ្របសង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាអ្នកមិនកុហក ។ ពាក្យថា អ្នកមិនមានការស្រេកឃ្វាន សេចក្តីថា តណ្ហា លោកហៅថា ការស្រេកឃ្វាន បានដល់តម្រេក តម្រេកខ្លាំង ។ បេ ។ អកិញ្ចា លោក: អកុសលមូល ។ តណ្ហាគឺការស្រេកឃ្វានៃ ព្រះ បច្ចេកសម្ពុទ្ធនោះ បានលះបង់ គាស់ឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន ឲ្យជាធម៌លែងកើត តទៅទៀត ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាអ្នកមិនមាន ការស្រេកឃ្វាន ហេតុនោះ (លោកពោលថា) បុគ្គលអ្នកមិនលោក អ្នកមិនកុហក អ្នកមិនមានការស្រេកឃ្វាន ។

[៣១៤] និម្មក្ខោ និច្ចន្តកសាវមោហោតិ ម-ក្ខោតិ យោ មក្ខោ មក្ខាយនា មក្ខាយិតត្តំ និដ្ឋ-រិយំ និដ្ឋរិយកម្មំ ។ កសាវាតិ ភគោ កសាវោ ឧោសោ កសាវោ មោហោ កសាវោ ឧោឧោ ឧបនាហោ មក្ខោ បឬ្ចាសោ ។ បេ ។ សព្ជាកុស-លាភិសង្ខ្លារ កសាវា ។ មោហោតិ ឧុក្ខេ អញ្ញា-ណំ ឧុក្ខសមុឧយេ អញ្ញាណំ ឧុក្ខនិរោធេ អញ្ញាណំ ឧុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ បុព្ជន្តេ អញ្ញាណំ អបរន្តេ អញ្ញាណំ បុព្ជន្តាបរន្តេ អញ្ញាណំ ឥឧប្ជចូយតាបដិចូសមុប្ជន្នេសុ ឧម្មេសុ អញ្ញាណំ យំ ឬ្ជរូបំ អញ្ញាណំ អឧស្ជនំ អនភិសមយោ អន-ឧុពោធោ សម្ពោធោ អប្ជដិវេធោ អសង្ខ្លាហានា អប-រិយោតាហានា អសមបេក្ខនា អប្ជចូវេក្ខនា អប្ជចូក្ខ-កម្មំ ឧុម្ទេជ្ជ៎ ពាលៃ អសម្ជជញ្ញ មោហោ សម្ទោហោ

[៣១២] *អធិប្បាយពាក្យថា អ្នកមិនមានការលុបគុណគេ មានទឹកចត់និងមោហៈកម្ចាត់ចេញហើយ ត្រង់ពាក្យថា ការលុបគុណ បានខាងការបំបាត់គុណ អាការៈនៃការលុបគុណ ភាពនៃការលុបគុណ សេចក្តីច្រណែន កម្មគឺសេចក្តីច្រណែន ។ ពាក្យថា ទឹកចត់ សំដៅយកវាគៈ ឈ្មោះថាទឹកចត់ ទោសៈ ឈ្មោះថាទឹកចត់ មោហៈ ឈ្មោះថាទឹកចត់ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ។ បេ ។ អកុសលាភិសង្ខារទាំងអស់ ឈ្មោះថាទឹកចត់ ។ ពាក្យថា មោហៈ បានដល់ការមិនដឹងក្នុងទុក្ខ ការមិនដឹងក្នុងទុក្ខសមុទ័យ ការមិនដឹងក្នុងទុក្ខនិរោធ ការមិនដឹងក្នុងទុក្ខនិរោធ-គាមិនីបដិបទា ការមិនដឹងក្នុងចំណែកខន្ធមុន ការមិនដឹងក្នុងចំណែកខន្ធក្រោយ ការមិនដឹងក្នុងចំណែកខន្ធមុននិងចំណែកខន្ធក្រោយ ការមិនដឹងក្នុងធម៌ទាំងឡាយ ដែលអាស្រ័យគ្នាកើតឡើង ព្រោះធម៌នេះជាបច្ច័យ គឺ ដែលជាការមិនដឹង ការមិនឃើញ ការមិនយល់ច្បាស់ ការមិនត្រាស់ដឹងតាម ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនកាន់យក (ដោយសាមញ្ញលក្ខណៈ) ការមិនចុះកាន់ (សាមញ្ញលក្ខណៈ) ការមិនសម្ងឹងស្មើ ការមិនពិចារណា អំពើមិនជាក់ច្បាស់ សន្ធានចិត្ត អាក្រក់ ភាពជាបុគ្គលល្ងង់ ការមិនដឹងខ្លួន ការវង្វេង ការវង្វេងសព្វ*

អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាជាលំ[១] អវិជ្ជាលង្គី មោហោ អកុសលមូលំ ។ តស្ស បច្ចេកសម្ពុទ្ធស្ស មក្ខោ ច កសាវោ ច មោហោ ច វន្តា[២] និទ្ធន្តា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា តស្មា សោ បច្ចេកសម្ពុទ្ធោ និម្មក្ខោ និទ្ធន្តកសាវមោហោ ។

[៣១៤] និរាសសោ សព្វលោកោ ភវិត្វាតិ អាសា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ សព្វលោកេតិ សព្វអបាយលោកេ សព្វមនុស្សលោកេ សព្វទេវលោកេ សព្វខន្ធលោកេ សព្វធាតុលោកេ សព្វអាយតនលោកេ ។ និរាសសោ សព្វលោកេ ភវិត្វាតិ សព្វលោកេ និរាសសោ ភវិត្វា និត្តណ្ហោ ភវិត្វា និប្បិបាសោ ភវិត្វាតិ និរាសសោ សព្វលោកេ ភវិត្វា ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។

១ ម. អយំ បាឋោ នត្ថិ ។ ២ ម. វន្តា សំវន្តា ។

អន្ទង់គឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា កិលេសជាគ្រឿងគ្របសង្កត់ចិត្តគឺអវិជ្ជា បណ្តាញគឺអវិជ្ជា សន្ទះទ្វារធំគឺអវិជ្ជា មោហៈ អកុសលមូលមានសភាពយ៉ាងនេះ ។ ការលុបគុណ ទឹកចត់ និងមោហៈ ព្រះបច្ចេក-សម្ពុទ្ធនោះ បានខ្ជាក់ចោល កម្ចាត់ចោល លះបង់ កាត់ផ្តាច់ រម្ងាប់គ្របសង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតបំផ្ទាញដោយភ្លើងគឺញាណ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាអ្នកមិនមានការលុបគុណគេ មានទឹកចត់និងមោហៈកម្ចាត់ចេញហើយ ។

[៣១៥] *ពាក្យថា មិនមានសេចក្តីប្រាថ្នា ក្នុងលោកទាំងមូល សេចក្តីថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានខាងតម្រេក តម្រេកខ្លាំង ។ បេ ។ អកិញ្ចា លោកៈ អកុសលមូល ។ ពាក្យថា ក្នុងលោកទាំងមូល គឺ ក្នុងអបាយលោកទាំងមូល មនុស្សលោកទាំងមូល ទេវលោកទាំងមូល ខន្ធលោកទាំងមូល ធាតុលោកទាំងមូល អាយតនលោកទាំងមូល ។ ពាក្យថា មិនមានសេចក្តីប្រាថ្នាក្នុងលោកទាំងមូល បានសេចក្តីថា ជាអ្នកមិនមានសេចក្តីប្រាថ្នា មិនមានតណ្ហា មិនមានសេចក្តីស្រេកឃ្ងានក្នុងលោកទាំងមូល ហេតុនោះ (លោកពោលថា) មិនមានសេចក្តីប្រាថ្នាក្នុងលោកទាំងមូល ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។*

តេនាហ សោ បច្ចេកសម្ពុទ្ធោ

និល្លោលុបោ និក្កុហោ និប្បិបាសោ
និម្មក្ខោ និទ្ធន្តកសាវមោហោ
និរាសសោ សព្វលោកេ ភវិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[៣១៦] បាបំ សហាយំ បរិវជ្ជយេថ
អនត្ថទស្សឹ វិសមេ និវិដ្ឋំ
សយំ ន សេវេ បសុតំ បមត្តំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[៣១៧] បាបំ សហាយំ បរិវជ្ជយេថាតិ បាបសហាយោ វុច្ចតិ យោ សោ សហាយោ ទសវត្ថុកាយ មិច្ឆាទិដ្ឋិយា សមន្នាគតោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ

ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលអ្នកមិនលោភ អ្នកមិនកុហក អ្នកមិនមានការស្រេកឃ្លាន អ្នកមិនមានការលុបគុណគេ មានទឹកចិត្ត និងមោហ:កម្ចាត់ចេញហើយ មិនមានសេចក្តីប្រាថ្នាក្នុងលោកទាំងមូល គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣១៦] បុគ្គល គួរជៀសវាង នូវសម្ងាញ់អាក្រក់ អ្នកឃើញនូវអំពើមិនមានប្រយោជន៍ អ្នកតាំងនៅក្នុងអំពើមិនស្មើ មិនគួរសេពគប់នូវបុគ្គលអ្នកខ្ជិលខ្ជាយ អ្នកធ្វេសប្រហែស ដោយខ្លួនឯង គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣១៧] ពាក្យថា បុគ្គលគួរជៀសវាង នូវសម្ងាញ់អាក្រក់ សេចក្តីថា ដែលហៅថា សម្ងាញ់អាក្រក់ បានដល់សម្ងាញ់ដែលប្រកបដោយមិច្ឆាទិដ្ឋិ មានវត្ថុ ១០ យ៉ាងថា ទានដែលគេឲ្យមិនមានផល បូជាធំមិនមានផល បូជាតូចមិនមានផល ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អធ្វើអាក្រក់ មិនមាន លោកនេះមិនមាន លោកដទៃមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ ពួកសត្វជាឱ្យបបាតិក:មិនមាន

ខគ្គវិសាណសុត្តនិទ្ទេសោ

លោកេ សមណាព្រាហ្មណា សម្ផក្ពតា សម្ផាបដិប-ជ្ជា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អ-ភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ អយំ ចាបសហាយោ ។ ចាបំ សហាយំ បរិវជ្ជយេថាតិ ចាបំ សហាយំ បរិវជ្ជយេថ រិវជ្ជេយ្យ បរិវជ្ជេយ្យាតិ ចាបំ សហាយំ បរិវជ្ជយេថ ។

[៣១៨] អនត្ថជ្ជ្ជ រិសមេ ជិវិជ្ជន្តិ អនត្ថ-ជ្ជ្ជ រុច្ចតិ យោ សោ សហាយោ ឧសវត្ថុកាយ មិច្ឆាជិជ្ជិយា សមជ្ជ្ជាកតោ ជត្តិ ជិជ្ជ្ជ ជត្តិ យិជ្ជ្ជ ។ បេ ។ យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ អយំ អនត្ថជ្ជ្ជ ។

ពួកសមណៈព្រាហ្មណ៍ក្នុងលោក ដែលប្រព្រឹត្តត្រឹមត្រូវ ប្រតិបត្តិត្រឹមត្រូវ បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាយ៉ាងខ្ពង់ខ្ពស់ចំពោះខ្លួន ហើយប្រកាសនូវលោកនេះ និងលោកខាងមុខ មិនមាន សម្ងាញ់បែបនេះ ឈ្មោះថាសម្ងាញ់អាក្រក់ ។ ពាក្យថា បុគ្គលគួរជៀសវាង នូវសម្ងាញ់អាក្រក់ បានសេចក្តីថា បុគ្គលគួរជៀសវាង គួរវៀរលែង គួរគេចវាង នូវសម្ងាញ់អាក្រក់ ហេតុនោះ (លោកពោលថា) បុគ្គលគួរជៀសវាងនូវសម្ងាញ់អាក្រក់ ។

[៣១៨] ពាក្យថា អ្នកឃើញនូវអំពើមិនមានប្រយោជន៍ អ្នកតាំងនៅក្នុងអំពើមិនស្មើ សេចក្តីថា ដែលហៅថា អ្នកឃើញនូវអំពើមិនមានប្រយោជន៍ បានខាងសម្ងាញ់ ដែលប្រកបដោយមិច្ឆាទិដ្ឋិ មានវត្ថុ ១០ យ៉ាងថា ទានដែលគេឲ្យ មិនមានផល បូជាធំ មិនមានផល ។ បេ ។ ដែលបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាយ៉ាងខ្ពង់ខ្ពស់ចំពោះខ្លួន ហើយប្រកាសនូវលោកនេះ និងលោកខាងមុខ មិនមាន សម្ងាញ់បែបនេះ ឈ្មោះថា សម្ងាញ់អ្នកឃើញ នូវអំពើមិនមានប្រយោជន៍ ។

វិសមេ ជិវ្ហិដ្ឋិ្ច វិសមេ ការយការ្ម ជិវ្ហិ្ច វិសមេ
ចិតការ្ម ជិវ្ហិ្ច វិសមេ មនោការ្ម ជិវ្ហិ្ច វិសមេ
ចាណាតិចាតេ ជិវ្ហិ្ច វិសមេ អទិន្នាទានេ ជិវ្ហិ្ច វិស-
មេ ការាមេសុមិច្ឆាចារេ ជិវ្ហិ្ច វិសមេ មុសាវាទេ
ជិវ្ហិ្ច វិសមាយ បិសុណាយ វាចាយ ជិវ្ហិ្ច វិសមា-
យ ផរុសាយ វាចាយ ជិវ្ហិ្ច វិសមេ សម្ផប្ផលាបេ
ជិវ្ហិ្ច វិសមាយ អភិជ្ឌាយ ជិវ្ហិ្ច វិសមេ ព្យាបាទេ
ជិវ្ហិ្ច វិសមាយ មិច្ឆាទិដ្ឋិយា ជិវ្ហិ្ច វិសមេសុ សង្ខា-
រេសុ ជិវ្ហិ្ច វិសមេសុ បញ្ចសុ ការាមគុណេសុ ជិវ្ហិ្ច
សត្តំ អលីកំ ឧបកតំ អជ្ឌោសិតំ អធិមុត្តិ្ច អនត្ត-
ទស្ឬ វិសមេ ជិវ្ហិ្ច ។

ពាក្យថា អ្នកតាំងនៅក្នុងអំពើមិនស្មើ សេចក្តីថា អ្នកតាំងនៅក្នុងកាយកម្ម មិនស្មើ តាំងនៅក្នុងវចីកម្មមិនស្មើ តាំងនៅក្នុងមនោកម្មមិនស្មើ គឺថា តាំងនៅក្នុងកម្មមិនស្មើ គឺបាណាតិបាត តាំងនៅក្នុងកម្មមិនស្មើគឺអទិន្នាទាន តាំងនៅក្នុងកម្មមិនស្មើគឺកាមេសុមិច្ឆាចារ តាំងនៅក្នុងកម្មមិនស្មើគឺមុសា-វាទ តាំងនៅក្នុងកម្មមិនស្មើ គឺបិសុណាវាចា តាំងនៅក្នុងកម្មមិនស្មើ គឺផរុសវាចា តាំងនៅក្នុងកម្មមិនស្មើ គឺសម្ផប្បលាបៈ តាំងនៅក្នុងកម្មមិនស្មើ គឺអភិជ្ឌា តាំងនៅក្នុងកម្មមិនស្មើ គឺព្យាបាទ តាំងនៅក្នុងកម្មមិនស្មើ គឺមិច្ឆាទិដ្ឋិ តាំងនៅក្នុងកម្មទាំងឡាយមិនស្មើ គឺសង្ខារ តាំងនៅ ជាប់ជាប់ស្ងិត ចូលទៅដល់ស៊ប់ លិចចុះ ចុះចិត្តស៊ប់ ក្នុងកម្មមិនស្មើ គឺ កាមគុណ ៥ ហេតុនោះ (លោកពោលថា) អ្នកឃើញ នូវអំពើមិន មានប្រយោជន៍ អ្នកតាំងនៅក្នុងអំពើមិនស្មើ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

[៣១៩] សយំ ច សេវេ បសុតំ បមត្តន្តិ បសុ-
តន្តិ យោបិ កាមេ ឯសតិ គវេសតិ បរិយេសតិ
តច្ចរិតោ តព្វហុលោ តគ្គរុកោ តន្និន្នោ តប្បោណោ
តប្បព្ភារោ តទធិមុត្តោ តទាធិបតេយ្យោ សោបិ
កាមប្បសុតោ ។ យោបិ តណ្ហាវសេន រូបេ បរិ-
យេសតិ យោបិ តណ្ហាវសេន រូបេ បដិលភតិ
យោបិ តណ្ហាវសេន រូបេ បរិភុញ្ជតិ សទ្ទេ គន្ធេ
រសេ ផោដ្ឋព្វេ បរិភុញ្ជតិ តច្ចរិតោ តព្វហុលោ
តគ្គរុកោ តន្និន្នោ តប្បោណោ តប្បព្ភារោ តទធិ-
មុត្តោ តទាធិបតេយ្យោ សោបិ កាមប្បសុតោ ។

ខគ្គវិសាណសុត្តនិទ្ទេស

[៣១៩] អធិប្បាយពាក្យថា មិនគួរសេពគប់ នូវបុគ្គលអ្នកខ្ជិលខ្ជាយ អ្នកធ្វេសប្រហែស ដោយខ្លួនឯង ត្រង់ពាក្យថា បុគ្គលអ្នកខ្ជិលខ្ជាយ សេចក្តីថា បុគ្គលណា ដើររក ស្វែងរក ស្វះស្វែងរក នូវកាមទាំងឡាយ ជាអ្នកប្រព្រឹត្តកាមនោះ ច្រើនដោយកាមនោះ ជ្ងន់ក្នុងកាមនោះ ទេរទៅរកកាមនោះ ទោទៅរកកាមនោះ ឈមទៅរកកាមនោះ ចុះចិត្តស៊ប់ក្នុងកាមនោះ យកកាមនោះជាអធិបតី បុគ្គលនោះឯង ឈ្មោះថាអ្នកខ្ជិលខ្ជាយក្នុងកាម ។ បុគ្គលណាស្វះស្វែងរករូបទាំង-ឡាយ ដោយអំណាចតណ្ហាក្តី បុគ្គលណា បានរូបទាំងឡាយ ដោយអំណាចតណ្ហាក្តី បុគ្គលណា ប្រើប្រាស់រូបទាំងឡាយ ដោយអំណាចតណ្ហាក្តី ប្រើប្រាស់សំឡេង ក្លិន រស និងផោដ្ឋព្ព: ដោយអំណាចតណ្ហាក្តី ជាអ្នកប្រព្រឹត្តអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ជ្ងន់ក្នុងអារម្មណ៍នោះ ទេរទៅរកអារម្មណ៍នោះ ទោរទៅរកអារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ចុះចិត្តស៊ប់ក្នុងអារម្មណ៍នោះ យកអារម្មណ៍នោះជាអធិបតី បុគ្គលនោះឯង ក៏ឈ្មោះថាអ្នកខ្ជិលខ្ជាយក្នុងកាមដែរ ។

បមត្តន្តិ បមាទោ វត្តព្ពោ ។ កាយទុច្ចរិតេ វា វចី-ទុច្ចរិតេ វា មនោទុច្ចរិតេ វា បញ្ចសុ វា កាមគុ-ណេសុ ចិត្តស្ស ហេស្សត្តោ ហេស្សត្តានុប្បជានំ កុសលានំ វា ធម្មានំ ភាវនាយ អសក្ក្ចកិរិយតា អសាតចកិរិយតា អនដ្ឋិតកិរិយតា ឋិលីនវុត្តិតា និក្ខិត្តច្ឆន្ទតា និក្ខិត្តធុរតា អនាសេវនា អភាវនា អពហុលីកម្មំ អនធិដ្ឋានំ អននុយោគោ យោ ឯវ-ម្ភូ បមាទោ បមជ្ជនា បមជ្ជិតត្តំ អយំ វុច្ចតិ បមា-ទោ ។ សយំ ន សេវេ បសុតំ បមត្តន្តិ បសុតញ្ច ន សេវេយ្យ បមត្តញ្ច ន សេវេយ្យ ន និសេវេយ្យ ន សំសេវេយ្យ ន បដិសេវេយ្យ ន អាចរេយ្យ ន សមាចរេយ្យ ន សមាទាយ វត្តេយ្យាតិ សយំ ន សេវេ បសុតំ បមត្តំ ។ ឯសោ ចេ ១ក្ខវិសាណ-កប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

ពាក្យថា អ្នកធ្វេសប្រហែស គឺសេចក្តីធ្វេសប្រហែស ខ្ញុំគប្បីពោលដូចតទៅនេះ ។ ការបណ្តោយចិត្ត ការផ្តល់កម្ទាំងដល់ការបណ្តោយចិត្ត ក្នុងកាយទុច្ចរិតក្តី ក្នុងវចីទុច្ចរិតក្តី ក្នុងមនោទុច្ចរិតក្តី ក្នុងកាមគុណទាំង ៥ ក្តី ពុំនោះសោត ការមិនធ្វើដោយផ្ចិតផ្ចង់ ការមិនធ្វើរឿយៗ ការមិនធ្វើឲ្យបិតថេរ កិរិយាប្រព្រឹត្តរួញរា ការដាក់សេចក្តីប្រាថ្នា ការដាក់ធុរៈ ការមិនសេពគប់ ការមិនចម្រើន ការមិនធ្វើឲ្យច្រើន ការមិនអធិដ្ឋាន ការមិនប្រកបរឿយៗ ក្នុងការចម្រើននូវធម៌ទាំងឡាយជាកុសល សេចក្តីប្រហែស សេចក្តីធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះឯណា នេះលោកហៅថា សេចក្តីធ្វេសប្រហែស ។ ពាក្យថា មិនគួរសេពគប់ នូវបុគ្គលអ្នកខ្ជិលខ្ជាយ អ្នកធ្វេសប្រហែសដោយខ្លួនឯង បានសេចក្តីថា មិនគួរសេព នូវបុគ្គលអ្នកខ្ជិលខ្ជាយផង មិនគួរសេព មិនគួរគប់រក មិនគួររាប់រក មិនគួររាប់អាន មិនគួរប្រព្រឹត្តអើពើ មិនគួរប្រព្រឹត្តរួម មិនគួរប្រព្រឹត្តសមាទាន នូវបុគ្គលអ្នកធ្វេសប្រហែសផង ហេតុនោះ (លោកពោលថា) មិនគួរសេពគប់ នូវបុគ្គលអ្នកខ្ជិលខ្ជាយ អ្នកធ្វេសប្រហែស ដោយខ្លួនឯង ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ព្រោះហេតុនោះ ព្រះបច្ចេក-សម្ពុទ្ធនោះ ពោលថា

ខគ្គវិសាណសុត្តនិទ្ទេសោ

ចាបំ សហាយំ បរិវជ្ជយេថ
អនត្ថទស្សឺ វិសមេ និវិដ្ឋំ
សយំ ន សេវេ បសុតំ បមត្តំ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[៣២០] ពហុស្សុតំ ធម្មធរំ ភជេថ
មិត្តំ ឧឡារំ បដិភាណវន្តំ
អញ្ញាយ អត្ថានិ វិនេយ្យ កង្ខំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[៣២១] ពហុស្សុតំ ធម្មធរំ ភជេថាតិ ពហុ-ស្សុតន្តិ ពហុស្សុតោ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថា សព្យញ្ជនា កេវ-លបរិបុណ្ណា បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូ-បស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ។

បុគ្គលគួរជៀសវាង នូវសម្ងាញ់អាក្រក់ អ្នកឃើញនូវ អំពើមិនមានប្រយោជន៍ អ្នកតាំងនៅក្នុងអំពើមិនស្មើ មិនគួរសេពគប់ នូវបុគ្គលអ្នកខ្ជិលខ្ជាយ អ្នកធ្វេស ប្រហែស ដោយខ្លួនឯង គប្បីប្រព្រឹត្តម្នាក់ឯង ដូច កុយរមាស ។

[៣២០] *បុគ្គលគួរគប់រកជនជាពហុស្សូត អ្នកទ្រទ្រង់ធម៌ ជាមិត្តដ៏ខ្ពង់ខ្ពស់ មានបដិភាណ បុគ្គលបានដឹងច្បាស់ នូវប្រយោជន៍ទាំងឡាយហើយ គួរកម្ចាត់ នូវសេចក្តី សង្ស័យ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។*

[៣២១] *អធិប្បាយពាក្យថា បុគ្គលគួរគប់រកជន ជាពហុស្សូត អ្នកទ្រទ្រង់ធម៌ ត្រង់ពាក្យថា ជនជាពហុស្សូត គឺ ជនអ្នកចេះដឹងច្រើន អ្នកចងចាំនូវសូត្រ សន្សំទុកនូវសូត្រ គឺថា ធម៌ទាំងឡាយណា មាន លម្អបទដើម លម្អបទកណ្តាល លម្អបទចុង ព្រមទាំងអត្ថនិងព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយៈ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមាន សភាពដូច្នោះ ជននោះបានស្តាប់ច្រើន បានទ្រទ្រង់ បានចាំស្ទាត់រត់ មាត់ បានពិនិត្យមើលដោយចិត្ត បានចាក់ធ្ងុះប្រពៃដោយសេចក្តីយល់ ។*

ធម្មធរន្តិ ធម្មំ ធារេន្តំ សុត្តំ គេយ្យំ វេយ្យាការណំ
គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភូតធម្មំ វេ-
ទល្លំ ។ ពហុស្សុតំ ធម្មធរំ ភគវាតិ ពហុស្សុតញ្ច
ធម្មធរញ្ច មិត្តំ ភគវាយ្យ សេវេយ្យ ភជិសេវេយ្យ សំ-
សេវេយ្យ បដិសេវេយ្យាតិ ពហុស្សុតំ ធម្មធរំ ភគវាថ ។

[៣២២] មិត្តំ ឧប្ប៉ារ៉ំ បដិភាណវន្តន្តិ ឧប្ប៉ាវោ
ហោតិ មិត្តោ សីលេន សមាធិនា បញ្ញាយ វិមុត្តិ-
យា វិមុត្តិញ្ញាណទស្ស៊នេន ។ បដិភាណវន្តន្តិ ឆយោ
បដិភាណវន្តោ បរិយត្តិប្ប៉ដិភាណា បរិបុច្ឆាបដិភា-
ណា អធិគមប្ប៉ដិភាណា ។

ឆតមោ បរិយត្តិប្ប៉ដិភាណា ។ ឥធេកច្ចស្ស
ពុទ្ធវចនំ បរិយាបុដំ ហោតិ សុត្តំ គេយ្យំ វេយ្យាការ-
ណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភូតធម្មំ
វេទល្លំ ឥស្ស បរិយត្តី ជិស្ស៊ាយ ឧដ្ឋាតិ អយំ
បរិយត្តិប្ប៉ដិភាណា ។

ពាក្យថា អ្នកទ្រទ្រង់ធម៌ សេចក្ដីថា អ្នកទ្រទ្រង់នូវធម៌ គឺ សុត្ត: គេយ្យ: វេយ្យាករណ: គាថា ឧទាន: ឥតិវុត្តក: ជាតក: អព្ភូតធម្ម: វេទ-ល្ល: ។ ពាក្យថា បុគ្គលគួរគប់រកជនជាពហុស្សូត អ្នកទ្រទ្រង់ធម៌ បានសេចក្ដីថា បុគ្គលគួរគប់រក គួរសេព គួររាប់រក គួររាប់អាន គួរសេពចំពោះ នូវមិត្តជាពហុស្សូតផង អ្នកទ្រទ្រង់ធម៌ផង ហេតុនោះ (លោកពោលថា) បុគ្គលគួរគប់រកជនជាពហុស្សូត អ្នកទ្រទ្រង់ធម៌ ។

[៣២២] ពាក្យថា ជាមិត្តដ៏ខ្ពង់ខ្ពស់ មានបដិភាណ អធិប្បាយថា ជនជាមិត្តដ៏ខ្ពង់ខ្ពស់ ដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិ-ញ្ញាណទស្សន: ។ ពាក្យថា មានបដិភាណ គឺជនមានបដិភាណ ៣ ពួក គឺមានបដិភាណក្នុងបរិយត្តិ ១ មានបដិភាណក្នុងបរិបុច្ឆា ១ មានបដិភាណក្នុងអធិគម: ១ ។

ជនអ្នកមានបដិភាណក្នុងបរិយត្តិ តើដូចម្ដេច ។ ជនខ្ះក្នុងសាស-នានេះ បានរៀននូវពុទ្ធវចន: គឺសុត្ត: គេយ្យ: វេយ្យាករណ: គាថា ឧទាន: ឥតិវុត្តក: ជាតក: អព្ភូតធម្ម: វេទល្ល: (ពុទ្ធវចន:នោះ) រមែងក្ដឿច្បាស់ដល់ជននោះ ព្រោះអាស្រ័យបរិយត្តិ នេះឈ្មោះថាអ្នកមានបដិភាណក្នុងបរិយត្តិ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

កតមោ បរិបុច្ឆាបដិកាណាវ ។ ឥធេកច្ចោ បរិបុច្ឆិតោ ហោតិ អត្ថេ ច ញាយេ ច លក្ខណេ ច ការណេ ច ឋានាឋានេ ច តស្ស បរិបុច្ឆំ និស្សាយ បដិភាតិ អយំ បរិបុច្ឆាបដិកាណាវ ។

កតមោ អនិតមប្បដិកាណាវ ។ ឥធេកច្ចស្ស អនិតតា ហោន្តិ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ចត្តារោ អរិយមគ្គា ចត្តារិ សាមញ្ញផលានិ ចតស្សោ បដិសម្ភិទាយោ ឆឡភិញ្ញាយោ ។ តស្ស អត្ថោ ញាតោ ធម្មោ ញាតោ និរុត្តិ ញាតា ។ អត្ថេ ញាតេ អត្ថោ បដិភាតិ[(១)] ធម្មេ ញាតេ ធម្មោ បដិភាតិ[(២)] និរុត្តិយា ញាតាយ និរុត្តិ បដិភាតិ[(៣)] ។ ឥមេសុ តីសុ ញាណំ បដិភាណប្បដិសម្ភិទា ។

១-២-៣ ម. បដិភាយតិ ។

ខគ្គវិសាណសុត្តនិទ្ទេស

ជនអ្នកមានបដិភាណ ក្នុងបរិបុច្ឆា តើដូចម្តេច ។ ជនខ្លះក្នុងសាសនានេះ ជាអ្នកសាកសួរក្នុងអត្ថ ក្នុងធម៌ដែលគួរដឹង ក្នុងលក្ខណៈ ក្នុងហេតុ ក្នុងឋានៈនិងអដ្ឋានៈ (សភាវៈមានអត្ថជាដើម) រមែងភ្ញឹកប្បាស់ដល់ជននោះ ព្រោះអាស្រ័យការសាកសួរ នេះ ឈ្មោះថាអ្នកមានបដិភាណក្នុងបរិបុច្ឆា ។

ជនអ្នកមានបដិភាណ ក្នុងអធិគមៈ តើដូចម្តេច ។ ជនខ្លះក្នុងសាសនានេះ បានត្រាស់ដឹងនូវសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិ-បាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឌង្គ ៧ មគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ អរិយមគ្គ ៤ សាមញ្ញផល ៤ បដិសម្ភិទា ៤ អភិ-ញ្ញា ៦ ។ បុគ្គលនោះ បានដឹងអត្ថ ដឹងធម៌ ដឹងនិរុត្តិ ។ កាលបើដឹងអត្ថហើយ អត្ថ រមែងប្បាស់ប្រាកដ កាលបើដឹងធម៌ហើយ ធម៌ រមែងប្បាស់ប្រាកដ កាលបើដឹងនិរុត្តិហើយ និរុត្តិ រមែងប្បាស់ប្រាកដ ។ ការដឹងក្នុងបដិភាណទាំង ៣ នេះ ឈ្មោះថាបដិភាណប្បដិសម្ភិទា ។

សោ បចេ្ចកសម្ពុទ្ធោ ឥមាយ បដិកាណាឬ្ជដិសម្ភិ-
ជាយ ឧបេតោ សមុបេតោ ឧចាកតោ សមុចាកតោ
ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា បចេ្ចក-
សម្ពុទ្ធោ បដិកាណាវ ។ យស្ស បរិយត្តិ ន ត្ថិ បរិ-
បុច្ឆា ន ត្ថិ អធិគមោ ន ត្ថិ កឹ តស្ស បដិកាយិស្ស-
តីតិ មិត្តំ ឧឬ្ជារ បដិកាណាវ ។

[៣២៣] អញ្ញាយ អត្ថានិ វិនេយ្យ កង្ខ្ជ្ជ
អត្ថត្ថំ អញ្ញាយ បរត្ថំ អញ្ញាយ ឧភយត្ថំ អញ្ញាយ
ធិជ្ជធម្មិកត្ថំ អញ្ញាយ សម្ប្ជាយិកត្ថំ អញ្ញាយ[1]
អកិញ្ញាយ ជានិត្ថា តុលយិត្ថា តីរយិត្ថា វិភាវយិត្ថា
វិភូតំ កត្ថា កង្ខ្ជ្ជ វិនេយ្យ បដិវិនេយ្យ បជហេយ្យ
វិនោទេយ្យ ព្យន្ត្ជីករេយ្យ អនភាវ ត្ជ្ជមេយ្យាតិ អញ្ញា-
យ អត្ថានិ វិនេយ្យ កង្ខ្ជ្ជ ។ ឯកោ ចរ ខ្ជ្ជវិសា-
ណាកប្ប ។ ត្ថេជាហ សោ បចេ្ចកសម្ពុទ្ធោ

---

1 ម. ឯត្ថន្ត្ជ បរមត្ថំ អញ្ញាយាតិ ទិស្ស្ជតិ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ប្រកប ប្រកបព្រម ចូលទៅជិត ចូលទៅជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រមដោយបដិភាណប្បដិសម្ភិ-ទានេះ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថាមានបដិភាណ ។ បុគ្គលណា មិនមានបរិយត្តិ មិនមានបរិបុច្ឆា មិនមានអធិគម: ធម្ម-ជាតអ្វី នឹងច្បាស់ប្រាកដ ដល់បុគ្គលនោះបាន ហេតុនោះ (លោកពោលថា) ជាមិត្តដ៏ខ្ពង់ខ្ពស់ មានបដិភាណ ។

[៣២៣] ពាក្យថា បុគ្គលបានដឹងច្បាស់នូវប្រយោជន៍ទាំងឡាយហើយ គួរកម្ចាត់នូវសេចក្តីសង្ស័យ សេចក្តីថា បុគ្គលដឹងនូវប្រយោជន៍ខ្លួន ដឹងនូវប្រយោជន៍ជនដទៃ ដឹងនូវប្រយោជន៍ទាំងពីរ ដឹងនូវប្រយោជន៍បច្ចុ-ប្បន្ន ដឹង ដឹងច្បាស់ ស្គាល់ ច្ងឹង ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដ នូវប្រយោជន៍ក្នុងលោកខាងមុខហើយ គួរកម្ចាត់ បំបាត់ចេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវសេចក្តីសង្ស័យ ហេតុនោះ (លោកពោលថា) បុគ្គលបានដឹងច្បាស់នូវប្រយោជន៍ទាំងឡាយហើយ គួរកម្ចាត់នូវសេចក្តីសង្ស័យ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

ខគ្គវិសាណសុត្តនិទ្ទេសោ

ពហុស្សុតំ ធម្មធរំ ភជេថ
មិត្តំ ឧឡារំ បដិកាណវន្តំ
អញ្ញាយ អត្ថានិ វិនេយ្យ កង្ខំ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[៣២៤] ទ្វិន្នា រតី កាមសុខញ្ច លោកេ
អនលង្ការិត្វា អនបេក្ខមានោ
វិភូសនដ្ឋានា វិរតោ សច្ចវាទី
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[៣២៥] ទ្វិន្នា រតី កាមសុខញ្ច លោកេតិ ទ្វិន្នាតិ ទ្វេ ទ្វិន្នា កាយិកា ច ទ្វិន្នា ចេតសិកា ច ទ្វិន្នា ។ បេ ។ អយំ កាយិកា ទ្វិន្នា ។ បេ ។ អយំ ចេតសិកា ទ្វិន្នា ។

ខគ្គវិសាណសុត្តនិទ្ទេស

បុគ្គលគួរគប់រកជនជាពហុស្សូត អ្នកទ្រទ្រង់ធម៌ ជាមិត្តដ៏ខ្ពង់ខ្ពស់ មានបដិភាណ បុគ្គលបានដឹងច្បាស់នូវប្រយោជន៍ទាំងឡាយហើយ គួរកម្ចាត់ នូវសេចក្តីសង្ស័យ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣២៧] *បុគ្គលមិនអើពើ មិនអាឡោះអាល័យនូវល្បែង នូវសេចក្តីត្រេកអរ និងកាមសុខក្នុងលោក ជាអ្នកវៀរចាកគ្រឿងស្អិតស្អាង អ្នកពោលពាក្យពិត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។*

[៣២៨] *អធិប្បាយពាក្យថា នូវល្បែង នូវសេចក្តីត្រេកអរ និងកាមសុខក្នុងលោក ត្រង់ពាក្យថា ល្បែង បានដល់ល្បែង ២ យ៉ាង គឺ ល្បែងប្រកបដោយកាយ ១ ល្បែងប្រកបដោយវាចា ១ ។ បេ ។ នេះ ល្បែងប្រកបដោយកាយ ។ បេ ។ នេះ ល្បែងប្រកបដោយវាចា ។*

រតីតិ អនុក្ក្ណ្ហិតាជិវចនមេតំ រតីតិ ។ កាម-
សុខន្តិ រុត្តញ្ហេតំ ភគវតា បញ្ចិមេ ភិក្ខវេ
កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា
ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា
រជនីយា សោតវិញ្ញេយ្យា សទ្ទា ឃានវិញ្ញេយ្យា
គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្ពា
ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា
រជនីយា ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណា
យំ ខោ ភិក្ខវេ ឥមេ បញ្ច កាមគុណេ
បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ ឥទំ វុច្ចតិ
កាមសុខន្តិ កាមសុខញ្ច ។ លោកោតិ មនុស្ស-
លោកោតិ ទ្វិន្ន្ហ រតី កាមសុខញ្ច លោកោ ។

ពាក្យថា សេចក្តីត្រេកអរ ចំពោះពាក្យថា សេចក្តីត្រេកអរ នេះ ជាឈ្មោះនៃសេចក្តីមិនអផ្សុក ។ ពាក្យថា កាមសុខ សេចក្តីថា មែនពិត ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ កាមគុណ ៥ តើដូចម្តេច រូប ដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយសេចក្តីប្រាថ្នា ជាទីតាំងនៃសេចក្តីត្រេកអរ សំឡេង ដែលគប្បីដឹងដោយត្រចៀក ក្លិន ដែលគប្បីដឹងដោយច្រមុះ រស ដែលគប្បីដឹងដោយអណ្តាត ផោដ្ឋព្វៈ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយសេចក្តីប្រាថ្នា ជាទីតាំងនៃសេចក្តីត្រេកអរ ម្នាលភិក្ខុទាំងឡាយ នេះឯង កាមគុណ ៥ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខ សោមនស្ស ណា កើតឡើងព្រោះអាស្រ័យកាមគុណ ៥ នេះ សេចក្តីសុខ សោម-នស្សនេះ តថាគតហៅថា កាមសុខ ហេតុនោះ (លោកពោលថា) កាមសុខ ។ ពាក្យថា ក្នុងលោក គឺ ក្នុងមនុស្សលោក ហេតុនោះ (លោកពោលថា) នូវល្បែង នូវសេចក្តីត្រេកអរ និងកាមសុខ ក្នុងលោក ។

[៣៦៦] អនលង្ករិត្វា អនបេក្ខមានោតិ ខិឌ្ឌញ្ច រតិញ្ច កាមសុខញ្ច លោកេ អនលង្ករិត្វា អនបេក្ខោ ហុត្វា បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ អនលង្ករិត្វា អនបេក្ខមានោ ។

[៣៦៧] វិភូសនដ្ឋានា វិរតោ សច្ចវាទីតិ វិភូសាតិ ទ្វេ វិភូសា អត្ថិ អាគារិកវិភូសា អត្ថិ អនាគារិកវិភូសា ។

កតមា អាគារិកវិភូសា ។ កេសា ច មស្សុ ច មាលា ច គន្ធា ច វិលេបនញ្ច អាភរណញ្ច បិលន្ធនញ្ច វត្ថញ្ច បសាធនញ្ច វេឋនញ្ច ឧច្ឆាទនំ បរិមទ្ទនំ នហាបនំ សម្ពាហនំ អាទាសំ អញ្ជនំ មាលាវិលេបនំ មុខចុណ្ណកំ មុខលេបនំ ហត្ថពន្ធំ សិខាពន្ធំ ទណ្ឌំ នាឡិកំ ខគ្គំ ឆត្តំ ឧបាហនា[១] ឧណ្ហីសំ វាលវីជនី[២] ឱទាតានិ វត្ថានិ ទីឃរស្សានិ ឥតិ វា អយំ អាគារិកវិភូសា ។

១ ម. ចិត្រុបាហនា ។ ២ ម. មណិវាឡពិជនី ។

ខគ្គវិសាណសុត្តនិទ្ទេស

[៣២៦] ពាក្យថា មិនអើពើ មិនអាឡោះអាល័យ សេចក្ដីថា មិនអើពើ មិនអាឡោះអាល័យ គឺថាលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវល្បែងផង នូវសេចក្ដីត្រេកអរផង នូវកាម-សុខផង ក្នុងលោក ហេតុនោះ (លោកពោលថា) មិនអើពើ មិនអាឡោះអាល័យ ។

[៣២៧] អធិប្បាយពាក្យថា ជាអ្នកវៀរចាកគ្រឿងស្អិតស្អាង អ្នកពោលពាក្យពិត ត្រង់ពាក្យថា គ្រឿងស្អិតស្អាង សំដៅយក គ្រឿងស្អិតស្អាង ២ យ៉ាង គឺ គ្រឿងស្អិតស្អាងសម្រាប់គ្រហស្ថក៏មាន គ្រឿងស្អិតស្អាងសម្រាប់បព្វជិតក៏មាន ។

គ្រឿងស្អិតស្អាងសម្រាប់គ្រហស្ថ តើដូចម្ដេច ។ សក់ ពុកមាត់ ពុកចង្កា ផ្ការម្រង គ្រឿងក្រអូប គ្រឿងស្រឡាប គ្រឿងអាករណៈ គ្រឿងប្រដាប់ សំពត់ គ្រឿងសម្អាង ឈ្នួត គ្រឿងអប់ ការច្របាច់រឹត ការផ្ងួតទឹក ការគក់ច្របាច់ កញ្ចក់ គ្រឿងបន្ដក់ កម្រងផ្ការ គ្រឿងលាប លំអិតសម្រាប់ប្រស់មុខ វត្ថុសម្រាប់លាបមុខ គ្រឿងប្រដាប់ដៃ ប្រដាប់ផ្ទួងសក់ ដំបង បំពង់ថ្នាំ ព្រះខ័ន ធ្នូ ស្បែកជើង ក្បាំងមុខ ស៊ែ សំពត់ស រ៉ែងខ្ទះ ខ្ទីខ្ទះ នេះគ្រឿងស្អិតស្អាងសម្រាប់គ្រហស្ថ ។

កតមា អនាគារិកាភិក្ខុសា[១] ។ ចីវរមណ្ឌនា បត្តមណ្ឌនា សេនាសនមណ្ឌនា ឥមស្ស វា បូតិកាយស្ស ពាហិរានំ វា បរិក្ខារានំ មណ្ឌនា វិភូសនា កេឡនា បរិកេឡនា គេធិកតា គេធិកត្តំ ចបលនា[២] ចាបល្យំ អយំ អនាគារិកាវិភូសា ។

សច្ចវាទីតិ សោ បច្ចេកសម្ពុទ្ធោ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស វិភូសនដ្ឋានា អារតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ វិភូសនដ្ឋានា វិរតោ សច្ចវាទី ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

ខិឌ្ឌា រតី កាមសុខញ្ច លោកេ
អនលង្ករិត្វា អនបេក្ខមានោ
វិភូសនដ្ឋានា វិរតោ សច្ចវាទី
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

---

១ ម. បព្វជិតស្ស វិភូសា ។ ២ ម. កេឡិតតា គតិតា គតិតត្តំ ចបលតា ។

គ្រឿងស្អិតស្អាងសម្រាប់បពូជិត តើដូចម្តេច ។ គ្រឿងប្រដាប់ចីវរ គ្រឿងប្រដាប់បាត្រ គ្រឿងប្រដាប់សេនាសនៈ ការប្រដាប់ ការស្អិតស្អាង ការលេង ការលេងសព្ទ ការជាប់ចិត្ត សេចក្តីជាប់ចិត្ត ការតាក់តែង សេចក្តីតាក់តែង នូវកាយស្អុយនេះ ឬនូវបរិក្ខារខាងក្រៅ នេះគ្រឿងស្អិតស្អាងសម្រាប់បពូជិត ។

ពាក្យថា អ្នកពោលពាក្យពិត សេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាអ្នកពោលពាក្យពិត តពាក្យពិត មានសម្តីទៀង មានសម្តីគួរជឿ មិនបោកប្រាស់សត្វលោក គឺជាអ្នកនៅធ្វាយ រៀរស្រឡះ ឃ្លាតចេញ រលាស់ចេញ ផុតស្រឡះ ប្រាសចេញ ចាកគ្រឿងស្អិតស្អាង នៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (លោកពោលថា) ជាអ្នករៀរចាកគ្រឿងស្អិតស្អាង អ្នកពោលនូវពាក្យពិត ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលមិនអើពើ មិនអាឡោះអាល័យនូវល្បែង នូវ
សេចក្តីត្រេកអរ និងកាមសុខក្នុងលោក ជាអ្នករៀ
ចាកគ្រឿងស្អិតស្អាង អ្នកពោលពាក្យពិត គប្បី
ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

ខគ្គវិសាណសុត្តនិទ្ទេសោ

[៣២៨] បុត្តញ្ច ទារំ បិតរញ្ច មាតរំ
ធនានិ ធញ្ញានិ ច ពន្ធវានិ
ហិត្វាន[1] កាមានិ យថោធិកានិ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[៣២៩] បុត្តញ្ច ទារំ បិតរញ្ច មាតរន្តិ បុត្តន្តិ ចត្តារោ បុត្តា អត្រជោ បុត្តោ ខេត្តជោ បុត្តោ ធិន្នកោ បុត្តោ អន្តេវាសិកោ បុត្តោ ។ ទារា ១ចូ១ន្តិ ភរិយាយោ ។ បិតាតិ យោ សោ ជនកោ ។ មាតាតិ យា សា ជនិកាតិ បុត្តញ្ច ទារំ បិតរញ្ច មាតរំ ។

[៣៣០] ធនានិ ធញ្ញានិ ច ពន្ធវានីតិ ធនានិ ១ចូ១ន្តិ[2] មុត្តា មណិ វេឡុរិយោ សង្ខោ សិលា បវាឡំ រជតំ ជាតរូបំ លោហិតង្គោ មសារគល្លោ ។ ធញ្ញានិ ១ចូ១ន្តិ បុព្វន្ធំ អបរណ្ណ្ហ ។ បុព្វណ្ណ្ហ ១ាម សាលី រីហិ យវោ គោធុមោ ១ង្គុ ១រកោ ១ុ១ុ្ទ្ធសកោ ។ អបរណ្ណ្ហ ១ាម ១ូ១ៃ ។

---

១ ម. ជហិត្វាន ។ ២ ម. ឯត្ថន្តរេ ហិរញ្ញំ សុវណ្ណន្តិ ទិស្សតិ ។

ខគ្គវិសាណសុត្តនិទ្ទេស

[៣២៨] បុគ្គលលះបង់ នូវបុត្ត ប្រពន្ធ បិតា មាតា ទ្រព្យ ស្រូវ ផៅពង្ស និងកាមទាំងឡាយ តាមថ្នាក់ តាមជាន់ហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣២៩] ពាក្យថា បុត្ត ប្រពន្ធ បិតា មាតា ត្រង់ពាក្យថា បុត្ត បានដល់បុត្ត ៤ ពួក គឺ បុត្តកើតអំពីខ្លួន ១ បុត្តកើតក្នុងខេត្ត ១ បុត្តដែលគេឲ្យ ១ បុត្តគឺកូនសិស្ស ១ ។ ភរិយាទាំងឡាយ ហៅថា ប្រពន្ធ ។ ពាក្យថា បិតា បានដល់ បុរសអ្នកបង្កើតកូន ។ ពាក្យថា មាតា បានដល់ស្ត្រីអ្នកបង្កើតកូន ហេតុនោះ (លោកពោលថា) បុត្ត ប្រពន្ធ បិតា មាតា ។

[៣៣០] ពាក្យថា ទ្រព្យ ស្រូវ ផៅពង្ស គឺ កែវមុក្តា កែវមណី កែវពៃទូរ្យ ស័ង្ខ ថ្ម កែវប្រពាឡ ប្រាក់ មាស កែវទទឹម កែវមរកត ហៅថា ទ្រព្យ ។ បុព្វន្ទជាត[1] អបរណ្ណជាត[2] ហៅថា ស្រូវ ។ ស្រូវខ្យាយស ស្រូវខ្យាយក្រហម ស្រូវដំណើប ស្រវែ ស្ពៅ ស្ពួយ គែលលក ឈ្មោះថាបុព្វណ្ណជាត ។ គ្រឿងសម្ង ឈ្មោះថាអបរណ្ណជាត ។

---

១ វត្ថុដែលត្រូវបរិភោគមុន ។ ២ វត្ថុដែលត្រូវបរិភោគក្រោយ ។

ពន្ធវានីតិ ចត្តារោ ពន្ធវា ញាតិពន្ធវាបិ ពន្ធុ គោត្ត-ពន្ធវាបិ ពន្ធុ មិត្តពន្ធវាបិ ពន្ធុ សិប្បពន្ធវាបិ ពន្ធូតិ ឆនានិ ឆញ្ញានិ ច ពន្ធវានិ ។

[៣៣១] ហិត្វាន កាមានិ យថោធិកានីតិ កាមាតិ ឧច្ចានតោ ទ្វេ កាមា វត្ថុកាមា ច កិ-លេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ ហិត្វាន កា-មានីតិ វត្ថុកាមេ បរិជានិត្វា កិលេសកាមេ បហា-យ បជហិត្វា វិនោទេត្វា ព្យន្តីការិត្វា អនភាវង្គមេ-ត្វាតិ ហិត្វាន កាមានិ ។ យថោធិកានីតិ សោតា-បត្តិមគ្គេន យេ កិលេសា បហីនា តេ កិលេសេន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតិ សកិជាគាមិមគ្គេន

ពាក្យថា ផៅពង្ស បានដល់ផៅពង្ស ៤ ពួក គឺ បុគ្គលជាប់ដោយញាតិ ឈ្មោះថាផៅពង្ស ១ បុគ្គលជាប់ដោយគោត្រ ឈ្មោះថាផៅពង្ស ១ បុគ្គលជាប់ដោយមិត្ត ឈ្មោះថាផៅពង្ស ១ បុគ្គលជាប់ដោយសិល្ប: ឈ្មោះថាផៅពង្ស ១ ហេតុនោះ (លោកពោលថា) ទ្រព្យ ស្រូវ ផៅពង្ស ។

[៣៣១] អធិប្បាយពាក្យថា លះបង់កាមទាំងឡាយ តាមថ្នាក់តាមជាន់ ត្រង់ពាក្យថា កាម តាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះហៅថា វត្ថុកាម ។ បេ ។ ទាំងនេះ ហៅថា កិលេសកាម ។ ពាក្យថា លះបង់កាមទាំងឡាយ គឺ កំណត់ដឹងនូវវត្ថុកាម ហើយលះបង់ ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវកិលេសកាម ហេតុនោះ (លោកពោលថា) លះបង់កាមទាំងឡាយ ។ ពាក្យថា តាមថ្នាក់តាមជាន់ គឺ កិលេសទាំង-ឡាយណា ដែលព្រះបច្ចេកសម្ពុទ្ធលះបង់ហើយ ដោយសោតាបត្តិមគ្គ លោកមិនមក មិនវិលមក មិនត្រឡប់មក កាន់កិលេសទាំងនោះទេ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសកទាគាមិមគ្ត

យេ កិលេសា បហីនា អនាគាមិមគ្គេន យេ កិលេសា បហីនា អរហត្តមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតីតិ ហិត្វាន កាមានិ យថោធិកានិ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

បុត្តញ្ច ទារំ បិតរញ្ច មាតរំ
ធនានិ ធញ្ញានិ ច ពន្ធវានិ
ហិត្វាន កាមានិ យថោធិកានិ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[៣៣២] សង្គោ ឯសោ បរិត្តមេត្ថ សោខ្យំ
អប្បស្សាទោ ទុក្ខមេត្ថ ភិយ្យោ
គណ្ឌោ[១] ឯសោ ឥតិ ញត្វា មតិមា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

១ ម. គឡោ ។

កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយអនាគាមិមគ្គ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយអរហត្តមគ្គ លោកមិនមក មិនវិលមក មិនត្រឡប់មក កាន់កិលេសទាំងនោះទេ ហេតុនោះ (លោកពោលថា) លះបង់នូវកាមទាំងឡាយ តាមថ្នាក់តាមជាន់ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលលះបង់ នូវបុត្ត ប្រពន្ធ បិតា មាតា ទ្រព្យ ស្រូវ ផ្ទៅពង្ស និងកាមទាំងឡាយ តាមថ្នាក់តាមជាន់ហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣៣២] កាមគុណនេះ ជាគ្រឿងចំពាក់ សេចក្តីសុខក្នុងកាមគុណនេះ មានប្រមាណតិច កាមគុណនេះមានសេចក្តីត្រេកអរតិច សេចក្តីទុក្ខក្នុងកាមគុណនេះ មានច្រើនក្រៃលែង កាមគុណនេះជាពក បុគ្គលអ្នកមានប្រាជ្ញាបានដឹងដូច្នេះហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣៣៣] សង្ហោ ឯសោ បរិត្តមេត្ត សោ១ន្តិ សង្ហោតិ វា ពន្ធ១ិសន្តិ វា អាមិសន្តិ វា លក្ខនន្តិ វា បលិពោធោតិ វា បញ្ចន្នេតំ កាមគុណានំ អធិ១ចនំ ។ បរិត្តមេត្ត សោ១ន្តិ រុត្តញ្ចេតំ ភគ១តា បញ្ចិមេ ភិក្ខ១ វេ កាមគុណា កតមេ បញ្ច ចក្ខុ១ិ-ញ្ញេយ្យា រូ១ា ឥដ្ឋា កន្តា មនាបា បិយរូ១ា កាមុ-បសញ្ហិតា ១ជនីយា សោត១ិញ្ញេយ្យា សទ្ទា ឃាន-១ិញ្ញេយ្យា គន្ធា ជិ១្ហ១ិញ្ញេយ្យា ១សា កាយ១ិញ្ញេយ្យា ផោដ្ឋព្ព១ា ឥដ្ឋា កន្តា មនាបា បិយរូ១ា កាមុបស-ញ្ហិតា ១ជនីយា ឥមេ ខោ ភិក្ខ១ វេ បញ្ច កាមគុណា

[៣៣៣] *អធិប្បាយពាក្យថា កាមគុណនេះ ជាគ្រឿងចំពាក់ សេចក្តីសុខក្នុងកាមនេះ មានប្រមាណតិច ពាក្យថា គ្រឿងចំពាក់ ក្តី ថាសន្ធូចក្តី ថានុយក្តី ថាគ្រឿងថ្ពក់ក្តី ថាកង្វល់ក្តី នេះជាឈ្មោះ នៃកាមគុណទាំង ៥ ។ ពាក្យថា សេចក្តីសុខ ក្នុងកាមនេះ មាន ប្រមាណតិច សេចក្តីថា មែនពិត ព្រះមានព្រះភាគ បានត្រាស់ព្រះ ពុទ្ធដីកានេះថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ កាមគុណ ៥ តើដូចម្តេច រូប ដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេក អរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយសេចក្តីប្រាថ្នា ជាទីតាំងនៃសេចក្តីត្រេកអរ សំឡេង ដែលគប្បីដឹង ដោយត្រចៀក ក្លិន ដែលគប្បីដឹងដោយច្រមុះ រស ដែលគប្បីដឹង ដោយអណ្តាត ផ្សព្វ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទី គាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយសេចក្តីប្រាថ្នា ជាទី តាំងនៃសេចក្តីត្រេកអរ ម្នាលភិក្ខុទាំងឡាយ ទាំងនេះឯង កាមគុណ ៥*

យំ ខោ ភិក្ខវេ ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ ឥទំ វុច្ចតិ កាមសុខំ អប្បកំ ឯតំ សុខំ[១] ឱមកំ ឯតំ សុខំ លាមកំ ឯតំ សុខំ ទុក្ខំ[២] ឯតំ សុខន្តិ សង្គោ ឯសោ បរិត្តមេត្ថ សោខ្យំ ។

[៣៣៤] អប្បស្សាទោ ទុក្ខមេត្ថ ភិយ្យោតិ អប្បស្សាទា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ អដ្ឋិកង្គ-លូបមា កាមា វុត្តា ភគវតា ។ មំសបេសូបមា កាមា វុត្តា ភគវតា ។ តិណុក្កូបមា កាមា វុត្តា ភគវតា ។ អង្គារកាសូបមា កាមា វុត្តា ភគវតា ។ សុបិនកូបមា កាមា វុត្តា ភគវតា ។ យាចិតកូបមា កាមា វុត្តា ភគវតា ។ រុក្ខផលូបមា កាមា វុត្តា ភគវតា ។

---

១ ម. ឯត្ថន្តរេ បរិត្តកំ ឯតំ សុខំ ថោមកំ ឯតំ សុខន្តិ ទិស្សន្តិ ។ ២ ម. ឆតុក្កំ ។

[៣៥៨] លទ្ធានុបេក្ខំ សមថំ វិសុទ្ធន្តិ ឧបេ-ក្ខាតិ យា ចតុត្ថជ្ឈានេ ឧបេក្ខា ឧបេក្ខនា អជ្ឈុ-បេក្ខនា ចិត្តស្ស បស្សទ្ធតា មជ្ឈត្តតា ចិត្តស្ស ។ សមថោតិ យា ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ អវិសាហារោ អវិក្ខេបោ អវិសាហជមានសតា ស-មថោ សមាធិន្ទ្រិយំ សមាធិពលំ សម្មាសមាធិ ។ ចតុត្ថជ្ឈានេ ឧបេក្ខា ច សមថោ ច សុទ្ធា ហោន្តិ វិសុទ្ធា បរិយោទាតា អនង្គណា វិគតូបក្លិ-លេសា មុទុភូតា កម្មនីយា ឋិតា អានេញ្ជប្បត្តា ។ លទ្ធានុបេក្ខំ សមថំ វិសុទ្ធន្តិ ចតុត្ថជ្ឈានេ ឧបេ-ក្ខញ្ច សមថញ្ច លទ្ធាន លភិត្វាតិ លទ្ធានុបេក្ខំ សមថំ វិសុទ្ធំ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

វិបិដ្ឋិកត្វាន សុខំ ទុក្ខញ្ច
បុព្វេ ច សោមនស្សទោមនស្សំ
លទ្ធានុបេក្ខំ សមថំ វិសុទ្ធំ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[៣៥៨] អធិប្បាយពាក្យថា បានទូវឧបេក្ខានិងសមថៈដ៏បរិសុទ្ធ ត្រង់ពាក្យថា ឧបេក្ខា បានដល់ការព្រងើយ អាការនៃការព្រងើយ ការព្រងើយកន្តើយ ភាពនៃចិត្តស្ងប់ ភាពនៃចិត្តតាំងនៅជាកណ្តាលក្នុងចតុត្ថជ្ឌាន ។ ពាក្យថា សមថៈ បានដល់ការតាំងនៅ ការតាំងនៅត្រម ការតាំងនៅខ្ជាប់ ការមិនរសេមរសាម ការមិនរាយមាយ ភាពមិនអណ្តែតអណ្តូង នៃចិត្ត សមថៈ សមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ ។ ឧបេក្ខានិងសមថៈ ក្នុងចតុត្ថជ្ឌាន ជាសភាវៈបរិសុទ្ធ ស្អាត ផ្ទូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្លិលេស ជាសភាពទន់ភ្ងន់ គួរដល់កម្ម នឹងនួន ដល់នូវការមិនញាប់ញ័រ ។ ពាក្យថា បានទូវឧបេក្ខានិងសមថៈដ៏បរិសុទ្ធ បានសេចក្ដីថា បាន បានហើយ នូវឧបេក្ខានិងសមថៈ ក្នុងចតុត្ថជ្ឌាន ហេតុនោះ (លោកពោលថា) បានទូវឧបេក្ខានិងសមថៈដ៏បរិសុទ្ធ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

> បុគ្គលធ្វើឲ្យនៅពីខាងក្រោយខ្នង នូវសុខ ទុក្ខ
> សោមនស្សនិងទោមនស្សក្នុងកាលមុន បានទូវ
> ឧបេក្ខានិងសមថៈដ៏បរិសុទ្ធ គប្បីប្រព្រឹត្តម្នាក់ឯង
> ដូចកុយរមាស ។

ខគ្គវិសាណសុត្តនិទ្ទេសោ

[៣៥៩] អារទ្ធវីរិយោ បរមត្តបត្តិយា
អលីនចិត្តោ អកុសីតវុត្តិ
ឧដ្ឋានិក្ក្រមោ ថាមពលូបបន្នោ
ឯកោ ចរេ ខគ្គវិសាណកប្ប ។

[៣៦០] អារទ្ធវីរិយោ បរមត្តបត្តិយាតិ បរមត្តំ វុច្ចតិ អមតំ និព្ពានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្ពានំ ។ បរមត្តស្ស បត្តិយា លាភាយ បដិលាភាយ អធិគមាយ ផុសនាយ សច្ឆិកិរិយាយ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ សម្ភាយ ថាមវា ឧដ្ឋាបរក្ក្រមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសូតិ អារទ្ធវីរិយោ បរមត្តបត្តិយា ។

ខគ្គវិសាណសុត្តនិទ្ទេស

[៣៥៩] បុគ្គល ប្រារព្ធព្យាយាម ដើម្បីសម្រេចនូវ
ប្រយោជន៍ដ៏ឧត្តម មានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្ត
មិនខ្ជិល មានព្យាយាមមាំ បរិបូណ៌ដោយកម្លាំងចិត្ត
និងកម្លាំងកាយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣៦០] ពាក្យថា ប្រារព្ធព្យាយាម ដើម្បីសម្រេចនូវប្រយោជន៍ដ៏ឧត្តម សេចក្តីថា អមតនិព្វាន ហៅថា ប្រយោជន៍ដ៏ឧត្តម បានដល់ការរម្ងាប់សង្ខារទាំងពួង ការលះបង់នូវឧបធិទាំងពួង ការអស់តណ្ហា ការអស់តម្រេក ការរលត់ និព្វាន ។ បុគ្គលជាអ្នកប្រារព្ធព្យាយាមក្នុងការលះអកុសលធម៌ ក្នុងការបំពេញកុសលធម៌ដើម្បីការដល់ ការបាន ការបានចំពោះ ការត្រាស់ដឹង ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ នូវប្រយោជន៍ដ៏ឧត្តម គឺជាអ្នកមានកម្លាំងចិត្ត មានសេចក្តីប្រឹងប្រែងមាំ មិនដាក់ធុរៈ ក្នុងកុសលធម៌ទាំងឡាយ ហេតុនោះ (លោកពោលថា) ប្រារព្ធព្យាយាម ដើម្បីសម្រេច នូវប្រយោជន៍ដ៏ឧត្តម ។

[៣៦១] អលីនចិត្តោ អកុសីតវុត្តីតិ សោ បច្ចេ-
កសម្ពុទ្ធោ អនុប្បន្នានំ ចាបកានំ អកុសលានំ
ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតি វាយមតি វីរិយំ
អារភតি ចិត្តំ បគ្គណ្ហাতি បធហাতি ឧប្បន្នានំ ចា-
បកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជ-
នេតি វាយមតি វីរិយំ អារភតি ចិត្តំ បគ្គណ្ហাতি បធ-
ហাতি អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ
ឆន្ទំ ជនেতি វាយমতি វីរិយং អារভতি চিত্তং পগ্গণ্হাতি
পধহাতি উপ্পন্নানং কুসলানং ধম্মানং ঠিতিযা
অসম্মোসায ভিযোভাবায বেপুল্লায ভাবনা-
চারিপূরিযা ছন্দং জনেতি বাযমতি বীরিযং আরভতি
চিত্তং পগ্গণ্হাতি পধহাতীতি এবং অলীনচিত্তো
អកុសីតវុត្តិ ។ អថវា ការាមំ តចោ ច
ណ្ហារូ ច អដ្ឋី ច អវសិស្សតុ សុស្សតុ សរីរៃ
មំសលោហិតំ យន្តំ បុរិសត្តាមេន បុរិសពលេន

[៣៦១] ពាក្យថា មានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្ត មិនខ្ជិល អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះញ៉ាំងឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីញ៉ាំងអកុសលធម៌ដ៏លាមកដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ញ៉ាំងឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីលះនូវអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ញ៉ាំងឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីញ៉ាំងកុសលធម៌ដែលមិនទាន់កើត ឲ្យកើតឡើង ញ៉ាំងឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីញ៉ាំងកុសលធម៌ដែលកើតឡើងហើយឲ្យបិតថេរ មិនឲ្យសាបសូន្យ ឲ្យចម្រើនក្រៃលែង ឲ្យទូលំទូលាយ ឲ្យពេញលេញដោយភាវនា ហេតុនោះ (លោកពោលថា) មានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្ត មិនខ្ជិល យ៉ាងនេះ ។ មួយទៀត បុគ្គលផ្គងចិត្ត តាំងចិត្តថា ចង់សល់នៅតែស្បែក សរសៃនិងឆ្អឹង ក៏ដោយចុះ ចង់សាច់ និងឈាមក្នុងសរីរៈ រីងស្ងួតទៅក៏ដោយចុះ គុណជាតណា ដែលបុគ្គលគប្បីសម្រេចដោយកម្លាំងចិត្តរបស់បុរស ដោយកម្លាំងកាយរបស់បុរស

បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ ន តំ អបា-បុណិត្វា វីរិយស្ស ឋានំ ភវិស្សតីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវម្បិ អលីនចិត្តោ អកុសីតវុត្តិ ។ ន តាវាហំ ឥមំ បល្លង្កំ ភិន្ទិស្សាមិ យាវ មេ ន អនុ-បាទាយ អាសវេហិ ចិត្តំ វិមុច្ចិស្សតីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវម្បិ អលីនចិត្តោ អកុសីតវុត្តិ ។

នាស្នាស្សំ ន បិវិស្សាមិ វិហារតោ ន និក្ខមី[១]

នបិ បស្សំ និបាតេស្សំ តណ្ហាសល្លេ អនូហតេតិ

ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវម្បិ អលីនចិត្តោ អកុសីតវុត្តិ ។ ន តាវាហំ ឥមម្ហា អាសនា ឧដ្ឋហិស្សាមិ យាវ មេ ន អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិស្សតីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឯវម្បិ អលីនចិត្តោ អកុសីតវុត្តិ ។

១ ម. និក្ខមេ ។

ដោយសេចក្តីព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស បើអាត្មាមិនទាន់សម្រេច នូវគុណជាតនោះទេ នឹងមិនបញ្ឈប់នូវព្យាយាមឡើយ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះ ក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា ចិត្តរបស់អាត្មាអញ មិនទាន់រួចចាកអាសវៈ ព្រោះមិនប្រកាន់មាំ ដរាបណា អាត្មាអញនឹងមិនទម្ងាយ ក្នែនដរាបនោះ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា

> កាលបើសរគឺតណ្ហា មិនទាន់រដកចេញទេ អាត្មាអញ
> នឹងមិនស៊ី នឹងមិនផឹក នឹងមិនចេញអំពីវិហារ ទាំង
> នឹងមិនដាក់នូវបង្ឍៀង (ទម្រេត) ឡើយ ។

បុគ្គល មានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះ ក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា បើចិត្តរបស់អាត្មាអញ នឹងមិនទាន់រួច ចាកអាសវៈ ព្រោះមិនប្រកាន់មាំ ដរាបណា អាត្មាអញនឹងមិនក្រោក ចាកអាសនៈនេះ ដរាបនោះ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះ ក៏មាន ។

ន តាវាហំ ឥមម្ហា ចង្ក្រមា ឱរោហិស្សាមិ រិហារ
ជិក្ខូមិស្សាមិ អឌ្ឍយោគា ជិក្ខូមិស្សាមិ ចាសាឌ
ជិក្ខូមិស្សាមិ ហម្ម្យា ជិក្ខូមិស្សាមិ គុហាយ ជិ-
ក្ខូមិស្សាមិ លេណា ជិក្ខូមិស្សាមិ ឥជ្ជិយា ជិក្ខ-
មិស្សាមិ ឥជ្ជាតាឌ ជិក្ខូមិស្សាមិ អដ្ដា ជិក្ខូមិ-
ស្សាមិ មាឌ្ឍ ជិក្ខូមិស្សាមិ ឧជ្ជ្ជ្ជ ជិក្ខូមិស្សាមិ
ឧបដ្ឋានសាលាយ ជិក្ខូមិស្សាមិ មណ្ឌ្ឌ ជិក្ខ-
មិស្សាមិ រុក្ខ្ខ្ខ ជិក្ខូមិស្សាមិ យាវ មេ ន
អនុ្ចាឌ្ឍ អាសវេហិ ចិត្តំ រិមុ្ចិ្ចស្ស្ស្ស ចិត្តំ
បក្ខ្ខ្ខ ឧ្ចាតិ ឧ្ចាតិ ឯ្ចម្ម្ម អលីនចិ្ចត្ត្ត អ្ចុ្ចសីត-
ុ្ចត្ត ។ ឥមស្ម្ម ្ចយ ្ចុ ្ចណ្ណ ្ចសមយ ្ចអ ្ចយ ្ចឌ ្ចអ-
ហ ្ចិ ្ចស ្ចមិ ្ចសមហ ្ចិ ្ចស ្ចមិ ្ចអ ្ចិ ្ចត ្ចិ ្ចស ្ចមិ ្ចផ ្ចសយ ្ចិ-
ស ្ចមិ ្ចសត ្ចិ ្ចត ្ចិ ្ចស ្ចមីតិ ្ចិ ្ចត ្ចិ ្ចបក ្ចណ ្ចណ ្ចតិ ្ចឧ ្ចតិ
ឯ ្ចម ្ចិ ្ចអ ្ចលីនចិ ្ចត ្ចត ្ចអ ្ចុ ្ចសីត ្ចុ ្ចត ្ចិ ។ ្ចឥ ្ចមស ្ចិ ្ចយ ្ចេ
ម ្ចជ ្ចជ ្ចិ ្ចត ្ចសមយ ្ចេ ្ចសាយ ្ចណ ្ចណ ្ចសមយ ្ចេ ្ចបុ ្ចេ ្ចត ្ចត ្ចិ

បុគ្គលផ្គងចិត្ត តាំងចិត្តថា អាត្មាអញនឹងមិនចុះអំពីទីចង្ក្រមនេះ មិនចេញអំពីវិហារនេះ មិនចេញអំពីអឌ្ឍយោគនេះ មិនចេញអំពីប្រាសាទនេះ មិនចេញអំពីប្រាសាទមានជ្រុង ៤ នេះ មិនចេញអំពីគុហានេះ មិនចេញអំពីគុកនេះ មិនចេញអំពីកុដិនេះ មិនចេញអំពីផ្ទះមានកំពូលនេះ មិនចេញអំពីប៉ម្ម១នេះ មិនចេញអំពីពោងនេះ មិនចេញអំពីពោងដោលនេះ មិនចេញអំពីឧបដ្ឋានសាលានេះ មិនចេញអំពីមណ្ឌបនេះ មិនចេញអំពីគល់ឈើនេះ បើចិត្តរបស់អាត្មាអញមិនទាន់រួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា អាត្មាអញនឹងនាំមក នឹងប្រមូលមក នឹងត្រាស់ដឹង នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់ នូវអរិយធម៌ ឲ្យទាន់ក្នុងបុព្វណ្ហសម័យនេះ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា អាត្មាអញនឹងនាំមក នឹងប្រមូលមក នឹងត្រាស់ដឹង នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់ នូវអរិយធម៌ ឲ្យទាន់ក្នុងវេលាថ្ងៃត្រង់នេះ ក្នុងវេលាថ្ងៃរសៀលនេះ ក្នុងវេលាមុនភត្តនេះ

ខគ្គវិសាណសុត្តនិទ្ទេសោ

បច្ឆាភត្តំ បុរិមយាមេ មជ្ឈិមយាមេ បច្ឆិមយាមេ
ការេ ជុណ្ហា រត្ត ហេមន្ត តិម្ហ បុរិមេ រយោ-
ខន្ធ មជ្ឈិមេ រយោខន្ធ បច្ឆិមេ រយោខន្ធ អរិ-
យឋ្ឋ អាហរិស្សាមិ សមាហរិស្សាមិ អធិតច្ឆិស្សាមិ
ផុសយិស្សាមិ សច្ឆិការិស្សាមីតិ ចិត្តំ បក្ខណ្ហាតិ
បឋមាតិ ឯវម្ប្យ អលីនចិត្តោ អកុសីតវុត្តិ ។

[៣៨២] ឧជ្ជុនិក្ខ្លាមោ ចាមពលូបមន្ទោតិ ឧជ្ជ-
ុនិក្ខ្លាមោតិ សោ បច្ចេកសម្ពុទ្ធោ ឧជ្ជុសមាចារោ
អហោសិ កុសលេសុ ធម្មេសុ អវដ្ឋិតសមាចារោ
ការយសុចរិតេ វចីសុចរិតេ មនោសុចរិតេ ទានសំ-
រិការេ សីលសមាចារេ ឧចោសថុបវាសេ មេត្ត-
យ្យតាយ ឃេត្ត្យតាយ សាមញ្ញតាយ ព្រហ្មញ្ញ-
តាយ ការ ជេដ្ឋាបចាយិការ អញ្ញតរញ្ញត-
រេសុ អធិកុសលេសុ ធម្មេសូតិ ឧជ្ជុនិក្ខ្លាមោ ។

ក្នុងវេលាក្រោយភត្តនេះ ក្នុងបឋមយាមនេះ ក្នុងមជ្ឈិមយាមនេះ ក្នុងបច្ឆិមយាមនេះ ក្នុងរនោចនេះ ក្នុងខ្នើតនេះ ក្នុងវស្សានរដូវនេះ ក្នុងហេមន្តរដូវនេះ ក្នុងគិម្ហរដូវនេះ ក្នុងចំណែកបឋមវ័យនេះ ក្នុងចំណែកមជ្ឈិមវ័យនេះ ក្នុងចំណែកបច្ឆិមវ័យនេះ បុគ្គលមានចិត្តមិនរួញារ ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះក៏មាន ។

[៣៦២] អធិប្បាយពាក្យថា មានព្យាយាមមាំ បរិបូណ៌ដោយកម្ទាំងចិត្តនិងកម្ទាំងកាយ ត្រង់ពាក្យថា មានព្យាយាមមាំ សេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាអ្នកមានការសមាទានមាំ ក្នុងពួកកុសលធម៌ មានការសមាទានខ្ជាប់ខ្ជួន ក្នុងកាយសុចរិត ក្នុងវចីសុចរិត ក្នុងមនោ-សុចរិត ក្នុងការចែករំលែក ក្នុងការសមាទានសីល ក្នុងការរក្សាឧបោសថ ក្នុងភាពជាអ្នកគោរពមាតា ក្នុងភាពជាអ្នកគោរពបិតា ក្នុងភាពជាអ្នកគោរពសមណៈ ក្នុងភាពជាអ្នកគោរពព្រាហ្មណ៍ ក្នុងសេចក្តីគោរពបុគ្គលជាច្បងក្នុងត្រកូល ក្នុងធម៌ទាំងឡាយជាអធិកុសលណាមួយ ហេតុនោះ (លោកពោលថា) មានព្យាយាមមាំ ។

ថាមពលូបបន្ទោតិ សោ បច្ចេកសម្ពុទ្ធោ ថាមេន ច ពលេន ច វីរិយេន ច បរក្កមេន ច ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមង្ខាតោតិ ឧឌ្ឍនិក្ខ្លាមោ ថាមពលូបបន្នោ ។ ឯកោ ចរេ ខគ្គវិសាណ-កប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

អារទ្ធវីរិយោ បរមត្តបត្តិយា
អលីនចិត្តោ អកុសីតវុត្តិ
ឧឌ្ឍនិក្ខ្លាមោ ថាមពលូបបន្នោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[៣៦៣] បដិសល្លានំ ឈានមរិញ្ចមានោ
ធម្មេសុ និច្ចំ អនុធម្មចារី
អាទីនវំ សម្មសិតា ភវេសុ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ពាក្យថា បរិបូណ៌ដោយកម្លាំងចិត្តនិងកម្លាំងកាយ បានសេចក្ដីថា ព្រះបច្ចេកសម្ពុទ្ធនោះ ដល់ ដល់ព្រម មកជិត មកជិតព្រម ចូលដល់ ចូលដល់ព្រម ប្រកបដោយកម្លាំងចិត្តផង កម្លាំងកាយផង ព្យាយាមផង សេចក្ដីប្រឹងប្រែងផង ហេតុនោះ (លោកពោលថា) មានព្យាយាមមាំ បរិបូណ៌ដោយកម្លាំងចិត្តនិងកម្លាំងកាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលប្រារព្ធព្យាយាម ដើម្បីសម្រេចនូវប្រយោជន៍
ដ៏ឧត្តម មានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល
មានព្យាយាមមាំ បរិបូណ៌ដោយកម្លាំងចិត្តនិងកម្លាំង
កាយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣៦៣] បុគ្គលមិនលះបង់ នូវការសម្ងំផង នូវឈានផង
ជាអ្នកប្រព្រឹត្តធម៌បន្ទាប់បន្សំ ក្នុងធម៌ទាំងឡាយ អស់
កាលជានិច្ច ពិចារណាឃើញទោសក្នុងភពទាំងឡាយ
គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

ខគ្គវិសាណសុត្តនិទ្ទេសោ

[៣៦៤] បដិសល្លានំ ឈានមរិញ្ចមានោតិ សោ បច្ចេកសម្ពុទ្ធោ បដិសល្លានារាមោ ហោតិ បដិសល្លានរតោ អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ ឈានមរិញ្ចតិ[(១)] អនុប្បន្នស្ស វា បឋមស្ស ឈានស្ស ឧប្បាទាយ យុត្តោ បយុត្តោ សំយុត្តោ អាយុត្តោ សមាយុត្តោ អនុប្បន្នស្ស វា ទុតិយស្ស ឈានស្ស អនុប្បន្នស្ស វា តតិយស្ស ឈានស្ស អនុប្បន្នស្ស វា ចតុត្ថស្ស ឈានស្ស ឧប្បាទាយ យុត្តោ បយុត្តោ សំយុត្តោ អាយុត្តោ សមាយុត្តោតិ ឯវំ ឈានមរិញ្ចតិ ។ អថវា ឧប្បន្នំ វា បឋមំ ឈានំ អាសេវតិ ភាវេតិ ពហុលីករោតិ ឧប្បន្នំ វា ទុតិយំ ឈានំ ឧប្បន្នំ វា តតិយំ ឈានំ ឧប្បន្នំ វា ចតុត្ថំ ឈានំ អាសេវតិ ភាវេតិ ពហុលីករោតីតិ ឯវម្ចិ ឈានមរិញ្ចតីតិ បដិសល្លានំ ឈានមរិញ្ចមានោ ។

---

១ ម. អនិរាកតជ្ឈានោ វិបស្សនាយ សមន្ទាគតោ ព្រូហេតា សុញ្ញាគារំ ឈាយី ឈានរតោ ឯកតមនុយុត្តោ សទត្ថគរុកោតិ បដិសល្លានំ ។ ឈានមរិញ្ចមានោតិ សោ បច្ចេកសម្ពុទ្ធោ ទ្វីហិ ការណេហិ ឈានំ នរិញ្ចតីតិ ទិស្សន្តិ ។

ខគ្គវិសាណសុត្តនិទ្ទេស

[៣៦៤] ពាក្យថា មិនលះបង់ នូវការសម្ងំផង នូវឈានផង អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាអ្នកមានការសម្ងំជាទីត្រេកអរ ត្រេកអរក្នុងការសម្ងំ ប្រកបរឿយៗនូវចេតោសមថៈខាងក្នុង មិនធ្វើឈានឲ្យរបូតចុះ មិនលះបង់ឈាន ប្រកប ប្រកបរឿយៗ ប្រកបព្រម ប្រកបមិនដាច់ ប្រកបមិនដាច់ព្រម ដើម្បីធ្វើបឋមជ្ឈានដែលមិនទាន់កើតឲ្យកើតឡើង ឬប្រកប ប្រកបរឿយៗ ប្រកបព្រម ប្រកបមិនដាច់ ប្រកបមិនដាច់ព្រម ដើម្បីធ្វើទុតិយជ្ឈានដែលមិនទាន់កើត ឬតតិយ-ជ្ឈានដែលមិនទាន់កើត ឬក៏ចតុត្ថជ្ឈានដែលមិនទាន់កើត ឲ្យកើតឡើង ហេតុនោះ ឈ្មោះថាមិនលះបង់នូវឈាន យ៉ាងនេះឯង ។ មួយទៀត ព្រះបច្ចេកសម្ពុទ្ធ សេព ចម្រើន ធ្វើឲ្យច្រើន នូវបឋមជ្ឈាន ដែលកើតឡើងហើយ ឬសេព ចម្រើន ធ្វើឲ្យច្រើន នូវទុតិយជ្ឈានដែលកើតឡើងហើយ ឬតតិយជ្ឈានដែលកើតឡើងហើយ ឬចតុត្ថជ្ឈានដែលកើតឡើងហើយ ហេតុនោះ ឈ្មោះថា មិនលះបង់នូវឈាន យ៉ាងនេះក៏មាន ហេតុនោះ (លោកពោលថា) មិនលះបង់ នូវការសម្ងំផង នូវឈានផង ។

[៣៦៤] ធម្មេសុ និច្ចំ អនុធម្មចារីតិ ធម្មា វុច្ចន្តិ ចត្តារោ សតិប្បដ្ឋានា ។ បេ ។ អរិយោ អដ្ឋង្គិកោ មគ្គោ ។ កតមេ អនុធម្មា ។ សម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិបទា ធម្មានុធម្មប្បដិបទា សីលេសុ បរិបូរិការិតា ឥន្ទ្រិយេសុ គុត្តទ្វារតា ភោជនេ មត្តញ្ញុតា ជាគរិយានុយោគោ សតិសម្បជញ្ញំ ឥមេ វុច្ចន្តិ អនុធម្មា ។ ធម្មេសុ និច្ចំ អនុធម្មចារីតិ ធម្មេសុ និច្ចកាលំ[១] សតតំ សមិតំ អព្វោកិណ្ណំ[២] បោខានុបោខំ ឧទកុម្មិជាតំ អវីចិ[៣] សន្តតិ សហិតំ ផុសិតំ បុរេភត្តំ បច្ឆាភត្តំ បុរិមយាមេ មជ្ឈិមយាមេ បច្ឆិមយាមេ កាឡេ ជុណ្ហេ វស្សេ ហេមន្តេ គិម្ហេ បុរិមេ វយោខន្ធេ មជ្ឈិមេ វយោខន្ធេ បច្ឆិមេ វយោខន្ធេ ចរតិ វិចរតិ ឥរិយតិ វត្តេតិ បាលេតិ យបេតិ យាបេតីតិ ធម្មេសុ និច្ចំ អនុធម្មចារី ។

---

១ ម. ឯត្ថន្តរេ ធុវកាលន្តិ ទិស្សតិ ។ ២ ម. អវោកិណ្ណំ ។ ៣ ម. ឧទកុមិកជាតំ អវីចិ ។

[៣៦៥] ពាក្យថា ជាអ្នកប្រព្រឹត្តធម៌បន្ទាប់បន្សំ ក្នុងធម៌ទាំង-ឡាយអស់កាលជានិច្ច អធិប្បាយថា សតិប្បដ្ឋាន ៤ ។ បេ ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ហៅថា ធម៌ ។ ធម៌បន្ទាប់បន្សំ តើដូចម្តេច ។ ការប្រតិបត្តិត្រូវ ការប្រតិបត្តិជាអនុលោម ការប្រតិបត្តិមិនមានទំនាស់ ការប្រតិបត្តិគួរតាមប្រយោជន៍ ការប្រតិបត្តិនូវធម៌តាមធម៌ ការបំពេញក្នុងសីលទាំងឡាយ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ការស្គាល់ប្រមាណក្នុងភោជន ការប្រកបរឿយៗ នូវសេចក្តីភ្ញាក់រឭក សតិនិងសម្បជញ្ញៈ ទាំងនេះហៅថា ធម៌បន្ទាប់បន្សំ ។ ពាក្យថា ជាអ្នកប្រព្រឹត្តធម៌បន្ទាប់បន្សំ ក្នុងធម៌ទាំងឡាយ អស់កាលជានិច្ច បានសេចក្តីថា ចរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ក្នុងធម៌ទាំង-ឡាយ អស់កាលជានិច្ច រឿយៗ ជាប់ត មិនដាច់ ញយៗ មិនល្ហាះ ជាប់មិនដាច់ ជាប់ត ជិតស្និទ្ធ វេលាមុនកត្ត វេលាក្រោយកត្ត បុរិមយាម មជ្ឈិមយាម បច្ឆិមយាម រនោច ខ្នើត រសូវានរដូវ ហេមន្តរដូវ គិម្ហរដូវ ចំណែកបុរិមវ័យ ចំណែកមជ្ឈិមវ័យ ចំណែកបច្ឆិមវ័យ ហេតុនោះ (លោកពោលថា) ជាអ្នកប្រព្រឹត្តធម៌ បន្ទាប់បន្សំ ក្នុងធម៌ទាំងឡាយ អស់កាលជានិច្ច ។

ខគ្គវិសាណសុត្តនិទ្ទេសោ

[៣៦៦] អាឝីនវំ សម្ម្ឧសិតា ភវេសូតិ សព្ងេ សង្ខ្ហារ អនិច្ចាតិ អាឝីនវំ សម្ម្ឧសិតា ភវេសុ សព្ងេ សង្ខ្ហារ ឝុក្ខ្ហាតិ សព្ងេ ឝម្ម្ហា អនត្តាតិ ។ បេ ។ យញ្ជ្ជ ញ្ជ្ជ សមុឝយឝម្ម្ំ សព្ងន្ត្ំ និរោឝឝម្ម្ន្តិ អាឝីនវំ សម្ម្ឧសិតា ភវេសូតិ អាឝីនវំ សម្ម្ឧសិតា ភវេសុ ។ ឯកោ ឝរេ ខគ្គវិសាណកប្ប្ោ ។ តេនាហ សោ បច្ងេកសម្ពុទ្ធោ

បដិសល្ល្ានំ ឈានមរ្ជ្ជ្ជ

ខគ្គវិសាណសុត្តនិទ្ទេស

[៣៦៦] ពាក្យថា ពិចារណាឃើញទោស ក្នុងភពទាំងឡាយ គឺ ពិចារណាឃើញនូវទោសក្នុងភពថា សង្ខារទាំងពួងមិនទៀង ថា សង្ខារ ទាំងពួងជាទុក្ខ ថា ធម៌ទាំងពួងជាអនត្តា ។ បេ ។ ពិចារណាឃើញ ទោសក្នុងភពថា ធម្មជាតណាមួយមានការកើតឡើងជាធម្មតា ធម្មជាត ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ហេតុនោះ (លោកពោល ថា) ពិចារណាឃើញទោសក្នុងភពទាំងឡាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

> បុគ្គលមិនលះបង់ នូវការសម្ងំផង នូវឈានផង ជាអ្នក ប្រព្រឹត្តធម៌បន្ទាប់បន្សុំ ក្នុងធម៌ទាំងឡាយ អស់កាល ជានិច្ច ពិចារណាឃើញទោស ក្នុងភពទាំងឡាយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣៦៧] បុគ្គលកាលប្រាថ្នានូវការអស់តណ្ហា ជាអ្នកមិន ប្រហែស មិនលួងខ្ជៅ ជាអ្នកចេះដឹង មានស្មារតី មានធម៌ពិចារណាហើយ ជាអ្នកទៀងទាត់ មាន ព្យាយាម គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣៦៨] តណ្ហាក្ខយំ បត្តយំ អប្ឋមត្ថោតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្ពតណ្ហា ធម្មតណ្ហា ។ តណ្ហាក្ខយំ បត្តយន្តិ រាគក្ខយំ ទោសក្ខយំ មោហក្ខយំ កតិ-ក្ខយំ ឧបបត្តិក្ខយំ បដិសន្ធិក្ខយំ ភវក្ខយំ[1] សំសារក្ខយំ វដ្តក្ខយំ ឥច្ឆន្តោ[2] បត្តយន្តោ អភិ-ប្ឋន្តោតិ តណ្ហាក្ខយំ បត្តយំ ។ អប្ឋមត្ថោតិ សោ បចេ្ចកសម្ពុទ្ធោ សក្ខ្ចចូការី សាតចូការី ។ បេ ។ អប្ឋមត្ថោ កុសលេសុ ធម្មេសូតិ តណ្ហាក្ខយំ បត្តយំ អប្ឋមត្ថោ ។

[៣៦៩] អនេលមូគោ សុតវា សតិមាតិ អនេ-លមូគោតិ សោ បចេ្ចកសម្ពុទ្ធោ បណ្ហិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវីតិ អនេលមូគោ ។

---

១ ម. អាសវក្ខយំ ។ ២ ម. ឯត្ថន្តរេ សាទិយន្តោ បិហាយន្តោតិ ទិស្សតិ ។

[៣៦៨] *អធិប្បាយពាក្យថា កាលប្រាថ្នានូវការអស់តណ្ហា ជាអ្នកមិនប្រហែស ត្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា កាលប្រាថ្នានូវការអស់តណ្ហា គឺកាលប្រាថ្នា ប៉ុនប៉ង ផ្គងបំណង នូវការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ការអស់គតិ ការអស់ឧបបត្តិ ការអស់បដិសន្ធិ ការអស់ភព ការអស់សង្សារ ការអស់វដ្តៈ ហេតុនោះ (លោកពោលថា) កាលប្រាថ្នានូវការអស់តណ្ហា ។ ពាក្យថា ជាអ្នកមិនប្រហែស គឺព្រះបច្ចេកសម្ពុទ្ធនោះ ជាអ្នកធ្វើសេចក្តីគោរព ។ បេ ។ ជាអ្នកមិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ហេតុនោះ (លោកពោលថា) កាលប្រាថ្នានូវការអស់តណ្ហា ជាអ្នកមិនប្រហែស ។*

[៣៦៩] *អធិប្បាយពាក្យថា មិនលូងខ្ចៅ ជាអ្នកចេះដឹង មានស្មារតី ត្រង់ពាក្យថា មិនលូងខ្ចៅ គឺព្រះបច្ចេកសម្ពុទ្ធនោះ ជាបណ្ឌិត មានប្រាជ្ញា មានការត្រាស់ដឹង មានញាណ មានការភ្ញឹកស្វាង មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ (លោកពោលថា) មិនលូងខ្ចៅ ។*

ខគ្គវិសាណសុត្តនិទ្ទេសោ

សុតវាតិ សោ បច្ចេកសម្ពុទ្ធោ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថា សព្យញ្ជនា កេវលបរិបុណ្ណា បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធាតិ សុតវា ។ សតិមាតិ សោ បច្ចេកសម្ពុទ្ធោ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតាតិ អនេលមូគោ សុតវា សតិមា ។

[៣៧០] សង្ខ្យាតធម្មោ និយតោ បជានវាតិ សង្ខ្យាតធម្មោ រុច្ចតិ ញាណំ យា បញ្ញា បជានណា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។

ពាក្យថា ជាអ្នកចេះដឹង គឺព្រះបច្ចេកសម្ពុទ្ធនោះ ជាពហុស្សុត ទ្រទ្រង់នូវចំណេះ សន្សំនូវចំណេះ ពួកធម៌ណាដែលល្អខាងដើម ល្អកណ្ដាល ល្អទីបំផុត ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្ម-ចរិយធម៌ ដ៏បរិសុទ្ធ បរិបូណ៌ ពេញលេញ ពួកធម៌មានសភាពដូច្នោះ គឺព្រះបច្ចេកសម្ពុទ្ធនោះ បានចេះចាំច្រើន បានទ្រទ្រង់ទុក ចាំស្ទាត់ រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្ងុះដោយទិដ្ឋិ ហេតុនោះ (លោកពោលថា) ជាអ្នកចេះដឹង ។ ពាក្យថា មានស្មារតី គឺព្រះបច្ចេក-សម្ពុទ្ធនោះ មានស្មារតី ប្រកបដោយសតិនិងប្រាជ្ញាជាគ្រឿងរក្សាខ្លួនដ៏ក្រៃលែង ជាអ្នករឭកឃើញនូវអំពើដែលធ្វើយូរហើយផង នូវសម្ដីដែលពោលយូរហើយផង ហេតុនោះ (លោកពោលថា) មិនលង់ខ្ជៅ ជាអ្នកចេះដឹង មានស្មារតី ។

[៣៧០] ពាក្យថា មានធម៌ពិចារណាហើយ ជាអ្នកទៀងទាត់ មានព្យាយាម អធិប្បាយថា ញាណ លោក ហៅថាធម៌ដែលពិចារណាហើយ បានដល់ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណានូវធម៌ ការយល់ត្រូវ ។

សង្ខ្យាតធម្មោតិ សោ បច្ចេកសម្ពុទ្ធោ សង្ខ្យាតធម្មោ ញ្ញាតធម្មោ តុលិតធម្មោ តីរិតធម្មោ វិភូតធម្មោ វិភាវិតធម្មោ សព្វេ សង្ខ្យាត អនិច្ចាតិ ។ បេ ។ យញ្ហិ ញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ សង្ខ្យាតធម្មោ ញ្ញាតធម្មោ តុលិតធម្មោ តីរិតធម្មោ វិភូតធម្មោ វិភាវិតធម្មោ ។ អថវា តស្ស បច្ចេកសម្ពុទ្ធស្ស ខន្ធា សង្ខ្យាតា[1] ធាតុយោ សង្ខ្យាតា អាយតនានិ សង្ខ្យាតានិ គតិយោ សង្ខ្យាតា ឧបបត្តិយោ សង្ខ្យាតា បដិសន្ធិយោ សង្ខ្យាតា ភវា សង្ខ្យាតា សំសារា សង្ខ្យាតា វដ្ដា សង្ខ្យាតា ។ អថវា បច្ចេកសម្ពុទ្ធោ ខន្ធបរិយន្តេ ឋិតោ ធាតុបរិយន្តេ ឋិតោ អាយតនបរិយន្តេ ឋិតោ គតិបរិយន្តេ ឋិតោ ឧបបត្តិបរិយន្តេ ឋិតោ បដិសន្ធិបរិយន្តេ ឋិតោ ភវបរិយន្តេ ឋិតោ សំសារបរិយន្តេ ឋិតោ វដ្ដបរិយន្តេ ឋិតោ សង្ខ្យារបរិយន្តេ ឋិតោ អន្តិមភវេ ឋិតោ អន្តិមទេហធរោ បច្ចេកសម្ពុទ្ធោ ។

---

1 ម. សង្ខ្យាតា ។

ពាក្យថា មានធម៌ពិចារណាហើយ គឺព្រះបច្ចេកសម្ពុទ្ធនោះ មានធម៌ពិចារណាហើយ មានធម៌ដឹងហើយ មានធម៌ថ្នឹងហើយ មានធម៌ត្រិះរិះហើយ មានធម៌ច្បាស់ហើយ មានធម៌ធ្វើឲ្យកើតប្រាកដហើយថា សង្ខារទាំងពួងមិនទៀង ។ បេ ។ មានធម៌ពិចារណាហើយ មានធម៌ដឹងហើយ មានធម៌ថ្នឹងហើយ មានធម៌ត្រិះរិះហើយ មានធម៌ច្បាស់ហើយ មានធម៌ធ្វើឲ្យកើតប្រាកដហើយថា ធម្មជាតណាមួយមានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ មួយទៀត ព្រះបច្ចេកសម្ពុទ្ធនោះ បានពិចារណាខន្ធ ពិចារ-ណាធាតុ ពិចារណាអាយតនៈ ពិចារណាគតិ ពិចារណាឧបបត្តិ ពិចារ-ណាបដិសន្ធិ ពិចារណាភព ពិចារណាសង្សារ ពិចារណាវដ្តៈ ។ មួយទៀត ព្រះបច្ចេកសម្ពុទ្ធបិតនៅក្នុងទីបំផុតនៃខន្ធ បិតនៅក្នុងទីបំផុតនៃធាតុ បិតនៅក្នុងទីបំផុតនៃអាយតនៈ បិតនៅក្នុងទីបំផុតនៃគតិ បិតនៅក្នុងទីបំផុតនៃឧបបត្តិ បិតនៅក្នុងទីបំផុតនៃបដិសន្ធិ បិតនៅក្នុងទីបំផុតនៃភព បិតនៅក្នុងទីបំផុតនៃសង្សារ បិតនៅក្នុងទីបំផុតនៃវដ្តៈ បិតនៅក្នុងទីបំផុតនៃសង្ខារ បិតនៅក្នុងភពជាទីបំផុត ព្រះបច្ចេកសម្ពុទ្ធទ្រទ្រង់នូវរាងកាយជាទីបំផុត ។

យស្មាយំ បច្ឆិមកោ ភវោ ចរិមោយំ សមុស្សយោ ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ សង្ខាតធម្មោ ។ និយតោតិ និយាមា វុច្ចន្តិ ចត្តារោ អរិយមគ្គា ។ ចតូហិ អរិយមគ្គេហិ សមន្នាគតោ និយតោ អរិយមគ្គេហិ និយាមំ បត្តោ សម្បត្តោ ផុសិតោ សច្ឆិកតោតិ និយតោ ។ បធានវាតិ បធានំ វុច្ចតិ វីរិយំ យោ ចេតសោ វីរិយារម្ភោ និក្កមោ បរក្កមោ ឧស្សាហោ ឧស្សោឡ្ហី ថាមោ ឋិតិ អសិថិលបរក្កមោ អនិក្ខិត្តច្ឆន្ទតា អនិក្ខិត្តធុរតា ធុរសម្បគ្គាហោ វីរិយំ វីរិយិន្ទ្រិយំ វីរិយពលំ សម្មាវាយាមោ ។ សោ បច្ចេកសម្ពុទ្ធោ ឥមិនា បធានេន ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា សោ បច្ចេកសម្ពុទ្ធោ បធានវាតិ សង្ខាតធម្មោ និយតោ បធានវា ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ភពនេះ ជាខាងក្រោយ រាងកាយនេះ ជាខាងក្រោយ

របស់បុគ្គលណា ការអន្ទោលទៅកាន់ជាតិ ជរ មរណៈ

គឺភពថ្មី របស់បុគ្គលនោះ មិនមានឡើយ

ហេតុនោះ (លោកពោលថា) មានធម៌ពិចារណាហើយ ។ ពាក្យថា ជាអ្នកទៀងទាត់ សេចក្តីថា អរិយមគ្គ ៤ ហៅថា ការទៀងទាត់ ។ បុគ្គលប្រកបដោយអរិយមគ្គ ៤ ឈ្មោះថាជាអ្នកទៀងទាត់ គឺជាអ្នកដល់ ដល់ព្រមពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់ នូវការទៀងទាត់ ដោយអរិយមគ្គទាំង-ឡាយ ហេតុនោះ (លោកពោលថា) ជាអ្នកទៀងទាត់ ។ ពាក្យថា មានព្យាយាម សេចក្តីថា សេចក្តីប្រឹងប្រែង ហៅថា សេចក្តីព្យាយាម បានដល់ ការប្រារព្ធព្យាយាមនៃចិត្ត ការប្រឹងប្រែង ការខ្នះខ្នែង ការឧស្សាហ៍ ការខ្នីឃ្នាត ការសង្វាត ការសង្វាតមាំ ការមិនបន្ធូរបន្ថយ ព្យាយាម ការមិនដាក់បំណង ការមិនទម្ងាក់ធុរៈ ការផ្គងនូវធុរៈ វីរិយៈ វីរិយិន្ទ្រិយ វីរិយពលៈ សម្មាវាយាមៈ ។ ព្រះបច្ចេកសម្ពុទ្ធនោះ ដល់ដល់ព្រម មកជិត មកជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបដោយសេចក្តីព្យាយាមនេះ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាមានព្យាយាម ហេតុនោះ (លោកពោលថា) មានធម៌ពិចារណាហើយ ជាអ្នកទៀងទាត់ មានព្យាយាម ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

តេនាហ សោ បច្ចេកសម្ពុទ្ធោ
តណ្ហាក្ខយំ បត្ថយំ អប្បមត្តោ
អនេឡមូគោ សុតវា សតិមា
សង្ខាតធម្មោ និយតោ បធានវា
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[៣៧១] សីហោវ សទ្ទេសុ អសន្តសន្តោ
វាតោវ ជាលម្ហិ អសជ្ជមានោ
បទុមំវ តោយេន អលិម្បមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[៣៧២] សីហោវ សទ្ទេសុ អសន្តសន្តោតិ យថា សីហោ មិគរាជា សទ្ទេសុ អសន្តាសី អបរិសន្តាសី អនុត្រាសី អនុព្វិគ្គោ អនុស្សុកី[(១)] អនុត្រាសោ អភិរុ អច្ឆម្ភី អនុត្រាសី អបលាយី បច្ចេកសម្ពុទ្ធោបិ សទ្ទេសុ អសន្តាសី អបរិសន្តាសី អនុត្រាសី អនុព្វិគ្គោ អនុស្សុកី អនុត្រាសោ អភិរុ អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោ វិហរតីតិ សីហោវ សទ្ទេសុ អសន្តសន្តោ ។

១ ម. អនុស្សង្កី ។

ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលប្រាជ្ញា នូវការអស់តណ្ហា ជាអ្នកមិនប្រហែស
មិនលូងខ្ជៅ ជាអ្នកចេះដឹង មានស្មារតី មានធម៌
ពិចារណាហើយ ជាអ្នកទៀងទាត់ មានព្យាយាម
គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣៧១] បុគ្គលអ្នកមិនតក់ស្ទុត ព្រោះសំឡេងទាំងឡាយ
ដូចសីហៈ មិនជាប់ក្នុងជាលដូចខ្យល់ មិនទទឹកដោយ
ទឹកដូចឈូក គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣៧២] ពាក្យថា បុគ្គលមិនតក់ស្ទុត ព្រោះសំឡេងទាំងឡាយដូចសីហៈ អធិប្បាយថា សីហៈជាស្តេចម្រឹគ មិនតក់ស្ទុត មិនរន្ធត់ មិនញាប់ញ័រ មិនភ្ញាក់ផ្អើល មិនព្រឺព្រួច មិនរំកើប មិនខ្ជាច មិនកិតកំ្យ មិនស្ងប់ស្ងែ មិនរត់ ព្រោះសំឡេងទាំងឡាយ យ៉ាងណាមិញ ឯព្រះបច្ចេកសម្ពុទ្ធក៏មិនតក់ស្ទុត មិនរន្ធត់ មិនញាប់ញ័រ មិនភ្ញាក់ផ្អើល មិនព្រឺព្រួច មិនរំកើប មិនខ្ជាច មិនកិតកំ្យ មិនស្ងប់ស្ងែ មិនរត់ លះកំ្យគួរខ្ជាច មិនព្រឺរោម ព្រោះសំឡេងទាំងឡាយ ក៏យ៉ាងនោះដែរ ហេតុនោះ (លោកពោលថា) បុគ្គលមិនតក់ស្ទុត ព្រោះសំឡេងទាំងឡាយ ដូចសីហៈ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

[៣៧៣] ភាគោ ជាលម្ហិ អសជ្ជមានោតិ ភ-
គោតិ បុរត្ថិមា ភាគា បច្ឆិមា ភាគា ឧត្តរ ភាគា
ទក្ខិណា ភាគា សរជា ភាគា សីតា ភាគា ឧណ្ហា
ភាគា បរិត្តា ភាគា អធិមត្តា ភាគា កាលភាគា វេរម្ភ-
ភាគា បក្ខិភាគា សុបណ្ណភាគា តាលបណ្ណភាគា រិច្ចូប-
ជភាគា ។ ជាលំ រុច្ចតិ សុត្តជាលំ ។ យថា ភាគោ
ជាលម្ហិ ន សជ្ជតិ ន ឧយ្ហតិ ន ពជ្ឈតិ ន
បលិពជ្ឈតិ ឯវមេវ ទ្វេ ជាលា តណ្ហាជាលញ្ច
ទិដ្ឋិជាលញ្ច ។ បេ ។ ឥទំ តណ្ហាជាលំ ។ បេ ។
ឥទំ ទិដ្ឋិជាលំ ឥស្ស បចេ្ចកសម្ពុទ្ធស្ស តណ្ហាជាលំ
បហីនំ ទិដ្ឋិជាលំ បដិនិស្សដ្ឋំ តណ្ហាជាលស្ស
បហីនត្តា ទិដ្ឋិជាលស្ស បដិនិស្សដ្ឋត្តា សោ បចេ្ចក-
សម្ពុទ្ធោ ។ បេ ។ ន សជ្ជតិ ន ឧយ្ហតិ ។ បេ ។
ទិដ្ឋសុតមុតវិញ្ញាតេ ធម្មេ ន សជ្ជតិ ន ឧ-
យ្ហតិ ន ពជ្ឈតិ ន បលិពជ្ឈតិ និក្ខន្តោ និស្សដ្ឋោ
វិប្ប មុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា
វិហរតីតិ ភាគោ ជាលម្ហិ អសជ្ជមានោ ។

ខគ្គវិសាណសុត្តនិទ្ទេស

[៣៧៣] អធិប្បាយពាក្យថា មិនជាប់ក្នុងជាលដូចខ្យល់ ត្រង់ពាក្យថា ខ្យល់ បានដល់ ខ្យល់ខាងកើត ខ្យល់ខាងលិច ខ្យល់ខាងជើង ខ្យល់ខាងត្បូង ខ្យល់មានធូលី ខ្យល់ត្រជាក់ ខ្យល់ក្តៅ ខ្យល់តិច ខ្យល់ច្រើន ខ្យល់កើតតាមកាល ខ្យល់ព្យុះ ខ្យល់ស្វាបសត្វ ខ្យល់ត្រុឌ ខ្យល់ផ្ទិតស្ទឹកស្នោត ខ្យល់កើតអំពីការបក់ ។ បណ្តាញ ធ្លើអំពីអំបោះ ហៅថា ជាល ។ ខ្យល់មិនជាប់ បុគ្គលចាប់មិនបាន មិនទើសទាក់ មិនជាប់ចំពាក់ ក្នុងជាល យ៉ាងណាមិញ ជាលមាន ២ យ៉ាង គឺ ជាលគឺតណ្ហា ១ ជាលគឺទិដ្ឋិ ១ ។ បេ ។ នេះជាលគឺតណ្ហា ។ បេ ។ នេះជាលគឺទិដ្ឋិ ព្រះបច្ចេកសម្ពុទ្ធនោះ លះចោលនូវជាលគឺតណ្ហា រលាស់ចោលនូវជាលគឺទិដ្ឋិ ព្រោះតែលះចោលនូវជាលគឺតណ្ហា ព្រោះតែរលាស់ចោលនូវជាលគឺទិដ្ឋិ ព្រះបច្ចេកសម្ពុទ្ធនោះ ទើបមិនជាប់ក្នុងរូប មិនជាប់ក្នុងសំឡេង ។ បេ ។ មិនជាប់ មិនកាន់យក មិនទើសទាក់ មិនជាប់ចំពាក់ក្នុងធម្មារម្មណ៍ ដែលឃើញ ឮ ប៉ះពាល់ឬដឹង គឺលោកងាកចេញ ដោះចេញ រួចស្រឡះ មិនប្រកប មានចិត្តមិនសល់រ៉ាល់ ក៏យ៉ាងនោះឯង ហេតុនោះ (លោកពោលថា) មិនជាប់ក្នុងជាល ដូចខ្យល់ ។

[៣៧៤] បឋមំ តោយេន អលិម្ឆមានោតិ បឋមំ រុច្ចតិ បឋមបុប្ផំ ។ តោយំ រុច្ចតិ ឧទកំ ។ យថា បឋមបុប្ផំ តោយេន ន លិម្ឆិយតិ អលិត្តំ អនុបលិត្តំ ឯវមេវ ទ្វេ លេចា តណ្ហាលេចោ ច ទិដ្ឋិលេចោ ច ។ បេ ។ អយំ តណ្ហាលេចោ ។ បេ ។ អយំ ទិដ្ឋិលេចោ តស្ស បចេ្ចកសម្ពុទ្ធស្ស តណ្ហា-លេចោ បហីនោ ទិដ្ឋិលេចោ បដិនិស្សដ្ឋោ តណ្ហា-លេបស្ស បហីនត្តា ទិដ្ឋិលេបស្ស បដិនិស្សដ្ឋត្តា សោ បចេ្ចកសម្ពុទ្ធោ រូបេ ន លិម្ឆតិ សទ្ទេ ន លិម្ឆតិ ។ បេ ។ ទិដ្ឋសុតមុតវិញ្ញាតព្ពេសុ ធម្មេសុ ន លិម្ឆតិ ឧបលិម្ឆតិ អលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្ឆមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ បឋមំ តោយេន អលិម្ឆមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្ប ។ តេនាហ សោ បចេ្ចកសម្ពុទ្ធោ

[៣៧២] ពាក្យថា មិនទទឹកដោយទឹក ដូចឈូក អធិប្បាយថា ផ្កាឈូក ហៅថា ឈូក ។ ឧទក: ហៅថា ទឹក ។ ផ្កាឈូកមិនជាប់ មិនប្រឡាក់ មិនជិតជាមដោយទឹក យ៉ាងណាមិញ គ្រឿងប្រឡាក់ ពីរយ៉ាង គឺ គ្រឿងប្រឡាក់ គឺតណ្ហា ១ គ្រឿងប្រឡាក់ គឺទិដ្ឋិ ១ ។ បេ ។ នេះគ្រឿងប្រឡាក់ គឺតណ្ហា ។ បេ ។ នេះគ្រឿងប្រឡាក់ គឺទិដ្ឋិ ព្រះបច្ចេកសម្ពុទ្ធនោះ លះបង់នូវគ្រឿងប្រឡាក់ គឺតណ្ហា រលាស់ចោលនូវគ្រឿងប្រឡាក់គឺទិដ្ឋិ ព្រោះតែលះបង់នូវគ្រឿងប្រឡាក់ គឺតណ្ហា ព្រោះតែរលាស់ចោល នូវគ្រឿងប្រឡាក់គឺទិដ្ឋិ ព្រះបច្ចេកសម្ពុទ្ធនោះ ទើបមិនប្រឡាក់ក្នុងរូប មិនប្រឡាក់ក្នុងសំឡេង ។ បេ ។ មិនជាប់ មិនជាប់ស្អិតក្នុងធម្មារម្មណ៍ដែលឃើញ ឮ ប៉ះពាល់ឬដឹង គឺថាលោកមិនប្រឡាក់ មិនជិតជាម ងាកចេញ ដោះចេញ រួចស្រឡះ មិនប្រកប មានចិត្តមិនសល់ រ៉ាល់ ក៏យ៉ាងនោះដែរ ហេតុនោះ (លោកពោលថា) មិនទទឹកដោយទឹក ដូចឈូក ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

ខគ្គវិសាណសុត្តនិទ្ទេសោ

សីហោវ សទ្ទេសុ អសន្តសន្តោ
ភ្ជតោវ ជាលម្ហិ អសជ្ជមានោ
បទុមំវ តោយេន អលិម្ប្យមានោ
ឯកោ ចរ ខ្គវិសាណកប្បោតិ ។

[៣៧៤] សីហោ យថា ទាឋពលី បសយ្ហ
ភជ្ជ មិគានំ អភិកុយ្យ ចារី
សេវេថ បន្តានិ សេនាសនានិ
ឯកោ ចរ ខ្គវិសាណកប្បោ ។

[៣៧៦] សីហោ យថា ទាឋពលី បសយ្ហ ភជ្ជ មិគានំ អភិកុយ្យ ចារីតិ យថា សីហោ មិគរាជា ទាឋពលី ទាឋាវុធោ សព្ពេ តិរច្ឆានគតេ ចាណេ អភិកុយ្យ អភិភវិត្វា អជ្ឈោត្ថរិត្វា បរិយាទិយិត្វា មទ្ទិត្វា ចរតិ វិចរតិ ឥរិយតិ វត្តេតិ ចាលេតិ យបេ-តិ យាបេតិ ឯវមេវ បច្ចេកសម្ពុទ្ធោបិ បញ្ញាពលី

ខគ្គវិសាណសុត្តនិទ្ទេស

បុគ្គលមិនតក់ស្ទុត ព្រោះសំឡេងទាំងឡាយ ដូចសីហៈ មិនជាប់ក្នុងជាល ដូចខ្យល់ មិនទទឹកដោយទឹក ដូចឈូក គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣៧៥] *សីហៈជាស្តេចម្រឹគ មានចង្កូមជាកម្ទាំង ប្រព្រឹត្តគ្របសង្កត់ កំហែង នូវសត្វទាំងឡាយ យ៉ាងណា បុគ្គលសេពសេនាសនៈ ដ៏ស្ងាត់ ក៏យ៉ាងនោះ គប្បីប្រព្រឹត្តទៅម្នាក់ឯង ដូចកុយរមាស ។*

[៣៧៦] *ពាក្យថា សីហៈជាស្តេចម្រឹគ មានចង្កូមជាកម្ទាំង ប្រព្រឹត្តគ្របសង្កត់ កំហែង យ៉ាងណា អធិប្បាយថា សីហៈជាស្តេចម្រឹគ មានចង្កូមជាកម្ទាំង មានចង្កូមជាអាវុធ គម្រាម កំហែង គ្របសង្កត់ កាច់កិនញ៉ាំញ៉ី នូវសត្វតិរច្ឆានទាំងពួង ចរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ យ៉ាងណាមិញ ឯព្រះបច្ចេកសម្ពុទ្ធ មានបញ្ញាជាកម្ទាំង*

បញ្ញាវុធោ សព្វប្បាណភូតេ បញ្ញាយ អភិភុយ្យ អភិភវិត្វា អជ្ឈោត្ថរិត្វា បរិយាទិយិត្វា មទ្ទិត្វា ចរតិ វិចរតិ ឥរិយតិ វត្តេតិ បាលេតិ យបេតិ យាបេតីតិ សីហោ យថា នាទពលី បសយ្ហ រាជា មិគានំ អភិភុយ្យចារី ។

[៣៧៧] សេវេថ បន្តានិ សេនាសនានីតិ យថា សីហោ មិគរាជា អរញ្ញវនបត្ថានិ អជ្ឈោ-គាហេត្វា ចរតិ វិចរតិ ឥរិយតិ វត្តេតិ បាលេតិ យបេតិ យាបេតិ ឯវមេវ បច្ចេកសម្ពុទ្ធោបិ អរញ្ញ-វនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ អប្ប-សទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហ-សេយ្យកានិ បដិសល្លានសារុប្បានិ ។ សោ ឯកោ គច្ឆតិ ឯកោ តិដ្ឋតិ ឯកោ និសីទតិ ឯកោ សេយ្យំ កប្បេតិ ឯកោ គាមំ បិណ្ឌាយ បវិសតិ ឯកោ បដិក្កមតិ ឯកោ រហោ និសីទតិ

មានបញ្ញាជាអាវុធ គម្រាម កំហែង គ្របសង្កត់ កាច់កិន ញ៉ាំញ៉ី នូវ សត្វទាំងពួងដោយបញ្ញា ហើយចរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ក៏យ៉ាងនោះដែរ ហេតុនោះ (លោកពោលថា) សីហ: ជាស្តេចម្រឹគ មានចង្ហូមជាកម្ទាំង ប្រព្រឹត្តគ្របសង្កត់ កំហែង យ៉ាង ណា ។

[៣៧៧] ពាក្យថា សេពនូវសេនាសន:ដ៏ស្ងាត់ អធិប្បាយថា សីហ:ជាស្តេចម្រឹគ ចូលកាន់ព្រៃតូចព្រៃធំ ហើយចរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ក៏សេពព្រៃ តូចព្រៃធំ ជាសេនាសន:ដ៏ស្ងាត់ មិនមានសំឡេង មិនមានសូរគឹកកង ប្រាសចាកខ្យល់ដែលកើតអំពីសរីរ:របស់ជន ជាទីស្ងាត់របស់មនុស្ស គួរ ដល់ការពួនសម្ងំ យ៉ាងនោះដែរ ។ ព្រះបច្ចេកសម្ពុទ្ធនោះ ដើរម្នាក់ឯង ឈរម្នាក់ឯង អង្គុយម្នាក់ឯង សិងម្នាក់ឯង ចូលទៅកាន់ស្រុក ដើម្បី បិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង គង់នៅក្នុងទីស្ងាត់ម្នាក់ឯង

ឯកោ ចង្កមំ អធិដ្ឋាតិ ឯកោ ចរតិ វិចរតិ ឥរិយតិ វត្តេតិ ចាលេតិ យបេតិ យាបេតីតិ សេវេថ បន្តានិ សេនាសនានិ ។ ឯកោ ចរេ ខគ្គវិសា-ណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

សីហោ យថា ទាឋពលី បសយ្ហ
រាជា មិគានំ អភិភុយ្យចារី
សេវេថ បន្តានិ សេនាសនានិ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[៣៧៨] មេត្តំ ឧបេក្ខំ ករុណំ វិមុត្តឺ
អាសេវមានោ មុទិតញ្ច កាលេ
សព្វេន លោកេន អវិរុជ្ឈមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[៣៧៩] មេត្តំ ឧបេក្ខំ ករុណំ វិមុត្តឺ អាសេវ-មានោ មុទិតញ្ច កាលេតិ សោ បច្ចេកសម្ពុទ្ធោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហ-រតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ

អធិដ្ឋានចង្ក្រមម្នាក់ឯង ចរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ម្នាក់ឯង ហេតុនោះ (លោកពោលថា) សេពនូវ សេនាសនៈដ៏ស្ងាត់ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុ នោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

សីហៈជាស្តេចម្រឹគ មានចង្កូមជាកម្ទាំង ប្រព្រឹត្តគ្រប
សង្កត់ កំហែង នូវសត្វទាំងឡាយ យ៉ាងណា បុគ្គល
សេពសេនាសនៈដ៏ស្ងាត់ ក៏យ៉ាងនោះ គប្បីប្រព្រឹត្ត
ម្នាក់ឯង ដូចកុយរមាស ។

[៣៧៨] បុគ្គលកាលសេពនូវវិមុត្តិ គឺ មេត្តា ឧបេក្ខា
ករុណានិងមុទិតាក្នុងកាលគួរ តែងត្រូវសត្វលោកទាំង
ពួងមិនស្អប់ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣៧៨]ពាក្យថា កាលសេពនូវវិមុត្តិ គឺមេត្តា ឧបេក្ខា ករុណានិងមុទិតា ក្នុងកាលគួរ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ដូចគ្នា ទិសទី ៣ ដូចគ្នា ទិសទី ៤ ដូចគ្នា

ឧទ្ធមជោ តិរិយំ សព្ពជិ សព្ពត្តតាយ សញ្ជាវន្តំ លោ-
កំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្ត-
តេន អប្ប្រមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា
វិហរតិ ការុណ្ណាសហគតេន ចេតសា មុទិតាសហ-
គតេន ចេតសា ឧបេក្ខាសហគតេន ចេតសា
ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិ-
យំ តថា ចតុត្ថំ ឥតិ ឧទ្ធមជោ តិរិយំ សព្ពជិ
សព្ពត្តតាយ សញ្ជាវន្តំ លោកំ ឧបេក្ខាសហគតេន
ចេតសា វិបុលេន មហគ្ត្តេន អប្ប្រមាណេន អវេ-
រេន អព្យាបជ្ជេន ផរិត្វា វិហរតីតិ មេត្តំ ឧបេក្ខំ
ការុណ្ណំ វិមុត្តឺ អាសេវមានោ មុទិតញ្ច ការាលេ ។

[៣៨០] សព្ជេន លោកេន អវិរុជ្ឈមានោតិ
មេត្តាជីនំ ភាវិតត្តា យេ បុរត្ថិមាយ ទិសាយ
សត្តា តេ អប្ជជិកុលា ហោន្ដិ យេ បច្ជិមាយ
ទិសាយ សត្តា យេ ឧត្ត្ជាយ ទិសាយ សត្តា

មានចិត្តប្រកបដោយមេត្តា ដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងមូល ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួងក្នុងទីទាំងពួង ដោយប្រការដូច្នេះ មានចិត្តប្រកបដោយករុណា មានចិត្តប្រកបដោយមុទិតា មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ដូចគ្នា ទិសទី ៣ ដូចគ្នា ទិសទី ៤ ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខា ដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងមូល ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួងក្នុងទីទាំងពួង ដោយប្រការដូច្នេះ ហេតុនោះ (លោកពោលថា) កាលសេពនូវវិមុត្តិ គឺមេត្តា ឧបេក្ខា ករុណានិងមុទិតា ក្នុងកាលគួរ ។

[៣៨០] *ពាក្យថា តែងត្រូវសត្វលោកទាំងពួងមិនស្អប់ អធិប្បាយថា ព្រោះព្រះបច្ចេកសម្ពុទ្ធនោះ ចម្រើនហើយនូវព្រហ្មវិហារ មានមេត្តាជាដើម ពួកសត្វណាក្នុងទិសខាងកើត ពួកសត្វទាំងនោះ រមែងមិនស្អប់ ពួកសត្វណា ក្នុងទិសខាងលិច ពួកសត្វណា ក្នុងទិសខាងជើង*

ខគ្គវិសាណសុត្តនិទ្ទេសោ

យេ ទក្ខិណាយ ទិសាយ សត្តា យេ បុរត្ថិមាយ អនុទិសាយ សត្តា យេ បច្ឆិមាយ អនុទិសាយ សត្តា យេ ឧត្តរាយ អនុទិសាយ សត្តា យេ ទក្ខិណាយ អនុទិសាយ សត្តា យេ អធោគមាយ ទិសាយ សត្តា យេ ឧបរិមាយ ទិសាយ សត្តា យេ ទសសុ ទិសាសុ វិទិសាសុ សត្តា តេ អប្បដិ-កូលា ហោន្តិ ។ សព្វេន លោកេន អវិរុជ្ឈមានោ-តិ សព្វេន សត្តលោកេន អវិរុជ្ឈមានោ អប្បដិវិរុ-ជ្ឈមានោ អឃដ្ដិយមានោ អប្បដិហញ្ញមានោតិ សព្វេន លោកេន អវិរុជ្ឈមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

មេត្តំ ឧបេក្ខំ ករុណំ វិមុត្តឹ
អាសេវមានោ មុទិតញ្ច កាលេ
សព្វេន លោកេន អវិរុជ្ឈមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

ខគ្គវិសាណសុត្តនិទ្ទេស

ពួកសត្វណា ក្នុងទិសខាងត្បូង ពួកសត្វណា ក្នុងទិសអាគ្នេយ៍ ពួកសត្វណា ក្នុងទិសពាយ័ព្យ ពួកសត្វណា ក្នុងទិសឦសាន ពួកសត្វណា ក្នុងទិសនិរតី ពួកសត្វណា ក្នុងទិសខាងក្រោម ពួកសត្វណា ក្នុងទិសខាងលើ ពួកសត្វណា ក្នុងទិសតូចទិសធំទាំង ១០ ពួកសត្វទាំងនោះ រមែងមិនស្អប់ ។ ពាក្យថា តែងត្រូវសត្វលោកទាំងពួងមិនស្អប់ បានសេចក្តីថា សត្វលោកទាំងពួងមិនទោមនស្ស មិនអាក់អន់ មិនថ្នាំងថ្នាក់ មិនខ្ជាំងខ្ជប់ ហេតុនោះ (លោកពោលថា) តែងត្រូវសត្វលោកទាំងពួងមិនស្អប់ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

> បុគ្គលកាលសេពនូវវិមុត្តិ គឺ មេត្តា ឧបេក្ខា ករុណា និងមុទិតា ក្នុងកាលគួរ តែងត្រូវសត្វលោកទាំងពួងមិនស្អប់ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣៨១] ភតញ្ច ទោសញ្ច បហាយ មោហំ
សង្ខ្លាលយិត្វាន សញ្ញោជនានិ
អសន្ត្តសំ ជីវិតសង្ខ្ហយម្ហិ
ឯកោ ចរេ ខ្គវិសាណកប្បោ ។

[៣៨២] ភតញ្ច ទោសញ្ច បហាយ មោហន្តិ ភតន្តិ យោ ភតោ សាភតោ ។ បេ ។ អភិជ្ឌា លោភោ អកុសលមូលំ ។ ទោសន្តិ យោ ចិត្តស្ស អាឃាតោ ។ បេ ។ ចណ្ឌិក្កំ អសុភោចោ អនត្តមនតា ចិត្តស្ស ។ មោហោតិ ទុក្ខេ អញ្ញាណំ ។ បេ ។ អវិជ្ជាលន្តី មោហោ អកុសលមូលំ ។ ភតញ្ច ទោសញ្ច បហាយ មោហន្តិ សោ បច្ចេកសម្ពុទ្ធោ ភតញ្ច ទោសញ្ច មោហញ្ច បហាយ បជហិត្វា វិនោទេត្វា ព្យន្តីកត្វា អនភាវង្គមេត្វាតិ ភតញ្ច ទោសញ្ច បហាយ មោហំ ។

[៣៨១] *បុគ្គលលះរាគៈ ទោសៈ និងមោហៈ ទម្លាយនូវ*

សញ្ញោជនៈទាំងឡាយ មិនតក់ស្ទុត ក្នុងការអស់ជីវិត

គឃ្លីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[៣៨២] *អធិប្បាយពាក្យថា លះរាគៈ ទោសៈ និងមោហៈ ត្រង់ពាក្យថា រាគៈ បានដល់ការត្រេកអរ ការត្រេកអរខ្លាំង ។ បេ ។ អកិណ្ណាលោកៈ អកុសលមូល ។ ពាក្យថា ទោសៈ បានដល់ការគុំកួននៃចិត្ត ។ បេ ។ ចិត្តកាច ការពោលពាក្យមិនពីពោះ ភាពនៃចិត្តមិនត្រេកអរ ។ ពាក្យថា មោហៈ បានដល់ការមិនដឹងទុក្ខ ។ បេ ។ សន្ទុះគឺអវិជ្ជា មោហៈ អកុសលមូល ។ ពាក្យថា លះរាគៈ ទោសៈ និងមោហៈ បានសេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ លះ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវរាគៈ ទោសៈ និងមោហៈ ហេតុនោះ (លោកពោលថា) លះរាគៈ ទោសៈ និងមោហៈ ។*

[៣៨៣] សង្ខាលយិត្វាន សញ្ញោជនានីតិ ទស សញ្ញោជនានិ កាមរាគសញ្ញោជនំ បដិឃសញ្ញោជនំ ។ បេ ។ អវិជ្ជាសញ្ញោជនំ ។ សង្ខាលយិត្វាន សញ្ញោជនានីតិ សញ្ញោជនានិ សង្ខាលយិត្វាន បទាលយិត្វាន សម្បទាលយិត្វាន បជហិត្វាន វិនោទេត្វាន ព្យន្តីករិត្វាន អនភាវង្គមេត្វាជាតិ សង្ខាលយិត្វាន សញ្ញោជនានិ ។

[៣៨៤] អសន្តសំ ជីវិតសង្ខយម្ហីតិ សោ បច្ចេកសម្ពុទ្ធោ ជីវិតបរិយោសានេ អសន្តាសី អបរិសន្តាសី អនុត្រាសី អនុព្វិគ្គោ អនុស្សុកី អនុត្រាសោ អភិរុ អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោតិ អសន្តសំ ជីវិតសង្ខយម្ហិ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

ខគ្គវិសាណសុត្តនិទ្ទេស

[៣៨៣] ពាក្យថា ទម្ងាយនូវសញ្ញោជនៈទាំងឡាយ អធិប្បាយ ថា សញ្ញោជនៈ ១០ យ៉ាង គឺ កាមរាគសញ្ញោជនៈ ១ បដិឃសញ្ញោជនៈ ១ ។ បេ ។ អវិជ្ជាសញ្ញោជនៈ ១ ។ ពាក្យថា ទម្ងាយ នូវសញ្ញោជនៈទាំង-ឡាយ បានសេចក្តីថា ទម្ទុះទម្ងាយ បំបែក បំផ្ងាញ លុះបង់ បន្ទោ-បង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវសញ្ញោជនៈទាំងឡាយ ហេតុនោះ (លោកពោលថា) ទម្ងាយនូវសញ្ញោជនៈទាំងឡាយ ។

[៣៨៤] ពាក្យថា មិនតក់ស្ទុតក្នុងការអស់ជីវិត គឺព្រះបច្ចេកស-ម្ពុទ្ធនោះ មិនតក់ស្ទុត មិនរន្ធត់ មិនញាប់ញ័រ មិនភ្ញាក់ផ្អើល មិនព្រឺ-ព្រួច មិនរំភើប មិនខ្ជាច មិនកិតកល់ យ មិនស្ងប់ស្ងែ ១ មិនរត់ លុះកល់ គួរខ្ជាច មិនព្រឺរោម ក្នុងការអស់ជីវិត ហេតុនោះ (លោកពោលថា) មិនតក់ស្ទុតក្នុងការអស់ជីវិត ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

ភតញ្ច ភោសញ្ច បហាយ មោហំ
សង្ខ្លាលយិត្វាន សញ្ញោជនានិ
អសន្ត្ដសំ ជីវិតសង្ខ្ហយម្ហិ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[៣៨៥] ភជន្ដិ សេវន្ដិ ច ការណត្ថា
និក្ការណា ទុល្ភភា អជ្ជ មិត្ដា
អត្ដត្ដបញ្ញា អសុចី មនុស្ស
ឯកោ ចរេ ខគ្គវិសាណកប្ប ។

[៣៨៦] ភជន្ដិ សេវន្ដិ ច ការណត្ថាតិ អត្ដត្ដការណា បរត្ដការណា ឧភយត្ដការណា ជិជ្ជនម្ហិកត្ដការណា សម្ប្រាយិកត្ដការណា បរម-ត្ដការណា ភជន្ដិ សម្ភជន្ដិ សេវន្ដិ បដិសេវន្ដីតិ ភជន្ដិ សេវន្ដិ ច ការណត្ថា ។

បុគ្គល លះរាគ: ទោស: និងមោហ: ទម្ងាយនូវ សញ្ញោជន:ទាំងឡាយ មិនតក់ស្ទុត ក្នុងការអស់ ជីវិត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[*៣៨៥*] *ជនទាំងឡាយ អ្នកមានការណ៍ជាប្រយោជន៍ ទើបគប់រក ទើបសេពគប់ ឯមិត្តថ្មីទាំងឡាយដែលឥត ត្រូវការណ៍ គេពុំងាយនឹងរកបានទេ ចំណែកមនុស្ស ទាំងឡាយដែលមិនស្អាត ជាអ្នកយល់ប្រយោជន៍របស់ ខ្លួន (ក៏តែងគប់រក តែងសេពគប់ដែរ) បុគ្គលគប្បី ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។*

[*៣៨៦*] *ពាក្យថា ជនទាំងឡាយ អ្នកមានការណ៍ជាប្រយោជន៍ ទើបគប់រក ទើបសេពគប់ សេចក្តីថា ពួកជនមានប្រយោជន៍ខ្លួនជាហេតុ មានប្រយោជន៍ អ្នកដទៃជាហេតុ មានប្រយោជន៍ទាំងពីរជាហេតុ មានប្រយោជន៍ក្នុងបច្ចុប្បន្នជាហេតុ មានប្រយោជន៍ ក្នុងបរលោកជា ហេតុ មានប្រយោជន៍ ក្នុងព្រះនិព្វានជាហេតុ ទើបគប់ សមគប់ សេពគប់ រាប់រក ហេតុនោះ (លោកពោលថា) ជនទាំងឡាយអ្នកមាន ការណ៍ជាប្រយោជន៍ ទើបគប់រក ទើបសេពគប់ ។*

ខគ្គវិសាណសុត្តនិទ្ទេសោ

[៣៨៧] ឯកាការណា ទុល្លភា អជ្ជ មិត្តាតិ ទ្វេ មិត្តា អាការិកមិត្តោ ច អនាការិកមិត្តោ ច ។ បេ ។ អយំ អាការិកមិត្តោ ។ បេ ។ អយំ អនាការិកមិ-ត្តោ ។ ឯកាការណា ទុល្លភា អជ្ជ មិត្តាតិ ឥមេ ទ្វេ មិត្តា អការណា[១] អហេតូ អប្បច្ចយា ទុល្លភាតិ[២] ឯកាការណា ទុល្លភា អជ្ជ មិត្តា ។

[៣៨៨] អត្តត្ថបញ្ញា អសុចី មនុស្សាតិ អត្តត្ថ-បញ្ញាតិ អត្តនោ អត្ថាយ អត្តនោ ហេតុ អត្តនោ បច្ចយា អត្តនោ ការណា ភជន្តិ សម្ភជន្តិ សេវន្តិ និសេវន្តិ សំសេវន្តិ អាចរន្តិ សមាចរន្តិ បយិរុចាសន្តិ បុច្ឆន្តិ បរិបញ្ហន្តីតិ អត្តត្ថប្បញ្ញា ។

---

១ ម. ឯត្ថន្តរេ និក្ការណាតិ ទិស្សតិ ។ ២ ម. ទុល្លភា ទុល្លទ្ធា សុទុល្លទ្ធាតិ ។

ខគ្គវិសាណសុត្តនិទ្ទេស

[៣៨៧] ពាក្យថា មិត្តថ្មីទាំងឡាយដែលឥតត្រូវការណ៍ គេពុំងាយនឹងរកបានទេ អធិប្បាយថា មិត្តមាន ២ ពួកគឺ អាគារិកមិត្ត ១ អនាគារិកមិត្ត ១ ។ បេ ។ នេះ អាគារិកមិត្ត ។ បេ ។ នេះ អនាគារិកមិត្ត ។ ពាក្យថា មិត្តថ្មីទាំងឡាយ ដែលឥតត្រូវការណ៍ គេពុំងាយនឹងរកបានទេ បានសេចក្ដីថា មិត្តទាំងពីរប្រភេទនេះ ដែលមិនមានការណ៍ មិនមានហេតុ មិនមានបច្ច័យ គេរកបានដោយក្រ ហេតុនោះ (លោកពោលថា) មិត្តថ្មីទាំងឡាយ ដែលឥតត្រូវការណ៍ គេពុំងាយនឹងរកបានទេ ។

[៣៨៨] អធិប្បាយពាក្យថា មនុស្សទាំងឡាយដែលមិនស្អាតជាអ្នកយល់ប្រយោជន៍របស់ខ្លួន ត្រង់ពាក្យថា ជាអ្នកយល់ប្រយោជន៍របស់ខ្លួន គឺ ពួកមនុស្សមិនស្អាត តែងគប់រក សមគប់ សេពគប់ រាប់រក អែប នៃប អែបជិត ចូលទៅរក ចូលទៅអង្គុយជិត សាកសួរ ដោះសា ព្រោះតែប្រយោជន៍របស់ខ្លួន ព្រោះតែហេតុរបស់ខ្លួន ព្រោះតែបច្ច័យរបស់ខ្លួន ព្រោះតែការណ៍របស់ខ្លួន ហេតុនោះ (លោកពោលថា) ជាអ្នកយល់ប្រយោជន៍របស់ខ្លួន ។

អសុចី មនុស្ឃាតិ អសុចិនា កាយកម្មេន សម-
ន្ធាកតាតិ អសុចី មនុស្ឃ ។ អសុចិនា វចីកម្មេន
សមន្ធាកតាតិ អសុចី មនុស្ឃ ។ អសុចិនា
មនោកម្មេន សមន្ធាកតាតិ អសុចី មនុស្ឃ ។
អសុចិនា ចាណាតិចាតេន អសុចិនា អទិន្នាទានេន
អសុចិនា កាមេសុ មិច្ឆាចារេន អសុចិនា មុសា-
វាទេន អសុចិយា បិសុណាយ វាចាយ អសុចិយា
ផរុសាយ វាចាយ អសុចិនា សម្ផប្ផលាបេន អសុចិ-
យា អភិជ្ឌាយ អសុចិនា ព្យាបាទេន អសុចិយា
មិច្ឆាទិដ្ឋិយា សមន្ធាកតាតិ អសុចី មនុស្ឃ ។ អសុ-
ចិយា ចេតនាយ សមន្ធាកតាតិ អសុចី មនុស្ឃ ។
អសុចិយា បត្ថនាយ សមន្ធាកតាតិ អសុចី មនុស្ឃ ។

ពាក្យថា មនុស្សមិនស្អាត សេចក្ដីថា ពួកមនុស្សប្រកបដោយកាយ-
កម្មមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ។ ពួកមនុស្សប្រកបដោយ
វចីកម្មមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ។ ពួកមនុស្សប្រកបដោយ
មនោកម្មមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ។ ពួកមនុស្សប្រកប
ដោយការមិនស្អាត គឺបាណាតិបាត ដោយការមិនស្អាត គឺអទិន្នាទាន
ដោយការមិនស្អាត គឺកាមេសុមិច្ឆាចារ ដោយការមិនស្អាត គឺមុសាវាទ
ដោយការមិនស្អាត គឺបិសុណាវាចា ដោយការមិនស្អាត គឺផរុសវាចា
ដោយការមិនស្អាត គឺសម្ផប្បលាបៈ ដោយការមិនស្អាត គឺអភិជ្ឌា
ដោយការមិនស្អាត គឺព្យាបាទ ដោយការមិនស្អាត គឺមិច្ឆាទិដ្ឋិ ឈ្មោះ
ថា មនុស្សមិនស្អាត ។ ពួកមនុស្សប្រកប ដោយចេតនាមិន
ស្អាត ឈ្មោះថា មនុស្សមិនស្អាត ។ ពួកមនុស្សប្រកប ដោយ
សេចក្ដីប្រាថ្នា មិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ។

ខគ្គវិសាណសុត្តនិទ្ទេសោ

អសុចិនា បណ្ឌិនិនា សមន្ទាតតាតិ អសុចី មនុស្ស ហីនា និហីនា បរិហីនា ឋិមកា លាមកា ជតុក្ខា បរិត្តាតិ អត្តត្ថបញ្ញា អសុចី មនុស្ស ។

[៣៨៩] ឯកោ ចរេ ខគ្គវិសាណកប្បោតិ ឯកោតិ ។ បេ ។ ចរេតិ អដ្ឋ ចរិយាយោ ។ បេ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

ភជន្តិ សេវន្តិ ច ការណត្ថា
និក្ការណា ទុល្ភកា អជ្ជ មិត្ត
អត្តត្ថបញ្ញា អសុចី មនុស្ស
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

ខគ្គវិសាណសុត្តនិទ្ទេសោ និដ្ឋិតោ ។

ពួកមនុស្សប្រកបដោយការតាំងសេចក្តីប៉ុនប៉ងមិនស្អាត ឈ្មោះថា មនុស្ស មិនស្អាត ថោកទាប ថោកថយ ទន់ទាប អាក្រក់ លាមក គម្រក់ មនុស្សកម្ទេចកម្ទី ហេតុនោះ (លោកពោលថា) មនុស្សទាំងឡាយ ដែលមិនស្អាត ជាអ្នកយល់ប្រយោជន៍របស់ខ្លួន ។

[៣៨៩] អធិប្បាយពាក្យថា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ត្រង់ពាក្យថា ម្នាក់ឯង ។ បេ ។ ពាក្យថា គប្បីប្រព្រឹត្ត បានដល់ចរិយា ៨ យ៉ាង ។ បេ ។ ហេតុនោះ (លោកពោលថា) គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

ជនទាំងឡាយអ្នកមានការណ៍ជាប្រយោជន៍ ទើបគប់រក
ទើបសេពគប់ ឯមិត្តថ្មីទាំងឡាយដែលឥតត្រូវការណ៍
គេពុំងាយនឹងរកបានទេ ចំណែកមនុស្សទាំងឡាយ
ដែលមិនស្អាត ជាអ្នកយល់ប្រយោជន៍របស់ខ្លួន (ក៏
តែងគប់រក តែងសេពគប់ដែរ) បុគ្គលគប្បីប្រព្រឹត្ត
ម្នាក់ឯង ដូចកុយរមាស ។

ចប់ ខគ្គវិសាណសុត្តនិទ្ទេស ។

អជិតោ តិស្សមេត្តេយ្យោ បុណ្ណកោ អថ មេត្តគូ
ធោតកោ ឧបសីវោ ច នន្ទោ ច អថ ហេមកោ
តោទេយ្យកប្ប ទុកយោ ជតុកណ្ណី ច បណ្ឌិតោ
ភទ្រាវុធោ ឧទយោ ច ចោសាលោ ចាបិ ព្រាហ្មណো
មោឃរាជា ច មេធាវី បិង្គិយោ ច មហាឥសិ
សោឡសន្ទំ បនេតេសំ ព្រាហ្មណានំវ សាសនំ
ចារាយនានំ និទ្ទេសោ តត្ថកា ច ភវន្តិ ហិ
ទ្វេ ក្ខវិសាណសុត្តានំ និទ្ទេសាបិ តត្ថេវ ច
និទ្ទេសោ ទុវិធា ញេយ្យោ បរិបុណ្ណោ សុលិក្ខិតោ ។

សុត្តនិទ្ទេសោ សមត្តោ ។

និទ្ទេសគឺការសម្តែងចេញ នូវពាក្យប្រៀនប្រដៅរបស់ព្រាហ្មណ៍ ជាអ្នកដល់នូវត្រើយ ទាំង ១៦ នាក់នុ៎ះ គឺ អជិត ១ តិស្សមេត្តេយ្យ ១ បុណ្ណកៈ ១ មេត្តគូ ១ ធោតកៈ ១ ឧបសីវៈ ១ នន្ទៈ ១ ហេមកៈ ១ តោ-ទេយ្យៈ ១ កប្បៈ ១ ជតុកណ្ណីបណ្ឌិត ១ ភទ្រាវុធ ១ ឧទយៈ ១ ពោសាលព្រាហ្មណ៍ ១ មោឃរាជមេធាវី ១ បិង្គិយមហាឥសី ១ ផង និទ្ទេសគឺការសម្តែងចេញនូវ ខគ្គវិសាណសូត្រទាំងឡាយ ក្នុងទីនោះផង និទ្ទេសទាំងពីរ មានប្រមាណប៉ុណ្ណោះ បណ្ឌិតគប្បីដឹងថា ជានិទ្ទេសដែលបរិបូណ៌ លោកចារឹកត្រឹមត្រូវហើយ ។

ចប់ សុត្តនិទ្ទេស ។

សុត្តន្តបិដក

ខុទ្ទកនិកាយ ចូឡនិទ្ទេស

ទុតិយភាគ

មាតិកា ទំព័រ

ចូឡនិទ្ទេស *ឧទយមាណវកปัญญานิទ្ទេស ទី ១៣* ១

ពោសាលមាណវកปัญญานิទ្ទេស ទី ១៤ ..... ២៣

មោឃរាជមាណវកปัญญานิទ្ទេស ទី ១៥ ..... ៤៥

បិង្គិយមាណវកปัญญานิទ្ទេស ទី ១៦ ..... ៨៥

សោឡសមាណវកปัญญานิទ្ទេស ១០១

ខគ្គវិសាណសុត្តនិទ្ទេស ១៩១

និទ្ទេស ២ ប្រការ ៣៨៤

រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

គណៈកម្មការពុទ្ធិកវប្ប:ធម៌អត្ថការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅព្រះត្រៃបិដកបាលី និងសេចក្តីប្រែជាភាសាខ្មែរ ដែលជាស្នាដៃ របស់លោកអ្នកប្រាជ្ញជំនាន់មុន គឺអាស្រ័យដោយការមើលឃើញនូវកត្តាចាំបាច់ មួយចំនួនដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្ប:ធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ដោយកុសលផលបុណ្យទាំងអម្បាលមាណ ដែលកើតអំពីធម្មទាននេះ
សូមឲ្យព្រះពុទ្ធសាសនាផ្សាយទៅគ្រប់ទិសទីទូទាំងសកលលោក
សូមឲ្យសព្វសត្វទាំងឡាយទាំងពួងបាននូវសេចក្តីសុខសួស្តី
សូមឲ្យមនុស្សគ្រប់ជាតិសាសន៍មានភាតរភាពនឹងគ្នា
សូមឲ្យពិភពលោកទាំងមូលមានសុខសន្តិភាព ។

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោម:

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org

"Wherever the Buddha's teachings have flourished,

either in cities or countrysides,

people would gain inconceivable benefits.

The land and people would be enveloped in peace.

The sun and moon will shine clear and bright.

Wind and rain would appear accordingly,

and there will be no disasters.

Nations would be prosperous

and there would be no use for soldiers or weapons.

People would abide by morality and accord with laws.

They would be courteous and humble,

and everyone would be content without injustices.

There would be no thefts or violence.

The strong would not dominate the weak

and everyone would get their fair share."

✻THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL✻

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

✻ The Vows of Samantabhadra ✻

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

✻ The Vows of Samantabhadra Avatamsaka Sutra ✻

DEDICATION OF MERIT

May the merit and virtue
accrued from this work
adorn Amitabha Buddha's Pure Land,
repay the four great kindnesses above,
and relieve the suffering of
those on the three paths below.
May those who see or hear of these efforts
generate Bodhi-mind,
spend their lives devoted to the Buddha Dharma,
and finally be reborn together in
the Land of Ultimate Bliss.
Homage to Amita Buddha!

NAMO AMITABHA

南無阿彌陀佛

《柬埔寨巴利文：小部阿含經：小義釋》

財團法人佛陀教育基金會 印贈

台北市杭州南路一段五十五號十一樓

Printed and donated for free distribution by

The Corporate Body of the Buddha Educational Foundation

11F, No. 55, Sec. 1, Hang Chow South Road, Taipei, Taiwan, R.O.C.

Tel: 886-2-23951198 , Fax: 886-2-23913415

Email: overseas@budaedu.org

Website: http://www.budaedu.org

Mobile Web: m.budaedu.org

This book is strictly for free distribution, it is not to be sold.

សម្រាប់ចែកជាធម្មទាន

Printed in Taiwan

200 copies; September 2019

CA088 - 17061